# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

# និង

# បរមត្ថមញ្ជូសាមហាដីកា

# សមាធិនិទ្ទេស

# ភាគទី ៤

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ៨ កើត ខែពិសាខ ព.ស. ២៥៥៤

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ២២៥ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែ[illegible] ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ពិតថេរដីកា**
**ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត**

**<u>កម្មវត្ថុ</u>** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**<u>យោង</u>** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន ។
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

***<u>ចម្លងជូន</u>*** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# បករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ
# និង
# បរមត្ថមញ្ជូសាមហាដីកា
# សមាធិនិទ្ទេស
# ភាគទី ៤

ដឹកនាំបកប្រែដោយ

ខ្ញុំព្រះករុណា

អាត្មាភាព យង់ សុជាត

ថ្ងៃ ៨ កើត ខែពិសាខ ពុទ្ធសករាជ ២៥៥៤

*ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុជាត*

ក

# និទានវចនៈ

**វិសុទ្ធិមគ្គ** ជាបករណ៍វិសេស ដែលព្រះថេរៈ **អ្នកស្រុកជម្ពូទ្វីប** មានឈ្មោះបោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនាកន្លងទៅហើយបានប្រមាណ ១.០០០ ឆ្នាំ **នៅកោះលង្កាទ្វីប** ព្រះថេរៈរូបនេះ គឺព្រះពុទ្ធឃោសៈ ឯលោកក៏បានរចនាគម្ពីរទុកជាច្រើន នៅក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារដ៏ធំ និងជាមរតក រហូតមកដល់សព្វថ្ងៃ ។ ការប្រែ **គម្ពីរព្រះត្រៃបិដក អដ្ឋកថា** ពី **ភាសាសីហឡៈ** មកជា **ភាសាមគធៈ** ឬ **ភាសាបាលី** ព្រះពុទ្ធឃោសៈបានប្រមូលធម៌នៅក្នុងព្រះត្រៃបិដក មកសម្ដែងទុកជាពួកៗ តាំងពី **សីល សមាធិ** និង **បញ្ញា** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬលំដាប់នៃការឆ្លើយសំណួរធម៌ក្នុងបច្ចុប្បន្ន គឺអធិប្បាយសេចក្ដីសង្ខេបឲ្យពិស្ដារ បទសំណួររបស់ **វិសុទ្ធិមគ្គ** ពោលដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំងអស់ គឺជាបេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈ បានអធិប្បាយដោយវិចិត្រពិស្ដារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋានទុកក្នុងទីនោះៗ ទូទៅ នេះសម្ដែងឲ្យដឹងថា លោកមានការបែកធ្លាយក្នុងព្រះត្រៃបិដក អាចលើកយកធម៌ ដែលពោលដោយសីល មករួបរួមទុកក្នុងពួកសីល លើកយកធម៌ដែលទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែលទាក់ទងជាមួយបញ្ញា មករួមទុកជាមួយពួកបញ្ញា ដោយ

១

បែកជានិទ្ទេសៗ រួមទាំងអស់មាន **២៣ និទ្ទេស**, រីឯប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡងដេញដោល, ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡៈ បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើលោកធ្វើបានជាទីពេញចិត្ត នឹងលើក **គម្ពីរអដ្ឋកថាភាសាសីហឡៈ** ឲ្យលោកប្រែជាភាសាមគធៈតទៅ ព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និងល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡៈទាំងពួង, ដូច្នោះ **គម្ពីរវិសុទ្ធិមគ្គនេះ** ជាវិជ្ជានិពន្ធ ដើម្បីសាកល្បងចំណេះដឹងរបស់ព្រះពុទ្ធឃោសៈ ។

ព្រះពុទ្ធឃោសៈ មានដើមកំណើតនៅ **ប្រទេសឥណ្ឌា នាតំបន់ពុទ្ធគយា** បានសិក្សាជំនាញនៅក្នុងព្រះពុទ្ធវចនៈ ទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាដ៏ក្រៃលែង លោកបានធ្វើដំណើរទៅ **លង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ហើយបានរចនាគម្ពីរវិសុទ្ធិមគ្គនៅទីនោះ និងប្រែ **ព្រះបាលីអដ្ឋកថា** ពីភាសាសីហឡៈមកជាភាសាមគធៈ ( ភាសាបាលី ) ។

ព្រះថេរៈ មានឈ្មោះដែលគ្រូទាំងឡាយកាន់យកហើយថា **ពុទ្ធឃោសៈ** ជាអ្នកមានភាពបរិសុទ្ធបរិបូណ៌ ប្រដាប់ដោយសទ្ធា វិជ្ជា និងសេចក្ដីព្យាយាមដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាបុគ្គលរុងរឿងដោយធម៌ ជាហេតុកើតនៃសេចក្ដីល្អ មានសីលាចារៈទៀងត្រង់ និងការឱនលំទោនជាដើម អាចឈោងចុះកាន់ជជៈគឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់បុគ្គលដទៃ ប្រកបដោយការមុតស្រួចនៃបញ្ញា មានចំណេះដឹង មិនទើសទាក់ក្នុងសត្ថុសាសនៈ ដោយបរិយត្តិផ្សេងៗ គឺព្រះ

គ

ត្រៃបិដក ព្រមទាំង **អដ្ឋកថា** ជា **មហាវេយ្យាករណ៍** ប្រកបដោយភាពវិចិត្រនៃពាក្យសម្ដី ទាំងទន់ភ្លន់ទូលំទូលាយ បន្ទំចេញបានស្អាត់ជំនាញ សន្សំឲ្យកើតករណសម្បត្តិ មានវាទៈប្រសើរត្រឹមត្រូវ បុគ្គលងាយយល់បានងាយ ជាមហាកវី ហែហមដោយបដិសម្ភិទាដែលបែកធ្លាយ ជាអលង្ការនៃវង្ស ព្រះថេរៈដែលនៅក្នុងមហាវិហារទាំងឡាយ ដែលជាប្រទីបនៃថេរវង្ស មានការដឹងតាំងមាំល្អហើយ ក្នុង **ឧត្តរិមនុស្សធម្ម** ដែលប្រដាប់ដោយគុណផ្សេងៗ មាន **អភិញ្ញា ៦** ជាដើម ហែហមដោយ **បដិសម្ភិទា** បានរចនាវិសុទ្ធិមគ្គនេះចប់ហើយ ។

វិសុទ្ធិមគ្គនេះ តាំងនៅក្នុងលោក សម្ដែងន័យដល់កុលបុត្រទាំងឡាយដែលស្វែងរកធម៌ ជាគ្រឿងដកចេញនូវលោក ដរាបប៉ុនដែលព្រះនាមថា **ពុទ្ធោ** របស់ព្រះលោកជេដ្ឋៈ ដែលស្វែងរកគុណដ៏ធំ មានព្រះទ័យដ៏បរិសុទ្ធ ជាតាទិបុគ្គលប្រព្រឹត្តទៅក្នុងលោក ។

គម្ពីរវិសុទ្ធិមគ្គនេះបានរចនាដោយ<br>ព្រះពុទ្ធឃោសាចារ្យ

ឃ

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនា

## ព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាឋានាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទា ព្រះពុទ្ធជាម្ចាស់ប្រៀបដូចជាព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាក្លួងរស្មី ទ្រង់កម្ចាត់ងងឹត គឺមោហៈធំអស់ហើយ ទ្រង់ញ៉ាំងពួកវេនេយ្យសត្វ ដែលប្រៀបដូចជាផ្កាឈូកឲ្យដឹងវិសេស ទ្រង់មានព្រះបញ្ញាគុណដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មងរះឡើងក្នុងលោក គួរដល់ការបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោករុងរឿងដោយរស្មី គឺព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃ ដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជះនៃបុណ្យ ចំពោះការថ្វាយវន្ទាព្រះរតនត្រ័យដែលកើតឡើងហើយ ដោយប្រការនោះៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបោរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារនៃបករណ៍វិសេស ឈ្មោះ **វិសុទ្ធិមគ្គ** ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាំងប្រណីត ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោលដើម្បីជាឧបាយក្នុងការសម្រេចភាពបរិសុទ្ធិដែលលោកជា **នាថ** មានព្រះចរិយាបរិសុទ្ធ មានហឫទ័យ

ង

ដែលព្រះករុណាឲ្យឧស្សាហ៍ហើយ លោកបានសម្រេចហើយ សម្ដែងទុកមិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈឯសម្នាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយ មានវិនិច្ឆ័យសេចក្ដីដ៏សុខុម ឲ្យបរិសុទ្ធ និងប្រកបដោយរបៀបរៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គនេះឲ្យបានល្អ ខ្ញុំប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរ ដោយប្រការដូច្នេះចុះ ។

**ព្រះធម្មបាលត្ថេរ** ជាជនជាតិស្រីលង្កា លោកបានសិក្សានៅក្នុងសំណាក់**មហាវិហារ** នាក្រុង **អនុរាធបុរៈ** ក្នុង **លង្កាទ្វីប** បានចូលរួមរចនា **គម្ពីរអដ្ឋកថា** ជាមួយព្រះពុទ្ធឃោសាចារ្យដែរ, លោកបានរចនាអដ្ឋកថា និងមហាដីកា ទើបបានទទួលការលើកសរសើរថាជា **ព្រះអដ្ឋកថាចារ្យ** និង **ព្រះដីកាចារ្យ** នៅ**កោះលង្កាទ្វីប** ក្នុងរវាងពុទ្ធសករាជ ៩៥០-១០០០ ។

គម្ពីរបរមត្ថមញ្ជូសាមហាដីកានេះរចនាដោយ

**ព្រះធម្មបាលត្ថេរ**

ច

# អារម្ភកថា

ការបកប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** និង **បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស ភាគ ៤** ជាភាគបញ្ចប់នេះ យើងខ្ញុំបានរៀបរៀងដោយល្អមកជាខេមរភាសា និងរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លាក្នុងព្រះរតនត្រ័យ និងជាពិសេសដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តភក្តីចំពោះព្រះរតនត្រ័យនោះ **អនុមោទនា** នូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ចំពោះបុណ្យធម្មទាននេះ និងបុណ្យកុសលដទៃៗ ទៀត ដូចជាបុណ្យថ្នាក់ការសម្តែងព្រះធម៌ នៅក្នុងកម្មវិធីបុណ្យផ្សេងៗ ទៅតាម **ខេត្ត ក្រុង** ជាច្រើននៅក្នុងប្រទេសកម្ពុជានេះ ដោយខ្ញុំព្រះករុណា អាត្មាភាពបានសម្តែងព្រះធម៌នៅកន្លែងណាៗ ក៏តែងតែបានទុកដាក់ប្រាក់បូជាព្រះធម៌ នៅកន្លែងនោះវិញ គ្រប់ៗកន្លែង ដោយសរុបប្រាក់នៅក្នុង **ព.ស. ២៥៥០** ប្រាក់ខ្មែរបាន **១៨.៤៩៥០០០ រៀល ( ១៨ លាន ៤ សែន ៩ ម៉ឺន ៥ ពាន់រៀល )** និងប្រាក់ដុល្លារ **៦៤៥ ដុល្លារសហរដ្ឋអាមេរិក** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា** ដែលមានពុទ្ធបរិស័ទទៅ **ប្រមាណ ៦៥ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ១០** ព្រះអង្គផងដែរ ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុង

៦

ការដឹកនាំគណៈធម្មយាត្រានោះ ដោយទៅថ្វាយបង្គំបាន ៥១ កន្លែង បានការឧបត្ថម្ភមកអំពីឧបាសក ឡាយ សុខុម និងឧបាសិកា ឱម លក្ខណា នៅក្នុង ព.ស. ២៥៥០ ( ១០.០២.២០០៧ ) ។

## នឹកឃើញស្រុកព្រះ

នឹកឃើញស្រុកព្រះ បានក្រាបសំពះ អង្គព្រះសាស្តា
សិរសាលំទោន ទុកដូចឈូកផ្កា បូជាសាស្តា
ជ្រះថ្លាក្រៃលែង ។
៦៥ អង្គា គាល់ព្រះកគវា ៥១ កន្លែង
នៅស្រុកឥណ្ឌា ចងចាំមិនលែង សោមនស្សពន់ពេក
ក្នុង ព.ស. ២៥៥០ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥១ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥០ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥១ ប្រាក់ខ្មែរបាន ១៥.៨៣១០០០ រៀល ( ១៥ លាន ៨ សែន ៣ ម៉ឺន ១ ពាន់ រៀល ) និងប្រាក់ដុល្លារ ៤៥ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺ បុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង ប្រទេសស្រីលង្កា ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ

ជ

១២១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៤ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ១៩ កន្លែង បានការជួយជ្រោមជ្រែងឧបត្ថម្ភអំពីឧបាសក ឡាយ សុខុម និងឧបាសក សោម រតនៈ ឧបាសិកា ស៊ុប វណ្ណា នៅក្នុង ព.ស. ២៥៥១ ( ០៤.០៤.២០០៨ ) ។

## ទឹកឃើញលង្កា

| | | |
|---|---|---|
| ទឹកឃើញលង្កា | ទឹកឃើញកាលណា | ជ្រះថ្លាក្រៃលែង |
| នៅពុទ្ធស្ថាន | ១៩ កន្លែង | ដែលខ្ញុំបានស្វែង |
| | ទៅថ្វាយបង្គំ ។ | |
| ១២១ អង្គា | គាល់ព្រះបាទា | នាស្ថានមនោរម |
| លើសុមនកូដ | ជេស្ថាឧត្ដម | ជាកំពូលភ្នំ |
| | ក្នុងប្រវត្តិពុទ្ធ ។ | |
| ទឹកដីលង្កា | ទឹកដីអស្ចារ្យ | ពេញពោរដោយឫទ្ធិ |
| ទឹកឃើញកាលណា | ជ្រះថ្លាក្រៃពិត | ធម្មយាត្រាប្រណីត |
| | ក្នុង ព.ស. ២៥៥១ ។ | |

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥២ ផ្នែកខាងសម្ដែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥១ ផងដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥២ ប្រាក់ខ្មែរបាន ២៧.១២៨០០០ រៀល ( ២៧ លាន ១ សែន ២ ម៉ឺន ៨ ពាន់

ឈ

រៀល ) និងប្រាក់ដុល្លារ **១៩៥** ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានា នៅក្នុង **ប្រទេសឥណ្ឌាជាលើកទីពីរ** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** មានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **អឿ សៅ** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៦៧** នាក់ ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥** ព្រះអង្គផងដែរ បានការឧបត្ថម្ភមក អំពីឧបាសក **ឃីត សុណាត** ឧបាសិកា **ហ៊ុន ម៉ារ៉ានី** M.SUSOKUNORAetMmeINN VISAL + NARITA et RAKSA. ក្រោមការជ្រោមជ្រែងរបស់ឧបាសិកា **អ៊ីង រិទ្ធារី** ឧបាសិកា **ស្ងួន កល្យាណ** ឧបាសិកា **ស្ងួន ចរណៃ** នៅក្នុង ព.ស. ២៥៥២ ( ១៦.០២.២០០៩ ) ។

## ជ្រះថ្លាខ្លាំងណាស់

ជ្រះថ្លាខ្លាំងណាស់ ព្រះពុទ្ធជាម្ចាស់ គុណធំក្រៃលែង
ច្រើនពុទ្ធសកករាជ សាសនាអង្វែង ល្អហួសការថ្លែង
ឱ ! ព្រះសាសនា ។
នៅស្រុកឥណ្ឌា ៦៧ អង្គា រួមគ្នានមស្ការ
១០៩ ពុទ្ធស្ថាន ព្រមចិត្តផ្គងថ្វា បីតិអស្ចារ្យ
ក្នុង ព.ស. ២៥៥២ ។

ញ

នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង **ប្រទេសស្រីលង្កាជាលើកទី ២** ដែលមានលោកគ្រូធម្មបណ្ឌិត **រស់ សុផាត** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **៣៦ នាក់** នៅក្នុងនោះទៀត ក៏មាន **ព្រះសង្ឃ ៣** ព្រះអង្គផងដែរ បានការឧបត្ថម្ភមកអំពីឧបាសក **ឆាយ អ៊ីវស៊ាង** ឧបាសិកា **ហុង គីមសែ** ក្រោមការជ្រោមជ្រែងរបស់ឧបាសក **យន្ត សួន** នៅក្នុង ព.ស. **២៥៥២** ( ១១.០៣.២០០៩ ) ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. **២៥៥៣** ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. **២៥៥២** ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. **២៥៥៣** ប្រាក់ខ្មែរបាន ១៣.០៨០០០០ រៀល ( **១៣** លាន ០ សែន ៨ ម៉ឺន ) និងប្រាក់ដុល្លារ **២០៨** ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌាជាលើកទី ៣** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ **១១១ នាក់** ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៦** ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន **៩៦ កន្លែង** បានការជ្រោមជ្រែងអំពីឧបាសក **ឡាយ សុខុម** នៅក្នុង ព.ស. **២៥៥៣** ( ២៥.០១.២០១០ ) ។

ជ

# ស្រណោះស្រុកព្រះ

ស្រណោះស្រុកព្រះ ជាប់តែល្អល្អះ ឥឡូវអនិច្ចា !
យើងខ្ញុំទាំងឡាយ បានទៅនមស្ការ ស្ងប់ស្ងៀមអស្ចារ្យ
ឱះ ឱ ! ពុទ្ធស្ថាន ។
នឹកឃើញកាលណា ចិត្តខ្ញុំជ្រះថ្លា គ្មានអ្វីប្រៀបបាន
១១១ អង្គ ៩៦ ពុទ្ធស្ថាន ព.ស.រាប់បាន
២៥៥៣ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៤ ផ្នែកខាងសម្តែងព្រះធម៌ ដូចគ្នានឹង ព.ស. ២៥៥៣ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៤ ប្រាក់ខ្មែរបាន ៣១.៩៩០០០០ រៀល ( ៣១ លាន ៩ សែន ៩ ម៉ឺន ) និងប្រាក់ដុល្លារ ៧២០ ដុល្លារ ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសលដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង ប្រទេសឥណ្ឌាជាលើកទី ៤ ដែលមានលោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ជាប្រធានក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ១១១ នាក់ ក្នុងនោះ ក៏មាន ព្រះសង្ឃ ៥ ព្រះអង្គផងដែរ ដោយទៅថ្វាយបង្គំបាន ៩៦ កន្លែង បានការជ្រោមជ្រែងមកពីឧបាសក ឡាយ សុខុម នៅក្នុង ព.ស. ២៥៥៤ ( ២៧.០២.២០១១ ) ។

ឋ

# គួរឱ្យសង្វេគ

គួរឲ្យសង្វេគ ស្រណោះពន់ពេក ពេលឃើញពុទ្ធស្ថាន
ធ្លាប់តែរុងរឿង ចម្រើនថ្កើងថ្កាន ឥឡូវប្រែប្រាំង
ប្រៀបបានព្រៃស្ងាត់ ។
២៧៧ អង្គា ប្រណម្យវន្ទា បង្គំថ្វាយថ្វាត់
បូជនីយដ្ឋាន ១២ នាដែនពុទ្ធរដ្ឋ ធម្មយាត្រាកំណត់
ក្នុងពុទ្ធសករាជ ២៥៥៤ ។

នៅមានបុណ្យកុសលនៅក្នុង ព.ស. ២៥៥៥ ផ្នែកខាងសម្តែងព្រះធម៌ដូចគ្នានឹង ព.ស. ២៥៥៤ ដែរ ដោយសរុបប្រាក់នៅក្នុង ព.ស. ២៥៥៥ ប្រាក់ខ្មែរបាន ៣៥,២៨២០០០ រៀល ( ៣៥ លាន ២ សែន ៨ ម៉ឺន ២ ពាន់រៀល ) និងប្រាក់ដុល្លារ **២៧៥៨ ដុល្លារ** ។ នៅបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថាននានានៅក្នុង **ប្រទេសឥណ្ឌា ជាលើកទី ៥** ដែលមានលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ ៦៨ នាក់ ក្នុងនោះ ក៏មាន **ព្រះសង្ឃ ៥ ព្រះអង្គ**ផងដែរ ដោយទៅថ្វាយបង្គំបាន **១៤ កន្លែងធំៗ** បានការជ្រោមជ្រែងមកពីឧបាសិកា **អ៊ឹង រិទ្ធារី** នៅក្នុង ព.ស. **២៥៥៥** ( ០២.០២.២០១២ ) ។

ឱ

*នៅមានបុណ្យកុសលមួយផ្នែកទៀត គឺបុណ្យកុសល ដែលខ្ញុំព្រះករុណា អាត្មាភាព បានទៅថ្វាយបង្គំនៅពុទ្ធស្ថានផ្សេងៗ នៅក្នុង* ***ប្រទេសស្រីលង្កាជាលើកទី ៣*** *ដែលមានលោកគ្រូអគ្គបណ្ឌិត* ***ប៊ុត សាវង្ស*** *ជាប្រធាន ក្នុងការដឹកនាំគណៈធម្មយាត្រានោះ ដែលមានពុទ្ធបរិស័ទទៅប្រមាណ* **១៤០ នាក់** *នៅក្នុងនោះទៀត ក៏មាន* ***ព្រះសង្ឃ ៥ ព្រះអង្គ*** *ផងដែរ ដោយទៅថ្វាយបង្គំបាន* ***៩ កន្លែង*** *ធំៗ បានការឧបត្ថម្ភមកអំពីឧបាសិកា* ***អ៊ឹង រិទ្ធារី*** *នៅក្នុង* ***ព.ស. ២៥៥៥*** *( ២៧.០៣.២០១២ ) ។*

## បានយល់ស្រុកព្រះ

| | | |
|---|---|---|
| *ជ្រះថ្លាខ្លាំងណាស់* | *បានយល់ស្រុកព្រះ* | *ជាតិភូមិសាស្តា* |
| *១៤ កន្លែង* | *៦៨ អង្គា* | *បានក្រាបវន្ទា* |
| | *បូជាគ្រប់ប្រាណ ។* | |
| *សិរីលង្កា* | *១៤០ អង្គា* | *៩ ពុទ្ធស្ថាន* |
| *ជ្រះថ្លាខ្លាំងណាស់* | *ដែលពួកខ្ញុំបាន* | *នមស្ការពុទ្ធស្ថាន* |
| | *ក្នុងពុទ្ធសករាជ ២៥៥៥ ។* | |

*ហេតុដូច្នេះ ដោយបុណ្យកុសលនេះ ខ្ញុំព្រះករុណា សូមឧទ្ទិសមហាកុសលទាំងអស់នេះ ជូនចំពោះញោមប្រុស* ***យង់ សុង*** *( ស្លាប់ ) និងញោមស្រី* ***ឈឹម ហាយ*** *( ស្លាប់ ) ម្យ៉ាងទៀត ញាតិកានៅក្នុងសង្សារវដ្ត ជាពិសេស*

៧

នោះ សូមលើកមហាកុសលទាំងអស់នេះ ជូនចំពោះលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** លោកគ្រូធម្មបណ្ឌិត **រស់ សុផាត** និងលោកគ្រូធម្មាចារ្យ **គាំ អ៊ីវ** ជាដើម សូមឲ្យបាននូវចំណែកបុណ្យកុសលនេះស្មើនឹងអាត្មាភាពផងដែរ សូម **អនុមោទនា !!!** ក៏សូមឲ្យមិត្តអ្នកកំពុងតែកាន់សៀវភៅនេះអាន ឲ្យបានបុណ្យកុសលនៃធម្មទាននេះគ្រប់ៗគ្នា សូមអនុមោទនានូវចំណែកនៃបុណ្យកុសលនេះ ឲ្យបានស្មើនឹងខ្ញុំព្រះករុណា អាត្មាភាពផងដែរ ។

ម្យ៉ាងទៀត ដោយអំណាចបុណ្យកុសលទាំងអស់នេះ ក៏សូមឲ្យបានជាឧបនិស្ស័យ ក្នុងការអស់ទៅនៃអាសវក្កិលេស នាកាលជាអនាគត កុំបីអាក់ខានឡើយ ( សូមឲ្យបានជាសាវ័កបារមីញាណ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ **អង្គណាទីមួយ ដែលជាឯតទគ្គៈផ្នែកខាងពហូសូត ១ មានសតិ ១ មានគតិ ១ មានធិតិ ១ ជាពុទ្ធុបដ្ឋាក ១** ) សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា **នត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

ណ

# ឈ្មោះអ្នកជួយប្រែ និងពិនិត្យអក្ខរាវិរុទ្ធ

លោកអ្នកដ៏មានអាយុ ម៉ី សាលួន ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ សឿន កុសល ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ គីម ម៉ានិត ជួយប្រែ

លោកអ្នកដ៏មានអាយុ ម៉ុន បូរ៉ា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ អ៊ឹម សុជាន ជួយប្រែ

លោកអ្នកដ៏មានអាយុ មាន វណ្ណនា ជួយវាយកុំព្យូទ័រ

លោកអ្នកដ៏មានអាយុ ពេជ្រ ឧត្តម ជួយវាយកុំព្យូទ័រ

ឧបាសក អ៊ឹម រ៉ៃយ៉ា ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក ឡាន សុខុម ជួយប្រែ

ឧបាសក ជិម ជំនិត ជួយពិនិត្យអក្ខរាវិរុទ្ធ

ឧបាសក បូ ស៊ីផួ ជួយពិនិត្យអក្ខរាវិរុទ្ធ

គ

# សមាជិកសមាគមធម្មទានអរិយវង្សយ៉ង់សុផាត

សម្តេចព្រះសង្ឃរាជគណមហានិកាយ នន្ទ ង៉ែត ជាប្រធានកិត្តិយស

ភិក្ខុ អគ្គបណ្ឌិតោ យង់ សុផាត ជាប្រធានសមាគម

លោកអភិបាលស្រុក ស្រេង ស្រ៊ាង ជាទីប្រឹក្សាសមាគម

ឧបាសក អ៊ឹម វ៉ៃយ៉ា ជាអនុប្រធានសមាគម

ឧបាសិកា ង៉ែត យូអេង ជាអនុប្រធានសមាគម

សាមណេរ ម៉ី សាលួន ជាលេខាធិការ

ឧបាសក ឡាន សុខុម ជាលេខាធិការរង

ឧបាសិកា តាំង ប៉ោងជីង ជាហេរញ្ញិក

ឧបាសិកា ជា នាង ជាបេឡា

លោកគ្រូធម្មបណ្ឌិត អឿ សៅ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ឡាយ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា អ៊ឹង រិទ្ធារី សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ហោ ភាព សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា គួ ប៊ុនគាង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឈុំ គីមហួយ សមាជិកកិត្តិយស និងឧបការគុណ

៨

ឧបាសិកា ប៉ែន រមណីយ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឱម លក្ខណា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក អ៊ឹង ប៊ុនហួរ សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា បួ ម៉ាឡា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក ប៊ុន ហេង សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ជុំ សុខុម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា មាស ម៉ូនីកា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា ឡឹក ពេញចិត្ត សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា សៀក ឆាយគីម សមាជិកកិត្តិយស និងឧបការគុណ

ឧបាសក បញ្ញា សមាជិកកិត្តិយស និងឧបការគុណ

ឧបាសិកា កែវ កល្យាណ ជាសមាជិកសកម្ម

ឧបាសិកា ឡេង ធីតា ជាសមាជិកសកម្ម

ឧបាសិកា ម៉ៅ នី ជាសមាជិកសកម្ម

ឧបាសិកា ហេង ចន្ទបុញ្ញាវតី ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារិទ្ធ ជាសមាជិកសកម្ម

ឧបាសក ហុង សុវណ្ណារ៉េត ជាសមាជិកសកម្ម

ទ

# មាតិកាធម៌

មាតិកា | លេខទំព័រ

## ភាវនានិទ្ទេស


១ - អាហារេបដិក្កូលសញ្ញា........................ ៧

- អាហារជាកម្មដ្ឋាន............................................... ៨
- ភាពជាបដិកូល ១០ យ៉ាង................................. ៩
- អាហារេបដិកូលសញ្ញាឈាន.............................. ១៨
- មហាដីកា.......................................................... ១៩
- អានិសង្សនៃអាហារេបដិកូលសញ្ញា..................... ៤៤

២ - ចតុធាតុវវដ្ឋាន........................................ ៤៧

- ភាវនាវិធី........................................................... ៥៥
- បឋវីកោដ្ឋាស...................................................... ៥៩
- អាបោកោដ្ឋាស.................................................... ៧០
- តេជោកោដ្ឋាស..................................................... ៧៨
- វាយោកោដ្ឋាស..................................................... ៧៩
- ការចម្រើនដោយសលក្ខណៈ............................... ៨០
- ការចម្រើនដោយលក្ខណៈវិកត្តិ............................ ៨២
- ការផ្សេងគ្នានៃធាតុខាងក្នុង និងខាងក្រៅ............ ៩៣

មាតិកា លេខទំព័រ

- អានិសង្សនៃចតុធាតុវវដ្ឋាន.................................... ៩៩
- សរុបសមាធិនិទ្ទេស.............................................. ១០០
- មហាដីកា ចតុធាតុវវដ្ឋាន...................................... ១០០
- អានិសង្សនៃការបំពេញសមាធិ.............................. ១៧៧

## ឥទ្ធិវិធនិទ្ទេស

៣ - លោកិយអភិញ្ញា៥.................................. ១៨៥
- វិធីហ្វឹកហាត់........................................................ ១៨៦
- វិធីចូលកសិណ...................................................... ១៨៧
- ការកំណត់មើលអង្គ................................................ ១៩០
- វិធីធ្វើយោគៈ......................................................... ១៩៣
- វិនិច្ឆ័យពាក្យ សមាហិតេ ចិត្តេ ............................ ១៩៤
- វិនិច្ឆ័យសព្ទ ឥទ្ធិ-ឫទ្ធិ............................................ ១៩៦
- មហាដីកា ឥទ្ធិវិធនិទ្ទេស........................................ ១៩៨
- ឥទ្ធិ ១០ យ៉ាង..................................................... ២១៩
- ភូមិនៃឥទ្ធិ............................................................. ២៣២
- បាទនៃឥទ្ធិ............................................................ ២៣៣
- បទ ៨ នៃឥទ្ធិ......................................................... ២៣៤

ន

មាតិកា លេខទំព័រ

- មូល ១៦ នៃឥទ្ធិ........................................ ២៣៥
- ការសម្តែងបាដិហារិយ៍ផ្សេងៗ........................ ២៤៣
- មហាដីកា ឥទ្ធិ ១០ យ៉ាង........................ ២៦១

## អភិញ្ញានិទ្ទេស

៤–ទិព្វសោតធាតុញ្ញាណ........................ ៣៣៧
- មហាដីកា ទិព្វសោតធាតុញ្ញាណ........................ ៣៤១
៥–ចេតោបរិយញ្ញាណ........................ ៣៤៩
- អធិប្បាយចិត្ត ១៦ ........................ ៣៥១
- មហាដីកា ចេតោបរិយញ្ញាណ........................ ៣៥៣
៦–បុព្វេនិវាសានុស្សតិញ្ញាណ........................ ៣៦២
- មហាដីកា បុព្វេនិវាសានុស្សតិញ្ញាណ........................ ៣៨៩
- កប្បកថា........................ ៣៦៩
- ពុទ្ធខេត្ត........................ ៣៧០
- តេជោសំវដ្តៈ........................ ៣៧១
- អាបោសំវដ្តៈ........................ ៣៨១
- វាយោសំវដ្តៈ........................ ៣៨៣

ប


## ៧ – ចុតូបបាតញ្ញាណ........................................ ៤៧១

## ៨ – ទិព្វចក្ខុញ្ញាណ................................................ ៤១៧

## ៩ – យថាកម្មូបគញ្ញាណ..................................... ៤២០

- អរិយុបវាទ................................................................ ៤២១
- ការបម្រើនទិព្វចក្ខុ.................................................... ៤២៨
- មហាដីកា ចុតូបបាតញ្ញាណ..................................... ៤៣១


## បកិណ្ណកកថា


- អារម្មណ៍របស់ឥទ្ធិវិធញ្ញាណ..................................... ៤៤៩
- អារម្មណ៍របស់ទិព្វសោតធាតុញ្ញាណ.......................... ៤៥១
- អារម្មណ៍របស់ចេតោបរិយញ្ញាណ............................ ៤៥២
- បច្ចុប្បន្នចិត្ត ៣ ...................................................... ៤៥៣
- អារម្មណ៍របស់បុព្វេនិវាសញ្ញាណ............................. ៤៥៧
- អារម្មណ៍របស់ទិព្វចក្ខុញ្ញាណ.................................. ៤៥៩
- អារម្មណ៍របស់អនាគតំសញ្ញាណ............................. ៤៦០
- អារម្មណ៍របស់យថាកម្មូបគញ្ញាណ.......................... ៤៦១
- មហាដីកា បកិណ្ណកកថា ........................................ ៤៦២

# ការនានិទ្ទេស

# អាហារេបដិក្កូលសញ្ញា

ឥឡូវនេះ ការនានិទ្ទេសនៃអាហារេបដិកូលសញ្ញា លោកបានលើកឡើងមកសម្តែងទុកបន្ទាប់អំពីអារុប្បនិទ្ទេសថា :

**ឯកាសញ្ញា-សញ្ញាមួយ** ដូច្នេះ មកដល់ហើយតាមលំដាប់ , បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងអាហារេបដិកូលសញ្ញាដូចតទៅនេះ :

សភាវៈឯណារមែងនាំមក ហេតុដូច្នេះ សភាវៈនោះ ទើបឈ្មោះថា **អាហារ** ប្រែថា សភាវៈដែលនាំមក , អាហារនោះមាន ៤ យ៉ាង គឺ **កពឡិង្ការាហារ ផស្សាហារ មនោសញ្ចេតនាហារ វិញ្ញាណាហារ** ។

## វត្ថុដែលអាហារនាំមក

សួរថា ក៏ក្នុងអាហារ ៤ យ៉ាងនោះ អាហារយ៉ាងណារមែងនាំអ្វីមក ?

ឆ្លើយថា កពឡិង្ការាហារ រមែងនាំឱជដ្ឋមករូប ( រូបកលាបៈមានឱជាជាទី ៨ ) ( គឺមហាភូតរូប ៤ និងពណ៌ ក្លិន រស ឱជា ) មក , ផស្សាហារនាំវេទនា ៣ មក , មនោសញ្ចេតនាហារនាំបដិសន្ធិក្នុងភព ៣ មក , វិញ្ញាណាហារនាំនាមរូបក្នុងខណៈបដិសន្ធិមក ។

## ភ័យដែលកើតព្រោះអាហារជាហេតុ

ក្នុងអាហារ ៤ យ៉ាងនោះ ភ័យ គឺ ការនិយមត្រេកអរមានព្រោះកពឡិង្ការាហារ , ភ័យគឺការចូលទៅរករមែងមានព្រោះផស្សាហារ, ភ័យ គឺការចូលទៅដល់

គឺ កើតមានព្រោះមនោសញ្ចេតនាហារ, ភ័យគឺបដិសន្ធិរមែងមានព្រោះវិញ្ញាណាហារ ឯក្នុងអាហារទាំងឡាយដែលមានភ័យចំពោះយ៉ាងដូច្នេះនោះ កពឡិង្ការាហារ ទើបគួរសម្តែងដោយព្រះឱវាទដែលប្រៀបធៀបអាហារដោយសាច់កូន , ផស្សាហារ គួរសម្តែងដោយព្រះឱវាទដែលប្រៀបធៀបផស្សៈ ដោយមេគោអត់ស្បែក , មនោសញ្ចេតនាហារ គួរសម្តែងដោយព្រះឱវាទដែលប្រៀបធៀបកពដោយរណ្តៅរងើកភ្លើង , វិញ្ញាណាហារ គួរសម្តែងដោយព្រះឱវាទដែលប្រៀបធៀបវិញ្ញាណដោយលំពែង ។

## អាហារ
## ដែលបំណាច់យកក្នុងកម្មដ្ឋាននេះ

ក្នុងអាហារ ៤ យ៉ាងនេះ កពឡិង្ការាហារចែកជាប្រភេទ គឺរបស់បរិភោគ របស់ក្រេបផឹក របស់ទំពាស៊ី របស់លិទ្ធភក្ស្យប៉ុណ្ណោះ ទ្រង់បំណាច់យកថា ជាអាហារក្នុងសេចក្តីនេះ ការតាមដឹងដែលកើតឡើងដោយការកាន់យកអាការបដិកូលក្នុងអាហារនោះ ឈ្មោះថា **អាហារេបដិកូលសញ្ញា** ព្រះយោគាវចរអ្នកប្រាថ្នានឹងចម្រើនអាហារេបដិកូលសញ្ញានោះ គប្បីរៀនយកកម្មដ្ឋានបានហើយ ចាំទុកមិនឲ្យខុសអំពីការដែលរៀនមក សូម្បីតែមួយបទ ទៅក្នុងទីស្ងាត់ សំងំនៅតែម្នាក់ឯង ហើយទើបពិចារណាមើលសភាវៈបដិកូលក្នុងកពឡិង្ការាហារ ដែលចែកជារបស់បរិភោគ របស់ក្រេបផឹក របស់ទំពាស៊ី របស់លិទ្ធភក្ស្យ ដោយអាការ ១០ , អាការ ១០ នេះ តើអ្វីខ្លះ គឺ :

**១ - គមនតោ** ដោយការដើរទៅ ។

២ - បរិយេសនតោ ដោយការស្វែងរក ។

៣ - បរិភោគតោ ដោយការបរិភោគ ។

៤ - អាសយតោ ដោយអាសយៈ ( អាបោធាតុក្នុងពោះវៀនដែលចេញមកផ្សំគ្នានឹងអាហារដែលលេបចូលទៅ )។

៥ - និធានតោ ដោយទីអាស្រ័យ ( គឺក្រពះអាហារ ) ។

៦ - អបរិបក្កតោ ដោយនៅមិនទាន់រលាយ ។

៧ - បរិបក្កតោ ដែលរលាយហើយ ។

៨ - ផលតោ ដោយផល ។

៩ - និស្សន្ទតោ ដោយការហូរចេញ ។

១០ - សម្មក្ខនតោ ដោយការប្រឡាក់ប្រឡូស ។

## គមនតោ - បដិកូលដោយការដើរទៅ

ក្នុងបទ ១០ នោះ បទថា **គមនតោ**-ដោយការដើរទៅនោះ មានសេចក្ដីថា បដិកូលដោយការដើរទៅ ព្រះយោគាវចរគប្បីពិចារណាឃើញដោយន័យដូច្នេះថា បព្វជិតក្នុងសាសនាដែលល្បីឈ្មោះថា មានអានុភាពច្រើនយ៉ាងនេះឯង ធ្វើការស្វាធ្យាយព្រះពុទ្ធវចនៈក្ដី ធ្វើសមណធម៌ក្ដីរហូតអស់រាត្រី វៀរលែងតែជិតភ្លឺហើយទៅធ្វើវត្តត្រង់លានព្រះចេតិយ និងលានព្រះពោធិព្រឹក្ស តាំងទឹកឆាន់ ទឹកប្រើប្រាស់ បោសសម្អាតបរិវេណ ជម្រះរាងកាយហើយឡើងទៅកាន់ទីអង្គុយមនសិការកម្មដ្ឋានពី ២០-៣០ ដង ហើយទើបក្រោកឡើងកាន់បាត្រ និងចីវរ ( ក៏ត្រូវ )លះតបោវ័ន ដែលប្រាសចាកជនរំខាន ងាយស្រួលដល់ ( ការនៅដោយ )បវិវេក ដល់ព្រម

ដោយម្ចប់ឈើ និងទឹកស្អាតត្រជាក់ ជាភូមិភាគគួររីករាយ ត្រូវលះបង់ក្តីសង្ឃឹមក្នុងការត្រេកអរក្នុងវិវេកដែលជាអរិយគុណ មានមុខឆ្ពោះទៅកាន់ស្រុកដើម្បីត្រូវការអាហារ ដូចឆ្កែចចកមានមុខឆ្ពោះទៅកាន់ព្រៃខ្មោច ដើម្បីត្រូវការសាកសពដូច្នោះ កាលទៅយ៉ាងនោះសោត តាំងអំពីចុះចាកគ្រែ ឬតាំងទៅ ក៏ត្រូវជាន់លើកម្រាលដែលប្រឡាក់ទៅដោយវត្ថុមិនស្អាត មានល្អងធូលី និង អាចម៍ជីងចក់ជាដើមជាប់ជើង តពីនោះ ក៏ត្រូវជួបរបស់ដែលបដិកូលក្រៃលែងជាងខាងក្នុងបន្ទប់ ព្រោះត្រូវលាងកន្លែងដែលវត្ថុបដិកូល មានអាចម៍កណ្តុរ និងអាចម៍ប្រចៀវជាដើមធ្វើឲ្យប្រឡាក់ តទៅទៀតក៏ត្រូវជួបផ្ទៃក្រោម ( កុដិ ) ដែលកាន់តែបដិកូលក្រៃលែងជាងផ្ទៃខាងលើ ព្រោះត្រូវលាងកន្លែងដែលប្រឡាក់ទៅដោយអាចម៍មៀម និងអាចម៍ព្រាបជាដើម បន្ទាប់មកត្រូវជួបបរិវេណដែលបដិកូលក្រៃលែងជាងផ្ទៃក្រោមកុដិ ព្រោះកន្លែងលាងជម្រះក៏ស្មោកគ្រោកទៅដោយស្មៅ និងស្លឹកឈើចាស់ៗដែលខ្យល់បក់មក ដោយបស្សាវៈ ឧច្ចារៈ ទឹកមាត់ ទឹកសម្បោរ របស់ពួកសាមណេរដែលមានជម្ងឺ ព្រមទាំងទឹក និងភក់ក្នុងរដូវភ្លៀងជាដើម ផ្លូវដើរទៅវិហារក៏បដិកូលក្រៃលែងជាងបរិវេណទៅទៀត ក៏ត្រូវជួប , ម្យ៉ាងទៀត លោកថ្វាយបង្គំព្រះពោធិព្រឹក្ស និងព្រះចេតិយតាមលំដាប់ហើយ ទៅឈប់ឈរនៅត្រង់កន្លែងវិតក្កមាលកៈ ( រោងធ្វើវិតក្ក ) ហើយត្រិះរិះថា ខ្លួនក៏ត្រូវមិនបានថែរក្សាព្រះចេតិយដ៏ស្រស់ស្អាតដូចជាគំនរកែវមុក្តា និងព្រះពោធិព្រឹក្សដ៏ស្រស់ស្អាតដូចជាក្ងោកពង់ និងសេនាសនៈដ៏ស្រស់ស្អាត មានទ្រង់ទ្រាយសង្ហារ ដូចទេពវិមាន បែរខ្នងដាក់ស្ថានទីដ៏គួររីករាយបែបនេះ ហើយទៅ ក៏ព្រោះអាហារជាហេតុដូច្នេះហើយ ឈានដើរទៅតាមផ្លូវឆ្ពោះទៅកាន់ស្រុក ក៏ត្រូវជួបផ្លូវមានជង្គត់ និងបន្លាខ្វះ ផ្លូវដែលត្រូវកម្លាំងទឹកច្រោះ

( ជារណ្តៅជ្រៅៗ ) និង ផ្លូវខ្ពស់ទាបៗ ខ្លះ តពីនោះ លោកត្រូវស្លៀកសំពត់ ( ដោយការជីងខ្លួន ) ដូចរុំបូស ក្រវាត់វត្ថពន្ធចង្កេះដោយការជីងខ្លួន ដូចចងសំពត់រុំដំបៅ គ្រងចីវរដោយការជីងខ្លួន ដូចឃ្លុំគ្រោងឆ្អឹង នាំបាត្រទៅដោយការជីងខ្លួន ដូចនាំអំបែងក្បឿងដាក់ថ្នាំទៅ ទៅដល់ទីជិតចន្លោះចូលស្រុក ក៏ត្រូវបានជួបសាកសពផ្សេងៗ ដូចជាសាកសពដំរីខ្លះ សាកសពសេះខ្លះ សាកសពគោខ្លះ សាកសពក្របីខ្លះ សាកសពមនុស្សខ្លះ សាកសពពស់ខ្លះ សាកសពឆ្កែខ្លះ មិនមែនត្រឹមតែជួបប៉ុណ្ណោះទេ សូម្បីក្លិនរបស់សាកសពទាំងនោះ ដែលមកប៉ះខ្ទប់ច្រមុះ ក៏ជាវត្ថុដែលលោកត្រូវតែអត់ធន់ដែរ តពីនោះ លោកត្រូវឈប់ឈរត្រង់ចន្លោះផ្លូវចូលទៅកាន់ស្រុក សម្លឹងមើលផ្លូវដើរក្នុងស្រុកជាមុន ដើម្បីចៀសវាងអន្តរាយមានដំរីកាច សេះកាចជាដើម ។

វត្ថុបដិកូលមានកម្រាល ដែលប្រឡាក់ល្អងធូលីជាដើម មានសាកសពច្រើនយ៉ាងជាបរិយោសាន ដូចពោលមកដូច្នេះនេះ ជាវត្ថុដែលលោកចាំបាច់ត្រូវជាន់ផង ត្រូវជួបផង ត្រូវហិតក្លិនផង ក៏ព្រោះអាហារជាហេតុ ភាពបដិកូលដោយការដើរទៅ ព្រះយោគាវចរគប្បីឃើញដូច្នេះថា ឱ ! បដិកូលពិតមែនហ្ន៎ អាហារនេះ ។

## បរិយេសនតោ - បដិកូលដោយការស្វែងរក

បដិកូលដោយការស្វែងរក តើដូចម្តេច ? បណ្ឌិតអ្នកអត់ធន់ចំពោះបដិកូលក្នុងការដើរទៅយ៉ាងនេះ ហើយចូលទៅកាន់ស្រុក ឃ្លុំខ្លួនដោយសង្ឃាដិ ក៏ត្រូវដើរទៅក្នុងផ្លូវតាមលំដាប់ផ្ទះ ដូចមនុស្សកំព្រាកាន់អំបែងក្បឿងដើរទៅដូច្នោះ ក្នុងផ្លូវ

នោះសោត ពេលរដូវភ្លៀង ក្នុងកន្លែងដែលជាន់ទៅ ជើងរអិលចុះក្នុងក្រឡុកភក់ដល់កំភួនជើង ត្រូវកាន់បាត្រដោយដៃម្ខាង លើកចីវរដោយដៃម្ខាង ពេលរដូវក្ដៅក៏ត្រូវទៅដើម្បីកិច្ចាចារ ទាំងដែលរាងកាយប្រឡាក់ប្រឡូសដោយធូលី និងកំទេចស្មៅដែលហុយឡើងដោយកម្លាំងខ្យល់ ដល់ទ្វារផ្ទះនោះៗហើយ ក៏ត្រូវជួបកន្លែងលាងជម្រះ ត្រូវជាន់ក្រឡុកស្មោកគ្រោក និងថ្លុកជ្រាំ ដែលលាយឡំទៅដោយរបស់ស្មោកគ្រោក មានទឹកលាងត្រី ទឹកលាងសាច់ ទឹកលាងអង្ករ ទឹកមាត់ ទឹកសម្បោរ អាចម៍ក្អែ និងអាចម៍ជ្រូកជាដើម ពោរពេញទៅដោយដង្កូវ និងរុយក្បាលខៀវ ហើយជាទីកន្លែងរបស់សត្វរុយដែលនៅក្នុងស្រុក ហើរឡើងមកទំលើសង្ឃាដិខ្លះ បាត្រខ្លះ ក្បាលខ្លះ កាលលោកចូលទៅដល់ផ្ទះសោត ម្ចាស់ផ្ទះពួកខ្លះក៏ឲ្យ ពួកខ្លះក៏មិនឲ្យ ពួកអ្នកឲ្យសោត ពួកខ្លះក៏ឲ្យបាយដែលដាំទុកតាំងពីម្សិលខ្លះ របស់ទំពាស៊ីសល់ៗខ្លះ ម្ហូបមានសម្លសណ្ដែកផ្អូមៗខ្លះ អ្នកមិនឲ្យសោត ពួកខ្លះប្រាប់ថា សូមលោកម្ចាស់ទៅប្រោសសត្វខាងមុខចុះ ករុណាម្ចាស់ប៉ុណ្ណោះ ពួកខ្លះក្លែងធ្វើជាមិនឃើញ អង្គុយព្រងើយៗ ពួកខ្លះក៏បែរមុខចេញ ពួកខ្លះក៏ស្រែកដោយពាក្យគ្រោតគ្រាតជាដើមថា ចេញទៅវើយ មនុស្សក្បាលត្រងោល យ៉ាងនេះលោកក៏ត្រូវដើរបិណ្ឌបាតទៅក្នុងស្រុក ដូចជាមនុស្សកំព្រា ហើយទើបចេញទៅដូច្នេះ ។ វត្ថុបដិកូលមានរណ្ដៅជាដើម ដូចពោលមកនេះ ជាវត្ថុដែលលោកត្រូវជាន់ផង ត្រូវជួបផង ត្រូវអត់ធន់ផង តាំងពីចូលទៅកាន់ស្រុករហូតដល់ចេញពីស្រុក ក៏ព្រោះអាហារជាហេតុដោយពិត ការបដិកូលដោយការស្វែងរក ព្រះយោគីគប្បីឃើញដូចនេះចុះថា ឱ ! បដិកូលពិតហ្ន៎ អាហារនេះ ។

## បរិភោគតោ - បដិកូលដោយការបរិភោគ

បដិកូលដោយការបរិភោគ តើដូចម្តេច ? ការបដិកូលដោយការបរិភោគ បព្វជិតអ្នកមានអាហារ ដែលស្វែងរកបានមកយ៉ាងនេះហើយ អង្គុយតាមសប្បាយក្នុងកន្លែងជាទីសប្បាយក្រៅស្រុក គប្បីឃើញដូច្នេះចុះថា លោកនៅមិនទាន់បានលូកដៃចុះក្នុងអាហារដែលនៅក្នុងបាត្រ ដរាបណា លោកបានឃើញភិក្ខុអ្នកជាគរុឋានិយៈក្តី ជាលជ្ជីក្តី ដូច្នោះហើយ ក៏អាចនិមន្ត ( ឬ អញ្ជើញឲ្យបរិភោគអាហារនោះ ) បានដរាបនោះ តែពេលលោកលូកដៃចុះទៅក្នុងអាហារនោះដោយប្រាថ្នានឹងឆាន់ នឹងស្រែកអញ្ជើញលោកឲ្យទទួលអាហារនោះ នឹងត្រូវមានការអៀនខ្មាស ពេលលោកលូកដៃចុះ ហើយច្របល់ ញើសដៃហូរចេញតាមម្រាមទាំង ៥ ធ្វើបាយដែលរឹងព្រោះការក្រៀមស្ងួត ឲ្យសើមទន់ទៅបាន ដូច្នេះ ពេលបិណ្ឌបាតនោះខូចភាពស្រស់ស្អាតហើយ ព្រោះការច្របល់ លោកធ្វើជាពុំនូតដាក់ចូលក្នុងមាត់ ហើយធ្មេញក្រោមធ្វើជាត្បាល់ ធ្មេញលើធ្វើជាអង្រែ អណ្តាតធ្វើកិច្ចជាដៃឲ្យសម្រេចទៅ បិណ្ឌបាតនោះ ដែលបុកដោយអង្រែ គឺធ្មេញ ត្រឡប់ទៅមកដោយអណ្តាត ប្រៀបដូចជាបាយឆ្កែក្នុងស្នូក នៅក្នុងមាត់នោះ ទឹកមាត់ថ្លា ត្រង់ចុងអណ្តាតក៏ប្រឡាក់ ទឹកមាត់ខាប់ពីកណ្តាលអណ្តាតចូលទៅក៏ប្រឡាក់ អាចម៍ធ្មេញក្នុងទីដែលឈើជម្រះធ្មេញចូលមិនដល់ក៏ប្រឡាក់ បិណ្ឌបាតនោះក៏បែកស្អិត និងប្រឡាក់ហើយយ៉ាងនេះ មានពណ៌ ក្លិន និងការតាក់តែងយ៉ាងវិសេស ត្រូវបាត់បង់ទៅមួយរំពេច ត្រឡប់ក្លាយជារបស់គួរឲ្យខ្ពើមរអើមយ៉ាងក្រៃលែង ដូចកម្អួតរបស់សុនខនៅក្នុងស្នូកបាយរបស់សុនខដូច្នោះ បិណ្ឌបាតនោះ សូម្បីជាយ៉ាងនេះ ក៏ជាវត្ថុដែលគប្បីលេបចូលទៅបាន ព្រោះវាកន្លងក្រសែចក្ខុ ( គឺ មើលមិនឃើញ ) ។

## អាសយតោ - បដិកូលដោយអាសយៈ

បដិកូលដោយអាសយៈ ( អាបោធាតុក្នុងពោះវៀនដែលចេញមកផ្សំគ្នានឹងអាហារដែលលេបចូលទៅ )នោះ ដូចម្តេច ? ការបដិកូលដោយអាសយៈគប្បីឃើញយ៉ាងដូច្នេះថា អាហារដែលបានបរិភោគចូលទៅហើយយ៉ាងនេះ កាលកំពុងចូលទៅខាងក្នុងពោះវៀន ព្រោះហេតុក្នុងអាសយៈ ៤ គឺ **បិត្តាសយ** ( អាសយៈ គឺទឹកប្រមាត់ ) **សេម្ហាសយ**( អាសយៈ គឺ សេម្ហ ) **បុព្វាសយ**( អាសយៈ គឺបុព្វ ) **លោហិតាសយ** ( អាសយៈ គឺលោហិត ) អាសយៈណាមួយរមែងមានដោយពិតសូម្បីដល់ព្រះសម្មាសម្ពុទ្ធ និងព្រះបច្ចេកពុទ្ធ ស្តេចចក្រពត្តិ តែសម្រាប់ពួកជនអ្នកមានបញ្ញាទន់ខ្ចី អាសយៈមានទាំង ៤ យ៉ាង ព្រោះហេតុនោះ អ្នកណាមានបិត្តាសយៈច្រើន( អាហារចូលទៅក្នុងពោះវៀន )របស់អ្នកនោះ ក៏ប្រាកដដូចជាប្រឡាក់ទៅដោយជ័រទន្សែខាប់ៗ គួរឲ្យខ្ពើមរអើមដ៏ក្រៃលែង អ្នកណាមានសេម្ហាសយៈច្រើន របស់អ្នកនោះក៏ប្រាកដដូចជាប្រឡាក់ទៅដោយទឹកត្របៀកកណ្តុរ អ្នកណាមានបុព្វាសយៈច្រើន របស់អ្នកនោះ ប្រាកដដូចជាប្រឡាក់ដោយប្រេងស្អុយ អ្នកណាមានលោហិតសយៈច្រើន របស់អ្នកនោះ ប្រាកដដូចជាទឹកជ្រលក់ចីវរ គួរឲ្យខ្ពើមរអើមក្រៃពេកណាស់ ។

## និធានតោ - បដិកូលដោយទីអាស្រ័យ

ការបដិកូលដោយទីអាស្រ័យ គឺក្រពះអាហារយ៉ាងណា ? ការបដិកូលដោយទីអាស្រ័យ គប្បីឃើញយ៉ាងនេះថា អាហារលេបចូលទៅប្រឡាក់ដោយអាសយៈ ៤ យ៉ាង ណាទីមួយហើយនោះ ចូលទៅខាងក្នុងពោះហើយ នឹងទៅអាស្រ័យនៅ

ក្នុងភាជនៈធ្វើដោយមាសក៏ទេ ទៅនៅក្នុងភាជនៈដ៏ពិសេសដទៃៗ មានភាជនៈប្រដាប់ដោយកែវមណី ឬភាជនៈធ្វើដោយប្រាក់ជាដើមក៏ទេ តែថា បើមនុស្សមានអាយុ ១០ ឆ្នាំ លេបចូលទៅ វាក៏ទៅអាស្រ័យនៅក្នុងឱកាសដែលប្រាកដ ដូចជារណ្ដៅលាមកដែលមិនបានលាងមក ១០ ឆ្នាំ បើមនុស្សមានអាយុ ២០-៣០-៤០-៥០-៦០-៧០-៨០-៩០ លេបចូលទៅ វាក៏ទៅអាស្រ័យនៅក្នុងឱកាសដែលប្រាកដដូចជារណ្ដៅលាមក ដែលមិនបានលាងមក ២០-៣០-៤០-៥០-៦០-៧០-៨០-៩០ ឆ្នាំ បើមនុស្សអាយុ ១០០ ឆ្នាំ លេបចូលទៅ វាក៏ទៅអាស្រ័យនៅក្នុងឱកាសដែលប្រាកដដូចជារណ្ដៅលាមក ដែលមិនបានលាងមក ១០០ ឆ្នាំ ។

## អបរិបក្កតោ - បដិកូលដោយការមិនទាន់រលាយ

ការបដិកូលដោយការនៅមិនទាន់រលាយយ៉ាងណា ? ការបដិកូលដោយការនៅមិនទាន់រលាយ គប្បីឃើញយ៉ាងនេះថា អាហារនោះ ដែលចូលទៅអាស្រ័យនៅក្នុងឱកាសយ៉ាងនោះហើយ នៅមិនទាន់រលាយត្រឹមណា ដែលលេបចូលទៅខាងក្នុង ក្នុងថ្ងៃនោះខ្លះ ក្នុងថ្ងៃម្សិលមិញខ្លះ ក្នុងថ្ងៃមុនខ្លះទាំងអស់ជាមួយគ្នា ដែលត្រូវស្រទាប់ស្លេសបិទទុក មានពពុះពោងឡើង ដែលកើតអំពីកម្ដៅភ្លើងជាតុក្នុងរាងកាយដុតកម្ដៅ ចូលដល់ភាពជារបស់គួរឲ្យខ្ពើមរអើមយ៉ាងក្រៃលែង តាំងពីនៅក្នុងទីមានប្រការដូចពោលហើយនោះ និងជាទីងងឹតស្លុប ត្រឡប់ទៅដោយក្លិនគួរឲ្យអៀនខ្មាស ដែលអប់ដោយក្លិនសាកសព ដែលជាអាហារផ្សេងៗ មានក្លិនស្អុយគួរឲ្យខ្ពើមរអើមត្រឹមប៉ុណ្ណោះ ប្រៀបដូចរបស់មិនស្អាតផ្សេងៗ ដូចជា ស្មៅស្លឹកឈើ កន្ទេលដាច់ដាច សាកសាពពស់ សាកសពសុនខ ព្រមទាំងសាកសព

មនុស្សដែលធ្លាក់ទៅក្នុងរណ្តៅស្មោកគ្រោក នៅក្បែរបន្ទោះផ្លូវចូលទៅក្នុងភូមិពួកចណ្ឌាល ដែលត្រូវភ្លៀងពុំជូរកាល ក្នុងរដូវក្តៅធ្លាក់ស្រោចហើយ ត្រូវកម្តៅក្តៅភេល ក៏បង្កើតជាពពុះនិងក្រពេញឡើង កាយក្លិនគួរឲ្យខ្ពើមរអើមដូច្នេះ ។

## បរិបក្កតោ - បដិកូលដោយការរលាយហើយ

បដិកូលដោយការរលាយហើយ ដូចម្តេច ? ការបដិកូលដោយការរលាយហើយ គប្បីឃើញយ៉ាងនេះថា អាហារនោះ កាលជាវត្ថុដែលរលាយទៅដោយភ្លើងធាតុក្នុងរាងកាយ ក្នុងឱកាសទីអាស្រ័យនៅនោះហើយ ក៏បានក្លាយជារបស់មានតម្លៃដូចមាស និងប្រាក់ក៏ទេ ដូចរ៉ែទាំងឡាយ មានរ៉ែមាស រ៉ែប្រាក់ជាដើមក៏ទេ តែវាត្រឡប់កើតពពុះ និងក្រពេញ ដូចជាករីសបច្ចុបក្កាសយ( ក្រពះឧច្ចារៈ ) ដូចដីពណ៌លឿងដែលគេកិនដោយត្បាល់កិន ហើយប្រចាប់ទុកក្នុងបំពង់ឫស្សីដូច្នោះ នឹងដូចជាមូត្រ បច្ចុមុត្តវត្ថិ ( ក្រពះបស្សាវៈ ) ។

## ផលតោ - បដិកូលដោយផល

ការបដិកូលដោយផល តើដូចម្តេច ? ការបដិកូលដោយផល គប្បីឃើញយ៉ាងនេះថា ក៏អាហារនេះដែលរលាយល្អប៉ុណ្ណោះ ទើបផលិតសព្វគ្រប់ មានសក់ រោម ក្រចក ធ្មេញជាដើមឡើងបាន ដែលរំលាយមិនល្អ ត្រឡប់ជាបន្ទរោគទាំង ១០០ ប្រភេទឡើង មានរមាស់ពងបែកធំៗ រមាស់ពងបែកគ្រាប់តូចៗ កន្ទាលត្រអាក ស្រែង យូន់ ហឺត ក្អក និងរាគមួល នេះជាផលរបស់វា ។

## និស្សន្ទតោ - បដិកូលដោយការហូរចេញ

បដិកូលដោយការហូរចេញ តើដូចម្តេច ? ការបដិកូលដោយការហូរចេញ

គប្បីឃើញយ៉ាងនេះថា ក៏អាហារនោះ កាលលេបចូលទៅក្នុងរន្ធតែមួយ ប៉ុន្តែកាលហូរចេញ ហូរចេញតាមរន្ធច្រើន ដូចអាចម៍ភ្នែក ហូរចេញតាមទ្វារភ្នែក អាចម៍ត្រចៀក ហូរចេញតាមត្រចៀក ម្យ៉ាងទៀត អាហារនោះ ក្នុងពេលបរិភោគ បរិភោគជាមួយមនុស្សពួកច្រើនក៏មាន តែក្នុងពេលហូរចេញ វាក្លាយជារបស់មិនស្អាត មានឧច្ចារៈ បស្សាវៈជាដើម ហើយបន្ទោបង់ចេញតែម្នាក់ឯង ម្យ៉ាងទៀត ក្នុងថ្ងៃទី ១ មនុស្សអ្នកបរិភោគវា រីករាយសប្បាយចិត្ត កើតបីតិសោមនស្សក៏មាន តែក្នុងថ្ងៃទី ២ វាក៏ហូរចេញ មនុស្សទាំងឡាយបិទច្រមុះ ងាកមុខចេញ ស្អប់ គួរឲ្យខ្ពើមរអើម ម្យ៉ាងទៀត ក្នុងថ្ងៃទី ១ មនុស្សត្រេកអរល្មោភជាប់ចិត្ត លេបវាចូលទៅក៏មាន តែលុះដល់ថ្ងៃទី ២ ព្រោះស្ថិតនៅមួយយប់ក៏ឈប់ត្រេកអរ កើតទុក្ខ ស្អប់ គួរខ្ពើម រង្កៀសបន្ទោបង់ចេញទៅ ព្រោះហេតុនោះ បុរាណាចារ្យទាំងឡាយទើបពោលទុលថា បាយ ទឹក របស់ទំពា និងរបស់ស៊ី ដែលមានតម្លៃច្រើន ចូលតាមរន្ធតែមួយ ប៉ុន្តែហូរចេញតាមរន្ធទាំង ៩ បាយ ទឹក របស់ទំពា និងរបស់ស៊ី ដែលមានតម្លៃច្រើន មនុស្សបរិភោគជាមួយគ្នាទាំងបក្ខពួក តែកាលបន្ទោបង់ចេញមក រមែងលាក់ពួន បាយ ទឹក របស់ទំពា និងរបស់ស៊ី ដែលមានតម្លៃច្រើន មនុស្សនិយម ត្រេកអរបរិភោគចូលទៅ តែកាលបន្ទោបង់ចេញមក បែរជាស្អប់ គួរឲ្យខ្ពើមរអើម បាយ ទឹក របស់ទំពា និងរបស់ស៊ី ដែលមានតម្លៃច្រើន កាលស្ថិតនៅមួយយប់ហើយ ក៏ជារបស់សាបសូន្យអស់តម្លៃទៅវិញ ។

## សម្មក្ខណតោ - បដិកូលដោយការប្រឡាក់

បដិកូលដោយការប្រឡាក់ តើដូចម្តេច ? បដិកូលដោយការប្រឡាក់គប្បី

ឃើញយ៉ាងនេះថា ក៏ឯអាហារនោះ សូម្បីក្នុងពេលបរិភោគក៏ប្រឡាក់ដៃ បបូរមាត់ អណ្ដាត និងពិតានមាត់ , ដៃ បបូរមាត់ អណ្ដាត និងពិតានមាត់នោះ ក៏ក្លាយជាវត្ថុបដិកូល ព្រោះត្រូវអាហារនោះប្រឡាក់ ទោះបីលាងហើយ ក៏ត្រូវលាងទៀតដែរ ដើម្បីកម្ចាត់ក្លិន កាលមនុស្សបរិភោគវាចូលទៅហើយ វារលាយបន្តជាដុំពពុះឡើងដោយភ្លើងធាតុក្នុងកាយ ដែលផ្សាយទៅទូទាំងរាងកាយ ហើយក៏ឡើងមកប្រឡាក់ធ្មេញ កើតជាអាចម៍ធ្មេញ ប្រឡាក់វត្ថុដែលជាប់ទាក់ទងនឹងមាត់ មានអណ្ដាត និងពិតានមាត់ កើតជាខេឡ: និងសេម្ហ:ជាដើមប្រឡាក់ទ្វារទាំងឡាយ មានទ្វារភ្នែក ត្រចៀក រន្ធប្រមុះ និងទ្វារក្រោមជាដើម កើតជាអាចម៍ភ្នែក អាចម៍ត្រចៀក អាចម៍ប្រមុះ ទឹកសម្បោរ ទឹកមូត្រ និងករីស: ប្រៀបដូចអង្ករ កាលត្រូវដាំ កាកទាំងឡាយ មានអង្កាម កន្ទក់ ក្បាលអង្កាមជាដើម រមែងអណ្ដែតឡើងមកប្រឡាក់មាត់ឆ្នាំង និងគម្របឆ្នាំងដូច្នោះ សូម្បីទ្វារទាំងឡាយនេះ ក៏វាប្រឡាក់ហើយ ទោះបីដុសលាងរាល់ថ្ងៃ ក៏នៅជារបស់មិនស្អាត មិនគួរឲ្យពេញចិត្ត ក្នុងទ្វារទាំងឡាយនោះសោត បើលាងទ្វារខាងក្រោមដោយដៃនោះ ដៃក៏ជារបស់ដែលត្រូវលាងដោយទឹកទៀត បើលាងទ្វារក្រោមហើយ ដៃនោះត្រូវជម្រះដោយលាមកគោខ្លះ ដោយដីខ្លះ ដោយលម្អិតក្រអូបខ្លះ ២ - ៣ ដង ទើបអស់ភាពបដិកូល ។

# អាហារេបដិកូលសញ្ញាឈាន

កាលយោគាវចរភិក្ខុនោះ ពិចារណាឃើញការបដិកូលដោយអាការ ១០ យ៉ាងនេះ ធ្វើឲ្យជាតក្កាហត ( នឹកភ្លាមបានភ្លាម ) វិតក្កាហត ( ត្រិះរិះភ្លាមបាន

ក្ខាម ) កពឡិង្ការាហាររមែងប្រាកដដោយអាការបដិកូល លោកសេព ចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះជារឿយៗ កាលលោកធ្វើយ៉ាងនោះ នីវរណៈទាំងឡាយ នឹងស្ងប់រំងាប់ ចិត្តក៏តាំងមាំដោយឧបចារសមាធិ តែមិនដល់អប្បនាទេ ព្រោះកពឡិង្ការាហារជាសភាវៈជ្រាលជ្រៅដោយសភាពជាសភាវធម៌ តែព្រោះថា សញ្ញា ( ការចងចាំ ) ក្នុងកពឡិង្ការាហារនោះ រមែងប្រាកដដោយអំណាចការកាន់យកអាការបដិកូល ព្រោះហេតុនោះ កម្មដ្ឋាននេះទើបដល់នូវការរាប់ ( គឺបានឈ្មោះ ) ថា អាហារេបដិកូលសញ្ញាដូច្នេះ ។

## មហាដីកា

## ពណ៌នា អាហារេបដិក្កូលភាវនា

ដែលឈ្មោះថា **ឧទ្ទេស** ( មាតិកាដែលលើកឡើងមកសម្តែង ) ក៏មាននិទ្ទេស ( ពាក្យសម្តែងលម្អិត ) ជាអត្ថាធិប្បាយ ព្រោះជាទេសនាដែលពន្យល់ដល់បុគ្គលអ្នកមានបញ្ញាទន់ខ្សោយ និងមានបញ្ញាថ្នាក់កណ្តាល និងជាភារៈដែលមកហើយក៏ចាំបាច់បំបែកឲ្យបានពិតប្រាកដ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា និទ្ទេសនៃការចម្រើនបដិកូលសញ្ញា ក្នុងអាហារដែលបានលើកឡើងមកសម្តែងទុក ( ក្នុងលំដាប់នៃអរូបកម្មដ្ឋាន ) យ៉ាងនេះថា សញ្ញា ១ ដូច្នេះ ដល់ហើយដោយលំដាប់ដូច្នេះ ។ ក្នុងពាក្យនោះ សព្ទថា **សញ្ញា** នេះ មកហើយក្នុងធម៌ដែលមានការចងចាំ ជាលក្ខណៈ ក្នុងពាក្យថា **រូបសញ្ញា សទ្ទសញ្ញា** ( ការចាំរូប ចាំសំឡេង ) ជាដើម , មកហើយក្នុងវិបស្សនា ក្នុងពាក្យថា **អនិច្ចសញ្ញា ទុក្ខសញ្ញា** ( ការចាំថា មិនទៀង , ការចាំថា ជាទុក្ខ ) ជាដើម , មកហើយក្នុង

សមថៈ ក្នុងប្រយោគថា **ឧទ្ធុមាតកសញ្ញាតិ វា សោបាករូបសញ្ញាតិ វា ឥមេ ធម្មា ឯកត្ថា ឧទាហុ នានត្ថា** ប្រែថា ម្នាលសោបាកៈ ពាក្យថាឧទ្ធុមាតកសញ្ញាក្ដី ពាក្យថារូបសញ្ញាក្ដី ធម៌ទាំងនេះមានអត្ថដូចគ្នា ឬមានអត្ថផ្សេងគ្នា ដូច្នេះជាដើម ។ ចំណែកក្នុងអធិការនេះ បណ្ឌិតគប្បីឃើញថា ក្នុងការបរិកម្មនៃសមថៈ ។ សេចក្ដីពិតថា ការកាន់យកអាការដែលជាបដិកូលក្នុងអាហារក្ដី ឧបចារឈានដែលកាន់យកអាការដែលជាបដិកូលក្នុងអាហារនោះ ធ្វើឲ្យកើតឡើងក្ដី លោកបំណងយកក្នុងទីនេះថា ជាអាហារេបដិកូលសញ្ញា ។ ក្នុងពាក្យនោះ ព្រះយោគាវចរគប្បីចម្រើនបដិកូលសញ្ញាក្នុងអាហារណា ដើម្បីការធ្វើវិភាគៈ គឺ ការទៀយណាយក្នុងអាហារនោះឲ្យកើតឡើង លោកអាចារ្យផ្ដើមពាក្យថា ឈ្មោះថា **អាហារ** ព្រោះអត្ថថា **នាំមក** ដូច្នេះជាដើម ក៏ដើម្បីនឹងបើកបង្ហាញអាហារសូម្បីទាំងអស់ ដោយជាប់ទាក់ទងនឹងអាហារដែលគប្បីចម្រើនបដិកូលសញ្ញានោះ ដោយកិច្ច ប្រភេទទោស និងឧបមា ។

ក្នុងពាក្យទាំងនោះ ពាក្យថា **នាំមក** គឺនាំមកនូវផលរបស់ខ្លួន ដោយភាពជាបច្ច័យដែលរាប់ថា ជាអាហារប្បច្ច័យ ដើម្បីការកើតឡើង ឬ ដើម្បីការតាំងនៅបានន័យថា ធ្វើឲ្យកើតឡើង និងធ្វើឲ្យប្រព្រឹត្តទៅ ។ **អាហារ** ឈ្មោះថា **កពឡិង្ការ** ព្រោះអត្ថថា ដែលបុគ្គលតែងធ្វើឲ្យជាពុំនូត , ពាក្យថា **កពឡិង្ការ** នេះ លោកអាចារ្យពោលទុកជាប់ទាក់ទងនឹងវត្ថុ ( មានបាយទឹកជាដើម ) , ឯការពោលដោយលក្ខណៈ ក៏គប្បីជ្រាបបានដោយធម៌ ដែលមានលក្ខណៈជា **ឱជា** , ធម៌នោះជា **កពឡិង្ការ** ( របស់ដែលគេធ្វើឲ្យជាពុំនូត ) ផង ជាអាហារដោយន័យ តាមដែលពោលហើយផង ព្រោះហេតុនោះ ទើបឈ្មោះថា **កពឡិង្ការាហារ** ។ សូម្បី

ក្នុងអាហារដ៏សេសក៏មានន័យដូច្នេះដែរ ។ សភាវៈឈ្មោះថា **ផស្ស** ព្រោះអត្ថថា ប៉ះខ្ទប់ ។ ពិតណាស់ ផស្សៈនេះ សូម្បីជានាមធម៌ ក៏រមែងប្រព្រឹត្តទៅដោយអាការដែលប៉ះខ្ទប់អារម្មណ៍ ។

ពិតណាស់ លោកពោលដល់ផស្សៈនោះថា មានការប៉ះខ្ទប់នឹងអារម្មណ៍ជាលក្ខណៈ ។ ធម្មជាតិឈ្មោះថា **ចេតនា** ព្រោះអត្ថថា តាំងចិត្ត ។ សេចក្តីថា ចាត់ចែងខ្លួនឯង ព្រមទាំងសម្បយុត្តធម៌ទាំងឡាយចូលទុកក្នុងអារម្មណ៍ , ចេតនាដែលអាស្រ័យចិត្ត ឈ្មោះថា **មនោសញ្ចេតនា** ។ ធម្មជាតិដែលឈ្មោះថា **វិញ្ញាណ** ព្រោះអត្ថថា ដឹងផ្សេងៗគ្នា ដោយជាប់ទាក់ទងនឹងខកំណត់នៃការឧប្បត្តិ ។ គប្បីជ្រាបអាហារទាំងឡាយដោយន័យសាមញ្ញ និងដោយន័យពិសេស ក្នុងទីនេះតាមប្រការដូចដែលបានពោលមកហើយ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ត្រាស់អាហារទាំងឡាយនោះទុក ៤ យ៉ាងប៉ុណ្ណោះ ធម៌ពួកដទៃមិនជាបច្ច័យដល់ផលរបស់ខ្លួនទេឬ ? ឆ្លើយថា ធម៌ពួកដទៃមិនជាបច្ច័យដល់ផលរបស់ខ្លួនក៏មិនមែន តែថា ធម៌ ៤ យ៉ាងពួកនេះ ជាបច្ច័យដោយប្រការដូចគ្នានោះក៏បាន ជាបច្ច័យដោយប្រការដទៃក៏បាន ព្រោះហេតុនោះ កាលមានភាពជាបច្ច័យ ក៏រមែងជាបច្ច័យដ៏លើស ( ជាបច្ច័យដ៏ពិសេស ) , ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ហៅចំពោះធម៌ ៤ យ៉ាងពួកនេះប៉ុណ្ណោះថា **អាហារ** ។

តើដូចម្តេច ? គឺថា ក្នុងបណ្តាអាហារពួកនេះ អាហារដំបូងកំពុងជាបច្ច័យក្នុងកលាបៈណា ដល់រូបធម៌ទាំងឡាយដែលទាក់ទងក្នុងកលាបៈនោះ តាមសមគួរនោះហើយ ក៏នៅនាំយករូប មានឱជាជាទី ៨ មក , អាហារប្រភេទទី ២ តែងនាំវេទនា ៣ មក , អាហារប្រភេទទី ៣ តែងនាំបដិសន្ធិក្នុងភព ៣ មក , អាហារប្រភេទ

ទី ៤ តែងនាំនាមរូបក្នុងខណៈបដិសន្ធិមក ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា កពឡិង្ការាហារនាំរូបមានឱជាជាទី ៨ មក ដូច្នេះជាដើម ,ម្យ៉ាងទៀត ក្នុងបណ្តាអាហារពួកនេះ គប្បីឃើញថា ឱជាដែលផ្សេងគ្នា ព្រោះភាពផ្សេងគ្នា ដោយឱជាដែលកើតអំពីកម្មជាដើម កាលមានការបានបច្ច័យ ក៏រមែងនាំរូប មានឱជាជាទី ៨ មក ធ្វើឲ្យតគ្នាទៅបាន ២-៣ ខែ ។ ផស្សាហារដែលផ្សេងគ្នា ព្រោះសេចក្តីផ្សេងគ្នាដោយផស្សៈដែលឧបការដល់សុខវេទនាជាដើម តែងនាំវេទនា ៣ មកតាមសមគួរ , មនោសញ្ចេតនាហារដែលផ្សេងគ្នា ព្រោះសេចក្តីផ្សេងគ្នា មានបុញ្ញាភិសង្ខារជាដើម តែងនាំមកនូវបដិសន្ធិដែលមានវិញ្ញាណ និងមិនមានវិញ្ញាណ តាមសមគួរក្នុងភព ៣ មានកាមភពជាដើម , វិញ្ញាណាហារតែងនាំមកនូវនាម រូប និងរូបនាម ក្នុងខណៈបដិសន្ធិតាមសមគួរដល់បច្ច័យដូច្នេះ ។ ន័យម្យ៉ាងទៀត លោកហៅធម៌ ៤ យ៉ាងពួកនេះប៉ុណ្ណោះថា **អាហារ** ដោយសេចក្តីថា ជាធម៌អ្នកឧបត្ថម្ភ ។ ដូចជាកពឡិង្ការាហារជាបច្ច័យ ដោយសេចក្តីថា ជាអ្នកឧបត្ថម្ភរូបកាយយ៉ាងណា នាមអាហារទាំងឡាយក៏ជាបច្ច័យ ដោយជាអ្នកឧបត្ថម្ភសម្បយុត្តធម៌ទាំងឡាយក៏ដូច្នោះ ។ ពិតយ៉ាងនោះ ទ្រង់ត្រាស់ទុកថា កពឡិង្ការាហារ រមែងជាបច្ច័យដល់កាយនេះ ដោយអាហារប្បច្ច័យ , នាមអាហារទាំងឡាយ រមែងជាបច្ច័យដល់សម្បយុត្តធម៌ទាំងឡាយ និងដល់រូបទាំងឡាយ ដែលមានសម្បយុត្តធម៌នោះជាសមុដ្ឋាន ដោយអាហារប្បច្ច័យដូច្នេះ ។

នៅមានន័យម្យ៉ាងទៀត កវឡិង្ការាហារ និងធម៌ ៣ យ៉ាង មានផស្សៈជាដើម លោកហៅថា អាហារ ព្រោះជាបច្ច័យពិសេសដល់ការបន្តខាងក្នុង ។ សេចក្តីពិតថា កពឡិង្ការាហារជាបច្ច័យពិសេសដល់រូបកាយរបស់សត្វទាំងឡាយ អ្នកបរិភោគ

កពឡិង្ការាហារ ។ ក្នុងផ្នែកនាមកាយ ផស្សៈជាបច្ច័យដល់វេទនា ។ មនោសញ្ចេតនាជាបច្ច័យដល់វិញ្ញាណ , វិញ្ញាណជាបច្ច័យដល់នាមរូប , ដូចដែលទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ កាយនេះមានការតាំងនៅបានដោយអាហារ , អាស្រ័យអាហារទើបតាំងនៅបាន , មិនមានអាហារក៏តាំងនៅមិនបាន យ៉ាងណា ព្រោះមានផស្សៈជាបច្ច័យ វេទនាទើបតាំងនៅបាន ។ ព្រោះមានសង្ខារជាបច្ច័យ វិញ្ញាណទើបតាំងនៅបាន ។ ព្រោះវិញ្ញាណជាបច្ច័យ នាមរូបទើបតាំងនៅបានក៏យ៉ាងនោះ ដូច្នេះឯង ។

ពាក្យថា **ព្រោះកពឡិង្ការាហារ** គឺ ព្រោះអាហារដែលធ្វើឲ្យជាពុំនូតៗ រមែងមាននិកន្តិ ( សេចក្តីប្រាថ្នា ) បានដល់ តណ្ហា , ឈ្មោះថា ជាភ័យ ក៏ព្រោះនាំមកនូវហាយនភាព( ការវិនាស ) ។ ពិតមែន ការបរិភោគអាហាររបស់បុគ្គលអ្នកមានចិត្តជាប់ជំពាក់ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ។ ពាក្យថា **កពឡិង្ការាហារេ** នេះជាសត្តមីវិភត្តក្នុងអត្ថថា ហេតុ ។ ក្នុងអាហារដ៏សេស ក៏យ៉ាងនេះ ។ ពាក្យថា **និកន្តិ** ប្រែថា សេចក្តីប្រាថ្នា បានដល់ ឆន្ទរាគៈ ។ បុគ្គលតែងខ្លាចចំពោះវត្ថុនេះ ព្រោះហេតុនោះ វត្ថុនេះទើបឈ្មោះថា ភ័យ , ភ័យ គឺ **និកន្តិ** ឈ្មោះថា **និកន្តិភយំ** ។ ឆន្ទរាគៈរបស់សត្វទាំងឡាយពួកនេះ ព្រោះហេតុនៃកពឡិង្ការាហារ ឈ្មោះថា ជាភ័យ គឺជារបស់គួរខ្លាច ក៏ព្រោះភាពជាហេតុនៃសេចក្តីវិនាសដែលមានប្រភេទជាការវិនាសក្នុងអត្តភាពនេះជាដើម គឺ វដ្តទុក្ខទាំងអស់ ។ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើថា រាគៈនៅក្នុងកពឡិង្ការាហារមានពិត **នន្ទិ** ( សេចក្តីត្រេកត្រអាល ) ក្នុងកពឡិង្ការាហារមានពិត តណ្ហាក្នុងកពឡិង្ការាហារមានពិត វិញ្ញាណ ក៏មានការតាំងមាំ ដុះដាល

ក្នុងភពឡើងកាហារនោះបាន ដូច្នេះជាដើម ។ ឈ្មោះថា **ឧបគមន** ( ការជាប់ជំពាក់ ) បានដល់ ការប្រជុំ ការព្រមព្រៀងដោយអារម្មណ៍របស់អ្នកលះវិបល្លាសមិនទាន់បាន ។ ការឧប្បត្តិនៃផស្សៈ មានផស្សៈដែលឧបការដល់សុខវេទនាជាដើម ឈ្មោះថា ជាភ័យ គឺជារបស់គួរខ្លាច ព្រោះជាហេតុមិនផុតចាកសេចក្តីទុក្ខ ៣ យ៉ាង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាស្រ័យផស្សៈជាបច្ច័យដល់សុខវេទនា សុខវេទនាក៏កើតឡើង ព្រោះវេទនាជាបច្ច័យ តណ្ហាក៏កើតឡើង ។ល។ ការកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការយ៉ាងនេះ ដូច្នេះ ។ ឈ្មោះថា **ឧប្បត្តិ** ព្រោះអត្ថថា ជាហេតុចូលទៅកើតឡើងក្នុងភពនោះៗ , ម្យ៉ាងទៀត ការចូលទៅឈ្មោះថា **ឧប្បត្តិ** បានដល់ ការបន្សាត់ទៅ ឈ្មោះថា ជាភ័យ គឺជារបស់គួរខ្លាច ក៏ព្រោះមិនផុតចាកសេចក្តីវិនាសទាំងឡាយ ដែលមានឧប្បត្តិជាមូល ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលអ្នកមិនដឹង បើតាក់តែងបុញ្ញាភិសង្ខារ បុញ្ញូបគវិញ្ញាណ ( វិញ្ញាណដែលចូលទៅព្រោះបុណ្យ ) ក៏រមែងកើតឡើង ។ បើតាក់តែងអបុញ្ញាភិសង្ខារ អបុញ្ញូបគវិញ្ញាណ ( វិញ្ញាណដែលចូលទៅព្រោះបាប ) ក៏រមែងកើតឡើងដូច្នេះជាដើម ។ ពាក្យថា **បដិសន្ធិ** បានដល់ ការបន្តជាមួយនឹងភពដទៃជាដើម នោះឈ្មោះថា ជាភ័យ គឺជារបស់គួរខ្លាច ក៏ព្រោះជាហេតុមិនផុតចាកទុក្ខទាំងឡាយ ដែលមានបដិសន្ធិជាហេតុ ។ ព្រោះហេតុនោះទើបទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បើរាគៈក្នុងវិញ្ញាណាហារមានហើយ នន្ទិ គឺការត្រេកត្រអាលក្នុងវិញ្ញាណាហារមានហើយ តណ្ហាក្នុងវិញ្ញាណាហារមានហើយ វិញ្ញាណក៏មានការតាំងមាំល្អលាស់ក្នុងវិញ្ញាណាហារនោះបាន ដូច្នេះជាដើម ។

បណ្ឌិតគប្បីសម្តែងកពឡិង្ការាហារ ដោយព្រះឱវាទដែលមានឧបមាដូចសាច់កូន ដើម្បីប្រយោជន៍ដល់ការបរិភោគ ដោយមិនមានឆន្ទរាគៈ ។ ព្រោះថា ភ័យ គឺ និកន្តិក្នុងកពឡិង្ការាហារនោះ រមែងមិនមាន ក៏ដោយប្រការយ៉ាងនេះ ឈ្មោះថា មេគោអត់ស្បែក ចូលទៅក្នុងស្ថានទីណាៗ សត្វទាំងឡាយក៏នឹងចឹកខាំវាក្នុងទីនោះៗ ជារឿយៗ ។ សម្រាប់ព្រះយោគាវចរ អ្នកឃើញនូវទោសក្នុងផស្សៈថា កាលមានផស្សៈ វេទនាក៏រមែងកើតឡើង វេទនាបណ្ឌិតគប្បីឃើញដូចជាកូនសរ គឺទុក្ខ ពិតដូច្នេះយ៉ាងនេះ ភ័យ គឺឧបគមនៈ ( ការជាប់ជំពាក់ ) ក៏រមែងមិនមាន ព្រោះហេតុនោះ ទើបលោកពោលថា គប្បីសម្តែងផស្សាហារដោយឱវាទដែលមានឧបមាដូចមេគោអត់ស្បែកដូច្នេះ ។ កាលព្រះយោគាវចរសម្លឹងឃើញថា ភពទាំង-ឡាយដូចរណ្តៅរងើកភ្លើង ព្រោះត្រូវភ្លើង ១១ កង ឆេះរោលរាលគ្រប់ទិសទីដូច្នេះ ភ័យ គឺ ឧប្បត្តិ ( ការចូលទៅក្នុងភព ) ក៏រមែងមិនមាន ព្រោះហេតុនោះ ទើបលោកពោលថា គប្បីសម្តែងមនោសញ្ចេតនាហារ ដោយព្រះឱវាទដែលមានឧបមាដូចរណ្តៅរងើកភ្លើង ដូច្នេះ ។

កាលព្រះយោគាវចរយល់ឃើញដោយប្រពៃដូច្នេះថា វិញ្ញាណដូចជាចោរ ព្រោះធ្វើឲ្យធ្លាក់ទៅក្នុងការវិនាស វេទនាដូចជាការទម្លាយ ព្រោះមានសេចក្តីអន់ធន់បានដោយលំបាក ដូច្នេះ ភ័យ គឺ បដិសន្ធិក៏រមែងមិនមាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គប្បីសម្តែងវិញ្ញាណាហារ ដោយព្រះឱវាទដែលមានឧបមាដូចចុងលំពែង ដូច្នេះ ។

លោកអាចារ្យ កាលបានបើកបង្ហាញទោសក្នុងអាហារទាំងឡាយ ដោយកិច្ចជាដើមជាសំខាន់យ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងដកយកអាហារតាមដែល

ប្រាថ្នាក្នុងបណ្តាអាហារទាំងនោះ សម្តែងវិធីមនសិការដោយភាពជារបស់បដិកូល ទើបពោលថា ក៏ក្នុងបណ្តាអាហារទាំង ៤ យ៉ាងពួកនេះ ដូច្នេះជាដើម ។ ព្រោះមកក្នុងឧបាទាយរូបនិទ្ទេសថា កពឡិង្ការាហារ ដូច្នេះ លោកអាចារ្យទើបពង្រីកសេចក្តីឲ្យពិសេសទៅជាងនោះ ពោលថា ដែលមានប្រភេទជារបស់ស៊ី របស់ក្រេបផឹក របស់ទំពា របស់លិទ្ធភក្សដូច្នេះ ឬថា ពាក្យថា **ដែលមានប្រភេទជារបស់ស៊ី របស់ក្រេបផឹក របស់ទំពា របស់លិទ្ធភក្ស** នេះជាពាក្យពោលដល់តួភូតរូប ( ដែលជាទីអាស្រ័យនៃឱជា ) ។ ក្នុងពាក្យទាំងនោះ ពាក្យថា ឯ **អត្ថន័យដែលមានប្រភេទជារបស់ស៊ី របស់ក្រេបផឹក របស់លិទ្ធភក្ស** គឺ មានការចែកជារបស់គួរបរិភោគ របស់គួរក្រេបផឹក របស់គួរទំពា របស់គួរលិទ្ធភក្ស ព្រោះមិនមានសេចក្តីត្រូវការដោយការនិយាយដល់ភាពផ្សេងគ្នានៃកាល សេចក្តីថារបស់ដែលបានបរិភោគហើយក្តី កំពុងបរិភោគក្តី នឹងបរិភោគក្តី ក៏ហៅថា **អសិត** ទាំងអស់ **អសិត** សំដៅដល់របស់ដែលគួរបរិភោគប៉ុណ្ណោះ យ៉ាងនេះជាដើម ដូចពាក្យថា **ទុទ្ធំ** សំដៅដល់ ទឹកដោះដែលគប្បីរីតចេញប៉ុណ្ណោះ ដូច្នោះ ។ ពាក្យថា អវធារណៈ " កំណត់យកសេចក្តីថា **កពឡិង្ការាហារោ** " គប្បីឃើញថា លោក **បដិសេធអាហារ** គឺ តួឱជាដែលដូចជាបដិសេធនាមអាហារ ៣ មានផស្សាហារជាដើម ។ ពិតមែន អាហារដែលប្រព្រឹត្តទៅជាមួយនឹងវត្ថុ មានបាយទឹកជាដើមប៉ុណ្ណោះដែលជាកម្មដ្ឋានក្នុងទីនេះ ព្រោះហេតុនោះ បណ្ឌិតឃើញន័យក្នុងពាក្យថា អាហារនេះ យ៉ាងនេះថា ឈ្មោះថា **អាហារ** ព្រោះអត្ថថា ដែលគេតែងនាំមក គឺលេបចូល ។ ចំណែកសេចក្តីដែលថា **អាហរតីតិ អាហារោ** ឈ្មោះថា អាហារ ព្រោះអត្ថថា **នាំមក** ដូច្នេះ បណ្ឌិតគប្បីជ្រាបដោយទាក់ទងនឹងឱជាដែលធ្វើឲ្យកើត

ឡើង ។ ពាក្យថា **ក្នុងអត្ថនេះ** មានសេចក្ដីថា ក្នុងអត្ថពោលគឺកម្មដ្ឋាននេះ ។ ពាក្យថា **សញ្ញាដែលកើតឡើង** លោកពោលដល់ការនា ដោយមានសញ្ញាជាប្រធាន ។ ពិតយ៉ាងនោះ លោកពោលថា ក៏ដោយអំណាចការកាន់យកអាការដែលជាបដិកូល ដូច្នេះជាដើម ។

ពាក្យថា **រៀនយកកម្មដ្ឋាន** គឺធ្វើកម្មដ្ឋានឲ្យជាចំណែកកាន់យកដោយល្អ ឲ្យជាការចាំទុកក្នុងចិត្ត ដោយបរិយត្តិធម៌ និងដោយពាក្យអត្ថាធិប្បាយ ព្រោះហេតុនោះ លោកទើបពោលថា មិនធ្វើឲ្យឃ្លាងឃ្លាតចាកការរៀន សូម្បី ១ បទ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ចាកការរៀន** គឺចាកការរៀនអំពីអាចារ្យ ។ ពាក្យថា **សូម្បីត្រឹមតែមួយបទ** គឺសូម្បីតែមួយបទ ឬ សូម្បីតែក្រុមមួយ មានសេចក្ដីថា សូម្បីត្រឹមតែចំណែកមួយ ។ ព្រោះហេតុអ្វី ទើបលោកពោលថា ដោយអាការ ១០ ដូចនេះហ្ន៎ ។ ព្រះយោគីគប្បីពិចារណាភាពបដិកូលក្នុងអាហារ ដោយអាការជាដើមយ៉ាងនេះថា ដោយការៈជាវិធីចិញ្ចឹមជីវិតដ៏ទាបបំផុត ។ ដោយការកើតឡើងនៃភាពញាប់ញ័រចិត្ត និងការជាប់ជំពាក់ ព្រោះការមិនបាន និងការបានបិណ្ឌបាត ព្រោះការដែលបរិភោគអាហារហើយ ធ្វើការស្រវឹងឲ្យកើត , ការធ្វើពួកជនវិឲ្យឆ្អែត ដូច្នេះក៏បាន មិនមែនឬ ? ខនេះសមដូចដែលទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ វិធីចិញ្ចឹមជីវិតដ៏ទាបបំផុត ក្នុងវិធីចិញ្ចឹមជីវិតទាំងឡាយនេះ គឺការត្រាច់បិណ្ឌបាត ម្នាលភិក្ខុទាំងឡាយ ពាក្យនិយាយមើលងាយក្នុងលោកទាំងនេះថា មនុស្សស៊ុំជុំបាយគេបរិភោគ មានដៃកាន់បាត្រត្រាច់ទៅដូច្នេះថា លុះមិនបានបិណ្ឌបាតក៏ញាប់ញ័រចិត្ត និងបានបិណ្ឌបាតក៏ជាប់ជំពាក់ ងប់ជ្រប់ លិចលង់ មិនសម្លឹងឃើញទោស មិនមានបញ្ញាលះបង់ បរិភោគដូច្នេះ , ម្យ៉ាងទៀត អាហារដែល

បរិភោគហើយ ជួនកាលក៏នាំមកនូវសេចក្ដីស្លាប់ ឬទុក្ខស្មើរតែនឹងស្លាប់ដល់បុគ្គល ពួកខ្លះ ពួកដង្កូវទាំងឡាយដែលមានប្រភេទជាពួកដង្កូវ ៣២ ត្រកូល មានពួក ឧកកោចកៈ( ពួកដង្កូវជញ្ជូនអាហារឲ្យពួកដង្កូវដទៃស៊ី )ជាដើម និងពួកតកោដកៈ ( ព្រូនទំពក់ ) ជាដើម រមែងអាស្រ័យអាហារដែលលេប បរិភោគទៅនោះ រស់ នៅដូច្នេះ ។

សូមឆ្លើយថា ជាដំបូងនឹងពោលទៅថ្មីដល់ការមនសិការ ជាវិធីចិញ្ចឹមជីវិតដ៏ ទាបបំផុត ដោយគិតថា សូមឲ្យយើងកុំគប្បីដូចជាអង្កត់អុសដុតខ្មោច ដូច្នេះ ទៀតសោត ព្រោះព្រះយោគីមានការបំពេញកម្មដ្ឋាន ដើម្បីជម្រះភាពសៅហ្មង នៃចិត្តហើយ យ៉ាងនោះដូចគ្នា នឹងពោលទៅថ្មីដល់ការត្រូវប្រឹងហាមការកើតឡើង នៃការញាប់ញ័រចិត្ត និងការជាប់ជំពាក់ជាដើម ព្រោះការមិនបាន និងការបាន បិណ្ឌបាតទៀតសោត ព្រោះព្រះយោគីអ្នកមានសីលបរិសុទ្ធល្អ មានការពិចារណា ក៏មិនមានការញាប់ញ័រចិត្ត និងការជាប់ជំពាក់ដោយពិត ។ ការស្រេវឹងក្នុងកត្ត ក៏ គប្បីជ្រាបថា រមែងមានជាប្រចាំ ឬថា រួមចុះក្នុងការបរិភោគ ។ តែមិនគួរបន្ថែម ចំនួនពួកដង្កូវចូលឡើយ ឬថា ជាចំណែកបន្ថែមហើយ ក៏ព្រោះក្នុងពាក្យថា ដោយ អាការ ១០ នេះ លោកមិនបានធ្វើការកំណត់ពិតប្រាកដទេ ។ ម្យ៉ាងទៀត គប្បី ឃើញថា មានការសង្គ្រោះអាការក្រៅពីនេះ ចូលក្នុងអាការ ១០ នេះ តាមន័យនេះ ព្រោះក្នុងអាការ ១០ នេះ លោកសង្គ្រោះយកការពិចារណាភាពជាបដិកូលទៅតាម សមគួរដល់ការដែលមាន ។ ដូចជាវត្ថុដែលមានអាចម៍តុកកែ អាចម៍កណ្ដុរ អាចម៍ ប្រចៀវជាដើម ដែលលោកកាន់យកហើយ មិនជាវត្ថុដែលមានទៅជាប្រចាំទេ ដូច្នេះឯង ។ ដូចគ្នានេះដែរ សូម្បីក្នុងអាការទាំងឡាយ មានការស្វែងរកជាដើម ក៏

គប្បីពោលទៅតាមសមគួរដល់ការដែលមាន ។

ក្នុងអាការទាំងឡាយថា **គមនតោ** ដោយការទៅជាដើម គប្បីជ្រាបថា សូម្បីការត្រឡប់មក ក៏មានការសង្គ្រោះដោយការទៅនោះឯង ព្រោះមានចំណែកដូចគ្នានឹងការទៅ ។ ក៏ការចូលទៅក្នុងសាលាជាដើម ក្នុងវេលាត្រឡប់មក ក៏ជារបស់បដិកូលដរាបដូចគ្នានឹងក្នុងគ្រាដែលស្វែងរក ព្រោះត្រូវអត់ធន់ក្នុងការឃើញរូបដែលគួរខ្ពើម និងហិតក្លិនស្អុយ ក្នុងពេលដែលឈានជាន់ស្ថានទីដែលមិនស្អាត ។ ពាក្យថា **ដោយការទៅ** គឺដោយការឆ្ពោះទៅកាន់គោចរគ្រាម ( ចន្លោះស្រុកដែលត្រាច់បិណ្ឌបាត ) ដោយជាប់ទាក់ទងនឹងកិច្ចាចារ ( ត្រាច់ទៅស្វែងរកអាហារ ) ។ ពាក្យថា **ដោយការស្វែងរកអាហារ** គឺដោយការត្រាច់ទៅក្នុងគោចរគ្រាម ដើម្បីប្រយោជន៍ដល់កិច្ចាហារ ។ ពាក្យថា **ដោយការបរិភោគ** គឺ ដោយការបរិភោគអាហារ ។ ឈ្មោះថា **អាសយ** ( អាស្រ័យ ) ព្រោះអត្ថថា ជារបស់ពីរយ៉ាងអាស្រ័យនៅជាប់នឹងរបស់ពីរយ៉ាងទៀត , ទោះបីថាប្រព្រឹត្តទៅរួមគ្នាក៏ជារបស់ដែលតាំងចុះ ព្រោះកម្លាំងរបស់កម្ម អាស្រ័យ គឺ តាំងនៅ ប្រព្រឹត្តទៅដោយមិនច្រឡូកច្រឡំគ្នានិងគ្នា ដោយអំណាចនៃព្រំដែន , បានដល់ កោដ្ឋាស ៤ យ៉ាង មានទឹកប្រមាត់ជាដើម ដែលតាំងនៅលើក្រពះអាហារថ្មី ។ **អា**-អក្សរ ( ក្នុងបទថា **អាសយ** ) នេះ មានអត្ថថា ព្រំដែន បានដល់ គប្បីពិចារណាភាពជាបដិកូលដោយអាសយៈ កោដ្ឋាសដែលជាទីអាស្រ័យនោះ ។ ឈ្មោះថា **និធាន** ទីសន្សំទុក ព្រោះអត្ថថា ជាកន្លែងអាហារតាមដែលបរិភោគហើយត្រូវកប់ គឺ សន្សំទុក បានដល់ ក្រពះអាហារថ្មី បានដល់ គប្បីពិចារណាភាពជាបដិកូល ដោយ**និធាន**-ទីសន្សំនោះ ។ ពាក្យថា **ដោយភាពជាអាហារដែលមិនទាន់រលាយ** គឺ អាហារដែល

នៅមិនរលាយទៅ ព្រោះភ្លើងធាតុដែលកើតអំពីកម្ម ដែលហៅថា ភ្លើងធាតុរំលាយអាហារ ។ ពាក្យថា **ដោយជាអាហារដែលរំលាយហើយ** គឺ ដោយភាវៈដែលជាអាហារតាមដែលបានបរិភោគហើយជារបស់រលាយហើយ ។ ពាក្យថា **ដោយផល** គឺ ដោយផលដែលកើតឡើង ។ ពាក្យថា **ដោយការហូរចេញ** គឺដោយការហូរប្រឡាក់ទៅខាងទ្វារនោះទ្វារនេះ ។ ពាក្យថា **ដោយការប្រឡាក់ប្រឡូស** គឺដោយការប្រឡាក់ប្រឡូសដោយប្រការទាំងពួង មានសេចក្ដីថា គប្បីពិចារណាភាពជារបស់បដិកូលក្នុងអាហារដោយអាការទាំងពួង ។ ក៏ពាក្យនិយាយដែលមានតាមលំដាប់ ចាប់តាំងពីពាក្យថា **គមនតោ** ( ដោយការទៅ ) ជាដើមនេះ លោកតាំងទុកដោយអំណាចលំដាប់នៃការកើតឡើងនៃកិរិយានោះៗ ។ ចំណែកឯការប្រឡាក់ប្រឡូស សូម្បីក្នុងពេលបរិភោគជាដើម ក៏ជារបស់បដិកូល ដោយពិសេសព្រោះការចេញ ( ក្អួតចេញ ) ព្រោះហេតុនោះ ទើបលោកតាំងទុកចុងក្រោយបំផុត ។

ពាក្យថា **មានអានុភាពច្រើនយ៉ាងនេះ** លោកពោលថា មានអានុភាពច្រើនក៏ដោយខបដិបត្តិដែលនឹងពោលដល់ក្នុងពេលឥឡូវនេះ ម្យ៉ាងទៀត លោកអាចារ្យកាលសម្ដែងថា ព្រះយោគាវចរ គប្បីធ្វើលំអនៃព្រះធម៌ ឲ្យសម្រេច ព្រោះការបរិហារសព្វត្ថកកម្មដ្ឋានជាដើមឲ្យចេញមុខ ហើយបដិបត្តិយ៉ាងនេះទៅចុះ ដូច្នេះ ទើបពោលថា ក្នុងព្រះសាសនាឈ្មោះថាមានអានុច្រើនយ៉ាងនេះ ដូច្នេះជាដើម ។ ក្នុងពាក្យនោះ **នាម** ស័ព្ទ ( ប្រែថា ឈ្មោះថា ) គប្បីឃើញក្នុងសេចក្ដីថា លើកតម្កើង ។ មានសេចក្ដីថា បព្វជិតគប្បីជាអ្នកឆ្ពោះមុខទៅកាន់ចន្លោះស្រុក ត្រាប់ទៅ ។ លោកអាចារ្យកាលសម្ដែងថា ក៏ការពិចារណាដោយការទៅជាដើមនេះ មិនជាអត្ថុទ្ទេសិក ( លើកសម្ដែងចំពោះខ្លួនប៉ុណ្ណោះទេ ។ តែជាជាអនុទ្ទេសិក ( មិន

សម្តែងចំពោះ ) ឡើយ ទើបកំណត់កាន់យកធុរៈទាំងពីរ ដោយពាក្យថា **សកលរត្តិំ** រហូតអស់រាត្រីដូច្នេះជាដើម ។ ពាក្យថា ( **បោសសម្មាត** ) **បរិវេណ** គឺទីលានដែលជាបរិវេណ ។ ក្នុងពាក្យថា ២០-៣០ ភារៈ នេះ លោកអាចារ្យពួកខ្លះពោលថា ការកំណត់ភារៈ ( ថា ១ ភារៈ ២ ភារៈជាដើម ) រមែងមានដោយអំណាចសន្តតិបច្ចុប្បន្ន , ចំណែកអាចារ្យមួយពួកទៀតពោលថា រមែងមានដោយអំណាចអាសនៈដែលក្តៅឡើង ។ ពិតមែន ភាវនាដែលនៅមិនទាន់ដល់ការគ្រប់សង្កត់នីវរណៈបាន រមែងបន្ទោបង់ការចុករោយកាយ ដោយអំណាចការអង្គុយយូរៗមិនបានឡើយ ព្រោះនៅមិនទាន់មានផរណាបីតិ ( បីតិផ្សាយទៅ ) ព្រោះហេតុនោះ ទើបមានការប្រែប្រួល( ប្តូរ )ឥរិយាបថតែម្តង។ ការកាន់យក ២០-៣០ភារៈលោកពោលទុកដោយការជាប់ទាក់ទងនឹងពេលត្រាច់បិណ្ឌបាតតាមដែលបានកំណត់ទុក ( គឺមនសិការកម្មដ្ឋានបាន ២០-៣០ ភារៈហើយ ក៏ល្មមដល់ពេលត្រាច់ទៅបិណ្ឌបាត ) ។ ន័យម្យ៉ាងទៀត ការមនសិការចាប់តាំងពីការទៅ រហូតដល់ការប្រឡាក់ប្រឡូសចាត់ជាភារៈមួយ , ព្រះយោគីមនសិការកម្មដ្ឋានទៅ ២០-៣០ ភារៈយ៉ាងនេះ ។ ពាក្យថា **មិនច្របូកច្របល់ដោយពួកមនុស្ស** គឺ ប្រាសចាកភាពអ៊ូអែរដោយពួកមនុស្ស , ពាក្យនោះ លោកសម្តែងដល់ភាពជាស្ថានទីដែលមានមនុស្សតិច ភាពជាស្ថានទីមានសំឡេងតិច និងភាពជាស្ថានទីដែលមិនមានសំឡេងអឺងកង ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **មានបវិវេកសុខ** គឺ គួរប្រាថ្នាព្រោះការស្ងាត់ចាកពួកមនុស្ស ឬថា ជាស្ថានទីដែលមានឧបការដល់ **បវិវេក** គឺការបំពេញឈាន ។ ពីរបទមុន ៗ ជាពាក្យប្រាប់ដល់ហេតុនៃពីរបទក្រោយ ៗ យ៉ាងនេះថា ព្រោះហេតុដែលសម្បូណ៌ម្លប់ឈើ និង ទឹកដូច្នេះ ទើបគួរជាទីរីករាយ

ព្រោះហេតុជាទីស្អាត ដូច្នោះ ទើបជាភូមិភាគដែលគួររីករាយដូច្នេះ ។ បទថា **អរិយំ** ( ដ៏ប្រសើរ ) គឺ មិនមានទោស ។ ពាក្យថា **ឈ្មោះថាសេចក្ដីត្រេកអរក្នុងវិវេក** គឺ សេចក្ដីត្រេកអរក្នុងការបំពេញឈាន ។

ឈ្មោះថា ស្ថានទីនៅរបស់ព្រះយោគាវចរ ដែលបានជម្រះហើយ បានបោស សម្អាតល្អហើយក៏ពិត សូម្បីដូច្នោះ ពេលខ្លះ ក្រោយការជម្រះ ក៏គប្បីមានភាព បដិកូល យ៉ាងនេះបានទៀត ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា លោក អាចារ្យពោលថា កន្ទែងប្រឡាក់ធូលីជាប់ជើង និងអាចម៍តុក្កែជាដើម ក៏ដើម្បី សម្ដែងវិធីឲ្យកើតការពិចារណាដល់ភាពជាបដិកូល ។ ក្នុងពាក្យទាំងនេះ ពាក្យថា **កម្រាល** លោកពោលដល់គ្រឿងកម្រាល មានព្រំស្លឹកឈើជាដើម ដែល ត្រូវក្រាលទុកដើម្បីរក្សាផ្ទៃដី ឈ្មោះថា **ជតុកា** បានដល់ ប្រចៀវប្រភេទតូចៗ ។ ពាក្យថា **ព្រោះសាបសូន្យ** គឺ ព្រោះត្រូវប្រទូសរ៉ាយ ។ បទថា **តតោ** គឺ បន្ទាប់នោះទៅ តពីនោះទៅ បណ្ឌិតគប្បីនាំយកបទថា **អប្បេកទា**-ម្ដងម្កាល ) មកសម្ពន្ធ សេចក្ដីក្នុងបទថា **ឧលូកបារាវតាទិ** នេះថា **អប្បេកទា ឧលូកបារាវតាទិ** ( ប្រែ ពេញសេចក្ដីថា ព្រោះប្រឡាក់ប្រឡូសទៅដោយអាចម៍ទីទុយ អាចម៍ព្រាប ជាដើមម្ដងម្កាល ។ ដោយ **អាទិ** សព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **ឧទកចិក្ខ-ល្លាទីហិ** ដោយប្រឡាក់កក់ជាដើម លោករួមយកកម្ទេចកំទី( សម្រាម ) ចូលទុក ផង ។ ផ្លូវអំពីបរិវេណចូលទៅក្នុងទីលានវិហារ ឈ្មោះថា ផ្លូវដើរទៅកាន់វិហារ ។

ពាក្យថា **កន្លែងរោងត្រិះរិះ** គឺ ត្រង់រោងត្រិះរិះ ដោយន័យថា ថ្ងៃនេះ យើង គប្បីត្រាច់ទៅដើម្បីភិក្ខាក្នុងទីណាហ្ន៎ ដូច្នេះជាដើម ។ ពាក្យថា **ផ្លូវទៅកាន់លង្វែក ស្រុក** គឺ ផ្លូវទៅកាន់លង្វែកស្រុក ។ បទថា **ខានុកណ្ដកមគ្គោ** ប្រែថា ផ្លូវដែល

ដែលមានដង្កត់ និងបន្ទា ។ ពាក្យថា **ត្រូវឃើញ** គឺត្រូវមើល ប្រើក្រសែភ្នែក ត្រួតពិនិត្យមើលផ្លូវ ។

ពាក្យថា **ដូចគ្នានឹងការបិទបូសជាដើម** ជាពាក្យសម្ដែងវត្ថុថា ព្រះយោគាវចរ អ្នកមានអធ្យាស្រ័យយ៉ាងនេះ គប្បីធ្វើការស្លៀកដណ្ដប់ជាដើម ដូចគ្នានឹងមនុស្ស ដែលកើតរោគបូសបិទបូស ដើម្បីចៀសវាងអន្តរាយ មានខ្យល់ កម្ដៅថ្ងៃជាដើម ដូច្នេះ ។ ន័យម្យ៉ាងទៀត មានការត្រូវនាំយក **គណ្ឌ** ស័ព្ទ ប្រែថា បូស ស័ព្ទមួយ មកសម្ពន្ធសេចក្ដីទុកថា **គណ្ឌំវិយគណ្ឌំ បដិច្ឆាទយមានេន** ( បិទបូស គឺកើតដូចបូស ) ។ ពាក្យថា **បូស** ជាពាក្យបរិយាយដល់អត្តភាព តាមព្រះពុទ្ធវចនៈដែលថា **គណ្ឌោតិ ខោ ភិក្ខវេ បញ្ចន្នេតំ ឧបាទានក្ខន្ធានំ អធិវចនំ** ( ម្នាលភិក្ខុទាំងឡាយ ពាក្យថា **បូសនេះ** ជាឈ្មោះរបស់ឧបាទានក្ខន្ធ ៥ ) ដូច្នេះ ជាពិសេសបានដល់ ភាពជាទុក្ខនៃរូបកាយ ព្រោះការប្រកបដោយការឈឺចាប់ ជាទីហូរចេញនៃវត្ថុ ស្មោកគ្រោក ព្រោះការហើមប៉ោងឡើង ស្អុយរលួយបែកធ្លាយទៅ ដោយការកើតឡើង ដោយការចាស់ទុំ និងដោយការរលត់ ។ ពាក្យថា **សំពត់រុំដំបៅ** បានដល់ ផ្ទាំងសំពត់ប្រើបិទដំបៅ ។ ពាក្យថា **នាំចេញអំពីបាត្រ** គឺលើកចេញពី ស្មោកបាត្រ ។ **បិ** ស័ព្ទក្នុងបទថា **គុណបានិបិ** សូម្បីសាកសពប្រព្រឹត្តទៅក្នុង អត្ថថា ទិតៀន មានសេចក្ដីថា ត្រូវឃើញនូវសាកសពទាំងឡាយនោះដូច្នេះ ។ ម្យ៉ាងទៀត ប្រព្រឹត្តទៅក្នុងអត្ថថា សម្ដែងដល់ការមានពិត មានន័យថា សូម្បី សាកសពនេះក៏មាននៅក្នុងទីជិតស្រុកនោះ ។ ពាក្យថា **ត្រូវអត់ធន់** គឺចាំបាច់ត្រូវ អត់ធន់ ព្រោះការមិនបានអាហារដោយប្រការដទៃ ។ ពាក្យថា **ត្រង់ផ្លូវចូលល្វែកស្រុក** គឺ ទីជិតផ្លូវចូលល្វែកស្រុក ឬថា ត្រង់ចន្លោះធរណីទ្វារ ។ ឈ្មោះថា

**គាមវប្ហា** ( ផ្លូវដើរក្នុងលំនៅស្រុក ) ។ ជាផ្លូវដើរដែលត្រូវឆ្លងកាត់ចូលទៅក្នុងលំនៅស្រុក អធិប្បាយថា ព្រះយោគីអ្នកមានចក្ខុសម្ពឹងមើលមួយជួរទឹម ត្រូវត្រួតពិនិត្យមើល ។

ពាក្យថា **កម្រោលជាដើម** គឺប្រភេទកម្រោលដែលប្រឡាក់ប្រឡូសទៅដោយអាចម៍តុកកែជាដើម ។ ក្នុងពាក្យថា **មានសាកសពសត្វជាច្រើន ជាបរិយោសាននេះ** គួរចំណាយយកការត្រូវត្រួតមើលផ្លូវក្នុងលំនៅស្រុក ដែលពាសពេញដោយមនុស្សអ្នកស្លៀកមិនរៀបរយ ដណ្តប់មិនរៀបរយមកពោលទុកផង ។ ព្រោះថាសូម្បីដូចដែលពោលនោះ ក៏ចាត់ថា បដិកូលដូចគ្នា ។ ពាក្យថា **អហោវត**( ឱហ្ន៎ ) ជាសព្ទនិបាត ក្នុងអត្ថថា តិះដៀល ។ ពាក្យថា **ភោ** ( លោកដ៏ចម្រើនទាំងឡាយអើយ ) ជាពាក្យស្រែកហៅដោយធម៌ ។ សេចក្តីថា ដរាបដល់អាហារជាបដិកូលឈ្មោះថា សូម្បីការទៅដើម្បីប្រយោជន៍ដល់អាហារណា នេះក៏ជារបស់ដែលគួរវង្វៀស ។

បទថា **គមនបដិកូលំ** មានសេចក្តីថា វត្ថុដែលជាបដិកូល គឺការទៅ ឈ្មោះថា **គមនបដិកូលំ** ។ **បិ** សព្ទ ( ប្រែថា សូម្បី ) ក្នុងពាក្យថា សូម្បីត្រូវអត់ធន់មានអត្ថថា រួបរួម , ដោយ **បិ** សព្ទនោះ លោករួមយកវត្ថុដែលជាបដិកូលនិងពោលដល់ ដោយន័យថា ការផុតទៅអំពីវត្ថុដែលជាបដិកូល សូម្បីត្រឹមប៉ុណ្ណេះមិនមែនទេ ។ វត្ថុជាបដិកូលយ៉ាងច្រើន សូម្បីដទៃអំពីនេះ យើងក៏ត្រូវអត់ធន់ទាំងអស់ដូច្នេះឯង ដូចនេះ ។ ពាក្យថា **ដណ្តប់សំពត់សង្ឃាដិ** គឺមានរាងកាយដណ្តប់ដោយសំពត់សង្ឃាដិ ដែលជាគ្រឿងស្លៀកដណ្តប់មានប្រការកំណត់ ។ ពាក្យថា **ក្នុងទី ( ជាទីដែលខ្វះជាន់តែម្តង )** គឺក្នុងជងផ្លូវទាំងឡាយ ។ ពាក្យថា **រហូតដល់**

**កំភួនជើង** គឺរហូតដល់បរិវេណកំភួនជើង ។ ពាក្យថា **ក្នុងទឹកភក់** គឺក្នុងដីឥដ្ឋលាយទឹក ។ បទថា **ឯកេន ចីវរំ** គឺប្រើដៃម្ខាងលើកចីវរដែលស្លៀក ។ ទឹកឈ្មោះថា **មច្ចធោវនំ**( ទឹកលាងត្រី ) ព្រោះអត្ថថា គេប្រើលាងត្រី ។ **សម្មិស្ស** ស័ព្ទ ( ប្រែថា ប្រឡូកប្រឡល់គ្នា ) គប្បីភ្ជាប់ចូលតែមួយបទ ( គឺដែលប្រឡូកប្រឡល់ជាមួយនឹងទឹក លាងត្រី ដែលប្រឡូកប្រឡល់ជាមួយនឹងទឹកលាងសាច់ ។ ល ។) , ឈ្មោះថា អណ្ដូងមានភក់ ជាទីហូរទៅរួមគ្នានឹងវត្ថុបដិកូលទាំងឡាយមានទឹកលាងមន្ទិលគភ៌ជាដើម ព្រមទាំងភក់ ។ ដែលជាទីពេញប្រៀបទៅដោយវត្ថុស្មោកគ្រោក ជ្រៅដល់ក្បាលជង្គង់ផងដែរ ។ ឈ្មោះថា ថ្លុកទឹកជ្រាំជាទីហូរទៅរួមគ្នានឹងវត្ថុបដិកូលទាំងឡាយ មានទឹកលាងមន្ទិលគភ៌ជាដើមតែម្យ៉ាង មិនមានភក់ទេ ។ បទថា **យតោ** បានដល់ កន្លែងអណ្ដូងភក់ល្បាប់ជាដើម ។ ពាក្យថា **រុយស្រុក** បានដល់ រុយក្បាលខៀវដែលហើរទៅជាក្រុមៗ ក្នុងលំផ្លែកស្រុកនោះ ។ បទថា **និលីយន្តិ** ប្រែថា ជីស្អិត ។ លោកអាចារ្យប្រារព្ធពាក្យថា សូម្បីកាលនឹងឲ្យជាដើម ដើម្បីសម្ដែងថា សូម្បីមនុស្សខ្វះកាលនឹងឲ្យ ក៏មានសេចក្ដីគោរពក្នុងពេលថ្វាយទាន ដោយទាក់ទងនឹងការមានសទ្ធា តែការមិនគោរពដែលប្រព្រឹត្តទៅដោយការទាក់ទងជាមួយអ្នកមិនមានសទ្ធានោះ ជារបស់ដែលគួរដល់ការពិចារណាដោយភាពជាវត្ថុបដិកូល ។ ឈ្មោះថា ក៏ធ្វើជាប្រងើយៗ ដោយគិតថា គេនឹងលះបង់យើងទៅ ដូច្នេះ ។ បទថា **គច្ឆ** ( ចូលទៅ ) គឺ ចូលទៅឲ្យផុត ។ ស័ព្ទថា **រេ** ប្រែថា នេះនែ៎ អើយ ។ ពាក្យថា **មនុស្សក្បាលត្រងោល** ជាពាក្យហៅដែលមិនមានសេចក្ដីអាឡោះអាល័យ ។ បទថា **សមុទាចរន្តិ** ប្រែថា ពោល ។ ព្រោះភាវៈនៃការត្រាច់សូមបិណ្ឌបាត ជាវិធីចិញ្ចឹមជីវិតយ៉ាងទាប ទើបលោកអាចារ្យ

ពោលថា ភិក្ខុត្រូវត្រាច់ទៅក្នុងលំនៅស្រុកដើម្បីបិណ្ឌបាត ហើយចេញមក ដូច មនុស្សកំព្រា ដូច្នោះ ។

បទថា **តត្ថ** ( ក្នុងអាហារនោះ ) គឺ ក្នុងអាហារដែលនៅក្នុងបាត្រនោះ ។ ឈ្មោះថា ក៏ត្រូវអៀនខ្មាស ព្រោះមានការគិតថា លោកមានសេចក្តីសង្ស័យក្នុងចិត្ត ថា អ្នកនេះប្រាថ្នានឹងឲ្យរបស់នៅសល់ដល់យើងឬទេហ្ន៎ ដូច្នេះ អធិប្បាយថា ញើស ស្រក់ហូរព្រោះអាហារក្តៅ ឬព្រោះភិក្ខុមានចិត្តក្តៅក្រហាយ ។ ពាក្យថា **ភត្តរឹង ព្រោះក្រៀមស្ងួត** គឺភត្តរឹង ព្រោះភាពក្រៀមស្ងួត ។ អធិប្បាយថា នឹងពោលទៅថ្វី ដល់ភត្តដែលជោកសើម ព្រោះទឹកដោះជូរ ទឹកក្រូចជាដើមហ្ន៎ ។ ដោយពាក្យថា **ញើសដែលស្រក់ហូរនោះ** លោកពោលដល់ភាពជាបដិកូល ព្រោះជាអាហារ ដែលលាយឡំដោយញើស ។

បទថា **តស្មឹ** បានដល់ បិណ្ឌបាត( អាហារ ) ។ ពាក្យថា **ខូចភាពស្រស់ ស្អាត** គឺភាពស្រស់ស្អាតវិនាសទៅ ដោយប្រការទាំងពួង ។ បទថា **វេមជ្ឈតោ បដ្ឋាយ** គឺចាប់តាំងពីកណ្តាលអណ្តាតទៅ ។ ពាក្យថា **អាចម៍ឆ្កែញ** គឺកំទេចអាចម៍ ឆ្កែញ ។ បទថា **វិចុណ្ណិតមក្ខិតោ** គឺអាហារដែលត្រូវធ្មេញទាំងពីរ ( លើ ក្រោម ) កិនបែកល្អិតហើយ ត្រូវទឹកមាត់ជាដើមផ្សើមហើយ ។ ក៏ភាពដល់ព្រមដោយពណ៌ ផ្សេងៗ ភាពដល់ព្រមដោយក្លិន និងភាពដល់ព្រមដោយគ្រឿងតាក់តែងក្នុងពេល មុនអាហារនេះ ក៏ប្រាកដយ៉ាងនេះ ភាពដល់ព្រមដោយពណ៌ផ្សេងៗ ជាដើមនោះ រមែងវិនាសទៅជាប្រាកដ ឯចំណែក រស អាចបាត់បង់ក៏បាន មិនបាត់បង់ក៏ បាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា បាត់បង់ពណ៌ក្លិន និងគ្រឿងតាក់ តែងផ្សេងៗ ទៅដូច្នេះ ។ ពាក្យថា **ក្នុងស្នូកបាយសុនខ** គឺក្នុងស្នូកស៊ីបាយសម្រាប់

សុនខទាំងឡាយ ។ ពាក្យថា **ដូចកម្អួតសុនខដែលគទុក** គឺដូចកម្អួតសុនខដែលក្អួតចេញមក ។ ដោយពាក្យថា ព្រោះកន្ទុងក្រសែក្អែកទៅហើយ ទើបជាវត្ថុដែលគួរគ្រលែងលេប លោកបើកបង្ហាញភាពជារបស់បដិកូលដ៏ឧក្រិដ្ឋ ។

ពាក្យថា ( **ដែលចូលដល់** ) **ការបរិភោគ** គឺដែលចូលដល់ការគ្រលែងលេប ។ ក្តាប់សេចក្តីថា អាហារនេះ លុះបានចូលដល់ខាងក្នុងក៏ជារបស់គួរឲ្យខ្ពើមរអើមយ៉ាងក្រៃលែង ដូចប្រឡាក់ដោយទន្សែខាប់ ដូច្នេះ ។ ពាក្យថា **ខាងក្នុង** គឺខាងក្នុងកោដ្ឋាស ។ អាហារដែលនៅមិនទាន់ចូលដល់ទីអាស្រ័យ គឺ នៅមិនទាន់ដល់ក្រពះអាហារថ្មីនៅឡើយ ក៏ជារបស់ដែលប្រឡូកប្រឡំដោយកោដ្ឋាស ដែលជាទីអាស្រ័យទាំងឡាយ មានទឹកប្រមាត់ជាដើម ព្រោះហេតុនោះ ទើបលោកពោលថា លុះចូលទៅដល់ ដូច្នេះ ។ លោកអាចារ្យប្រាថ្នាយកសេចក្តីសង្ស័យក្នុងចិត្តដែលថា ឈ្មោះថា អាសយៈដែលផុតអំពីអាមាសយៈ ( ក្រពះអាហារថ្មី ) និងបក្កាសយ ( ក្រពះអាហារចាស់ ) នេះ គឺអ្វីទៀតសោត ដូច្នេះ ទើបពោលថា ព្រោះហេតុដែលដូច្នេះ ជាដើម ។ **អាសយ** គឺទឹកប្រមាត់នោះឯង ឈ្មោះថា **បិត្តាសយ** ។ លោកពោលថា មានច្រើនក្រៃលែង ក៏ព្រោះមហាជនចំណែកច្រើនជាអ្នកមានបញ្ញាក្រាស់ , ពាក្យថា **ដោយកោដ្ឋាសដែលជាទីអាស្រ័យតាមប្រការដូចពោលមកយ៉ាងនេះ** គឺគប្បីពិចារណាភាពជារបស់បដិកូលដោយកោដ្ឋាស ដែលជាទីអាស្រ័យតាមប្រការយ៉ាងនេះថា អាហារជារបស់គួរឲ្យខ្ពើមរអើម ចូលទៅខាងក្នុងហើយលាយឡំដោយកោដ្ឋាស ដែលជាទីអាស្រ័យ មានទឹកប្រមាត់ជាដើម ដ៏គួរឲ្យខ្ពើមរអើមជាង ក៏រមែងជារបស់គួរឲ្យខ្ពើមរអើមក្រៃលែងឡើង ដូច្នេះ ។

សូម្បីក្នុងពាក្យថា ដោយទីសន្សំទុកនេះ ក៏មានន័យដូច្នេះដែរ ។ បទថា **សោ**

បានដល់ អាហារ ។ ពាក្យថា **អ្នកមានអាយុ ១០ ឆ្នាំ** គឺសត្វមានអាយុ ១០ ឆ្នាំ តាំងពីកើតមក ។ ពាក្យថា **ក្នុងឱកាស** គឺក្នុងបរិវេណដែលហៅថាក្រពះអាហារ ។

ពាក្យថា **ក្នុងឱកាសប្រាកដដូច្នេះ** គឺ ក្នុងឱកាសដែលមានដូច្នេះ មានសេចក្តីថា ដែលដូចជារណ្តៅឧច្ចារៈដែលមិនបានលាងជម្រះមករហូត ១០ ឆ្នាំ រហូតដល់ ១០០ ឆ្នាំ ។ ពាក្យថា **ដែលចូលដល់ការសន្សំទុក** គឺដែលចូលដល់ភាពជាវត្ថុដែលគប្បីសន្សំទុក ។ បទថា **យថាវុត្តប្បការេ** មានប្រការតាមដែលពោលមកហើយ មានសេចក្តីថា ឈ្មោះថា **យថាវុត្តប្បការោ** ព្រោះអត្ថថា មានប្រការតាមដែលពោលមកហើយ ដោយពាក្យថា បើថាបុគ្គលអ្នកមានអាយុ ១០ ឆ្នាំ ជាដើម ។ បានដល់ ក្នុងតំណែងមានប្រការតាមដែលបានពោលមកហើយនោះ ។ ពាក្យថា **ការងងឹតអន្ធកាយ៉ាងក្រៃលែង** គឺភាពងងឹតអន្ធកាហួសនឹងប្រៀបបាន ។ ក្អាប់សេចក្តីថា រមែងចូលដល់ការស្អប់ខ្ពើមដ៏យ៉ាងក្រៃលែង តាំងនៅក្នុងចំណែកដែលមានក្លិនស្អុយ គួរឲ្យខ្ពើមរអើមណាស់ ។ សួរថា ក្នុងខនោះដូចគ្នានឹងអ្វី លោកអាចារ្យឆ្លើយថា **យថា នាម** ដូច្នេះជាដើម ។ ក្នុងអណ្តូងដែលភ្លៀងពុំជួរកាលធ្លាក់ស្រោច វត្ថុស្មោកគ្រោកដោយច្រើន រមែងអណ្តែតផុសឡើង ខ្ចាយទៅខាងនោះខាងនេះ ព្រោះហេតុនោះ ទើបលោកប្រើសព្ទថា ភ្លៀងពុំជួរកាល ។ សព្ទថា ស្មៅ ស្លឹកឈើ កំទេចកន្ទេល លោកមិនបានប្រើដើម្បីសម្តែងថា សូម្បីវត្ថុដែលមិនស្អាត ក៏ដល់សភាពជារបស់មិនស្អាត ព្រោះការលាយឡំគ្នានឹងវត្ថុដែលមិនស្អាត ។ ពាក្យថា **បន្ទុជាពពុះ និងព្រួចទឹកដែលកើតអំពីភាពក្តៅហប់ព្រោះកម្តៅនៃភ្លើងក្នុងកាយដុតរោល** គឺ បន្ទុពពុះ និងព្រួចដែលកើតព្រោះត្រូវភ្លើងធាតុរំលាយអាហារដុតរំលាយ ។ ពាក្យថា **ដូចធាតុមាស ធាតុប្រាក់ជាដើម** មាន

សេចក្ដីថា ប្រៀបដូចធាតុមាស ឬធាតុប្រាក់ជាដើម កាលត្រូវគេដុតដោយវិធីការ ក៏បញ្ចេញមាស ឬប្រាក់ជាដើមចេញមក ក៏ពោលបានថា ចូលដល់ភាពជាមាស ឬប្រាក់ជាដើម យ៉ាងណា អាហារនេះមិនដូច្នោះទេ តែថា អាហារដែលត្រូវភ្លើងក្នុងកាយរំលាយហើយនេះ បែរជាបញ្ចេញពពុះ និងព្រួច ដល់ភាពជាឧច្ចារៈពេញក្រពះអាហារចាស់ ដូចដីពណ៌លឿងដែលគេកិនដោយត្បាល់ថ្ម ដែលមានឈ្មោះថា **សណ្ហករណី** ត្បាល់កិន ព្រោះអត្ថថា ជាការធ្វើឲ្យល្អិត ហើយដាក់ទុកក្នុងបំពង់ គឺក្នុងឫស្សីតូចៗ ដោយឡាតពណ៌ និងសណ្ឋាន ចូលដល់សភាពជាបស្សាវៈពេញក្រពះបស្សាវៈ ។ ចំណែកឯ អាហារជារបស់ជន្លួវមិនប្រាកដឡើយ ដូចជាបំណែកអណ្ដាតភ្លើងដែលត្រូវរលត់ ។ រីឯ **រស** លោកប្រកាសទុកដោយ **ផល** ឯចំណែកទាំងនោះ មានចំណែកដូចគ្នានឹងអាហារដែលនៅមិនទាន់រលាយ ព្រោះហេតុនោះ ក្នុងទីនេះ ទើបលោកអាចារ្យ សម្ដែងតែចំណែកដែលជាឧច្ចារៈ និងបស្សាវៈទុកប៉ុណ្ណោះ មិនប៉ះពាល់ដល់ចំណែកទាំងនោះទេ ។

លោកអាចារ្យកាលនឹងសម្ដែងថា ឈ្មោះថា **ផល** របស់វត្ថុដែលជាបដិកូល ក៏ត្រូវជាវត្ថុបដិកូលនោះឯង ដូច្នេះទើបពោលថា ដែលត្រូវរំលាយដោយប្រពៃពិតនេះនោះឯងដូច្នេះ ។ ដោយ **អាទិ**-ស័ព្ទ( ប្រែថា ជាដើម ) ក្នុងបទថា **កេសលោម នខទន្តាទីនិ** មានសក់ រោម ក្រចក ធ្មេញជាដើម លោកអាចារ្យមិនបានរួមយក **សព** ( វត្ថុគួរឲ្យខ្ពើម ) ទាំងឡាយ មានស្បែកជាដើម ដែលមានមកក្នុងព្រះបាលីក្នុងអាការ ៣២ តែម្យ៉ាងប៉ុណ្ណោះ តែគប្បីឃើញថា លោកពោលថា **សាកសព ផ្សេងៗ** នេះលោករួមយកវត្ថុដែលមិនស្អាតទាំងឡាយ ដែលផុតចាកកោដ្ឋាស ៣២ មានអាចម៍ភ្នែក អាចម៍ត្រចៀក អាចម៍ធ្មេញ ទឹកសម្ភារៈជាដើមផង ។

បទថា **និស្សន្ទមានោ** ប្រែថា ពេលចេញក្រៅ មានន័យថា ពេលហូរចេញ, ដោយ **អាទិ** ស័ព្ទក្នុងបទថា **អាទិនាបការេន** ដោយប្រការថា...ជាដើមនេះ លោករួមយកវត្ថុស្មោកគ្រោកមានប្រការយ៉ាងនេះ គឺ រន្ធប្រមុះ បានដល់ ទឹកសម្បោរ, ផ្លូវមាត់ បានដល់ ទឹកមាត់ ពេលខ្វះក៏ទឹកប្រមាត់ សេម្ហ: លោហិត: វត្ថុដែលក្អួត, ទ្វារធំ បានដល់ ឧច្ចារ:, ខាងរន្ធបស្សាវ: បានដល់ ទឹកបស្សាវ:, ខាងរណ្ដៅរោមក្នុងកាយទាំងអស់ បានដល់ ញើសដូច្នេះ ។ លោកពោលពាក្យថា **ក្នុងថ្ងៃមុននេះ** រំពឹងដល់ថ្ងៃដែលហូរចេញ ។ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងថ្ងៃទី ២ កាលនឹងឲ្យវាហូរចេញទៅ ដូច្នេះ ។ ពាក្យថា **មុខបងចិញ្ចើម** គឺមានមុខជ្រីវជ្រួញដោយអំណាចនៃការរង្កៀស ។ ព្រោះហេតុនោះ ទើបលោកពោលថា រង្កៀសដូច្នេះ។ ពាក្យថា **អៀនអន់** គឺកើតការមិនសប្បាយចិត្តថា ឈ្មោះថា សូម្បីវត្ថុនេះ យើងក៏គប្បីសម្លឹងមើលដោយពិតដូច្នេះ ។ ពាក្យថា **ត្រេកអរ** គឺត្រេកអរដោយឆន្ទរាគ:ដែលមានអាការធ្វើចិត្តឲ្យប្រែប្រួល ដូចពណ៌ជ្រលក់សំពត់ដែលធ្វើសំពត់ឲ្យប្រែពណ៌ទៅផ្សេងៗ ដូច្នោះ ។ ពាក្យថា **ជាប់** គឺជាប់ដោយសេចក្ដីប្រាថ្នាដែលមានការសង្ឃឹមជាសភាវ: បានដល់ សេចក្ដីលោភ ។ ពាក្យថា **ជំពាក់** គឺមានចិត្តពាក់ព័ន្ធនៅក្នុងអាហារនោះ ដូចជាជាប់ស្អិតព្រោះភាវ:ដោះបានដោយលំបាក ។ ពាក្យថា **ងប់ជ្រប់** គឺដល់ការងប់ជ្រប់ គឺការវង្វេងវង្វាន់ដោយតណ្ហាក្នុងរស ។ ពាក្យថា **អស់តម្រេក** គឺទៅប្រាសសេចក្ដីត្រេកអរ ។ ពាក្យថា **លំបាក** គឺជាទុក្ខ ។ បទថា **ហរាយមានោ** ប្រែថា អៀនខ្មាស ។ ពាក្យថា **រង្កៀស** គឺ គួរតិះដៀល ។

ពាក្យថា **ទ្វារ ៩** លោកប្រែទុកដោយការទាក់ទងនឹងទ្វារធំៗ ដែលប្រាកដច្បាស់ រមែងហូរចេញតាមប្រហោងរោមទាំងឡាយដោយពិត ។ ពាក្យថា **រមែង**

**គេចពួន** គឺរមែងពួនសម្ងំមិនសម្ដែងខ្លួន ឬថា រមែងអៀនខ្មាស ។ ពាក្យថា **តាមប្រការដូចពោលមកនេះ** គឺតាមប្រការទាំងនេះ គឺការឲ្យចូលទៅតាមទ្វារ ១ ការឲ្យចេញមកតាមទ្វារទាំងឡាយជាច្រើន ដោយអាការជាច្រើន ។ ពេលឲ្យចូលទៅក៏ប្រកាសឲ្យដឹង ពេលឲ្យចេញមកក៏លាក់ពួន ពេលឲ្យចូលទៅក៏កើតបីតិសោមនស្ស ពេលឲ្យចេញមកក៏អៀនខ្មាស ពេលឲ្យចូលទៅក៏ត្រេកអរ ពេលឲ្យចេញមកក៏អស់ការត្រេកអរដូច្នេះ ។

ដោយបិ-ស័ព្ទ ក្នុងបទថា **បរិភោគកាលេបិ** សូម្បីក្នុងពេលបរិភោគ លោកសម្ដែងថា ឈ្មោះថា អាហារដែលគ្រាន់តែចូលទៅប៉ុណ្ណោះ ក៏ធ្វើឲ្យប្រហោងទ្វារដែលចូលទៅ គួររង្កៀសបាន នឹងពោលទៅថ្វីដល់អាហារដែលបានកម្ដៅ រហូតដល់រលាយ នឹងមិនធ្វើឲ្យប្រហោងទ្វារដទៃគួររង្កៀសនោះ ។ បទថា **ឯស** បានដល់ អាហារ ។ ពាក្យថា **ដើម្បីកម្ចាត់ក្លិន** គឺដើម្បីកម្ចាត់ក្លិនឆ្អេះឆ្អាប ។ ពាក្យថា **ភ្លើងក្នុងកាយ** បានដល់ ភាពក្ដៅក្នុងកាយដែលប្រព្រឹត្តទៅតាមភ្លើងជាតុរំលាយអាហារ ។ បទថា **ផេណុទ្ទេហកំ** ប្រែថា ដូចជាពពុះ ។ ពាក្យថា **រលាយទៅ** គឺដល់នូវការរលាយទៅ ។ បទថា **ឧត្តរមានោ** ប្រែថា គ្រើឡើងមកលើ ។ ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **សេម្ហាទិ** មានស្លេស្មជាដើម រួមយកទឹកប្រមាត់ជាដើមចូលផង ។ ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **ករីសាទិ** មានឧច្ចារៈជាដើម រួមយកញើសជាដើមចូលផង ។ ឈ្មោះថា **ទ្វារទាំងនេះ** បានដល់ ទ្វារទាំងឡាយមានមាត់ជាដើម ។ ពាក្យថា **ទ្វារខ្លះ** លោកពោលសំដៅយករន្ធបន្ទោបង់បស្សាវៈ ។ ក៏មនុស្សអ្នកមានជាតិស្អាត សូម្បីលាងជម្រះទ្វារទាំងឡាយ មានមាត់ជាដើមហើយ ក៏ត្រូវលាងជម្រះដៃម្ដងទៀតដែរ ។ ពាក្យថា **ទ្វារខ្លះដទៃទៀត** លោកពោលសំដៅ

យកទ្វារធំ ។ ពាក្យថា **២-៣ ដង** គឺ ២ ដង ឬ ៣ ដង ។ ក៏ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបសេចក្តីផ្សេងគ្នាដូច្នេះ គឺភាពជារបស់បដិកូលនៃការទៅស្វែងរក ដើម្បីប្រយោជន៍ដល់អាហារ លោកពោលថា ជាភាពបដិកូលក្នុងអាហារ ។ ភាពជាបដិកូលនៃការបរិភោគ លោកពោលថា ជាភាពបដិកូលក្នុងអាហារ ក៏ដោយការដែលមានអាហារនោះ ជាទីអាស្រ័យ ។ ភាពជាបដិកូលនៃកោដ្ឋាសដែលជាទីអាស្រ័យ និងជាទីសន្សំទុក លោកពោលថា ជាភាពបដិកូលក្នុងអាហារ ក៏ព្រោះមានការជាប់ទាក់ទងនឹងអាហារនោះ ។ ភាពជាបដិកូលនៃអាការក្រៅពីនេះ លោកពោលថា ជាសភាពបដិកូលក្នុងអាហារ ក៏ព្រោះភាពជាវិការ ( ការធ្វើឲ្យជាប្រភេទផ្សេងៗ ) នៃអាហារនោះ ដូច្នេះ ។ ក៏សូម្បីអាហាររបស់ពួកជន្លូវ ក៏គប្បីតាំងទុកក្នុងផ្នែកភាពជាវិការនៃអាហារនេះបានដូច្នេះ ឯង ។

ពាក្យថា **និមិត្តនោះ** គឺអារម្មណ៍ដែលប្រាកដដោយអំណាចអាការជាបដិកូលនៃព្រះយោគាវចរអ្នកដាក់ចិត្តនៅដដែលៗ ដោយអាការទាំងឡាយតាមដែលពោលហើយ ដែលជានិមិត្តនៃភាវនា ដែលកំណត់ដឹងថា ជាកពឡិង្ការាហារ ។ មិនមែនឧគ្គហនិមិត្ត ឬបដិភាគនិមិត្តទេ ។ ប្រសិនបើក្នុងកពឡិង្ការាហារនោះ ឧគ្គហនិមិត្តគប្បីកើតឡើងបានដូច្នេះ សូម្បីបដិភាគនិមិត្តក៏គួរនឹងអាចកើតបាន ។ កាលជាយ៉ាងនោះបាន ក៏គួរនឹងមានឈានដែលដល់អប្បនា តែក៏មិនអាចកើតបាន ព្រោះហេតុអ្វី ព្រោះការបម្រើនមានអាការផ្សេងៗ និងព្រោះកម្មដ្ឋានមានសភាពជ្រាលជ្រៅដោយភាពជាសភាវធម៌ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះការដែលកពឡិង្ការាហារ ជាអារម្មណ៍ដ៏ជ្រាលជ្រៅដោយសភាពជាសភាវធម៌ ដូច្នេះ ។ ក្នុងកម្មដ្ឋាននេះ ព្រះយោគាវចរភាវនាឲ្យប្រព្រឹត្តទៅដោយអំណាចអាការ

ដែលជាបដិកូល ក៏ពិត ។ សួម្បីដូច្នោះបណ្ឌិតគួរជ្រាបថា កពឡិង្ការាហារប្រព្រឹត្ត ទៅអាស្រ័យធម៌ពួកណា ធម៌ពួកនោះឯងជាបដិកូល មិនមែនបញ្ញត្តិ ព្រោះហេតុនោះ ឈានទើបមិនអាចដល់អប្បនាបានក្នុងកម្មដ្ឋាននោះ ព្រោះភាវនាប្រព្រឹត្ត ទៅប្រារព្ធយកសភាវធម៌ ដោយការចាប់យកអាការដែលជាបដិកូល គឺជាគន្ធនោះឯង , និងព្រោះសភាវធម៌ទាំងឡាយមានសភាពជ្រាលជ្រៅដោយសភាវៈតែម្តង ។ ពិតមែន សច្ចៈ ២ ប្រការដំបូង ( គឺ ទុក្ខ , សមុទយ ) ឈ្មោះថា កើតជារបស់ឃើញបានដោយលំបាក គឺ ព្រោះមានជម្រៅនោះឯង ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើចិត្តតាំងមាំដោយប្រពៃដោយឧបចារសមាធិសោត នឹងហៅឈ្មោះកម្មដ្ឋានថា សញ្ញានោះ បានយ៉ាងដូចម្តេច ដូច្នេះទើបពោលថា ក៏សញ្ញា...ដោយអំណាចការកាន់អាការដែលជាបដិកូលដូច្នេះជាដើម ។

( ចប់ មហាដីកា )

## អានិសង្សនៃអាហារេបដិក្កូលសញ្ញា

ចិត្តរបស់ភិក្ខុអ្នកប្រកបរឿយៗ នូវអាហារេបដិកូលសញ្ញានេះ រមែងថយ រមែងរួញ រមែងចេញចាកសេតណ្ហា លោកជាបុគ្គលប្រាសចាកការស្រវឹង ដោយបរិភោគអាហារត្រឹមតែដើម្បីត្រូវការឆ្លងទុក្ខទៅបានដូច ( អ្នកធ្វើដំណើរផ្លូវកន្តារ ) មានសេចក្តីត្រូវការនឹងឆ្លងផ្លូវកន្តារ( ឲ្យបាន មិនមានអ្វីបរិភោគ ក៏ត្រូវសម្លាប់កូន ) ហើយបរិភោគសាច់កូនឯងដូច្នោះ ក្នុងទីនេះរាគៈដែលប្រព្រឹត្តទៅក្នុងបញ្ចកាមគុណរបស់លោក ក៏នឹងដល់នូវការកំណត់ដឹង ( លះបាន ) មិនលំបាក ព្រោះមានការកំណត់ដឹងកពឡិង្ការាហារ ដោយអាការបដិកូលជាមុន គឺជាគន្លងផ្លូវ លោកនឹងកំណត់ដឹងរូបក្ខន្ធបាន ដោយមានការកំណត់ដឹងបញ្ចកាមគុណជាមុខ ម្យ៉ាងទៀតសូម្បីការចម្រើន កាយគតាសតិរបស់លោក ក៏នឹងដល់ភាពបរិបូណ៌ដោយអំណាចភាពជាបដិកូលនៃអាហារ មានអាហារដែលនៅមិនទាន់រលាយជាដើមផង លោករាប់ថា ជាបុគ្គលធ្វើដំណើរក្នុងប្រការបដិបត្តិអនុលោមដល់អសុភសញ្ញាផង ម្យ៉ាងទៀត លោកអាស្រ័យខ.បដិបត្តិនេះហើយ កាលនៅមិនទាន់បានសម្រេចដល់ទីបំផុត គឺ ព្រះអមតៈក្នុងទិដ្ឋធម៌នេះ ក៏នឹងមានសុគតិជាទីទៅក្នុងខាងមុខដូច្នេះឯង ។

នេះជាពាក្យសម្តែងពន្យល់យ៉ាងពិស្តារ នៅក្នុងការចម្រើនអាហារេបដិកូលសញ្ញា ។

## មហាដីកា

## អានិសង្សនៃអាហារេបដិក្កូលសញ្ញា

ឥឡូវនេះ លោកអាចារ្យ បំណងសម្តែងអានិសង្សនៃភាវនានេះ ទើបពោល

ថា **ឥមញ្ច បទ** ដូច្នេះជាដើម ។ ពាក្យថា **ចេញចាករសតណ្ហា** គឺប្រាសចាកតណ្ហាក្នុងរសទាំងឡាយ មានរសផ្អែមជាដើមជាអារម្មណ៍ ។ ពាក្យថា **រមែងថយត្រឡប់** គឺរមែងងាកត្រឡប់ ព្រោះទ្រទ្រង់អាការជាអនេកនៃភាពជាបដិកូលក្នុងអាហារនោះទុកបាន ។ ពាក្យថា **រមែងវិលត្រឡប់** គឺគេចទៅ បានដល់ មិនរាយប៉ាយទៅ ។ ពាក្យថា **រមែងបែរត្រឡប់** គឺឈប់ទៅ ។ ពាក្យថា **បុគ្គលអ្នកត្រូវការឆ្លងផ្លូវកន្តារ** គឺបុគ្គលអ្នកមានប្រយោជន៍ដោយការឆ្លងផ្លូវកន្តារ មានកិច្ចាហារបានដោយលំបាកដ៏ធំធេងក្រៃលែង ។ ពាក្យថា **ប្រាសចាកការស្រវឹង** គឺ មិនមានការស្រវឹង ព្រោះមិនមានការស្រវឹង គឺ មានះជាដើម គប្បីឃើញថា ដោយស័ព្ទថា **មិនមានការស្រវឹងនោះ** គឺ លោកកាន់យកទាំងសេចក្តីដែលមិនមានការលេងការប្រដាប់ និងការតុបតែងជាដើមនៃព្រះយោគីនោះដូច្នេះ ។ ពាក្យថា **ដោយគន្លង** គឺ **ការកំណត់ដឹងកពឡិង្ការាហារ** គឺ ដោយការកំណត់ដឹងកពឡិង្ការាហារ ដោយអាការជាបដិកូល តាមន័យដែលបានពោលហើយ ជាគន្លង ។ ពាក្យថា **រាគៈដែលប្រកបក្នុងកាមគុណ ៥** គឺ រាគៈដែលប្រកបក្នុងកាមគុណ ៥ ឬមានកាមគុណ ៥ នោះជាប្រយោជន៍ ដោយអត្ថថា មិនផុតទៅបាន ។ ឈ្មោះថា **រមែងដល់ការកំណត់ដឹង** គឺការឈានកន្លង ។ ពិតមែន កាលរសតណ្ហាទៅប្រាសដោយប្រពៃហើយនោះ សូម្បីតណ្ហាដ៏សេស មានរូបតណ្ហាជាដើម ក៏រមែងមានការទៅប្រាសផងដែរ ព្រោះភាពជាអ្នកស្គាល់ប្រមាណក្នុងភោជនដ៏ខ្ពង់ខ្ពស់ ។ និងកាលមានការឈានកន្លងនូវតណ្ហាដែលមានអារម្មណ៍បាន ក៏រមែងមានការឈានកន្លងអារម្មណ៍បានផងដែរ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ព្រះយោគីរមែងកំណត់ដឹងរូបក្ខន្ធជាគន្លង គឺ ការកំណត់ដឹងកាមគុណ ៥** ដូច្នេះ ។ សេចក្តីពិតថា

កាលរូបាយតនៈជាដើម ត្រូវបានកំណត់ដឹង ( ការឈានកន្ទង ) ក្ខុតរូបទាំងឡាយ ដែលជាទីអាស្រ័យនៃរូបាយតនៈជាដើមនោះ និងបសាទទាំងឡាយ ដែលកាន់យករូបាយតនៈជាដើម ក៏អាចនឹងកំណត់ដឹងបានដោយងាយផងដែរ ។ ដោយ **អាទិ** សព្ទក្នុងបទថា **អបរិបក្កាទិ** ( អាហារដែលនៅមិនទាន់រលាយជាដើម ) គប្បីឃើញថារួមយកទាំងកោដ្ឋាសដែលជាអាសយៈ និងជាទីសន្សំទុក ។ ក្នុងពាក្យនោះ វត្ថុដទៃដែលមិនទាន់រលាយ ក៏បានដល់អាហារថ្មីនោះឯង ។ ដោយសព្ទថា **អាសយ** ( កោដ្ឋាសដែលជាអាសយៈ ) គឺការសម្រេចកំណត់យកទឹកប្រមាត់ សេម្ហៈ ខ្ទុះ និងលោហិត ដោយសព្ទថា **បរិបក្ក** ( អាហារដែលរលាយហើយ ) គឺ ការកំណត់យកឧច្ចារៈ និងបស្សាវៈ , ដោយសព្ទថា **ផល** គឺ សម្រេចការកំណត់យកកោដ្ឋាសទាំងពួង មានសក់ជាដើម ព្រោះហេតុនោះទើបលោកពោលថា **សូម្បីកាយគតាសតិភាវនា ក៏រមែងដល់សេចក្តីបរិបូណ៌បាន** ដូច្នេះ ។ ពាក្យថា **ចំពោះអសុភសញ្ញា** គឺចំពោះអសុភភាវនា សេចក្តីថា ចំពោះការប្រកបរឿយៗ នូវការចម្រើនអសុភដែលមិនមានវិញ្ញាណ ។ ឈ្មោះថា **ជាបុគ្គលបដិបត្តិបដិបទាដែលអនុលោម** ក៏ដោយការកំណត់ភាវៈដែលមិនស្អាត មានក្លិនស្អុយគួរខ្ពើមរអើមនៃរាងកាយ ដោយកាន់យកអាការដែលជាបដិកូល ។ ពាក្យថា **ខបដិបត្តិនេះ** គឺការចម្រើនបដិកូលសញ្ញាក្នុងអាហារនេះ ។ ពាក្យថា **មានអមតធម៌ជាទីបំផុត** គឺមានព្រះនិព្វានជាទីបញ្ចប់ មានន័យថា មានការធ្វើឧបចារឈានដែលហៅថា អាហារេបដិកូលសញ្ញាភាវនាឲ្យជាបាទ ចម្រើនវិបស្សនាសម្រេចព្រះនិព្វាន ។

( ចប់ មហាដីកា )

( អាហារេបដិកូលភាវនា ចប់ហើយដោយប្រការដូច្នេះ )

# ចតុធាតុវវត្ថាន

ឥឡូវនេះ និទ្ទេស ( ពាក្យអធិប្បាយ ) ការចម្រើនចតុធាតុវវត្ថាន ដែលលោកសម្តែងទុកបន្ទាប់ពីអាហារេបដិកូលសញ្ញាមកថា **វវត្ថាន** ១ ដូច្នេះ មកដល់ហើយដោយលំដាប់ ។

## អធិប្បាយពាក្យបទមាតិកា

វិនិច្ឆ័យក្នុងបទមាតិកានោះ បទថា **វវត្ថាន** ( វិគ្រោះមើល ) បានដល់សន្និដ្ឋាន ( ការយល់ឃើញ ) តាមដែលបានកំណត់ឃើញសភាវៈ ( របស់វា ) ការវិគ្រោះមើលធាតុទាំង ៤ ឈ្មោះថា ចតុធាតុវវត្ថាន , ពាក្យថា **ធាតុមនសិការ** ( ធ្វើទុកក្នុងចិត្តដោយសភាវៈជាធាតុ ) **ធាតុកម្មដ្ឋាន**( កម្មដ្ឋានមានធាតុជាអារម្មណ៍ ) **ចតុធាតុវវត្ថាន** ( ការវិគ្រោះមើលធាតុ ៤ ) ដោយសេចក្តី គឺ ដូចគ្នា ។

## ចតុធាតុវវត្ថានពីរយ៉ាង

ចតុធាតុវវត្ថាននេះ មានពីរយ៉ាង គឺ សង្ខេប ១ ពិស្តារ ១ ចតុធាតុវវត្ថានសង្ខេបនោះ មានមកក្នុងមហាសតិប្បដ្ឋានសូត្រយ៉ាងពិស្តារ មានមកក្នុងមហាហត្ថិបទោបមសូត្រ រាហុលោវាទសូត្រ និងធាតុវិភង្គសូត្រ ។

## ចតុធាតុវវត្ថានសង្ខេប

ពិតមែន ចតុធាតុវវត្ថាននោះ មានមកដោយសង្ខេបក្នុងមហាសតិប្បដ្ឋានសូត្រជាធម៌សម្រាប់បុគ្គលអ្នកចម្រើនធាតុកម្មដ្ឋាន ដែលមានបញ្ញាចាស់ក្លាដូច្នេះថា ម្នាលភិក្ខុទាំងឡាយ គោឃាតកអ្នកជំនាញ ឬ កូនសិស្សគោឃាតក សម្លាប់គោហើយ

ពន្លះ ចៀរសាច់ចេញជាចំណែក ៗ ហើយក៏អង្គុយលក់ នៅត្រង់ផ្លូវបែកជា ៤ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក៏ដូច្នោះ គប្បីពិចារណាមើលកាយនេះឯង ដែលវាតាំងនៅយ៉ាងណា ដែលលោកតាំងទុកយ៉ាងណា ក៏ដោយធាតុថា មាននៅក្នុងកាយនេះ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។

## អធិប្បាយ សេចក្តីក្នុងព្រះសូត្រ

សេចក្តីនៃព្រះសូត្រនោះថា គោឃាតកអ្នកឈ្លាស ឬកូនសិស្សគោឃាតក ត្រូវគេជួលដោយបាយ និងថ្លៃឈ្នួល សម្លាប់គោហើយ ពន្លះធ្វើឲ្យជាចំណែកៗ ក៏អង្គុយលក់នៅត្រង់ផ្លូវបែកជា ៤ ពោលគឺ ត្រង់កណ្តាលផ្លូវធំ ដែលឆ្ពោះមុខទៅទិសទាំង ៤ យ៉ាងណា ភិក្ខុក៏ដូចគ្នា គប្បីពិចារណាមើលកាយ ដែលឈ្មោះថា តាំងនៅយ៉ាងណា ព្រោះតាំងនៅដោយអាការនៃឥរិយាបថ ៤ យ៉ាងណាមួយ ឈ្មោះថា តាំងទុកយ៉ាងណា ព្រោះវាតាំងនៅដោយអាការយ៉ាងណា ដោយធាតុយ៉ាងនេះថា នៅក្នុងកាយនេះមាន ធាតុដី ។ ល ។ ធាតុខ្យល់ ។

សួរថា ពុទ្ធាធិប្បាយមានដូចម្តេច ?

ឆ្លើយថា ពុទ្ធាធិប្បាយមានយ៉ាងនេះថា កាលគោឃាតកបំប៉នគោក្តី ដឹកវាមករោងសម្លាប់ក្តី ដឹកវាមកដល់ហើយចងទុកត្រង់រោងសម្លាប់នោះក្តី កំពុងសម្លាប់ក្តី ឃើញវាត្រូវគេសម្លាប់ វាស្លាប់ក្តី ការដឹងច្បាស់ថា គោនៅមិនបាត់ទៅដរាបណា ដែលគេនៅមិនទាន់បានពន្លះវាជាចំណែកៗ ចេញ តែកាលពន្លះយកទៅអង្គុយលក់ហើយ ការដឹងថាគោទើបបាត់ទៅ ក្លាយជាការដឹងថា មំសៈទៅវិញ ការគិតដូច្នេះ មិនបានមានដល់គេទេថា យើងលក់គោ ជនទាំងនេះនាំយកគោទៅ តែការ

ពិត គេរមែងមានការគិតយ៉ាងនេះថា យើងលក់សាច់ ជនទាំងនេះនាំយកសាច់ទៅ ដូច្នេះ យ៉ាងណា កាលភិក្ខុនៅជាគ្រហស្ថក្តី បួសហើយក្តី ក្នុងកាលមុន ដែលនៅជាបុថុជ្ជនល្ងង់ខ្លៅក្តី ការដឹងថាសត្វ ថាបុរស ថាបុគ្គលនៅមិនទាន់បាត់ទៅដរាប ដែលលោកនៅមិនទាន់ពិចារណាមើលកាយនេះឯង ដែលវាតាំងនៅយ៉ាងណា ដែលលោកប្រកាសទុកយ៉ាងណា ក៏ដោយធាតុ ធ្វើឲ្យជាឃនវិនិព្ភោគ ( បែកចេញទៅជាចំណែកតូច ) កាលលោកពិចារណាឃើញដោយធាតុ សត្តសញ្ញា( ការសម្គាល់ថា សត្វ ) ទើបបាត់ទៅ ចិត្តទើបតាំងមាំ ថាជាធាតុយ៉ាងណា ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកជំនាញសម្លាប់ ។ ល ។ ក៏អង្គុយលក់នៅត្រង់ផ្លូវបែកជា ៤ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក៏ដូច្នោះដូចគ្នា គប្បីពិចារណាមើលកាយនេះ ។ ល ។ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។

រីឯ ក្នុងមហាហត្ថិបទោបមសូត្រ មានមកយ៉ាងពិស្តារ ព្រោះជាធម៌សម្រាប់អ្នកចម្រើនធាតុកម្មដ្ឋាន ដែលមិនមែនអ្នកមានបញ្ញាចាស់ក្លា ដូច្នេះថា ម្នាលអាវុសោទាំងឡាយ ធាតុដីខាងក្នុង តើដូចម្តេច ? វត្ថុណាមាននៅក្នុងខ្លួន អាស្រ័យខ្លួនជារបស់រឹងគ្រោតគ្រាត ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន វត្ថុនោះ គឺអ្វី វត្ថុនោះ គឺ សក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ។ ល ។ អាហារថ្មី អាហារចាស់ ឬ សូម្បីវត្ថុដទៃណានីមួយទៀត ដែលមាននៅក្នុងខ្លួន អាស្រ័យខ្លួន ជារបស់រឹងគ្រោតគ្រាត ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន ម្នាលអាវុសោទាំងឡាយ នេះហៅថា ធាតុដីខាងក្នុង ។

និងថា ម្នាលអាវុសោទាំងឡាយ ធាតុទឹកខាងក្នុងតើដូចម្តេច ? វត្ថុណាមាន

នៅក្នុងខ្លួន អាស្រ័យខ្លួន ជារបស់សើមជ្រួតជ្រាប ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន វត្ថុនោះគឺអ្វី ? វត្ថុនោះ ទឹកប្រមាត់ ។ល។ ទឹកមូត្រ ឬសូម្បីវត្ថុដទៃណាមួយទៀត ដែលមាននៅក្នុងខ្លួន អាស្រ័យនៅក្នុងខ្លួន ជារបស់សើមជ្រួតជ្រាប ដែលបុគ្គលប្រកាន់ថាជារបស់ខ្លួន ម្នាលអាវុសោទាំងឡាយ នេះហៅថា ធាតុទឹក ។

និងថា ម្នាលអាវុសោទាំងឡាយ ធាតុភ្លើងខាងក្នុង តើដូចម្តេច ? វត្ថុណាដែលមាននៅក្នុងខ្លួន អាស្រ័យនៅក្នុងខ្លួន ជារបស់ក្តៅ ដែលបុគ្គលប្រកាន់ថាជារបស់ខ្លួន វត្ថុនោះគឺអ្វី ? វត្ថុនោះគឺវត្ថុដែលជាហេតុដុតកម្តៅកាយ ១ ជាហេតុធ្វើឲ្យទ្រុឌទ្រោមកាយ ១ ជាហេតុធ្វើឲ្យក្រវល់ក្រវាយកាយ ១ ជាគ្រឿងដុតរំលាយយ៉ាងល្អនូវរបស់ដែលបរិភោគ គ្រេបផឹក ទំពាស៊ី លិទ្ធភ្លក្សចូលទៅ ១ ឬថា វត្ថុដទៃណាមួយទៀត ដែលមាននៅក្នុងខ្លួន អាស្រ័យខ្លួន ជារបស់ក្តៅ ដែលបុគ្គលប្រកាន់ថាជារបស់ខ្លួន ម្នាលអាវុសោទាំងឡាយ នេះហៅថា ធាតុភ្លើងខាងក្នុង ។

និងថា ម្នាលអាវុសោទាំងឡាយ ធាតុខ្យល់ខាងក្នុង តើដូចម្តេច ? វត្ថុណាមាននៅក្នុងខ្លួន អាស្រ័យនៅក្នុងខ្លួន ជារបស់បក់ផាត់ ដែលបុគ្គលប្រកាន់ថាជារបស់ខ្លួន វត្ថុនោះគឺអ្វី វត្ថុនោះគឺខ្យល់បក់ឡើងលើ ខ្យល់បក់ចុះក្រោម ខ្យល់នៅក្នុងពោះ ខ្យល់នៅក្នុងពោះវៀន ខ្យល់បក់ទៅតាមអវយវៈតូចធំ ខ្យល់ដកដង្ហើមចេញចូលដូច្នេះក្តី ឬថា វត្ថុដទៃណាមួយទៀត ដែលមាននៅក្នុងខ្លួន អាស្រ័យខ្លួនជារបស់បក់ផាត់ ដែលបុគ្គលប្រកាន់ថាជារបស់ខ្លួន ម្នាលអាវុសោទាំងឡាយ នេះហៅថា ធាតុខ្យល់ខាងក្នុង ។

ដូច្នេះ ចតុធាតុវវដ្ឋាន ក្នុងមហាហត្ថិបទោបមសូត្រមានយ៉ាងណា សូម្បីក្នុង

រាហុលោវាទសូត្រ និងធាតុវិភង្គសូត្រ ក៏មានដូច្នោះដែរ ។

## អធិប្បាយពាក្យក្នុងមហាហត្ថិបទោបមសូត្រ

តទៅនេះជាពាក្យពន្យល់បទ មានសេចក្ដីក្នុងព្រះសូត្រនោះ ដំបូងបទថា **អជ្ឈត្តំ បច្ចត្តំ** ទាំងពីរបទនេះ ជាពាក្យសង្កត់ស័ព្ទនិយកៈ វត្ថុដែលកើតក្នុងខ្លួន មានន័យថា ទាក់ទងនៅក្នុងសន្តានរបស់ខ្លួន ឈ្មោះថា **និយក** និយកៈនេះឯងហើយលោកពោលថា **អជ្ឈត្តំ** ព្រោះវត្ថុនោះប្រព្រឹត្តទៅក្នុងខ្លួន ពោលថា **បច្ចត្តំ** ព្រោះវត្ថុនោះអាស្រ័យខ្លួនប្រព្រឹត្តទៅ ដូចពាក្យដែលប្រព្រឹត្តទៅចំពោះពួកស្ត្រីក្នុងលោក គេក៏ហៅថា **អធិត្ថី** ពាក្យពេជចំពោះស្រី ដូច្នោះ ។

### បឋវី

បទថា **កក្ខឡំ** ប្រែថា រឹង , បទថា **ខរិគតំ** ប្រែថា គ្រោតគ្រាត ក្នុងពីរបទនោះ បទទី ១ ប្រាប់លក្ខណៈ បទទី ២ ប្រាប់អាការ ព្រោះបឋវីធាតុនោះ មានលក្ខណៈរឹង មានអាការគ្រោតគ្រាត ព្រោះហេតុដូច្នោះ លោកទើបពោលថា **កក្ខឡំ ខរិគតំ** ។

បទថា **ឧបាទិន្នំ** ប្រែថា ប្រកាន់មាំ អធិប្បាយថា ប្រកាន់យក ក្ដួចកាន់យកទុកយ៉ាងមាំ ដោយសម្គាល់យ៉ាងនេះ ថាយើង ថារបស់យើង ។

បទថា **សេយ្យថីទំ** ជានិបាត និបាតនោះមានសេចក្ដីថា សួរថា វត្ថុនោះយ៉ាងដូចម្ដេច តពីនោះ លោកនឹងសម្ដែងឆ្លើយសេចក្ដីដែលសួរនោះ ទើបពោលពាក្យតទៅថា **កេសា លោមា** ជាអាទិក្នុងបឋវីធាតុនិទ្ទេសនេះ គប្បីជ្រាបថាលោកសម្ដែងបឋវីធាតុដោយអាការ ២០ ព្រោះបន្ថែមមត្ថលុង្គំ ចូលដោយពាក្យថា **យំ វា បនញ្ញម្បិ**

**កិញ្ចិ** ឬសូម្បីវត្ថុណាមួយផ្សេងទៀត ក៏លោកសង្គ្រោះយកវត្ថុជាបឋវីធាតុដែលគប្បីមាននៅក្នុងចំណែកនៃធាតុ ៣ ដ៏សេសផង ។

## អាបោ

វត្ថុណាសើមជ្រួតជ្រាបទៅបាន គឺទៅដល់ទីនោះៗបាន ដោយការៈ គឺ ហូរទៅ ព្រោះហេតុនោះ វត្ថុនោះទើបឈ្មោះថា **អាបោ** វត្ថុនៅក្នុងអាបោទាំងឡាយដែលមានប្រការផ្សេងៗ ដោយអំណាចនៃសមុដ្ឋាន មានកម្មសមុដ្ឋានជាដើម ព្រោះហេតុនោះ វត្ថុនោះទើបឈ្មោះថា **អាបោគត** វត្ថុនោះបានដល់អ្វី វត្ថុនោះ បានដល់លក្ខណៈ គឺការជ្រួតជ្រាបបាននៃអាបោធាតុ ។

## តេជោ

វត្ថុដែលឈ្មោះថា **តេជោ** ព្រោះអំណាចនៃភាពជាគ្រឿងធ្វើឲ្យក្តៅ វត្ថុណានៅក្នុងតេជោទាំងឡាយ ដោយន័យដែលពោលហើយនោះឯង ព្រោះហេតុនោះទើប ឈ្មោះថា **តេជោគត** វត្ថុនោះបានដល់អ្វី វត្ថុនោះ បានដល់ លក្ខណៈគឺជារបស់ក្តៅនៃតេជោធាតុ ។

ពាក្យថា **យេន ច ( សន្តប្បតិ )** មានសេចក្តីថា រាងកាយនេះ រមែងក្តៅ គឺ កើតជាចំហាយក្តៅឡើង ព្រោះគ្រុន មានគ្រុនក្តៅជាដើម ព្រោះតេជោគតៈបានកម្រើកឡើង ។

ពាក្យថា **យេន ច ជរិយតិ** មានសេចក្តីថា រាងកាយនេះ តែងតែទ្រុឌទ្រោម គឺដល់នូវភាពជាអ្នកមានឥន្ទ្រិយ ( មានភ្នែកជាដើម ) ទន់ខ្សោយទៅ ដល់នូវភាពថយកម្លាំង និងដល់នូវភាពជាអ្នកមានស្បែកជ្រីវជ្រួញ និងមានសក់ស្កូវជាដើម

ព្រោះតេជោគតៈណា ។ ពាក្យថា **យេន ច បរិទយ្ហតិ** មានសេចក្ដីថា រាងកាយនេះរសាប់រសល់ បុគ្គលនោះត្អូញត្អែរថា ខ្ញុំក្ដៅណាស់ ខ្ញុំក្ដៅណាស់ រង់ចាំលេបថ្នាំមានសត្តធោតសប្បិ ( ទឹកដោះថ្លាដែលជម្រះ ១០០ ដង ) និង ( គោសីតច័ន្ទផ្សំដោយទឹកដោះគោ ) ផ្ចិតផ្ចើពីស្ទឹកត្នោតផង ព្រោះតេជោគតៈណាមួយកម្រើកឡើង ។

ពាក្យថា **យេន ច អសិត បិត ខាយិត សាយិតំ សម្មាបរិណាមំ គច្ឆតិ** មានសេចក្ដីថា វត្ថុដែលបរិភោគចូលទៅ មានបាយជាដើម វត្ថុដែលផឹកចូលទៅមានទឹកបាន:ជាដើមក្ដី វត្ថុដែលទំពាស៊ីចូលទៅ មានសដូវផង់ជាដើមក្ដី វត្ថុដែលលិទ្ធភ្លក្សចូលទៅ មានស្វាយទុំ និងទឹកឃ្មុំ ទឹកអំពៅជាដើមក្ដី រមែងដល់នូវភាពរលាយទៅដោយល្អ មានន័យថា ដល់នូវភាពជ្រួតជ្រាបទៅ ដោយជាវត្ថុដែលរាងកាយត្រូវការផ្សេងៗ មានរស គឺវត្ថុរាវដែលមានប្រយោជន៍ដល់រាងកាយជាដើម ព្រោះតេជោគតណា ។

ក៏ក្នុងអាការ ៤ យ៉ាងនោះ អាការ ៣ ខាងដើម មានតេជោធាតុជាសមុដ្ឋានអាការចុងក្រោយ មានកម្មជាសមុដ្ឋានតែម្យ៉ាង ។

## វាយោ

វត្ថុដែលឈ្មោះថា **វាយោ** ព្រោះអំណាចនៃភាពជាវត្ថុធ្វើឲ្យរសាត់ទៅ វត្ថុណានៅក្នុងវាយោទាំងឡាយ ដូចន័យដែលពោលមកហើយ ព្រោះហេតុនោះ វត្ថុនោះ ទើបឈ្មោះថា **វាយោគត** វត្ថុនោះបានដល់អ្វី វត្ថុនោះ បានដល់ លក្ខណៈ គឺ ការ កម្រើក ។

ពាក្យថា **ឧទ្ធង្គមា វាតា** គឺខ្យល់បក់ឡើងលើ ញ៉ាំងអាការ មានកើ និង ប្អើកជាដើមឲ្យប្រព្រឹត្តទៅ, ពាក្យថា **អធោគមា វាតា** គឺខ្យល់បក់ចុះក្រោមនាំយក ឧច្ចារៈបស្សាវៈជាដើមចេញទៅ ពាក្យថា **កុច្ឆិសយា វាតា** គឺខ្យល់នៅក្រៅពោះវៀន ។ ពាក្យថា **កោដ្ឋាសយា វាតា** គឺ ខ្យល់នៅខាងក្នុងពោះវៀន ។ ពាក្យថា **អង្គមង្គានុសារិនោ វាតា** គឺខ្យល់ដែលរត់ទៅតាមអវយវៈតូចធំទូទាំងសរីរៈ តាមរន្ធសរសៃឈាម ញ៉ាំងការបត់អវយវៈ និងការលាតអវយវៈជាដើមឲ្យកើតឡើងបាន ។ ពាក្យថា **អស្សាសោ** បានដល់ ខ្យល់ដកដង្ហើមចូលខាងក្នុង , ពាក្យថា **បស្សាសោ** បានដល់ ខ្យល់ដកដង្ហើមចេញក្រៅ ។

ដូច្នេះ ក្នុងខ្យល់ ៦ យ៉ាងនេះ ខ្យល់ ៥ ខាងដើម ជាចតុសមុដ្ឋាន , ខ្យល់អស្សាសបស្សាសៈ មានចិត្តជាសមុដ្ឋានតែម្យ៉ាង ។

ដោយបទនេះថា **យំ វា បនញ្ញម្បិ កិញ្ចិ** ឬសូម្បីវត្ថុដទៃណាមួយទៀត ក្នុងទុកនិទ្ទេស មានអាបោធាតុនិទ្ទេសជាដើម គឺ លោកសង្គ្រោះយកវត្ថុដែលជាអាបោធាតុជាដើម ដែលគប្បីមានក្នុងចំណែកនៃធាតុដ៏សេសចូលផង ។

ដោយប្រការដូចពោលមកនេះ ធាតុ ៤ គឺ លោកសម្តែងឲ្យពិស្តារហើយដោយអាការ ៤២ គឺ បឋវីធាតុ... ដោយអាការ ២០ , អាបោធាតុ... ដោយអាការ ១២ , តេជោធាតុ... ដោយអាការ ៤ , វាយោធាតុ... ដោយអាការ ៦ ដូច្នេះឯង ។

នេះជាការពណ៌នាសេចក្តីនៃបាលីក្នុង ធាតុវវត្ថាន ( វិត្ថារន័យ ) នោះប៉ុណ្ណោះឯង ។

## ភាវនាន័យ-វិធីភាវនា

## សង្ខេបន័យ

រីឯវិនិច្ឆ័យក្នុងភាវនាន័យ ក្នុងធាតុកម្មដ្ឋាននេះ គប្បីជ្រាបដូច្នេះ សម្រាប់ភិក្ខុអ្នកមានបញ្ញាចាស់ក្លា ការកំណត់ធាតុដោយពិស្តារ ( បែកទៅតាមអាការ ៤២ ) ថា កេសាបឋវីធាតុ សក់ទាំងឡាយជាធាតុដី លោមាបឋវី រោមទាំងឡាយជាធាតុដីដូច្នេះជាដើម ប្រាកដជានឹងយឺតយូរ តែកាលលោកមនសិការដោយលក្ខណៈថា វត្ថុដែលមានលក្ខណៈរឹង ជាធាតុដី វត្ថុដែលមានលក្ខណៈជ្រួតជ្រាប ជាធាតុទឹក វត្ថុដែលមានលក្ខណៈក្តៅ ជាធាតុភ្លើង វត្ថុដែលមានលក្ខណៈកម្រើក ជាធាតុខ្យល់ ដូច្នេះ កម្មដ្ឋានក៏នឹងប្រាកដ សម្រាប់ភិក្ខុអ្នកមានបញ្ញាមិនចាស់ក្លា កាលមនសិការ ( ដោយសង្ខេប ) យ៉ាងនោះ កម្មដ្ឋានរមែងរលត់ទៅ មិនភ្លឺស្វាង កាលមនសិការយ៉ាងពិស្តារតាមន័យមុន កម្មដ្ឋានទើបប្រាកដ សេចក្តីនេះមានឧបមាយ៉ាងណា ? មានឧបមាថា កាលភិក្ខុពីររូបស្វាធ្យាយបាលីដែលមានបេយ្យាលៈច្រើន ភិក្ខុអង្គដែលមានបញ្ញាចាស់ក្លា ញុំាងបេយ្យាលៈមុខ ( ន័យពេញ ) ឲ្យពិស្តារ គឺ សូត្រពេញមួយចប់ ឬ ពីរចប់ តពីនោះលោកក៏ស្វាធ្យាយតែក្បាលទាំងពីរ គឺដើមនិងចុង ក្នុងលោកពីរអង្គនោះ អង្គដែលមានបញ្ញាមិនចាស់ក្លា នឹងជាអ្នកពោលយ៉ាងនេះថា “ នុ៎ះមិនឈ្មោះថា ស្វាធ្យាយទេ មិនធ្វើតាមវិធីការ ឲ្យបបូរមាត់ប៉ះគ្នា ( គឺ សូត្រលះៗទៅ មិនបានប៉ុន្មានក៏ចប់ទៅ ហើយបបូរមាត់ដូចជានៅមិនទាន់ប៉ះគ្នា ) ការស្វាធ្យាយវិធីនេះប៉ុន្មានបែប ( បាលី ) ទើបរត់មាត់ ” លោកញុំាងបេយ្យាលៈមុខដែលមកដល់ៗ ឲ្យពិស្តារគ្រប់កន្លែង ធ្វើការស្វាធ្យាយទៅ( គឺស្វាធ្យាយពេញគ្រប់កន្លែង មិនលះតាមបេយ្យាលៈ ) ភិក្ខុមួយអង្គទៀត គឺ អង្គ

ដែលមានបញ្ញាចាស់ក្លា ក៏ពោលនឹងលោកអង្គនោះយ៉ាងនេះថា “ នុំះមិនបានឈ្មោះ ថា ស្វាធ្យាយទេ ព្រោះមិនដល់ទីបំផុត កាលស្វាធ្យាយវិធីនេះប៉ុន្មានបែប( បាលី ) ទើបនឹងចប់ដូច្នេះ ” យ៉ាងណា ការកំណត់ធាតុយ៉ាងពិស្ដារ ទៅតាមអាការ មាន សក់ជាដើម ក៏ប្រាកដយឺតយូរ សម្រាប់ភិក្ខុអ្នកមានបញ្ញាចាស់ក្លា កាលលោក មនសិការយ៉ាងសង្ខេបដោយន័យថា “ វត្ថុដែលមានលក្ខណៈរឹងជាធាតុដី ” ជាដើម កម្មដ្ឋានទើបប្រាកដ សម្រាប់ភិក្ខុមួយអង្គទៀត មនសិការយ៉ាងនោះ កម្មដ្ឋាននឹង ងងឹត មិនជាក់ច្បាស់ កាលមនសិការដោយពិស្ដារទៅតាមអាការ មានសក់ជាដើម កម្មដ្ឋានទើបប្រាកដក៏យ៉ាងនោះឯង ។

## វិធីចម្រើនធាតុកម្មដ្ឋាន
## សម្រាប់ភិក្ខុអ្នកមានបញ្ញាចាស់ក្លា

ព្រោះហេតុនោះ ភិក្ខុអ្នកមានបញ្ញាចាស់ក្លាប្រាថ្នានឹងបំពេញកម្មដ្ឋាននេះ ដំបូង គប្បីជាអ្នកនៅក្នុងទីស្ងាត់មនុស្ស សំងំនៅតែម្នាក់ឯងហើយ រំពឹងដល់រូបកាយរបស់ ខ្លួនឲ្យសព្វ កំណត់យកថា ជាធាតុទាំងឡាយដោយសង្ខេបយ៉ាងនេះថា “ ភាវៈរឹងក្ដី ភាវៈគ្រោតគ្រាតក្ដីឯណានៅក្នុងកាយនេះ ជាធាតុដី ភាវៈដែលជ្រួតជ្រាបក្ដី ភាវៈ រាវក្ដីឯណាទីមួយ មាននៅក្នុងកាយនេះ នេះជាធាតុទឹក ភាវៈរោលរាលក្ដី ភាវៈក្ដៅ ក្ដីឯណាទីមួយនៅក្នុងកាយនេះ នេះជាធាតុភ្លើង ភាវៈបក់ទៅក្ដី ភាវៈកម្រើកបានក្ដី ឯណាមួយមាននៅក្នុងកាយនេះ នេះជាធាតុខ្យល់ ” ដូច្នេះហើយ រំពឹងពិចារណាថា ត្រឹមតែជាធាតុ មិនមែនសត្វ មិនមែនជីវៈ ដោយបរិកម្មថា ដី ទឹក ជាដើមរឿយៗ កាលភិក្ខុនោះ ព្យាយាមយ៉ាងនោះ សមាធិ ( ភាវនា ) ដែលបញ្ញា ( ធ្វើកិច្ច )

ពិចារណាបែកធាតុ កំណត់បាន ជាសមាធិមិនដល់អប្បនា ត្រឹមតែជាឧបចារ ព្រោះមានសភាវធម៌ជាអារម្មណ៍ រមែងកើតឡើងបាន ដោយមិនយូរឡើយ ។

ឬមិនដូច្នោះ កោដ្ឋាស ៤ ពួកនេះ ដែលព្រះធម្មសេនាបតីពោលទុកដើម្បីសម្តែងភាពដែលមហាភូតទាំង ៤ ជានិស្សត្ត ( មិនមែនសត្វ ) ថា “ អាកាសដែលអាស្រ័យឆ្អឹង ១ អាស្រ័យសរសៃ ១ អាស្រ័យសាច់ ១ អាស្រ័យស្បែក ១ ហ៊ុមព័ទ្ធ បានឈ្មោះថា រូបប៉ុណ្ណោះឯង ” ដូច្នេះ ភិក្ខុគប្បីញែកកោដ្ឋាស ពួកនោះចេញដោយដៃ គឺ ញាណដែលប្រព្រឹត្តទៅតាមចន្លោះនៃកោដ្ឋាសនោះ ៗ កំណត់ធាតុទាំងឡាយតាមន័យនោះឯងថា “ ភាវៈរឹងក្តី ភាវៈគ្រោតគ្រាតឯណានីមួយ នៅក្នុងពួកកោដ្ឋាសនោះ នេះជាធាតុដី ” ដូច្នេះជាដើម និងពិចារណាថា ត្រឹមតែជាធាតុ មិនមែនសត្វ មិនមែនជីវៈ ដោយបរិកម្មថា ធាតុដី ធាតុទឹក ជាអាទិ៍ រឿយៗ កាលលោកព្យាយាមយ៉ាងនោះ សមាធិភាវនា ដែលបញ្ញាធ្វើកិច្ចពិចារណាបែកធាតុ កំណត់បាន ជាសមាធិមិនដល់អប្បនា ត្រឹមតែឧបចារ ព្រោះការមានសភាវធម៌ជាអារម្មណ៍ រមែងកើតឡើងបាន ដោយមិនយូរឡើយ ។

នេះជាភាវនាន័យក្នុងចតុធាតុវវដ្ឋាន ដែលមកដោយសង្ខេប ។

## វិត្ថារន័យ

ឯភាវនាន័យក្នុងចតុធាតុវវដ្ឋានដែលមានមកដោយពិស្តារ គប្បីជ្រាបដូចតទៅនេះ ។ ឯព្រះយោគីអ្នកមានបញ្ញាមិនទាន់ចាស់ក្លា ប្រាថ្នានឹងចម្រើនកម្មដ្ឋាន គប្បីរៀនអំពីធាតុឲ្យពិស្តារដោយអាការ ៤២ ក្នុងសម្នាក់របស់លោកអាចារ្យ ហើយ នៅក្នុងសេនាសនៈមានប្រការដូចពោលមកហើយ ធ្វើកិច្ចទាំងពួងឲ្យស្រេច

ហើយទៅក្នុងទីស្ងាត់មនុស្ស ពួនសំងំ ទើបចម្រើនកម្មដ្ឋានដោយអាការ ៤ យ៉ាងនេះ គឺដោយសសម្ភារសង្ខេប ( សង្ខេបកោដ្ឋាសទាំងឡាយជាក្រុមៗ តាមអាការរបស់ធាតុនោះៗ ) ដោយសសម្ភារវិភត្តិ ( ចែកកោដ្ឋាសនៃធាតុនោះៗ កំណត់យកអាការមួយៗ ) ដោយសលក្ខណៈសង្ខេប ( សង្ខេបកោដ្ឋាសទាំងឡាយចូលជាក្រុមៗ តាមលក្ខណៈរបស់ធាតុនោះ ) ដោយសលក្ខណវិភត្តិ ( ចែកកោដ្ឋាសនៃធាតុនោះៗ កំណត់លក្ខណៈមួយៗ ) ។

## ចម្រើនដោយសសម្ភារសង្ខេប

ក្នុងអាការ ៤ នោះ ចម្រើនដោយសសម្ភារសង្ខេប ដូចម្តេច ? ភិក្ខុក្នុងសាសនានេះ កំណត់យកអាការរឹងគ្រោតគ្រាតក្នុងកោដ្ឋាស ២០ ថា បឋវីធាតុ , កំណត់យកអាការសើមជ្រួតជ្រាបដែលជាសភាពរាវ ពោលគឺ ជាទឹកក្នុងកោដ្ឋាស ១២ ថា អាបោធាតុ , កំណត់យកភាពក្តៅដែលជាគ្រឿងដុតរោលក្នុងកោដ្ឋាស ៤ ថា តេជោធាតុ , កំណត់យកអាការបក់ទៅមកក្នុងកោដ្ឋាស ៦ ថា វាយោធាតុ កាលលោកកំណត់ យ៉ាងនោះ ធាតុទាំងឡាយនឹងប្រាកដជាប លោកអាវជ្ជនាការ ហើយមនសិការនូវធាតុទាំងឡាយនោះរឿយៗ ឧបចារសមាធិនឹងកើតឡើងតាមន័យដូចពោលហើយនោះឯង តែបើភិក្ខុណាចម្រើនយ៉ាងនោះ កម្មដ្ឋាននៅមិនទាន់សម្រេច ភិក្ខុនោះគប្បីចម្រើនដោយសសម្ភារវិភត្តិចុះ ។

## ចម្រើនដោយសសម្ភារវិភត្តិ

ចម្រើនដោយសសម្ភារវិភត្តិ ដូចម្តេច ? គឺភិក្ខុនោះ ដំបូងគប្បីធ្វើឧគ្គហ-កោសល ៧ ប្រការ និងមនសិការកោសល្យ ១០ ប្រការ ដែលពោលហើយក្នុង

កាយគតាសតិកម្មដ្ឋាននិទ្ទេសទាំងអស់ មិនឲ្យខ្វះចន្លោះហើយ ធ្វើវិធីដូចពោលក្នុងកាយគតាសតិកម្មដ្ឋាននិទ្ទេសនោះ គ្រប់យ៉ាង ចាប់ផ្តើមអំពីស្វាធ្យាយដោយវាចានូវអាការទាំងឡាយ មានអាការពួកតចបញ្ចកៈជាដើមក្នុងអាការ ៣២ ទាំងដោយអនុលោម និងបដិលោម ចំណែកសេចក្តីផ្សេងគ្នាមានដូច្នេះប៉ុណ្ណោះ គឺ កាលមនសិការអាការទាំងឡាយ មានសក់ជាដើម ដោយពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទដូចគ្នា តែថាក្នុងកាយគតាសតិនោះ ត្រូវតាំងចិត្តទុកក្នុងបដិកូលក្នុងធាតុវវដ្ឋាននេះ ត្រូវតាំងចិត្តទុកក្នុងធាតុ ព្រោះហេតុនោះ យោគាវចរភិក្ខុកាលមនសិការអាការទាំងឡាយ មានសក់ជាអាទិ៍ ម្យ៉ាង ៥ ចំណែក ដោយប្រការមានពណ៌ជាដើមហើយ ក្នុងទីបំផុតគប្បីញុាំងមនសិការឲ្យប្រព្រឹត្តទៅដូច្នេះ ។

## បឋវីកោដ្ឋាស

### កេសា - សក់ទាំងឡាយ

រីឯ សក់ទាំងឡាយនេះ កើតត្រង់ស្បែកហុំមស្រោបលលាដ៍ក្បាល ក្នុងស្បែកហុំមស្រោបលលាដ៍ក្បាល និងសក់ទាំងឡាយនោះ ស្បែកហុំមស្រោបលលាដ៍ក្បាល មិនដឹងថា សក់ទាំងឡាយដុះលើយើង សក់ទាំងឡាយសោតក៏មិនដឹងថា យើងដុះលើស្បែកហុំមលលាដ៍ក្បាល ប្រៀបដូចក្នុងស្មៅកុណ្ឌៈទាំងឡាយ ដុះនៅលើដំបូកកណ្តៀរ ដំបូកកណ្តៀរមិនដឹងថា ស្មៅកុណ្ឌៈទាំងឡាយដុះលើយើង ស្មៅកុណ្ឌៈសោតក៏មិនដឹងថា យើងដុះលើដំបូកកណ្តៀរ ក៏ដូច្នោះ ( ធម៌ គឺ វត្ថុ ) ទាំងឡាយនោះ ប្រាសចាកការគិត និងសេចក្តីត្រិះរិះដល់គ្នានិងគ្នា ឯសក់ទាំងឡាយ ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ

សុញ្ញទទេ ( ចាកអត្តា ) មិនមែនសត្វ ជារបស់គ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## លោមា - រោមទាំងឡាយ

រោមទាំងឡាយដែលដុះលើស្បែកស្រោបសរីរៈ ក្នុងស្បែកស្រោបសរីរៈ និងរោមទាំងឡាយនោះ ស្បែកស្រោបសរីរៈមិនដឹងថា រោមទាំងឡាយដុះលើយើង រោមទាំងឡាយសោតក៏មិនដឹងថា យើងដុះលើស្បែកស្រោបសរីរៈ ប្រៀបដូចស្បូវភ្លាំងទាំងឡាយ ដែលដុះក្នុងផ្ទះដែលគេបោះបង់ចោល ផ្ទះដែលគេបោះបង់ចោលនោះមិនដឹងថា ស្បូវភ្លាំងដុះកន្លែងយើង ស្បូវភ្លាំងសោតក៏មិនដឹងថា យើងដុះក្នុងផ្ទះដែលគេបោះបង់ចោល ក៏ដូច្នោះ ធម៌ទាំងឡាយនោះប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯរោមទាំងឡាយក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សុញ្ញទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុដោយប្រការដូច្នេះ ។

## នខា - ក្រចកទាំងឡាយ

ក្រចកទាំងឡាយកើតលើចុងម្រាមទាំងឡាយ ម្រាមដៃ និងក្រចកទាំងឡាយនោះ ម្រាមដៃទាំងឡាយមិនដឹងថា ក្រចកកើតលើចុងម្រាមរបស់យើង ក្រចកទាំងឡាយសោតក៏មិនដឹងថា យើងកើតលើចុងម្រាមទាំងឡាយ ប្រៀបដូចក្មេងទាំងឡាយយកឈើសៀតគ្រាប់ទន្លេលេង ឈើទាំងឡាយមិនដឹងថា គ្រាប់ទន្លេជាប់លើយើង គ្រាប់ទន្លេសោតក៏មិនដឹងថា យើងជាប់លើឈើទាំងឡាយ ក៏ដូច្នោះ , ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯក្រចកទាំងឡាយ

ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេ ចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## ឧដ្ឋា - ឆ្អឹងទាំងឡាយ

ឆ្អឹងទាំងឡាយកើតនឹងធ្អឹងចង្កា ធ្អឹងចង្កា និងឆ្អឹងទាំងឡាយនោះ ធ្អឹងចង្កា មិនដឹងថា ឆ្អឹងទាំងឡាយដុះលើយើង ឆ្អឹងទាំងឡាយសោតក៏មិនដឹងថា យើងដុះលើធ្អឹងចង្កា ប្រៀបដូចសសរផ្ទះ ត្រូវជាងឈើទាំងឡាយរុំគល់សសរដោយជ័រប្រភេទណាមួយ ហើយកប់ក្នុងរណ្ដៅថ្មទាំងឡាយ រណ្ដៅថ្មទាំងឡាយមិនដឹងថា សសរទាំងឡាយតាំងនៅក្នុងយើង សសរទាំងឡាយសោតក៏មិនដឹងថា យើងតាំងនៅក្នុងរណ្ដៅ ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯឆ្អឹងទាំងឡាយក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុដោយប្រការដូច្នេះ ។

## តចោ - ស្បែក

ស្បែកស្រោបសរីរៈទាំងអស់ ក្នុងសរីរៈនិងស្បែកនោះ សរីរៈមិនដឹងថា យើងត្រូវស្បែកស្រោប ស្បែកសោតក៏មិនដឹងថា សរីរៈត្រូវយើងហ៊ុមស្រោប ប្រៀបដូចពិណធំ ដែលស្រោបដោយស្បែកគោសុទ្ធ ពិណធំមិនដឹងថា យើងត្រូវស្បែកគោសុទ្ធស្រោប ស្បែកគោសោតក៏មិនដឹងថា ពិណធំត្រូវយើងស្រោបទុក ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯស្បែកនោះ ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ

សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុដោយប្រការដូច្នេះ ។

## មំសំ - សាច់

សាច់បូកលាបជាប់នៅតាមគ្រោងឆ្អឹង សាច់និងគ្រោងឆ្អឹងនោះ គ្រោងឆ្អឹងមិនដឹងថា យើងត្រូវសាច់ ៩០០ ប្រភេទផ្សេងៗគ្នា បូកលាបហើយ សាច់សោតក៏មិនដឹងថា គ្រោងឆ្អឹងត្រូវយើងបូកលាប ប្រៀបដូចជញ្ជាំងផ្ទះបូកដោយដីឥដ្ឋដុំធំៗ ជញ្ជាំងមិនដឹងថា យើងត្រូវដីឥដ្ឋដុំធំបូកលាប ដីឥដ្ឋដុំធំសោត ក៏មិនដឹងថា ជញ្ជាំងត្រូវយើងបូកលាប ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា សាច់នោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុដោយប្រការដូច្នេះ ។

## ឆហារូ - សរសៃទាំងឡាយ

សរសៃទាំងឡាយចងរឹតឆ្អឹងទាំងឡាយទុកនៅខាងក្នុងសរីរៈ ឆ្អឹង និងសរសៃទាំងឡាយនោះ ឆ្អឹងទាំងឡាយមិនដឹងថា យើងត្រូវសរសៃទាំងឡាយចងរឹត សរសៃទាំងឡាយសោតក៏មិនដឹងថា ឆ្អឹងទាំងឡាយត្រូវយើងចងរឹត ប្រៀបដូចឈើ ( ដើង ) ជញ្ជាំងត្រូវគេចងដោយវល្លិទាំងឡាយ ឈើ ( ដើង ) ជញ្ជាំងមិនដឹងថា យើងត្រូវវល្លិចង វល្លិសោតក៏មិនដឹងថា ឈើ ( ដើង ) ជញ្ជាំងត្រូវយើងចងទុក ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯសរសៃទាំងឡាយក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជា

អព្យាកត: សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## អដ្ឋិ - ឆ្អឹងទាំងឡាយ

ឆ្អឹងទាំងឡាយនោះ ឆ្អឹងកែងជើងទ្រឆ្អឹងកជើង តាំងនៅ ឆ្អឹងកជើងទ្រឆ្អឹងស្មងជើង ឆ្អឹងស្មងជើងទ្រឆ្អឹងភ្លៅ ឆ្អឹងភ្លៅទ្រឆ្អឹងចង្កេះ ឆ្អឹងចង្កេះទ្រឆ្អឹងខ្នង ឆ្អឹងខ្នងទ្រឆ្អឹងក ឆ្អឹងកទ្រឆ្អឹងក្បាល ឆ្អឹងក្បាលតាំងនៅលើ ឆ្អឹងកតាំងនៅលើឆ្អឹងខ្នង ឆ្អឹងខ្នងតាំងនៅលើឆ្អឹងចង្កេះ ឆ្អឹងចង្កេះតាំងនៅលើឆ្អឹងភ្លៅ ឆ្អឹងភ្លៅតាំងនៅលើឆ្អឹងស្មង ឆ្អឹងស្មងតាំងនៅលើឆ្អឹងកជើង ឆ្អឹងកជើងតាំងនៅលើឆ្អឹងកែងជើង ក្នុងឆ្អឹងទាំងនោះ ឆ្អឹងកែងជើងមិនដឹងថា យើងទ្រឆ្អឹងកជើងទេ ឆ្អឹងកជើងមិនដឹងថា យើងទ្រឆ្អឹងស្មងជើងទេ ឆ្អឹងស្មងជើងមិនដឹងថា យើងទ្រឆ្អឹងភ្លៅទេ ឆ្អឹងភ្លៅមិនដឹងថា យើងទ្រឆ្អឹងចង្កេះទេ ឆ្អឹងចង្កេះមិនដឹងថា យើងទ្រឆ្អឹងខ្នងទេ ឆ្អឹងខ្នងមិនដឹងថា យើងទ្រឆ្អឹងកទេ ឆ្អឹងកមិនដឹងថា យើងទ្រឆ្អឹងក្បាលទេ ឆ្អឹងក្បាលមិនដឹងថា យើងតាំងនៅលើឆ្អឹងកទេ ឆ្អឹងកមិនដឹងថា យើងតាំងនៅលើឆ្អឹងខ្នងៗ មិនដឹងថា យើងតាំងនៅលើឆ្អឹងចង្កេះៗ មិនដឹងថា យើងតាំងនៅលើឆ្អឹងភ្លៅៗ មិនដឹងថា យើងតាំងនៅលើឆ្អឹងស្មងៗ មិនដឹងថា យើងតាំងនៅលើឆ្អឹងកជើងៗ មិនដឹងថា យើងតាំងនៅលើឆ្អឹងកែងជើងទេ ប្រៀបដូចក្នុងគំនរវត្ថុដែលដាក់ត្រួតៗគ្នា មានឥដ្ឋ ឈើ និងអាចម៍គោជាដើម ចំណែកក្រោមៗ មិនដឹងថា យើងទ្រចំណែកខាងលើៗ ចំណែកខាងលើៗសោត ក៏មិនដឹងថា យើងតាំងនៅលើចំណែកខាងក្រោមៗ ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯឆ្អឹង

ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេ ចាកអត្តា មិនមែនសត្វ ជាវត្ថុរឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## អដ្ឋិមិញ្ជំ - ខួរក្នុងឆ្អឹង

ខួរក្នុងឆ្អឹងតាំងនៅផ្នែកខាងក្នុងរបស់ឆ្អឹងនោះៗ ក្នុងឆ្អឹង និងខួរនោះ ឆ្អឹងទាំងឡាយមិនដឹងថា ខួរតាំងនៅខាងក្នុងយើងទេ ខួរសោតក៏មិនដឹងថា យើងតាំងនៅខាងក្នុងឆ្អឹងទាំងឡាយដែរ ប្រៀបដូចលំពង់ឈើទាំងឡាយ មានលំពង់ផ្តៅដែលត្រូវភ្លើងហើយជាដើម ត្រូវបុគ្គលស៊កចូលខាងក្នុងបំពង់ឈើ មានបំពង់ឫស្សីជាអាទិ៍ បំពង់ឫស្សីជាដើមមិនដឹងថា លំពង់ផ្តៅជាដើមត្រូវគេស៊កចូលក្នុងយើង លំពង់ផ្តៅជាដើមសោត ក៏មិនដឹងថា យើងនៅក្នុងបំពង់ឫស្សីជាដើម ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯខួរក្នុងឆ្អឹងក៏ជាកោដ្ឋាសមួយផ្នែក ក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## វក្កំ - តម្រងបស្សាវៈ

វក្កំជាដុំសាច់មួយគូជាប់នៅហ្នឹងសរសៃធំ គល់ជាខ្សែមួយរត់ចេញពីបំពង់កទៅបន្តិច បែកជាពីរខ្សែស្រោបបេះដូង ក្នុងសរសៃធំ និងវក្កៈនោះ សរសៃធំមិនដឹងថា វក្កៈជាប់នៅហ្នឹងយើង វក្កៈក៏មិនដឹងថា យើងជាប់នៅហ្នឹងសរសៃធំ ប្រៀបដូចផ្លែស្វាយមួយគូ ដែលជាប់នៅហ្នឹងទងជាមួយគ្នា ទងមិនដឹងថា ផ្លែស្វាយមួយគូនៅជាប់នឹងយើង ផ្លែស្វាយមួយគូនោះសោត ក៏មិនដឹងថា យើងនៅជាប់ហ្នឹងទង

ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯវក្កុំក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## ហទយំ - បេះដូង

បេះដូងអាស្រ័យនៅត្រង់កណ្តាលធ្អឹងប្រអប់ទ្រូង តាំងនៅខាងក្នុងសរីរៈ ធ្អឹងប្រអប់ទ្រូង និងបេះដូងនោះ ខាងក្នុងធ្អឹងប្រអប់ទ្រូងមិនដឹងថា បេះដូងអាស្រ័យនឹងយើង បេះដូងសោត ក៏មិនដឹងថា យើងអាស្រ័យនៅខាងក្នុងធ្អឹងប្រអប់ទ្រូង ប្រៀបដូចដុំសាច់ដែលគេទុកនៅក្នុងស្នែង ( ស្វាបគ្រុឌ ) ចាស់ៗ ស្នែងមិនដឹងថា ដុំសាច់គេទុកនៅក្នុងយើង ដុំសាច់សោតក៏មិនដឹងថា យើងត្រូវគេទុកខាងក្នុងស្នែងចាស់ ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯបេះដូងក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## យកនំ - ថ្លើម

ថ្លើមតាំងនៅជាប់ធ្អឹងជំនីខាងស្តាំ ក្នុងចំណែកខាងក្នុងដោះទាំងពីរក្នុងសរីរៈ ក្នុងធ្អឹងជំនីខាងស្តាំ ក្នុងចំណែកខាងក្នុងដោះ និងថ្លើមនោះ ធ្អឹងជំនីស្តាំក្នុងចំណែកខាងក្នុងដោះ មិនដឹងថា ថ្លើមជាប់នៅហ្នឹងយើងទេ ថ្លើមសោតក៏មិនដឹងថា យើងជាប់នៅហ្នឹងធ្អឹងជំនីខាងស្តាំក្នុងចំណែកខាងក្នុងដោះ ប្រៀបដូចដុំសាច់មួយគូដែល

ជាប់នៅនឹងអំបែងថ្ពាំង អំបែងថ្ពាំងមិនដឹងថា ដុំសាច់មួយគូជាប់នៅនឹងយើង ដុំសាច់មួយគូនោះសោតក៏មិនដឹងថា យើងជាប់នៅនឹងអំបែងថ្ពាំង ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯថ្លើមនោះ ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## កិលោមកំ - វាវ

ក្នុងវាវទាំងឡាយ វាវប្រភេទមិនប្រាកដ ហ៊ុមជុំវិញហទយៈ និងវក្កៈ វាវប្រភេទប្រាកដ ហ៊ុមស្រោបដុំសាច់នៅក្នុងស្បែកទូទាំងសរីរៈ ក្នុងវក្កៈ ហទយៈ ដុំសាច់ទូទាំងសរីរៈ និងវាវនោះ វក្កៈ ហទយៈ ដុំសាច់ទូទាំងសរីរៈមិនដឹងថា យើងត្រូវវាវ ហ៊ុមស្រោប វាវសោតក៏មិនដឹងថា វក្កៈ ហទយៈ និងដុំសាច់ទូទាំងសរីរៈត្រូវយើងស្រោប ប្រៀបដូចដុំសាច់ដែលគេខ្ចប់ទុកដោយសំពត់កខ្វក់ សាច់មិនដឹងថា យើងត្រូវគេខ្ចប់ទុកដោយសំពត់កខ្វក់ សំពត់កខ្វក់នោះសោតក៏មិនដឹងថា សាច់ត្រូវគេខ្ចប់ ទុកដោយយើង ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯវាវក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## បិហកំ - ក្រពះ

ក្រពះនៅជាប់ផ្នែកខាងលើនៃពិតានពោះ ខាងឆ្វេងនៃបេះដូង ផ្នែកលើនៃពិតានពោះ និងក្រពះនោះ ផ្នែកលើនៃពិតានពោះ មិនដឹងថា ក្រពះជាប់ហ្នឹងយើង

ក្រពះសោតក៏មិនដឹងថា យើងជាប់ផ្នែកលើនៃពោះ ប្រៀបដូចដុំអាចម៍គោដែលជាប់ផ្នែកលើនៃជង្រុកស្រូវ ផ្នែកលើនៃជង្រុកស្រូវមិនដឹងថា ដុំអាចម៍គោជាប់ហ្នឹងយើង ដុំអាចម៍គោសោតក៏មិនដឹងថា យើងជាប់ហ្នឹងផ្នែកលើនៃជង្រុកស្រូវ ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯក្រពះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## បច្ចាសំ - ស្អូត

ស្អូតព្យរឃ្នុំបេះដូង និងថ្លើម នៅក្នុងរវាងដោះទាំងពីរ ក្នុងចំណែកខាងក្នុងនៃសរីរៈ ក្នុងចំណែកខាងក្នុងនៃសរីរៈ និងស្អូតនោះ ក្នុងចំណែកខាងក្នុងនៃសរីរៈ មិនដឹងថា ស្អូតព្យរនៅត្រង់យើង ស្អូតសោតក៏មិនដឹងថា យើងព្យរនៅក្នុងចំណែកខាងក្នុងនៃសរីរៈ មានរូបយ៉ាងនោះ ប្រៀបដូចសម្បុកសត្វដែលព្យរខាងក្នុងនៃជង្រុកស្រូវចាស់ៗ ចំណែកខាងក្នុងនៃជង្រុកចាស់មិនដឹងថា សម្បុកសត្វព្យរនៅក្នុងយើង សម្បុកសត្វសោតក៏មិនដឹងថា យើងព្យរនៅខាងក្នុងជង្រុកស្រូវចាស់ ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯស្អូតនោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុដោយប្រការដូច្នេះ ។

## អន្តំ - ពោះវៀនធំ

ពោះវៀនធំនៅក្នុងខាងក្នុងនៃសរីរៈ មានចុងនៅគល់កម្ចាង និងនៅជាប់ទ្វារធំម្ខាង ក្នុងខាងក្នុងនៃសរីរៈ និងពោះវៀនធំនោះ ខាងក្នុងសរីរៈមិនដឹងថា ពោះវៀន

ធំនៅក្នុងយើង ពោះវៀនធំសោតក៏មិនដឹងថា យើងនៅខាងក្នុងនៃសរីរៈ ប្រៀបដូចសពពស់ដាច់ក្បាលដែលគេធ្លាយដាក់ចុះក្នុងស្នូកឈាម ស្នូកឈាមមិនដឹងថា សពពស់នៅក្នុងយើង សពពស់សោតក៏មិនដឹងថា យើងនៅក្នុងស្នូកឈាម ក៏ដូច្នោះធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯពោះវៀនធំក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុដោយប្រការដូច្នេះ ។

## អន្តគុណំ - ពោះវៀនតូច

ពោះវៀនតូចរុំព័ទ្ធពោះវៀនធំ ដែលបត់ទៅបត់មក ២១ ផ្នត់ នៅក្នុងរវាងនៃពោះវៀនធំ ក្នុងពោះវៀនធំ និងពោះវៀនតូចនោះ ពោះវៀនធំមិនដឹងថា ពោះវៀនតូចរុំព័ទ្ធខ្លួនទេ ពោះវៀនតូចសោតក៏មិនដឹងថា ខ្លួនរុំព័ទ្ធពោះវៀនធំដែរ ប្រៀបដូចខ្សែតូចទាំងឡាយ ដែលវេញធ្វាក់ចង្វាយខ្សែធំ សម្រាប់ជូតជើង ចង្វាយខ្សែធំសម្រាប់ជូតជើងមិនដឹងថា ខ្សែតូចវេញក្រងយើង ខ្សែតូចសោតក៏មិនដឹងថា យើងវេញក្រងចង្វាយខ្សែធំសម្រាប់ជូតជើង ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯពោះវៀនតូចក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## ឧទរិយំ - អាហារថ្មី

អាហារថ្មី គឺ វត្ថុដែលបរិភោគ ក្រេបផឹក ទំពាស៊ី លិទ្ធភ្លក្សចូលទៅនៅក្នុងពោះ ក្នុងពោះ និងអាហារថ្មីនោះ ពោះមិនដឹងថា អាហារថ្មីនៅក្នុងយើងទេ អាហារ

ថ្មីសោតក៏មិនដឹងថា យើងនៅក្នុងពោះដែរ ប្រៀបដូចកម្ទេចក្អែលដែលនៅក្នុងស្នូកក្អែ ស្នូកបាយក្អែមិនដឹងថា កម្ទេចក្អែនៅក្នុងយើង កម្ទេចក្អែសោតក៏មិនដឹងថា យើងនៅក្នុងស្នូកក្អែដែរ ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯអាហារថ្មីក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## ករីសំ - អាហារចាស់

អាហារចាស់នៅហ្នឹងចុងពោះវៀនធំ សណ្ឋានដូចបំពង់ឫស្សី ប្រវែងប្រមាណ ៨ ធ្នាប់ ដែលហៅថា **បក្កាសយ**( ក្រពះឧច្ចារៈ ) ក្នុងក្រពះឧច្ចារៈ និងអាហារចាស់នោះ ក្រពះឧច្ចារៈមិនដឹងថា អាហារចាស់នៅហ្នឹងយើង អាហារចាស់សោតក៏មិនដឹងថា យើងនៅក្នុងក្រពះឧច្ចារៈ ប្រៀបដូចដីពណ៌លឿងដ៏ម៉ដ្ឋ ដែលគេញាត់ចូលក្នុងបំពង់ឫស្សី បំពង់ឫស្សីមិនដឹងថា ដីពណ៌លឿងនៅក្នុងយើង ដីពណ៌លឿងសោតក៏មិនដឹងថា យើងនៅក្នុងបំពង់ឫស្សី ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯអាហារចាស់ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## មត្ថលុង្គំ - ខួរក្នុងក្បាល

ខួរក្នុងក្បាល នៅក្នុងខាងក្នុងលលាដ៍ក្បាល ក្នុងខាងក្នុងនៃលលាដ៍ក្បាល និង ខួរក្បាលនោះ ខាងក្នុងនៃលលាដ៍ក្បាលមិនដឹងថា ខួរក្បាលនៅក្នុងយើង ខួរ

ក្បាលសោតក៏មិនដឹងថា យើងនៅខាងក្នុងនៃលលាដ៍ក្បាល ប្រៀបដូចដុំម្សៅដែលគេដាក់ចុះក្នុងសំបកឃ្លោកចាស់ៗ សំបកឃ្លោកមិនដឹងថា ដុំម្សៅនៅក្នុងយើង ដុំម្សៅសោតក៏មិនដឹងថា យើងនៅក្នុងសំបកឃ្លោក ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯខួរក្នុងក្បាលក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជារបស់រឹងគ្រោតគ្រាត ជាបឋវីធាតុ ដោយប្រការដូច្នេះ ។

## អាបោកោដ្ឋាស

## បិត្តំ - ទឹកប្រមាត់

ក្នុងប្រមាត់ទាំងឡាយ ទឹកប្រមាត់ប្រភេទចល័តទីបាន ជារបស់ជាប់នៅជាមួយនឹងជីវិតិន្ទ្រិយ ជ្រួតជ្រាបទូទាំងសរីរៈ ប្រភេទទឹកប្រមាត់ថង់ នៅក្នុងថង់ទឹកប្រមាត់ ក្នុងសរីរៈ , ទឹកប្រមាត់ចល័ត និងថង់ទឹកប្រមាត់ ព្រមទាំងតឹកប្រមាត់ថង់សរីរៈមិនដឹងថា ទឹកប្រមាត់ចល័ត ជ្រួតជ្រាបលើយើង ប្រមាត់មិនជាប់នៅហ្នឹងកន្លែងសោតក៏មិនដឹងថា យើងជ្រួតជ្រាបក្នុងសរីរៈ ប្រៀបដូចខ្លាញ់ដែលជ្រាបក្នុងនំនំមិនដឹងថា ខ្លាញ់ជ្រួតជ្រាបក្នុងយើង ខ្លាញ់សោតក៏មិនដឹងថា យើងជ្រួតជ្រាបក្នុងនំ ក៏ដូច្នោះ ថង់ទឹកប្រមាត់មិនដឹងថា ប្រមាត់ថង់នៅក្នុងយើង ឯប្រមាត់ថង់សោតក៏មិនដឹងថា ខ្លួននៅក្នុងថង់ទឹកប្រមាត់ ប្រៀបដូចស្រែកឺននោងព្រៃដែល

ពេញដោយទឹកភ្លៀង ស្រុកីនទោងព្រៃមិនដឹងថា ទឹកភ្លៀងនៅក្នុងយើង ទឹកភ្លៀងសោតក៏មិនដឹងថា យើងនៅក្នុងស្រុកីនទោងព្រៃដែរ ក៏ដូច្នោះ ធម៌ទាំងឡាយនោះប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯទឹកប្រមាត់ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## សេម្ហំ - ស្លេស្ម

ស្លេស្មមានប្រមាណមួយកម្បង់ ( បាឋៈថា ១ បាត្រ ) នៅហ្នឹងពិតានពោះក្នុងពិតានពោះ និងស្លេស្មនោះ ពិតានពោះមិនដឹងថា ស្លេស្មនៅហ្នឹងយើង ស្លេស្មសោតក៏មិនដឹងថា យើងនៅហ្នឹងពិតានពោះ ប្រៀបដូចអណ្តូងទឹកស្មោកគ្រោកដែលមានដុំពពុះទឹកកើតពីលើ អណ្តូងទឹកស្មោកគ្រោកមិនដឹងថា ដុំពពុះទឹកកើតលើយើង ដុំពពុះទឹកសោតក៏មិនដឹងថា យើងកើតលើអណ្តូងទឹកស្មោកគ្រោក ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯស្លេស្មក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## បុព្វោ - ខ្ទុះ

បុព្វមិនមានឱកាស គឺ ទីនៅជាប្រចាំក្នុងកន្លែងនៃរាងកាយណាមួយទេ កាលត្រូវដង្កត់ជង់ បន្ទាមុត និងអណ្តាតភ្លើងជាដើមប៉ះត្រូវ ឈាមក៏កករ ឬបូស និងពងបែកជាដើមកើតឡើង វាក៏មកប្រាកដក្នុងកន្លែងនៃរាងកាយនោះៗ ឯង ហើយ

ក្នុងកន្លែងនៃរាងកាយ ដែលត្រូវជង្គត់ និងបន្ទាជាដើមប៉ះត្រូវជាមួយនឹងបុព្វានោះ កន្លែងនៃរាងកាយដែលត្រូវជង្គត់ និងបន្ទាជាដើមប៉ះត្រូវ មិនដឹងថា បុព្វាកើតនៅក្នុងយើង បុព្វាសោតក៏មិនដឹងថា យើងនៅក្នុងកន្លែងនៃរាងកាយទាំងឡាយនោះ ប្រៀបដូចដើមឈើដែលមានជ័រហូរ ដោយអំណាចនៃការកាប់ដោយពូថៅជាដើម កន្លែងដែលត្រូវកាប់ជាដើមនៃដើមឈើក៏មិនដឹងថា ជ័រមកនៅក្នុងយើង ជ័រសោតក៏មិនដឹងថា យើងនៅក្នុងកន្លែងដែលត្រូវកាប់ជាដើមរបស់ដើមឈើ ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯបុព្វាជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុដោយប្រការដូច្នេះ ។

## លោហិតំ - ឈាម

ក្នុងលោហិតទាំងឡាយ ***សំសរណលោហិត***( ឈាមមានចលនា ) ជ្រួតជ្រាបទៅទូទាំងសរីរៈ ដូចទឹកប្រមាត់( ប្រភេទមានចលនា ) ***សន្និចិតលោហិត***( លោហិតមិនមានចលនា )ពេញចំណែកខាងក្រោមទីនៅរបស់ថ្លើម មានប្រមាណមួយកម្បង់ញុំាំងក្រពះ បេះដូង ថ្លើម និងសួតឲ្យសើម ក្នុងលោហិតពីរយ៉ាងនោះ វិនិច្ឆ័យក្នុងសំសរណលោហិត ក៏ដូចគ្នានឹងប្រភេទប្រមាត់ដែលមិនជាប់នៅនឹងកន្លែងនោះដែរ ចំណែកក្នុងលោហិតម្យ៉ាងទៀត គឺ ***សន្និចិតលោហិត*** គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ទឹកដែលបុគ្គលចាក់ដាក់ក្នុងអំបែងឆ្នាំងចាស់ៗ ឆ្នាំងធ្លុះស្រក់ចុះ ទៅធ្វើដុំដីនិង ដុំគ្រួសជាដើម ដែលនៅខាងក្រោមឲ្យសើម ដុំដី និង ដុំគ្រួសជាដើម មិនដឹង

ថា យើងត្រូវទឹកធ្វើឲ្យសើម ទឹកសោតក៏មិនដឹងថា យើងធ្វើឲ្យដុំដី និងដុំគ្រួសជាដើមឲ្យសើម យ៉ាងណា ចំណែកខាងក្រោមនៃថ្ងឹមក្តី ក្រពះជាដើមក្តី មិនដឹងថា ឈាមខាំងនៅក្នុងយើង ឬថា ឈាមធ្វើយើងឲ្យសើម ឈាមសោតក៏មិនដឹងថា យើងខាំងនៅពេញចំណែកខាងក្រោមនៃថ្លើម ធ្វើក្រពះជាដើមឲ្យសើមដូច្នេះដូចគ្នា ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯលោហិតក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## សេទោ - ញើស

ញើសខាំងនៅពេញរន្ធសក់ និងរោមខ្លះ ហូរចេញមកក្នុងពេលដែលក្តៅព្រោះភ្លើងជាដើមខ្លះ ក្នុងរន្ធសក់ និងរោម និងញើសនោះ រន្ធសក់ និងរោមទាំងឡាយមិនដឹងថា ញើសហូរចេញអំពីយើង ញើសសោតក៏មិនដឹងថា យើងហូរចេញអំពីរណ្តៅសក់ និងរោមទាំងឡាយ ប្រៀបដូចបាច់ក្រអៅឈូក និងដើមព្រលិតលុះត្រូវគេដកឡើងពីទឹក រន្ធក្នុងក្រអៅឈូកជាដើមក៏មិនដឹងថា ទឹកហូរចេញពីយើង ទឹកដែលកំពុងហូរចេញអំពីរន្ធក្រអៅឈូកជាដើមសោត ក៏មិនដឹងថា យើងហូរចេញអំពីរន្ធបាច់ក្រអៅឈូកជាដើម ក៏ដូច្នេះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯញើសនោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## មេទោ - ខ្លាញ់ខាប់

ខ្លាញ់ខាប់ គឺ ខ្លាញ់ខាប់ដែលផ្សាយទៅទាំងសរីរៈ របស់មនុស្សធាត់ ជាប់នៅតាមសាច់ ( ដុំ ) សម្រាប់មនុស្សស្គមជាប់នៅតាមកំភួនជើងជាដើម ក្នុងសាច់ដុំ និងខ្លាញ់ខាប់នោះ សាច់ដុំក្នុងសរីរៈទាំងអស់ ( របស់មនុស្សធាត់ ) ក្តី ក្នុងអវយវៈ មានស្មង កំភួនជើងជាដើម ( របស់មនុស្សស្គម ) ក្តី មិនដឹងថាខ្លាញ់ជាប់នឹងយើង ខ្លាញ់សោតក៏មិនដឹងថា យើងជាប់នឹងសាច់ដុំ នៅក្នុងសរីរៈទាំងអស់ ( របស់មនុស្សធាត់ ) ឬក្នុងអវយវៈ មានកំភួនជើងជាដើម ( របស់មនុស្សស្គម ) ដូចដុំសាច់ដែលគេខ្ចប់ទុកដោយសំពត់ចាស់ពណ៌លឿត ( លឿងខ្ចី ) ដុំសាច់មិនដឹងថា សំពត់ពណ៌លឿងខ្ចីជាប់ហ៊ុំយើង សំពត់ចាស់ពណ៌លឿងខ្ចីសោតក៏មិនដឹងថា យើងជាប់ហ៊ុំដុំសាច់ក៏ដូច្នោះ ធម៌ទាំងឡាយនោះប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯខ្លាញ់ខាប់នោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការស្រើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## អស្សុ - ទឹកភ្នែក

ទឹកភ្នែកកើតឡើងកាលណា កាលនោះ វាក៏ដក់នៅពេញរន្ធភ្នែកខ្លះ ហូរចេញមកខ្លះ រន្ធភ្នែក និងទឹកភ្នែកនោះ រន្ធភ្នែកមិនដឹងថា ទឹកភ្នែកនៅក្នុងយើង ទឹកភ្នែកសោតក៏មិនដឹងថា យើងនៅក្នុងរន្ធភ្នែក ប្រៀបដូចផ្ទៃត្នោតខ្ចីៗ ដែលពេញដោយទឹក ផ្ទៃត្នោតខ្ចីមិនដឹងថា ទឹកនៅក្នុងយើង ទឹកក្នុងផ្ទៃត្នោតខ្ចីសោតក៏មិនដឹងថា យើងនៅក្នុងផ្ទៃត្នោតខ្ចី ក៏ដូច្នេះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះ

ដល់គ្នានិងគ្នា ឯទឹកភ្នែកនោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិតជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## វសា - ខ្លាញ់រាវ

ខ្លាញ់រាវ គឺ ខ្លាញ់ដែលរលាយនៅតាមបាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ដូចប្រមុះ ថ្ងាស និងចង្ក័យស្មា ក្នុងពេលត្រូវកម្តៅ ព្រោះភ្លើងជាដើម ក្នុងកន្លែងនៃរាងកាយ មានបាតដៃជាដើម និងខ្លាញ់រាវនោះ កន្លែងនៃរាងកាយ មានបាតដៃជាដើមមិនដឹងថា ខ្លាញ់រាវហៀរហូរលើយើង ខ្លាញ់រាវសោតក៏មិនដឹងថា យើងហៀរហូរក្នុងកន្លែងនៃរាងកាយ មានបាតដៃជាដើម ប្រៀបដូចបាយក្តាំងដែលគេប្រឡាក់ខ្លាញ់ បាយក្តាំងមិនដឹងថា ខ្លាញ់ហៀរហូរលើយើង ខ្លាញ់សោតក៏មិនដឹងថា យើងហៀរហូរលើបាយក្តាំង ក៏ដូច្នេះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិតនិងការត្រិះរិះដល់គ្នានិងគ្នា ឯខ្លាញ់រាវនោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## ខេឡោ - ទឹកមាត់

ទឹកមាត់កាលមានបច្ច័យធ្វើឲ្យទឹកមាត់ចេញមកយ៉ាងនោះ វាក៏ហូរចុះចាកក្រពេញថ្ពាល់ទាំងពីរមកនៅលើអណ្តាត ក្នុងអណ្តាត និងទឹកមាត់នោះ អណ្តាតមិនដឹងថា ទឹកមាត់ហូរចេញចាកក្រពេញថ្ពាល់ទាំងពីរខាងមកនៅលើយើង ទឹកមាត់សោតក៏មិនដឹងថា យើងហូរចុះចាកក្រពេញថ្ពាល់ទាំងពីរខាង មកនៅលើអណ្តាត

ប្រៀបដូចរណ្ដៅនៅមាត់ច្រាំងនៃស្ទឹងដែលមានទឹកជ្រាបចេញមិនដាច់ ផ្ទៃរណ្ដៅមិនដឹងថា ទឹកនៅក្នុងយើង ទឹកសោតក៏មិនដឹងថា យើងនៅក្នុងផ្ទៃនៃរណ្ដៅ ដូច្នេះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯទឹកមាត់នោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## សិង្ឃាណិកា - ទឹកសម្បោរ

បើទឹកសម្បោរកើតឡើងកាលណា កាលនោះ វាក៏ដក់នៅពេញរន្ធច្រមុះខ្លះហូរចេញមកខ្លះ ក្នុងប្រហោងច្រមុះ និងទឹកសម្បោរនោះ រន្ធច្រមុះមិនដឹងថា ទឹកសម្បោរនៅក្នុងយើង ទឹកសម្បោរសោតក៏មិនដឹងថា យើងនៅក្នុងរន្ធច្រមុះ ប្រៀបដូចសម្បកខ្យងហោងដែលពេញដោយទឹកខ្ទេះ សម្បកខ្យងហោងមិនដឹងថា ទឹកខ្ទេះនៅក្នុងយើង ទឹកខ្ទេះសោតក៏មិនដឹងថា យើងនៅក្នុងសម្បកខ្យងហោង ដូច្នេះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯទឹកសម្បោរនោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុដោយប្រការដូច្នេះ ។

## លសិកា - ទឹករំអិល

ទឹករំអិលធ្វើកិច្ច គឺ ការលាបសន្លាក់នៃឆ្អឹងទាំងឡាយឲ្យសម្រេច នៅក្នុងសន្លាក់នៃឆ្អឹងប្រមាណ ១៨០ កន្លែង ក្នុងសន្លាក់ ១៨០ កន្លែង និងទឹករំអិលនោះ

សន្ទាក់ ១៨០ កន្ទែនមិនដឹងថា ទឹករំអិលលាបយើង ទឹករំអិលសោតក៏មិនដឹងថា យើងលាបសន្ទាក់ ១៨០ កន្ទែនឲ្យជាប់ ប្រៀបដូចក្ដៅទេះ ដែលមនុស្សបន្តក់ដោយប្រេង ក្ដៅមិនដឹងថា ប្រេងលាបយើង ប្រេងសោតក៏មិនដឹងថា យើងលាបក្ដៅរទេះក៏ដូច្នេះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯទឹករំអិលនោះ ក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## មុត្តំ - ទឹកមូត្រ

បើទឹកមូត្រនៅខាងក្នុងប្លោកបស្សាវៈ ក្នុងប្លោកបស្សាវៈ និងទឹកមូត្រនោះ ប្លោកបស្សាវៈមិនដឹងថា ទឹកមូត្រនៅក្នុងយើង ទឹកមូត្រសោតក៏មិនដឹងថា យើងនៅក្នុងប្លោកបស្សាវៈ ប្រៀបដូចឆ្នាំងដីគ្រោតគ្រាត ដែលគេបោះចុះទៅផ្កាប់នៅក្នុងរណ្ដៅស្មោកគ្រោក ឆ្នាំងដីគ្រោតគ្រាតមិនដឹងថា ទឹកស្មោកគ្រោកនៅក្នុងយើង ទឹកស្មោកគ្រោកសោតក៏មិនដឹងថា យើងនៅក្នុងឆ្នាំងដីខ្សាច់ក៏ដូច្នោះ ធម៌ទាំងឡាយនោះ ប្រាសចាកការគិត និងការត្រិះរិះដល់គ្នានិងគ្នា ឯមូត្រនោះក៏ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ ជាវត្ថុរាវ មានអាការសើមជ្រួតជ្រាប ជាអាបោធាតុ ដោយប្រការដូច្នេះ ។

## តេជោកោដ្ឋាស

ព្រះយោគាវចរ កាលញុំាងមនសិការឲ្យប្រព្រឹត្តទៅក្នុងបឋវីកោដ្ឋាស និង អាបោកោដ្ឋាសទាំងឡាយ មានសក់ជាអាទិ៍ ដូចពោលមកហើយ គប្បីញុំាង មនសិការឲ្យប្រព្រឹត្តទៅក្នុងតេជោកោដ្ឋាសទាំងឡាយយ៉ាងនេះថា :

រាងកាយ រមែងក្តៅព្រោះភ្លើងណា ភ្លើងដែលជាហេតុឲ្យក្តៅនៃរាងកាយនេះ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យទទេ ចាកអត្តា មិនមែនសត្វ មានអាការក្តៅ ជាតេជោធាតុ ។

រាងកាយ រមែងទ្រុឌទ្រោមព្រោះភ្លើងណា ភ្លើងដែលជាហេតុញុំាងរាងកាយ ឲ្យទ្រុឌទ្រោមនេះ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជា អព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ មានអាការក្តៅ ជាតេជោធាតុ ។

រាងកាយ រមែងសោប់សល់ព្រោះភ្លើងណា ភ្លើងដែលជាហេតុញុំាងកាយ ឲ្យសោប់សល់នៃរាងកាយនេះ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមាន ការគិត ជាអព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ មានអាការក្តៅ ជា តេជោធាតុ ។

របស់បរិភោគ ក្រេបផឹក ទំពាស៊ី លិទ្ធភក្សចូលទៅហើយ រមែងដល់នូវការ រលាយទៅដោយល្អព្រោះភ្លើងណា ភ្លើងដែលជាហេតុញុំាងរបស់បរិភោគ ក្រេបផឹក ទំពាស៊ីលិទ្ធភក្សនេះ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជា អព្យាកតៈ សូន្យទទេចាកអត្តា មិនមែនសត្វ មានអាការក្តៅ ជាតេជោធាតុ ។

## វាយោកោដ្ឋាស

តពីនោះ គប្បីកំណត់ឧទ្ធង្គមវាត ខ្យល់បក់ឡើងលើ , កំណត់អធោគមវាត ជាខ្យល់បក់ចុះក្រោម , កំណត់កុច្ឆិសយវាត ជាខ្យល់បក់នៅក្នុងពោះ , កំណត់កោដ្ឋាសយវាត ជាខ្យល់បក់នៅខាងក្នុងពោះវៀន , កំណត់អង្គមង្គានុសារិវាត ជាខ្យល់បក់ទៅតាមអង្គាយវៈតូចធំ , កំណត់អស្សាសបស្សាសៈ ជាខ្យល់ដកដង្ហើមចូល និងចេញ គប្បីមនសិការឲ្យប្រព្រឹត្តទៅក្នុងវាយោកោដ្ឋាសទាំងឡាយ យ៉ាងនេះថា :

ឯខ្យល់បក់ឡើងលើទាំងឡាយ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិតជាអព្យាកតៈ សូន្យចាកអត្តា មិនមែនសត្វ មានអាការបក់ទៅមក ជាវាយោធាតុ ។

ឯខ្យល់បក់ចុះក្រោមទាំងឡាយ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិតជាអព្យាកតៈ សូន្យចាកអត្តា មិនមែនសត្វ មានអាការបក់ទៅមក ជាវាយោធាតុ ។

ឯខ្យល់នៅក្នុងពោះ ឬ ក្រៅពោះវៀនទាំងឡាយ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិតជាអព្យាកតៈ សូន្យចាកអត្តា មិនមែនសត្វ មានអាការបក់ទៅមក ជាវាយោធាតុ ។

ខ្យល់បក់នៅក្នុងពោះវៀនទាំងឡាយ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យចាកអត្តា មិនមែនសត្វ មានអាការបក់ទៅមក ជាវាយោធាតុ ។

ឯខ្យល់បក់ទៅមកតាមអន្តរាវយវៈតូចធំទាំងឡាយ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិត ជាអព្យាកតៈ សូន្យចាកអត្តា មិនមែនសត្វ មានអាការបក់បោកទៅមក ជាវាយោធាតុ ។

ឯខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញទាំងឡាយ ជាកោដ្ឋាសមួយផ្នែកក្នុងរាងកាយនេះ មិនមានការគិតជាអព្យាកតៈ សូន្យចាកអត្តា មិនមែនសត្វ មានអាការបក់ទៅមក ជាវាយោធាតុ ។

ធាតុទាំងឡាយនឹងប្រាកដដល់ព្រះយោគាវចរនោះ អ្នកមានមនសិការប្រព្រឹត្តទៅយ៉ាងនេះ កាលលោកអាវជ្ជនាការទៅ មនសិការនូវធាតុទាំងនោះរឿយៗ ឧបចារសមាធិនឹងកើតឡើង តាមន័យដូចពោលមកហើយនោះឯង ។

តែកាលព្រះយោគាវចរអង្គណាចម្រើនទៅយ៉ាងនោះ កម្មដ្ឋាននៅមិនទាន់សម្រេច ព្រះយោគាវចរអង្គនោះគប្បីចម្រើនដោយសលក្ខណៈសង្ខេបចុះ ។

## ចម្រើនដោយសលក្ខណៈសង្ខេប

គប្បីចម្រើនដោយសលក្ខណៈសង្ខេបដូចម្ដេច ? គប្បីកំណត់យកលក្ខណៈដែលរឹងគ្រោតគ្រាត ២០ ថាជាធាតុដី គប្បីកំណត់យកលក្ខណៈសើមជ្រួតជ្រាបក្នុងកោដ្ឋាស ២០ នោះឯង ថាជាធាតុទឹក គប្បីកំណត់លក្ខណៈដែលក្ដៅក្នុងកោដ្ឋាស ២០ នោះឯង ថាជាធាតុភ្លើង គប្បីកំណត់យកលក្ខណៈដែលកម្រើកបានក្នុងកោដ្ឋាស ២០ នោះឯង ថាជាធាតុខ្យល់ ។

គប្បីកំណត់យកលក្ខណៈ សើមជ្រួតជ្រាបបានក្នុងកោដ្ឋាស ១២ នោះឯង ថាជាធាតុទឹក គប្បីកំណត់យកលក្ខណៈដែលក្ដៅក្នុងកោដ្ឋាស ១២ នោះឯង ហើយ

ថាជាធាតុភ្លើង គប្បីកំណត់យកលក្ខណៈដែលកម្រើកបានក្នុងកោដ្ឋាស ១២ នោះឯងថាជាធាតុខ្យល់ គប្បីកំណត់យកលក្ខណៈដែលរឹងគ្រោតគ្រាត ក្នុងកោដ្ឋាស ១២ នោះឯងថាជាធាតុដី ។

គប្បីកំណត់យកលក្ខណៈ ដែលក្ដៅក្នុងកោដ្ឋាស ៤ នោះ ថាជាធាតុភ្លើង គប្បីកំណត់យកលក្ខណៈដែលកម្រើកបាន ដែលញែកចេញចាកធាតុភ្លើង នោះមិនបានថា ជាធាតុខ្យល់ គប្បីកំណត់យកលក្ខណៈដែលរឹងគ្រោតគ្រាត ដែលញែកចេញចាកធាតុភ្លើងនោះមិនបានថាធាតុដី គប្បីកំណត់យកលក្ខណៈដែលសើមជ្រួតជ្រាប ដែលញែកចេញចាកធាតុភ្លើងនោះមិនបាន ថាជាធាតុទឹក ។

គប្បីកំណត់យកលក្ខណៈ ដែលកម្រើកបានក្នុងកោដ្ឋាស ៦ នោះឯង ថាជាធាតុខ្យល់ គប្បីកំណត់យកលក្ខណៈដែលរឹងគ្រោតគ្រាតក្នុងកោដ្ឋាស ៦ នោះឯងថាជាធាតុដី គប្បីកំណត់យកលក្ខណៈសើមជ្រួតជ្រាប ក្នុងកោដ្ឋាស ៦ នោះឯងថាជាធាតុទឹក គប្បីកំណត់យកលក្ខណៈដែលក្ដៅ ក្នុងកោដ្ឋាស ៦ នោះឯង ថាជាធាតុភ្លើង ។

កាលបើព្រះយោគាវចរកំណត់ទៅយ៉ាងនោះ ធាតុទាំងឡាយរមែងប្រាកដ ឧបចារសមាធិរមែងកើតឡើងដល់លោកអ្នកដែលអាវជ្ជនាការ មនសិការនៅក្នុងហេតុទាំងឡាយនោះរឿយៗ តាមន័យដែលពោលហើយនោះឯង ។

តែកាលព្រះយោគាវចរអង្គណា សូម្បីចម្រើនទៅយ៉ាងនោះ កម្មដ្ឋានក៏នៅមិនទាន់សម្រេច ព្រះយោគីអង្គនោះ គប្បីចម្រើនដោយសលក្ខណៈវិភត្តិតទៅ ។

## ចម្រើនដោយសលក្ខណៈវិភត្តិ

គប្បីចម្រើនដោយលក្ខណៈវិភត្តិដូចម្ដេច ? គប្បីចាប់យកកោដ្ឋាសទាំងឡាយមានសក់ជាអាទិ៍ តាមន័យដូចបានពោលមកហើយ ក្នុងសសម្ភារវិភត្តិនោះឯង មកកំណត់លក្ខណៈដែលរឹងគ្រោតគ្រាតក្នុងសក់ថាធាតុដី គប្បីកំណត់លក្ខណៈសើមជ្រួតជ្រាបក្នុងសក់នោះឯងថាធាតុទឹក គប្បីកំណត់លក្ខណៈដែលក្ដៅក្នុងសក់នោះថាធាតុភ្លើង គប្បីកំណត់លក្ខណៈដែលកម្រើកក្នុងសក់នោះ ថាធាតុខ្យល់ គប្បីកំណត់ធាតុបួនៗ ក្នុងកោដ្ឋាសមួយៗ គ្រប់កោដ្ឋាសយ៉ាងនេះ កាលលោកកំណត់ទៅយ៉ាងនោះ ធាតុទាំងឡាយរមែងប្រាកដ ឧបចារសមាធិ រមែងកើតឡើងដល់លោកអ្នកដែលជាអាវជ្ជនាការ មនសិការនូវធាតុទាំងឡាយនោះរឿយៗ តាមន័យដូចពោលមកហើយនោះឯង ។

## មនសិការដោយអាការ ១៣ ក៏បាន

ឯន័យម្យ៉ាងទៀត គប្បីមនសិការធាតុទាំងឡាយ ដោយអាការទាំងនេះក៏បានគឺ

| | | |
|---|---|---|
| វចនត្ថតោ | ដោយអត្ថនៃពាក្យ | ។ |
| កលាបតោ | ដោយកលាបៈ គឺជាសំណុំ | ។ |
| ចុណ្ណតោ | ដោយរំលាយឲ្យជាចុណ្ណៈ | ។ |
| លក្ខណាទិតោ | ដោយអាការ មានលក្ខណៈជាដើម | ។ |
| សមុដ្ឋានតោ | ដោយសមុដ្ឋាន | ។ |
| នានត្តេកត្តតោ | ដោយភាពផ្សេងគ្នា និងដូចគ្នា | ។ |
| វិនិព្ភោគាវិនិព្ភោគតោ | ដោយញែកបាន និងញែកមិនបាន | ។ |

| | |
|---|---|
| *សភាគវិសភាគតោ* | *ដែលចូលគ្នាបាន និងចូលគ្នាមិនបាន ។* |
| *អជ្ឈត្តិកពាហិរវិសេសតោ* | *ដោយការប្លែកគ្នានៃធាតុខាងក្នុង និងធាតុខាងក្រៅ ។* |
| *សង្គហតោ* | *ដែលរួបរួមគ្នា ចូលជាមួយគ្នា ។* |
| *បច្ចយតោ* | *ដោយជាបច្ច័យដល់គ្នានិងគ្នា ។* |
| *អសមន្នាហារតោ* | *ដោយមិនមានការរិះគិត ។* |
| *បច្ចយវិភាគតោ* | *ដោយចំណែកនៃបច្ច័យ ។* |

## ដោយអត្ថនៃពាក្យ

*ក្នុងអាការទាំងនោះ ព្រះយោគាវចរ កាលមនសិការដោយអត្ថនៃពាក្យ គប្បីមនសិការដោយអត្ថនៃពាក្យតាមដែលប្លែកគ្នា និងដូចគ្នាយ៉ាងនេះ ចំពោះន័យដែលប្លែកគ្នាមានសេចក្តីថា ធាតុ ឈ្មោះថា* ***បឋវី*** *ព្រោះជារបស់គ្រោតគ្រាត , ឈ្មោះថា* ***អាបោ*** *ព្រោះហូរទៅបាន ឬ ព្រោះជ្រួតជ្រាបទៅបាន ឬព្រោះធ្វើឲ្យសើម , ឈ្មោះថា* ***តេជោ*** *ព្រោះធ្វើឲ្យក្តៅ , ឈ្មោះថា* ***វាយោ*** *ព្រោះបក់ទៅ ចំណែកន័យមិនប្លែកគ្នា គប្បីមនសិការថា វត្ថុដែលឈ្មោះថា ធាតុ ព្រោះទ្រទ្រង់នូវលក្ខណៈរបស់ខ្លួន ព្រោះជាទីតាំងនៃទុក្ខ និងជាទីទទួលទុក្ខ ។*

## ដោយកលាបៈ

*ពោលដោយកលាបៈ មានពណ៌នាថា បឋវីធាតុដែលលោកសម្តែងដោយអាការ ២០ ដោយន័យថា សក់ រោមជាដើម និងអាបោធាតុដែលសម្តែងដោយអាការ ១២ ដោយន័យថា ប្រមាត់ ស្លេស្មជាដើមនេះ ព្រោះក្នុងអាការទាំងនោះ*

មានការប្រជុំគ្នានៃធម៌ ៨ គឺ ពណ៌ ក្លិន រស ឱជា និងធាតុទាំង ៤ ការសម្មតិថា **សក់** ទើបមានបាន កាលធម៌ទាំងនោះត្រូវបែកដាច់ពីគ្នា ការសម្មតិថា សក់ក៏មិនមាន ។

ព្រោះហេតុនោះ ពាក្យថា **សក់** បានដល់ សំណុំនៃធម៌ ៨ នោះឯង, ពាក្យថា **រោម** ជាដើម ក៏ដូច្នោះ តែក្នុងកោដ្ឋាសពួកនោះ កោដ្ឋាសមានកម្មជាសមុដ្ឋានកោដ្ឋាសនោះជា ( ទសធម្មកលាបៈ ) សំណុំនៃធម៌ ១០ ព្រមទាំងជីវិតិន្ទ្រិយ និងភាវរូបផង តែក៏គង់រាប់ថា ជាបឋវីធាតុ អាបោធាតុ ដោយអំណាចនៃលក្ខណៈដែលប្រាកដច្បាស់ ព្រះយោគីគប្បីមនសិការដោយកលាបៈដូចពោលមកដូច្នេះ ។

## ដោយជាចុណ្ណៈ

ដោយជា **ចុណ្ណ** មានអធិប្បាយថា បឋវីធាតុដែលល្អិតរហូតជាប្រភេទបរិមាណូ ជាលម្អងល្អិតក្នុងសរីរៈនេះ មានកំណត់កាន់យកដោយប្រមាណរាងកាយមនុស្សខ្នាតកណ្ដាល បឋវីធាតុនោះមានត្រឹមតែមួយទោណប៉ុណ្ណោះ ឯអាបោធាតុដែលមានប្រមាណកន្លះទោណនោះ ជួយផ្សារឲ្យជាប់គ្នា តេជោធាតុជួយរក្សាមិនឲ្យស្អុយ វាយោធាតុជួយទ្រទ្រង់ ទើបមិនឲ្យខ្ចាត់ខ្ចាយ មិនឲ្យបែកធ្លាយ វាមិនខ្ចាត់ខ្ចាយ មិនបែកធ្លាយ ទើបបានទទួលភាវៈវិកប្ប ( ការកំណត់ញែកភាវៈ ) ច្រើនយ៉ាង មានការរាប់ថាស្រី ថាប្រុសជាដើម និងប្រកាសភាវៈផ្សេងៗ មានស្គមធាត់ ខ្ពស់ ទាប មាំមួន អន់ថយជាដើម ។

ចំណែកអាបោធាតុដែលដល់ការរាប់ថា ជារបស់រាវ មានអាការជ្រួតជ្រាបក្នុងសរីរៈនេះ អាស្រ័យបឋវីធាតុ តេជោធាតុជួយរក្សាទុក វាយោធាតុជួយទ្រទុក

ទើបមិនស្រក់ មិនហូរចេញមកក្រៅ វាមិនស្រក់មិនហូរចេញមកអស់ ទើបសម្ដែងភាពឆ្អែតឆ្អន់ចេញមកឲ្យប្រាកដ ។

ចំណែកតេជោធាតុដែលមានការក្ដៅជាលក្ខណៈ មានអាការអប់ឧណ្ហ ញុំាងរបស់ដែលបរិភោគចូលទៅ ផឹកចូលទៅជាដើមឲ្យរលាយបាន ក្នុងសរីរៈនេះ អាស្រ័យបឋវីធាតុ អាបោធាតុជួយរក្សាទុក វាយោធាតុជួយទ្រទុក ទើបធ្វើកាយនេះឲ្យអប់ឧណ្ហបាន និងនាំយកការដល់ព្រមនៃពណ៌សម្បុរឲ្យដល់កាយផងដែរ និងម្យ៉ាងទៀត កាយនេះត្រូវតេជោធាតុធ្វើឲ្យអប់ឧណ្ហ ទើបមិនបានសម្ដែងភាពស្អុយឲ្យប្រាកដ ។

ចំណែកវាយោធាតុដែលមានការកម្រើកញ័រ និងទ្រទ្រង់ជាលក្ខណៈ បក់ទៅតាមអង្គាយវៈតូចធំក្នុងសរីរៈនេះ អាស្រ័យបឋវីធាតុ អាបោធាតុជួយភ្ជាប់ តេជោធាតុជួយរក្សាទុក ទើបទ្រកាយនេះទុកបាន ឯកាយនេះដែលវាយោធាតុ ដែលមានលក្ខណៈទ្រទ្រង់នោះ ទប់ជ្រែងទើបមិនដួល ទើបតាំងត្រង់បាន ឯវាយោធាតុម្យ៉ាងទៀត ( មានលក្ខណៈកម្រើកញ័រ ) ជម្រុញហើយ ទើបសម្ដែងវិញ្ញត្តិក្នុងឥរិយាបថ គឺ ដើរ ដេក ឈរ អង្គុយ បត់បាន លាតបាន កម្រើកដៃជើងបាន ។

ធាតុយន្ត ( គ្រឿងកែច្នៃដែលធ្វើដោយធាតុ ) នេះប្រព្រឹត្តទៅដូចគ្នានឹងមាយារូប ( រូបបួម ដូចកាពយន្ត ) ជាគ្រឿងបោកបញ្ឆោតមនុស្សល្ងង់បាន ដោយភាវៈមានភាវៈស្រី និងភាវៈប្រុសជាដើម ដូច្នេះ ។

ព្រះយោគាវចរគប្បីមនសិការដោយ ( លម្អិតឲ្យ ) ជាចុណ្ណដូចពោលមកហើយដូច្នេះ ។

## ដោយអាការមានលក្ខណៈជាដើម

ប្រការថា ដោយអាការមានលក្ខណៈជាដើម មានពណ៌នាថា ព្រះយោគាវចរគប្បីអាវជ្ជនាការដល់ធាតុទាំង ៤( ជា ៣ ប្រការ ) ដូច្នេះថា **ធាតុ** ( ១ ) មានលក្ខណៈដូចម្ដេច , ( ២ ) មានរស ( គឺជាកិច្ច )ដូចម្ដេច , ( ៣ ) មានអាការប្រាកដដូចម្ដេចជាដើម ហើយទើបមនសិការដោយអាការ មានលក្ខណៈជាដើមយ៉ាងនេះថា :

បឋវីធាតុមានភាពរឹងគ្រោតគ្រាតជាលក្ខណៈ មានភាពជាទីអាស្រ័យនៃធាតុដទៃជារស មានការទ្រទ្រង់ធាតុដទៃទុកបានជាអាការប្រាកដ ។

អាបោធាតុមានការហូរជាលក្ខណៈ មានការកពូនធាតុដទៃជារស មានការភ្ជាប់ ( ធាតុដទៃ ) ទុកជាអាការប្រាកដ ។

តេជោធាតុមានការក្ដៅជាលក្ខណៈ មានការធ្វើឲ្យរលាយជារស មានការធ្វើឲ្យទន់ដល់រាងកាយរឿយៗ ជាអាការប្រាកដ ។

វាយោធាតុមានការទ្រទ្រង់ជាលក្ខណៈ មានការកម្រើកញ័រជាកិច្ច មានការសម្ដែងឥរិយាបថផ្សេងៗបាន ជាអាការប្រាកដ ។

## ដោយសមុដ្ឋាន

ប្រការថា ( ដោយសមុដ្ឋាន ) មានអធិប្បាយថា ព្រះយោគាវចរគប្បីមនសិការដោយសមុដ្ឋានយ៉ាងនេះថា កោដ្ឋាស ៤២ មានសក់ជាដើម ដែលព្រះមានព្រះភាគទ្រង់សម្ដែងទុក ទ្រង់សម្ដែងជាកោដ្ឋាសនៃធាតុ មានបឋវីធាតុជាដើម ដោយពិស្ដារ ក្នុងកោដ្ឋាសទាំងឡាយនោះ កោដ្ឋាស ៤ គឺអាហារថ្មី អាហារ

ចាស់ បុព្វោ មូត្រ ជាឧតុសមុដ្ឋាន ( មានរដូវជាសមុដ្ឋាន ) តែម្យ៉ាង , ៤ នេះ គឺ ទឹកភ្នែក ញើស ទឹកមាត់ ទឹកសម្បោរ ជាឧតុចិត្តសមុដ្ឋាន ( មានរដូវខ្លះ ចិត្តខ្លះជាសមុដ្ឋាន ) ភ្លើងញ៉ាំងអាហារដែលបរិភោគចូលទៅជាដើមឲ្យរលាយ ជាកម្មសមុដ្ឋាន ( មានកម្មជាសមុដ្ឋាន ) តែម្យ៉ាង ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ជាចិត្តសមុដ្ឋាន ( មានចិត្តជាសមុដ្ឋាន ) តែម្យ៉ាង , កោដ្ឋាសដ៏សេសទាំងអស់ ( គឺ បឋវី និងអាបោ កោដ្ឋាស ២៤ មានសក់ជាដើម , តេជោកោដ្ឋាស ៣ ខាងដើម និងវាយោកោដ្ឋាស ៥ រួមជា ៣២ នេះ ) ជាចតុសមុដ្ឋាន ( គឺ មានកម្មខ្លះ ចិត្តខ្លះ អាហារខ្លះ រដូវខ្លះជាសមុដ្ឋាន ) ។

## ដោយសេចក្ដីផ្សេងគ្នា និងសេចក្ដីដូចគ្នា

សេចក្ដីថា **ដោយការផ្សេងគ្នា និងដូចគ្នា** មានពណ៌នាថា ធាតុទាំងពួងរមែងមានសេចក្ដីផ្សេងគ្នា ដោយអាការមានលក្ខណៈប្រចាំខ្លួនជាដើម ពិតមែនលក្ខណៈ រស និងអាការប្រាកដ នៃបឋវីធាតុម្យ៉ាង នៃធាតុដទៃ មានអាបោធាតុជាដើមម្យ៉ាង តែថា ធាតុទាំងឡាយនោះសូម្បីកើតផ្សេងគ្នា ដោយអំណាចនៃអាការមានលក្ខណៈជាដើម និងដោយអំណាចនៃសមុដ្ឋាន មានកម្មសមុដ្ឋានជាដើមក៏មានសេចក្ដីដូចគ្នា ដោយអំណាចនៃភាពជារូប ជាមហាភូត ជាធាតុ ជាធម៌ និងជារបស់មិនទៀងជាដើម ។

ពិតហើយ ធាតុទាំងពួងបានឈ្មោះថា រូប ព្រោះធាតុទាំងពួងនោះ មិនកន្លងរុប្បនលក្ខណៈ( លក្ខណៈ គឺការបែកធ្លាយ ) ទៅបាន ឈ្មោះថា ជាមហាភូតដោយហេតុច្រើនយ៉ាង ដូចមានប្រាកដភាពធំជាដើម ។

ពាក្យថា ដូចមានប្រាកដភាពធំជាដើមនោះ អធិប្បាយថា ធាតុទាំងឡាយនេះ ទ្រង់ហៅថា **មហាភូត** ដោយហេតុទាំងនេះ គឺ :

| | | |
|---|---|---|
| **មហន្តបាតុភាវតោ** | ព្រោះប្រាកដភាពធំ | ។ |
| **មហាភូតសមញ្ញតោ** | ព្រោះស្មើដោយមហាភូត | ។ |
| **មហាបរិហារតោ** | ព្រោះត្រូវបរិហារច្រើន | ។ |
| **មហាវិការតោ** | ព្រោះមានវិការធំ | ។ |
| **មហត្តាភូតត្តា ច** | ព្រោះជារបស់ធំ និងព្រោះជារបស់ពិតផង ។ | |

## ការមានប្រាកដភាពធំ

ក្នុងបទទាំងឡាយនោះ បទថា **ព្រោះមានប្រាកដភាពធំ** មានសេចក្ដីថា ភូត គឺ ធាតុទាំង ៤ នេះ ប្រាកដជារបស់ធំ ទាំងក្នុងអនុបាទិន្នសន្តាន ទាំងក្នុងឧបាទិន្នសន្តាន ការដែលប្រាកដជារបស់ធំនៃសន្តាន ២ យ៉ាងនោះ ក្នុងអនុបាទិន្នសន្តាន ពោលទុកហើយក្នុងពុទ្ធានុស្សតិនិទ្ទេស ដោយន័យថា ផែនដីនេះ បើគិតពីកម្រាស់ បានប្រមាណប៉ុណ្ណេះ គឺ ២៤០.០០០០ យោជន៍ ដូច្នេះជាដើម សូម្បីក្នុងឧបាទិន្នសន្តាន ក៏ប្រាកដជារបស់ធំដូចគ្នា ដោយប្រាកដនៃសរីរៈត្រី អណ្ដើក ទេវតា និងទានពជាដើម ដូចបាលីថា ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ អត្តភាព ( ជង្ឃនរបស់សត្វ ) ទាំងឡាយ វែងប្រវែង ១០០ យោជន៍ក៏មានដូច្នេះជាដើម ។

## សេចក្តីស្មើគ្នាដោយមហាភូត

បទថា **ព្រោះស្មើដោយមហាភូត** មានពណ៌នាថា ភូត គឺធាតុទាំងឡាយនោះ ខ្លួនឯងមិនបានជាវត្ថុមានពណ៌ខៀវឡើយ តែសម្តែងឧបាទាយរូបពណ៌ខៀវបាន ខ្លួនឯងមិនបានជាវត្ថុមានពណ៌លឿងឡើយ តែសម្តែងឧបាទាយរូបពណ៌លឿងបាន ខ្លួនឯងមិនបានជាវត្ថុមានពណ៌ក្រហមឡើយ តែសម្តែងឧបាទាយរូបពណ៌ក្រហមបាន ខ្លួនឯងមិនបានជាវត្ថុមានពណ៌សទេ តែសម្តែងឧបាទាយរូបពណ៌សបាន ប្រៀបដូចអ្នកលេងកល សម្តែងល្បិចធ្វើទឹកដែលមិនមែនកែវ ឲ្យជាកែវបាន សម្តែងដុំដីដែលមិនមែនមាសឲ្យជាមាសបានក៏ដូច្នោះ , ម្យ៉ាងទៀត ប្រៀបដូចមនុស្សអ្នកលេងកលនោះ ខ្លួនឯងមិនមែនជាយក្ខ មិនមែនជាសត្វ តែសម្តែងជាយក្ខក៏បាន ជាសត្វក៏បាន ដូច្នោះ ព្រោះហេតុនោះ ធាតុទាំងឡាយនោះ ទើបបានឈ្មោះថា មហាភូត ប្រៀបដូចមនុស្សចម្លែក ( ឬមនុស្សមិនពិត ) ធំ គឺ អ្នកលេងកល ។

ម្យ៉ាងទៀត ភូតធំទាំងឡាយ មានយក្ខជាដើមចាប់ ( គឺ ចូលសណ្ឋិត ) ក្នុងអ្នកណា ភូតដែលសណ្ឋិតនៅក្នុងអ្នកនោះ រមែងរកមិនឃើញឡើយ ក្នុងខាងក្នុងកាយរបស់អ្នកនោះ សូម្បីខាងក្រៅកាយរបស់គេ ក៏មិនជួប និងវាមិនបានអាស្រ័យអ្នកនោះក៏មិនមែន យ៉ាងណា សូម្បីភូត គឺ ធាតុទាំងឡាយនោះ ក៏ដូច្នោះដូចគ្នា ទីតាំងនៅខាងក្នុងគ្នានិងគ្នាក៏មិនឃើញ ទីតាំងនៅខាងក្រៅគ្នានិងគ្នា ក៏មិនឃើញ និងវាមិនបានអាស្រ័យគ្នានិងគ្នាក៏មិនមែន ព្រោះហេតុនោះ ធាតុទាំងឡាយនោះ ទើបបានឈ្មោះថា **មហាភូត** ព្រោះស្មើដោយភូតធំ មានយក្ខជាដើម ព្រោះថា មានទីតាំងរកគិតមិនដល់ ប្រការ ១ ។

ន័យម្យ៉ាងទៀត ភូតធំទាំងឡាយ ពោលគឺ យក្ខិនីបិទបាំងការៈដែលខ្លួនជា

ភូត គួរឲ្យខ្លាចស្រេចហើយ បញ្ឆោតសត្វទាំងឡាយដោយពណ៌សម្បុរ សណ្ឋាន និងភាពកែក្រាយ ដ៏គួរឲ្យពេញចិត្ត យ៉ាងណា សូម្បី ភូត គឺធាតុទាំងឡាយនេះ ក៏ដូច្នោះ បិទបាំងរស ( គឺ កិច្ច ) និងលក្ខណៈប្រចាំខ្លួន ឲ្យមានសភាពផ្សេង មានភាពដែលខ្លួន ជារបស់គ្រោតគ្រាតជាដើមបាត់ហើយ បញ្ឆោតមនុស្សល្ងង់ ដោយឆវីវណ្ណដ៏ស្អាត ដែលទ្រទ្រង់អង្គាយវៈតូចធំដ៏គួរពេញចិត្ត និងដោយការ កម្រើកជើង ផ្ទាត់ម្រាម និងញាក់ចិញ្ចើមដ៏គួរឲ្យពេញចិត្ត ក្នុងសណ្ឋានទាំងឡាយ មានសណ្ឋានរាងកាយស្ត្រី និងបុរសជាដើម មិនឲ្យឃើញសភាពនៃខ្លួន ព្រោះ ហេតុនោះ ធាតុទាំងឡាយទើបឈ្មោះថា **មហាភូត** ព្រោះស្មើនឹងភូតធំ គឺយក្ខិនី ព្រោះជាវត្ថុបោកបញ្ឆោត ប្រការ ១ ។

## ការដែលត្រូវបរិហារច្រើន

បទថា **ព្រោះត្រូវបរិហារច្រើន** មានន័យថា ព្រោះត្រូវបរិហារដោយបច្ច័យ ទាំងឡាយជាច្រើន ពិតមែន **ភូត** គឺធាតុទាំងឡាយនោះកើតឡើងហើយ គឺប្រព្រឹត្ត ទៅបានដោយបច្ច័យទាំងឡាយ មានរបស់បរិភោគ និងគ្រឿងស្លៀកពាក់ជាដើម ដែលរាប់ថាច្រើន ព្រោះត្រូវនាំចូលមកបំប៉នរាល់ៗថ្ងៃ ព្រោះហេតុនោះ ទើបឈ្មោះ ថា **មហាភូត** ន័យម្យ៉ាងទៀត ឈ្មោះថា **មហាភូត** ព្រោះជាភូត មានគ្រឿងបរិហារ ច្រើនដូច្នេះក៏បាន ។

## ការមានវិការធំ

បទថា **ព្រោះមានវិការធំ** មានសេចក្តីថា ភូត គឺធាតុទាំងឡាយនោះ ទាំង ដែលជាឧបាទិន្ន ទាំងដែលជាអនុបាទិន្ន ជាធម្មជាតិមានសភាពធំខុសប្រក្រតី ក្នុង

២ យ៉ាងនោះ សម្រាប់អនុបាទិន្ន ភាពធំខុសប្រក្រតី រមែងប្រាកដក្នុងកាលកប្បវិនាស សម្រាប់ឧបាទិន្នប្រាកដ កាលធាតុកម្រើក ពិតហើយ :

អណ្តាតភ្លើងឆេះសន្ធោសន្ធៅអំពីផែនដី ស្ទុះឡើងទៅដល់ព្រហ្មលោក ក្នុងកាលលោកត្រូវភ្លើងប្រល័យកប្បឆេះ ។

មួយសែនកោដិចក្រវាឡរលំរលាយទៅ កាលលោកវិនាសដោយទឹកប្រល័យកប្បកម្រើកឡើង ។

មួយសែនកោដិចក្រវាឡខ្ចាត់ខ្ចាយទៅ កាលលោកវិនាសដោយធាតុខ្យល់ប្រល័យកប្បកម្រើកឡើង ។

ប្រការមួយ រាងកាយត្រូវពស់កដ្ឋមុខ ( មាត់ឈើ ) ខាំហើយ រមែងរឹងក្រទាំង រាងកាយនោះ ព្រោះបឋវីធាតុកម្រើក ក៏រមែងរឹងក្រទាំង ដូចដែលរឹងក្រទាំង ព្រោះត្រូវពស់កដ្ឋមុខខាំដូច្នោះ ។

ប្រការមួយទៀត រាងកាយត្រូវពស់បូតិមុខ ( មាត់ស្អុយ ) ខាំហើយ រមែងស្អុយរលួយទៅ រាងកាយនោះ ព្រោះអាបោធាតុកម្រើក ក៏រមែងស្អុយរលួយ ដូចដែលស្អុយរលួយ ព្រោះត្រូវពស់បូតិមុខខាំ ដូច្នោះ ។

ប្រការមួយទៀត រាងកាយត្រូវពស់អគ្គិមុខ ( មាត់ភ្លើង ) ខាំហើយ រមែងក្តៅរោលរាល រាងកាយនោះ ព្រោះតេជោធាតុកម្រើក ក៏រមែងក្តៅរោលរាល ដូចដែលក្តៅរោលរាល ព្រោះត្រូវពស់អគ្គិមុខខាំ ដូច្នោះ ។

ប្រការមួយទៀត រាងកាយត្រូវពស់សត្ថមុខ ( មាត់កាំបិត ) ខាំហើយ រមែងដាច់ដាច រាងកាយនោះ ព្រោះវាយោធាតុកម្រើក ក៏រមែងដាច់ដាច ដូចដាច់ដាច ព្រោះត្រូវពស់សត្ថមុខខាំ ដូច្នោះ ។

ភូត គឺ ធាតុទាំងឡាយ មានវិការធំៗ ដូច្នេះ ព្រោះហេតុនោះ ទើបបាន ឈ្មោះថា **មហាភូត** ។

## សេចក្តីជារបស់ធំនិងពិតផង

សេចក្តីថា ព្រោះជារបស់ធំ និងព្រោះជារបស់ពិតផងនោះ មានសេចក្តីថា ភូត គឺ ធាតុទាំងឡាយនោះ ឈ្មោះថា **ជារបស់ធំ** ព្រោះជាវត្ថុដែលគប្បីកំណត់ឲ្យឃើញ តាមសភាពបានដោយសេចក្តីព្យាយាមធំ ព្រោះសភាវៈជាវត្ថុដែលដឹងបានដោយលំបាក ឈ្មោះថា **ជារបស់ពិត** ព្រោះជារបស់មានពិត ព្រោះហេតុនោះ ទើបបាន ឈ្មោះថា **មហាភូត** ព្រោះជារបស់ធំ និងជារបស់ពិត ។

ធាតុទាំងពួងនោះ បានឈ្មោះថា **មហាភូត** ដោយហេតុច្រើនយ៉ាង មានភាពជាវត្ថុ មានប្រាកដភាពធំជាដើម ដូចពោលមកដូច្នោះ ។

តែព្រោះទ្រទ្រង់ទុក្ខនូវលក្ខណៈរបស់ខ្លួន ១ ជាទីតាំងនៃទុក្ខ ១ ព្រោះជាទីទទួលទុក្ខ ១ ធាតុទាំងពួង ទើបបានឈ្មោះថា **ធាតុ** ព្រោះមិនកន្លងលក្ខណៈរបស់ធាតុ ដូចពោលមក ឈ្មោះថា **ធម៌** ក៏ព្រោះទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួននោះឯង និងព្រោះទ្រទ្រង់តាមសមគួរដល់ខណៈរបស់ខ្លួនផង ឈ្មោះថា **មិនទៀង** ព្រោះសេចក្តីថា អស់ទៅ , ឈ្មោះថា **ជាទុក្ខ** ព្រោះមានភាពជាភ័យ , ឈ្មោះថា **អនត្តា** ព្រោះមិនមានសារៈ ធាតុទាំងពួង មានសេចក្តីដូចគ្នា ព្រោះជារូប ជាមហាភូត ជាធាតុ ជាធម៌ និងជារបស់មិនទៀងជាដើមដូច្នេះឯង ព្រះយោគាវចរគប្បីមនសិការដោយសេចក្តីផ្សេងគ្នា និងសេចក្តីដូចគ្នា ដូចពោលមកដូច្នេះ ។

## ការបែកគ្នាបាន និងបែកគ្នាមិនបាន

សេចក្តីថា ដោយការបែកគ្នាបាន និងបែកគ្នាមិនបាន មានសេចក្តីថា ធាតុទាំងឡាយនោះកើតរួមគ្នាពិត បែកគ្នាជាចំណែកមិនបាន សូម្បីក្នុងកលាបៈមួយៗ មានសុទ្ធដ្ឋកកលាបៈជាដើម ដែលមានចំនួនតិចបំផុតក្តី តែពោលដោយលក្ខណៈមួយក៏បែកគ្នាបាន ព្រោះព្រះយោគាវចរគប្បីមនសិការដោយបែកគ្នាបាន និងបែកគ្នាមិនបានដូចពោលមកដូច្នេះ ។

## ការចូលគ្នាបាន និងចូលគ្នាមិនបាន

ប្រការថា ដោយការចូលគ្នាបាន និងចូលគ្នាមិនបាននោះ មានសេចក្តីថា ក្នុងធាតុទាំងឡាយនោះ សូម្បីញែកគ្នាមិនចេញយ៉ាងនេះក្តី ធាតុពីរខាងមុខចូលគ្នាបាន ព្រោះជាធាតុធ្ងន់ដូចគ្នា ធាតុពីរខាងក្រោយក៏យ៉ាងនោះ គឺ ចូលគ្នាបាន ព្រោះជាធាតុស្រាលដូចគ្នា តែថាធាតុពីរខាងមុខ និងធាតុពីរខាងក្រោយ , ធាតុពីរខាងក្រោយ និងធាតុពីរខាងមុខចូលគ្នាមិនបាន ព្រះយោគាវចរគប្បីមនសិការដោយការចូលគ្នាបាន និងចូលគ្នាមិនបានដូចពោលមកដូច្នេះ ។

## ការប្លែកគ្នានៃធាតុខាងក្នុង និងធាតុខាងក្រៅ

ប្រការថា ដោយការប្លែកគ្នានៃធាតុខាងក្នុង និងធាតុខាងក្រៅនោះ មានសេចក្តីថា ធាតុខាងក្នុងជាទីអាស្រ័យនៃវិញ្ញាណ វត្ថុ វិញ្ញត្តិ និងឥន្ទ្រិយទាំងឡាយ មានឥរិយាបថ មានសមុដ្ឋាន ៤ ចំណែកធាតុខាងក្រៅមានប្រការផ្ទុយគ្នានឹងធាតុខាងក្នុងដែលពោលមកហើយ ព្រះយោគាវចរគប្បីមនសិការដោយការប្លែកគ្នានៃធាតុខាងក្នុង និងធាតុខាងក្រៅ ដូចពោលមកដូច្នេះ ។

## ការរួមចូលគ្នា

ប្រការថា ដោយការរួមដែលដូចគ្នាចូលគ្នានោះ មានសេចក្ដីថា បឋវីធាតុចំណែកដែលមានកម្មជាសមុដ្ឋាន ក៏រួមចូលជាមួយគ្នានឹងធាតុដទៃ ដែលមានកម្មជាសមុដ្ឋានដូចគ្នា ព្រោះមិនមានការផ្សេងគ្នានៃសមុដ្ឋាន បឋវីធាតុចំណែកដែលមានឧតុដទៃ មានចិត្តជាដើមជាសមុដ្ឋានក៏យ៉ាងនោះ គឺ រួមចូលជាមួយគ្នានឹងធាតុដទៃដែលមានឧតុដទៃ មានចិត្តជាដើមជាសមុដ្ឋានដូចគ្នា ព្រះយោគាវចរគប្បីមនសិការដោយរួម ដែលដូចគ្នាចូលជាមួយគ្នា ដូចពោលមកដូច្នេះ ។

## ភាពជាបច្ច័យដល់គ្នានិងគ្នា

ប្រការថា ដែលជាបច្ច័យដល់គ្នានិងគ្នានោះ មានសេចក្ដីថា បឋវីធាតុដែលអាបោធាតុជួយប្រមូលផ្ដុំ តេជោធាតុជួយរក្សាទុក វាយោធាតុជួយទ្រទុកនោះឯង ជាបច្ច័យដែលជាទីតាំងនៃមហាភូតរូប ៣ នោះ ។

អាបោធាតុដែលតាំងនៅក្នុងបឋវី តេជោធាតុជួយរក្សាទុក វាយោធាតុជួយទ្រទុក នោះឯងហើយជាបច្ច័យ ជាគ្រឿងធ្វើឲ្យជាប់គ្នានៃមហាភូត ៣ នោះ ។

តេជោធាតុដែលតាំងនៅក្នុងបឋវី អាបោធាតុជួយចងទុក វាយោធាតុជួយទ្រទុក នោះឯងហើយជាបច្ច័យ ជាគ្រឿងធ្វើឲ្យក្ដៅនៃមហាភូត ៣ នោះ ។

វាយោធាតុដែលតាំងនៅក្នុងបឋវី អាបោធាតុជួយចងទុក តេជោធាតុជួយធ្វើឲ្យក្ដៅ នោះឯងជាបច្ច័យ ជាគ្រឿងទ្រទ្រង់មហាភូត ៣ នោះ ។

ព្រះយោគាវចរ គប្បីមនសិការដែលជាបច្ច័យដល់គ្នានិងគ្នា ដូចពោលមកដូច្នេះ ។

## ភាពមិនមានការរិះគិត

ប្រការថា **ដោយការមិនមានការរិះគិតនោះ** មានសេចក្ដីថា ឯធាតុ ៤ នោះ បឋវីធាតុមិនដឹងថា យើងជាបឋវីធាតុ ឬថា យើងជាទីតាំងនៃមហាភូត ៣ ( ទើបជាបច្ច័យរបស់មហាភូត ៣ នោះ )ដូច្នេះ សូម្បីមហាភូត ៣ ក្រៅពីនេះ ក៏មិនដឹងថា បឋវីធាតុជាទីតាំងនៃយើងទាំងឡាយ ទើបជាបច្ច័យនៃយើងទាំងឡាយ ដូច្នេះ ន័យក្នុងធាតុទាំងពួង ក៏ដូចន័យនេះ ព្រះយោគាវចរគប្បីមនសិការដោយការមិនមានការរិះគិត ដូចពោលមកដូច្នេះ ។

## ការចែកបច្ច័យ

ប្រការថា **ដោយចំណែកបច្ច័យនោះ** មានការពណ៌នាថា ក៏បច្ច័យរបស់ធាតុទាំងឡាយមាន ៤ គឺ កម្ម ចិត្ត ឧតុ អាហារ ក្នុងបច្ច័យទាំងនោះ កម្មនោះឯងជាបច្ច័យនៃធាតុទាំងឡាយ ដែលមានកម្មជាសមុដ្ឋាន បច្ចយធម៌ ៣ មានចិត្តជាដើមមិនជាបច្ច័យទេ ធាតុទាំងឡាយដែលមានចិត្តជាដើមជាសមុដ្ឋានសោត ក៏មានបច្ចយធម៌ តាមលំដាប់ មានចិត្តជាដើមនោះឯងជាបច្ច័យ ធម៌ក្រៅពីនេះមិនជាបច្ច័យទេ ។

ម្យ៉ាងទៀត កម្មជាជនកប្បច្ច័យនៃធាតុទាំងឡាយ ដែលមានកម្មជាសមុដ្ឋាន ជាឧបនិស្សយប្បច្ច័យនៃធាតុដ៏សេស ( មានធាតុដែលមានចិត្តជាសមុដ្ឋានជាដើម ) ដោយបរិយាយ ។

ចិត្តជាជនកប្បច្ច័យនៃធាតុទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ជាបច្ឆាជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃធាតុដ៏សេស ។

អាហារជាជនកប្បច្ច័យនៃធាតុទាំងឡាយ ដែលមានអាហារជាសមុដ្ឋាន ជាអាហារប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃធាតុដែលនៅសល់ ។

ឧតុជាជនកប្បច្ច័យនៃធាតុទាំងឡាយ ដែលមានឧតុជាសមុដ្ឋាន ជាអត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃធាតុដ៏សេស ។

មហាភូតដែលមានកម្មជាសមុដ្ឋាន រមែងជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានកម្មជាសមុដ្ឋានដូចគ្នាខ្លះ ដែលមានវត្ថុដទៃ មានចិត្តជាដើមជាសមុដ្ឋានខ្លះក៏បាន ។

ដូចគ្នានេះដែរ មហាភូតដែលមានចិត្តជាសមុដ្ឋាន រមែងជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានដូចគ្នាខ្លះ ដែលមានវត្ថុដទៃ មានកម្មជាដើមជាសមុដ្ឋានខ្លះក៏បាន ។

មហាភូតដែលមានអាហារជាសមុដ្ឋាន រមែងជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានអាហារជាសមុដ្ឋានដូចគ្នាខ្លះ ដែលមានវត្ថុដទៃ មានកម្មជាដើមជាសមុដ្ឋានខ្លះក៏បាន ។

មហាភូតដែលមានឧតុជាសមុដ្ឋាន រមែងជាបច្ច័យនៃមហាភូតទាំងឡាយ ដែលមានឧតុជាសមុដ្ឋានដូចគ្នាខ្លះ ដែលមានវត្ថុដទៃ មានកម្មជាដើមជាសមុដ្ឋានខ្លះក៏បាន ។

ក្នុងមហាភូតដែលមានកម្មជាសមុដ្ឋានទាំងនោះ បឋវីធាតុដែលមានកម្មជាសមុដ្ឋាន រមែងជាបច្ច័យ ដោយជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយ-ប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងជាទីតាំងនៃធាតុដទៃផង ( មានអាបោធាតុជាដើម ) ដែលមានកម្មជាសមុដ្ឋានដូចគ្នា តែជាមិនជាបច្ច័យដោយជនកប្បច្ច័យទេ

ម្យ៉ាងទៀត ជាបច្ច័យដោយជានិស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យនៃមហាភូតដែលទាក់ទងគ្នា ៣ ទៀត ( គឺ មហាភូតដែលមាន ចិត្ត អាហារ និងឧតុជាសមុដ្ឋាន ) តែមិនបានជាបច្ច័យដោយជាទីតាំង មិនបានជាជនកប្បច្ច័យ ។

ម្យ៉ាងទៀត ក្នុងមហាភូតដែលមានកម្មជាសមុដ្ឋានទាំងនោះ អាបោធាតុរមែងជាបច្ច័យដោយជាសហជាតប្បច្ច័យជាដើម និងជាគ្រឿងចងឲ្យជាប់គ្នាផងនៃធាតុ ៣ ទៀត តែមិនជាជនកប្បច្ច័យទេ ជាបច្ច័យដោយជានិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃមហាភូតដែលទាក់ទង ៣ ទៀត ( គឺ ដែលមានចិត្ត អាហារ ឧតុជាសមុដ្ឋាន ) ដូចគ្នា តែមិនបានជាបច្ច័យដោយជាគ្រឿងចងឲ្យជាប់គ្នា មិនបានកើត ដោយជាជនកប្បច្ច័យទេ ។

ម្យ៉ាងទៀត ក្នុងមហាភូតដែលមានកម្មជាសមុដ្ឋានទាំងនោះ តេជោធាតុរមែងជាបច្ច័យ ដោយជាសហជាតប្បច្ច័យជាដើម និងជាគ្រឿងអប់ឧណ្ហផងនៃធាតុ ៣ ទៀត តែមិនជាជនកប្បច្ច័យទេ ជាបច្ច័យដោយជានិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃមហាភូតដែលជាប់គ្នា ៣ ទៀត ( គឺ ដែលមាន ចិត្ត អាហារ ឧតុជាសមុដ្ឋាន )ដូចគ្នា តែមិនបានជាគ្រឿងអប់ឧណ្ហ មិនបានជាជនកប្បច្ច័យទេ ។

ម្យ៉ាងទៀត ក្នុងមហាភូតដែលមានកម្មជាសមុដ្ឋានទាំងនោះ វាយោធាតុរមែងជាបច្ច័យ ដោយជាសហជាតប្បច្ច័យជាដើម និងជាគ្រឿងទ្រផងនៃធាតុ ៣ ទៀត តែមិនជាជនកប្បច្ច័យទេ ជាបច្ច័យដោយជានិស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យនៃមហាភូតដែលទាក់ទង ៣ ទៀត ( គឺដែលមានចិត្ត អាហារ ឧតុជាសមុដ្ឋាន ) ដូចគ្នា តែមិនជាគ្រឿងទ្រ មិនជាជនកប្បច្ច័យទេ ។

ន័យសូម្បីក្នុងមហាភូតដទៃ មានបឋវីធាតុដែលមាន ចិត្ត អាហារ ឧតុ ជា

សមុដ្ឋានជាដើម ក៏មានន័យដូច្នេះ ។

រីឯក្នុងធាតុទាំងឡាយនោះ ដែលប្រព្រឹត្តទៅដោយអំណាចបច្ច័យ មានសហជាតប្បច្ច័យជាដើម ដូចពោលមកនេះ :

ធាតុ ៣ អាស្រ័យធាតុ ១ ត្រូវជា ៤ និងធាតុ ១ អាស្រ័យធាតុ ៣ ត្រូវជា ៤ , តែធាតុ ២ អាស្រ័យធាតុ ២ ត្រូវជា ៦ ។

ពិតមែន ក្នុងធាតុទាំងឡាយ មានបឋវីធាតុជាដើម ធាតុ ៣ អាស្រ័យធាតុ ១ ដូច្នេះ គឺចាត់ធាតុម្ដង ៣ អាស្រ័យធាតុម្ដង ១ ទើបត្រូវជា ៤ គ្រប់កន្លែងដូចគ្នានេះដែរ ក្នុងធាតុទាំងឡាយមានបឋវីធាតុជាដើម ធាតុ ១ អាស្រ័យធាតុ ៣ ដូច្នេះ គឺចាត់ធាតុម្ដង ១ អាស្រ័យធាតុម្ដង ៣ ទៀត ក៏ត្រូវជា ៤ គ្រប់កន្លែងដូចគ្នា , តែធាតុ ២ អាស្រ័យធាតុ ២ ដូច្នេះគឺ ធាតុ ២ ខាងក្រោយ អាស្រ័យធាតុ ២ ខាងមុខ( ១ ) , ធាតុ ២ ខាងមុខ អាស្រ័យធាតុ ២ ខាងក្រោយ( ១ ) , ធាតុទី ២ ទី ៤ អាស្រ័យធាតុទី ១-៣( ១ ) , ធាតុទី ១-៣ អាស្រ័យធាតុទី ២-៤( ១ ) , ធាតុទី ២-៣ អាស្រ័យធាតុទី ១-៤( ១ ) , ធាតុទី ១-៤ អាស្រ័យធាតុទី ២-៣( ១ ) ទើបត្រូវជា ៦ ។

ក្នុងធាតុទាំងនោះ បឋវីធាតុជាបច្ច័យនៃការទប់ក្នុងពេលឈាន និងឈរជាដើម បឋវីធាតុនោះឯង ដែលអាបោធាតុឧបត្ថម្ភហើយ ក៏ជាបច្ច័យនៃការទ្រទ្រង់ចំណែកអាបោធាតុត្រូវបឋវីឧបត្ថម្ភហើយ ជាបច្ច័យនៃការមិនខ្ចាត់ខ្ចាយ តេជោធាតុត្រូវវាយោធាតុឧបត្ថម្ភហើយ ក៏ជាបច្ច័យនៃការលើកឡើង វាយោធាតុត្រូវតេជោធាតុឧបត្ថម្ភហើយ ក៏ជាបច្ច័យនៃការកម្រើក ។

ព្រះយោគាវចរ គប្បីមនសិការដោយចំណែកបច្ច័យដូចពោលមកដូច្នេះ ។

## ធាតុវវត្ថានឲ្យសម្រេចឧបចារសមាធិ

កាលព្រះយោគាវចរមនសិការទៅ ដោយកំណត់អាការ ១៣ មានអត្ថនៃពាក្យជាដើម ដូចពោលមកនេះ ធាតុទាំងឡាយរមែងប្រាកដ ដោយមុខមួយៗ កាលលោកនឹកគិតមនសិការធាតុទាំងនោះរឿយៗ ឧបចារសមាធិរមែងកើតឡើង តាមន័យដែលពោលមកហើយនោះឯង ឧបចារសមាធិនេះ ក៏បានឈ្មោះថា ចតុធាតុវវត្ថាននោះឯង ព្រោះកើតឡើងដោយអានុភាពនៃញាណដែលកំណត់ធាតុ ៤ ។

## អានិសង្សនៃធាតុវវត្ថាន

រីឯភិក្ខុអ្នកប្រកបរឿយៗ នូវចតុធាតុវវត្ថាននេះ រមែងចាក់ចុះដល់សុញ្ញតា ( ការសូន្យចាកតួខ្លួន ) ដកសត្តសញ្ញា( ការសម្គាល់ថាជាសត្វបុគ្គល ) ចេញបាន ព្រោះដកសត្តសញ្ញាបាន លោកមិនបាច់កំណត់ញែកថា ពាលម្រឹគ ថាយក្ខ ថាអារក្សទឹកជាដើម រមែងជាអ្នកគ្របសង្កត់ការភ័យខ្លាចបាន គ្របសង្កត់ការមិនត្រេកអរ និងការត្រេកអរបាន មិនដល់នូវការបានចិត្ត និងអន់ចិត្ត ព្រោះឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ទាំងឡាយ ព្រមទាំងជាអ្នកមានបញ្ញាច្រើន មានអមតៈ( និព្វាន ) ជាទីបំផុត ឬមិនដូច្នោះ ក៏នឹងមានសុគតិជាទីទៅក្នុងខាងមុខ ។

អ្នកមានបញ្ញា គប្បីសេពធាតុវវត្ថានដែលមានអានុភាពច្រើនយ៉ាងនេះ ដែលព្រះយោគីអ្នកជាសីហៈដ៏ប្រសើរសេពហើយជានិច្ចចុះ ។

នេះជាការវិនាទិទ្ទេសនៃធាតុវវត្ថាន ។

## សរុបសមាធិនិទ្ទេស

*ការពណ៌នាសេចក្ដីគ្រប់ប្រការនៃបញ្ហាកម្ម ប្រការថា សមាធិគប្បីបំពេញដូចម្ដេច ក្នុងបញ្ហាកម្មនេះខ្ញុំបានធ្វើទុកដោយន័យថា អ្វីឈ្មោះថា* ***សមាធិ*** *ដែលឈ្មោះថា* ***សមាធិ*** *ព្រោះអត្ថថាដូចម្ដេច ដូច្នេះជាដើម ដើម្បីសម្ដែងសេចក្ដីពិស្ដារនិងន័យនៃការបំពេញសមាធិ ត្រូវចប់ហើយត្រឹមប៉ុណ្ណេះ ។*

*សមាធិនេះក៏មានត្រឹមតែ ២ យ៉ាងប៉ុណ្ណោះ ជាសមាធិដែលបំណងយកក្នុងទីនេះ គឺឧបចារសមាធិ ១ អប្បនាសមាធិ ១ ក្នុងសមាធិ ២ យ៉ាងនោះ ឧបចារសមាធិ គឺ ឯកគ្គតាក្នុងកម្មដ្ឋាន ១០ និងក្នុងចិត្តដែលជាបុព្វភាគនៃអប្បនាទាំងឡាយ , អប្បនាសមាធិ គឺ ឯកគ្គតានៃចិត្តក្នុងកម្មដ្ឋាន ដ៏សេស ៣០ សមាធិទាំង ២ យ៉ាងនោះ ឈ្មោះថា ជាធម៌ដែលព្រះយោគាវចរបានចម្រើនហើយ ក៏ព្រោះកម្មដ្ឋានទាំងនោះ លោកបានបំពេញហើយ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបធ្វើការពណ៌នាសេចក្ដីគ្រប់ប្រការនៃបញ្ហា ប្រការថា* ***សមាធិ*** *គប្បីបំពេញដូចម្ដេចដូច្នេះ ចប់ហើយ ។*

# មហាដីកា

## ពណ៌នា ការចម្រើនចតុធាតុវវដ្ឋាន

*លោកអាចារ្យពោលថា និទ្ទេសនៃការចម្រើនចតុធាតុវវដ្ឋាន ដែលលោកសម្ដែងថែទុកយ៉ាងនេះថា វវដ្ឋាន ១ ដូច្នេះ ដល់ហើយតាមលំដាប់ ព្រោះធ្វើទុកក្នុងចិត្តថា ឈ្មោះថា* ***ឧទ្ទេស*** *( ពាក្យលើកឡើងសម្ដែង ) ក៏មាននិទ្ទេស ( ពាក្យអធិប្បាយ ) ជាសេចក្ដី ព្រោះដោយច្រើន បុគ្គលជាអ្នកមានបញ្ញាទន់ខ្លី និងមាន*

បញ្ញាថ្នាក់កណ្ដាល ដែលជាការៈមកហើយក៏ត្រូវទទួលនាំទៅជាពិតប្រាកដដូច្នេះ ក្នុងពាក្យនោះ កាលវវដ្ឋាន ( ការកំណត់ ) និងមានសេចក្ដីផ្សេងគ្នា តាមសេចក្ដីផ្សេងគ្នានៃអារម្មណ៍ សូម្បីដូច្នោះ លោកក៏ធ្វើវវដ្ឋាននោះមិនឲ្យផ្សេងគ្នា ព្រោះស្មើគ្នាដោយភាពជាវវដ្ឋាន ពោលថា វវដ្ឋាន ១ ដូច្នេះ , ម្យ៉ាងទៀត ក្នុងខាងដើមទោះបីជាមានសេចក្ដីផ្សេងគ្នានៃអារម្មណ៍ តែក្នុងពេលសម្រេច ប្រយោជន៍វវដ្ឋាននោះ ក៏មានអារម្មណ៍ ១ ប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោក អាចារ្យពោលថា វវដ្ឋាន ១ ដូច្នេះ ដូចជាថា សម្រាប់ព្រះយោគីអ្នកធ្វើការងារ ក្នុងអាការ ៣២ ក្នុងខាងដើមៗ មនសិការរមែងប្រព្រឹត្តទៅក្នុងកោដ្ឋាសទាំងឡាយ ម្ដង ១ កោដ្ឋាសក៏ពិត តែក្នុងខាងក្រោយ នឹងមានការសម្រេចប្រយោជន៍បាន ក្នុងខណៈ ១ ចំពោះកោដ្ឋាស ១ ប៉ុណ្ណោះ , មិនមែនក្នុងកោដ្ឋាសទាំងអស់ទេ យ៉ាងណា សូម្បីក្នុងកម្មដ្ឋាននេះក៏ដូច្នោះដូចគ្នា ។ ក្នុងសេចក្ដីនោះ គួរនឹងមានពាក្យសួរថា ដូចជាថា កម្មដ្ឋាន គឺអាការ ៣២ មនសិការរមែងប្រព្រឹត្តទៅដោយមិនផ្សេងគ្នា ព្រោះស្មើគ្នាដោយភាពជាបដិកូលផងយ៉ាងណា សូម្បីក្នុងកម្មដ្ឋាននេះ មនសិការក៏រមែងប្រព្រឹត្តទៅដោយមិនផ្សេងគ្នា ព្រោះស្មើគ្នាដោយភាពជាធាតុក៏ដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា វវដ្ឋាន ១ ដូច្នេះឬ ? ឆ្លើយថា ន័យនេះមិនជាយ៉ាងនោះទេ ព្រោះថា ក្នុងកម្មដ្ឋាន គឺអាការ៣២នោះ ចាប់តាំងពីការឈានកន្លងបញ្ញត្តិទៅ ព្រះយោគីត្រូវធ្វើមនសិការឲ្យប្រព្រឹត្តទៅក្នុងអាការទាំងពួង ដោយទាក់ទងជារបស់បដិកូលតែប៉ុណ្ណោះ ។ ចំណែកក្នុងកម្មដ្ឋាននេះ ព្រះយោគីត្រូវមនសិការ ក្នុងធាតុទាំងឡាយដោយសភាវៈ និង លក្ខណៈរបស់ខ្លួន , មិនមែនដោយភាពជារបស់ស្មើគ្នាដោយភាពជាធាតុទេ ព្រោះហេតុនោះ ទើបលោកពោលថា បានដល់ ការប្តេជ្ញាចិត្ត

ដោយទាក់ទងនឹងការចូលទៅកំណត់សភាវៈ ។

ម្យ៉ាងទៀត ប្រយោជន៍អ្វីដោយការនិយាយវែងឆ្ងាយដូច្នេះនោះ ។ គប្បីឃើញថា លោកបំណងសម្ដែងថា កម្មដ្ឋានម្យ៉ាង មិនលាយដោយកម្មដ្ឋាន ៣៩ ពួកដទៃ ឈ្មោះថា ចតុធាតុវវដ្ឋានមានប្រាកដដូច្នេះ ទើបពោលថា **ឯកំ វវដ្ឋានំ** វវដ្ឋាន ១ ដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ទើបលោកពោលថា **ចតុធាតុវ-វដ្ឋានស្ស ភាវនា និទ្ទេសោ** ( និទ្ទេសនៃការចម្រើនចតុធាតុវវដ្ឋាន ) ដូច្នេះឯង ។ ការកំណត់ គឺ ភាវនានោះឯង ដោយភាពផ្សេងគ្នានៃចតុធាតុវវដ្ឋានមិនមែនឬ ? ឆ្លើយថា លោកពោលទុកក៏ព្រោះពាក្យនិយាយមានសេចក្ដីផ្សេងគ្នាថា ឈ្មោះថា វវដ្ឋាន ( ការកំណត់ ) ប្រព្រឹត្តទៅមួយគ្រា ការធ្វើឲ្យច្រើននូវវវដ្ឋាននោះ ក៏ឈ្មោះថា **ភាវនា** ( ការចម្រើន ) ។ សួរថា លោកសម្ដែងខៃភាវនាយ៉ាងដូចម្ដេច ព្រោះសេចក្ដីថា ភាវនានោះកន្លងផុតអារម្មណ៍ខាងវិថីទ្វារ ? ឆ្លើយថា ខនេះមិនមែនជាការខុសទេ ព្រោះបញ្ញត្តិថា ភាវនាប្រព្រឹត្តទៅក្នុងសេចក្ដីថា **ចម្រើន** ។ ពិតមែនការកំណត់យកកម្មដ្ឋាន ដែលមានសេចក្ដីថា **ចម្រើន** លោកបំណងយក ថាជាភាវនាក្នុងទីនេះ ។

ពាក្យថា **ដោយទាក់ទងនឹងការចូលទៅកំណត់សភាវៈ** គឺ ដោយការទាក់ទងនឹងការចូលទៅទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួនដែលមានលក្ខណៈរឹងជាដើម ។ ពិតហើយ កម្មដ្ឋាននឹងប្រព្រឹត្តទៅដោយទាក់ទងនឹងការកំណត់ត្រឹមតែបញ្ញត្តិ ដូចជាកម្មដ្ឋាន មានបឋវីជាដើមក៏ទេ ។ នឹងត្រូវប្រព្រឹត្តទៅដោយការទាក់ទងនឹងការកំណត់ពណ៌ មានពណ៌ខៀវជាដើម ដូចកម្មដ្ឋាន មាននីលកសិណជាដើមក៏ទេ ទាំងនឹងត្រូវប្រព្រឹត្តទៅដោយការទាក់ទងនឹងការកំណត់សាមញ្ញលក្ខណៈមានភាពជា

របស់មិនទៀងជាដើមនៃសង្ខារទាំងឡាយ ដូចជាវិបស្សនាកម្មដ្ឋានក៏ទេ ។ តែថារមែងប្រព្រឹត្តទៅដោយការទាក់ទងនឹងការកំណត់សភាវៈនៃធាតុ ៤ មានបឋវីធាតុជាដើមដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ដោយការទាក់ទងនឹងការចូលទៅកំណត់សភាវៈដូច្នេះ ។ សេចក្តីថា ដោយការទាក់ទងនឹងការចូលទៅទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន មានលក្ខណៈរឹងជាដើម ។ ពាក្យថា **ការសម្រេចចិត្ត** គប្បីជ្រាបថា បានដល់ ការសម្រេចចិត្តដោយញាណ មិនមែនការសម្រេចចិត្តដោយយេវាបនកចេតសិក ដែលហៅថា អធិមោក្ខចេតសិក ទាំងមិនមែនជាការសម្រេចចិត្តដោយធម៌ មានវិតក្កជាដើម ។ ពាក្យថា **ធាតុមនសិការ** គឺ ការធ្វើទុកក្នុងចិត្តក្នុងធាតុទាំងឡាយ មានសេចក្តីថា មនសិការ ដែលជាភាវនាប្រារព្ធធាតុ ៤ ។ ឈ្មោះថា **កម្មដ្ឋាន** ព្រោះអត្ថថា ជាកម្ម ព្រោះជាវត្ថុគួរធ្វើដោយជាឋានៈព្រោះជាហេតុនៃសុខវិសេសទាំងឡាយរបស់ព្រះយោគី បានដល់ ការធ្វើសេចក្តីព្យាយាមដែលប្រព្រឹត្តទៅដោយការទាក់ទងនឹងការកំណត់សភាវៈនៃមហាភូត ៤ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ពាក្យ ៣ ពាក្យ ថាធាតុមនសិការធាតុកម្មដ្ឋាន ចតុធាតុវវដ្ឋាន ពោលដោយន័យ មានន័យដូចគ្នា ដូច្នេះ ។ បទថា **តយិទំ** បានដល់ ចតុធាតុវវដ្ឋាន ។ សួរថា ព្រោះហេតុអ្វី ទើបលោកពោលថាមកហើយដោយ ២ ប្រការ ដូច្នេះហ្ន៎ ក្នុងធាតុវិភង្គសូត្រ ចតុធាតុវវដ្ឋាន មកហើយដោយការទាក់ទងនឹងការមិនសង្ខេប និងពិស្តារពេក ព្រោះដូច្នោះ លោកក៏គួរនឹងពោលថា មកហើយដោយ ៣ ប្រការមិនមែនឬ ? ឆ្លើយថា មិនគួរនឹងពោលថា មកហើយដោយ ៣ ប្រការទេ ព្រោះសូម្បីក្នុងធាតុវិភង្គសូត្រនោះទ្រង់បានធ្វើការប្រមូលយកធាតុខាងក្នុងធាតុទាំងឡាយទុក មិនមាននៅសល់ដោយ

ប្រភេទណាមួយឡើយ និងព្រោះបានកំណត់យកធាតុខាងក្រៅទាំងឡាយទុកហើយ , ន័យម្យ៉ាងទៀត ក្នុងពាក្យថា មកហើយដោយពីរប្រការនេះ បណ្ឌិតកុំកាន់យកជាខកំណត់ពិតប្រាកដយ៉ាងនេះថា មកហើយដោយពីរប្រការប៉ុណ្ណោះ តែថាគប្បីកាន់យកថា មកហើយតែម្ដង ដោយពីរប្រការដូច្នេះចុះ ការរួបរួមប្រការទី ៣ ដែលសម្រេចហើយដោយពាក្យថា មកហើយដោយពីរប្រការនោះ ។ ន័យដែលមិនសង្ខេប និងពិស្ដារពេកនោះ គប្បីឃើញថា លោករួមទុកហើយ ដោយទាក់ទងនឹងការផ្ដោតជាប់នៅក្នុងពាក្យថា **សង្ខេបតោ ច វិត្ថារតោ ច** - ដោយសង្ខេប និងដោយពិស្ដារនេះ ឬ រួមទុកដោយ **ច** ស័ព្ទនោះឯង ។ ន័យម្យ៉ាងទៀត ចំណែកពិស្ដារនឹងមានប្រាកដ ក្នុងន័យដែលមិនសង្ខេបនិងពិស្ដារពេក ដោយការបដិសេធន៍ចំណែកដែលដូចជាសង្ខេបពេក ជាគន្លងផ្លូវ យ៉ាងណា លោកធ្វើចំណែកដែលពិស្ដារនោះឲ្យជាប់នៅក្នុងន័យពិស្ដារតែម្យ៉ាង ពោលថា មកហើយក្នុង ២ ប្រការដូច្នេះ ។ ពាក្យថា មកហើយដោយពិស្ដារ ដោយទាក់ទងនឹងព្រះយោគីអ្នកចម្រើនធាតុកម្មដ្ឋានដែលជាអ្នកមានបញ្ញាមិនចាស់ក្លាប៉ុន្មាន ដូច្នេះ នឹងមានការប្រើបាន ក៏ព្រោះបានធ្វើអធិប្បាយយ៉ាងនេះ ។ ម្យ៉ាងទៀត ពាក្យថា **ក្នុងមហាសតិប្បដ្ឋានសូត្រនេះ** បណ្ឌិតគប្បីឃើញថា ត្រឹមតែជាឧទាហរណ៍ , ព្រោះមកហើយក្នុងសតិប្បដ្ឋានសូត្រ និងកាយគតាសតិសូត្រជាដើមក៏យ៉ាងនោះដូចគ្នា ។ ពាក្យថា **ក្នុងរាហុលោវាទសូត្រ** គឺ ក្នុងមហារាហុលោវាទសូត្រ ។ បទថា **ធាតុវិភង្គេ** គឺ ក្នុងធាតុវិភង្គសូត្រ និងក្នុងធាតុវិភង្គ ក្នុងព្រះអភិធម្ម ។

ក្នុងមហាសតិប្បដ្ឋានសូត្រទេសនាមកហើយ ធ្វើឧបមាដោយជុំវិញ ទាក់ទងនឹងសេចក្ដីក៏ពិត សូម្បីយ៉ាងនោះ ឈ្មោះថា ឧបមា ( រឿងប្រៀបធៀប ) ក៏មាន

ប្រយោជន៍ត្រឹមតែដើម្បីបើកបង្ហាញអត្ថនៃឧបមេយ្យ ( រឿងដែលគប្បីឲ្យឧបមាប្រៀបធៀប ) នោះឯង ព្រោះហេតុនោះ លោកអាចារ្យប្រាថ្នាសម្ដែងឧបមាមុនហើយ ទើបបើកផ្ទាអត្ថនៃឧបមេយ្យ ទើបនាំព្រះបាលីមកដោយពាក្យថា **សេយ្យថាបិ** ជាដើម ។ សួរថា ព្រោះហេតុអ្វី ក្នុងមហាសតិប្បដ្ឋានសូត្រនេះ ព្រះអង្គទ្រង់ធ្វើការសម្ដែងខែកម្មដ្ឋានដោយទាក់ទងជាធាតុ និងសូម្បីក្នុងព្រះសូត្រនោះ ក៏ទ្រង់ធ្វើការសម្ដែងខែទុកដោយទាក់ទងជាមួយមហាភូត ៤ ហ្ន៎ ? ឆ្លើយថា គប្បីជ្រាបថាក្នុងមហាសតិប្បដ្ឋានសូត្រនេះ ទ្រង់ធ្វើការសម្ដែងខែកម្មដ្ឋានទុកដោយទាក់ទងជាធាតុដើម្បីសម្ដែងសេចក្ដីជារបស់សូន្យទទេចាកអត្តា សូម្បីក្នុងព្រះសូត្រនោះទ្រង់ធ្វើការសម្ដែងទុកដោយទាក់ទងជាមហាភូត ដើម្បីការប្រាកដច្បាស់ ដោយភាពជារបស់គ្រោតគ្រាត និងដើម្បីការបានជាកម្មដ្ឋានដែលអនុកូលដល់ចរិតរបស់វេនេយ្យជនពួកខ្លះ ។ ក្នុងពាក្យទាំងនោះ ឈ្មោះថា អត្ថថាជាធាតុ ក្នុងពាក្យថា បឋវីធាតុជាដើម បានដល់ អត្ថថា ជាសភាវៈ ឈ្មោះថា អត្ថថាជាសភាវៈ បានដល់ អត្ថថាជារបស់សូន្យទទេ , ឈ្មោះថា អត្ថថា ជារបស់សូន្យទទេ បានដល់ អត្ថថា មិនមែនសត្វ ។ ធាតុ គឺ បឋវី ឈ្មោះថា បឋវីធាតុ ព្រោះអត្ថថា ជាសភាវៈជារបស់សូន្យទទេ និងមិនមែនសត្វ តាមប្រការដូចពោលមកដូច្នេះ ។ សូម្បីក្នុងអាបោធាតុជាដើមក៏មានន័យដូច្នេះ ។ ពាក្យថា **បឋវីធាតុ** បានដល់ ធាតុដែលជាទីតាំងនៃរូបធម៌ទាំងឡាយដែលកើតរួមគ្នា , ដូចគ្នានេះដែរ ពាក្យថា **អាបោធាតុ** បានដល់ ធាតុដែលជ្រួតជ្រាប , ពាក្យថា **តេជោធាតុ** បានដល់ ធាតុដែលធ្វើឲ្យរលាយ , ពាក្យថា **វាយោធាតុ** បានដល់ ធាតុដែលបក់ផាត់ គប្បីជ្រាបពាក្យសមាស និងន័យក្នុងភាពជាធាតុ ក្នុងបណ្ដាធាតុទាំងនេះ តាមប្រការដូចពោលមក

យ៉ាងនេះចុះ នេះជាសេចក្ដីសង្ខេបក្នុងពាក្យពោលទាំងនេះ ចំណែកសេចក្ដីពិស្ដារនឹងមានមកដល់ខាងមុខ ។

ដោយពាក្យថា **ឯវំ** ( យ៉ាងនេះ ) ក្នុងពាក្យថា **ឯវំ តិក្ខបញ្ញស្ស** ជាអ្នកមានបញ្ញាចាស់ក្លាយ៉ាងនេះ លោកសំដៅយកព្រះបាលីតាមដែលទ្រង់សម្ដែងទុក ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ទេសនាដោយពិស្ដារ ទ្រង់ធ្វើទុកក៏សម្រាប់ព្រះយោគីអ្នកមានបញ្ញាមិនចាស់ក្លា ដូច្នេះ ទើបពោលថា ជាអ្នកមានបញ្ញាចាស់ក្លាដូច្នេះ ។ ប្រៀបដូចជាបុគ្គលឈ្មោះថា វត្ថុយុគិក ព្រោះអត្ថថា គួរដល់សំពត់គូយ៉ាងណា ព្រះយោគីក៏ឈ្មោះថា **ធាតុកម្មដ្ឋានិក** ព្រោះអត្ថថា គួរដល់ធាតុកម្មដ្ឋានឬមានប្រយោជន៍ដោយធាតុកម្មដ្ឋានដូច្នេះ បានដល់ ព្រះយោគីអ្នកជាធាតុកម្មដ្ឋានិកនោះ ។

បទថា **ទក្ខោ** បានដល់ ជាអ្នកច្លាតក្នុងសមញ្ញានោះៗ បានដល់ ជាអ្នកដឹងថា ក្នុងគោមានកន្ទុយ និងស្នែងស្រួចពីកំណើត មកនៅលើជ្រញ់ កាលនៅមិនទាន់ពន្លះ ឬ កាត់ចំណែកដែលនៅរួមគ្នាឲ្យទៅជាចំណែកតូចៗ មានឆ្អឹង សាច់ជា-ដើម ក៏រមែងមានសមញ្ញាថា **គោ** កាលកំពុងពន្លះ ឬ កាត់បែងជាចំណែក ក៏នៅមានសមញ្ញាថា **គោ** តែថា កាលបានកាត់ជាចំណែកហើយ ក៏បានវោហារថា ដុំតូចៗ មានឆ្អឹង និងសាច់ជាដើម ។ ពាក្យថា **អ្នកសម្លាប់គោ** គឺ អ្នកសម្លាប់គោដើម្បីប្រយោជន៍ដល់ការចិញ្ចឹមជីវិត ។ បទថា **កូនសិស្ស** បានដល់ មនុស្សអ្នកនៅជិតគេ ដោយទាក់ទងនឹងការធ្វើការងារ ព្រោះចិញ្ចឹមជីវិតដោយអាស្រ័យការធ្វើការងាររបស់អ្នកសម្លាប់គោនោះ ។ ពាក្យថា **ចាក់** គឺ ចាក់គោមួយក្បាលត្រង់ទីកន្លែងមួយ ។ ពាក្យថា **ពោលគឺត្រង់កណ្ដាលផ្លូវធំ** បានដល់ ពោលគឺ ត្រង់ផ្លូវធំ

បែកជា ៤ ដែលជាទីសម្លាប់គោនោះឯង ។ ព្រោះត្រង់ក្រសែផ្លូវធំបែកជា ៤ នោះ គឺជាទីមកប្រជុំគ្នាអំពីទិសទាំង ៤ ដូច្នោះ ស្ថានទីនោះ ទើបមានដល់ក្រសែផ្លូវធំបែកជា ៤ បានដល់ ត្រង់កន្លែងផ្លូវធំបែកជា ៤ នោះ ។ ឈ្មោះថា **ពីលា** ព្រោះអត្ថថា ដែលគេតែងពន្ធះ គឺ បែងជាចំណែក បានដល់ ភាគ ( ចំណែក ) ព្រោះធ្វើ **វ**-អក្សរឲ្យជា **ព**-អក្សរ និងធ្វើ **ឥ**-អក្សរ ឲ្យជា **ល្ង**-អក្សរ ។ ដើម្បីសម្តែងន័យថា ចំណែកនោះៗឯង ទើបលោកពោលថា **កោដ្ឋាសំ កត្វា** ធ្វើឲ្យជាចំណែកៗដូច្នេះ ។ **ឋិត** ស័ព្ទ ជាស័ព្ទដែលប្រាប់ឲ្យដឹងដល់ភាពជាអ្នកព្រមព្រៀងដោយឥរិយាបថ ដែលហៅថា ឈរ ដូចក្នុងប្រយោគថា **ឋិតោ វា** ឈរក្តីជាដើម ឬ ភាពជាអ្នកព្រមព្រៀងដោយឥរិយាបថផ្សេងៗ បណ្តាឥរិយាបថដទៃ លើកលែងតែការដើរ ព្រោះ **ឋា**-ស័ព្ទ ( **ឋា**-ធាតុ ) មានអត្ថថា បដិសេធការដើរ តែថាក្នុងទីនេះ ទ្រង់បំណងយក **ឋិត**-ស័ព្ទ ដែលប្រាប់ឲ្យដឹងដល់អាការប្រព្រឹត្តទៅនៃរូបកាយ ដោយអាការណាមួយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ចតុន្នំ ឥរិយាបថានំ យេន កេនចិ អាការេន ឋិតត្តា យថាឋិតំ** ( ទីទៅ ព្រោះតាំងនៅដោយអាការណាមួយ នៃឥរិយាបថ ៤ ) ដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដោយអាការ** គឺ ដោយអាការប្រព្រឹត្តទៅនៃរូបកាយ មានអាការឈរជាដើម ។ ពិតមែន អាការទាំងឡាយ មានអាការឈរជាដើម លោកហៅថា ឥរិយាបថ ព្រោះភាពជាទីតាំងនៃការប្រព្រឹត្តទៅរបស់កិរិយាផ្លូវកាយ ដែលហៅថា ឥរិយាបថ ។ ពាក្យថា **តាមទីតាំងនៅ** គឺ តាមដែលប្រព្រឹត្តទៅ ។ ការតាំងនៅតាមដែលពោលមកហើយនោះឯង លោកបំណងថា ជាការទ្រទ្រង់នៅក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកពោលថា តាមដែលទ្រទ្រង់នៅ ព្រោះភាពជាកាយតាម

ដែលតាំងនៅហើយនោះឯង ដូច្នេះ ។ ម្យ៉ាងទៀត បទថា **ឋិតំ** ( តាំងនៅ ) ជាបទសម្តែងសេចក្តីប្រកបព្រមដោយឥរិយាបថ ដែលហៅថា ឈរនៃកាយ ។ បទថា **បណិហិតំ** ( តម្កល់ ) ជាបទសម្តែងសេចក្តីប្រកបព្រមដោយឥរិយាបថដទៃអំពីឥរិយាបថឈរនោះ ។ ម្យ៉ាងទៀត បទថា **ឋិតំ** ជាបទសម្តែងកំណត់រូបធម៌ទាំងឡាយដែលហៅថា **កាយ** ដោយអំណាចកិច្ចរបស់ខ្លួន ក្នុងខណៈនោះៗ ។ បទថា **បណិហិតំ** ជាបទសម្តែងការកំណត់រូបធម៌ទាំងឡាយដែលហៅថា **កាយ** ដោយអំណាចកិច្ចនៃបច្ច័យ បណ្ឌិតគប្បីជ្រាបសេចក្តីនៃបទទាំងនេះ តាមប្រការដូចពោលមកនេះចុះ ។ ពាក្យថា **ដោយភាពជាធាតុ** បានដល់ ធ្វើធាតុឲ្យជាធាតុ គឺឲ្យជាបឋវីធាតុជាដើមតែម្យ៉ាងៗ ។ បទថា **បច្ចវេក្ខតិ** គឺពិចារណាមួយៗ បានដល់ការញែកគូដោយញាណចក្ខុ ។

ឥឡូវនេះ លោកអាចារ្យប្រាថ្នាសម្តែងសេចក្តីដែលបានពោលទុក ដោយទាក់ទងជាពាក្យបើកបង្ហាញអត្ថនៃស័ព្ទក្នុងព្រះបាលីដោយពាក្យថា **យថា ធេកោ** ប្រៀបដូចជាអ្នកសម្លាប់គោដ៏ឆ្លាតជាដើម ដោយទាក់ទងនឹងការធ្វើការៈនៃអត្ថឲ្យជាក់ច្បាស់ ទើបពោលថា ប្រៀបដូចជា កាលអ្នកសម្លាប់គោ ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ចិញ្ចិមគោ** គឺធ្វើឲ្យធំធាត់ដោយវត្ថុ មានកន្ទក់ស្រូវ គ្រាប់កប្បាសជាដើម ដើម្បីសម្តែងការកើត និងការចម្រើននៃសាច់ ។ បទថា **វធិតំ មតំ** គឺជាគោដែលត្រូវសម្លាប់ ។ បទថា **មតំ** បានដល់ ត្រឹមតែស្លាប់ប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា **តាវទេវ** ដរាបប៉ុណ្ណោះ ។ ឈ្មោះថា **សេចក្តីសម្គាល់ថាជាគោក៏នៅមិនទាន់វិនាសបាត់ទៅ** មានសេចក្តីថា សេចក្តីសម្គាល់ថាជាគោ ព្រោះអាស្រ័យអវយវៈធំតូចពួកណា កាលគោត្រឹមតែស្លាប់ហើយ សេចក្តី

សម្គាល់ថាជាគោ ក៏នៅមិនទាន់វិនាសបាត់ទៅ ព្រោះការនៅជាប់គ្នានៃអវយវៈទាំងនោះមិនទាន់វិនាស ។ បទថា **ពិលាសោ ( វិលសោ )** បានដល់ ធ្វើឲ្យជាចំណែកៗ ពាក្យថា **បែង** គឺពន្ធះយកចេញអំពីគ្រោងឆ្អឹង ឬថា ធ្វើសាច់ដែលពន្ធះចេញអំពីគ្រោងឆ្អឹងហើយនោះ ឲ្យជាចំណែកៗ ។ ព្រោះហេតុនោះ ទើបលោកពោលថា សេចក្តីសម្គាល់ថាជាសាច់ រមែងប្រព្រឹត្តទៅដូច្នេះ ។ ឈ្មោះថា **សូម្បីជាបញ្ជិត** គឺអ្នកដែលមិនបានកាន់យកកម្មដ្ឋាន ។ ពាក្យថា **ការបំបែកឃនៈ** បានដល់ ការបំបែក គឺ បំបែកចេញនូវ **សន្តតិឃនៈ**( ភាពជាដុំព្រោះការបន្តគ្នា ) , **សមូហឃនៈ**( ភាពជាដុំព្រោះការរួមគ្នា ) , **កិច្ចឃនៈ**( ភាពជាដុំព្រោះកិច្ចនាទី ) និង **អារម្មណឃនៈ**( ភាពជាដុំព្រោះដឹងអារម្មណ៍ដូចគ្នា )។ ពាក្យថា **កាលពិចារណាដោយភាពជាធាតុ** គឺ កាលធ្វើការបំបែកឃនៈតាមដែលពោលមកហើយ ពិចារណាដោយភាពជាធាតុ ។ ដោយពាក្យថា សេចក្តីសម្គាល់ថា ជាសត្វ លោកពោលដល់សញ្ញាដែលប្រព្រឹត្តទៅដោយអំណាចនៃអត្តានុទិដ្ឋិថា សេចក្តីសម្គាល់ថា ជាសត្វ ការសម្គាល់ថា ជាសត្វ ដែលប្រព្រឹត្តទៅដោយការទាក់ទងនឹងវោហារ ( បញ្ញត្តិ ) និងការវិនាសបាត់ទៅក្នុងពេលនោះ ក៏ចាត់ថាគួរផងដែរ ព្រោះធ្វើឲ្យដឹងតាមសេចក្តីពិត ។ ពិតមែន កាលមានពាក្យអធិប្បាយតាមប្រការដូចពោលមកនេះ សេចក្តីនៃឧបមេយ្យ ទើបនឹងប្រៀបធៀបគ្នាបាន ទើបស្មើគ្នាបាននឹងសេចក្តីនៃឧបមា តាមដែលបានត្រាស់ទុក ជាពិតប្រាកដ ។ ព្រោះហេតុនោះ ទើបលោកពោលថា ចិត្តរមែងតាំងមាំ ដែលទាក់ទងជាធាតុប៉ុណ្ណោះ ដូច្នេះ ។

លោកអាចារ្យ កាលបានសម្តែងឋានៈនៃធាតុកម្មដ្ឋាន ដែលមកដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះ បំណងសម្តែងឋានៈដែលមកដោយពិស្តារ ទើបពោល

ថា ចំណែកក្នុងមហាហត្ថិបទោបមសូត្រដូច្នេះជាដើម ។ ដោយពាក្យថា ដូចជាក្នុងមហាហត្ថិបទោបមសូត្រនេះ លោកប្រៀបធៀបដល់ការដែលធាតុកម្មដ្ឋានមកដោយពិស្តារ ក្នុងរាហុលោវាទសូត្រ និងធាតុវិភង្គសូត្រ មិនមែនប្រៀបធៀបទេសនានយ័ទាំងអស់ទេ ព្រោះទេសនានយ័ក្នុងរាហុលោវាទសូត្រ និងធាតុវិភង្គនោះមកហើយដោយប្រការដទៃ ។

បទថា **តត្រ** គឺក្នុងបឋមមហាហត្ថិបទោបមសូត្រ តាមដែលព្រះសារីបុត្របានសម្តែងទុកហើយនោះ ។ បទថា **អជ្ឈត្តិកា** ខាងក្នុង គឺរាប់ទាក់ទងក្នុងសន្តានរបស់សត្វ ។ សូម្បីដោយពីរបទថា **អជ្ឈត្តំ បច្ចត្តំ** ( វត្ថុដែលមានក្នុងខ្លួន អាស្រ័យខ្លួន ) ដែលលោកពោលដល់ធម៌ ដែលជារបស់ចំពោះបុគ្គលនោះៗ , ព្រោះហេតុនោះទើបលោកពោលថា ទាំងពីរបទនេះ ជាពាក្យហៅវត្ថុដែលជានិយកៈដូច្នេះ ។ វត្ថុដែលប្រព្រឹត្តទៅជាប់នៅហ្នឹងខ្លួន ដោយអំណាចការចូលដល់ភាពជាវត្ថុដែលគប្បីកាន់យកបានក្នុងខ្លួន ព្រោះជាធម៌ដែលរាប់ទាក់ទងក្នុងការបន្តរបស់ខ្លួន ឈ្មោះថា **អជ្ឈត្ត** ។ ឯឈ្មោះថា **បច្ចត្ត** ព្រោះជាធម៌ដែលរាប់ទាក់ទងក្នុងការបន្តគ្នានោះៗ ។ ព្រោះហេតុនោះឯង ទើបលោកពោលថា លោកហៅថា **អជ្ឈត្ត** ព្រោះប្រព្រឹត្តទៅក្នុងខ្លួន ហៅថា **បច្ចត្ត** ព្រោះអាស្រ័យខ្លួនប្រព្រឹត្តទៅដូច្នេះ ។ បទថា **កក្ខឡំ** បានដល់ រឹង ។ ព្រោះហេតុដែលវត្ថុនោះ ( បឋវីធាតុ ) រមែងជាទីតាំងនៃរូបធម៌ដែលកើតរួមគ្នាទាំងឡាយបាន ក៏ដោយភាពជារបស់រឹងដូច្នោះ ទើបលោកពោលថា ជារបស់រឹងដូច្នេះ ។ បទថា **ខរិគតំ** គឺ ក្នុងបណ្តារបស់រឹង គឺ មានសភាវៈរឹងទាំងឡាយ បានដល់ ទាក់ទងក្នុងរបស់រឹងនោះ មានសេចក្តីថា មានសភាវៈរឹងនោះឯង ។ ប៉ុន្តែព្រោះហេតុតែរបស់ដែលមានសភាវៈរឹង រមែងមាន

អាការគ្រោតគ្រាត ព្រោះប្រាកដដោយអាការគ្រោតគ្រាត , ដូច្នោះ ទើបលោកពោលថា គ្រោតគ្រាតដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា បទទី ២ ជាពាក្យប្រាប់អាការ ។ វត្ថុដែលតាំងនៅក្នុងសរីរៈ ឈ្មោះថា **ឧបាទិន្ន** ។ លោកអាចារ្យសំដៅយកកាពជាវត្ថុដែលមានកម្មជាសមុដ្ឋាន ប្រាថ្នាសម្តែងឧបាទិន្នទោះថា សូម្បីវត្ថុដែលជាឧបាទិន្នក៏មាន សូម្បីវត្ថុដែលជាអនុបាទិន្នក៏មាន វត្ថុទាំងអស់នេះចាត់ជាឧបាទិន្នតែម្យ៉ាង ដោយទាក់ទងជាវត្ថុដែលតណ្ហាបរិតៃ ក្លួចកាន់ ប្រកាន់មាំដូច្នេះ ទើបពោលថា បទថា **ជាឧបាទិន្នធម៌** គឺជារបស់ដែលតណ្ហា និងទិដ្ឋិរួបរឹតយ៉ាងមាំដូច្នេះជាដើម ។ ក្នុងពាក្យទាំងអស់នោះ មានពាក្យប្រកបសេចក្តីថា ប្រកាន់ថាជារបស់យើង ប្រកាន់មាំថាជាយើង ។ ពាក្យថា **វត្ថុនេះយ៉ាងដូចម្តេចខ្លះ** ជាពាក្យនិយាយដែលជាកថេតុកម្យតាបុច្ឆា ពាក្យសួរដើម្បីត្រូវការនឹងឆ្លើយខ្លួនឯង ព្រោះហេតុនោះ ទើបលោកពោលថា មានន័យថា បើសួរថា វត្ថុនោះយ៉ាងដូចម្តេចហ្ន៎ ដូច្នេះ ។ ពាក្យថា **បន្ទាប់ពីនោះទៅ** គឺ ខាងក្រោយ ។ ពាក្យថា **នោះ** គឺ ( កាលនឹងសម្តែង ) បឋវីធាតុនោះ ដែលបានសម្តែងទុកដោយប្រភេទ មានអជ្ឈត្តិកា ( ខាងក្នុង ) ជាដើម ។ ពាក្យថា **កាលនឹងសម្តែង** គឺ កាលនឹងសម្តែងដោយវត្ថុ ។ ព្រះសារីបុត្ររួមយកខួរក្បាលចូលជាមួយខួរក្នុងឆ្អឹងនោះឯង ទើបមិនបាន លើកយកខួរក្បាលចូលទុកជាកោដ្ឋាសមួយ ដោយឡែកក្នុងព្រះបាលីពេលនេះក៏ពិត សូម្បីយ៉ាងនោះ ក្នុងបដិសម្ភិទាមគ្គ លោកកាន់យកខួរក្បាលជាកោដ្ឋាសមួយដោយឡែក ដើម្បីនឹងសម្តែងឲ្យបរិបូណ៌ដោយអាការ ២០ ព្រោះហេតុនោះ លោកអាចារ្យ កាលនឹងរួមយកខួរក្បាលនោះ ចូលទុកក្នុងកោដ្ឋាសនៃបឋវីធាតុទាំងឡាយ ព្រោះជាកោដ្ឋាសដ៏ក្រៃលែងដោយភាពរឹងនោះឯង

ទើបពោលថា គប្បីជ្រាបថា លោកសម្តែងខែបឋវីធាតុទុកដោយអាការ ២០ រួមយកខួរក្បាលចូលផងដូច្នេះ ។ មា៉្យងទៀត ដោយពាក្យថា ឬថាវត្ថុណាមួយ សូម្បីយ៉ាងដទៃនេះ គប្បីឃើញថា លោករួមយកខួរក្បាលទុកក្នុងព្រះបាលី ។ ព្រោះដូច្នោះ ក្នុងទីនេះពាក្យថា ឬថាវត្ថុណាមួយ សូម្បីយ៉ាងដទៃនេះ មានការសំដៅដល់បទដើម និងបទចុង ព្រោះមានពាក្យនិយាយថា គប្បីជ្រាបថា លោកសម្តែងខែបឋវីធាតុទុកដោយអាការ ២០ រួមយកខួរក្បាលចូលផង , ពាក្យថា ឬថាវត្ថុណាមួយ សូម្បីយ៉ាងដទៃដូច្នេះ ។ គប្បីប្រកបពាក្យពោលម្តងទៀតថា **យំ វា បនញ្ញម្បិ កិញ្ចិតិ អវសេសេសុ តីសុ កោដ្ឋាសេសុ** ( ពាក្យថា ឬថាវត្ថុណាមួយ សូម្បីយ៉ាងដទៃ ត្រូវលោករួមយក បឋវីធាតុក្នុងកោដ្ឋាស ៣ ដ៏សេស ) ។ ពាក្យថា **ក្នុងកោដ្ឋាស ៣** បានដល់ ក្នុងកោដ្ឋាស ៣ ប្រការ ( មានកោដ្ឋាសដែលមានចិត្តជាសមុដ្ឋានជាដើម ) ។ មិនមែនកោដ្ឋាសទាំងនោះមាន ៣ កោដ្ឋាសទេ ។

ពាក្យថា **ដោយភាវៈដែលហូរទៅ** គឺ ដោយភាវៈដែលស្រក់ហូរ ។ បទថា **អប្បោតិ** ប្រែថា ជ្រាបទៅ ។ បទថា **បប្បោតិ** ប្រែថា ដល់ , ពាក្យថា **ជ្រាបទៅជាដើម** នេះលោកពោលទុកព្រោះជាសសម្ភារៈអាបោ ។ ពិតមែន សសម្ភារ-អាបោនោះ រមែងជ្រាបទៅ និងសូម្បីឋានៈនោះៗ ដែលរាប់ថា ជាសសម្ភារបឋវីដោយភាវៈដែលហូរទៅ , ឬថាជាពាក្យដែលលោកពោលទុកដោយទាក់ទង ជាលក្ខណៈ របស់អាបោនោះឯង ។ ពិតហើយ លក្ខណៈអាបោនោះ រមែងជ្រាបទៅគឺដល់ឋានៈនោះៗ ពោលគឺមហាភូតរូប ៣ ដ៏សេស ដែលធ្វើការសម្ព័ន្ធគ្នា ជាប់គ្នា និងមិនឲ្យខ្ចាត់ខ្ចាយ ដោយភាពជារបស់ដែលហូរ ដែលសម្រេចហើយ ព្រោះភាពជារបស់វា ដោយភាពជាសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និង និស្សយប្បច្ច័យ

ជាដើម គឺរមែងគួរដល់ភាវៈដែលនឹងគប្បីពោល **អប្បោតិ បប្បោតិ** ដូច្នេះឯង ។

ពាក្យថា **ដោយអំណាចនៃការធ្វើឲ្យក្តៅ** គឺដោយភាវៈក្តៅក្លា ។ ពាក្យថា **តាមន័យដែលបានពោលហើយ** គឺតាមន័យដែលបានពោលហើយក្នុងអាបោធាតុថា **នានាវិធេសុ** ( ច្រើនយ៉ាងផ្សេងៗ គ្នា ) ដោយទាក់ទងជាតេជោធាតុ ដែលមានកម្មជាសមុដ្ឋានជាដើម ។ បទថា **កុប្បិតេន** ប្រែថា ដែលកម្រើកហើយ ។ ពាក្យថា កើតកម្តៅធ្លលឡើង គឺត្រូវភាពក្តៅធ្លលគ្របសង្កត់ ។ ពាក្យថា **ទ្រុឌទ្រោម** គឺមានការដល់ភាពចាស់ជរា ។ លោកអាចារ្យមានបំណងនឹងសម្តែងថា ការប្រព្រឹត្តទៅនៃភាពដល់ការចាស់ជរាក្នុងរាងកាយនេះ ដែលមានបានដោយអំណាចនៃតេជោធាតុ បណ្ឌិតគប្បីជ្រាបដោយពាក់ព័ន្ធដល់ភាពជាជរាប្រាកដចុះដូច្នេះ ទើបពោលថា គឺ ដល់ភាពជាអ្នកមានឥន្ទ្រិយទន់ខ្សោយ ដូច្នេះជាដើម ។ ការក្តៅហួសពីកម្តៅប្រក្រតីក្នុងសរីរៈ ឈ្មោះថា **សន្តាប** ( ក្តៅធ្លល ) ការក្តៅខ្លាំងដែលប្រព្រឹត្តទៅដោយការទាក់ទងនឹងការដុតរោលសរីរៈ ឈ្មោះថា **បរិទាហ** ( ក្តៅធំ ) ដែលពោលមកនេះ នេះជាការផ្សេងគ្នានៃកម្តៅទាំងនេះ ។ ម្យ៉ាងទៀត ពាក្យថា **ជាហេតុទ្រុឌទ្រោម** មានសេចក្តីថា ជាហេតុទ្រុឌទ្រោមដោយរោគជរា មានគ្រុនក្តៅជាដើម សូម្បីដូច្នេះក៏គួរ ។ ទឹកដោះថ្លាដែលគេកម្តៅម្តងហើយម្តងទៀត រហូត ៧ ដងហើយ ទើបដាក់ត្រាំទុកក្នុងទឹកត្រជាក់ ហើយលើកឡើង លោកហៅថា សតធោតសប្បិ ( ទឹកដោះស្រស់ដែលសម្រិតហើយ ១០០ ដង ) ។ បទថា **អសិតំ** បានដល់ របស់បរិភោគ ។ បទថា **ខាយិតំ** ប្រែថា របស់ទំពាស៊ី ។ បទថា **សាយិតំ** ប្រែថា របស់លិទ្ធភ្លក្ស ។ ពាក្យថា **ដល់ការរលាយទៅបានដោយប្រពៃ** លោកពោលដោយការទាក់ទងជាមួយនឹងភ្លើងធាតុ ដែលមានការរលាយបាន

ដោយប្រពៃជាប្រក្រតី ឯការរលាយទៅមិនប្រពៃ បណ្ឌិតគប្បីជ្រាបដោយការទាក់ទងនឹងភ្លើងធាតុនោះ ដែលមិនមានការរំលាយបានដោយប្រពៃជាប្រក្រតីនោះតែម្ដង ។ ពាក្យថា **ដោយភាពជារសជាដើម** គឺដោយទាក់ទងជារស ឈាម សាច់ ខ្លាញ់ខាប់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង និងទឹកសុក្កៈ ។ ពាក្យថា **ការញែកគ្នា** គឺភាពម្យ៉ាងម្នាក់ បានដល់ ការមិនដូចគ្នានិងគ្នា ។ ពិតហើយ កាលអាហារដែលមានប្រភេទជារបស់បរិភោគជាដើម មានការប្រែប្រួលទៅ រសក៏រមែងមាន មានសេចក្ដីថា រសធាតុអាស្រ័យសេចក្ដីប្រែប្រួលនោះកើតឡើង ។ បណ្ឌិតគប្បីនាំពាក្យទាំងពួងទៅដោយន័យថា កាលរសមានភាពប្រែប្រួលទៅ ក៏រមែងមានឈាមដូច្នេះជាដើម ដូចគ្នាយ៉ាងនេះចុះ ។

ពាក្យថា **ដោយអំណាចការបក់ទៅ** គឺដោយអំណាចនៃការឃ្លាតចាកទី ឬថាដោយអំណាចនៃការទៅព្រមជាមួយនឹងភាពរហ័ស ។ ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **ឧគ្គារហិកាទិ** ( ការភើ ការឡើ្អកជាដើម ) គប្បីឃើញថា រួមយកខ្យល់ទាំងឡាយដែលធ្វើការក្អួត ការខាកស្ដោះជាដើមឲ្យប្រព្រឹត្តទៅ ។ ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **ឧច្ចារបស្សាវាទិ** ( ឧច្ចារបស្សាវៈជាដើម ) គប្បីឃើញថា រួមយកទឹកប្រមាត់ ស្លេស្ម ទឹករំអិល និងកោដ្ឋាសដែលបញ្ចេញក្លិនស្អុយតែម្យ៉ាងជាដើម ។ **កុច្ឆិ**-ស័ព្ទ ដែលប្រែថា បរិវេណពោះ ជាស័ព្ទបរិយាយទាក់ទងនឹងឧទរ ( ពោះ ) ក៏ពិត តែព្រោះខាងក្នុងពោះវៀន លោកពោលទុកដោយ **កោដ្ឋ**-ស័ព្ទ ដែលប្រែថា ប្រហោងពោះ បរិវេណពោះដែលនៅសល់អំពីចំណែកដែលជាប្រហោងពោះនោះ លោកពោលដល់ **កុច្ឆិ**-ស័ព្ទ ក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកពោលថា **កុច្ឆិសយា វាតាតិ អន្តានំ ពហិវាតា** ( ពាក្យថា

ខ្យល់ដែលនៅក្នុងបរិវេណពោះ បានដល់ ខ្យល់ខាងក្រៅពោះវៀន ) ដូច្នេះ ។ ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **សម្មិញ្ជនបសារណាទិ** ( មានការបត់ មានការលាត ជាដើម ) ជាការសង្គ្រោះកិរិយាផ្លូវកាយទាំងពួង មានក្រឡេកមើល ការបែរមើល ការលើកជើង ការឈានជើងជាដើម ។ ដោយពាក្យថា **ខ្យល់អស្សាសៈ និង ខ្យល់បស្សាសៈមានចិត្តជាសមុដ្ឋានតែម្យ៉ាង** នេះលោកសម្តែងថា ខ្យល់អស្សាសៈ និងខ្យល់បស្សាសៈមិនមានការប្រព្រឹត្តទៅផុតសរីរៈ ។ សេចក្តីពិតថា រូបដែល មានចិត្តជាសមុដ្ឋាន មិនមានការកើតឡើង ខាងក្រៅសរីរៈ ។ សួរថា បើយ៉ាងនេះ ពាក្យពោលថា ពាក្យថា **ខ្យល់បស្សាសៈ** បានដល់ ខ្យល់ត្រង់រន្ធច្រមុះដែលចេញ ទៅខាងក្រៅ , សម្រាប់មនុស្សដែលមានច្រមុះវែង រមែងប្រព្រឹត្តទៅ ប៉ះខ្ទប់នៅ ត្រង់ចុងច្រមុះ សម្រាប់មនុស្សមានច្រមុះខ្លីក្រៅពីនេះ រមែងប្រព្រឹត្តទៅប៉ះខ្ទប់ត្រង់ សាច់រឹមបបូរមាត់លើ ដូច្នេះ នឹងមានបានដូចម្តេចហ្ន៎ ? ឆ្លើយថា គប្បីជ្រាបថា លោកពោលពាក្យនោះទុក ដោយការទាក់ទងនឹងខ្យល់ដែលមានចិត្តជាសមុដ្ឋាន រួមទាំងខ្យល់ដែលមានឧតុជាសមុដ្ឋានដែលប្រព្រឹត្តទៅក្នុងសន្តាន ព្រោះប្រព្រឹត្តទៅ ដោយអាការដែលចេញទៅខាងក្រៅ ។ ពាក្យថា **ក្នុងទីទាំងពួង** លោកពោល កំណត់យកពាក្យសម្តែងខែធាតុ ៣ មានអាបោធាតុជាដើម ។ ក្នុងពាក្យសម្តែងខែ ទាំងនោះ ដោយពាក្យថា ឬថាដោយវត្ថុណាមួយ សូម្បីយ៉ាងដទៃនេះ ក្នុងពាក្យ សម្តែងខែអាបោធាតុ គប្បីឃើញថា រួមយកទឹកសម្ភវៈផង , ក្នុងពាក្យសម្តែងខែ តេជោធាតុ គប្បីឃើញថា រួមយកកម្តៅដែលមានជាប្រក្រតីក្នុងសរីរៈ , ក្នុងពាក្យ សម្តែងខែវាយោធាតុ គប្បីឃើញថា រួមយកខ្យល់ដែលផ្សាយទៅតាមសរសៃដែល ធ្វើពកបូសឲ្យកើតឡើងលើផ្ទៃស្បែកជាដើមក្នុងទីនោះៗ ។ ខ្យល់ដែលធ្វើអាការបត់

ជាដើមឲ្យកើតឡើង មានចិត្តជាសមុដ្ឋានតែម្យ៉ាង , សួរថា បើយ៉ាងនេះ ពាក្យដែលពោលថា វាយោគតៈ ៥ ខាងដើម មានសមុដ្ឋាន ៤ ដូចនេះ នឹងគប្បីមានបានយ៉ាងដូចម្តេច ? ឆ្លើយថា ខ្យល់ដែលបក់ទៅតាមអវយវៈតូចធំ មិនមែនមានចំពោះតែអាការបត់ជាដើមឲ្យកើតឡើងតែម្យ៉ាងទេ , តែថា សូម្បីជាយ៉ាងដទៃអពីការធ្វើអាការបត់ជាដើមឲ្យកើតឡើងនោះ ក៏មានដោយពិត ព្រោះដូច្នោះ មិនមានការខុសឃ្លៀងឃ្លាតទេ ។

សព្ទថា ***ឥតិ*** ( ដោយប្រការដូចពោលមកនេះ ) ជាពាក្យទាញយកប្រការដែលបានពោលមកហើយ ។ ព្រោះហេតុនោះ ទើបពោលថា ***វីសតិយា អាការេ-ហិ*** ( គឺ លោកអធិប្បាយធាតុ ៤ ទុក ដោយអាការ ៤២ គឺ បឋវីធាតុដោយអាការ ២០ ) ជាដើម ។ បទថា ***ឯត្ថ*** មានសេចក្តីថា ក្នុងធាតុកម្មដ្ឋានដែលមកហើយដោយពិស្តារនេះ ។ ដោយពាក្យនោះ លោកអាចារ្យសម្តែងថា ពាក្យពណ៌នានេះ មិនមែនជាសំវណ្ណនា ( ពាក្យអធិប្បាយ ) សេចក្តីនៃមហាហត្ថិបទោបមសូត្រតែម្យ៉ាងប៉ុណ្ណោះទេ , វាជាការសំវណ្ណនាសេចក្តីក្នុងមហារាហុលោវាទសូត្រនិងធាតុវិភង្គសូត្រផងដែរ ។ សូម្បីក្នុងភាវនានយ ក៏មាននយដូចគ្នានេះដែរ ។ ពិតយ៉ាងនោះមែន លោកពោលថា ដែលមកហើយ សូម្បីក្នុងរាហុលោវាទសូត្រនិង ធាតុវិភង្គសូត្រក៏ដូចដែលមកហើយ ក្នុងមហាហត្ថិបទោបមសូត្រនេះ ដូច្នេះ ។

បទថា ***ភាវនានយេ*** គឺក្នុងនយនៃការចម្រើន ។ មានសេចក្តីថា ការចម្រើនកម្មដ្ឋានរមែងសម្រេចបានដោយភាវនាវិធីណា ក៏បានដល់ ភាវនាវិធីនោះ ។ បទថា ***ឯត្ថ*** បានដល់ ក្នុងធាតុកម្មដ្ឋាន ។ លោកអាចារ្យប្រាថ្នាសម្តែងសេចក្តីដែលថា ព្រោះហេតុតែកម្មដ្ឋាននេះ ដែលមកហើយដោយពីរប្រការ គឺលោកសម្តែងទុក

ដោយពីរប្រការ ដោយអំណាចនៃបុគ្គលពីរជំពូក គឺ បុគ្គលអ្នកមានបញ្ញាចាស់ក្លា និងបុគ្គលអ្នកមានបញ្ញាមិនចាស់ក្លាពួកណា ដូច្នោះ សូម្បីការបំពេញកម្មដ្ឋាននៃបុគ្គល ពួកនោះក៏គួរប្រាថ្នាជាពីរប្រការដូចគ្នា ដូច្នេះនោះសិន ទើបផ្ដើមពាក្យថា សម្រាប់ភិក្ខុអ្នកមានបញ្ញាចាស់ក្លាដូច្នេះជាដើម ។ **ឥតិ-ស័ព្ទ** ក្នុងបទថា **លោមា បឋវីធាតុ** មានអត្ថថា **អាទិ** ( ប្រែថា ជាដើម ) ។ ពាក្យថា **ការកំណត់ធាតុដោយពិស្ដារយ៉ាងនេះ** គឺការកំណត់ធាតុកម្មដ្ឋានដោយពិស្ដារយ៉ាងនេះ ដោយអាការ ៤២ ដោយន័យថា សក់ជាបឋវីធាតុ រោមជាបឋវីធាតុជាដើម ។ ពាក្យថា **រមែងប្រាកដជាវែងឆ្ងាយ** គឺ រមែងប្រាកដជាយឺតយូរ ជាអូសបន្ទាយទៅ ។ ពាក្យថា **លក្ខណៈរឹងឯណា** គឺ លក្ខណៈរឹង បានដល់ ភាវៈដែលរឹងឯណា ក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម ។ សូម្បីក្នុងពាក្យថា លក្ខណៈដែលទ្រទ្រង់ឯណាជាដើម ក៏មានន័យដូច្នេះ ។ ពាក្យថា **កាលលោកមនសិការទៅយ៉ាងនេះ** គឺ កាលលោកមិនប៉ះពាល់ មិនពិចារណាតួវត្ថុ លោកមនសិការឲ្យប្រព្រឹត្តទៅ ដោយត្រឹមតែលក្ខណៈប៉ុណ្ណោះយ៉ាងនេះ ។ បទថា **អស្ស** បានដល់ ភិក្ខុអ្នកមានបញ្ញាញាណចាស់ក្លា ។ ពាក្យថា **កម្មដ្ឋានក៏នឹងត្រូវប្រាកដច្បាស់** គឺ លក្ខណៈនោះៗ ឯង ដែលជាទីតាំងនៃការប្រព្រឹត្តទៅនៃភាពការធ្វើសេចក្ដីព្យាយាម នឹងត្រូវប្រាកដច្បាស់ , ម្យ៉ាងទៀត ព្រោះលក្ខណៈនោះប្រាកដដោយល្អ កម្មដ្ឋាន គឺ មនសិការដែលប្រព្រឹត្តទៅប្រារព្ធលក្ខណៈនោះ ទើបជាធម្មជាតិប្រាកដច្បាស់ គឺ ក្លៀវក្លា ។ តាមភាពដែលភិក្ខុអ្នកមានបញ្ញាចាស់ក្លា ជាអ្នកពេញចិត្តក្នុងទេសនាធម៌ដ៏សង្ខេបដោយអំណាចការចាស់ក្លានៃឥន្ទ្រិយ , សម្រាប់អ្នកមានបញ្ញាទន់ខ្សោយ ការនានឹងសម្រេចមិនបានឡើយដោយប្រការទាំងពួង ព្រោះហេតុនោះ ទើបលោកពោលថា សម្រាប់

ភិក្ខុអ្នកមានបញ្ញាមិនចាស់ក្លាដូច្នេះ ។ ពាក្យថា **កាលមនសិការទៅយ៉ាងនេះ** គឺ កាលមនសិការទៅដោយសង្ខេបតាមន័យដែលបានពោលហើយ ។ ពាក្យថា **នឹងត្រូវងងឹត មិនជាក់ច្បាស់** ប្រកបសេចក្តីថា កម្មដ្ឋាន នឹងមិនប្រាកដច្បាស់ ដូចជាការធ្វើឲ្យងងឹតទៅដោយការមិនប្រាកដ ។ ពាក្យថា **តាមន័យមុន** គឺ តាមន័យដែលពោលហើយក្នុងពេលមុន ដោយពាក្យថា " សក់ជាបឋវីធាតុ " ជាដើម ។ កាលមនសិការដោយពិស្តារដោយការប៉ះពាល់ ( ពិចារណា ) វត្ថុកម្មដ្ឋាន រមែងប្រាកដច្បាស់ ព្រោះការដែលបុគ្គលអ្នកមានបញ្ញាមិនចាស់ក្លា ជាអ្នកពេញចិត្តក្នុងធម៌ទេសនាដោយពិស្តារ ព្រោះមិនមានការត្រិះរិះ ឬពិចារណាដោយឆាប់រហ័ស ។

ឥឡូវនេះ លោកអាចារ្យប្រាថ្នានឹងបើកបង្ហាញសេចក្តីតាមដែលពោលហើយដោយឧបមា ទើបពោលថា ប្រៀបដូចជា កាលភិក្ខុពីរអង្គដូច្នេះជាដើម ។ ពាក្យថា **បេយ្យាលមុខ** គឺ ១ វារៈ គឺ ២ វារៈខាងដើម ដែលជាមុខ គឺជាគន្លងនៃព្រះបាលីដែលមានបេយ្យាលៈ ។ ពាក្យថា **ឲ្យពិស្តារ** គឺស្វាធ្យាយទៅដោយមិនមានសល់ ។ ពាក្យថា **ដោយទាក់ទងនឹងចំណែកទាំងពីរ** គឺ ដោយទាក់ទងនឹងការកាន់យកខាងដើម និងទីបំផុតនៃវារៈនោះៗ ។ ពាក្យថា **ត្រឹមឲ្យបបូរមាត់ប៉ះខ្ទប់គ្នា** គឺ ត្រឹមឲ្យបបូរមាត់សម្ផស្សគ្នា ។ បណ្ឌិតគប្បីជ្រាបការប្រៀបធៀបដោយឧបមាយ៉ាងនេះថា ប្រៀបដូចជាក្នុងការពិចារណាគន្ថៈ ភិក្ខុអ្នកមានបញ្ញាចាស់ក្លា រមែងពេញចិត្តសេចក្តីសង្ខេប មិនពេញចិត្តសេចក្តីពិស្តារ ។ ចំណែកភិក្ខុក្រៅនេះ អ្នកមានបញ្ញាមិនចាស់ក្លា រមែងពេញចិត្តសេចក្តីពិស្តារ មិនពេញចិត្តសេចក្តីសង្ខេប យ៉ាងណា សូម្បីន័យនៃភាវនា បណ្ឌិតគប្បីជ្រាបឧបមេយ្យដូច្នោះចុះ ។

ពាក្យថា **ព្រោះដូច្នោះ** គឺព្រោះហេតុដែលសេចក្តីសង្ខេបជាទីសប្បាយសម្រាប់

ភិក្ខុអ្នកមានបញ្ញាចាស់ក្លា និងសេចក្តីពិស្តារជាទីសប្បាយសម្រាប់ភិក្ខុអ្នកមានបញ្ញាមិនចាស់ក្លា ដូច្នោះ ។ ព្រោះហេតុដែលព្រះយោគីអ្នកប្រាថ្នាបំពេញកម្មដ្ឋាន ចាំបាច់ប្រារព្ធបុព្វកិច្ច ( កិច្ចដែលគួរធ្វើមុន ) មានការជម្រះសីលឲ្យហ្មត់ចត់ជាដើម ។ បុព្វកិច្ចដែលដល់ព្រមដោយអាការទាំងពួងនោះ លោកអាចារ្យបានពោលទុកក្នុងខាងដើមរួចហើយ ព្រោះហេតុនោះ ក្នុងទីនេះទើបលោកមិនលើកមក ។ ម្យ៉ាងទៀត ព្រោះហេតុថា ភាវនារមែងសម្រេចដល់បុគ្គលអ្នកមានកាយពួនសំងំ និងមានចិត្តពួនសំងំប៉ុណ្ណោះ , មិនមែនមានដល់បុគ្គលដទៃទេ លោកអាចារ្យកាលនឹងសម្តែងអាការពួនសំងំទាំងពីរនោះ ទើបពោលថា **រហោគតេន បដិសល្លីនេន** ក្នុងពីរបទនោះ បទថា **រហោ គតេន** ប្រែថា ទៅក្នុងទីស្ងាត់ មានន័យថា តែម្នាក់ឯង ចូលទៅក្នុងស្ថានទីដែលអនុកូលដល់ភាវនា ។ បទថា **បដិសល្លីនេន**-ពួនសំងំ គឺឃុំគ្រងចិត្តចាកអារម្មណ៍ផ្សេងៗ សំងំនៅក្នុងកម្មដ្ឋាន មានន័យថា មានចិត្តតម្កល់ក្នុងកម្មដ្ឋាននោះ ។ ពាក្យថា **នឹកដល់រូបកាយរបស់ខ្លួនទូទាំងរាងកាយ** មានសេចក្តីថា ព្រោះហេតុថា រូបកាយនេះ ជាមហាភូត ៤ , ដូច្នោះ ព្រះយោគាវចរកាលនឹងមនសិការករជកាយរបស់ខ្លួន រហូតទូទាំងរាងកាយ តាំងពីបាតជើងឡើងទៅ តាំងពីចុងសក់ចុះមក ខាងទទឹងមានស្បែកព័ទ្ធជុំវិញ ដោយទាក់ទងនឹងធាតុទើបប្រមូលនឹកដល់ការទាក់ទងជាមហាភូត ៤ ថា ក្នុងកាយនេះ មានបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ដូច្នេះ ។ ឥឡូវនេះ លោកអាចារ្យបំណងសម្តែងវិធីមនសិការធាតុទាំងនោះ ដោយលក្ខណៈ និងដោយអាការប្រាកដ ទើបពោលថា **យោ ឥមស្មឹ កាយេ** ជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ភាវៈដែលរឹង** លោកពោលដល់លក្ខណៈ ព្រោះ

ថា មានភាពរឹងជាលក្ខណៈ ។

ដោយពាក្យថា **ភាវៈដែលរឹង** លោកពោលដល់អាការប្រាកដ អធិប្បាយថា អាការដែលគប្បីកាន់យកដោយញាណ ។ ឈ្មោះថា **ភាវៈរាវ** ចាត់ជាលក្ខណៈ ព្រោះ អាបោធាតុមានការហូរជ្រាបជាសភាវៈ , ឈ្មោះថា **ការកកខន់** ( ចងភ្ជាប់ ) ចាត់ជាអាការប្រាកដ ។ ឈ្មោះថា **ភាវៈដែលក្ដៅ** ចាត់ជាលក្ខណៈ ព្រោះតេជោធាតុ មានការក្ដៅជាសភាវៈ , ឈ្មោះថា **ការធ្វើឲ្យរលាយទៅ** ចាត់ជាអាការប្រាកដ ។ ឈ្មោះថា **ការបក់ផាត់** ចាត់ជាលក្ខណៈ ព្រោះវាយោធាតុមានការទ្រទ្រង់ជាសភាវៈ , ឈ្មោះថា **ធ្វើឲ្យកម្រើកទៅ** ចាត់ជាអាការប្រាកដ និងបានឈ្មោះថា អាការប្រាកដ ក៏បានដល់ អាការដែលជាក់ច្បាស់ដល់ញាណដោយអំណាចនៃការដែលធាតុទាំងឡាយធ្វើកិច្ចរបស់ខ្លួន ។ ព្រោះហេតុអ្វី ក្នុងធាតុទាំង ៤ នេះ ទើបមានការកាន់យកភាវៈ ២ យ៉ាង ? ឆ្លើយថា មានការកាន់យកភាវៈ ២ យ៉ាង ក៏ព្រោះដោយអធ្យាស្រ័យនៃបុគ្គល ។ ពិតមែន សម្រាប់ព្រះយោគីខ្លះ មនសិការធាតុទាំងឡាយ ធាតុទាំងនេះរមែងដល់ភាវៈដែលលោកគប្បីកាន់យកបានដោយសភាវៈ សម្រាប់ព្រះយោគីខ្លះក៏ដោយការធ្វើកិច្ចរបស់ខ្លួន , ក្នុងព្រះយោគីពីរជំពូកនោះ ព្រះយោគីអង្គដែលលោកហៅថា **រស** កាលមនសិការធាតុទាំងឡាយក្នុងខាងដើម រមែងកំណត់កាន់យកដោយលក្ខណៈរបស់ខ្លួន សូម្បីដោយរសរបស់ខ្លួនតែ ១ ធាតុ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា កំណត់ធាតុទាំងឡាយ ដោយសង្ខេបយ៉ាងនេះថា ភាវៈដែលរឹង ឬភាវៈដែលគ្រោតគ្រាតក្នុងកាយនេះឯណា ។ល។ ដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **កំណត់យក** គឺ កំណត់យកធាតុទាំងឡាយដោយលក្ខណៈ ឬថា ដោយរស ដោយញាណ

ដែលជាអ្នកកាន់យក ។ នេះជាការចម្រើនកម្មដ្ឋានក្នុងន័យនៃការនា ដោយសង្ខេបសិន ។

ព្រះយោគាវចរ កំណត់ធាតុទាំងឡាយយ៉ាងនេះហើយ កាលមនសិការធាតុទាំងឡាយ ព្រមទាំងលក្ខណៈជាដើមយ៉ាងនេះថា ក្នុងកាយនេះ មានបឋវីធាតុ គឺ ភាវៈដែលរឹង ឬភាវៈដែលគ្រោតគ្រាត , មានអាបោធាតុ គឺ ភាវៈដែលហូរ ឬភាវៈដែលសម្ព័ន្ធ , មានតេជោធាតុ គឺ ភាវៈដែលក្ដៅ ឬភាវៈដែលធ្វើឲ្យរលាយ , មានវាយោធាតុ គឺភាវៈដែលបក់ផាត់ ឬភាវៈដែលធ្វើឲ្យកម្រើក ក៏គប្បីនឹកដល់ គប្បីមនសិការហើយ មនសិការទៀត អស់កាល ១០០ ដង ខ្វះ ១០០០ ដង ខ្វះ គប្បីធ្វើឲ្យជាវត្ថុដែលពិចារណាបានមាំទាំ ជាវត្ថុដែលគួរពិចារណាជាពិសេស បានតាំងមាំដោយជុំវិញ ។ កាលព្រះយោគីនោះ មនសិការយ៉ាងនេះ អាការណាក្នុងបណ្ដាអាការទាំងឡាយ មានលក្ខណៈជាដើមប្រាកដជាធម្មជាតិច្បាស់ល្អ ព្រះយោគីគប្បីកាន់យកចំពោះអាការនោះៗឯង រំលងអាការដទៃចេញ ធ្វើមនសិការ ឲ្យប្រព្រឹត្តទៅដោយពាក្យជាដើមថា បឋវីធាតុ អាបោធាតុ ព្រមទាំងអាការនោះ ។ ក៏ព្រះយោគីអ្នកមនសិការយ៉ាងនេះ គប្បីធ្វើមនសិការកោសល្យឲ្យតាំងឡើងដោយអាការ ១០ ពួកនេះ គឺ តាមលំដាប់ មិនលឿនពេក មិនយឺតពេក ដោយការពារការរាយមាយ ដោយឈានកន្លងបញ្ញត្តិ ដោយរំលងចំណែកដែលមិនប្រាកដ ទៅតាមលំដាប់ ដោយលក្ខណៈ និងដោយព្រះសូត្រ ៣ សូត្រ ។

ក្នុងអាការ ១០ យ៉ាងនោះ ពាក្យថា **តាមលំដាប់** គឺ តាមលំដាប់គ្នាបានដល់ ដោយលំដាប់នៃកម្មដ្ឋាន ដែលព្រះយោគីរៀនក្នុងសម្នាក់របស់អាចារ្យក៏លំដាប់នោះបានដល់ លំដាប់ទេសនានោះឯង ។ ព្រះយោគីកាលមនសិការទៅតាម

លំដាប់យ៉ាងនេះ គប្បីមនសិការកុំលឿនពេក ។ ព្រោះថា កាលព្រះយោគាវចរមនសិការលឿនពេក ការមនសិការកម្មដ្ឋាន ក៏រមែងប្រព្រឹត្តទៅជាប់តគ្នាមិនដាច់ខ្សែឡើយ តែថា កម្មដ្ឋាននឹងមិនប្រាកដជាក់ច្បាស់ មិននាំមកនូវគុណវិសេស ។ ព្រោះដូច្នោះ គួរមនសិការកុំលឿនពេក ។ មួយវិញទៀត ព្រះយោគីគប្បីមនសិការកុំលឿនពេកយ៉ាងណា ក៏គប្បីមនសិការកុំយឺតពេក ក៏ដូច្នោះ ។ ព្រោះថា កាលព្រះយោគីមនសិការយឺតពេក កម្មដ្ឋានរមែងមិនដល់ទីបញ្ចប់បាន និងរមែងមិនជាបច្ច័យដល់ការសម្រេចគុណវិសេស ។ ក្នុងរឿងនេះបណ្ឌិតគប្បីសម្ដែងរឿងបុរសអ្នកដើរផ្លូវប្រញាប់ពេក និងយឺតពេកជាឧទាហរណ៍ចុះ ។ ពាក្យថា **ការពារភាពរាយមាយ** គឺ គប្បីហាមការដែលចិត្តលះបង់កម្មដ្ឋាន ហើយរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗខាងក្រៅ ។ ពិតហើយ កាលមានសេចក្ដីរវើរវាយទៅខាងក្រៅ ព្រះយោគីរមែងសាបសូន្យ រមែងប្រាសចាកកម្មដ្ឋាន ។ ក៏ក្នុងរឿងនេះបណ្ឌិតគប្បីសម្ដែងបុរសអ្នកដើរផ្លូវដែលមានគន្លងអាចដើរបានតែម្នាក់ ដូចផ្លូវមានរណ្ដៅជាឧទាហរណ៍ចុះ ។ ពាក្យថា **ដោយឈានកន្លងបញ្ញត្តិ** មានសេចក្ដីថា បញ្ញត្តិថា បឋវីធាតុជាដើមនេះឯណា គប្បីឈានកន្លងបញ្ញត្តិនោះចេញ ហើយតាំងចិត្តទុកក្នុងលក្ខណៈទាំងឡាយប៉ុណ្ណោះ ។

កាលព្រះយោគីលះបង់បញ្ញត្តិ ញុំាងមនសិការឲ្យប្រព្រឹត្តទៅក្នុងលក្ខណៈទាំងឡាយ មានលក្ខណៈរឹងជាដើមប៉ុណ្ណោះយ៉ាងនេះ លក្ខណៈទាំងឡាយរមែងប្រាកដជាធម្មជាតិជាក់ច្បាស់ល្អ ច្បាស់លាស់ល្អ ។ ចិត្តរបស់លោករមែងបានការសេពថ្មីក ដោយអំណាចការមនសិការរឿយៗយ៉ាងនេះ ។ រូបកាយទូទាំងរាងកាយរមែង ប្រាកដដោយគ្រាន់តែជាធាតុ គឺជារបស់សូន្យទទេ មិនមែនសត្វ មិនមែនជីវៈ

ផ្លាស់ប្តូរឥរិយាបថទៅជារឿយៗ ដោយខ្សែទាញ គឺ ចិត្ត ដូចតុក្កតាយន្ត ដែលផ្លាស់ប្តូរឥរិយាបថទៅរឿយៗដោយខ្សែយន្ត ដូច្នោះ ។ បើលោកបង្អោនមនសិការទៅខាងក្រៅខ្លះ លំដាប់នោះ សត្វទាំងឡាយ មានមនុស្ស និងតិរច្ឆានជាដើមដែលកំពុងធ្វើដំណើរទៅ រមែងលះអាការដែលជាសត្វ ប្រាកដដល់លោក ដោយគ្រាន់តែជាការប្រជុំនៃធាតុប៉ុណ្ណោះ កិរិយាដែលពួកគេធ្វើ ក៏រមែងប្រាកដជាកិរិយានៃអាយ៉ង ដែលសម្រេចដោយធាតុ ធ្វើឲ្យប្រព្រឹត្តទៅ វត្ថុមានគ្រឿងផឹក និងរបស់បរិភោគជាដើម ដែលពួកគេបរិភោគ រមែងប្រាកដដូចជាគំនរធាតុ ដែលគេដាក់ចូលទៅក្នុងគំនរធាតុដូច្នោះ ។ លំដាប់នោះចិត្តរបស់លោក ទោះបីថា បានការសេពថ្មីកហើយដោយប្រការនោះ ប្រសិនបើឡើងកាន់ភាវនាវិធីមិនបាន ដោយអំណាចនៃឧទ្ធច្ចៈ ព្រោះប្រារព្ធយកសេចក្តីព្យាយាមខ្លាំងពេកក្តី ដោយអំណាចនៃកោសជ្ជៈព្រោះមានសេចក្តីព្យាយាមធូរថយពេកក្តី , ក្នុងពេលនោះ លោកគប្បីធ្វើការប្រកបក្នុងវីរិយៈ និងសមាធិតាមន័យដែលមកហើយក្នុងព្រះសូត្រ ៣ សូត្រពួកនេះ គឺ អធិចិត្តសូត្រ អនុត្តរសីតិភាវសូត្រ ពោជ្ឈង្គសូត្របុះ ។ ព្រោះហេតុនោះ ខ្ញុំព្រះអង្គទើបពោលថា ព្រះសូត្រ ៣ សូត្រ ។ កាលព្រះយោគី មានការពេញចិត្តចំពោះសេចក្តីព្យាយាម ធ្វើមនសិការឲ្យប្រព្រឹត្តទៅក្នុងលក្ខណៈនោះៗ ឯងយ៉ាងនេះ ក្នុងពេលណាឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមប្រព្រឹត្តទៅ ជាធម្មជាតិដែលមានភាពស្មើគ្នា ហ្មត់ចត់ល្អ ក្នុងពេលនោះ អង្គឈានទាំងឡាយ មានវិតក្កជាដើម ដែលបានការឧបត្ថម្ភអំពីពលធម៌ ៧ យ៉ាង មានកម្លាំងខ្លាំងក្លា ព្រោះភាវៈឆ្ងាយចាកធម៌ទាំងឡាយដែលជាសត្រូវ មានភាពជាអ្នកមិនមានសទ្ធាជាដើម រមែងប្រាកដជាធម្មជាតិជាក់ច្បាស់ឡើង នីវរណៈទាំងឡាយ ក៏ត្រូវគ្របសង្កត់បាន ព្រម

ទាំងបាបធម៌ទាំងឡាយ ដែលតាំងនៅក្នុងចិត្តប្បាទជាមួយគ្នានឹងនីវរណធម៌នោះផង ដែរ ព្រោះជាសត្រូវដោយត្រង់របស់អង្គឈាននោះ ។ ក៏ដោយលំដាប់ភាវនាត្រឹម ប៉ុណ្ណោះ គឺ ព្រះយោគីនេះ សម្រេចឧបចារឈាន ដែលមានលក្ខណៈនៃធាតុជា អារម្មណ៍ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា “ ថា... រាំ បឋវីធាតុ អាបោធាតុជាដើម រឿយៗ ។ល។ សមាធិប្រាកដត្រឹមតែឧបចារសមាធិ រមែងកើត ឡើងដូច្នេះ ។

ក្នុងពាក្យទាំងនោះ **មត្ត**-ស័ព្ទ ( ប្រែថា ត្រឹមតែ ) ក្នុងពាក្យថា **ធាតុមត្តតោ** មានអត្ថថា ហាមវត្ថុពិសេស មានសេចក្ដីថា បុគ្គលក្រៅព្រះសាសនានេះ និង មហាជនក្នុងលោក លើកវត្ថុពិសេសជាដើមថា “ សត្វ ជីវៈ ” ដែលមិនមានពិត ឯណាទុក ក្នុងអត្ថភាពនេះ ដោយត្រឹមតែការគិតប៉ុណ្ណោះ លោកហាមវត្ថុពិសេស នោះទុក ដោយពាក្យថា **ធាតុមត្តតោ** ( ត្រឹមតែជាធាតុ )នោះ , ព្រោះហេតុនោះ ទើបលោកពោលថា ដោយមិនមែនសត្វ ដោយមិនមែនជីវៈដូច្នេះ ។ ពាក្យថា **គប្បីនឹកដល់** គឺ គប្បីនឹកបង្អោនមក ។ ពាក្យថា **គប្បីធ្វើទុកក្នុងចិត្ត** គប្បីដាក់ចិត្ត គឺគប្បីតាំងលក្ខណៈនៃធាតុទុកក្នុងចិត្ត ដោយត្រឹមតែជាធាតុ ដោយអំណាចការ ចម្រើនហើយចម្រើនទៀត ។ ពាក្យថា **គប្បីពិចារណា** គឺ គប្បីពិចារណាលក្ខណៈ នៃធាតុនោះៗឯង ដោយឡែកៗ បានដល់ គប្បីសម្លឹងឃើញដោយប្រចក្សជាប់តគ្នា ដោយចក្ខុ គឺ ញាណដែលសម្រេចព្រោះភាវនា ។

ពាក្យថា **កាលលោកព្យាយាមយ៉ាងនេះ** គឺកាលព្រះយោគីនោះប្រកបរឿយៗ នូវភាវនាយ៉ាងនេះ គឺ តាមប្រការដូចពោលមកហើយ បានដល់ កាលធ្វើសេចក្ដី ព្យាយាម ការព្យាយាម ការតស៊ូដោយប្រពៃនោះឯង ឲ្យប្រព្រឹត្តទៅដោយភាពជា

អ្នកធ្វើយ៉ាងគោរព ដោយភាពជាអ្នកធ្វើជាប់តគ្នា ។ ដោយភាពជាអ្នកសេពវត្ថុជាទីសប្បាយ , ដោយការកំណត់សមថនិមិត្ត ដោយការធ្វើពោជ្ឈង្គទាំងឡាយឲ្យប្រព្រឹត្តទៅជារឿយៗ ដោយការប្រព្រឹត្តមិនអាល័យក្នុងកាយ និងក្នុងជីវិត ដោយការដែលមិនដល់នូវការធុញទ្រាន់ក្នុងរវាងធ្វើការនាឲ្យឈានទៅមុខ មិនដាក់ចុះភាពឧស្សាហ៍ក្នុងការប្រកបរឿយៗនូវភាវនានោះ ។ ពាក្យថា **សមាធិដែលកំណត់កាន់យកបានដោយបញ្ញា ដែលពិចារណាប្រភេទនៃធាតុ** មានសេចក្ដីថា កាមាវចរ-សមាធិដែលដល់កំពូល ដែលព្រះយោគីកាន់យកបានដោយគ្រប់ចំណែក ដោយមិនលះក្នុងខាងដើម កណ្ដាល និងទីបំផុត គឺខាងចុង ដោយការនាបញ្ញា ដែលមានកិច្ចពិចារណា ត្រួតពិនិត្យ ដោយការពិចារណាសភាវលក្ខណៈនៃធាតុទាំងឡាយមានបឋវីធាតុជាដើម ដែលប្រាកដត្រឹមតែឧបចារសមាធិ ព្រោះមិនដល់ភាពជាមហគ្គតៈ រមែងកើតឡើង ។ ពាក្យថា **ឧបចារសមាធិ** គប្បីជ្រាបដោយត្រឹមតែជាស័ព្ទនិយមប្រើ ។ ពិតមែន សមាធិដែលប្រព្រឹត្តទៅជិតអប្បនា ឈ្មោះថាឧបចារសមាធិ តែថា ក្នុងធាតុកម្មដ្ឋាននេះ មិនមានអប្បនាសមាធិទេ ។ សូម្បីដូច្នោះ ក៏ពោលទុកយ៉ាងនេះថា ឧបចារសមាធិសមាធិដែលប្រព្រឹត្តទៅជិតអប្បនាក៏ព្រោះការដែលមានលក្ខណៈស្មើដូចគ្នានឹងសមាធិដូច្នោះ ( គឺ ស្មើគ្នានឹងសមាធិដែលប្រព្រឹត្តទៅជិតអប្បនាសមាធិ ) ។ សួរថា ក៏ព្រោះហេតុអ្វី ទើបក្នុងកម្មដ្ឋាននេះ មិនមានអប្បនា ? ឆ្លើយថា លោកអាចារ្យពោលដល់ហេតុក្នុងការដែលមិនមានអប្បនានោះថា ព្រោះការដែលមានសភាវធម៌ជាអារម្មណ៍ដូច្នេះ អធិប្បាយនេះ លោកពោលទុកក្នុងមរណានុស្សតិនិទ្ទេសហើយផងដែរថា កាលក្នុងសភាវធម៌មិនមានការនាវិសេស ព្រោះអារម្មណ៍ដែលជាសភាវធម៌នោះ ជារបស់ជ្រាលជ្រៅ

អប្បនាក៏រមែងមិនកើតឡើង , ចំណែកលោកុត្តរឈាន មានការដល់អប្បនាបាន ក្នុងអារម្មណ៍ ( សូម្បីថាជាសភាវធម៌ ) ក៏ដោយទាក់ទងនឹងលំដាប់នៃការចម្រើន វិសុទ្ធិ , អរូបជ្ឈានទី ២ ទី ៤ មានការដល់អប្បនាបានក្នុងអារម្មណ៍សូម្បីថា ជាសភាវធម៌ ក៏ទាក់ទងនឹងភាពជាភាវនាឈានកន្លងអារម្មណ៍ ( របស់ឈានដើមៗ ) ដូច្នេះ ។

លោកអាចារ្យ កាលសម្តែងធាតុកម្មដ្ឋានដោយតាមរយៈការកំណត់កាន់យកធាតុ ៤ ក្នុងរូបកាយ ដោយមិនមានការប៉ែកគ្នាយ៉ាងនេះហើយ ឥឡូវនេះ ប្រាថ្នាសម្តែងវិធីមនសិការទៀត ដែលមកហើយក្នុងព្រះសូត្រ សូម្បីដោយសង្ខេប តាមរយៈការចែកកោដ្ឋាស ៤ យ៉ាង មានឆ្អឹងជាដើម ក្នុងរូបកាយនោះ ទើបផ្តើមពាក្យថា **អដ្ឋ វាំ បទ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ មានការភ្ជាប់សេចក្តីបានថា **យេ ឥមេ ចត្តារោ កោដ្ឋាសា វុត្តា** ( កោដ្ឋាស ៤ ពួកនេះឯណា ដែលលោកពោលទុក ) ។ ប្រៀបដូចជាទីអាស្រ័យឈើស្លួតវល្លិស្មៅ និងដីឥដ្ឋផ្សេងៗគ្នា ក៏ព្រោះការសាងឡើង តាំងនៅតាមសមគួរដល់បច្ច័យ ទើបមានសមញ្ញាថា ផ្ទះឡើងមក ឈ្មោះថា ផ្ទះមិនមាននៅក្នុងវត្ថុពួកនោះយ៉ាងណា , ព្រោះអាស្រ័យ ឆ្អឹង សរសៃ សាច់ និងស្បែក មានប្រការផ្សេងៗ ព្រោះការសាងឡើង ប្រព្រឹត្តតាមសមគួរដល់បច្ច័យ ទើបមានសមញ្ញាថា សរីរៈឡើងមក , អត្តា ជីវៈអ្វីៗ មិនមាននៅក្នុងកោដ្ឋាសទាំងនេះក៏ដូច្នោះ ។ ព្រះសារីបុត្តត្ថេរសម្តែងថា គ្រាន់តែជាអាកាសដែលកោដ្ឋាសទាំងនោះព័ទ្ធជុំវិញសុទ្ធៗ ។ លោកអាចារ្យកាលនឹងបើកបង្ហាញដល់សេចក្តីនេះថា ទេសនាជាទេសនាដែលសម្តែងដល់ភាពជារបស់សូន្យទទេចាកសត្វយ៉ាងដូច្នេះ ទើបពោលថា ដើម្បីសម្តែងភាវៈដែលមហាភូត ៤ មិនមែនសត្វដូច្នេះ

ជាដើម ។ ក្នុងពាក្យរបស់ព្រះសារីបុត្តនោះ ពាក្យថា **អាស្រ័យឆ្អឹង** គឺ អាស្រ័យ ឆ្អឹងដែលមានចំនួន ៣០០ កំណាត់ ដែលតាំងនៅអាស្រ័យគ្នាឡើងទៅតាម លំដាប់ មានឆ្អឹងកែងជើងជាដើម ។ ពាក្យថា **សរសៃ** បានដល់ សរសៃមាន ប្រភេទ ៩០០ សរសៃ ដែលតាំងនៅចងគ្រោងឆ្អឹងនោះៗ ឯងទុក ។ ពាក្យថា **សាច់** បានដល់ សាច់ ៩០០ ដុំ ដែលតាំងនៅលាបបូកគ្រឿងឆ្អឹងនោះៗឯងទុក ។ ពាក្យថា **ស្បែក** បានដល់ អាស្រ័យ គឺ កាន់យកស្បែកក្រាស់ៗ ដែលតាំងនៅ ហ៊ុមសរីរៈទាំងអស់ទុក ដែលត្រូវបិទបាំងទុកដោយធវី ជាទីមកនៃរោគបែកស្រកា និងរោគកមរមាស់ជាដើម ។ **ច-**ស័ព្ទក្នុងបទទាំងពួង មានអត្ថន័យថា រួបរួម ។ ពាក្យថា **អាកាសព័ទ្ធជុំវិញ** បានដល់ ដូចជាអាកាសព័ទ្ធជុំវិញវត្ថុ មានឈើស្ងួត ជាដើមពួកនោះ គឺ ឈើស្ងួតដែលគេតាំងទុកដោយទាក់ទងជាគ្រោងជញ្ជាំងជាដើម វល្លិដែលចងឈើស្ងួតនោះៗឯង , ដីឥដ្ឋដែលបូកលាប ស្មៅដែលប្រក់ទាំងខាងក្នុង និងខាងក្រៅ រមែងដល់នូវការហៅថា ជាផ្ទះនោះឯង គឺ រមែងបានបញ្ញត្តិថា **ផ្ទះ** យ៉ាងណា , អាកាស ព័ទ្ធជុំវិញអវយវៈទាំងឡាយ មានឆ្អឹងជាដើម តាមដែល ពោលមកហើយ ទាំងខាងក្នុង និងខាងក្រៅ អាស្រ័យអវយវៈ មានឆ្អឹងជាដើម នោះៗឯង ក៏រមែងដល់នូវការហៅរូបនោះឯងថា គឺរមែងបានវោហារថា **រាងកាយ** ក៏ដូច្នោះ ។ មយ៉ាងទៀត ប្រៀបដូចជាក្នុងផ្លូវលោក មនុស្សទាំងឡាយហៅថា **ផ្ទះ** ដែលដល់នូវការហៅថា **ផ្ទះ** ព្រោះអាស្រ័យវត្ថុទាំងឡាយ មានឈើស្ងួតជាដើម ហៅថា ផ្ទះក្សត្រ ផ្ទះព្រាហ្មណ៍ដូច្នេះ យ៉ាងណា សូម្បីសរីរៈនេះ ក៏រមែងហៅថា សរីរក្សត្រ សរីរៈព្រាហ្មណ៍យ៉ាងនេះ ក៏ដូច្នោះ អធិប្បាយថា សត្វណាៗក្តី ជីវៈ ណាៗ ក្តី មិនមាននៅក្នុងសរីរៈនេះទេ ។

បទថា **តេ** ប្រកបសេចក្ដីថា ចែកហើយចែកទៀតនូវកោដ្ឋាស ៤ យ៉ាងពួកនោះ ។ ពាក្យថា **ដែលត្រាច់ទៅក្នុងចន្លោះកោដ្ឋាសនោះៗ** មានសេចក្ដីថា ប្រើដៃពោលគឺ ញាណជ្រៀតចូលទៅតាមចន្លោះនៃកោដ្ឋាសពួកនោះ គឺ ចន្លោះនៃឆ្អឹងនិងសរសៃ នៃសរសៃនិងសាច់ នៃសាច់និងស្បែក ។ ពាក្យថា **ចែក** គឺ ជ្រែកចូលទៅរឿយៗ , ន័យម្យ៉ាងទៀត ពាក្យថា **ចែក** បានដល់ ប្រើដៃ គឺ ញាណត្រាច់ទៅក្នុងចន្លោះនៃកោដ្ឋាសទាំងឡាយមានឆ្អឹងជាដើម ធ្វើការចែកកោដ្ឋាសមួយៗឲ្យដាច់ពីគ្នា ។ ពាក្យថា **បណ្ដាកោដ្ឋាសពួកនេះ** គឺ ក្នុងបណ្ដាកោដ្ឋាស ៤ មានឆ្អឹងជាដើមតាមដែលបានពោលហើយ ដែលបានចែក ធ្វើរូបកាយរបស់ខ្លួនទាំងអស់ឲ្យទៅជា ៤ ចំណែក ។ ពាក្យថា **តាមន័យមុននោះឯង** គឺ តាមន័យដែលបានពោលហើយក្នុងពេលមុន ដោយពាក្យថា ភាវៈរឹង ឬភាវៈគ្រោតគ្រាត ក្នុងកាយនេះឯណាដូច្នេះជាដើមនោះឯង ។ ក្នុងសេចក្ដីនេះ មានវិធីចម្រើនដែលគួរពោលដល់ បណ្ឌិតគប្បីជ្រាបវិធីចម្រើននោះ ដោយអាការដែលបានពោលទុកក្នុងន័យតទៅចុះ ។

ក៏ក្នុងន័យដែលពោលមកហើយដោយពិស្ដារ មានការត្រូវនាំបទថា **ចតុធាតុវវដ្ឋានេ** ចូលមកប្រកបទុក ។ សេចក្ដីថា បណ្ឌិតគប្បីជ្រាបដោយភាវនាន័យយ៉ាងនេះ គឺដោយអាការដែលនឹងពោលដល់ក្នុងពេលឥឡូវនេះ ។ សួរថា ព្រោះហេតុអ្វី ទើបលោកពោលថា រៀនធាតុដោយពិស្ដារ ដោយអាការ ៤២ ដូច្នេះធាតុដែលមានត្រឹមតែ ៣២ អាការខាងដើម មិនមានដោយពិតហើយមិនមែនឬ ? ឆ្លើយថា ការដែលពោលនេះមិនបានចាត់ជាការខុសទេ ព្រោះព្រះយោគីអាចរៀនយកធាតុទាំងឡាយបាន ក៏ដោយអាស្រ័យវត្ថុជាប្រធាននោះឯង ។ ពាក្យថា **ក្នុងសេនាសនៈមានប្រការដូចបានពោលមកហើយ** គឺ មានប្រការដូចពោលមកហើយ

ដោយពាក្យថា ដល់ព្រមដោយអង្គ ៥ គឺជាសេនាសនៈដែលមិនឆ្ងាយពីគោចរគ្រាមពេក មិនជិតពេកជាដើមដូច្នេះ ។ ពាក្យថា **ធ្វើកិច្ចទាំងពួងស្រេចហើយ** មានសេចក្តីថា ព្រះយោគី ឈ្មោះថា ជាអ្នកធ្វើកិច្ចទាំងពួងស្រេចហើយ ព្រោះអត្ថថា បានធ្វើកិច្ចទាំងពួង មានការលះបលិពោធជាដើមស្រេចហើយ ដោយពាក្យនោះលោកសម្តែងថា ក៏កិច្ចមានការជម្រះសីល ឲ្យហ្មត់ចត់ជាដើមរបស់ព្រះយោគីនេះ បានសម្រេចរួចហើយ មុនការរៀនយកកម្មដ្ឋាននោះ ។ ពាក្យថា **ដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងសម្ភារៈ** មានសេចក្តីថា ឈ្មោះថា **សម្ភារៈ** ព្រោះអត្ថថា ជាគ្រឿងប្រកបពុទ្ធិវោហារ ( បញ្ញត្តិជាហេតុឲ្យដឹង ) នោះក៏បានដល់និមិត្ត គឺវត្ថុដែលជាហេតុ ។ និមិត្តនេះ តើដូចម្តេច គឺបឋវីធាតុជាដើម ពិតមែនពុទ្ធិវោហារថា ( បឋវី ) ក្នុងអាការ ២០ មានសក់ជាដើម ចាត់ថាមានបឋវីធាតុជានិមិត្ត ព្រោះប្រព្រឹត្តទៅអាស្រ័យភាពរឹង ។ ព្រោះដូច្នោះ ក្នុងបឋវីធាតុនោះទើបមានឈ្មោះថា បឋវីសម្ភារៈ ។ កោដ្ឋាសទាំងឡាយ មានសក់ជាដើម ឈ្មោះថា សសម្ភារៈ ព្រោះអត្ថថា ប្រព្រឹត្តទៅនឹងសម្ភារៈ ព្រោះភាពដែលមានបឋវីធាតុដែលមានសេចក្តីពិសេសនោះ ។ សូម្បីក្នុងកោដ្ឋាសទាំងឡាយ មានកោដ្ឋាសនៃអាបោធាតុជាដើមក៏មានន័យនេះដែរ ។ សង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅជាមួយនឹងសម្ភារៈ ឈ្មោះថា **សសម្ភារសង្ខេប** ប្រកបសេចក្តីថា គប្បីចម្រើនដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តនឹងសម្ភារៈនោះ ។ កាលកំណត់ធាតុ ដោយការកំណត់យកធាតុ ៤ មានបឋវីធាតុជាដើម ក្នុងកោដ្ឋាស ២០ ក្នុងកោដ្ឋាស ១២ ក្នុងកោដ្ឋាស ៤ និងក្នុងកោដ្ឋាស ៦ តាមលំដាប់ដោយសង្ខេប ឈ្មោះថា ការចម្រើនដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងសម្ភារៈ ។ ព្រោះហេតុនោះ ទើប

លោកពោលថា កិច្ចក្នុងសាសនានេះ រមែងកំណត់អាការរឹង ក្នុងកោដ្ឋាស ២០ ដូច្នេះជាដើម ។

ពាក្យថា **ដោយការចែកកោដ្ឋាសដែលប្រព្រឹត្តទៅនឹងសម្ភារៈ** បានដល់ដោយការចែកកោដ្ឋាសទាំងឡាយ មានសក់ជាដើម ដែលប្រព្រឹត្តទៅនឹងសម្ភារៈ មានសេចក្តីថា ជាការកំណត់ដោយភាពជាបឋវីធាតុ គឺការចែក មិនកាន់យកកោដ្ឋាស ២០ មានសក់ជាដើមព្រមគ្នា ដូចនៅក្នុងពេលមុនទេ ។ សូម្បីក្នុងកោដ្ឋាសនៃអាបោធាតុជាដើម ក៏មានន័យដូច្នេះ ។ ពាក្យថា **ដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈ** មានសេចក្តីថា ធម្មជាតិឈ្មោះថា **លក្ខណំ ( លក្ខណៈ ) ព្រោះអត្ថថា ជាគ្រឿងកំណត់** បានដល់ សភាវៈនៃធម៌ទាំងឡាយ ក្នុងទីនេះបានដល់ ភាវៈដែលរឹងជាដើម ។ ព្រោះដូច្នោះ ឈ្មោះថា **សលក្ខណា** ( ប្រព្រឹត្តទៅនឹងលក្ខណៈ ) ក៏ព្រោះអត្ថថា ប្រព្រឹត្តទៅនឹងលក្ខណៈទាំងឡាយ ព្រោះប្រកបដោយលក្ខណៈ មានលក្ខណៈរឹងជាដើម , បានដល់ អាការ ៤២ មានសក់ជាដើម , បានដល់ ដោយសង្ខេបនៃកោដ្ឋាស ( ឬ អាការ ) ដែលប្រព្រឹត្តនឹងលក្ខណៈពួកនោះ ។ ប្រការនេះមានការអធិប្បាយថា ការចម្រើនដោយកាន់យកកោដ្ឋាស ២០ មានសក់ជាដើមព្រមគ្នា កំណត់លក្ខណៈទាំង ៤ យ៉ាង មានភាវៈរឹងជាដើម ក្នុងកោដ្ឋាសទាំងនោះ ឈ្មោះថា ការចម្រើនដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈ ។ សូម្បីក្នុងកោដ្ឋាសនៃអាបោធាតុជាដើម ក៏មានន័យដូច្នេះ ។ ពាក្យថា **ដោយការចែកកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈ** គឺការចែកកោដ្ឋាសទាំងឡាយ មានសក់ជាដើម ដែលមានលក្ខណៈជាដើម ដោយលក្ខណៈរឹងជាដើម មានសេចក្តីថា ជាការចម្រើនដោយអំណាចការកំណត់លក្ខណៈ

ទាំងឡាយក្នុងអាការ ៤២ មានសក់ជាដើមក្នុង មួយអាការៗ ៤ លក្ខណៈ មានភាវៈរឹងជាដើម ។

លោកអាចារ្យ ប្រាថ្នាសម្តែងវិភាវនាន័យ ដែលបានលើកឡើងមកសម្តែងដោយអាការ ៤ តាមប្រការដូចពោលមកនេះ ទើបផ្តើមពាក្យថា យ៉ាងដូចម្តេចទើបឈ្មោះថា រមែងចម្រើនដោយសង្ខេបនៃកោដ្ឋាស ដែលប្រព្រឹត្តទៅនឹងសម្ភារៈដូច្នេះជាដើម ។ ម្យ៉ាងទៀត ក្នុងរឿងនេះ ប្រៀបដូចជាបុគ្គលអ្នកមានបញ្ញាចាស់ក្លាក៏នៅមានការចាត់ជាពីរជំពូក ដោយទាក់ទងនឹងភាពជាអ្នកមានឥន្ទ្រិយចាស់ក្លានិងមានឥន្ទ្រិយទន់ខ្ចី ព្រោះភាវៈដែលចាស់ក្លា ក៏នៅមានភាពខ្ពង់ខ្ពស់ និងភាពអន់ថយ ។ ក្នុងបុគ្គលពីរជំពូកនោះ ន័យមុនលោកពោលទុកដោយសង្ខេប ដោយទាក់ទងនឹងបុគ្គលអ្នកមានឥន្ទ្រិយចាស់ក្លា , ន័យទី ២ លោកពោលទុក ទាក់ទងនឹងបុគ្គលអ្នកមានឥន្ទ្រិយទន់ខ្ចី យ៉ាងណា សូម្បីបុគ្គលដែលមានបញ្ញា មិនចាស់ក្លាក៏មានការចាត់ជាពីរជំពូកបានដូច្នោះដែរ ។ ក្នុងបុគ្គលទាំងនោះ គប្បីជ្រាបថា បុគ្គលណាជាអ្នកមានឥន្ទ្រិយចាស់ក្លា លោកសម្តែងន័យក្នុងការចម្រើន ដោយសង្ខេបនូវកោដ្ឋាសដែលប្រព្រឹតទៅនឹងសម្ភារៈ និងដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈ ក៏ដោយអំណាចនៃបុគ្គលនោះ ។ រីឯ បុគ្គលណា ជាអ្នកមានឥន្ទ្រិយមិនទាន់ចាស់ក្លា លោកសម្តែងន័យក្នុងការចម្រើន ដោយការចែកកោដ្ឋាសដែលប្រព្រឹត្តទៅនឹងសម្ភារៈ និងដោយចែកកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈទុក ក៏ដោយអំណាចនៃបុគ្គលនោះ ។ កាលព្រះយោគាវចរនោះ កំណត់ទៅតាមប្រការដូចពោលមកនេះប៉ុណ្ណោះ ធាតុទាំងឡាយទើបប្រាកដច្បាស់ ព្រោះការដែលបានកំណត់កាន់យកធាតុទាំងឡាយបាន យ៉ាងមានសេចក្តីពិសេស ។ ចំណែកក្នុងទីនេះ គប្បី

ជ្រាបវិធីចម្រើនតាមន័យដែលបានពោលមកហើយក្នុងខាងដើមនោះចុះ ។

ដោយពាក្យថា កាលភិក្ខុរូបណា លោកពោលសំដៅយកបុគ្គលអ្នកមានឥន្ទ្រិយមិនទាន់ចាស់ក្លា ។ ពាក្យថា **ចម្រើនទៅតាមប្រការដូចពោលមកនេះ** គឺ ចម្រើនទៅដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងសម្ភារៈ ។

ព្រះយោគីរមែងជាអ្នកឆ្លាត ព្រោះរៀនយកដោយវិធីណា វិធីនោះមាន ៧ យ៉ាង ហៅថា **ឧគ្គហកោសល** ឬថា ញាណដែលកើតឡើងព្រោះការរៀននោះឈ្មោះថា **ឧគ្គហកោសល** ។ សូម្បីមនសិការកោសល បណ្ឌិតក៏គប្បីជ្រាបតាមន័យដូចគ្នានេះចុះ ។ ពាក្យថា **ក្នុងអាការ ៣២** គឺ ក្នុងកោដ្ឋាស ៣២ យ៉ាង មានសក់ជាដើម ដែលបានកំណត់កាន់យក ដោយអំណាចធាតុមនសិការ ។ ម្យ៉ាងទៀត លោកពោលពាក្យថា ( ក្នុងអាការ ៣២ ) នេះទុកក្នុងកោដ្ឋាសនៃតេជោ និងវាយោ មិនមានការកំណត់តាមរយៈពណ៌របស់កោដ្ឋាសជាដើម ។ ពាក្យថា **ការធ្វើវិធីការដែលលោកពោលទុកក្នុងកាយគតាសតិកម្មដ្ឋាននោះទាំងអស់** បានដល់ ធ្វើ គឺ ធ្វើវិធីការនៃការនាទាំងអស់ ដែលមកហើយចាប់តាំងពីការផ្តើមមាតិកាសម្តែងឧគ្គហកោសល ដែលលោកពោលទុកដោយពាក្យថា ផ្លូវវាចា ផ្លូវចិត្តជាដើម រហូតដល់បទថា ដោយអំណាចការរំលងទៅតាមលំដាប់ជាដើមឲ្យដល់ព្រម ពាក្យថា **ដោយអំណាចនៃពណ៌ជាដើម** គឺ ដោយអំណាចការកំណត់ដោយពណ៌ សណ្ឋាន ទិស និងឱកាស ។ ការមនសិការដោយអំណាចនៃពណ៌ជាដើមនេះ ជាចំណែកខាងដើម ដែលជាសាធារណៈដល់ការមនសិការពណ៌ ជាបដិកូលនៃធាតុទាំងឡាយ ព្រោះហេតុនោះ លោកអាចារ្យប្រាថ្នាសម្តែងការមនសិការធាតុដែលចែកចេញហើយនោះឯង ទើបពោលថា ក្នុងពេលចុងក្រោយ គប្បីធ្វើមនសិការឲ្យប្រព្រឹត្តទៅយ៉ាង

នេះដូច្នេះ ។

ពាក្យថា **ធម៌ទាំងឡាយនេះប្រាសចាកការគិតដល់ និងការពិចារណាដល់គ្នានិងគ្នា** មានសេចក្ដីថា ធម៌ដែលអាស្រ័យមហាភូតទាំងឡាយ ដែលត្រូវហៅយ៉ាងនេះថា ស្បែកហ៊ុមស្រោបលលាដ៏ក្បាល សក់ជារបស់សូន្យទទេចាកការគិត និងការពិចារណាដល់គ្នានិងគ្នាយ៉ាងនេះថា សក់កើតពីលើយើង ពួកយើងកើតនៅលើស្បែកហ៊ុមស្រោបលលាដ៏ក្បាលនេះ ដូច្នេះ ។ គប្បីឃើញថា ដោយពាក្យនេះលោកសម្ដែងត្រឹមតែជាធាតុ ព្រោះមិនមានសេចក្ដីព្យាយាមនៃហេតុ និងផល , ម្យ៉ាងទៀត ដោយពាក្យនោះ ត្រូវបានលោកសម្ដែងថា សូម្បីការគិតដល់ និងការពិចារណាក៏មិនមានសេចក្ដីព្យាយាមយ៉ាងនេះដូចគ្នា , ការពិតថា ធម្មជាតិពួកនោះ និងហេតុទាំងឡាយនៃធម្មជាតិពួកនោះ មិនមែនថា ល្មមគិតបាន និងពិចារណាបានដោយប្រការនោះៗ ហើយក៏កើតឡើង ឬ ដល់ភាពជាបច្ច័យទេ ។ ស័ព្ទថា **ឥតិ** ( តាមប្រការដូចពោលមកនេះ ) ជាពាក្យបញ្ជាក់ដល់ប្រការដែលពោលមកហើយ ។ ពាក្យថា **មិនមានចេតនា** គឺជាធម៌ដែលមិនមានចេតនា ឬថា ជាធម៌ដែលប្រាសចាកចេតនា ។ ពាក្យថា **ជាអព្យាកត** គឺទាក់ទងក្នុងអព្យាកតធម៌ ។ ពាក្យថា **របស់សូន្យទទេ** គឺជារបស់សូន្យទទេចាកអត្តា ។ ព្រោះហេតុនោះៗឯង ទើបឈ្មោះថា **និស្សត្ត** ( មិនមែនសត្វ ) ។ ឈ្មោះថា ជារបស់រឹង ព្រោះមានភាពរឹងជាលក្ខណៈជាដើម ។ ព្រោះហេតុនោះៗឯង ទើបឈ្មោះថា ជាបឋវីធាតុ , ភ្ជាប់សេចក្ដីថា **ឯវំ មនសិការោ បវត្តេតព្វោ** - គប្បីមនសិការឲ្យប្រព្រឹត្តទៅយ៉ាងនេះ ។ គប្បីធ្វើមនសិការឲ្យប្រព្រឹត្តទៅយ៉ាងនេះ ក្នុងកោដ្ឋាសទាំងពួង ។

ក្នុងពាក្យថា **នៅក្នុងផ្ទះស្ងាត់** នេះលោកកាន់យកកាយថា ជាផ្ទះស្ងាត់ ដើម្បីសម្តែងភាពប្រាសចាកអត្តា អ្នកសោយ ( អ្នកចូលទៅអាស្រ័យនៅ ) ដោយបរមត្ថ ។

ពាក្យថា **មធុកដ្ឋិកេ** ប្រែថា គ្រាប់ទន្សេ ។ លោកបំណាងយកថ្នក់ដើម្បីទ្រទ្រង់សសរផ្ទះថា **ហលុមហិន** រណ្តៅគ្រឹះ ។

មានការកាន់យកស្បែកគោស្រស់ ដើម្បីសម្តែងដល់ភាពដែលស្បែកគោស្រស់នេះ ក៏ដូចគ្នានឹងភាពដែលមានក្លិនស្អុយជាដើម ។

មានការកាន់យកដីឥដ្ឋដុំធំ ព្រោះភាពដែលបន្ទះសាច់ទាំងឡាយដោយច្រើនជាបន្ទះក្រាស់ៗ ។

ពាក្យថា **ក្នុងឈើគ្រោងជញ្ជាំង** បានដល់ ក្នុងឈើដែលជាគ្រឿងជញ្ជាំងនៃកុដិដែលមានជញ្ជាំងឈើ ។

លោកអាចារ្យពោលថា ឆ្អឹងកែងជើង តាំងទ្រឆ្អឹង-កជើង ដូច្នេះជាដើមហើយក៏នៅពោលទៀតថា ឆ្អឹងក្បាលតាំងនៅលើឆ្អឹង-ក ដូច្នេះជាដើមទៀត ដើម្បីសម្តែងថា សូម្បីភាវៈមានឆ្អឹង-កជើងជាដើម គប្បីត្រូវទ្រ ក៏ត្រូវសម្រេចដែរ ដោយមិនត្រូវនឹកដល់ ដូចភាវៈដែលឆ្អឹងកែងជើងជាដើមជាទីរង ឬទ្រ ។

ពាក្យថា **ក្នុងលំពង់ផ្តៅដែលគេទុកស្បៀមជាដើម** គឺ ក្នុងលំពង់ផ្តៅដែលពោលដោយភ្លើង ។

គ្រោងឆ្អឹងទ្រូង លោកហៅថា ឆ្អឹងទ្រូង ព្រោះដូចបន្ទោះទ្រុង។ ដើម្បីសម្តែងឆ្អឹងទ្រូងនោះជារបស់មិនមាំទាំ ទើបលោកកាន់យក បន្ទោះទ្រុងសង្រែកចាស់ៗ ធ្វើជាឧទាហរណ៍ ។

បទថា **មយកមំសបិណ្ឌេ** ប្រែថា ក្នុងដុំសាច់មួយគូ ។

ដោយសេចក្តីថា **វាវ** មានពណ៌ស ទើបលោកពោលដល់សំពត់ចាស់ ទុកដោយភាពជាឧទាហរណ៍ថា ក្នុងសាច់ដែលគេប្រើសំពត់ចាស់ខ្ចប់ទុកដូច្នេះ ។ ក្នុងពាក្យថា តម្រងបស្សាវៈ បេះដូង និងសាច់ក្នុងសរីរៈទាំងអស់រមែងមិនដឹង...... ដូច្នោះដូចគ្នានេះ គប្បីប្រកបសេចក្តីថា តម្រងបស្សាវៈ និងបេះដូង រមែងមិនដឹងថា ពួកយើងត្រូវវាវមិនប្រាកដ បិទទុក និងសាច់ក្នុងសរីរៈទាំងអស់ក៏មិនដឹងថា យើងត្រូវវាវមិនប្រាកដ បិទទុកដូច្នេះ ។

ពាក្យថា **ពាក់ខាងលើនៃជង្រុកស្រូវ** គឺ ផ្នែកខាងលើ ក្នុងជង្រុកស្រូវ ។

ពាក្យថា **ក្នុងរវាងដោះទាំងពីរ** គឺត្រង់កណ្តាលបរិវេណដោះទាំងពីរ , តែគប្បីជ្រាបបរិវេណដោះ ទាក់ទងក្នុងខាងក្នុង ។

ពាក្យថា **ចន្លោយពោះវៀនធំ ២១ ផ្នត់** គឺបរិវេណពោះវៀនធំ ដែលបត់ជា ២១ កន្លែង ។

លោកសំដៅយកអាហារដែលបរិភោគហើយ ដែលតាំងនៅក្នុងក្រពះអាហារថា **ឧទរិយំ** ( អាហារថ្មី ) ព្រោះហេតុនោះ ទើបលោកពោលថា **អាហារថ្មី** បានដល់ របស់បរិភោគ របស់ផឹក របស់ទំពាស៊ី និងរបស់លិទ្ធភក្សដែលតាំងនៅក្នុងពោះ ដូច្នេះ ។

ទឹកប្រមាត់មិននៅក្នុងស្រោម ជារបស់ប្រព្រឹត្តទៅទាក់ទង និងកម្មជរូប ដូចគ្នានឹងលោហិតដែលហូរជ្រាបទៅ និងដូចគ្នានឹងចំហាយក្តៅក្នុងរាងកាយ ព្រោះហេតុនោះ ទើបលោកពោលថា ទឹកប្រមាត់មិននៅក្នុងស្រោម ជារបស់ជាប់នៅនឹងជីវិតិន្ទ្រិយជ្រួតជ្រាបទូទៅទាំងសរីរៈ ។ ដោយពាក្យថា **ជាប់នៅនឹង** គប្បីឃើញថា

លោកសម្តែងសេចក្តីដែលទឹកប្រមាត់មិននៅក្នុងស្រោមនេះ មានបាន កាលមានជីវិតិន្ទ្រិយ មិនមែនសម្តែងដល់ភាពជារបស់កើតអំពីកម្មតែម្យ៉ាង ដូចជាជីវិតិន្ទ្រិយទេ , ពាក្យថា **ក្នុងស្រោមទឹកប្រមាត់** គឺ ក្នុងថង់ទឹកប្រមាត់ដែលដូចគ្នានឹងស្រោមននោងព្រៃធំ ។ ពាក្យថា **ជាវត្ថុរាវ** គឺជាទឹក ។

ស្ថានទីចោលវត្ថុទាំងឡាយ មានទឹកស្អុយ និងមន្ទិលគភ៌ជាដើម ឈ្មោះថា អណ្តូងទឹកជ្រាំ ( ចន្ទនិកា ) បានដល់ ក្នុងថ្លុកទឹកជ្រាំនោះ ។ លោកអាចារ្យមានសេចក្តីប្រាថ្នាថា ទីអាស្រ័យនៃខ្ទុះ មិនមែនរបស់សាធារណៈដល់បុគ្គលគ្រប់ជំពូកទេ ព្រោះអធិប្បាយថា មានដល់បុគ្គលអ្នកមានបញ្ហាខ្យាយពួកខ្លះប៉ុណ្ណោះ ដូច្នេះ ទើបពោលថា ខ្ទុះ ( មិនមានឱកាសទីអាស្រ័យជាប្រចាំទេ ) ដូច្នេះ ។

ពាក្យថា **ដូចគ្នានឹងទឹកប្រមាត់** គឺដូចគ្នានឹងទឹកប្រមាត់មិននៅក្នុងស្រោម ។ ពាក្យថា **ទូទាំងសរីរៈ** គឺគ្រប់ចំណែកនៃសរីរៈដែលជាប់នៅជាមួយនឹងជីវិតិន្ទ្រិយ ។ ពាក្យថា **ធ្វើតម្រងបស្សាវៈ បេះដូង ថ្លើម និងសួតឲ្យសើមនេះ** គប្បីឃើញថា ធ្វើថ្លើមឲ្យសើម ដោយការធ្វើចំណែកខាងក្រោមឲ្យពេញ និងធ្វើអវយវៈដទៃឲ្យសើម ដោយការជ្រាបសន្សឹមៗ ទៅលើអវយវៈទាំងនោះ ។ ពាក្យថា **ធ្វើដុំដី ដុំគ្រួសជាដើម ខាងក្រោមឲ្យទទឹក** គប្បីឃើញថា ជាពាក្យប្រៀបធៀប ដើម្បីសម្តែងភាពជាវត្ថុអ្នកធ្វើឲ្យសើម និងវត្ថុដែលត្រូវធ្វើឲ្យសើមស្មើគ្នា ដូចគ្នា ដោយមិនមានសេចក្តីព្យាយាម មិនមែនដើម្បីសម្តែងសេចក្តីដូចគ្នាដោយទីតាំង។ ពិតមែនភាវៈដែលលោហិតខាប់ តាំងនៅខាងក្រោមនៃអវយវៈទាំងឡាយពួកខ្លះ ដែលអាចធ្វើឲ្យសើម និងខាងលើអវយវៈពួកខ្លះ លោកសម្តែងទុកក្នុងកាយគតាសតិហើយ។ គប្បីជ្រាបពាក្យប្រកបសេចក្តីយ៉ាងនេះថា ទីតាំងត្រង់ផ្នែកខាងក្រោមនៃថ្លើម រមែង

មិនដឹងថា មានលោហិតតាំងនៅក្នុងយើង អវយវៈទាំងឡាយ មានថ្ងៃមជាដើមក៏ មិនដឹងថា លោហិតធ្វើពួកយើងឲ្យសើម ។

ពាក្យថា **ខ្លាញ់ខាប់** គឺខ្លាញ់ដែលដល់ភាពជារបស់ខាប់ គឺភាពជារបស់ដុំ ។ ប្រកបសេចក្ដីថា សាច់ក្នុងសរីរៈទាំងអស់ , ពាក្យថា **សាច់ក្នុងសរីរៈទាំងអស់នោះ** លោកពោលយកសរីរៈរបស់មនុស្សធាត់ ។ សូម្បីខ្លាញ់ខាប់ មានភាពជាវត្ថុខាប់ គឺភាពជាដុំ តែក៏មិនមានភាពរឹងដូចជាសាច់ ព្រោះហេតុនោះ ទើបលោកពោលថា ជាវត្ថុខន់ ដូច្នេះ ព្រោះហេតុនោះឯង ខ្លាញ់ខាប់នេះ ទើបមានភាពជាកោដ្ឋាសនៃអាបោធាតុ ។

ពាក្យថា **ក្នុងប្រឡង់គ្រាប់ត្នោតខ្ចីដែលពេញទៅដោយទឹក** លោកពោលសំដៅយកប្រហោងក្នុងនៃផ្លែត្នោតដែលមិនទាន់ទុំល្អ មានទឹក ត្រូវកាត់ក្បាល ។

គប្បីឃើញថា លោកអាចារ្យបើកបង្ហាញដល់ភាពដែលខ្លាញ់រាវ មានភាពដូចគ្នានឹងភាវៈដែលមិនមានសេចក្ដីព្យាយាមដោយឡោះមុខ និងជ្រួតជ្រាបទៅក្នុងទីទទួលរបស់ខ្លួន ព្រោះហេតុនោះ ទើបបានសម្ដែងរឿងខ្លាញ់ដែលនៅលើបាយក្ដាំងទុក ។ ពាក្យថា **បច្ច័យដែលធ្វើឲ្យទឹកមាត់ស្រៀវឡើង** បានដល់ របស់ដែលមានរសហឹរ ជូរហឹរ និងផ្អែមជាដើម ។

បណ្ឌិតគប្បីប្រែត្រឡប់ការចែកប្រកបពាក្យនិយាយថា ព្រះយោគីកាលធ្វើមនសិការឲ្យប្រព្រឹត្តទៅក្នុងកោដ្ឋាសទាំងឡាយ មានសក់ទាំងឡាយហើយ ក៏គប្បីធ្វើមនសិការឲ្យប្រព្រឹត្តទៅក្នុងកោដ្ឋាសនៃតេជោ ។ ពាក្យថា **វត្ថុដែលជាហេតុធ្វើឲ្យរាងកាយក្ដៅ** គឺតេជោដែលមានកិច្ចធ្វើឲ្យរាងកាយក្ដៅ ជាហេតុធ្វើឲ្យរាងកាយក្ដៅ ។ ពាក្យថា **តេជោ** លោកកំណត់យកអាការដែលគួរកំណត់កាន់យកនៃតេជោ

នោះៗឯង ។ សូម្បីក្នុងពាក្យថា វត្ថុដែលជាហេតុធ្វើឲ្យរាងកាយទ្រុឌទ្រោម ជាដើម ក៏មានន័យនេះដែរ ។

ពាក្យថា **ដោយពាក់ព័ន្ធថា ជាខ្យល់អស្សាសៈ និងខ្យល់បស្សាសៈ** គឺដោយភាពជាខ្យល់ត្រង់ប្រហោងច្រមុះដែលចូលទៅខាងក្នុង និងចេញទៅខាងក្រៅ ។ ពាក្យថា **អ្នកមានមនសិការប្រព្រឹត្តទៅយ៉ាងនេះ** គឺអ្នកមានមនសិការកម្មដ្ឋានប្រព្រឹត្តទៅដោយការចែកកោដ្ឋាស ដែលប្រព្រឹត្តទៅនឹងសម្ភារៈតាមអាការដែលបានពោលមកហើយនេះ ។ ពាក្យថា **ធាតុទាំងឡាយនឹងប្រាកដ** គឺធាតុទាំងឡាយនឹងជាក់ច្បាស់ព្រោះបានកំណត់កាន់យកដោយពិស្តារ ។ វិធីការចម្រើន សូម្បីក្នុងអាការនេះ ក៏គប្បីជ្រាបតាមន័យដែលបានពោលមកហើយក្នុងខាងដើមនោះចុះ ។ បទថា **តត្ថ** ប្រែថា ក្នុងកោដ្ឋាស ២០ ពួកនោះឯង ។ សូម្បីក្នុងបទថា **បរិបាចនលក្ខណំ-**លក្ខណៈដែលធ្វើឲ្យរលាយ ។ **វិត្ថម្ភនលក្ខណំ**-លក្ខណៈដែលតឹងនេះ គប្បីនាំបទថា **តត្ថ** មកសម្ព័ន្ធផង ។

បទថា **តត្ថ** មួយបទទៀត មានសេចក្តីថា ក្នុងកោដ្ឋាស ១២ ពួកនោះៗឯង ។ ក្នុងបណ្តាកោដ្ឋាសពួកនេះ ព្រោះការដែលកោដ្ឋាស ២០ មានសក់ជាដើម (តែមួយកោដ្ឋាស) ជាកោដ្ឋាសដែលមានរូបរាង ធាតុទាំងឡាយ មានអាបោធាតុជាដើម ដែលមាននៅក្នុងកោដ្ឋាស ២០ ពួកនោះ ទើបជារបស់ដែលគប្បីដឹងបានងាយដូចគ្នានឹងវត្ថុទាំងឡាយ មានទឹកជាដើម ក្នុងគ្រឿងលម្អិតសម្រាប់ផ្ទុកទឹកជាដើម ព្រោះហេតុនោះ ទើបលោកពោលថា គប្បីកំណត់ចំពោះលក្ខណៈដែលជ្រួតជ្រាបក្នុងកោដ្ឋាស ២០ ពួកនោះឯង ដូច្នេះជាដើម , លោកអាចារ្យធ្វើទុកក្នុងចិត្តថា ធាតុទាំងឡាយ មានវាយោធាតុជាដើម ក្នុងបណ្តាតេជោធាតុ កោដ្ឋាសទាំងឡាយ មាន

ភ្លើងដែលធ្វើឲ្យរាងកាយក្តៅជាដើម មិនមែនរបស់ដែលគប្បីដឹងបានងាយយ៉ាងនោះ ដូច្នេះហើយ ទើបពោលថា ដែលមិនបែកអំពីគេជោនោះ ដូច្នេះ មិនពោលថា ក្នុងកោដ្ឋាស ៤ ពួកនោះៗឯង ។ សួរថា បើមានអធិប្បាយយ៉ាងនេះដូច្នោះ ក្នុងវាយោកោដ្ឋាសទាំងឡាយ ព្រះយោគីគប្បីកំណត់កាន់យកធាតុទាំងឡាយ ក្នុងកោដ្ឋាស ៦ ពួកនោះៗឯង បានយ៉ាងដូចម្តេច ? ឆ្លើយថា ពិតមែន សូម្បីវាយោកោដ្ឋាសទាំងឡាយ មានខ្យល់ដែលបក់ឡើងលើជាដើម រមែងចូលដល់ភាពជាធាតុដែលគួរកំណត់កាន់យកបាន ក៏ដោយអាការដែលរួមគ្នានោះឯង , ចំណែកតេជោកោដ្ឋាស មានភ្លើងដែលធ្វើឲ្យក្តៅជាដើម មិនបានចូលដល់ភាពជាធាតុដែលគួរកំណត់ដោយអាការដែលរួមគ្នាទេ ព្រោះហេតុនោះ ប្រការដែលពោលមកនេះ មិនខុសទេ ។ ក្នុងបទទាំងនោះ បទថា **តេន** បានដល់ ដែលមិនបែកអំពីតេជោធាតុនោះ ។ ពាក្យថា **មិនបែកគ្នា** គឺជារបស់មិនប្រាសចាកគ្នា , ម្យ៉ាងទៀតលោកពោលទុកយ៉ាងនេះ ក៏ដោយទាក់ទងនឹងធាតុដែលនៅក្នុងកលាបៈនោះៗ ។ ពាក្យថា **កាលកំណត់ទៅយ៉ាងនេះ** គឺ កាលកំណត់ធាតុទាំងឡាយដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈដោយអាការដែលបានពោលហើយ ។ ពាក្យថា **តាមន័យដែលបានពោលហើយ** គឺ តាមន័យដែលបានពោលហើយក្នុងខាងដើមដោយពាក្យថា កាលលោកព្យាយាមយ៉ាងនេះ ដូច្នេះជាដើម ។

ពាក្យថា **កាលចម្រើនទៅយ៉ាងនេះ** គឺ សូម្បីកំណត់យកពាក្យទាំងឡាយដោយសង្ខេបនៃកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈចម្រើនទៅ ។

ពាក្យថា **តាមន័យដែលបានពោលហើយក្នុងពេលមុន** គឺតាមន័យដែលបានពោលហើយ ក្នុងការចម្រើនដោយការចែកកោដ្ឋាស ដែលប្រព្រឹត្តជាមួយនឹងសម្ភារៈ

ពាក្យថា **ដោយន័យដូចគ្នានេះ** គឺដោយន័យដូចគ្នានឹងសរសៃសក់ ។ ពាក្យថា **ក្នុងកោដ្ឋាសទាំងពួង** បានដល់ ក្នុងកោដ្ឋាសទាំងអស់ដ៏សេស ដែលចែកចេញជា ៤១ កោដ្ឋាស ។ លោកពោលដល់ការកំណត់កាន់យកធាតុ ១៦៨ ទុក ក្នុងអាការនេះដោយប្រការដូច្នេះ ។ ចំណែកវិធីការចម្រើនក្នុងអាការនេះ ក៏មានន័យដូចបានពោលហើយ ក្នុងខាងដើមនោះឯង ។

ឥឡូវនេះ លោកអាចារ្យប្រាថ្នាសម្តែងវិធីមនសិការក្នុងធាតុទាំងឡាយ សូម្បីដោយសេចក្តីនៃពាក្យជាដើម ទើបពោលថា **វចនត្ថតោ** ( ដោយសេចក្តីនៃពាក្យ ) ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **វចនត្ថតោ** ( ដោយសេចក្តីនៃពាក្យ ) មានសេចក្តីថា ព្រោះហេតុដែលការរៀនយកកម្មដ្ឋាន រមែងមានដោយអំណាចពាក្យនិយាយ មុនរឿងដទៃទាំងអស់ ព្រោះក្នុងខាងដើម ព្រះយោគីគប្បីកាន់យកសេចក្តីនៃកម្មដ្ឋាននោះបាន ក៏ដោយពាក្យនិយាយជាគន្លងផ្លូវដូច្នោះ ទើបលោកអាចារ្យបានពោលដល់ធាតុទាំងឡាយជារបស់គួរមនសិការ តាមន័យនៃពាក្យ ។ បទថា **កលាបតោ-ដោយជាសំណុំ** មានសេចក្តីថា ព្រោះហេតុដែលធាតុទាំងនោះរមែងប្រព្រឹត្តទៅ ( ជាសំណុំ ) មិនមែនបែកគ្នាជាផ្នែកៗ ដូច្នេះ ទើបលោកពោលដល់សេចក្តីដែលធាតុទាំងឡាយ ជារបស់ដែលព្រះយោគី អ្នកកំណត់កាន់យកធាតុទាំងឡាយ ដោយពិសេស និងដោយសាមញ្ញ ដោយអំណាចសេចក្តីនៃពាក្យដែលគួរមនសិការ សូម្បីដោយភាពជាសំណុំ ។ រីឯកលាបៈដែលជាសំណុំធាតុទាំងនោះ មានបរិមាណល្អិតយ៉ាងក្រៃលែង ព្រោះហេតុនោះ លោកអាចារ្យប្រាថ្នាសម្តែងការកំណត់ធាតុទាំងឡាយ មានបឋវីធាតុជាដើម ដែលទាក់ទងនៅក្នុងកលាបៈពួកនោះ ដែលគប្បីប្រមាណ គប្បីរាប់ក្នុងសរីរៈ ទើបពោលសេចក្តីដែល

ធាតុទាំងឡាយ ជារបស់គួរមនសិការដោយភាពជាវត្ថុល្អិតជាចុណ្ណៈ ការមនសិការធាតុទាំងនោះ ដែលជាវត្ថុល្អិតជាចុណ្ណៈនេះនោះ រមែងមានបានដោយអំណាចការរួមចូលគ្នា ព្រោះហេតុនោះ លោកអាចារ្យប្រាថ្នាសម្ដែងធាតុ ដែលគប្បីកាន់យកដែលមានសភាវៈរបស់ខ្លួន ដែលប្រាសចាកគ្នាមិនបាននោះឯង ទើបបានពោលដល់ការមនសិការដោយលក្ខណៈជាដើមទុក ។ ឯព្រះយោគីអ្នកកំណត់កាន់យកធាតុទាំងឡាយ ដោយលក្ខណៈជាដើម ព្រោះហេតុដែលកាលនឹងកំណត់កាន់យកធាតុទាំងឡាយ តាមរយៈកោដ្ឋាស ៤២ ក្នុងការសន្សំកម្មដ្ឋាន ដោយការបែកកោដ្ឋាសដែលប្រព្រឹត្តទៅនឹងលក្ខណៈ ចាំបាច់ត្រូវជ្រាបការបែកបទប្រការនេះ គឺកោដ្ឋាសប៉ុណ្ណោះមានឧតុជាសមុដ្ឋាន កោដ្ឋាសប៉ុណ្ណោះមានចិត្តជាសមុដ្ឋាន ដូចនេះដូច្នោះ ទើបលោកពោលដល់មនសិការដោយសមុដ្ឋានទុក ។

លោកអាចារ្យបំណងសម្ដែងថា ព្រះយោគីគួរធ្វើការកំណត់កាន់យកធាតុទាំងនោះ ដែលបានកំណត់ដឹងសមុដ្ឋានហើយយ៉ាងនេះ ដោយលក្ខណៈដែលផ្សេងគ្នានិងលក្ខណៈដែលដូចគ្នា ដោយវៀរចាកការអនុលោមតាមសត្វ មិនត្រូវគិតដល់សត្វដូច្នេះ ទើបបានពោលការមនសិការដោយសេចក្ដីផ្សេងៗ គ្នា និងសេចក្ដីដូចគ្នាទុក ។ លោកបំណងសម្ដែងថា សេចក្ដីផ្សេងគ្នាខនេះ គឺជាធាតុទាំងនេះ សូម្បីថា មានសភាវៈបែកគ្នាបានដោយលក្ខណៈដែលផ្សេងគ្នា ក៏មិនបែកគ្នាដោយជាចំណែកៗព្រោះភាពដែលមានទីតាំង ដែលមិនអាចញែកសម្ដែងបាន ដូច្នេះ ក៏គប្បីកំណត់កាន់យក ទើបពោលដល់ការមនសិការ ដោយសេចក្ដីបែកគ្នា និងមិនបែកគ្នាទុក ។ លោកប្រាថ្នាសម្ដែងថា សេចក្ដីផ្សេងគ្នាប្រការនេះ គឺមានការប្រព្រឹត្តទៅមិនបែកគ្នា គឺ ជាតុខ្លះប៉ុណ្ណោះ មានចំណែកដូចគ្នានឹងធាតុខ្លះ ធាតុខ្លះក៏មានចំណែកខុសគ្នា

ដូច្នេះ ក៏គួរកាន់យក ទើបបានពោលដល់ការមនសិការ ដោយមានចំណែកដូចគ្នា និងមានចំណែកខុសគ្នាទុក ។ លោកប្រាថ្នាសម្តែងថា សេចក្តីផ្សេងគ្នាប្រការនេះ គឺធាតុទាំងឡាយដែលមានចំណែកដូចគ្នា និងមានចំណែកខុសគ្នា ដែលជាខាងក្នុង ក៏ប្រកបដោយកិច្ចពិសេសដូច្នេះ ផ្នែកខាងក្រៅក៏ផ្ទុយគ្នានឹងផ្នែកខាងក្នុង គប្បីកំណត់កាន់យក ទើបបានពោលដល់ការមនសិការ ដោយសេចក្តីផ្សេងគ្នានៃធាតុខាងក្នុង និងធាតុខាងក្រៅទុក ។ លោកប្រាថ្នាសម្តែងថា សេចក្តីផ្សេងគ្នាដោយការរួមចូលជាមួយគ្នាក្នុងធាតុទាំងឡាយ មានការរួមចូលជាមួយគ្នា បានដោយជាតិដែលដូចគ្នាជាដើម ក៏គួរកំណត់កាន់យកដូច្នេះ ទើបបានពោលដល់ការមនសិការដោយការរួមចូលជាមួយគ្នាទុក ។ លោកប្រាថ្នាសម្តែងថា គួរកំណត់កាន់យកធាតុទាំងឡាយ ដោយភាវៈដែលឧបត្ថម្ភដល់គ្នានិងគ្នា ដោយកិច្ចតាមដែលជារបស់ខ្លួន មានការទ្រទ្រង់ជាដើមដូច្នេះ ទើបបានពោលដល់ការមនសិការដោយបច្ច័យទុក ។ លោកប្រាថ្នាសម្តែងថា គប្បីកំណត់កាន់យកធាតុទាំងនោះ តាមន័យដែលមិនមានការព្យាយាមដូច្នេះ ទើបបានពោលដល់ការមនសិការ ដោយមិនមានការត្រិះរិះដល់គ្នាទុក ។ លោកប្រាថ្នាសម្តែងថា គប្បីកំណត់កាន់យកធាតុទាំងឡាយ ដោយសេចក្តីផ្សេងគ្នានៃធម៌ដែលជាបច្ច័យរបស់ខ្លួន និងដោយការផ្សេងគ្នានៃបច្ច័យដូច្នេះ ទើបបានពោលដល់ការមនសិការដោយការបែកបច្ច័យ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបហេតុ ក្នុងការកំណត់ដោយអាការ ១៣ យ៉ាង ពួកនេះ តាមប្រការដូចពោលមកនេះចុះ ។ ពាក្យថា **ដោយអាការទាំងឡាយ** គឺដោយប្រការទាំងឡាយ ឬថា ដោយហេតុទាំងឡាយ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ព្រោះភាវៈដែលផ្សាយទៅ** គឺ ព្រោះភាវៈដែល

ធំ ដោយពាក្យនោះ លោកពោលដល់អត្ថនៃសព្ទដោយន័យនៃនិរុត្តិថា ឈ្មោះថា **បុថុវី** ព្រោះភាវៈដែលធំ **បុថុវី** នោះឯងជា **បឋវី** ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា **បឋវីដោយសេចក្តីថា ទ្រទ្រង់** មានសេចក្តីថា ទទួល គឺចូលទៅទ្រទ្រង់ទុក ដោយភាពជាទីតាំង ។ អត្ថនៃបទថា **អប្បោតិ** ( ជ្រាបទៅ ) ខ្ញុំបានពោលទុកក្នុងខាងដើមហើយ ។ បទថា **អាបិយតិ** ( ជ្រួតជ្រាប ) បានដល់ នឹងត្រូវធ្វើឲ្យស្អួតទៅ អាចារ្យពួកខ្លះថា ដែលគេតែងផឹកបាន ។ អាចារ្យទាំងឡាយពោលថា ក៏សេចក្តីដូចពោលមកនេះ រមែងប្រើបានក្នុងសសម្ភារអាបោដូច្នេះ ។ សេចក្តីពិត ក្នុងលក្ខណៈអាបោ ក៏រមែងប្រើបានដូចគ្នា ។ ពិតមែន អាបោនោះ រមែងប្រព្រឹត្តទៅដូចជាថា ត្រូវកួតរូប ៣ ដ៏សេសក្រេបផឹក ដោយអាការដែលរឹង ( នៃធាតុដី ) ដែលធ្វើឲ្យឆ្អិន ( នៃធាតុភ្លើង ) និងដែលធ្វើឲ្យស្អួត ( នៃធាតុខ្យល់ ) ដូច្នេះ ។ បទថា **អប្បាយតិ** ធ្វើឲ្យសើម បានដល់ កពូន ។ ពិតហើយ អាបោធាតុមានការធ្វើឲ្យកកខន់ជារស ។ បទថា **តេជយតិ** ប្រែថា ធ្វើឲ្យរឹង មានសេចក្តីថា ធ្វើកួត ៣ ដ៏សេសឲ្យក្តៅ ដោយភាវៈដែលរឹងមាំ ។ បទថា **វាយតិ** ( បក់ទៅ ) គឺ រំកិលទៅ មានសេចក្តីថា ធ្វើសំណុំកួតរូបឲ្យទៅ ដោយភាពជាហេតុឲ្យទៅដល់ក្នុងបរិវេណដទៃ ។

លោកអាចារ្យ កាលពោលសេចក្តីនៃពាក្យថា **ធាតុ** ដោយន័យពិសេសមុនយ៉ាងនេះ ហើយឥឡូវនេះ ប្រាថ្នានឹងពោលដោយន័យសាមញ្ញ ទើបពោលថា ចំណែកដោយការមិនប្លែកគ្នាដូច្នេះជាដើម ។ ពាក្យថា **ព្រោះទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន** មានសេចក្តីថា ដូចជាវត្ថុដែលពួកតិត្ថិយៈគិតឡើងយ៉ាងនេះថា " ប្រក្រតី អត្តា " ជាដើម មិនមានដោយបរមត្ថយ៉ាងណា ធាតុពួកនេះ មិនមានដោយបរមត្ថ

ដូច្នោះ ក៏ទេ ។ ក៏ធាតុពួកនេះ ឈ្មោះថា **ធាតុ** ក៏ព្រោះអត្ថថា ទ្រទ្រង់លក្ខណៈរបស់ខ្លួន គឺ សភាវៈ ។ ពាក្យថា **ព្រោះជាទីតាំងនៃទុក្ខ** គឺព្រោះសាងនូវទុក្ខ ។ ពិតមែន ធាតុពួកនេះ ត្រូវកំណត់បានដោយភាពជាហេតុ រមែងសាងឡើងនូវសង្សារទុក្ខច្រើនប្រការ ដូចធាតុដែក ធាតុលោហៈជាដើម រមែងបង្កើតឡើងនូវដែក លោហៈជាដើមក៏ដូច្នោះ ។ ពាក្យថា **ព្រោះជាទីតាំងនៃទុក្ខ ( ទុក្ខធានតោ )** មានសេចក្ដីថា ឈ្មោះថា **ធាតុ** ព្រោះជាទីតាំងនៃទុក្ខយ៉ាងនេះ គឺព្រោះសាងឡើងនូវទុក្ខច្រើនប្រការ ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច ឬព្រោះអត្ថថា ជាហេតុឲ្យសត្វទាំងឡាយតាមតាក់តែងនូវទុក្ខនោះ និងព្រោះអត្ថថា ជាទីទ្រទ្រង់ គឺជាទីតាំងនៃទុក្ខតាមដែលតាក់តែងហើយនោះ ។ ម្យ៉ាងទៀត មានសេចក្ដីថា មិនមែនជីវៈ ជាធាតុដូច្នេះ ក៏ត្រូវពោលទុកផងដែរ ។ ពិតយ៉ាងនោះ ព្រះមានព្រះភាគទ្រង់បានធ្វើទេសនាទុក ក៏ដើម្បីប្រយោជន៍ដល់ការដកសេចក្ដីប្រកាន់ថា ជាជីវៈ ក្នុងប្រយោគថា **ឆធាតុរោ អយំ ភិក្ខុ បុរិសោ** ម្នាលភិក្ខុ បុរសនេះមានធាតុ ៦ ដូច្នេះជាដើមដូច្នេះឯង ។ លោកអាចារ្យ បើកផ្សារនូវលក្ខណៈព្រមទាំងរសនៃធាតុទាំងឡាយដោយមិនសាធារណៈ និងដោយសាធារណៈ សូម្បីដោយសេចក្ដីនៃពាក្យជាប្រមុខយ៉ាងនេះ នោះហើយ ព្រោះហេតុនោះ ទើបពោលថា គប្បីមនសិការតាមន័យនៃពាក្យ តាមរយៈន័យពិសេស និងន័យសាមញ្ញយ៉ាងនេះ ដូច្នេះ ។ ចំណែកការមនសិការរបស់ព្រះយោគីអ្នកកំណត់ធាតុទាំងឡាយ ដោយន័យនៃពាក្យជាប្រមុខបណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងខាងដើមនោះចុះ ។

ពាក្យថា **ដោយអាការ** គឺ ដោយប្រការ ។ ម្យ៉ាងទៀត កោដ្ឋាសទាំងឡាយឈ្មោះថា **អាការ** ព្រោះអត្ថថា ជាទីតាំងដែលមានធាតុទាំងឡាយប្រជុំគ្នា គឺ

ប្រាកដ ។ ពាក្យថា **ព្រោះការប្រជុំគ្នានៃធម៌ ៨ យ៉ាង** គឺព្រោះការប្រជុំគ្នានៃធម៌ ៨ យ៉ាង មានវណ្ណៈជាដើម តាមដែលពោលហើយ មានរូបផ្សេងៗ តាមភាពផ្សេងគ្នានៃបច្ច័យ បានដល់ ព្រោះអាស្រ័យធម៌ ៨ យ៉ាងនោះ ដោយមានការប្រជុំព្រមគ្នា ( នឹងធម៌ ៨ យ៉ាងនោះ ) ដោយអំណាចនៃអាការដែលអាស្រ័យគ្នាផ្សេងៗគ្នា ។ ឈ្មោះថា សម្មតិថា **សក់** ក៏ត្រឹមតែវោហារ ។ ពាក្យថា **ព្រោះបានបំបែកធម៌ពួកនោះៗឯង** គឺ ព្រោះបានបំបែកធម៌ទាំងឡាយ មានវណ្ណៈជាដើមពួកនោះៗឯង , ដូចជាថា កាលប្រើបញ្ញាបំបែកទៅ ក៏រមែងជួបធម៌ ៨ យ៉ាង មានវណ្ណៈជាដើម បានដោយបរមត្ថ ( មួយៗ ) ជាធម៌ដែលផ្សេងៗគ្នា យ៉ាងណា សក់នឹងមានដោយបរមត្ថ ព្រោះជាធម៌ដែលផ្សេងអំពីធម៌ ៨ យ៉ាង មានវណ្ណៈជាដើម ដូច្នោះក៏ទេ , ព្រោះដូច្នោះ ទើបមានអត្ថាធិប្បាយថា សម្មតិថា **សក់** រមែងមានបាន ព្រោះអាស្រ័យធម៌ទាំងឡាយដែលកើតឡើងព្រមគ្នាពួកណា កាលបានធ្វើធម៌ពួកនោះ ឲ្យបែកគ្នាជាចំណែកៗហើយ សម្មតិថា **សក់** ក៏មិនមាន , ប្រាកដត្រឹមតែជាវោហារប៉ុណ្ណោះ ។

ពាក្យថា **ត្រឹមតែជាសំណុំធម៌ ៨ យ៉ាងប៉ុណ្ណោះនេះ** លោកពោលកាន់យកធម៌ ៨ យ៉ាង មានវណ្ណៈជាដើម ដែលកាន់យកបាន ដោយសេចក្ដីដូចគ្នានឹងការបញ្ញត្តិថា **សក់** មិនបានពោលព្រោះសេចក្ដីដែលសរសៃសក់ទាំងនោះ ត្រឹមតែជាធម៌ ៨ យ៉ាង ។ ឈ្មោះថា **កោដ្ឋាសដែលមានកម្មជាសមុដ្ឋាន** បានដល់ សរសៃសក់ទាំងឡាយ និងពោលដល់គល់ឫសរបស់សរសៃសក់មុន សូម្បីក្នុងកោដ្ឋាសដ៏សេស មានរោមជាដើម បណ្ឌិតគប្បីជ្រាបតាមសមគួរក្នុងន័យដូចគ្នានេះចុះ ។ ក្នុងពាក្យថា **ទាំងសំណុំធម៌ ១០ យ៉ាងនេះ** គួរនឹងពោលដល់កោដ្ឋាសនៃតេជោ

ដែលធ្វើរបស់បរិភោគជាដើមឲ្យរលាយទៅ ជាទាំងសំណុំធម៌ ៩ យ៉ាង ។ លោកអាចារ្យធ្វើក្នុងចិត្តថា កោដ្ឋាសទាំងឡាយ មានសក់ជាដើមពួកនេះឯង ជាសំណុំធម៌ ៨ យ៉ាង ៩ យ៉ាង និង ១០ យ៉ាងតាមសមគួរ កាលបើដូច្នោះ ព្រោះហេតុអ្វី ព្រះយោគីទើបត្រូវមនសិការដោយគ្រាន់តែជាធាតុ មានបឋវីធាតុជាដើមទៀត ហើយពោលថា **ឧស្សទវសេន បន សូម្បីដូច្នោះ...** ដោយទាក់ទងជាធាតុដែលប្រជុំគ្នាដូច្នេះជាដើម ។ ព្រោះហេតុដែលធាតុមនសិការនេះ មានប្រយោជន៍ត្រឹមតែជាការដកសេចក្ដីក្រាន់ថា ជាសត្វប៉ុណ្ណោះ និងបំបែកធម៌ រមែងប្រព្រឹត្ត ទៅព្រមដើម្បីការដកសេចក្ដីសម្គាល់ថាជាសត្វបាន ដោយប្រពៃ ដូច្នោះ ព្រះយោគីក៏គួរនឹងជ្រាបដល់ការបែកធម៌ ក្នុងកោដ្ឋាសទាំងឡាយយ៉ាងនេះ ។ ពិតមែន ក្នុងបណ្ដាកោដ្ឋាសពួកនេះ កោដ្ឋាស ៦ មានសមុដ្ឋាន ១ គឺ : អាហារថ្មី អាហារចាស់ ខ្ទុះ និងបស្សាវៈ **មានឧតុជាសមុដ្ឋាន** , ធាតុភ្លើងរំលាយអាហារ មានរបស់បរិភោគជាដើម **មានកម្មជាសមុដ្ឋាន** , ខ្យល់អស្សាសៈ និងខ្យល់បស្សាសៈ **មានចិត្តជាសមុដ្ឋាន** , កោដ្ឋាស ៤ គឺ ញើស ទឹកភ្នែក ទឹកមាត់ ទឹកសម្បោរ **មានសមុដ្ឋានពីរ គឺ ឧតុនិងចិត្ត** , កោដ្ឋាស ៣២ ដ៏សេស មានសមុដ្ឋាន ៤ ។

ក្នុងបណ្ដាកោដ្ឋាសទាំងនោះ កលាបៈ គឺ សំណុំរូប ១ ក្នុងតេជោកោដ្ឋាសដែលរំលាយអាហារ មានរបស់បរិភោគជាដើមជាជីវិតនវកៈ ( មាន ៩ រូបព្រមទាំងជីវិត ) , ក្នុង ១ កលាបៈៗ ដែលមានឧតុជាសមុដ្ឋានក្ដី ដែលមានចិត្តជាសមុដ្ឋានក្ដី ក្នុងបណ្ដាកោដ្ឋាសដែលមានសមុដ្ឋាន ១ ពួកដទៃ ជាអដ្ឋកៈ ( មាន ៨ រូប ) ។ ក្នុងបណ្ដាកោដ្ឋាសដែលមានសមុដ្ឋាន ២ មួយកលាបៈៗ ២ តាមរយៈឧតុ និង ចិត្ត ( គឺ កលាបៈក្នុងញើសដែលមានឧតុជាសមុដ្ឋាន ១ កលាបៈ

ក្នុងញើសដែលមានចិត្តជាសមុដ្ឋាន ១ កលាបៈជាដើម រួម ៤ កោដ្ឋាស ក៏ត្រូវជា ៨ កលាបៈ ) ជាពួកអដ្ឋកៈ ( មាន ៨ រូប ) ក្នុងបណ្តាកោដ្ឋាសដែលមានសមុដ្ឋាន ៤ កលាបៈមួយៗ ៣ ដែលមានឧតុ ចិត្ត និងអាហារជាសមុដ្ឋាន ជាពួកអដ្ឋកៈ ( មាន ៨ រូប ) កលាបៈក្នុងកោដ្ឋាសដែលមានឧតុ និងចិត្តជាសមុដ្ឋាន ជាពួកសទ្ទនវកៈ ( មាន ៩ រូបទាំងសទ្ទៈ ) , កលាបៈ ៨ ក្នុងតេជោកោដ្ឋាស និងវាយោកោដ្ឋាស រួម ៨ កោដ្ឋាស ជាពួកជីវិតនវកៈ ( មានរូប ៩ ទាំងជីវិត ) , ក្នុងកោដ្ឋាស ២៤ ដ៏សេស មានកលាបៈ ដែលប្រព្រឹត្តទៅនឹងកលាបៈទាំងពីរ គឺ កាយទសកៈ ( មាន ១០ រូប ទាំងកាយបសាទ ) និងភាវទសកៈ ( មាន ១០ រូប ព្រមទាំងភាវរូប ) និងមានកលាបៈដែលប្រព្រឹត្តទៅនឹងចក្ខុទសកៈ សោតទសកៈ ជិវ្ហាទសកៈ និងវត្ថុទសកៈ នៅត្រង់កោដ្ឋាសនៃសាច់ទាំងឡាយ ដែលមានឈ្មោះថា ភ្នែកជាដើម ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា មិនប៉ះពាល់ដល់ការចែកប្រភេទក្នុងរូបកាយ ដែលមានអាយតនៈបរិបូណ៌ កាន់យកកលាបៈទាំងឡាយដោយអំណាចនៃសេចក្តី ( រួបរួមកលាបៈដែលដូចគ្នា ) ជាកលាបៈដូចគ្នា ក៏មានរូបកលាបៈ ១៤៧ កលាបៈ ដោយការចែករូបធម៌ ក៏រមែងមានរូបធម៌ ១៥០០ រូបជាង , តែកាលកាន់យកការចែកប្រភេទនៃកលាបៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងកោដ្ឋាសទាំងនោះ ដោយការចែកកោដ្ឋាសទាំងឡាយ ១ កោដ្ឋាសៗ ជារូបតូចៗ ក៏នឹងមានប្រភេទនៃរូបធម៌ទាំងឡាយ មិនអាចរាប់បាន ។ ព្រះយោគីគប្បីកំណត់ចែកកោដ្ឋាស ៤២ យ៉ាងពួកនេះ ក្នុងចំណែកផ្សេងគ្នាដោយប្រភេទជាច្រើន ក្នុងចំណែកធម៌ តាមប្រការដែលបានពោលមកនេះ តាមរយៈធាតុ ៤ នោះឯង ដោយការកាន់យកធាតុដែលប្រជុំគ្នា។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា សូម្បី

ដូច្នោះ ដោយទាក់ទងតាមរយៈធាតុដែលប្រជុំគ្នា ព្រះយោគីគប្បីមនសិការនូវធាតុ ។ ល ។ ដូច្នេះ ក្នុងន័យនោះ គប្បីជ្រាបវិធីមនសិការតាមន័យដែលបានពោល មកហើយនោះចុះ ។

សេចក្តីថា **មជ្ឈិមេន បមាណេន** គឺដោយខ្នាតកណ្តាល ដែលមានក្នុងរាង កាយខ្នាតកណ្តាល ដោយកម្ពស់ និង កម្រាស់ជុំវិញខ្លួន ។ ពាក្យថា **ដែលនឹង ត្រិះរិះកាន់យក** គឺដែលនឹងត្រិះរិះកាន់យកដោយបញ្ញា ។ ក្នុងពាក្យថា ដែលល្អិត ជាចុណ្ណៈ ដោយបែកជាបរមាណូនេះ អាចារ្យពួកខ្លះពោលថា ប្រៀបដូចជាចំណែក ទី ៨ ( ១/៨ ) នៃអង្គុល ឈ្មោះថា **យវៈ** , ចំណែកទី ៨ នៃយវៈ ឈ្មោះថា **ឩកា** , ចំណែកទី ៨ នៃឩកា ឈ្មោះថា **លិក្ខា** , ចំណែកទី ៨ នៃលិក្ខា ឈ្មោះថា **រថរេណុ** , ចំណែកទី ៨ នៃរថរេណុ ឈ្មោះថា **តជ្ជារី** , ចំណែកទី ៨ នៃតជ្ជារី ឈ្មោះថា **អណូ** យ៉ាងណា ចំណែកទី ៨ នៃអណូ ក៏ឈ្មោះថា **បរមាណូ** ក៏ ដូច្នោះ ។ ចំណែកក្នុងបករណ៍អដ្ឋកថាពោលថា មួយអង្គុលស្មើនឹង ៧ ធញ្ញមាស , មួយធញ្ញមាសស្មើនឹង ៧ ឩកា , មួយឩកាស្មើនឹង ៧ លិក្ខា , មួយលិក្ខាស្មើនឹង ៣៦ រថរេណុ , មួយរថរេណុស្មើនឹង ៣៦ តជ្ជារី , មួយតជ្ជារីស្មើនឹង ៣៦ អណូ , មួយអណូស្មើនឹង ៣៦ បរមាណូ ដូច្នេះ ។ ព្រោះដូច្នោះ ឈ្មោះថា **បរមាណូ** មានខ្នាតស្មើនឹងចំណែកទី ៣៦( ១/៣៦ ) នៃអណូ មានកោដ្ឋាសនៃអាកាស មិន បានជាអារម្មណ៍របស់មំសចក្ខុ ជាអារម្មណ៍របស់ទិព្វចក្ខុប៉ុណ្ណោះ ។ លោកអាចារ្យ សំដៅយកបរមាណូដូចពោលនោះ ពោលថា ដែលល្អិតជាចុណ្ណៈ ដោយបែកជា បរមាណូ ដូច្នេះ គឺជាវត្ថុល្អិតសែនល្អិត ដោយប្រភេទនៃបរមាណូ តាមដែលពោល មកហើយ។ ពាក្យថា **ជាធូលីល្អិត** គឺ ព្រោះល្អិតជាចុណ្ណៈ ដោយបែកជាបរមាណូ

នោះៗ ឯង ទើបដល់ភាពជាធូលីល្អិត ហួសនឹងប្រៀបបាន ។

ពាក្យថា **មានប្រមាណមួយទោណ** គឺមានប្រមាណ ១៦ នាឡិ ។ សូម្បី ក្នុងបទថា **ទោណមត្តា សិយា** នេះ គប្បីនាំបទថា **មជ្ឈិមេន បមាណេន** មក សម្ព័ន្ធទុក ។ ដោយពាក្យនោះ លោកពោលថា ៤ ក្ដាប់ តាមប្រក្រតីបាន ១ កុឌុវៈ , ៤ កុឌុវៈ បាន ១ នាឡិ , ១៦ នាឡិ ដោយនាឡិនោះបាន ១ ទោណ , ក៏ទោណនោះ ត្រូវជា ១២ នាឡិ ដោយនាឡិនគរមគធៈដូច្នេះ ។ ពាក្យថា **ដែលអាបោធាតុធ្វើឲ្យកកខន់** គឺ ដែលអាបោធាតុប្រមូលរួមទុក ដោយអំណាចនៃ ការសម្ព័ន្ធមិនឲ្យខ្ចាត់ខ្ចាយទៅ ។ ពាក្យថា **ដែលតេជោធាតុតាមរក្សា** គឺ ដែល តេជោធាតុតាមរក្សាទុក មិនឲ្យដល់នូវភាពសើម ឬ ការហៀរហូរទៅ ព្រោះ អាបោធាតុ មានសភាវៈជ្រួតជ្រាប ។ ពាក្យថា **ដែលវាយោធាតុទ្រទុក** គឺ ទ្រទ្រង់ ដែលវាយោធាតុធ្វើឲ្យដល់ការតាំងនៅមាំបានយ៉ាងល្អក្រៃលែង ជាខ្យល់ដែលរួបរួម គ្នា ។ ពាក្យថា **រមែងមិនខ្ចាត់ខ្ចាយ មិនបែកធ្លាយទៅ** មានសេចក្ដីថា បឋវីធាតុ ទោះបីជាធូលីល្អិត បានបច្ច័យអំពីអាបោធាតុ តេជោធាតុ និង វាយោធាតុ ដែល មានកិច្ចជ្រួតជ្រាប ធ្វើឲ្យរលាយ និងធ្វើឲ្យកម្រើកហើយ ត្រូវជ័រធ្វើឲ្យសើម ត្រូវ ភាពក្ដៅធ្វើឲ្យឆ្អិន ត្រូវខ្យល់ធ្វើឲ្យដល់ការតាំងមាំបាន ក៏រមែងមិនខ្ចាត់ខ្ចាយ និងមិន បែកធ្លាយទៅខាងនោះខាងនេះ ដូចជាកំទេចម្សៅ ទោះបីជាដុំ ក៏ដល់ភាពជាវត្ថុ ដែលអ្នកណាៗ គប្បីកាន់យកបានដោយប្រការផ្សេងៗ ។ ព្រោះហេតុនោះ ទើប លោកអាចារ្យពោលថា កាលមិនខ្ចាត់ខ្ចាយដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ការកំណត់** គឺ ការបែក ។ សូម្បីតេជោធាតុ និងវាយោធាតុ ជាធាតុ ដែលមានសភាវៈពិត ដែលជារូបធម៌ក៏ដោយ តែថា សភាវៈដែលជាដុំសំណុំឯណា

ដែលបុគ្គលរមែងមិនបានជួបក្នុងបថវីធាតុ និងអាបោធាតុ សភាវៈដែលជាដុំដូច្នោះ រមែងមិនបានជួបក្នុងតេជោធាតុ និងវាយោធាតុ ព្រោះហេតុនោះ ព្រោះមិនមានភាពជាវត្ថុដែលគប្បីវាល់រាប់បាន ទើបលោកមិនលើកប្រភេទវត្ថុដែលល្អិតជាចុណ្ណៈទុកក្នុងតេជោធាតុ និងវាយោធាតុនោះ ។ ពិតហើយ សូម្បីក្នុងសសម្ភារតេជោ និងសសម្ភារវាយោទាំងឡាយ បុគ្គលនឹងរកភាពជាវត្ថុដែលគប្បីវាស់វាល់ មិនបានឡើយ ។ បទថា **យូសគតា** ប្រែថា ដល់ភាពជារបស់រាវ គឺជារបស់ហូរបាន ។ ព្រោះហេតុនោះៗ ឯង ទើបមានអាការបង្ខំទុក ។ បទថា **ន បគ្ឃរតិ** ប្រែថា មិនហូរ ។ បទថា **ន បរិស្សវតិ** ប្រែថា មិនស្រក់ហូរ ។ លោកពោលថា ធ្វើភាពផ្អែតផ្អូនឲ្យប្រាកដ ក៏ព្រោះអាបោធាតុ មានការកកខន់ជារស ។

ដោយពាក្យថា **មានអាការក្តៅ** នេះលោកសម្តែងថា សូម្បីចំហាយក្តៅតាមប្រក្រតីក្នុងរាងកាយ ក៏រមែងមានដោយអំណាចនៃតេជោធាតុ ពោលគឺភ្លើងរំលាយអាហារនោះៗឯង ។ ពាក្យថា **បន្ទំ** គឺធ្វើឲ្យក្តៅ ។ ពិតមែន តេជោធាតុនោះកាលដល់ភាពជាហេតុនៃសម្បត្តិ មានរសជាដើម ដោយការធ្វើអាហារដែលបរិភោគទៅហើយ ឲ្យរលាយទៅដោយប្រពៃ ក៏ពោលបានថា បន្ទំកាយនេះទុក គឺធ្វើឲ្យក្តៅ ។ ព្រោះហេតុនោះ ទើបលោកពោលថា មិនប្រាកដភាពស្អុយឡើយដូច្នេះ ។ តេជោធាតុ រមែងជាបច្ច័យពិសេសនៃការដល់ព្រមដោយវណ្ណៈក្នុងសរីរៈ ព្រោះមានកម្មជាឧបនិស្ស័យ និងព្រោះមានភាពជាហេតុនៃភាពស្រស់ថ្លារបស់ចិត្ត នឹងពោលទៅថ្មីដល់តេជោធាតុតាមដែលពោលមកហើយ និងមិនជាបច្ច័យពិសេសនៃរូបសម្បត្តិ ដែលមានឧតុ និងអាហារជាសមុដ្ឋាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា នឹងនាំមកនូវវណ្ណសម្បត្តិដូច្នេះ ។

ក្នុងពាក្យថា **មានការធ្វើឲ្យកម្រើក និងរុញច្រាន ឬគាំទ្រជាលក្ខណៈ** នេះ អាចារ្យ ពួកខ្លះពោលថា ឈ្មោះថា **សមុទីរណំ** ធ្វើឲ្យកម្រើក បានដល់ បណ្តេញ គឺ ធ្វើឲ្យស្ងួតក្រៀមអស់ទៅ ។ អាចារ្យមួយពួកពោលថា ឈ្មោះថា **វិត្ថម្ភនំ**( រុញច្រាន ) បានដល់ ការធ្វើកូត ៣ ដែលនៅសល់ ឲ្យដល់ការៈគាំទ្រគ្នា បានដល់ ទល់ទ្រគ្នាទុក ។ បទថា **តាយ** បានដល់ វាយោធាតុដែលមានភាពរុញច្រាន ជាលក្ខណៈ ។ ពាក្យថា **វាយោធាតុម្យ៉ាងទៀត** គឺ វាយោធាតុដែលមានការធ្វើឲ្យកម្រើករំកិលទៅ ជាលក្ខណៈ ។ ពិតហើយ វាយោធាតុនោះ មានការបក់ផាត់ទៅជាសការៈ ព្រោះហេតុនោះ ទើបលោកពោលថា ត្រូវទល់ទ្រគ្នា ។ ឈ្មោះថា **ការទល់ទ្រគ្នាយ៉ាងខ្លាំង** បានដល់ ភាពជាហេតុកើតឡើងក្នុងចំណែកនៃសំណុំរូប ។ ឈ្មោះថា **អវយគ្គនំ** បានដល់ ភាពជាហេតុឲ្យកើតឡើងក្នុងទីជិតនៃសំណុំរូប ។ បទថា **លាឡេតិ** ធ្វើឲ្យកម្រើក គឺ ខិតរំកិល ។ ការមនសិការដែលជាវត្ថុល្អិតមកហើយ ដើម្បីប្រយោជន៍ណា ឥឡូវនេះ លោកអាចារ្យប្រាថ្នាសម្តែងប្រយោជន៍នោះ តាមរយៈពាក្យចុងក្រោយ ទើបពោលថា **ឯវមេតំ** ដូច្នេះជាដើម ( **តុក្កតាយន្ត** ។ល។ តាមប្រការដូចពោលមកនេះ ) ។ ក្នុងពាក្យទាំងនោះ ពាក្យថា **តុក្កតាយន្ត ដែលធ្វើដោយធាតុ** មានសេចក្តីថា កាលមិនមានអត្តាជាអ្នកធ្វើតុក្កតាយន្ត ដែលធ្វើដោយធាតុ រមែងប្រព្រឹត្តទៅដោយអំណាចនៃចិត្ត ដូចរូបអាយ៉ងដែលកម្រើកបានដោយសរសៃអំបោះដូច្នោះ ។ វិធីមនសិការក្នុងអាការនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលមកហើយនោះឯង ។ អាការមានលក្ខណៈជាដើមនៃធាតុ ៤ ដែលលោកបានពោលទុកហើយក្នុងខាងដើម ក្នុងរឿងនោះៗ ក៏ពិត សូម្បីយ៉ាងនោះ លោកក៏ប្រាថ្នាសម្តែងអាការ មានលក្ខណៈជាដើមពួកនោះ មិនឲ្យមានសល់

ហើយសម្តែងវិធីកំណត់កម្មដ្ឋាន មួយកម្មដ្ឋានៗ ទើបផ្តើមពាក្យថា **លក្ខណាទិតោ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ មានសេចក្តីថា ឈ្មោះថា លក្ខណៈព្រោះអត្ថថា ជាគ្រឿងកំណត់ បឋវីធាតុឈ្មោះថា **កក្ខឡត្ត លក្ខណា** ព្រោះអត្ថថា មានភាពរឹង ជាលក្ខណៈ ។ សួរថា ក៏ភាពរឹងនោះឯង ជាបឋវីធាតុ មិនមែនឬ ? ឆ្លើយថា ការដែលពោលមកនេះ ក៏ជាសេចក្តីពិត , ទោះបីជាយ៉ាងនោះ សូម្បីធម៌មិនមានការបែកគ្នា តែដោយអំណាចនៃធម៌ដែលត្រូវកំណត់ដឹង ព្រមទាំងមានអត្ថនៃសត្វនៅមិនទាន់បានដឹងច្បាស់ លោកក៏ធ្វើនិទ្ទេស ពាក្យសម្តែងខែទុកយ៉ាងនេះ ដោយភាពផ្សេងគ្នា ដែលសម្រេចដោយអាការ គឺ គ្រឿងកំណត់ , ព្រោះថា កាលបើយ៉ាងនេះ ក៏នឹងមានការត្រាស់ដឹងអត្ថពិសេសបាន ។ ន័យម្យ៉ាងទៀត គប្បីឃើញសេចក្តីក្នុងពាក្យនេះ យ៉ាងនេះថា ឈ្មោះថា **លក្ខណៈ** ព្រោះអត្ថថា បណ្ឌិតមែងកំណត់បាន , ធាតុរឹង ដែលបណ្ឌិតគប្បីកំណត់បាន ឈ្មោះថា **កក្ខឡត្តលក្ខណា** ។ សូម្បីក្នុងធាតុដ៏សេស ក៏មានន័យដូច្នេះ ។ ពាក្យថា **មានភាពជាទីតាំងអាស្រ័យជារស** គឺ មានការជាទីអាស្រ័យនៃធម៌ដែលកើតរួមគ្នាទាំងឡាយជាកិច្ច ។ ព្រោះហេតុនោះៗឯង ទើបប្រាកដដល់ញាណ ដោយអាការទ្រទ្រង់ធម៌ពួកនោះទុក ព្រោះហេតុនោះ ទើបឈ្មោះថា មានការទ្រទ្រង់ទុកជាបច្ចុប្បដ្ឋាន ។ ក៏ក្នុងទីនេះ លោកមិនបានលើកយកបទដ្ឋាន(ហេតុជិត) ទុកជាធម៌យ៉ាងដទៃ ឬដោយភាវៈ ដែលមានជាចំណែកសាធារណៈ ដូចហេតុឆ្ងាយទេ ។ ម្យ៉ាងទៀត ក្នុងពាក្យពណ៌នាវារៈការសម្តែងធម៌ជាដើម លោកសម្តែងភាពជាបច្ច័យដល់ធម៌ពួកដទៃទុកដោយអាការមានរសជាដើមហើយ ក៏បានលើកបទដ្ឋាន ដើម្បីសម្តែងភាពជាធម៌មានបច្ច័យទុក យ៉ាងណា ក្នុងធាតុ ៤ នេះ មិនបានលើកបទដ្ឋានទុកដូចគ្នានោះ

ទេ ។ ក៏ក្នុងទីនេះបណ្ឌិតគប្បីឃើញថា ព្រោះមានពាក្យសួរថា ដោយការបើកបង្ហាញដល់បច្ច័យដែលផ្សេងគ្នា គឺមិនជាសាធារណៈដល់ធាតុដទៃទុកខាងមុខនៃធាតុទាំង-ឡាយ ទើបលោកមិនបានលើកបទដ្ឋាន ដែលជាធម៌យ៉ាងដទៃទុក ។ ពាក្យថា **មានការធ្វើឲ្យកកខន់ជារស** គឺ មានការធ្វើធម៌ដែលកើតរួមគ្នាទាំងឡាយឲ្យចម្រើនជាកិច្ច ។ ពិតយ៉ាងនោះ លោកពោលដល់អាបោធាតុនោះថា ធ្វើការផ្អែតផ្អន់នៃធម៌ទាំងនោះឲ្យប្រាកដ ។ ពាក្យថា **មានការប្រមូលផ្ដុំជាបច្ចុប្បដ្ឋាន** គឺ រួបរួមធម៌ទាំងឡាយដែលកើតរួមគ្នាជាបច្ចុប្បដ្ឋាន ដូចទឹកខាងក្រៅរួបរួមគ្រឿងចុណ្ណៈ(លំអិត) សម្រាប់ងូតទឹកទុកដូច្នោះ ។ ពាក្យថា **មានការធ្វើឲ្យទន់ដល់ធម៌ទាំងឡាយដែលកើតរួមគ្នាជាបច្ចុប្បដ្ឋាន** គឺ ដូចភ្លើងខាងក្រៅធ្វើវត្ថុទាំងឡាយឲ្យទន់ មានល័ខ និងក្រឹស្នាជាដើម ។ ឈ្មោះថា **ការរំកិល** បានដល់ ភាពជាហេតុធ្វើឲ្យដល់ក្នុងទីដទៃនៃសំណុំកូតរូប ឬបានដល់ ស្ទុះចេញទៅ ដូចពន្លកឈើដុះចេញពីគ្រាប់ដូច្នោះ ។

ឈ្មោះថា **មានឧតុជាសមុដ្ឋានតែម្យ៉ាង** ព្រោះមិនកើតឡើងដោយអំណាចនៃកម្មជាដើម ។ ឈ្មោះថា មានឧតុ និងចិត្តជាសមុដ្ឋាន ព្រោះពេលខ្លះកើតពីឧតុ ពេលខ្លះកើតពីចិត្ត ។ ពាក្យថា **កោដ្ឋាសដ៏សេស** គឺ កោដ្ឋាស ៣២ ដែលនៅសល់ ដូចពោលហើយ គឺ កោដ្ឋាស ២៤ មានសក់ជាដើម កោដ្ឋាសនៃតេជោ ៣ ខាងដើម និងកោដ្ឋាសនៃវាយោ ៥ ។ ពាក្យថា **សូម្បីទាំងអស់** សេចក្ដីថា កោដ្ឋាសទាំងនោះសូម្បីទាំងអស់ ឈ្មោះថាមានធម៌ទាំង ៤ ជាសមុដ្ឋាន ព្រោះកើតឡើងដោយអំណាចនៃកម្មជាដើម ។ ពិតមែន ផ្នែកដែលនៅជាប់សាច់នៃកោដ្ឋាសទាំង-ឡាយ មានសក់ជាដើម រមែងជាផ្នែកដែលមាន កម្ម អាហារ និងចិត្តជាសមុដ្ឋានដូច្នេះ ។

ពាក្យថា **ដោយភាពផ្សេងៗគ្នា និងដោយភាពដូចគ្នា** គឺ ដោយសេចក្តីផ្សេងគ្នា និងសេចក្តីដូចគ្នា ។ ពិតហើយ ធម៌ទាំងឡាយមិនដូចគ្នា ឈ្មោះថា **នានត្តំ** ( ជាភាពផ្សេងគ្នា ) , សេចក្តីដូចគ្នា ឈ្មោះថា **ឯកត្តំ** ( សេចក្តីតែមួយដូចគ្នា ) ពាក្យថា **សូម្បីទាំងអស់** គឺសូម្បីទាំង ៤ ។ ប្រការថា **សលក្ខណាទិតោ** ( ដោយលក្ខណៈរបស់ខ្លួនជាដើម ), សេចក្តីថា លក្ខណៈរបស់ខ្លួន ឈ្មោះថា **សលក្ខណំ** ដោយលក្ខណៈរបស់ខ្លួននោះ ឈ្មោះថា **សលក្ខណាទិតោ** ។ ដោយ **អាទិ**-ស័ព្ទ គប្បីឃើញថា សង្គ្រោះយកទាំងភាពទន់ និងភាពរឹងជាដើម ដូចគ្នានឹង រស និងបច្ចុប្បដ្ឋាន ។ សួរថា ព្រោះហេតុអ្វី ទើបលោកពោលថា មានសេចក្តីផ្សេងៗគ្នា តាមរយៈធាតុដែលមានកម្មជាសមុដ្ឋាន ដូច្នេះ , ធាតុ ៤ មានសេចក្តីដូចគ្នា តាមរយៈធាតុដែលមានកម្មជាសមុដ្ឋានដូចគ្នាជាដើម ព្រោះជាសមុដ្ឋានសាធារណៈ មិនមែនឬ ? ឆ្លើយថា មិនមែនទេ លោកពោលយ៉ាងនោះ ព្រោះសំដៅយកសេចក្តីផ្សេងគ្នាដែលមានអាទិថា ធាតុដែលមានកម្មជាសមុដ្ឋាន មួយពួក ធាតុដែលមានឧតុជាសមុដ្ឋានក៏មួយពួកដូច្នេះ ។ បទថា **ឯតាសំ** បានដល់ ធាតុទាំងឡាយ ។ ពាក្យថា **លក្ខណៈដែលបែកធ្លាយ** គឺ សភាវៈដែលវិនាស ។ ក៏ឈ្មោះថា សេចក្តីវិនាសនេះគឺអ្វី ? គឺ ការឧប្បត្តិដែលត្រូវប្រែប្រួលទៅ ក្នុងកាលមានការប្រជុំគ្នានៃបច្ច័យដែលជាសត្រូវ មានភាពត្រជាក់ជាដើម ។ម្យ៉ាងទៀត ភាពជាហេតុនៃការឧប្បត្តិប្រែប្រួលទៅនៃរូបធម៌ដែលមានហើយនោះ ក្នុងកាលមានការប្រជុំគ្នានៃបច្ច័យដែលជាសត្រូវ មានភាពត្រជាក់ជាដើមនោះ ឈ្មោះថា **ការបែកធ្លាយ** ។ ពាក្យថា **ព្រោះមិនកន្លងផុត** គឺ ព្រោះមិនលះបង់ ។

ក៏ឈ្មោះថា ភាពប្រាកដជារបស់ធំក្នុងទីនេះ បណ្ឌិតគប្បីជ្រាបដោយទាក់ទង

នឹងសម្ភារធាតុ ជាភូតមានវិការធំ ក៏យ៉ាងនោះ គប្បីជ្រាបដោយការទាក់ទងនឹងធាតុ គឺ លក្ខណៈដែលដូចគ្នានៃមហាភូត ។ ការមានការបរិហារច្រើន និងការប្រាកដ ភាពធំ គប្បីជ្រាបតាមរយៈធាតុទាំងពីរ( សសម្ភារធាតុ និងលក្ខណធាតុដូច្នេះ )។ ព្រោះសំដៅដល់ **ភូត**-ស័ព្ទ ទើបមានពាក្យសម្តែងខែជានបុំសកលិង្គថា **ឯតានិ** ។ ឈ្មោះថា **ប្រាកដជារបស់ធំ** ព្រោះធ្វើវត្ថុទាំងឡាយដែលមិនអាចរាប់បរិមាណបាន និងដែលមានភាពវែងឆ្ងាយ ភាពទូលំទូលាយច្រើនយោជន៍ឲ្យកើតឡើង ដោយ អំណាចការរួមគ្នា និងដោយអំណាចការបន្តគ្នា ដោយការរួមគ្នានៃរូបកលាបៈច្រើន សែនកលាបៈ ។ សេចក្តីថា **ចត្តារិ នហុតានិ** ប្រែថា ៤០០០០ ។ ប្រាកដជា របស់ធំ ព្រោះជាសរីរៈកម្ពស់ ៣ គាវុតជាដើម នៃទេវតា និងទានវៈជាដើម ។

តទៅនេះជាអត្ថន័យរបស់ពាក្យ ក្នុងពាក្យថា **មហាភូតនោះ** ឈ្មោះថា មហា ភូត ព្រោះអត្ថថា ប្រាកដ គឺ កើត បង្កើតជារបស់ធំ ។ នាយមាយាការ ( អ្នក លេងល្បិច ) ឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាបុគ្គលដែលមានវត្ថុគួរចម្លែកចិត្ត ជាច្រើន ឬថា វត្ថុដែលមិនមានពិតជាច្រើន ដោយអំណាចការធ្វើវត្ថុគួរអស្ចារ្យ ច្រើនយ៉ាងឲ្យប្រាកដដោយការធ្វើវត្ថុប្លែកៗ ច្រើនយ៉ាងឲ្យប្រាកដ និងដោយការធ្វើ វត្ថុគួរចម្លែកចិត្តច្រើនយ៉ាងឲ្យប្រាកដ ។ សត្វទាំងឡាយ មានយក្ខជាដើម ឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាភូតដែលធំក្រៃលែង ដោយអំណាចនៃជាតិនោះឯង , ម្យ៉ាងទៀត គប្បីឃើញថា **មហាភូត**-ស័ព្ទនេះ ជាស័ព្ទនិយមប្រើក្នុងស័ព្ទទាំងនោះ ។ ចំណែកធាតុទាំងឡាយ មានបឋវីធាតុជាដើម ប្រាកដដូចមហាភូត ព្រោះ ជាវត្ថុបោកបញ្ឆោត និងព្រោះជាវត្ថុមានទីតាំង ដែលមិនអាចបញ្ជាក់បាន ទើប ឈ្មោះថា **មហាភូត** ។ ព្រោះភាពដែល **មហាភូត**-ស័ព្ទ មានពីរលិង្គ ទើបលោក

ធ្វើឲ្យជានបុំសកលិង្គ ។ ក្នុងអត្ថទាំងពីរនោះ ឈ្មោះថា ភាពជាវត្ថុបោកបញ្ឆោត មានសេចក្តីថា ខ្លួនឯងជាសភាវៈដែលមិនមានពណ៌ខៀវជាដើមឡើយ ក៏ធ្វើសភាវៈ ដែលមានពណ៌ខៀវជាដើមឲ្យប្រាកដ និងជាសភាវៈរកស្រី រកប្រុសមិនបានឡើយ ក៏ធ្វើអាការដែលជាស្រី ជាប្រុសជាដើមឲ្យប្រាកដ ។ យ៉ាងនោះដូចគ្នា ឈ្មោះថា ភាពជាវត្ថុដែលមានទីតាំង ដែលមិនអាចបញ្ជាក់បានក៏ដោយ ការដែលធាតុទាំងឡាយដែលតាំងនៅខាងក្នុង និងខាងក្រៅនៃគ្នានិងគ្នាមិនបាននោះ បានអាស្រ័យគ្នានិងគ្នាហើយ ក៏មានការប្រាកដឡើង ។ សេចក្តីពិតថា ធាតុពួកនេះ បើថា តាំងនៅខាងក្នុងនៃគ្នានិងគ្នាបានសោត ក៏មិនគប្បីធ្វើកិច្ចរបស់ខ្លួនបាន ព្រោះការដែលជ្រួតជ្រាបទៅក្នុងគ្នានិងគ្នា , ប្រសិនបើ តាំងនៅខាងក្រៅនៃគ្នានិងគ្នាបាន នឹងជាវត្ថុបែកពីគ្នា , កាលបើយ៉ាងនោះ វាទៈថា ជាវត្ថុដែលមិនបែកគ្នា ក៏គប្បីប្រើមិនបាន ព្រោះដូច្នោះ ទើបជាវត្ថុមានទីតាំងដែលមិនអាចបញ្ជាក់បាន ។ សូម្បីជាយ៉ាងនេះ ធាតុទាំងឡាយក៏នៅឧបការគ្នា ធាតុ ១ ឧបការដល់ធាតុ ៣ ដ៏សេសបាន ដោយកិច្ចពិសេសរបស់ខ្លួន មានភាពជាទីតាំងជាដើម ជាកិច្ចពិសេស ដែលជាហេតុឲ្យធាតុទាំងឡាយ ជាបច្ច័យដោយសហជាតបច្ច័យជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា តែថា វាមិនអាស្រ័យគ្នានិងគ្នាប្រាកដឡើងក៏ទេ ។ ពាក្យថា **ដែលគួរពេញចិត្ត** គឺ ដែលគួរចាប់ចិត្ត បានដល់ដែលគួរស្នេហា ។ ពាក្យថា **ដោយឆវីវណ្ណ ទ្រង់ទ្រាយ និងអាការកែក្រាយ** គឺ ដោយពណ៌សម្បុរ ដែលមានពណ៌ទឹកត្នោតជាដើម ។ ដោយទ្រង់ទ្រាយមាំមួន ស្តើង និងស្គមជាដើម ឬ ដោយអាការកែក្រាយនៃដៃ និងចិញ្ចើមជាដើម ។ បទថា **សរសលក្ខណំ** គឺ លក្ខណៈដែលជាសភាវៈ ឬសភាវៈព្រមទាំងកិច្ច ។

លោកអាចារ្យកាលនឹងពោលដល់អត្ថន័យរបស់ពាក្យ ក្នុងពាក្យថា ព្រោះមានការបរិហារច្រើននេះ ទើបពោលថា ព្រោះត្រូវបរិហារដោយបច្ច័យទាំងឡាយជាច្រើន ។ល។ ឬឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាភូតដែលមានការបរិហារច្រើន ដូច្នេះ ។ ក្នុងអត្ថន័យរបស់ពាក្យទាំងនោះ ក្នុងបទដំបូង ក្នុងអត្ថន័យក្រោយ ( គឺបទថា **មហាបរិហារានិ** ) លោកលុប **បរិហារ**-ស័ព្ទ ដែលជាបទក្រោយចេញ ហើយពោលថា **មហាភូតានិ** ដូច្នេះ ។

ពាក្យថា **ពិតដូចដែលពោលនោះ** មានន័យថា លោកអាចារ្យប្រាថ្នាសម្ដែងវិការនោះថា ព្រោះហេតុនោះៗឯង គឺ ព្រោះមានវិការធំនោះឯងដូច្នេះ ទើបពោលថា ( កាលលោកត្រូវភ្លើងឆេះ ។ ល ។ អណ្ដាតភ្លើងរមែងឆេះឡើង ) អំពីផែនដីដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អច្ចិមតោ** កែជា **អគ្គិស្ស**-នៃភ្លើង ។ ចក្កវាឡមួយសែនកោដិ ឈ្មោះថា **កោដិសតសហស្សេកំ ចក្កវាឡំ** លោកពោលរួមសែនកោដិចក្រវាឡទាំងអស់នោះតែ ១ ដោយភាពជាអាណាខេត្ត ១ ។ ពាក្យថា **រមែងវិនាសទៅ** បានដល់ ការវិនាស គឺ បែកធ្លាយទៅ ព្រោះភ្លៀងធ្វើឲ្យវិបត្តិ ( ភ្លៀងទឹកក្រុត ) ធ្លាក់ចុះមក ដូចអំបិលដែលដល់ភាពវិនាសទៅព្រោះទឹកក្បុង ។ បទថា **កុប្បិតេន** ប្រែថា កម្រើក ។ ពាក្យថា **រមែងខ្ចាត់ខ្ចាយទៅ** បានដល់ រមែងរាត់រាយទៅ គឺ បែកធ្លាយទៅ ។

លោកអាចារ្យ កាលសម្ដែងភាពជារបស់មានវិការធំ ក្នុងមហាភូតដែលជាអនុបាទិន្នទាំងឡាយហើយ កាលនឹងសម្ដែងមហាភូតដែលជាឧបាទិន្នទាំងឡាយទើបពោលថា **បត្ថទ្ធោ** រឺងជាដើម ។ ក្នុងបទទាំងនោះ **វា**-ស័ព្ទ ក្នុងពាក្យថា **កដ្ឋមុខេន វា** មានសេចក្ដីជា **ឧបមា** ។ ការប្រៀបធៀបដូចជារាងកាយដែលត្រូវ

ពស់មាត់ឈើខាំ រមែងត្រូវរឹងទៅ យ៉ាងណា រាងកាយនោះ ព្រោះការកម្រើកនៃបឋវីធាតុ ក៏រមែងដូចជានៅក្នុងពស់មាត់ឈើ គឺ រមែងត្រូវរឹងដូចពស់មាត់ឈើខាំដូច្នោះ ។ ន័យម្យ៉ាងទៀត វា-ស័ព្ទ មានសេចក្តីថា កំណត់សេចក្តី ។ គប្បីនាំ វា-ស័ព្ទ នោះមកសម្ព័ន្ធសេចក្តីយ៉ាងនេះថា **បឋវីធាតុប្បកោបេន វា** ដូច្នេះ ។ ក្នុងពាក្យនេះទើបមានសេចក្តីដូច្នេះថា រាងកាយសូម្បីថា ត្រូវពស់មាត់ឈើខាំ នឹងត្រូវរឹងបាន ក៏ព្រោះការកម្រើកនៃបឋវីធាតុនោះឯង ។ ព្រោះដូច្នោះ រាងកាយនោះដែលមិនផ្សេងអំពីបឋវីធាតុនោះ ទើបដូចជាត្រូវពស់មាត់ឈើខាំជានិច្ចកាលដូច្នេះ ។ ម្យ៉ាងទៀត វា-ស័ព្ទ មានសេចក្តីមិនកំណត់ពិតប្រាកដ ក្នុងពាក្យនោះ ទើបមានសេចក្តីដូច្នេះថា រាងកាយដែលត្រូវពស់មាត់ឈើខាំ នឹងត្រូវរឹងទៅក៏ដោយ ឬមិនត្រូវរឹងទៅដោយអំណាចការរាយមន្តក៏ដោយ តែព្រោះការកម្រើកនៃបឋវីធាតុ រាងកាយដែលប្រាសចាកពាក្យរាយមន្តនោះ ក៏រមែងត្រូវរឹងទៅបានផងដែរ ដូចត្រូវពោះមាត់ឈើខាំដូច្នោះ ដូច្នេះឯង ។

ពាក្យថា **ស្អុយរលួយ** គឺ ក្រមរឃូន់ ។ ពាក្យថា **ក្តៅរោលរាល** គឺ ក្តៅទូទាំងខ្លួន បានដល់ កើតការក្តៅឡើង ។ ពាក្យថា **បែកធ្លាយ** គឺ បែកធ្លាយទៅដោយជុំវិញ ជាកំទេចផង់ ដោយបែកជាចំណែកល្អិតក្រៃលែង ដូចសរីរៈរបស់ឧបសេនត្ថេរ ដូច្នោះ ។ សេចក្តីថា **មហាវិការានិ ភូតានិ** ប្រែថា ភូតដែលមានវិការធំ ។ បទថា **មហាភូតានិ** គប្បីឃើញថា ជាពាក្យសម្តែងខែ ដោយលុបបទចុង ( គឺបទថា **វិការានិ** ) ក្នុងបទដើម ( គឺបទថា **មហាវិការានិ** ) ។ ក្នុងការដែលព្រះយោគីលះវិបល្លាសចេញហើយ កំណត់កាន់យកភូតទាំងឡាយ សូម្បីប្រាកដដល់សត្វទាំងពួង ដោយឈ្មោះថា **បឋវី** ( ដី ) ជាដើម តាមសេចក្តីពិត

វៀរសេចក្ដីព្យាយាមដ៏ធំក្រៃលែងចេញហើយ ក៏មិនអាចកាន់យកបានទេ ព្រោះហេតុនោះទើបលោកហៅថា **មហន្តានិ** ( ធំក្រៃលែង ) ព្រោះមានសភាវៈដែលគប្បីដឹងបានដោយកម្រ ។ ពិតមែន ភូតទាំងនោះជាធម្មជាតិដែលគប្បីដឹងបានដោយកម្រ បុគ្គលអ្នកឈរគិតថា មិនធំក្រៃលែង លុះបានឃើញភាវៈដែលភូតទាំងនោះជារបស់កំណត់កាន់យកបានដោយកម្រ ក៏រមែងដឹងថា ឱ ភូតទាំងនេះ ធំក្រៃពេកហ្ន៎ដូច្នេះ , មួយ៉ាងទៀត ធាតុ ៤ ឈ្មោះថា **មហាភូត** ព្រោះហេតុទាំងឡាយមានភាពជាចំណែកមួយនៃខន្ធ ៥ ដែលឈ្មោះថា មហាភូតជាដើម ។ ពិតមែនធាតុទាំងនេះ លោកហៅថា **មហាភូត** ព្រោះហេតុទាំងឡាយនេះ គឺ ព្រោះជាចំណែកមួយនៃខន្ធ ៥ ដែលឈ្មោះថាមហាភូត ព្រោះដូចគ្នានឹងមហាភូត ( កន្លែងដែលមានវត្ថុផ្សេងៗ ជាច្រើន ) ព្រោះជាទីអាស្រ័យនៃភូត សត្វទាំងឡាយដែលធំក្រៃលែង ឬជាច្រើន ព្រោះភាពជាវត្ថុមានដោយច្រើន និងព្រោះដល់នូវការអស់រលត់ទៅក្នុងព្រះអរហន្ត អ្នកជាមហាភូតដូច្នេះ ។

ក្នុងបណ្ដាហេតុទាំងនោះ ពាក្យថា **ព្រោះជាចំណែកមួយនៃខន្ធ ៥ ដែលឈ្មោះថាមហាភូត** មានសេចក្ដីថា ខន្ធ ៥ ទ្រង់ត្រាស់ហៅថា ភូតដោយមិនប្លែកគ្នាក្នុងប្រយោគថា **ភូតមិទន្តិ ភិក្ខវេ សមនុបស្សថ** ( ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរតាមពិចារណាមើលថា វត្ថុនេះជាភូតចុះ ) ដូច្នេះជាដើម ។ ក្នុងពាក្យថា **ខន្ធ ៥ ទ្រង់ត្រាស់ហៅថា ភូតនោះ** មានន័យថា ខន្ធដែលប្រព្រឹត្តទៅក្នុងកាមភព រូបភព ឬបញ្ចវោការភព និងក្នុងសញ្ញីភពជាចំណែក ខ្វះនេះឯណា ខន្ធ ៥ នោះ រមែងគួរដល់ភាពជារបស់គួរនឹងហៅថា **មហាភូត** ព្រោះមានវិស័យ ( ព្រំដែន គឺ ភពទាំងឡាយ ) ច្រើន ។ ក៏ធាតុ ៤ មានបឋវីធាតុជាដើម ជាចំណែកមួយនៃខន្ធ ៥

ដែលឈ្មោះថា **មហាភូតនោះ** ទើបហៅថា **មហាភូត** ពិតមែន វោហារដែលប្រព្រឹត្ត ទៅក្នុងចំណែករួម ក៏នៅឃើញប្រើ សូម្បីក្នុងចំណែករាយទាំងឡាយ ដូចពាក្យថា ទន្លេដែលបានឃើញ និងថា សំពត់ដែលត្រូវភ្លើងឆេះដូច្នោះ ។ ពាក្យថា **ព្រោះដូចគ្នានឹងមហាភូត** ( កន្លែងដែលមានវត្ថុផ្សេងៗ និងមានឧបការច្រើន ) មានសេចក្តីថា ធាតុ ៤ មានបឋវីធាតុជាដើម ឈ្មោះថា **ភូត** ព្រោះអត្ថថា ជាទីដែលមានឧបាទាយរូបទាំងឡាយ ដោយការប្រព្រឹត្តទៅជាមួយធាតុ ៤ នោះ ។ សមញ្ញាថា **ភូតនេះនោះ** រមែងបានក្នុងធាតុ ៤ ពួក នេះ ព្រោះឧបាទាយរូបទាំងមិនវិបរិតទៅ ក៏ព្រោះការដែលមិនប្រព្រឹត្តទៅក្នុងវត្ថុដទៃៗ , ធាតុ ៤ នេះមានឧបការច្រើនដល់សត្វលោក និងជាទីអាស្រ័យនៃឧបាទាយរូបទាំងឡាយ មានចក្ខុជាដើម និងវត្ថុទាំងឡាយ មានសមុទ្រជាដើម ព្រោះហេតុនោះ ទើបមានសមញ្ញាថា **មហាភូត**។ ពាក្យថា **ព្រោះជាទីអាស្រ័យនៃភូត សត្វទាំងឡាយអ្នកជាំក្រៃលែង ឬជាច្រើន** មានសេចក្តីថា ធាតុ ៤ ឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាទីដែលមានភូតទាំងឡាយជាច្រើន ព្រោះមានភាពជាទីអាស្រ័យនៅនៃភូត គឺសត្វទាំងឡាយ ចាប់ផ្តើមអំពីព្រះបាទមហាសម្មតិ និងព្រះបាទមន្ធាតុ ព្រះបាទទេវរាជាទាំងឡាយ មានសក្កទេវរាជជាដើម ពួកអសុរទាំងឡាយ មានព្រះបាទវេបចិត្តិជាដើម , ពួកព្រហ្មទាំងឡាយ មានមហាព្រហ្មជាដើម ដែលជាអ្នកធំក្រៃលែង គឺមានអានុភាពច្រើន ឬថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះសាវកទាំងឡាយ ដែលជាអ្នកធំក្រៃលែងដោយគុណធម៌ ដោយការប្រៀបផ្ទឹមគ្នា ឬថា សត្វសូម្បីគ្រប់ជំពូក ។ ព្រោះថា រាងកាយរបស់សត្វទាំងនោះ ប្រកបដោយមហាភូត ៤ ។ ពាក្យថា **ព្រោះភាពជាវត្ថុដែលមានច្រើនប្រការ** គឺ ព្រោះភាពជា

វត្ថុមានប្រាកដច្រើនប្រការ ។ ក៏មហាសត្វនេះ ឃើញប្រើក្នុងសេចក្ដីជាវត្ថុមានជាច្រើន ក្នុងប្រយោគថា **មហាជនោ សន្និបតិតោ** ( មហាជនប្រជុំគ្នា ) ដូច្នេះជាដើម ។ ធាតុទាំងឡាយ មានបឋវីធាតុជាដើម សូម្បីក្នុងអត្តភាពមួយ ក៏រមែងប្រព្រឹត្តទៅមានប្រភេទមិនអាចរាប់បាន ។ ព្រោះដូច្នោះ ទើបឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាវត្ថុដែលមានប្រាកដច្រើនប្រការ គឺច្រើនយ៉ាង បានដល់ មានច្រើនសែនប្រភេទ ។ ពាក្យថា **ព្រោះរលត់ទៅក្នុងព្រះអរហន្ត អ្នកជាមហាភូត** គឺព្រោះដល់នូវការអស់ទៅដោយអំណាចនៃព្រះអរហន្ត អ្នកជាមហាភូត ។

ពិតហើយ ទ្រង់ហៅ ព្រះខីណាស្រពថា **ភូត** ក្នុងប្រយោគមានយ៉ាងនេះថា **កាលវេលារមែងទំពាស៊ីភូត ( សត្វ ) ទាំងឡាយ ព្រមទាំងខ្លួនរបស់វា កន្លងអស់ទៅ រីឯ អ្នកជាភូតនោះ ព្រះអរហន្តទំពាស៊ីពេលវេលា លោកជាភូតនោះបានដុតហើយនូវតណ្ហា អ្នកដុតរោលភូត ( សត្វ )** ដូច្នេះជាដើម ។ សេចក្តីពិតថា ព្រះខីណាស្រព ទ្រង់ហៅថា **ភូត** បានដោយចំណែកមួយ ព្រោះជាអ្នកមិនបដិសន្ធិក្នុងភពតទៅឡើយ ព្រោះបានកាត់ផ្តាច់តណ្ហាដែលជាគ្រឿងនាំឆ្ពោះទៅកាន់ភពបានហើយ បុគ្គលទាំងឡាយក្រៅពីនេះ មិនហៅថាភូតទេ ព្រោះមិនទាន់កន្លងវោហារទៅបាន ។ **ភូត** គឺ ព្រះអរហន្តនោះឯង ហៅថា **មហាភូត** ក្នុងទីនេះដោយអំណាចការបូជា ដូចដែលហៅថា មហាខីណាស្រព និងហៅថា មហាមោគ្គល្លានដូច្នោះ ។ ធាតុទាំងឡាយ ដែលប្រព្រឹត្តទៅដោយអំណាចការជាប់ជំពាក់នៅក្នុងសង្សារវដ្តដែលមិនមានទីបំផុតខាងដើម រមែងមានការរលត់អស់ទៅ ក្នុងសន្តានរបស់លោក ដែលជាមហាភូត តាមដែលពោលមកហើយនេះឯង មិនមែនក្នុងទីដទៃទេ ។ ព្រោះដូច្នោះ ទើបឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាភូត គឺ ដល់នូវ

ការរលត់អស់ទៅក្នុងលោកដែលជាមហាភូត ព្រោះធ្វើការលុប **ភូត-ស័ព្ទ** ក្នុងបទដើមចេញមួយស័ព្ទ ( **មហាភូតេ ភូតា បរិយោសានំ បត្តាតិ មហាភូតា** ) ។ គប្បីជ្រាបថា ធាតុទាំងនេះ ឈ្មោះថា **មហាភូត** ព្រោះហេតុទាំងឡាយ មានភាពជាចំណែកមួយនៃខន្ធ ៥ ដែលឈ្មោះថា **មហាភូត** ជាដើម តាមប្រការដូចពោលមកនេះចុះ ។ សេចក្ដីព្រមព្រៀងដោយវិសេសលក្ខណៈ មានភាពរឹង និង ការហូរជ្រាបជាដើមនៃធាតុទាំងឡាយ មានបឋវីធាតុជាដើម រមែងមានដល់វត្ថុដែលមិនលះបង់លក្ខណៈដែលជាធាតុទាំងឡាយប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះមិនកន្លងផុតលក្ខណៈដែលជាធាតុដូច្នេះ ។ វិសេសលក្ខណៈនឹងមានដោយការវៀរចាកសាមញ្ញលក្ខណៈក៏ទេ ម្យ៉ាងទៀត សាមញ្ញលក្ខណៈនឹងប្រព្រឹត្តទៅ មិនសំដៅដល់វិសេសលក្ខណៈក៏ទេ ។ ពិតយ៉ាងនោះ បោរាណាចារ្យទាំងឡាយ ពោលថា :

វត្ថុដែលមានសាមញ្ញលក្ខណៈ រមែងមិនវៀរចាកលក្ខណៈ ដែលផ្សេងគ្នា ( វិសេសលក្ខណៈ ) ព្រោះមានការសំដៅដល់តួសភាវៈនោះ វត្ថុដែលជាសភាវៈធម៌ដូចគ្នា រមែងកាន់យកលក្ខណៈទាំងពីរនោះឯង ព្រមទាំងខ្លួនឯងកើតឡើងដូច្នេះ ។

ពាក្យថា **ដោយការទ្រទ្រង់លក្ខណៈរបស់ខ្លួនទុក** មានសេចក្ដីថា ហៅថាធាតុ ដោយការទ្រទ្រង់លក្ខណៈរបស់ខ្លួនទុកឯណា សូម្បីហៅថា **ធម៌** ក៏ដោយការទ្រទ្រង់លក្ខណៈរបស់ខ្លួនទុកនោះៗឯង , ព្រោះទាំងពីរប្រការ ( គឺធាតុ និងធម៌ ) ជាពាក្យបើកបង្ហាញដល់ភាពជាវត្ថុដែលមិនមែនសត្វ មិនមែនជីវៈ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ទុកថា **ឆធាតុរោយំ ភិក្ខុ បុរិសោ** ម្នាលភិក្ខុ បុរសនេះមានធាតុ

៦ នឹងថា **ធម្មេសុ ធម្មានុបស្សី វិហរតិ** រមែងជាអ្នកតាមពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ដូច្នេះ ។ ព្រោះការដែលរូបទាំងឡាយពោលដោយលក្ខណៈដ៏សមគួរ ក៏មានលក្ខណៈដែលតិចតួចពេក កាលប្រៀបធៀបនឹងនាមធម៌ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា តាមសមគួរដល់ខណៈរបស់ខ្លួនដូច្នេះៗ ពាក្យថា **ព្រោះការទ្រទ្រង់ទុក** គឺ ព្រោះការតាំងទុក មានសេចក្តីថា ព្រោះការធ្វើឲ្យប្រព្រឹត្តទៅ ។ ពាក្យថា **ព្រោះអត្ថថា អស់ទៅ** គឺព្រោះការដែលអស់ទៅ គឺ បែកធ្លាយទៅ ។ ពាក្យថា **ព្រោះអត្ថថា ជាភ័យ** គឺព្រោះការដែលមានភ័យចំពោះមុខដោយការបៀតបៀន ដោយការកើតឡើង និងប្រាសទៅ ។ ពាក្យថា **ព្រោះអត្ថថា មិនមានសារៈ** គឺ ព្រោះវៀរចាកអត្តសារៈ ។

ពាក្យថា **បណ្តាធាតុទាំងឡាយ ដែលកើតរួមគ្នាទាំងនេះនោះឯង** គឺបណ្តាធាតុ ៤ ដែលកើតព្រមគ្នាទាំងនេះនោះឯង គឺប្រព្រឹត្តទៅព្រមគ្នានោះឯង ទោះបីជាបាននៅក្នុងវេលាដូចគ្នា ក៏ឈ្មោះថា ជារបស់មិនបែកគ្នាដែលជាចំណែកៗ សូម្បីក្នុងកលាបៈយ៉ាងទាបបំផុត ដោយកំណត់យ៉ាងទាប មានសុទ្ធដ្ឋកកលាបៈជាដើមមួយកលាបៈៗ គឺ ក្នុងសុទ្ធដ្ឋកកលាបៈ បណ្តាកលាបៈ មានឧតុ ចិត្ត និងអាហារជាសមុដ្ឋានទាំងឡាយ ក្នុងជីវិតនវកកលាបៈ ក្នុងបណ្តាកលាបៈដែលកើតអំពីកម្មទាំងឡាយ ព្រោះជាទីតាំងដែលមិនអាចបែកពីគ្នាបាន ។ ពិតហើយ ទីណាមានបឋវីធាតុ ដោយភាពជាទីតាំងនៃធាតុ ៣ ទីនោះៗឯង ក៏មានធាតុដទៃតាមរយៈការជ្រួតជ្រាប កម្តៅ និងការធ្វើឲ្យកម្រើកនៃបឋវីធាតុនោះៗឯង ។ សូម្បីក្នុងធាតុដ៏សេសក៏មានន័យដូច្នេះដែរ ។

អធិប្បាយថា **ធាតុ ២ ខាងដើម** ឈ្មោះថា ជាសភាគៈដល់គ្នានិងគ្នា ព្រោះ

ជាធាតុធ្ងន់ សួរថា ក្នុងធាតុ ២ យ៉ាងនោះ សូម្បីក្នុងបឋវីធាតុ ក៏មានភាពស្រាល បាន ( មិនមែនឬ ? ) ។ ពិតយ៉ាងនោះ បឋវីធាតុនោះ ទ្រង់សម្ដែងខែទុកថា ដែលរឹង ដែលទន់ ដែលល្អិត ដែលគ្រោតគ្រាត ដែលធ្ងន់ ដែលស្រាល ដូច្នេះ សូម្បីក្នុងអាបោធាតុក៏មានភាពស្រាលបានមិនមែនឬ ? ឆ្លើយថា មិនមានភាព ស្រាលទេ ព្រោះលោកប្រាថ្នាយកភាពធ្ងន់ ដោយនិប្បរិយាយ ។ ការពិតថា ភាព ធ្ងន់នោះឯង កាលប្រៀបផ្ទឹមនឹងបឋវីធាតុដែលធ្ងន់ជាងហើយ ក៏ពោលបានដោយ បរិយាយថា ភាពស្រាល ដូចគ្នានឹងភាពត្រជាក់នៃតេជោធាតុដូច្នោះ ។ ប្រសិនបើ យ៉ាងនេះ ពាក្យថា **រូបស្ស លហុតា** ( ភាពស្រាលនៃរូប ) តើដូចម្ដេច ? ឆ្លើយថា សូម្បីភាពស្រាលនៃរូបនេះ ក៏មានន័យដូចដែលបានពោលមកហើយ នោះឯង ព្រោះមានដោយការប្រៀបផ្ទឹមនឹងអាការដែលស្រាល ( គួរនឹងថាដោយ ការប្រៀបផ្ទឹមនឹងអាការដែលធ្ងន់ជាង ) ។ ពិតមែន **បរិច្ឆេទរូប វិការរូប** និង លក្ខណរូបទាំងឡាយ រមែងមិនមានដោយបរមត្ថ ព្រោះត្រឹមតែជាវិការខុសប្លែក គ្នានៃនិប្ផន្នរូបទាំងឡាយ ។ ព្រោះដូច្នោះ លោកកំណត់យកភាពធ្ងន់ ដែលសម្រេច ដោយបរមត្ថ ទើបពោលថា ធាតុ ២ ខាងដើម ឈ្មោះថា សភាគៈគ្នា ព្រោះ ជាធាតុធ្ងន់ ។ ដោយបទថា យ៉ាងនោះដូចគ្នា លោកប្រៀបធៀបដល់ប្រការដែល ថាជា សភាគៈគ្នានេះ ។ បទថា **ទ្វេ ( ធាតុ ២ ) នេះ** គប្បីនាំចូលមកសម្ព័ន្ធក្នុង បទថា **បច្ឆិមា** ខាងចុងនេះ ដូចដែលនាំមកសម្ព័ន្ធនឹងបទថា **បុរិមា** ខាងដើមនេះចុះ ។ អធិប្បាយថា ឈ្មោះថា ជាវិសភាគៈគ្នា ក៏ព្រោះជាធាតុធ្ងន់ និងជាធាតុស្រាល។ គប្បីប្រកបភាពជាសភាគៈគ្នា និងភាពជាវិសភាគៈគ្នា ដោយសភាវៈទាំងឡាយ ដូច ដែលប្រកបទុកដោយភាពជាធាតុធ្ងន់ និងធាតុស្រាល ដូច្នេះចុះ ។

ធាតុទាំងឡាយឈ្មោះថា ជាខាងក្នុង គឺជាខាងក្នុងដូចដែលពោលមកហើយក្នុងខាងដើម មានន័យថា ទាក់ទងក្នុងសន្តានរបស់សត្វ ។ ពាក្យថា **នៃវត្ថុរបស់វិញ្ញាណ វិញ្ញត្តិ និងឥន្ទ្រិយទាំងឡាយ** គឺ នៃវត្ថុរបស់វិញ្ញាណ ៦ មានចក្ខុវត្ថុជាដើម , នៃវិញ្ញត្តិ ២ និងនៃឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ និងជីវិតិន្ទ្រិយ ។ ចំណែកអាចារ្យពួកណាពោលថា ពាក្យថា **វត្ថុនៃវិញ្ញាណ** គឺ លោកកាន់យកហទយវត្ថុដូច្នេះ ដោយស័ព្ទថា **ឥន្ទ្រិយ** គប្បីជ្រាបថា លោកអាចារ្យទាំងនោះ កាន់យកឥន្ទ្រិយដែលជារូបទាំង ៨ ( បានដល់ បសាទរូប៥ ភាវៈ២ ជីវិត១ ) ។ លោកពោលពាក្យថា មានប្រការផ្ទុយគ្នាតាមដែលពោលមកហើយ ធ្វើអធិប្បាយថា ធាតុខាងក្រៅទាំងឡាយមានបរិយាយខុសប្លែកគ្នានឹងធាតុខាងក្នុង ដែលបានពោលមកហើយ គឺមិនមែនជាទីអាស្រ័យនៃវត្ថុរបស់វិញ្ញាណ វិញ្ញត្តិ និងឥន្ទ្រិយទាំងឡាយទេ និងប្រាសចាកឥរិយាបថដោយប្រការទាំងពួងយ៉ាងណា ក៏មានបរិយាយផ្ទុយគ្នានឹងធាតុខាងក្នុងដែលបានពោលមកហើយ គឺ ជាធាតុ ដែលមានធាតុ ៤ យ៉ាងជាសមុដ្ឋាន ដូច្នោះ តែនឹងមិនជាធាតុ ដែលមានធម៌ ៤ យ៉ាង ជាសមុដ្ឋាន ព្រោះមិនមានសមុដ្ឋានពីធម៌ណាៗដូចជាលក្ខណរូប ក៏មិនមែន ព្រោះធាតុខាងក្រៅពួកនោះ មានឧតុជាសមុដ្ឋាន ។ សម្រាប់ធាតុដែលជាខាងក្នុងទាំងឡាយ គួរពោលដល់ភាពជាទីអាស្រ័យនៃលហុតារូបជាដើមខ្លះ ឬ មិនត្រូវពោលដល់ ។ ការកាន់យកវិញ្ញត្តិបាន ជាប្រការដែលគួរកំណត់ ។

ពាក្យថា **ធាតុ ( ដែលមានកម្មជាសមុដ្ឋាន ) ក្រៅពីនេះ** បានដល់ អាបោធាតុ តេជោធាតុ និង វាយោធាតុ ។ ពាក្យថា **មានការរួមចូលជាមួយគ្នា** គឺមានការរួមចូលជាមួយគ្នាដោយសជាតិសង្គហៈ ។ ការរួមយកធម៌ទាំងឡាយដែលមានជាតិ

ស្មើគ្នា ចូលជាមួយគ្នា ហៅថា **សជាតិសង្គហៈ** ។ ព្រោះហេតុនោះ ទើបលោក ពោលថា ព្រោះមិនមានភាពផ្សេងគ្នានៃសមុដ្ឋាន ដូច្នេះ ។

ពាក្យថា **រមែងជាបច្ច័យដែលជាទីតាំងនៃមហាភូត ៣** មានសេចក្តីថា ដែល មហាភូតរូបពួកណាប្រមូលផ្តុំហើយ ដោយអំណាចការរួបរួមទុក ។ តាមរក្សា ហើយដោយអំណាចការធ្វើឲ្យក្តៅ ( បន្ទុំ ) , និងទល់ទ្រហើយ ដោយអំណាច ការធ្វើឲ្យកម្រើក រមែងជាទីអាស្រ័យនៃមហាភូតទាំងនោះ តាមរយៈជាទីទ្រទ្រង់ ជាទីតាំងនៃមហាភូត ៣ ដែលកើតរួមគ្នានឹងខ្លួននោះឯង ឬថា រមែងជាបច្ច័យដោយ អំណាចនៃសហជាតប្បច្ច័យជាដើម ដែលជាទីតាំងតាមន័យដូចដែលបានពោលមក ហើយ ដូច្នេះឯង ។ សូម្បីក្នុងធាតុដ៏សេស ក៏មានន័យដូច្នេះ ។

លោកអាចារ្យបានសម្តែងដល់ភាពដែលធាតុទាំងឡាយ មិនមានការនឹកដល់ គ្នាទុកក្នុងខាងដើមថា ធម៌ទាំងនេះប្រាសចាកការត្រិះរិះដល់ និងការពិចារណា ដល់គ្នានិងគ្នា ដូច្នេះហើយក៏ពិត សូម្បីយ៉ាងនោះ កាលនឹងសម្តែងថា គួរធ្វើការ កំណត់កាន់យកកម្មដ្ឋានជាអាការមួយទៀត ដោយន័យនេះ ទើបលោកពោលថា ក៏ក្នុងបណ្តាធាតុពួកនេះ បឋវីធាតុដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ច-ស័ព្ទ ក្នុង ពាក្យថា **បឋវីធាតុ ចេត្ថ** មានអត្ថថា រួបរួម ( ក្នុងទីនេះ ប្រែថា ម្យ៉ាងទៀត ) , ដោយ ច-ស័ព្ទនោះ លោកសម្តែងថា សូម្បីសេចក្តីនេះក៏ជាមនសិការប្រការ ១ ។ បទថា **ឯត្ថ** ប្រែថា ក្នុងបណ្តាធាតុទាំងនេះ ។ លោកអាចារ្យកាលសម្តែងដល់ភាព មិនមានការត្រិះរិះដល់ក្នុងកិច្ចរបស់ខ្លួន ដូចគ្នានឹងក្នុងខ្លួនឯងថា រមែងមិនដឹងថា យើងជាបឋវីធាតុខ្លះ ថាយើងជាបច្ច័យខ្លះ ដូច្នេះហើយ ប្រាថ្នាសម្តែងដល់មហា ភូត ៣ ដែលគប្បីឧបការ ក៏មិនមានការត្រិះរិះដល់ ដូចគ្នានឹងបឋវីធាតុដែលជាអ្នក

ឧបការៈ ទើបពោលពាក្យថា **មហាភូត ៣ ដទៃ** ដូច្នេះជាដើម ។ បទថា **សព្វត្ថ** ប្រែថា ក្នុងធាតុទាំងពួង គឺសូម្បីក្នុងធាតុទាំងពួង ក៏មានការដាច់ដោយឡែក(ដោយ) កិច្ចរបស់ខ្លួនអំពីមហាភូតដែលខ្លួនគប្បីឧបការនោះ ។

ពាក្យថា **ដោយការចែកបច្ច័យ** គឺ ដោយការចែកធម៌ដែលជាបច្ច័យនោះឯង និងដោយការចែកភាពជាបច្ច័យ ។ ពិតមែន ដោយពាក្យថា **ដោយបច្ច័យនេះ** លោកពោលដល់ធាតុទាំងឡាយ មានបឋវីធាតុជាដើម ជាបច្ច័យដល់ភូត ៣ ដ៏សេស ដោយភាពជាទីតាំងជាដើម ដែលមិនសាធារណៈដល់ធាតុដទៃៗ ។ ចំណែកក្នុងពាក្យថា **ដោយការចែកបច្ច័យនេះ** មានសេចក្ដីថា ធាតុទាំងឡាយ មានបឋវីធាតុជាដើម និងមានការកើតឡើងបាន ព្រោះធម៌ពួកណា លោកក៏ពោលការចែកធម៌ពួកនោះជាតួបច្ច័យ និងជាបច្ច័យដល់ធាតុទាំងឡាយ មានបឋវីធាតុជាដើម ដោយមិនមានសល់ តាមប្រការដូចពោលមកនេះ ជាភាពផ្សេងគ្នានៃអាការទាំងពីរ( ដោយបច្ច័យ និងដោយការចែកបច្ច័យពួកនេះ ។ ពាក្យថា **កម្ម** បានដល់ កម្ម ដែលជាកុសល និងអកុសល ដែលធ្វើរូបឲ្យកើតឡើងបាន ។ ពាក្យថា **ចិត្ត** បានដល់ ចិត្តយ៉ាងណាមួយដែលធ្វើរូបឲ្យកើតឡើងបាន ។ ពាក្យថា **អាហារ** បានដល់ អាហារខាងក្នុងដែលធ្វើរូបឲ្យកើតឡើងបាន ។ ពាក្យថា **ឧតុ** បានដល់ ឧតុយ៉ាងណាមួយ ដោយសេចក្ដីក៏បានដល់ តេជោធាតុ ។ ពាក្យថា **អវធារណៈ** ( ពាក្យកំណត់សេចក្ដី ) ថា កម្មប៉ុណ្ណោះ លោកពោលទុកដើម្បីសម្ដែងភាពមិនលាយឡំគ្នាដោយសមុដ្ឋាន ដោយពាក្យថា **កម្មប៉ុណ្ណោះ** នុ៎ះជាការដែលលោកសម្ដែងដល់ភាពដែលកម្មជាបច្ច័យដោយបរិយាយ ដល់ភូតប្រភេទខ្លះ សូម្បីដែលមិនបានកើតអំពីកម្ម ។ ពិតយ៉ាងនោះ លោកនឹងពោលថា រូបមានកម្មជាបច្ច័យ មានចិត្តជាសមុដ្ឋាន

ដូច្នេះជាដើម ។ សួរថា ក៏ធម៌ សូម្បីយ៉ាងដទៃអំពីកម្មក៏គប្បីជាបច្ច័យដល់ធាតុដែលមានកម្មជាសមុដ្ឋានទាំងឡាយ មិនមែនឬ ? ឆ្លើយថា គប្បីជាបច្ច័យបាន តែថា ធម៌យ៉ាងដទៃនោះក៏មានការប្រព្រឹត្តទៅ ព្រោះកម្មនោះឯង ព្រោះហេតុនោះ ទើបលោកធ្វើពាក្យនិយាយជាអវធារណៈទុក ដើម្បីហាមធម៌ដែលមានការប្រកបបែកគ្នា ព្រោះហេតុនោះ ទើបលោកពោលថា ធម៌ទាំងឡាយមានចិត្តជាដើមមិនបានជាបច្ច័យដូច្នេះ ។ សូម្បីក្នុងពាក្យថា **ដល់ធាតុដែលមានចិត្តជាដើមជាសមុដ្ឋាននេះ** ក៏គួរនឹងពោលពាក្យអធិប្បាយនេះខ្លះតាមសមគួរ ។ ពាក្យថា **ធម៌ក្រៅពីនេះ** បានដល់ ធម៌ពួកដទៃអំពីចិត្តជាដើម ។ ពាក្យថា **ជនកប្បច្ចយ** លោកពោលសំដៅយកភាពជាធម៌ដែលធ្វើធាតុទាំងឡាយឲ្យកើតឡើង ។ ចំណែក ឈ្មោះថា **បច្ច័យ** គឺ កម្មប្បច្ច័យនោះឯង , ព្រោះព្រះមានព្រះភាគត្រាស់ទុកថា ចេតនាដែលជាកុសល និងអកុសលរមែងជាបច្ច័យដោយកម្មប្បច្ច័យដល់វិបាកខន្ធ និងដល់កដត្តារូប ដូច្នេះ ។

ពាក្យថា **ដល់ធាតុដ៏សេស** គឺ ដល់ធាតុទាំងឡាយដែលមានចិត្តជាដើម ជាសមុដ្ឋាន ។ ពាក្យថា **រមែងជាឧបនិស្សយប្បច្ច័យដោយបរិយាយ** មានសេចក្តីថា ព្រោះក្នុងបករណបដ្ឋាន ឧបនិស្សយប្បច្ច័យមកហើយដល់នាមធម៌ទាំងឡាយប៉ុណ្ណោះ ឧបនិស្សយប្បច្ច័យទើបមិនមានដល់រូបធម៌ទាំងឡាយដោយនិប្បរិយាយ ។ តែគប្បីជ្រាបថា ឧបនិស្សយប្បច្ច័យមិនមាន ដោយវៀរបរិយាយព្រះសូត្រ តាមពាក្យត្រាស់ក្នុងព្រះសូត្រថា **បុគ្គលំ ឧបនិស្សាយ វនសណ្ឌំ ឧបនិស្សាយ** អាស្រ័យនូវបុគ្គលយ៉ាងក្រៃលែង អាស្រ័យយ៉ាងក្រៃលែងនូវព្រៃក្រាស់ ដូច្នេះ ។ ពាក្យថា **ចិត្តរមែងជាជនកប្បច្ច័យ** គឺ ចិត្តដែលមានប្រាកដដែលជាបច្ច័យ ដោយអំណាចនៃ

សហជាតប្បច្ច័យ និស្សយប្បច្ច័យ និងអាហារប្បច្ច័យជាដើម អាស្រ័យភាពជាអ្នកធ្វើឲ្យតាំងឡើង ក៏ពោលបានថា រមែងជាជនកប្បច្ច័យ ។ សូម្បីក្នុងអាហារ និងឧតុ ក៏មានន័យដូច្នេះឯង ។

លោកអាចារ្យកាលសម្តែងការចែកបច្ច័យក្នុងធាតុទាំងឡាយ ដោយអំណាចនៃបច្ចយធម៌ទាំងឡាយ មានកម្មជាដើមយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងការចែកបច្ច័យសូម្បីដោយអំណាចនៃធាតុទាំងឡាយ ដែលមានកម្មជាដើមនោះ ជាសមុដ្ឋាន ទើបលើកឡើងសម្តែងដោយពាក្យថា មហាភូតដែលមានកម្មជាសមុដ្ឋានជាដើម ជាលំដាប់ដំបូងហើយ ទើបសម្តែងខែដោយពាក្យថា បណ្តាធាតុទាំងនោះ បឋវីធាតុដែលមានកម្មជាសមុដ្ឋានដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **បឋវីធាតុដែលមានកម្មជាសមុដ្ឋាន** បានដល់ បឋវីធាតុដែលកើតអំពីកម្មដែលហៅដោយឈ្មោះសាមញ្ញ ក្នុងពាក្យថា មហាភូតដែលមានកម្មជាសមុដ្ឋាននេះ ។ ពាក្យថា **ដល់ធាតុទាំងឡាយដែលមានកម្មជាសមុដ្ឋានក្រៅពីនេះ** គឺ រមែងជាបច្ច័យដល់ធាតុ ៣ មានអាបោធាតុជាដើម ដែលកើតអំពីកម្ម ដោយទាក់ទងនឹងសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ និងដែលទាក់ទងជាទីតាំង ដោយភាពជាអ្នកឧបការ ធាតុដែលឧបការខ្លួនទាំងនោះ ដោយការកើតឡើងព្រមគ្នា ។ ដោយភាពជាទីទទួលទ្រទុក ដោយការទ្រទ្រង់ទុក តាំងពីការកើតរហូតដល់ការរលត់ , និងដោយមិនទាន់មានការប្រាសទៅ ម្យ៉ាងទៀត កាលនឹងជាបច្ច័យ មិនបានជាបច្ច័យដោយទាក់ទងជាអ្នកធ្វើធាតុទាំងនោះឲ្យកើត ដូចជាកម្មរបស់ខ្លួន ព្រោះមិនបានជាសមុដ្ឋាន អ្នកធ្វើធាតុទាំងនោះឲ្យតាំងឡើង ។ ក្នុងទីនេះភាពជាទីតាំង ( នៃធាតុ ៣ ដ៏សេស ) ក៏ត្រូវសង្គ្រោះហើយដោយ

ស័ព្ទថា និស្សយប្បច្ច័យនោះឯងក៏ពិត សូម្បីដូច្នោះ លោកអាចារ្យប្រាថ្នា សម្តែង ប្រការដ៏ពិសេសនេះថា ក៏ការដែលបឋវីធាតុជាទីតាំងនៃធាតុដែលកើតរួមគ្នា ចាត់ជាកិច្ចដែលមិនទូទៅដល់កិច្ចយ៉ាងដទៃដូច្នេះ លោកទើបពោលថា ធ្វើឲ្យជាកិច្ចដោយឡែកម្យ៉ាងទៀតថា និងដោយទាក់ទងជាទីតាំងដូច្នេះ ។ សូម្បីក្នុងពាក្យថា និងដោយទាក់ទងជាគ្រឿងប្រកាន់ជាដើមក៏មានន័យនេះដែរ ។ ពាក្យថា **ដល់មហាភូត ៣ សន្តតិ** មានសេចក្តីថា លោកកាន់យកសន្តតិ ៣ ដោយសន្តតិអាស្រ័យការប្រព្រឹត្តទៅដោយមិនដាច់ខ្សែនៃមហាភូត ៤ ដែលមាន ឧតុ ចិត្ត និងអាហារជាសមុដ្ឋាន ដោយមិនលាយឡំគ្នានិងគ្នា ។ ឈ្មោះថា ភាពជាទីតាំងនៃបឋវីធាតុ រមែងមានដល់ធម៌ទាំងឡាយដែលកើតរួមគ្នាប៉ុណ្ណោះ ព្រោះហេតុនោះ ទើបលោកពោលថា មិនបានជាបច្ច័យដោយការទាក់ទងជាទីតាំង ។ សូម្បីក្នុងពាក្យថា មិនបានជាបច្ច័យដោយការទាក់ទងជាគ្រឿងប្រកាន់ទុកជាដើមក៏មានន័យដូច្នេះ ។ បទថា **ឯត្ថ** ប្រែថា បណ្តាមហាភូតដែលមានកម្មជាសមុដ្ឋានពួកនេះ ។ ពាក្យថា **សូម្បីក្នុងបណ្តាធាតុទាំងឡាយ មានបឋវីធាតុជាដើម មានចិត្ត អាហារ ។ ល ។ ក៏មានន័យដូច្នេះដែរ** លោកចង្អុលបង្ហាញថា ក្នុងពាក្យពណ៌នាសេចក្តីថា បឋវីធាតុដែលមានចិត្តជាសមុដ្ឋាន រមែងជាបច្ច័យដល់ធាតុទាំងឡាយ ដែលមានចិត្តជាសមុដ្ឋានក្រៅពីនេះដូច្នេះជាដើម ក៏គួរនឹងនាំន័យនៃបែបផែនដែលធ្វើបានងាយចូលទៅ ។

ច-ស័ព្ទ ក្នុងសេចក្តីថា **សហជាតាទិបច្ចយវសប្បវត្តាសុ ច បន** ម្យ៉ាងទៀត បណ្តាធាតុដែលប្រព្រឹត្តទៅតាមអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើមនេះ មានអត្ថថា រួមបញ្ចូល , **បន**-ស័ព្ទ មានអត្ថថា ជាន័យផ្សេង តែថាដោយស័ព្ទទាំងពីរនោះ លោកសម្តែងសេចក្តីនេះថា ធាតុទាំងឡាយដែលប្រព្រឹត្ត

ទៅព្រោះបច្ច័យ មានសហជាតបច្ច័យជាដើម តាមដែលពោលមកហើយ រមែង ប្រព្រឹត្តទៅដោយអាការប្លែកៗគ្នានេះ ដូច្នេះ ។

ឥឡូវនេះ ដើម្បីសម្ដែងអាការដែលប្លែកៗ គ្នានោះ ទើបលោកអាចារ្យពោល គាថាថា **ឯកំ បដិច្ច** ជាដើម ។ ក្នុងគាថានោះ មានពាក្យប្រកបសេចក្ដីថា ធាតុ ៣ អាស្រ័យធាតុ ១ ប្រព្រឹត្តទៅ ៤ អាការ , ធាតុ ១ នោះឯង អាស្រ័យធាតុ ៣ ប្រព្រឹត្តទៅ ៤ អាការ , ធាតុ ២ អាស្រ័យធាតុ ២ ប្រព្រឹត្តទៅ ៦ អាការ ។ ចំណែកអត្ថាធិប្បាយមានថា កាលធាតុទាំងឡាយ មានបឋវីធាតុជាដើម ប្រភេទ មួយៗ មានភាពជាបច្ច័យ ធាតុ ៣ ដ៏សេស មួយៗ ក៏មានភាពជាបច្ចយុប្បន្ន ( ផលដែលកើតឡើងព្រោះបច្ច័យ ) ប្រការដែលពោលមកដូច្នេះនេះ ជាចតុក្ក ១ ( ពួកអាការ ៤ ១ពួក ) , កាលធាតុ ៣ ធាតុមួយៗ មានភាពជាបច្ច័យ ធាតុ មួយៗដ៏សេស ក៏មានភាពជាបច្ចយុប្បន្ន ប្រការដែលពោលមកដូច្នេះនេះ ចាត់ជា បតុក្ក ១ ទៀត , កាលធាតុពួក ២ នេះ ធាតុមួយៗ គឺ ធាតុទី១និងទី២ , ធាតុទី ៣និងទី៤ , ធាតុទី១និងធាតុទី៣ , ធាតុទី២និងធាតុទី៤ , ធាតុទី១និងធាតុទី៤ , ធាតុទី២និងធាតុទី៣ មានភាពជាបច្ច័យ ធាតុ ២ ដ៏សេស ធាតុមួយៗ ក្នុងបណ្ដា ធាតុ ៤ នោះៗ ក៏មានភាពជាបច្ចយុប្បន្ន ប្រការដែលពោលមកដូច្នេះនេះ ចាត់ជា ឆក្ក១ ( ពួកអាការ ៦ ១ពួក ) ។ សម្រាប់ធាតុទាំងឡាយដែលប្រព្រឹត្តទៅដោយ អាការ ៤ និងដោយអាការ ៦ ដោយភាពជាបច្ច័យតាមប្រការដូចដែលពោលមក នេះ បណ្ឌិតគប្បីជ្រាបដល់ការចែកថា មានភាពជាបច្ចយុប្បន្ន ដោយការទាក់ទងជា ធាតុពួក ១ ពួក ២ និងពួក ៣ និងដោយការទាក់ទងជាធាតុពួក ៣ ពួក ២ និង ពួក ១ តាមលំដាប់ចុះ ។ ភាពជាបច្ច័យនេះ បណ្ឌិតគប្បីជ្រាបដោយការទាក់ទង

ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ អត្ថិប្បច្ច័យ និង អវិគតប្បច្ច័យ និងដោយប្រធាន គឺដល់គ្នានិងគ្នា សូម្បីក្នុងភាពជាបច្ច័យនោះៗ ឯង ។ បានដល់ ភាពជាបច្ច័យ ដែលទ្រង់សម្ដែងយកក្នុងបដិច្ចវារៈថា **ឯកំ មហាភូតំ បដិច្ច តយោ មហាភូតា ។ល។ ទ្វេ មហាភូតេ បដិច្ច ទ្វេ មហាភូតា ឧប្បជ្ជន្តិ** ( ប្រែថា មហាភូត ៣ អាស្រ័យភូត ១ កើតឡើង មហាភូត ១ អាស្រ័យមហាភូត ៣ កើតឡើង មហាភូត ២ អាស្រ័យមហាភូត ២ កើតឡើង ) ដូច្នេះ ។

ដោយ**អាទិ**-ស័ព្ទក្នុងបទថា **អភិក្កមបដិក្កមាទិ** ( ឈានទៅ និងឈានត្រឡប់មកជាដើម ) គប្បីឃើញថា រួមយកការធ្វើកិរិយាផ្លូវកាយ មានការចាប់ ការលែងជាដើម ។ ឈ្មោះថា រមែងជាបច្ច័យដល់ការទល់ទ្រ ព្រោះកិរិយាដែលប៉ះខ្ទប់ សម្រេចបានដោយអំណាចបឋវីធាតុ ។ បទថា **សាវ** បានដល់ បឋវីធាតុនោះឯង ។ ឈ្មោះថា ដែលអាបោធាតុស្របតាម សម្ពន្ធសេចក្ដីថា ដល់ការៈដែលអាបោធាតុមិនជាប្រធានក្នុងការឈប់ប៉ុណ្ណោះ និងដល់ការៈដែលបឋវីធាតុជាប្រធាន ព្រោះហេតុនោះ ទើបជាបច្ច័យដល់ការឈប់ គឺការបញ្ឈប់ជើង ព្រោះក្នុងការបញ្ឈប់ជើង បឋវីធាតុនោះ ក៏មានកិច្ចយ៉ាងល្អក្រៃលែង ដូចគ្នានឹងភាពជាទីតាំង ( នៃធាតុ ៣ ដ៏សេស ) ។ បទថា **អវក្ខេបនស្ស** ប្រែថា ដល់ការដាក់ជើងចុះ ។ ក៏ក្នុងការដាក់ជើងចុះនោះ អាបោធាតុដែលមានសភាពធ្ងន់ជាង រមែងមានសេចក្ដីព្យាយាមយ៉ាងល្អក្រៃលែង ព្រោះហេតុនោះ ទើបលោកពោលថា អាបោធាតុដែលបឋវីធាតុជាប់តាមហើយដូច្នេះ ។ តេជោធាតុដែលមានភាពស្រាលក៏យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលដល់ការៈដែលតេជោ-

ធាតុនោះ ត្រូវវាយោធាតុជាប់តាមក្នុងពេលដែលលើកជើងឡើង ។ វាយោធាតុដែលមានការទៅខាងទទឹង មានការព្យាយាមយ៉ាងល្អក្រៃលែងក្នុងពេលដែលរុញជើងទៅ និងការបង្អិលជើង ព្រោះហេតុនោះ ទើបលោកបានកាន់យកភាវៈដែលវាយោធាតុនោះ ត្រូវតែជាធាតុជាប់តាម ។ ក្នុងកិរិយាទាំងនោះ ការនាំជើងឆ្ពោះមុខទៅចាកទីកន្លែងដែលឈរ ឈ្មោះថា **អតិហរណំ**-ការរុញទៅ បានដល់ ការនាំជើងទៅខាងមុខ ។ ការនាំជើងឈានកន្លងទៅបន្តិចចាកទីកន្លែងនោះ ឈ្មោះថា **វិតិហរណំ**-ការគេច បានដល់ ការទៅម្ខាងផ្លូវ ។

ពាក្យថា **ដោយមុខម្យ៉ាង** គឺ ដោយគន្លងនៃការកំណត់កាន់យកធាតុទាំង-ឡាយម្យ៉ាងៗ បណ្ដាអាការ ១៣ ដែលលោកអាចារ្យបានចែកទុកដោយន័យថា ឈ្មោះថា **បឋវី** ព្រោះភាវៈដែលផ្សាយទៅជាដើម ។ បទថា **ស្វាយំ** ប្រែថា ឧបចារសមាធិនេះ ។ សួរថា ក៏ឧបចារសមាធិនេះ នឹងមានបរិយាយថា **វវដ្ឋាន** បានយ៉ាងដូចម្ដេច ? លោកអាចារ្យបានពោលឆ្លើយថា **ចតុន្នំ ធាតូនំ** ជាដើម ព្រោះកើតឡើងដោយអានុភាពនៃញាណដែលបានកំណត់ធាតុ ៤ ។ ឥឡូវនេះ លោកអាចារ្យប្រាថ្នាសម្ដែងអានិសង្សនៃការវនានេះ ទើបពោលថា **ឥមញ្ច បន** ដូច្នេះជាដើម ។ ពាក្យថា **រមែងចាក់ចុះដល់ភាពជារបស់សូន្យទទេ** មានសេចក្ដីថា កាលព្រះយោគីកំណត់ភាពជាអនត្តានៃរូបកាយបាន ដោយការឃើញភាពត្រឹមតែជាធាតុ ភាពជាអនត្តា សូម្បីនៃនាមកាយ ក៏រមែងប្រាកដច្បាស់បាន ដោយស្រេបតាមការឃើញភាពជាអនត្តានៃរូបកាយនោះ ព្រោះហេតុនោះ ទើបចាក់ចុះដល់ភាពជារបស់សូន្យទទេចាកអត្តា បានដោយប្រការទាំងពួង គឺ តាំងនៅក្នុងភាពជារបស់សូន្យទទេចាកអត្តានោះ ។ ពាក្យថា **រមែងដកសត្តសញ្ញាបាន** មានសេចក្ដីថា

ព្រោះហេតុនោះៗ ឯង ក៏រមែងកើតកន្ទ្រាក់ រមែងដកការសម្គាល់តាមភាពមិនពិត ដែលប្រព្រឹត្តទៅយ៉ាងនេះថា សត្វ មនុស្ស បុរស ស្ត្រី ដូច្នេះបាន ។ ពាក្យថា **កាលមិនដល់ការកំណត់ជ្រើសរើសថា ជាសត្វសាហាវ យក្ខ អារក្ខទឹកជាដើម** មានសេចក្ដីថា កាលមិនធ្វើការកំណត់ជ្រើសរើស មានយ៉ាងនេះថា ពួកសីហៈ ខ្លា ដំបងពួកនេះជាដើម ជាសត្វសាហាវ ពួកនេះជាពួកយក្ខ ពួកអារក្ខទឹក ដូច្នេះជាដើម ក៏រមែងអត់ធន់ គឺគ្របសង្កត់ការខ្លាច និងអារម្មណ៍ដែលគួរខ្លាចបាន ដូចគ្នានឹងព្រះវិណាស្រេព ព្រោះបានឃើញត្រឹមតែជាធាតុហើយយ៉ាងល្អ សូម្បីក្នុងខន្ធសន្តាន របស់អ្នកដទៃ ដូចគ្នានឹងខន្ធសន្តានរបស់ខ្លួន ។ គឺ លោកពោលការមិនដល់ការកំណត់ជ្រើសរើសតាមដែលពោលមកហើយ ថាជាហេតុនៃការអត់ធន់ ភាពខ្លាច និង អារម្មណ៍ដែលគួរខ្លាច ។ ឈ្មោះថា **ឧគ្ឃាដោ**-ការត្រេកអរ បានដល់ ការរីករាយចិត្ត ។ ឈ្មោះថា **និគ្ឃាដោ** - ការខូចចិត្ត បានដល់ ការលំបាកចិត្ត ។ ឯឈ្មោះថា នឹងជាអ្នកមានបញ្ញាច្រើន ក៏ព្រោះធ្វើការបំបែកភាពជាដុំក្នុងកាយ ដោយទាក់ទងតាមរយៈថា ជាធាតុបានប្រពៃនោះឯង ។ ពិតយ៉ាងនោះ លោកពោលទុកថា កម្មដ្ឋាននេះអនុកូលសមគួរដល់បុគ្គលអ្នកជាពុទ្ធិចរិត អធិប្បាយថា ឬឈ្មោះថា មានសុគតិជាទីទៅខាងមុខ ក៏ព្រោះភាពដែលឥន្ទ្រិយទាំងឡាយនៅមិនទាន់ចាស់ក្លាដោយជុំវិញ ។

ការពណ៌នាអត្ថដ៏ជ្រាលជ្រៅ

នៃចតុធាតុវវដ្ឋាន ដែលប្រដាប់ដោយន័យនៃការនា ១៩ ន័យ ចប់ហើយ

ពាក្យសួរដល់សភាវៈដែលមានពិតជាដើម ដោយពាក្យថា **អ្វីជាសមាធិជាដើម** រមែងមានត្រឹមតែដើម្បីប្រយោជន៍ គឺ ការដឹងនូវការបែក ៗ ប្រភេទនៃធម៌ដែលដឹងហើយដោយសភាវៈដែលមានប្រាកដជាដើម ដែលកំពុងពោលដល់ រមែងជាការដឹងបានដោយងាយ ក៏ព្រោះពាក្យអធិប្បាយយ៉ាងពិស្តារ មានអធិប្បាយយ៉ាងសង្ខេបជាខាងដើម , តែថា លោកសង្គ្រោះវិធីអធិប្បាយយ៉ាងសង្ខេបទុកដោយវិធីអធិប្បាយយ៉ាងពិស្តារ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដើម្បីសម្តែងភាពពិស្តារ និងការនាន័យនៃសមាធិដូច្នេះ ន័យម្យ៉ាងទៀត លោកអាចារ្យពោលថា ដើម្បីសម្តែងសេចក្តីពិស្តារ និងការនាន័យដូច្នេះ ដោយបំណងថា សូម្បីដោយពាក្យថា **អ្វីជាសមាធិ ជាដើមនេះ** លោកសម្តែងភាពផ្សេងៗ ដោយប្រការទាំងពួងនៃសមាធិនោះឯង , សូម្បីអានិសង្សនៃការចម្រើន ក៏ត្រូវអាស្រ័យការនាន័យនោះ ដូច្នេះដែរ ។ ពាក្យថា **ដោយប្រការទាំងពួង** គឺ ដោយប្រការនៃការធ្វើបុព្វកិច្ចនៃការនា មានការកាត់បលិពោធជាដើមទាំងពួងចេញ និងដោយការសម្តែងការចម្រើនកម្មដ្ឋានទាំងពួង ។

លោកអាចារ្យកាលពោលថា ជាការចប់ហើយ ដូច្នេះហើយ បំណងនឹងបើកបង្ហាញភាវៈដែលចប់នោះៗ ឯង ទើបពោលថា **ទុវិធោយេវ** ដូច្នេះជាដើម ។ ពាក្យថា **សមាធិដែលប្រាថ្នាយកក្នុងទីនេះ** លោកពោលដល់លោកិយសមាធិ ។ ពាក្យថា **ក្នុងកម្មដ្ឋាន ១០** បានដល់ ក្នុងកម្មដ្ឋាន ១០ ដែលលោកពោលទុកក្នុងខាងដើមថា នាំមកនូវឧបចារឈាន ។ បទថា **អប្បនាបុព្វភាគចិត្តេសុ** ប្រែថា ក្នុងចិត្តទាំងឡាយដែលជាចំណែកខាងដើមនៃអប្បនា បានដល់ ក្នុងចិត្តុប្បាទទាំងឡាយដែលជាចំណែកខាងដើមនៃឈាន ៨ ។ ពាក្យថា **ឯកគ្គតា** បានដល់ ឯកគ្គតាក្នុង

វិថីដែលមានអាវជ្ជនៈដូចគ្នានឹងវិថីដែលមានអាវជ្ជនៈផ្សេងៗគ្នា ។ ពាក្យថា **ក្នុងកម្មដ្ឋានដ៏សេស** គឺ ក្នុងកម្មដ្ឋាន ៣០ ដែលបានពោលទុកហើយថា នឹងនាំមកនូវអប្បនា ។

( ចប់មហាដីកា )

# អានិសង្សនៃការបំពេញសមាធិ

ចំណែកក្នុងបញ្ហាដែលពោលទុកថា អ្វីជាអានិសង្សនៃការបំពេញសមាធិ ? មានពាក្យឆ្លើយថា អានិសង្សនៃការបំពេញសមាធិ មាន ៥ ប្រការ មានទិដ្ឋធម្មសុខវិហារ ( ភាពនៅជាសប្បាយក្នុងបច្ចុប្បន្ន ) ជាអានិសង្សជាដើម ។

## ១-មានទិដ្ឋធម្មសុខវិហារជាអានិសង្ស

ភិក្ខុពួកណាជាព្រះអរហន្តខីណាស្រព រមែងចម្រើនសមាធិដោយបំណងថា នឹងចូលសមាបត្តិ ឲ្យចិត្តមានអារម្មណ៍តែមួយ នៅជាសុខអស់ថ្ងៃ ការចម្រើនអប្បនាសមាធិរបស់ពួកភិក្ខុនោះ ឈ្មោះថា មានទិដ្ឋធម្មសុខវិហារជាអានិសង្ស ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ ( នឹងព្រះចុន្ទ ) ថា “ **ម្នាលចុន្ទ ឈានធម៌នោះ មិនហៅថា សល្លេខក្នុងអរិយវិន័យទេ ឈានធម៌ពួកនោះ ហៅថា ទិដ្ឋធម្មសុខវិហារ ក្នុងអរិយវិន័យនេះ** ” ។

## ២-មានវិបស្សនាជាអានិសង្ស

ទាំងការចម្រើនអប្បនាសមាធិ ទាំងការចម្រើនឧបចារសមាធិ ដោយន័យនៃការបានចន្លោះក្នុងទីចង្អៀតរបស់ព្រះសេក្ខៈ និងបុថុជ្ជនទាំងឡាយ អ្នកចម្រើនដោយប្រាថ្នាថា ចេញចាកសមាបត្តិហើយ ប្រកបវិបស្សនា ទាំងចិត្តក៏នៅតាំងមាំ ឈ្មោះថា មានវិបស្សនាជាអានិសង្ស ព្រោះសមាធិនោះជាបទដ្ឋាន ( ហេតុជិត ) នៃវិបស្សនា ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ទុកថា “ **ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីចម្រើនសមាធិចុះ ភិក្ខុអ្នកមានចិត្តតាំងមាំហើយ រមែងដឹងច្បាស់តាមសេចក្ដីពិត** ” ។

## ៣ - មានអភិញ្ញាជាអានិសង្ស

ចំណែកភិក្ខុពួកណាញុំាងសមាបត្តិ ៨ ឲ្យកើតហើយ ចូលឈានដែលជាបាទនៃអភិញ្ញា ចេញចាកសមាបត្តិហើយ កាលប្រាថ្នា ក៏ធ្វើអភិញ្ញាដែលមានន័យដូចពោលទុកដោយប្រការថា ជាមនុស្សម្នាក់ ហើយ ( អធិដ្ឋាន ) ឲ្យជាមនុស្សច្រើននាក់ក៏បាន ដូច្នេះជាដើមឲ្យកើតឡើងបាន ការចម្រើនអប្បនាសមាធិនៃភិក្ខុពួកនោះ ឈ្មោះថា មានអភិញ្ញាជាអានិសង្ស ព្រោះសមាធិនោះ ( ក្នុងហេតុដែលនឹងឲ្យបានអភិញ្ញា ) មានព្រមជាបទដ្ឋាននៃអភិញ្ញាបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកថា លោកបង្អោនចិត្តទៅចំពោះ ដើម្បីធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញានូវធម៌ដែលគប្បីធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញាណាៗក្តី លោកក៏សម្រេចភាពជាអ្នកអាច ដើម្បីធ្វើឲ្យប្រចក្សបានក្នុងអភិញ្ញាសច្ចិករណីយធម៌នោះៗ ផងដែរ ( ក្នុងហេតុដែលនឹងឲ្យបានអភិញ្ញា ) មានព្រម ។

## ៤ - មានភពពិសេសជាអានិសង្ស

បុថុជ្ជនពួកណា មានឈានមិនសានសូន្យ ប្រាថ្នាចូលដល់ព្រហ្មលោកថា យើងនឹងកើតក្នុងព្រហ្មលោក ឬសូម្បីមិនប្រាថ្នាក៏ដោយ តែមិនសាបសូន្យចាកសមាធិ ការចម្រើនអប្បនាសមាធិរបស់បុថុជ្ជនពួកនោះ ឈ្មោះថា មានភពពិសេសជាអានិសង្ស ព្រោះសមាធិនោះនាំភពពិសេសមកឲ្យ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុកថា សួរថា បុគ្គលទាំងឡាយបំពេញបឋមជ្ឈានដែលនៅជាបរិត្តកុសលបាន ហើយស្លាប់ទៅ បានកំណើតក្នុងទីណា ? ឆ្លើយថា បានកំណើតរួមជាមួយនឹងពួកទេព ពួកព្រហ្មបារិសជ្ជា ដូច្នេះជាអាទិ៍ , ចំណែកការចម្រើនឧបចារសមាធិសោត ក៏នាំភពពិសេស គឺសុគតិជាន់កាមាវចរៈ ៦ មកឲ្យដូចគ្នា ។

## ៥ – មាននិរោធជាអានិសង្ស

ចំណែកព្រះអរិយៈពួកណា ញុំាងសមាបត្តិ ៨ ឲ្យកើត ហើយចូលនិរោធសមាបត្តិ ចម្រើនសមាធិដោយប្រាថ្នាថា នឹងជាអ្នកមិនមានចិត្ត ( រំលត់ការគិត ) ចូលដល់និរោធនិព្វាន នៅសម្រាកក្នុងទិដ្ឋធម៌ ទិដ្ឋធម៌នេះត្រឹម ៧ ថ្ងៃចុះ ការចម្រើនអប្បនាសមាធិរបស់ព្រះអរិយៈពួកនោះ ឈ្មោះថា មាននិរោធជាអានិសង្ស ព្រោះហេតុនោះ ទើបព្រះសារីបុត្រពោលទុកថា ការដឹងក្នុងការចម្រើន ភាពជាវសី ( ស្ទាត់ជំនាញក្នុងការចូលនិរោធសមាបត្តិ ) ដោយញាណចរិយា ១៦ ដោយសមាធិចរិយា ៩ ចាត់ជាញាណក្នុងនិរោធសមាបត្តិ ។

នេះជាអានិសង្សនៃការចម្រើនសមាធិ ៥ ប្រការ មានទិដ្ឋធម្មសុខវិហារជាដើម ដូចពោលមកដូច្នេះ ។

ព្រោះហេតុនោះ បណ្ឌិតទើបមិនគួរប្រមាទក្នុងការប្រកបសមាធិភាវនា ដែលមានអានិសង្សជាអនេក ជាគ្រឿងជម្រះមន្ទិល គឺ កិលេសបានដូច្នេះ ។

ក៏ឯដោយការពណ៌នាសេចក្តីត្រឹមតែប៉ុណ្ណេះ សមាធិក្នុងវិសុទ្ធិមគ្គ ដែលព្រះមានព្រះភាគទ្រង់សម្តែងទុកដោយមាតិកា គឺ សីល សមាធិ បញ្ញា ដោយគាថាថា **សីលេ បតិដ្ឋាយ នរោ សបញ្ញោ** ជាអាទិនេះ ក៏ត្រូវបានអធិប្បាយចប់ហើយមួយប្រការទៀត ។

# មហាដីកា

# ពណ៌នាកថា ស្តីអំពីអានិសង្សនៃសមាធិ

*អត្តភាពដែលមាននៅដោយប្រចក្ស លោកហៅថា ទិដ្ឋធម៌ , ការនៅជាសុខក្នុងទិដ្ឋធម៌នោះ ឈ្មោះថា ទិដ្ឋធម្មសុខវិហារ ( ការនៅជាសុខក្នុងអត្តភាពនេះ) ដោយពាក្យថា ចូលសមាបត្តិនេះ ជាការចង្អុលបង្ហាញដល់អប្បនាសមាធិនោះឯង ក៏ពិតមែន សូម្បីដូច្នោះ ដោយបទថា* **មានចិត្តជាឯកគ្គៈ** *ដូច្នេះ រមែងកាន់យកឧបចារសមាធិបានដែរ ព្រោះហេតុនោះ ដើម្បីនឹងហាមនូវឧបចារសមាធិនោះ ទើបលោកអាចារ្យពោលថា ការចម្រើនអប្បនាសមាធិរបស់លោកទាំងនោះដូច្នេះ ។ ប្រការថា* **ន ខោ បនេតេ** *ដូច្នេះ បានដល់ ឈានធម៌ពួកនោះ ដែលបានចម្រើនទុកក្នុងលទ្ធិខាងក្រៅ ដែលត្រឹមតែជាការធ្វើឲ្យចិត្តមានអារម្មណ៍តែមួយ។ ឈ្មោះថា ក្នុងវិន័យរបស់ព្រះអរិយៈជាម្ចាស់ គឺក្នុងសាសនារបស់ព្រះមានព្រះភាគ ឈ្មោះថា* **មិនហៅថា សល្លេខធម៌** *ព្រោះធ្វើអធិប្បាយថា មិនជាបដិបទាដែលជាគ្រឿងជុសខាត់កិលេសទាំងឡាយ រីឯធម៌ទាំងឡាយ មានអវិហិង្សាជាដើម ក្នុងព្រះសាសនាចាត់ជាសល្លេខធម៌បាន ព្រោះជាបាទនៃលោកុត្តរធម៌ ។ ពាក្យថា* **ក្នុងទីបង្អៀត** *បានដល់ ក្នុងទីបង្អៀតយ៉ាងក្រៃលែង គឺ ក្នុងសង្សារវដ្ត ដែលប្រព្រឹត្តទៅជាទីតាំងនៃវត្ថុថោកទាប ហួសនឹងប្រៀបបាន ព្រោះភាពជាទីដែលសៅហ្មង ដោយភាពសៅហ្មង គឺ តណ្ហាជាដើម ។ ពាក្យថា* **ដោយន័យនៃការបានឱកាស** *បានដល់ ដោយន័យនៃការបានឱកាស ពោលគឺ ខណៈទី ៩ ដែលសមគួរដល់ការបានមកនូវអត្តភាព ។ ពិតហើយ ព្រោះឱកាសនោះរកបានដោយលំបាក បុគ្គលអ្នកច្រើន*

ដោយភាពតក់ស្លុត អ្នកនឹងសម្រេចអធិគម( ធម៌ដែលគប្បីសម្រេច ) គឺ អប្បនា បាន ក៏ព្យាយាមក្នុងឧបចារសមាធិនោះឯង ហើយក៏ រមែងធ្វើការងារក្នុងវិបស្សនា ដោយគិតថា យើងនឹងឈានកន្លងទុក្ខក្នុងសង្សារវដ្ដ ដោយឆាប់រហ័ស ។

ពាក្យថា **ជាបាទនៃអភិញ្ញា** គឺជាបាទ បានដល់ជាទីតាំងនៃអភិញ្ញាទាំងឡាយ មានការសម្ដែងឫទ្ធិជាដើម ។ **ឥតិ**-ស័ព្ទ ក្នុងប្រការថា **ហោតីតិ វុត្តនយា** ( មានន័យ ដែលត្រាស់ទុក... ក៏ធ្វើឲ្យជា... ) មានសេចក្ដីថា ប្រការ , ដោយ **ឥតិ**-ស័ព្ទនោះ លោកសង្គ្រោះប្រការដែលបានពោលមកហើយ សូម្បីនៃអភិញ្ញាដ៏សេសថា មានន័យដែលបានត្រាស់ទុកដោយប្រការនេះ ។ ពាក្យថា **ក្នុងកាលហេតុគ្រប់ៗយ៉ាងនៅមាន** គឺ កាលហេតុនៃការសម្រេចអភិញ្ញា ដែលសម្រេចហើយក្នុងភពមុននៅមាន ។ លោកហៅការតាំងចិត្ត ដែលព្រះយោគាវចរគប្បីប្រាថ្នាដើម្បីការសម្រេចអភិញ្ញាថា បុព្វហេតុ មិនហៅវសីភាវៈ( ការជំនាញ ) ក្នុងសមាបត្តិទាំងឡាយថា បុព្វហេតុទេ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ក្នុងកាលហេតុគ្រប់ៗយ៉ាងនៅមានដូច្នេះ ។ ពាក្យថា **នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា** គឺ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយបញ្ញា ដ៏វិសេសក្រៃលែង ដែលកំពុងពោលដល់ការបែក ។ ពាក្យថា **នូវធម៌** គឺ នូវធម៌ដែលគួរចម្រើន និងនូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ប្រកបសេចក្ដីថា **អភិញ្ញាសច្ឆិកិរិយាយ ចិត្តំ អភិនិន្នា មេតិ** ( បង្អោនចិត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់ដោយអភិញ្ញា ) ។ បទថា **តត្រ តត្រេវ** ប្រែថា ក្នុងធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់នោះៗឯង ។ ភិក្ខុឈ្មោះថា **ភព្វ** ( អ្នកគួរ ) ព្រោះភាពជាអ្នកមានប្រក្រតីធ្វើឲ្យប្រេចក្ស ក្នុងភាពជាសក្ខី ភាវៈនៃភព្វនោះ ឈ្មោះថា **សក្ខិភព្វតា** ( ភាពជាអ្នកគួរក្នុងភាព

ជាសក្ខី ) បានដល់ ភាពជាអ្នកគួរក្នុងភាពជាសក្ខីនោះ ។

លោកអាចារ្យ កាលប្រារព្ធដល់កម្មដែលជាហេតុទៅកាន់ភពនោះៗ សម្តែងថា កាលមិនមានសេចក្តីប្រាថ្នាភពកើតឡើង កិច្ច គឺសេចក្តីប្រាថ្នាភព ក៏រមែងមិនសម្រេចបាន ដោយការដែលបានធ្វើ បានសន្សំកម្មទុកហើយនោះឯង ដូច្នេះ ទើបពោលថា មិនប្រាថ្នាក៏ដោយ ដូច្នេះ ។ បុគ្គលឈ្មោះថា **សហព្យ** ព្រោះអត្ថថា ទៅ គឺ ប្រព្រឹត្តទៅរួមគ្នា បានដល់ សហាយ , តែក្នុងទីនេះប្រាថ្នាយកអ្នកចូលដល់ភពជាមួយគ្នា ភាវៈនៃ **សហព្យ** ឈ្មោះថា **សហព្យតា** ( ភាពជាសហាយ ) បានដល់ រមែងចូលដល់ភាពជាសំឡាញ់នោះ ។

លោកអាចារ្យធ្វើពាក្យសួរទុកក្នុងចិត្តថា ការចម្រើនអប្បនាសមាធិប៉ុណ្ណោះ ឬ ដែលមានភពពិសេសជាអានិសង្ស ឬថា ការចម្រើនសមាធិសូម្បីក្រៅពីនេះ ក៏មានភពពិសេសជាអានិសង្សដែរ ដូច្នេះ ទើបពោលថា សូម្បីការចម្រើនឧបចារសមាធិ ដូច្នេះជាដើម ។

ពាក្យថា **និព្វាន** បានដល់ ការរលត់ទៅនៃសេចក្តីទុក្ខ ៣ យ៉ាង ។ ភាពជាសង្ខារទុក្ខដែលរាប់ទាក់ទងក្នុងរូបធម៌ សូម្បីថានៅមានពិត ក៏ដូចជាមិនមានតែម្តង ព្រោះមិនមានចិត្ត ព្រោះហេតុនោះ ទើបលោកពោលថា ពួកយើងនៅជាសុខដូច្នេះ ។ ពាក្យថា **ដោយញាណចរិយា ១៦** គឺ ដោយញាណចរិយា ៨ ពួកនេះ គឺ អនិច្ចានុបស្សនា១ ទុក្ខានុបស្សនា១ អនត្តានុបស្សនា១ និព្វិទានុបស្សនា១ វិរាគានុបស្សនា ១ និរោធានុបស្សនា ១ បដិនិស្សគ្គានុបស្សនា ១ វិវដ្ដានុបស្សនា ១ ដូច្នេះ និងដោយអរិយមគ្គញ្ញាណ និងអរិយផលញ្ញាណ ៨ ទៀត ទើបរួមជាញាណចរិយា ១៦ យ៉ាងនេះ ។ ពាក្យថា **ដោយសមាធិចរិយា ៩** គឺដោយសមាធិចរិយា ៩ នេះ

ដោយអំណាចរូបជ្ឈាន ៥ និងអរូបជ្ឈាន ។ ចំណែកអាចារ្យពួកខ្លះពោលថា រូបឈានសមាធិ ៤ អរូបឈានសមាធិ ៤ រួមឧបចារសមាធិរបស់ឈានទាំងពីរជា ១ ទើបត្រូវជា ៩ យ៉ាងនេះ ដូច្នេះ ។

បទថា **សមាធិភាវនាយោគេ**-ក្នុងការបំពេញសមាធិភាវនា បានដល់ ក្នុងការបំពេញ គឺក្នុងការប្រកបរឿយៗ នូវសមាធិភាវនា ឬថា ក្នុងការបំពេញ ពោល គឺ ចម្រើនសមាធិ ។ **ភាវនា** ( ការចម្រើន ) លោកហៅថា **យោគ** ( សេចក្តីព្យាយាម , ការបំពេញ ) ។ ដូចដែលទ្រង់ត្រាស់ទុកថា **យោគា វេ ជាយតេ ភូរិ** ( បញ្ញារមែងកើតពីយោគៈ ) ។

ដោយ **ចិ**-សព្ទ ក្នុងបទថា **សមាធិចិ** លោករួមយកសីល ។

( ចប់ ការពណ៌នា សមាធិនិទ្ទេស )

## បរិច្ឆេទទី ១១

ឈ្មោះ **សមាធិនិទ្ទេស** ក្នុងបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ
ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់ភាពជាបាមោជ្ជ នៃសាធុជនដូច្នេះឯង ។

# បន្ថែមលំដាប់
# នៃនិទ្ទេសដែលពោលមកហើយ

ទី ១ សីលនិទ្ទេស ទី ២ ធុតង្គនិទ្ទេស

ទី ៣ កម្មដ្ឋានគហណនិទ្ទេស ទី ៤ បឋវីកសិណនិទ្ទេស

ទី ៥ សេសកសិណនិទ្ទេស ទី ៦ អសុភនិទ្ទេស

ទី ៧ ឆអនុស្សតិនិទ្ទេស ទី ៨ សេសអនុស្សតិនិទ្ទេស

ទី ៩ ព្រហ្មវិហារនិទ្ទេស ទី ១០ អារុប្បនិទ្ទេស

ទី ១១ ពីរនិទ្ទេស គឺ អាហារេបដិកូលសញ្ញា និងធាតុវវដ្ឋាន ( ដែលលោករួមគ្នា ហៅថា សមាធិនិទ្ទេស ) ។

# ឥទ្ធិវិធនិទ្ទេស

ព្រោះហេតុនៃការចម្រើនសមាធិនេះ ខ្ញុំម្ចាស់បានពោលទុកថា មានអភិញ្ញាជាអានិសង្ស ដោយអំណាចនៃលោកិយអភិញ្ញាទាំងឡាយឯណា ព្រះយោគីអ្នកបានចតុត្ថជ្ឈានក្នុងកសិណទាំងឡាយ មានបឋវីកសិណជាដើមហើយ គួរធ្វើយោគៈតទៅ ដើម្បីញ៉ាំងអភិញ្ញាទាំងឡាយនោះឲ្យដល់ព្រម ព្រោះថា ការធ្វើបានយ៉ាងនោះ ការចម្រើនសមាធិនោះរបស់លោក ក៏នឹងជាភាវនាដែលមានអានិសង្សបានហើយ ហើយនឹងជាសមាធិដ៏មាំទាំក្រៃលែងជាងភាវនាប្រក្រតីផង លោកនឹងប្រកបដោយ សមាធិភាវនា ដែលមានអានិសង្សដែលបានហើយដ៏មាំទាំក្រៃលែង ក៏នឹងញ៉ាំងការចម្រើនបញ្ញាឲ្យដល់ព្រមបានដោយងាយផងដែរ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទាំងឡាយ នឹងផ្តើមអភិញ្ញាកថាមុនក្នុងកាលឥឡូវនេះ ។

## លោកិយអភិញ្ញា ៥

លោកិយអភិញ្ញា មាន ៥ គឺ

១- ឥទ្ធិវិធ ការសម្តែងឫទ្ធិផ្សេងៗ បាន ។

២- ទិព្វសោតធាតុញ្ញាណ ការដឹងដូចបានឮដោយសោតធាតុជាទិព្វ ។

៣- ចេតោបរិយញ្ញាណ ការដឹងចិត្តរបស់អ្នកដទៃបាន ។

៤- បុព្វេនិវាសានុស្សតិញ្ញាណ ការដឹងក្នុងការតាមរឭកជាតិមុនៗ របស់ខ្លួនបាន

៥- សត្តានំ ចុតូបបាតញ្ញាណ ការដឹងក្នុងការចុតិ និង បដិសន្ធិរបស់សត្វទាំងឡាយ ។

ព្រះមានព្រះភាគត្រាស់ទុកដោយន័យថា ភិក្ខុនោះ ក្នុងកាលចិត្តតាំងមាំបរិសុទ្ធ

ស្អាត មិនមានការគិតទៅតាមអំណាចសេចក្ដីប្រាថ្នា ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការងារ តាំងនៅ ដល់នូវការមិនញាប់ញ័រយ៉ាងនេះហើយ នាំចិត្តនោះទៅ បង្អោនចិត្តនោះទៅ ដើម្បីឫទ្ធិមួយប្រភេទ លោកក៏សម្រេចប្រភេទនៃឫទ្ធិបានច្រើនយ៉ាង គឺ មនុស្សម្នាក់អធិដ្ឋានឲ្យជាមនុស្សច្រើននាក់ក៏បាន ដូច្នេះជាដើម ដើម្បីទ្រង់សម្ដែងអានិសង្សនៃការចម្រើនសមាធិ និងដើម្បីសម្ដែងធម៌ដ៏ប្រណីតក្រៃលែងឡើងទៅ ដល់កុលបុត្រទាំងឡាយ អ្នកបានសម្រេចសមាធិ ក្នុងចតុត្ថជ្ឈានហើយ ។

## ចិត្តបរិទមនវិធិ - វិធីហ្វឹកហាត់ចិត្ត

ក្នុងលោកិយអភិញ្ញា ៥ នោះ ព្រះយោគីអ្នកជាអាទិកម្មិកៈ ( អ្នកធ្វើដំបូង ) ប្រាថ្នានឹងធ្វើ **ឥទ្ធិវិកុព្វន**( ការធ្វើឫទ្ធិផ្សេងៗ ) មានឫទ្ធិ គឺមនុស្សម្នាក់ អធិដ្ឋានឲ្យជាមនុស្សច្រើននាក់បានជាដើម គប្បីញ៉ាំងសមាបត្តិ ៨ ក្នុងកសិណ ៨ មានឱទាតកសិណជាប្រការចុងក្រោយឲ្យកើត ហ្វឹកហាត់ចិត្តដោយអាការ ១៤ នេះ គឺ :

| | |
|---|---|
| កសិណានុលោមតោ | ដោយអនុលោមកសិណ |
| កសិណបដិលោមតោ | ដោយបដិលោមកសិណ |
| កសិណានុលោមបដិលោមតោ | ដោយអនុលោម និងបដិលោមកសិណ |
| ឈានានុលោមតោ | ដោយអនុលោមឈាន |
| ឈានបដិលោមតោ | ដោយបដិលោមឈាន |
| ឈានានុលោមបដិលោមតោ | ដោយអនុលោម និងបដិលោមឈាន |
| ឈានុក្កន្តកតោ | ដោយកន្លងឈាន |

| | |
|---|---|
| កសិណុក្កន្តកតោ | ដោយកន្លងកសិណ |
| ឈានកសិណុក្កន្តកតោ | ដោយកន្លងទាំងឈាន ទាំងកសិណ |
| អង្គសង្កន្តិតោ | ដោយរំកិលអង្គឈាន |
| អារម្មណសង្កន្តិតោ | ដោយរំកិលអារម្មណ៍ |
| អង្គារម្មណសង្កន្តិតោ | ដោយរំកិលទាំងអង្គ ទាំងអារម្មណ៍ |
| អង្គវវដ្ឋាបនតោ | ដោយកំណត់មើលអង្គ |
| អារម្មណវវដ្ឋាបនតោ | ដោយកំណត់មើលអារម្មណ៍ |

សួរថា ក៏ក្នុងអាការទាំងនោះ កសិណានុលោម ( តាមលំដាប់កសិណ ) ដូចម្តេច ។ល។ ? អារម្មណវវដ្ឋាបន កំណត់មើលអារម្មណ៍យ៉ាងដូចម្តេច ?

## ចូលអនុលោមកសិណ

វិសជ្ជនាថា ភិក្ខុក្នុងសាសនានេះ ចូលឈានក្នុងកសិណ ៨ តាមលំដាប់ ដូច្នេះ គឺ ចូលឈានក្នុងបឋវីកសិណ តពីនោះ ចូលក្នុងអាបោកសិណ... ជាដើម តាំងពី ១០០ ដង ១០០០ ដង ក្តី នេះឈ្មោះថា **កសិណានុលោម**-តាមលំដាប់កសិណ ។

## ចូលបដិលោមកសិណ

ចំណែកការចូលឈានយ៉ាងនោះហើយ ដោយបញ្រ្ចាសតាំងពីឱទាតកសិណចូលមក ឈ្មោះថា **កសិណបដិលោម**-ចូលបញ្រ្ចាសកសិណ ។

## ចូលទាំងអនុលោម និងបដិលោមកសិណ

ការចូលឈានក្នុងកសិណដែលចូលហើយ ចូលទៀត ( ១០០ ដង ១០០០

ជង ) ដោយចូលទាំងតាមលំដាប់ ទាំងបញ្ច្រាសលំដាប់ដូច្នេះ ក៏ចូលតាំងពីបឋវី កសិណទៅរហូតដល់ឱទាតកសិណ ចូលតាំងពីឱទាតកសិណមករហូតដល់បឋវី កសិណ ឈ្មោះថា **កសិណានុលោមបដិលោម** ទាំងតាមលំដាប់ ទាំងបញ្ច្រាស លំដាប់កសិណ ។

## ចូលដោយអនុលោមឈាន

ពេលនេះការចូលឈានហើយ ចូលទៀត តាំងពីបឋមជ្ឈានទៅតាមលំដាប់ រហូតដល់នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា **ឈានានុលោម**-តាមលំដាប់ឈាន។

## ចូលបដិលោមឈាន

ការចូលឈានហើយ ចូលទៀត តាំងពីនេវសញ្ញានាសញ្ញាយតនៈ ចូលមក រហូតដល់បឋមជ្ឈាន ឈ្មោះថា **ឈានបដិលោម**-បញ្ច្រាសលំដាប់ឈាន ។

## ចូលទាំងអនុលោម និងបដិលោមឈាន

ការចូលឈានហើយ ចូលទៀត ដោយចូលទាំងតាមលំដាប់ ទាំងបញ្ច្រាស លំដាប់ ដូច្នេះ គឺចូលតាំងពីបឋមជ្ឈានទៅរហូតដល់នេវសញ្ញានាសញ្ញាយតនៈ និង ចូលតាំងពីនេវសញ្ញានាសញ្ញាយតនៈ ចូលមករហូតដល់បឋមជ្ឈាន ឈ្មោះថា **ឈានានុលោមបដិលោម**-ទាំងតាមលំដាប់ ទាំងបញ្ច្រាសលំដាប់ឈាន ។

## ចូលកន្លងឈាន

រីឯការចូលមិនកន្លងកសិណ តែកន្លងឈាន ដោយធ្វើឲ្យជាឯកន្តរិក ( កន្លង ឈានបន្តបន្ទាប់ម្តងមួយ ) យ៉ាងនេះ គឺ ចូលបឋមជ្ឈានក្នុងបឋវីកសិណហើយចូល

តតិយជ្ឈានក្នុងបឋវីកសិណនោះឯង បន្ទាប់ពីនោះ បើកបឋវីកសិណចេញ ចូលអាកាសានញ្ចាយតនៈ ហើយបន្ទាប់ពីនោះ ចូលអាកិញ្ចញ្ញាយតនៈ ដូច្នេះ ឈ្មោះថា **ឈានុក្កន្តក**-កន្លងឈាន ។

សម្បយោជនា ( ការប្រកបសេចក្ដី ) ដែលមានកសិណដ៏សេស មានអាបោកសិណជាអាទិ៍ ជាដើមទៅ ក៏គប្បីធ្វើយ៉ាងនេះដូច្នេះ ។

## ចូលកន្លងកសិណ

ការមិនចូលកន្លងឈាន តែកន្លងកសិណ ដោយធ្វើឲ្យជា **ឯកន្តរិក** ( កន្លងកសិណបន្តបន្ទាប់ម្ដងមួយ ) ដោយន័យនេះ គឺ ចូលបឋមជ្ឈានក្នុងបឋវីកសិណហើយ ចូលបឋមជ្ឈាននោះឯងទៀតក្នុងតេជោកសិណ តពីនោះ ក្នុងនីលកសិណហើយ តពីនោះ ក្នុងលោហិតកសិណ... ដូច្នេះ ឈ្មោះថា **កសិណុក្កន្តក**-កន្លងកសិណ ។

## ចូលកន្លងទាំងឈាន ទាំងកសិណ

ការកន្លងទាំងឈាន ទាំងកសិណដោយន័យនេះ គឺចូលបឋមជ្ឈានក្នុងបឋវីកសិណហើយ តពីនោះ ចូលតតិយជ្ឈានក្នុងតេជោកសិណ បើកនីលកសិណហើយចូលអាកាសានញ្ចាយតនៈ ចូលអាកិញ្ចញ្ញាយតនៈ តពីលោហិតកសិណ ដូច្នេះ ឈ្មោះថា **ឈានកសិណុក្កន្តក**-កន្លងទាំងឈាន ទាំងកសិណ ។

## ចូលរំកិលអង្គ

ចំណែកការចូលបឋមជ្ឈានក្នុងបឋវីកសិណ ហើយចូលឈានសម្បីក្រៅពីនេះគឺទុតិយ... តតិយ... ចតុត្ថ... ក្នុងបឋវីកសិណនោះដូចគ្នា ឈ្មោះថា **អង្គសង្កន្តិក**

( ចូលរំកិលអង្គ ) ។

## ចូលរំកិលអារម្មណ៍

ចូលឈានគ្រប់កសិណយ៉ាងនេះ គឺ ចូលបឋមជ្ឈានក្នុងបឋវីកសិណហើយ ចូលបឋមជ្ឈាននោះឯងក្នុងអាបោកសិណ ។ ល ។ ចូលបឋមជ្ឈាននោះឯងក្នុងឱទាតកសិណ ដូច្នេះ ឈ្មោះថា **អារម្មណសង្កន្តិក**-រំកិលអារម្មណ៍ ។

## ចូលរំកិលទាំងអង្គទាំងអារម្មណ៍

ការរំកិលទាំងអង្គ ទាំងអារម្មណ៍ ដោយឯកន្តរិក ( រំកិលទៅម្តងមួយ ) យ៉ាងនេះ គឺ ចូលបឋមជ្ឈានក្នុងបឋវីកសិណហើយ ចូលទុតិយជ្ឈានក្នុងអាបោ-កសិណ តតិយជ្ឈានក្នុងតេជោកសិណ ចតុត្ថជ្ឈានក្នុងវាយោកសិណ បើកនីល-កសិណហើយ ចូលអាកាសានញ្ចាយតនៈ ចូលវិញ្ញាណញ្ចាយតនៈ បន្ទាប់ពីកសិណ ចូលអាកិញ្ចញ្ញាយតនៈ បន្ទាប់ពីលោហិតកសិណ ចូលនេវសញ្ញានាសញ្ញាយតនៈ បន្ទាប់ពីឱទាតកសិណ ដូច្នេះ ឈ្មោះថា **អង្គារម្មណសង្កន្តិក**-រំកិលទាំងអង្គទាំងអារម្មណ៍ ។

## ការកំណត់មើលអង្គ

ចំណែកការកំណត់មើលត្រឹមតែអង្គឈានយ៉ាងនេះ គឺកំណត់មើលបឋមជ្ឈានថា មានអង្គ ៥ ហើយកំណត់មើលទុតិយជ្ឈានថាមានអង្គ ៣... តតិយជ្ឈានថាមានអង្គ ២... ចតុត្ថជ្ឈាន អាកាសានញ្ចាយតនៈ ។ល។ នេវសញ្ញានាសញ្ញាយតនៈ ក៏មានអង្គពីរយ៉ាងនោះ ដូច្នេះ ឈ្មោះថា **អង្គវវត្ថាបន**-កំណត់មើលអង្គ ។

## កំណត់មើលអារម្មណ៍

ន័យដូចគ្នា ការកំណត់មើលត្រឹមតែអារម្មណ៍យ៉ាងនេះ គឺ កំណត់មើលថា នេះបឋវីកសិណហើយ កំណត់មើលថា នេះអាបោកសិណ ។ល។ នេះឱទាតកសិណ ដូច្នេះ ឈ្មោះថា **អារម្មណវវត្ថាបន**-កំណត់មើលអារម្មណ៍ ។

អាចារ្យមួយពួកត្រូវការឲ្យមានអង្គារម្មណវវត្ថាបន ( ការកំណត់មើលទាំងអង្គទាំងអារម្មណ៍ ) មួយប្រការទៀត តែព្រោះអង្គារម្មណវវត្ថាបនមិនមកក្នុងអដ្ឋកថាទាំងឡាយ អង្គារម្មណវវត្ថាបននោះ ទើបមិនជាការសំខាន់ក្នុងការភាវនា ។

## ការសម្តែងឫទ្ធិជាការធ្ងន់

ប្រការដែលនៅមិនបានហ្វឹកហាត់ចិត្ត ដោយអាការ ១៤ យ៉ាង ដូចពោលមកនេះហើយ ព្រះអាទិកម្មិកយោគាវចរអ្នកមិនធ្លាប់បំពេញភាវនាមកពីមុន នឹងញ៉ាំងការធ្វើឫទ្ធិផ្សេងៗ ឲ្យសម្រេចបាននោះ មិនមែនឋានៈនឹងមានបាន ព្រោះថា សូម្បីតែការបរិកម្មកសិណ ក៏ជាការធ្ងន់ដល់ព្រះអាទិកម្មិកទៅហើយ ម្យ៉ាងទៀត ក្នុងរយ ឬក្នុងពាន់ប៉ុណ្ណោះ នឹងអាចបរិកម្មបាន សម្រាប់អ្នកធ្វើបរិកម្មកសិណបានហើយ ការធ្វើបដិភាគនិមិត្តឲ្យកើតឡើងជាការធ្ងន់ ម្យ៉ាងទៀត ក្នុងរយ ឬក្នុងពាន់ប៉ុណ្ណោះ នឹងអាច ( ធ្វើនិមិត្តឲ្យកើតឡើងបាន ) កាលនិមិត្តកើតឡើងហើយ ការពង្រីកនិមិត្តនោះ ទៅរហូតដល់សម្រេចអប្បនាបាន ក៏ជាការធ្ងន់ ម្យ៉ាងទៀត ក្នុងរយ ឬក្នុងពាន់ប៉ុណ្ណោះ នឹងអាចសម្រេចអប្បនាបាន សម្រាប់អ្នកបានអប្បនាហើយ ការហ្វឹកហាត់ចិត្តដោយអាការ ១៤ ក៏ជាការធ្ងន់ ម្យ៉ាងទៀត ក្នុងរយ ឬក្នុងពាន់ប៉ុណ្ណោះ ទើបអាច ( ហ្វឹកហាត់ចិត្តដោយអាការ ១៤ បាន ) សម្រាប់អ្នកមាន

ចិត្តដែលបានហ្វឹកហាត់ចិត្តដោយអាការ ១៤ ហើយសោត ឯការសម្តែងឫទ្ធិផ្សេងៗបាន ក៏នៅជាការធ្ងន់ មួយវិញទៀត ក្នុងរយ ឬក្នុងពាន់ប៉ុណ្ណោះ ទើបអាច ( សម្តែងឫទ្ធិផ្សេងៗ ) បាន សូម្បីអ្នកសម្តែងឫទ្ធិផ្សេងៗ បានហើយ ភាពជាខិប្បនិសន្តិ ( រួមចិត្តចូលឈានបានឆាប់រហ័ស ) ក៏ជាការធ្ងន់ , មួយវិញទៀត ក្នុងរយ ឬ ក្នុងពាន់ប៉ុណ្ណោះ ទើបជាខិប្បនិសន្តិបាន និទស្សនៈដូចព្រះរក្ខិតត្ថេរ អ្នកមានវស្សា ៨ រាប់តាំងពីឧបសម្បទាមក មួយអង្គក្នុងភិក្ខុអ្នកមានឫទ្ធិប្រមាណ ៣ ម៉ឺនអង្គ ដែលមកព្យាបាលជំងឺព្រះមហារោហណគុត្តត្ថេរ ក្នុងថេរម្ពត្ថលវិហារ ដូច្នោះ អានុភាពរបស់លោក បានពោលទុកក្នុងបឋវីកសិណនិទ្ទេសហើយ ក៏ព្រោះព្រះមហាថេរៈបានឃើញអានុភាពនោះរបស់លោកហើយ ទើបពោលដាស់តឿនភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ បើរក្ខិតៈនឹងមិនបាននៅក្នុងទីនេះហើយ យើងទាំងឡាយក៏នឹងបានទទួលការតិះដៀលថា ភិក្ខុទាំងនេះមិនអាចនឹងការពារស្តេចនាគបាន ព្រោះដូច្នោះ បានឈ្មោះថា អាវុធប្រចាំខ្លួន ដែលនឹងគប្បីកាន់ត្រាច់ទៅ ជម្រះមន្ទិលប្រេះសិនទើបកាន់ត្រាច់ទៅនោះឯង ទើបគួរ ភិក្ខុទាំង ៣ ម៉ឺនអង្គនោះ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ ក៏បានជាខិប្បនិសន្តិគ្រប់អង្គ សូម្បីមានខិប្បនិសន្តិហើយ កម្រនឹងបានជាទីពឹងរបស់អ្នកដទៃ មួយក្នុងរយ ក្នុងពាន់ប៉ុណ្ណោះ ទើបអាចជាទីពឹងរបស់អ្នកដទៃបាន ដូចព្រះថេរៈមួយអង្គ កាលភ្លៀងរងើកភ្លើងដែលមារបណ្តាលឡើងឲ្យប្រព្រឹត្តទៅក្នុងពេលធ្វើគិរិភណ្ឌវាហនបូជា និម្មិតផែនដីឡើងក្នុងអាកាស ការពារភ្លៀងរងើកភ្លើងមិនឲ្យធ្លាក់ចុះមកត្រូវមនុស្សបាន ដូច្នោះ ។

## អ្នកមានបុព្វយោគ

## ចាស់ក្លាមិនចាំបាច់ហ្វឹកហាត់ដូច្នេះ ក៏សម្រេចឫទ្ធិបាន

តែសម្រាប់លោកអ្នកមានបុព្វយោគ ( សេចក្តីព្យាយាមដែលធ្វើអំពីកាលមុន ) ចាស់ក្លា ដូចព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងអគ្គសាវកទាំងឡាយ សូម្បីវៀរចាកការនៃនានុក្រម ( គឺការហ្វឹកហាត់ចិត្តតាមលំដាប់ ) មានប្រការដូចពោលមកនេះ ឥទ្ធិវិកុព្វនៈនេះ និងគុណទាំងឡាយដទៃផ្សេងៗ ដោយបដិសម្ភិទាជាដើម ក៏អាចសម្រេចបាន ដោយអំណាចនៃការបានព្រះអរហត្តដោយពិត ព្រោះហេតុនោះ ព្រះអាទិកម្មិកយោគាវចរ ទើបគួរហ្វឹកហាត់ចិត្ត ដោយអាការ ១៤ នេះ ធ្វើចិត្តឲ្យទន់ឲ្យគួរដល់ការងារ ដោយអំណាចការចូលឈាន ធ្វើឆន្ទៈឲ្យជាធំ និងធ្វើវីរិយៈឲ្យជាធំ ធ្វើចិត្តឲ្យជាធំ ធ្វើវិមង្សាឲ្យជាធំ និងដោយអំណាចការធ្វើឲ្យជាវសី មានអាវជ្ជនវសីជាដើម ទើបធ្វើយោគៈដើម្បីឥទ្ធិវិធចុះ ប្រៀបដូចជាងមាសអ្នកប្រាថ្នានឹងធ្វើគ្រឿងប្រដាប់ផ្សេងៗ ក៏រមែងធ្វើមាសឲ្យទន់គួរដល់ការងារ ដោយកម្មវិធីមានផ្លុំភ្លើងជាដើម ហើយទើបធ្វើបានដូច្នោះ ម្យ៉ាងទៀត ប្រៀបដូចជាងឆ្នាំងអ្នកប្រាថ្នានឹងធ្វើភាជនៈផ្សេងៗ ក៏រមែងធ្វើដីឲ្យជាដីដែលប្រពាច់ល្អ ឲ្យជាដីទន់ ហើយទើបធ្វើបាន ដូច្នោះ តែលោកអ្នកដល់ព្រមដោយបុព្វហេតុ ( គឺ បុព្វយោគដែលពោលហើយ ) សូម្បីប្រព្រឹត្តទៅឲ្យស្ទាត់ជំនាញត្រឹមតែចតុត្ថជ្ឈានក្នុងកសិណទាំងឡាយក៏សម្រេចបាន ។

## វិធីធ្វើយោគៈ

ឯយោគៈក្នុងការធ្វើឥទ្ធិវិធៈឲ្យសម្រេចនោះ នឹងគប្បីធ្វើដោយវិធីណា ព្រះ

មានព្រះភាគ ទ្រង់សម្តែងវិធីនោះ ទើបត្រាស់ថា **សោ ឯវំ សមាហិតេ ចិត្តេ** ភិក្ខុនោះកាលតាំងចិត្តមាំយ៉ាងនេះហើយ ដូច្នេះជាដើម ។

## វិនិច្ឆ័យពាក្យថា សោ ឯវំ សមាហិតេ ចិត្តេ ជាដើម

តទៅនេះជាពាក្យវិនិច្ឆ័យក្នុងវិធីនោះ តាមគន្លងន័យនៃព្រះបាលីនោះឯង ក្នុងបទព្រះបាលីទាំងនោះ បទថា **សោ** គឺព្រះយោគីអ្នកសម្រេចចតុត្ថជ្ឈានហើយនោះ ពាក្យថា **ឯវំ** នោះ ជាពាក្យសម្តែងលំដាប់ចតុត្ថជ្ឈាន ដោយពាក្យនេះ ជាការអធិប្បាយថា បានចតុត្ថជ្ឈានដោយលំដាប់ការសម្រេច ចាប់ផ្តើមអំពីការសម្រេចបឋមជ្ឈានមក , បទថា **សមាហិតេ** គឺតាំងមាំដោយចតុត្ថជ្ឈានសមាធិនេះ , បទថា **ចិត្តេ** សំដៅយករូបាវចរចិត្ត ចំណែកក្នុងបទដ៏សេស មានបទថា **បរិសុទ្ធេ-បរិសុទ្ធ** ជាដើម មានវិនិច្ឆ័យថា ចិត្តឈ្មោះថា **បរិសុទ្ធ** ព្រោះភាវៈ គឺ សេចក្តីបរិសុទ្ធនៃសតិដោយអំណាចឧបេក្ខា ព្រោះបរិសុទ្ធនោះឯង ទើបឈ្មោះថា **ស្អាត** អធិប្បាយថា ផូរផង់ ។

ឈ្មោះថា **មិនមានអង្គណៈ** ព្រោះភាពដែលអង្គណៈ មានរាគៈជាដើម ត្រូវកម្ចាត់ទៅដោយការរលត់ទៅនៃបច្ច័យទាំងឡាយ មានសុខជាដើម ។

ព្រោះភាពមិនមានអង្គណៈនោះឯង ទើបឈ្មោះថា ប្រាសចាកឧបក្កិលេស ព្រោះថា **ចិត្ត** រមែងសៅហ្មងដោយអង្គណៈ ។

ឈ្មោះថា **ចិត្តទន់** ព្រោះជាចិត្តដែលបានអប់រំល្អហើយ អធិប្បាយថា ជាចិត្តដែលដល់នូវភាពជាវសី ( នៅក្នុងអំណាច ) ព្រោះចិត្តដែលប្រព្រឹត្តទៅក្នុងអំណាច លោកហៅថា **ចិត្តទន់** ព្រោះភាពជាចិត្តទន់នោះឯង ទើបជាចិត្តគួរដល់ការងារ អធិប្បាយថា ធន់នឹងការធ្វើ គឺ ប្រើការបាន ចិត្តទន់ជាចិត្តគួរដល់ការងារ

ដូចជា មាសដែលគេខាត់ ឬដេញមន្ទិលល្អហើយ ក៏ទន់ប្រើបានដូច្នោះ ឯភាពទន់និងគួរដល់ការងារទាំងពីរនោះ នឹងមានបានក៏ព្រោះភាពដែលចិត្តបានអប់រំល្អហើយប៉ុណ្ណោះ ដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញធម៌ដទៃត្រឹមតែមួយដែលបានអប់រំធ្វើឲ្យច្រើនហើយ ជារបស់ទន់គួរដល់ការងារដូចជាចិត្តនេះឡើយ ដូច្នេះ ។ ព្រោះភាពដែលចិត្តនោះតាំងមាំក្នុងអាការទាំងឡាយមានភាពជាវត្ថុបរិសុទ្ធជាដើម ទើបឈ្មោះថា **តាំងមាំ** ព្រោះតាំងមាំនោះឯង ទើបឈ្មោះថា ដល់នូវការមិនញាប់ញ័រ អធិប្បាយថា មិនកម្រើក មិនមានសេចក្តីកម្រើកញាប់ញ័រ ឬថា ឈ្មោះថា **តាំងមាំ** ព្រោះតាំងមាំនៅក្នុងអំណាចរបស់ខ្លួនដោយភាពជាចិត្តទន់ គួរដល់ការងារ, ឈ្មោះថា **ដល់នូវភាពមិនញាប់ញ័រ** ព្រោះជាចិត្តដែលមានគុណ មានសទ្ធាជាដើមប្រកបហើយ ពិតមែន ចិត្តដែលសទ្ធាប្រកបហើយ រមែងមិនញាប់ញ័រដោយការមិនជឿ កាលវិរិយៈផ្គងហើយ រមែងមិនញាប់ញ័រដោយភាពខ្ជិលច្រអូស បើសតិប្រកបហើយ រមែងមិនញាប់ញ័រដោយការភ្លេចភ្លាំង បើសមាធិប្រកបហើយ រមែងមិនញាប់ញ័រដោយភាពរវើរវាយ បើបញ្ញាប្រកបហើយ រមែងមិនញាប់ញ័រដោយការមិនដឹង ទៅព្រមនឹងពន្លឺភ្លឺស្វាងនៃញាណហើយ រមែងមិនញាប់ញ័រដោយភាពងងឹត គឺ កិលេស ចិត្តដែលធម៌ ៦ ប្រការនេះប្រកបហើយ រមែងជាចិត្តដល់នូវ ភាពដែលមិនញាប់ញ័រ ចិត្តប្រកបដោយអង្គ ៨ ដូចពោលមកនេះ ទើបជាចិត្តគួរដល់ការងារនាំឆ្ពោះទៅដើម្បីការធ្វើឲ្យជាក់ច្បាស់ ដោយការដឹងដ៏ក្រៃលែងនូវអភិញ្ញាសច្ឆិករណីយធម៌ទាំងឡាយ ។

## វិនិច្ឆ័យព្រះបាលីមួយទៀត

គប្បីជ្រាបន័យដទៃទៀត ឈ្មោះថា **តាំងមាំ** ព្រោះជាសមាធិក្នុងចតុត្ថជ្ឈាន ឈ្មោះថា **បរិសុទ្ធ** ព្រោះភាពជាចិត្តនៅឆ្ងាយពីនីវរណៈ, ឈ្មោះថា **ស្អាត** ព្រោះឈានកន្លងអង្គគ្រោតគ្រាត មានវិតក្កជាដើម, ឈ្មោះថា **មិនមានអង្គណៈ** ព្រោះការមិនមានឥច្ឆាវចរៈ ( ការត្រាច់រង្គាត់ទៅនៃសេចក្តីប្រាថ្នា ) ទាំងឡាយដ៏ថោកទាប ក៏ជាសត្រូវនៃការបានឈាន, ឈ្មោះថា **ប្រាសចាកឧបក្កិលេស** ព្រោះការប្រាសទៅនៃគ្រឿងសៅហ្មងចិត្ត មានអភិជ្ឈាជាដើម ក៏ ( បទទាំងពីរ គឺ **អនង្គណៈ** និង **វិកតុបក្កិលេស** ) នេះ គប្បីជ្រាបតាមទំនងសេចក្តីក្នុងអនង្គណសូត្រ និងវត្ថសូត្រចុះ , ឈ្មោះថា **ជាចិត្តទន់** ព្រោះដល់នូវភាពជាវសី , ឈ្មោះថា **គួរដល់ការងារ** ព្រោះចូលដល់ភាពជាបាទនៃឥទ្ធិ , ឈ្មោះថា **តាំងមាំ** ព្រោះដល់នូវភាពមិនញាប់ញ័រ មានសេចក្តីថា តាំងមាំ , វត្ថុដែលមិនញាប់ញ័រ ព្រោះចូលដល់ភាពជាចិត្តប្រណីត ដោយភាពបរិបូរណ៍នៃភាវនា ។

ចិត្តប្រកបដោយអង្គ ៨ ដោយន័យនេះ ក៏ជាចិត្តគួរដល់ការនាំឆ្ពោះទៅ គឺជាបាទ ជាបទដ្ឋាន ( ហេតុជិត ) ដើម្បីធ្វើឲ្យជាក់ច្បាស់ដោយការដឹងដ៏ក្រៃលែងនូវអភិញ្ញាសច្ឆិករណីយធម៌ទាំងឡាយ ដូច្នេះ ។

## វិនិច្ឆ័យសព្ទ ឥទ្ធិ-ឫទ្ធិ

គប្បីជ្រាបវិនិច្ឆ័យក្នុងបាលីថា នាំចិត្តឆ្ពោះទៅ បង្អោនចិត្តឆ្ពោះទៅ ដើម្បីការសម្តែងឫទ្ធិនេះតទៅ វត្ថុដែលឈ្មោះថា **ឫទ្ធិ** ព្រោះអត្ថថា សម្រេច មានអធិប្បាយថា ព្រោះអត្ថថា កើតផល និងព្រោះអត្ថថា បានចំពោះ ព្រោះថា វត្ថុណាកើតផល

និងបុគ្គលបានចំពោះនូវវត្ថុណា វត្ថុនោះក៏ហៅបានថា សម្រេច ដូចព្រះបាលីក្នុងកាមសូត្រថា **កាមំ កាមយមានស្ស តស្ស ចេតំ សមិជ្ឈតិ** កាលបុគ្គលប្រាថ្នាវត្ថុកាម បើវត្ថុដែលប្រាថ្នានោះសម្រេចដល់បុគ្គលនោះ ( គឺគេបានតាមប្រាថ្នា ) សោតន័យដូចគ្នា បាលីថា **នេក្ខម្ម** ឈ្មោះថា **ឫទ្ធិ** ព្រោះសម្រេច គឺកើតផល ឈ្មោះថា **បាដិហារិយ** ព្រោះនាំចេញនូវបដិបក្ខធម៌ , **អរហត្តមគ្គ** ឈ្មោះថា ឫទ្ធិ ព្រោះសម្រេច គឺ បានសម្រេច ឈ្មោះថា **បាដិហារិយ** ព្រោះនាំចេញនូវបដិបក្ខធម៌ ។

ន័យម្យ៉ាងទៀត ឈ្មោះថា **ឫទ្ធិ** ព្រោះអត្ថថា សម្រេច គឺកើតផល , ពាក្យថា **ឫទ្ធិ** នេះ ជាឈ្មោះនៃឧបាយសម្បទា ( ការដល់ព្រមនៃឧបាយ ) ពិតមែនឧបាយសម្បទា រមែងសម្រេច គឺឲ្យផល ព្រោះជាហេតុឲ្យកើតផលតាមប្រាថ្នា ដូចបាលីថា ចិត្តគហបតីនេះឯង ជាអ្នកមានសីល មានធម៌ដ៏ល្អ បើប្រាថ្នាថា ក្នុងអនាគតកាល សូមឲ្យយើងបានជាស្តេចចក្រពត្តិចុះដូច្នេះ សេចក្តីប្រាថ្នារបស់លោកនឹងសម្រេច គឺ កើតផលជាពិតប្រាកដ ព្រោះការតាំងចិត្តប្រាថ្នារបស់អ្នកមានសីលជាកិរិយាដ៏ស្អាតដូច្នេះ ។

ន័យម្យ៉ាងទៀត សត្វទាំងឡាយ រមែងសម្រេច គឺ ចម្រើននូវគុណជាតិនោះ ព្រោះហេតុនោះ គុណជាតិនោះ ទើបឈ្មោះថា **ឫទ្ធិ** មានអធិប្បាយថា ពាក្យថា **ឥជ្ឈន្តិ** សម្រេចន័យនេះ បំណងយកសេចក្តីថា ជាអ្នកចម្រើនរុងរឿង ។

# មហាដីកា

## ឥទ្ធិវិធនិទ្ទេសវណ្ណនា

លោកអាចារ្យកាលនឹងសម្ដែងសេចក្ដីនៃសមាធិកថា មានអានិសង្សជិតៗ ឃើញបានប្រចក្សក្នុងលំដាប់ ដោយទាក់ទងនឹងពាក្យសំវណ្ណនា ទើបពោលថា សមាធិភាវនានេះជាដើម ។ លោកអាចារ្យកាលពោលហើយថា គប្បីធ្វើសេចក្ដីព្យាយាមដើម្បីការសម្រេចអភិញ្ញាដូច្នេះហើយ ប្រាថ្នាសម្ដែងប្រយោជន៍ពិសេសទាំងឡាយ ក្នុងការធ្វើសេចក្ដីព្យាយាមដើម្បីការសម្រេចអភិញ្ញានោះ ទើបពោលថា ព្រោះថា កាលបើយ៉ាងនេះដូច្នេះជាដើម ។ ភាពមាំទាំក្រៃលែង និង ការសុខស្រួលនៃវិបស្សនា ចាត់ជាអានិសង្សនៃសមាធិភាវនានោះឯង ក៏ពិត សូម្បីយ៉ាងនោះ លោកិយអភិញ្ញា ៥ យ៉ាង ក៏ត្រូវប្រាកដ គឺ ដឹងដោយភាពជាអានិសង្សនៃសមាធិភាវនាតាមដែលពោលហើយ ព្រោះហេតុនោះ ទើបលោកពោលដល់សមាធិភាវនាមានអានិសង្ស ដែលព្រះយោគីបានសម្រេច ដោយទាក់ទងនឹងអភិញ្ញាពួកនោះ ៗ ឯង ។ និងពោលដល់សមាធិដែលមាំទាំក្រៃលែងដោយការហ្វឹកហាត់ចិត្ត ដោយអាការ ១៤ ទុក ។ សូម្បីភាពជាវសីក្នុងលោកិយអភិញ្ញាទាំងឡាយ ក៏បានដល់ភាពជាវសីនៃសមាធិនោះឯង , ម្យ៉ាងទៀត យ៉ាងនោះដូចគ្នា លោកពោលថា នឹងធ្វើបញ្ញាភាវនាឲ្យសម្រេចបានដោយងាយផងដែរ ព្រោះមានព្រះពុទ្ធវចនៈថា **សមាហិតោ យថា ភូតំ បជានាតិ** ( ភិក្ខុមានចិត្តតាំងមាំ រមែងដឹងច្បាស់ទៅតាមសេចក្ដីពិតបាន ) ដូច្នេះ ។ ពាក្យថា **ព្រោះដូច្នោះ** អធិប្បាយថា ព្រោះហេតុដែលការបានអានិសង្ស ភាពមាំមួនដ៏ក្រៃលែងនៃសមាធិភាវនា បញ្ញាភាវនានឹងសម្រេច

បានដោយប្រពៃផងដែរ ដូច្នោះ ខ្ញុំនឹងផ្ដើមកថាស្ដីអំពីអភិញ្ញាមុន ។ ចំណែកឱកាសនៃបញ្ញាការនាទីនឹងមានមកដល់តាមក្រោយ ។

ក្ខាប់សេចក្ដីថា **ភគវតា បញ្ចលោកិកាភិញ្ញាវត្ថា** ព្រះមានព្រះភាគត្រាស់លោកិយអភិញ្ញា ៥ យ៉ាង ក្នុងព្រះសាសនានេះ មិនមែនត្រឹមតែឈាន ៤ ប៉ុណ្ណោះទេ ដែលភិក្ខុគប្បីធ្វើឲ្យសម្រេច , ទាំងមិនមែនឥទ្ធិវិធញ្ញាណប៉ុណ្ណោះទេ តែថា សូម្បីយ៉ាងដទៃក៏មាន ព្រោះហេតុនោះ ទើបទ្រង់ត្រាស់អភិញ្ញា ៥ ទុកដើម្បីទ្រង់សម្ដែង... និងដើម្បីទ្រង់សម្ដែងធម៌ដ៏ប្រណីត ដ៏ប្រណីតក្រៃលែងឡើងទៅៗ ។

ពាក្យថា **ឥទ្ធិវិកុព្វនា** បានដល់ កិរិយាដែលលះរូបរាងប្រក្រតី ដែលរាប់ថាជាឫទ្ធិ , ពាក្យនេះលោកពោលទុកដោយភាពដែលវិកុព្វនាឥទ្ធិជាប្រធាន ក្នុងបណ្ដាឫទ្ធិទាំងឡាយ , ម្យ៉ាងទៀត គប្បីឃើញភាពយ៉ាងនេះថា ឥទ្ធិ និងវិកុព្វនា ( ឫទ្ធិ និងការធ្វើឲ្យក្លាយជារបស់ផ្សេង ៗ បាន ) ។ គប្បីឃើញថា ជាការកាន់យកវិកុព្វនាមួយផ្នែក ដោយហេតុដែលពោលហើយនោះឯង ។ អរូបសមាបត្តិទាំងឡាយ រមែងមិនកើតឡើងដោយអំណាចនៃអាកាសកសិណទេ ឯលោកក៏ធ្វើអាលោកកសិណឲ្យទាក់ទងក្នុងឱទាតកសិណ ពោលថា ដែលមានឱទាតកសិណជាទីបំផុតដូច្នេះ ។ ព្រោះប្រារព្ធវិធីហ្វឹកហាត់ចិត្ត ដោយអាការមានតាមលំដាប់កសិណជាដើម , តែថា សូម្បីកសិណទាំងពីរនោះ គឺ អាកាសកសិណ និងអាលោកកសិណ ក៏គប្បីត្រូវការដូចគ្នា ដើម្បីប្រយោជន៍ដល់ការនិម្មិតអាកាសជាដើម ។ ប្រការថា **អដ្ឋ អដ្ឋ** ( ១កសិណ ៨សមាបត្តិ ) គឺ ក្នុងបណ្ដាកសិណតាមដែលពោលមកហើយ ១កសិណ ៨សមាបត្តិ ។ ពាក្យថា **ដោយតាមលំដាប់កសិណ** គឺ តាមលំដាប់នៃកសិណ ។ ក៏គប្បីជ្រាបថា ជាលំដាប់ដោយ

ទាក់ទងនឹងទេសនា ។ រីឯតាមលំដាប់ឈាន គប្បីជ្រាបថា ជាលំដាប់ ព្រោះទាក់ទងនឹងការបដិបត្តិ ។ **ឧក្កមនំ** ( ការកន្លង ឈ្មោះថា **ឧក្កមន្តំ** ) **ឧក្កមន្តំ** នោះឯងជា **ឧក្កន្តកំ** ការកន្លងឈានឈ្មោះថា **ឈានុក្កន្តកំ** បានដល់ ដោយការកន្លងឈាននោះ មានសេចក្តីថា ដោយការកន្លងឈាន គឺដោយការកន្លងឈាននោះ ។ ពាក្យថា **ដោយការរំកិលអង្គ** គឺ ដោយការឆ្លងអង្គ ។ ភិក្ខុគប្បីហ្វឹកហាត់ចិត្តដើម្បីកំណត់លក្ខណៈក្នុងការចូលឈានជាដើមបាន ក្នុងពេលដែលត្រូវការ ក្នុងស្ថានទីដែលត្រូវការ , ម្យ៉ាងទៀត ក្នុងការចូលឈាននេះ ដើម្បីកំណត់អារម្មណ៍ទាំងឡាយនៃឈានពួកនោះដែរ ។ ព្រោះថា កាលបើយ៉ាងនេះ លោកក៏រមែងសម្រេចភាពស្ទាត់ជំនាញ ក្នុងការចូលឈានជាដើមបាន ។

ពាក្យថា **រមែងចូលឈាន** សួរថា រមែងចូលឈានទាំង ៤ យ៉ាងឬ ឬថាតែម្យ៉ាងក៏បានហ្ន៎ ? ព្រោះក្នុងការចូលឈាននេះ បើត្រូវការចូលឈានទាំង ៤ យ៉ាង ក៏មិនមានប្រការផ្សេងគ្នាអំពីការរំកិលអង្គ ប្រសិនបើត្រូវចូលឈានតែម្យ៉ាងណាមួយ ក៏មិនមានប្រការផ្សេងគ្នាអំពីការរំកិលអារម្មណ៍ , ឆ្លើយថា នេះមិនមែនជាប្រការដែលខុសទេ ព្រោះអាការទាំងនោះសម្រេចភាពផ្សេងគ្នា ដោយអំណាចនៃការនឹកគិត , គឺ គប្បីជ្រាបថា ក្នុងពេលណាភិក្ខុនឹកគិតដល់តែការចូលឈានតាមលំដាប់កសិណប៉ុណ្ណោះ ហើយចូលឈានទាំងឡាយក្នុងកសិណនោះៗ មិនបាននឹកគិតដល់ការរំកិលអង្គ ហើយចូលឈាន ក្នុងពេលនោះ ក៏ឈ្មោះថា មានការចូលឈានតាមលំដាប់កសិណ ។ ចំណែកក្នុងពេលណានឹកគិតដល់ការរំកិលអង្គ ហើយចូលឈានទាំងឡាយ ក្នុងពេលនោះក៏ឈ្មោះថា មានការរំកិលអង្គ ។ បណ្ឌិតគប្បីជ្រាបប្រការប្លែកផ្សេងគ្នា សូម្បីនៃអាការ មានការតាមលំដាប់កសិណ ការរំកិល

អារម្មណ៍ជាដើម ក៏តាមន័យនេះ ។ អធិប្បាយថា ការហ្វឹកហាត់ចិត្តប្រការនេះ ឈ្មោះថា **កសិណានុលោម** គឺ តាមលំដាប់កសិណ ។

បទថា **តថេវ-ដោយប្រការនោះដូចគ្នា** មានសេចក្តីថា **តថា**-ស័ព្ទ មានសេចក្តីថា នាំពាក្យថា **បដិបាដិយា អដ្ឋសុ កសិណេសុ សតក្ខត្តុម្បិ សហស្សក្ខត្តុម្បិ** សូម្បីត្រឹម ១០០ ដង សូម្បីត្រឹម ១០០០ ដង ក្នុងកសិណ ៨ តាមលំដាប់ចូលទៅប្រៀបផ្ទឹម ។ ក៏ក្នុងអាការនេះជាលំដាប់ដោយបដិលោម ។ ព្រោះហេតុនោះ ទើបលោកពោលថា ដោយបំព្រួញលំដាប់ ដូច្នេះ ។ ក៏ក្នុងអាការនេះមានអត្ថាធិប្បាយយ៉ាងនេះថា ភិក្ខុចូលឈានក្នុងឱទាតកសិណមុន បន្ទាប់ពីនោះទៅក៏ចូលឈានក្នុងលោហិតកសិណជាដើម គប្បីពោលទៅរហូតដល់បឋវីកសិណចុះ ។

ពាក្យថា **ការចូលឈានហើយចូលទៀត** លោកពោលដល់អាការចូលច្រើនដង ដែលបានពោលហើយថា ១០០ ដង ១០០០ ដង ។

បទថា **តត្ថេវ** គឺ ក្នុងបឋវីកសិណនោះឯង ។

ពាក្យថា **បន្ទាប់ពីនោះទៅ** គឺ ពេលក្រោយ បានដល់ ពេលដទៃដែលបានចេញចាកឈានទី ៣ ហើយ ។ បទថា **តទេវ** គឺ បឋវីកសិណនោះឯង ។ ពាក្យថា **បន្ទាប់ពីនោះទៅ ក៏ចូលអាកិញ្ចញ្ញាយតនៈ** មានសេចក្តីថា បន្ទាប់ពីនោះទៅក៏ចេញចាកអាកាសានញ្ចាយតនសមាបត្តិ ដែលប្រព្រឹត្តទៅក្នុងអាកាស ដែលបើកបឋវីកសិណ មិនមនសិការវិញ្ញាណញ្ចាយតនៈ ធ្វើវិញ្ញាណញ្ចាយតនៈនោះ ចេញហើយ ក៏ចូលអាកិញ្ចញ្ញាយតនៈដែលប្រព្រឹត្តទៅក្នុងការមិនមាននៃអាកាសានញ្ចាយតនវិញ្ញាណ តាមដែលពោលមកហើយ ។ **កសិណ** គឺ អាកាសដែលបើកបឋវីកសិណ រមែងជាបក្ខពួកនៃបឋវីកសិណនោះឯង ព្រោះហេតុនោះ ទើបលោក

ពោលថា ការមិនកន្ទុងកសិណដូច្នេះ ។ ន័យម្យ៉ាងទៀត ការកន្ទុងកសិណណាៗ ក្នុងបណ្តាកសិណ ៨ ឈ្មោះថា ជាការកន្ទុងកសិណក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកពោលថា សូម្បីការកន្ទុងតែឈាន មិនកន្ទុងកសិណអ្វីៗ ក្នុងបណ្តាកសិណ ៨ ថា ការមិនកន្ទុងកសិណដូច្នេះ ក្នុងពាក្យថា ការកន្ទុងឈាននេះ គប្បីហាមកសិណដែលត្រូវការដោយពាក្យអវធារណៈ គឺជា **ឈានុក្កន្តិកមេវ** ( ការកន្ទុងឈានប៉ុណ្ណោះ ) និងដើម្បីសម្តែងសភាវៈដែលមានប្រាកដនៃការកន្ទុងនោះ លោកអាចារ្យកាលពោលថា **ឯវំ កសិណំ** ជាដើមហើយ និងបន្តលបង្ហាញប្រការនោះទៀត ក្នុងកសិណដ៏សេសទាំងឡាយ ព្រមទាំងទីអាស្រ័យ ទើបពោលថា គប្បីធ្វើពាក្យប្រកបសេចក្តី សូម្បីដែលមានអាបោកសិណជាដើម ជាមូល តាមន័យដូចពោលមកនេះ ដូច្នេះ ព្រោះហេតុនោះឯង ទើបលោកពោលថា ដោយន័យនេះ ដូច្នេះជាដើម ។ ការកន្ទុងឈានក្នុងកសិណទាំងឡាយ មានបឋវីកសិណជាដើម ដែលមានបឋមជ្ឈានជាមូល គឺ លោកអាចារ្យបានសម្តែងហើយ ដោយប្រការណា សូម្បីការកន្ទុងឈានក្នុងបឋវីកសិណជាដើមនោះ ដែលមានទុតិយជ្ឈាន ជាដើមជាមូល បណ្ឌិតគប្បីសម្តែងបានតាមសមគួរដោយប្រការនោះ ។

បទថា **តទេវ** គឺ បឋមជ្ឈាននោះឯង សូម្បីក្នុងការកន្ទុងកសិណ បណ្ឌិតក៏គប្បីធ្វើពាក្យប្រកបតាមសេចក្តីដែលមានអាបោកសិណជាដើមជាមូល តាមន័យដែលបានពោលហើយដូចគ្នា គប្បីធ្វើពាក្យប្រកបសេចក្តីដែលមានទុតិយជ្ឈានជាដើម ជាមូល តាមន័យដែលបានពោលមកហើយនោះដូចគ្នាតាមសមគួរ ។

ពាក្យថា **ចេញអំពីលោហិតកសិណក៏ចូលអាកិញ្ចញ្ញាយតនៈ** គឺនឹកដល់លោហិតកសិណ ធ្វើទុកចំពោះមុខហើយ ក៏ចូលអាកាសានញ្ចាយតនជ្ឈាន ដោយ

មិនមនសិការ គឺ មិនធ្វើទុកក្នុងចិត្តក្នុងអាកាសដែលបើកកសិណដែលប្រាកដហើយ ដោយការបើកលោហិតកសិណនោះ ហើយទើបធ្វើការប្រាសទៅនៃវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងពេលមុន ក្នុងពេលដែលបើកលោហិតកសិណនោះ ឲ្យជាអារម្មណ៍ចូលអាកិញ្ចញ្ញាយតនៈ ។

ពាក្យថា **ចូលឈានដ៏សេស** គឺ រូបាវចរឈានដ៏សេសទាំងឡាយ ។ ព្រោះថា មិនមានការរំកិលអង្គក្នុងអរូបជ្ឈានទាំងឡាយ ។ ទាំងអរូបជ្ឈានទាំងនោះក៏មិនបានប្រព្រឹត្តទៅក្នុងបឋវីកសិណ ។ ចំណែកពាក្យណា ដែលលោកពោលថា បើកនីលកសិណហើយ ចូលអាកាសានញ្ចាយតនៈដូច្នេះ ដែលជាពាក្យពោលដល់ការពន្យាអង្គ និងអារម្មណ៍ ពាក្យនោះ បណ្ឌិតគប្បីឃើញថា លោកពោលទុកដោយទាក់ទងនឹងឈានតាមដែលបាន គឺដោយបរិយាយនោះឯង ។ ចំណែកដោយនិប្បរិយាយ ការរំកិលអារម្មណ៍រមែងបានក្នុងរូបជ្ឈានទាំងឡាយប៉ុណ្ណោះ ដូចជាការពន្យាអង្គ រមែងបានក្នុងរូបជ្ឈានទាំងឡាយប៉ុណ្ណោះដូច្នោះ ។ ពិតមែន សេចក្តីដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ដទៃនៃឈាននោះៗ នុ៎ះឯងឈ្មោះថា ការរំកិលអារម្មណ៍ ។ ព្រោះហេតុនោះ ទើបលោកពោលថា ការចូលចំពោះឈានមួយប៉ុណ្ណោះក្នុងកសិណទាំងពួង ឈ្មោះថា ការរំកិលអារម្មណ៍ ដូច្នេះ ។

ដូចជា អ្នកណាៗ មិនអាចនឹងពោលថា សូម្បីកសិណ គឺអាកាសវិញ្ញាណទាំងឡាយ ក៏មានការសង្គ្រោះដោយស័ព្ទថា ក្នុងកសិណទាំងពួងដូច្នេះបាន ព្រោះក្នុងការហ្វឹកហាត់ចិត្តនេះ កសិណ ៨ ប៉ុណ្ណោះ ជាអារម្មណ៍ដែលព្រះយោគីសម្រេចយ៉ាងណា អ្នកណាៗ ក៏មិនអាចនឹងពោលដល់អរូបជ្ឈាន សូម្បីទាំងពួងថា ឈានមួយដូច្នេះក៏បាន ព្រោះការហ្វឹកហាត់ចិត្តដោយការទាក់ទងនឹងសមាបត្តិ ៨ ជាកិច្ច

ដែលព្រះយោគីប្រាថ្នាដូច្នោះ ។ ព្រោះដូច្នោះ គប្បីជ្រាបការរំកិលអង្គ និងអារម្មណ៍ ដោយទាក់ទងនឹងពួកអរូបជ្ឈាន ជាការដែលលោកពោលដោយបរិយាយ ។ ពិតយ៉ាងនោះ អរូបវិញ្ញាណដួងដំបូងក្នុងអាកាសដែលបើកបីតកសិណឯណា លោកអាចារ្យសំដៅយកវិញ្ញាណញ្ចាយតនៈដែលមានរូបវិញ្ញាណដួងដំបូងនោះជាអារម្មណ៍ពោលថា បន្ទាប់ពីបីតកសិណ ក៏ចូលវិញ្ញាណញ្ចាយតនៈ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាប អត្ថាធិប្បាយសូម្បីក្នុងពីរបទដ៏សេសដោយន័យនេះ បទថា **ឯកន្តរិកវសេន** មានសេចក្តីថា ***អន្តរ***-សត្រូ មានអត្ថថាដទៃ ។ ***អន្តរ*** នោះឯងជា ***អន្តរិក*** , ការចូលឈានឈ្មោះថា **ឯកន្តរិក** ព្រោះអត្ថថា ជាទីដែលមានឈាន ( ឬកសិណ ) ដទៃរួមគ្នា បានដល់ ដោយទាក់ទងនឹងការចូលឈាន ដែលឈ្មោះថា **ឯកន្តរិក** នោះ អង្គឈានទាំងឡាយ និងអារម្មណ៍រមែងមានខប្លែកគ្នាដោយប្រការដទៃ រួមគ្នាបានយ៉ាងណា ក៏រមែងមានការប្លែកគ្នា ដោយការទាក់ទងនឹងការចូលក៏ដូច្នោះ ។ ក៏ប្រការប្លែកគ្នានោះ រមែងមានបានដោយទាក់ទងនឹងការឆ្លងអង្គ និងអារម្មណ៍នៃឈានថ្នាក់ទាបពួកនោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ការរំកិលអង្គទាំងឡាយ និងអារម្មណ៍ទាំងឡាយ តាមរយៈការមានឈាន ឬកសិណដទៃរួមគ្នាទៅដូច្នេះ ។ កាលមានការកំណត់អង្គទាំងឡាយដោយន័យថា ឈាននេះមានអង្គ ៥ ជាដើម និងអារម្មណ៍ទាំងឡាយដោយន័យថា បឋវីកសិណជាដើម ក៏រមែងមិនមានប្រការផ្សេងគ្នាណាៗ ក្នុងការកំណត់អង្គ និងអារម្មណ៍ទាំងនោះរួមគ្នា ព្រោះហេតុនោះ វិធីនេះ ទើបលោកមិនបានដកមកក្នុងអដ្ឋកថាទាំងឡាយ ។ ក៏ព្រោះធ្វើអត្ថាធិប្បាយយ៉ាងនេះ ក្នុងអាការមានការកន្លងឈានជាដើម ការកន្លងឈានជាដើមមានបានដោយភាវៈដែលមានឈាន ឬកសិណដទៃរួមគ្នា លោកមិនបានលើកឡើង

ទុកដោយជាវិធីតាមលំដាប់ វិធីបំពេញលំដាប់ និងវិធីតាមលំដាប់ និងបំពេញលំដាប់ ។ ការហ្វឹកហាត់ចិត្តសូម្បីរៀនន័យពួកនោះ ក៏សម្រេចបាន ព្រោះហេតុនោះ ដើម្បីចៀសវាងភាពយឺតយូរវិធីនោះ ទើបមិនបានដកមកក្នុងអដ្ឋកថាទាំងឡាយ ។

ពាក្យថា **អ្នកមិនបានការអប់រំភាវនាទុក** គឺ អ្នកមិនបានកសាងបុញ្ញាធិការទុកក្នុងឈាន និងអភិញ្ញាទាំងឡាយ អាចារ្យពួកខ្លះពោលថា រួមទាំងអ្នកប្រាសចាកឧបនិស្ស័យក្នុងឈាន និងអភិញ្ញានោះៗ ។ ការធ្វើសេចក្ដីព្យាយាមដែលជាចំណែកខាងដើម ឈ្មោះថា **អាទិកម្ម** ព្រះយោគាវចរឈ្មោះថា **អាទិកម្មិក** ព្រោះអត្ថថាមាន**អាទិកម្ម**នោះ បានដល់ អ្នកមិនបានធ្វើការសន្សំពីមុន ប្រកបរឿយៗ នូវភាវនា ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ក៏ប្រការថា ព្រះយោគាវចរ ដូច្នេះជាដើម , ពាក្យថា **សូម្បីការបរិកម្មកសិណ ក៏ចាត់ថាជាភារៈធ្ងន់** អធិប្បាយថា ឈ្មោះថា ការបរិកម្មក្នុងកសិណ ដើម្បីការកើតឡើងនៃឧគ្គហនិមិត្ត ដោយការបដិបត្តិក្នុងដួងកសិណ ដោយវិធីការចៀសវាងទោសនៃកសិណជាដើមនោះ ក៏ចាត់ជាភារៈធ្ងន់ នឹងពោលទៅថ្វីដល់ឥទ្ធិវិកុព្វនា ( ឫទ្ធិ និងការធ្វើបានផ្សេងៗ ) ។ ពាក្យថា **ការធ្វើនិមិត្តឲ្យកើតឡើង** គឺ ការធ្វើបដិភាគនិមិត្តឲ្យកើតឡើង ។ ពាក្យថា **ការពង្រីកនិមិត្តនោះ** គឺ ពង្រីកនិមិត្ត និងភាវនានោះ ។ សេចក្ដីពិតថា វៀរភាវនាចេញប៉ុណ្ណោះ ការពង្រីកនិមិត្តក៏មានមិនបាន ។ ព្រះយោគាវចរពួកខ្លះបានឧបចារសមាធិហើយ ក៏មិនអាចសម្រេចអប្បនាសមាធិបាន ព្រះយោគាវចរសូម្បីដូច្នេះ រមែងមានច្រើនតែម្ដង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ការពង្រីកនិមិត្តនោះរហូតដល់សម្រេចអប្បនាបាន ក៏ចាត់ជាភារៈធ្ងន់ ។ម្យ៉ាងទៀត ពាក្យថា **ការសម្រេចអប្បនាបាន** លោកពោលដល់ការសម្រេចសមាបត្តិ ៨ ។

ឧបនិស្ស័យនៃសមាបត្តិទាំងឡាយជាផ្នែកមួយ ឧបនិស្ស័យនៃអភិញ្ញាទាំងឡាយក៏ជាផ្នែកមួយ ព្រោះហេតុនោះ លោកទើបពោលថា សូម្បីសម្រាប់ព្រះយោគាវចរអ្នកហ្វឹកហាត់ចិត្ត ដោយអាការ ១៤ បានហើយ ឈ្មោះថា **ឥទ្ធិវិកុព្វនា** ចាត់ជាការៈធ្ងន់ ។ ព្រះយោគាវចរឈ្មោះថា **ខិប្បនិសន្តិ** ព្រោះអត្ថថា មានការសម្លឹងមើល គឺ សម្លឹង បានដល់ សម្លឹងអារម្មណ៍របស់ឈាន មានបឋវីកសិណជាដើម បានឆាប់រហ័ស បានដល់ ភាវៈដែលចូលឈានបានរហ័ស ភាវៈនៃខិប្បនិសន្តិនោះ ឈ្មោះថា **ខិប្បនិសន្តិភាវោ**-ភាពជាអ្នកសម្លឹងបានឆាប់រហ័ស ។ ស្ថានទីដែលពោរពេញដោយដើមស្វាយខ្ចី ដែលពួកព្រះថេរៈ មានព្រះមហាមហិន្ទត្ថេរជាដើមនិមន្តចុះ ឈ្មោះថា ថេរម្ពត្ថលៈ លោកអាចារ្យប្រាថ្នាសេចក្ដីនេះថា ប្រៀបដូចជាពួកដែលមានអាជីពជាអ្នកចម្បាំង រមែងកាន់យកអាវុធ មានដាវ និងលំពែងជាដើម ដែលប្រាសចាកស្នឹមប៉ុណ្ណោះ ត្រាច់ទៅដើម្បីយកឈ្នះ គូបដិបក្ខយ៉ាងណា សូម្បីភិក្ខុក៏គប្បីប្រើឈាន និងអភិញ្ញាដែលប្រាសចាកមន្ទិលប៉ុណ្ណោះដើម្បីយកឈ្នះកិលេសដូច្នោះ ទើបពោលថា **ព្រោះដូច្នោះ** ដូច្នេះជាដើម ។

ពាក្យថា **ជាទីពឹងនៃអ្នកដទៃ** ក្នុងទីនេះ ប្រាថ្នាយកការរំងាប់អន្តរាយដល់មនុស្សដទៃបាន ។ ពិតមែន ការរំងាប់អន្តរាយដល់អ្នកដទៃបាននោះ ជាការៈធ្ងន់ក្រៃលែងជាងភាពជាខិប្បនិសន្តិ ព្រោះកើតបានដោយលំបាកជាង ជាវត្ថុដែលភិក្ខុគប្បីចាត់ចែងបានដោយអំណាចការធ្វើកិច្ចដ៏ប្រញាប់ឲ្យសម្រេចបាន ។ ក៏លោកអាចារ្យប្រាថ្នាបើកបង្ហាញការរំងាប់អន្តរាយដល់អ្នកដទៃ ដែលសាធកៈហើយដោយរឿងរបស់ព្រះរក្ខិតត្ថេរនោះឯង ដោយរឿងការការពារភ្លៀងរងើកភ្លើង ដែលជាកិច្ចដ៏ធ្ងន់ លំបាកក្រៃលែងជាងនោះ ទើបពោលថា ដូចព្រះបរិត្តាយកត្ថេរ ។ ល ។

ក្នុងពិធីគិរិភណ្ឌវាហនបូជា ក៏និម្មិតផែនដីឡើងក្នុងអាកាស ជាគ្រឿងការពារភ្លៀងរងើកភ្លើងដូច្នោះ ដូច្នេះ ។ ឈ្មោះថា **ពិធីគិរិភណ្ឌវាហនបូជា** បានដល់ វិធីបូជាដោយប្រទីបដ៏ធំក្រៃលែងទូទាំងកោះ ចាប់តាំងពីគិរិចេតិយជាដើមទៅ និងក្នុងសមុទ្រចម្ងាយ ១ យោជន៍ ។

ពាក្យថា **និម្មិតផែនដី** មានសេចក្តីថា និម្មិតផែនដីឡើងក្នុងអាកាសមានទំហំប៉ុននឹងភ្លៀងរងើកភ្លើង ដែលមារធ្វើឲ្យប្រព្រឹត្តទៅ ក៏ធ្លាក់ត្រូវខ្លួនមនុស្សទាំងឡាយមិនបានឡើយ សូម្បីត្រឹមតែមួយគ្រាប់ ។

ពាក្យថា **អ្នកមានបុញ្ញយោគដែលមានកម្លាំង** មានសេចក្តីថា អ្នកមានឧបនិស្ស័យក្រាស់ បានដល់ អ្នកមានអភិនីហារច្រើន ដែលជាហេតុនៃអភិញ្ញាទាំងឡាយ មានឥទ្ធិវិធជាដើម ។ ដោយ**អាទិ**-ស័ព្ទ( ប្រែថា ជាដើម )ក្នុងបទថា **អគ្គសាវកាទីនំ**-ព្រះអគ្គសាវកជាដើម លោករួមយកព្រះមហាសាវកទាំងឡាយខ្លះផង ។ ឈ្មោះថា លំដាប់នៃការនៃទា បានដល់ ការហ្វឹកហាត់ចិត្តតាមដែលពោលមកហើយ ។ **អាទិ**-ស័ព្ទ ក្នុងបទថា **បដិសម្ភិទាទិ**-បដិសម្ភិទាជាដើម គប្បីឃើញថារួមយកញាណដែលដឹងឋានៈ និងអឋានៈជាដើមផងដែរ មិនមែនចំពោះតែអភិញ្ញាដ៏សេសប៉ុណ្ណោះទេ ។ ពិតមែន សូម្បីព្រះសាវកទាំងឡាយ ក៏សម្រេចញាណដែលដឹងឋានៈ និងអឋានៈជាដើមបានផងដែរ ។ ពាក្យថា **ព្រោះដូច្នោះ** មានសេចក្តីថា ព្រោះហេតុដែលវៀរលំដាប់នៃការនៃទាតាមដែលពោលមកហើយ អភិញ្ញាទាំងឡាយរមែងសម្រេចដល់បុគ្គល អ្នកដល់ព្រមដោយបុញ្ញហេតុប៉ុណ្ណោះ មិនសម្រេចដល់បុគ្គលក្រៅពីនេះទេ ។ ពាក្យថា **ដោយវិធីការមានផ្តុំភ្លើងជាដើម** គឺដោយវិធីមានការធ្វើឲ្យក្តៅ ការបំពក់ភ្លើងជាដើម ។ ដោយ ច-ស័ព្ទ ក្នុងបទថា

**យថា** ច លោករួមយកវិធីដែលមិនបានពោលដល់ផង មានការកម្មោលរ័ខជាដើម នៃពួកជាងល័ខជាដើម ។ ពាក្យថា **ដោយអំណាចការចូលឈាន ធ្វើឆន្ទៈឲ្យជាប្រធាន** គឺ ដោយអំណាចនៃការចូលឈាន ធ្វើកត្តុកម្យតាឆន្ទៈឲ្យជាប្រធាន គឺ ជាធុរៈ ជាធំ ចេញមុខដោយន័យថា ប្រសិនបើអភិញ្ញា នឹងសម្រេចដល់បុគ្គលអ្នកមានឆន្ទៈបានដូច្នេះជាដើម , ឬថា ធ្វើឆន្ទៈនោះឲ្យកើតឡើងបានហើយ ក៏ធ្វើឆន្ទៈនោះឲ្យជាប្រមុខ ( ជាធម៌ដ៏សំខាន់ ) ដោយការនោ ។ សូម្បីក្នុងអធិបតីធម៌ដ៏សេសទាំងឡាយ ( មានវិរិយៈជាដើម ) ក៏មានន័យដូច្នេះ ។ ពាក្យថា **ដោយអំណាចនៃវសីភាវៈ មានអាវជ្ជនវសីជាដើមនេះ** លោកពោលសំដៅយកការធ្វើភាពជាវសីក្នុងសមាបត្តិទាំង ៨ ឲ្យកើតឡើងបានយ៉ាងល្អក្រៃលែង ។ ក៏ការធ្វើភាពជាវសីឲ្យកើតឡើងនោះឯង រមែងមានបានដោយអំណាចនៃព្រះយោគីអ្នកជាអាទិកម្មិក មិនមែនដោយអំណាចនៃអធិការដែលបានធ្វើទុកទេ ព្រោះហេតុនោះទើបលោកពោលថា តែការដែលព្រះយោគីអ្នកជាអាទិកម្មិក អ្នកដល់ព្រមដោយបុព្វហេតុ ។ ល ។ រមែងគួរ ដូច្នេះ ។ អធិប្បាយថា ពិតមែន ព្រះយោគីអ្នកដល់ព្រមដោយបុព្វហេតុ នឹងគប្បីធ្វើឈានណាឲ្យជាបាទ ញ៉ាំងអភិញ្ញាឲ្យកើតឡើងគប្បីត្រូវការភាពជាវសី ដែលសន្សំទុកយ៉ាងល្អក្រៃលែង ក្នុងឈាននោះប៉ុណ្ណោះ មិនមែនក្នុងឈានទាំងអស់ឡើយ ។ លោកអាចារ្យជាច្រើនពោលថា ព្រោះមានពាក្យនិយាយថា អ្នកមានវសីដែលបានសន្សំហើយ ត្រឹមតែឈានទី ៤ ដូច្នេះ អភិញ្ញាទើបសម្រេចបាន សូម្បីវៀរអរូបសមាបត្តិទាំងឡាយ ។ ពាក្យនិយាយរបស់អាចារ្យទាំងនោះ ទោះបីជាលោកពោលទុកទាក់ទងនឹងព្រះយោគី អ្នកដល់ព្រមដោយបុព្វហេតុ ក៏ចាត់ថាត្រឹមត្រូវផងដែរ ។ បើថាលោកពោលទុកដោយទាក់ទងនឹង

បុគ្គលក្រៅពីនេះ ក៏ចាត់ថា ត្រឹមតែជាមតិរបស់អាចារ្យពួកនោះ ។ បទថា **យថា** ប្រែថា ដោយប្រការណា គឺ ដោយវិធីណា ។ បទថា **ឯត្ថ** បានដល់ ក្នុងការធ្វើឥទ្ធិវិធឲ្យសម្រេច ។

បទថា **តត្រ** លោកដកយកវិធីនោះៗ ឯង ។ ពាក្យថា **តាមគន្លងនៃព្រះបាលី** គឺតាមគន្លងនៃគតិព្រះបាលីនោះឯង មានន័យថា តាមលំដាប់នៃការសំវណ្ណនាព្រះបាលី ។ លោកអាចារ្យពោលថា គឺ ព្រះយោគីអ្នកសម្រេចចតុត្ថជ្ឈាន ព្រោះទ្រង់ត្រាស់ទុកថា ចូលដល់ចតុត្ថជ្ឈានដូច្នេះ ហើយត្រាស់ថា ភិក្ខុនោះ **ឯវំ**-ស័ព្ទក្នុងបទថា **ឯវំ សមាហិតេ** កាលចិត្តតាំងមាំដោយប្រពៃហើយយ៉ាងនេះ មានអត្ថថា សម្ដែងដល់ការតាំងមាំដោយប្រពៃនៃចតុត្ថជ្ឈាន ដែលបានសម្រេចតាមលំដាប់នៃការសម្រេចឈាន ៣ ខាងក្រោម ព្រោះហេតុនោះ ទើបលោកពោលថា ពាក្យថា **ឯវំ** នេះ ជាពាក្យសម្ដែងលំដាប់នៃចតុត្ថជ្ឈានដូច្នេះ គឺជាពាក្យសម្ដែងចតុត្ថជ្ឈាន និងលំដាប់នៃការសម្រេចចតុត្ថជ្ឈាននោះ ។ សេចក្ដីថា ព្រះយោគាវចរអ្នកបានសម្រេចចតុត្ថជ្ឈានសមាធិ ដោយការតាំងមាំដោយប្រពៃ និងដោយលំដាប់នៃការសម្រេចណា ក៏ជាពាក្យសម្ដែងសេចក្ដីតាំងមាំដោយប្រពៃ និងលំដាប់ទាំងពីរនោះៗ ព្រោះហេតុនោះ ទើបលោកពោលថា អធិប្បាយបានថា ។ ល ។ ដោយលំដាប់នៃការសម្រេចបឋមជ្ឈានជាដើមនេះ ដូច្នេះ ។ បទថា **ឯវំ** នេះ បំភ្លឺដល់ការតាំងមាំដោយប្រពៃនៃចតុត្ថជ្ឈាន ព្រមទាំងសមាធិដែលជាហេតុមកក៏ពិត ។ តែចំពោះសមាធិដ៏បរិសុទ្ធ ព្រោះសតិប៉ុណ្ណោះជាប្រធាន ដោយភាពជាអធិដ្ឋាននៃឫទ្ធិ ព្រោះហេតុនោះ ទើបលោកពោលថា គឺ កាលចិត្តតាំងមាំដោយប្រពៃ ដោយចតុត្ថជ្ឈានសមាធិនេះ ដូច្នេះ បទថា **ឧបេក្ខាសតិបារិសុទ្ធិភាវេន** ប្រែថា ព្រោះមាន

សេចក្តីបរិសុទ្ធនៃសតិ ដែលឧបេក្ខាធ្វើឲ្យកើត ។ សេចក្តីពិតថា កាលបារិសុទ្ធិឧបេក្ខា ( ឧបេក្ខាបរិសុទ្ធ ) ដែលបរិសុទ្ធចាកធម៌ដែលជាសត្រូវ និងគ្រឿងសៅហ្មងទាំងពួង មិនមានភាពខ្វល់ខ្វាយ សូម្បីក្នុងការស្ងប់ធម៌ដែលជាសត្រូវប្រព្រឹត្តទៅចតុត្ថជ្ឈាន និងធម៌ទាំងឡាយ ដែលសម្បយុត្តនឹងចតុត្ថជ្ឈាននោះ ក៏បរិសុទ្ធល្អ ។ និងមានភាពក្បៀវក្លាល្អ ក្នុងបាឋៈនោះ ទ្រង់ធ្វើទេសនាដោយមានសតិជាប្រធាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ឈ្មោះថា **បរិសុទ្ធ** ព្រោះមានសេចក្តីបរិសុទ្ធនៃសតិ ដែលឧបេក្ខាធ្វើឲ្យកើតដូច្នេះ ។ ព្រោះសេចក្តីបរិសុទ្ធនោះឯង ទើបមានភាពផូរផង់ គឺ ការប្រព្រឹត្តទៅវិសេសតាមបច្ច័យវិសេស ដូចភាពផូរផង់ ឬភ្លឺថ្លា ព្រោះការខាត់ពណ៌នៃមាស ដែលគេដុតល្អហើយដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ឈ្មោះថា **បរិយោទាតេ**-ផូរផង់ ព្រោះភាពបរិសុទ្ធនោះឯង អធិប្បាយថា ស្រស់ថ្លា ។

ពាក្យថា **ដោយការកម្ចាត់បច្ច័យទាំងឡាយ មានសុខវេទនាជាដើមបានហើយ** គឺដោយការសង្កត់សង្កិនសុខ និងសោមនស្ស ព្រមទាំងទុក្ខ និងទោមនស្ស ដែលជាបច្ច័យដល់រាគៈ និងទោសៈបានតាមលំដាប់ ។ ព្រោះលោកពោលទុកថា សុខជាបច្ច័យដល់សោមនស្ស សោមនស្សជាបច្ច័យដល់រាគៈ ។ ទុក្ខជាបច្ច័យដល់ទោមនស្សដូច្នេះជាដើម ។ ប្រៀបដូចធម៌ទាំងឡាយ មានរាគៈជាដើម លោកហៅថា **អង្គណ**-ទីទួល ព្រោះជាមន្ទិល និងភាពសៅហ្មងនៃចិត្តយ៉ាងណា ហៅថា **ឧបក្កិលេស** ព្រោះមានសេចក្តីថា ចូលទៅធ្វើឲ្យលំបាកក៏ដូច្នោះ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **វិគតុបក្កិលេស**-ប្រាសចាកឧបក្កិលេស ព្រោះមិនមានកិលេសដូចទីទួលនោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះថា ចិត្ត

រមែងលំបាក ព្រោះកិលេសដូចទីទួល , សេចក្តីថា រមែងលំបាក គឺក្តៅក្រហាយ។ ពាក្យថា **ព្រោះបានអប់រំទុកល្អហើយ** គឺ ព្រោះបានអប់រំទុកហើយដោយ ល្អ ដោយការធ្វើឲ្យដល់ភាពស្ទាត់ជំនាញ ។ ព្រោះហេតុនោះ ទើបលោកពោលថា **ដល់ភាពជាវសី** មានសេចក្តីថា ដល់ការប្រព្រឹត្តទៅក្នុងអំណាចដោយអាការ ៥ មានអាវជ្ជនៈជាដើម ឬ ដោយការហ្វឹកហាត់ដែលមានអាការ ១៤ ។ ពិតហើយ ចិត្តដែលប្រព្រឹត្តក្នុងអំណាច លោកហៅថា ចិត្តទន់ ដូចស្បែកដែលត្រូវសម្ងាប់ល្អ ហើយ និងដូចល័ខដែលធ្វើបរិកម្មល្អហើយ ក៏ព្រោះការដល់ភាពស្ទាត់ជំនាញ ។ ពាក្យថា **សមគួរដល់ការងារ** គឺសមគួរដល់ការធ្វើឫទ្ធិ មានវិកុព្វនាឥទ្ធិជាដើម ។ ពាក្យថា **ភាវៈទាំងឡាយពីរនោះ** បានដល់ ភាវៈទាំង ២ ភាវៈដែលទន់ និងគួរដល់ការងារ ។

ក្នុងបទថា **នាហំ** ជាដើម ន-អក្សរនេះ មានអត្ថថា បដិសេធ ។ បទថា **អហំ** ព្រះសាស្តាទ្រង់សម្តែងដល់ព្រះអង្គឯង ។ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា **ភិក្ខវេ** ។ ពាក្យថា **យ៉ាងដទៃ** គឺ យ៉ាងដទៃអំពីចិត្ត ដែលកំពុងពោលដល់នៅក្នុងឥឡូវនេះ ។ បទថា **ឯកធម្មម្បិ** ភ្ជាប់សេចក្តីថា **ឯកម្បិ សភាវធម្មំ ន សមនុបស្សាមិ**-តថាគតរកមិនឃើញសភាវធម៌ សូម្បីត្រឹមតែមួយ ។ ក្នុងព្រះតម្រាស់នេះ មានន័យដូច្នេះគឺ ម្នាលភិក្ខុទាំងឡាយ តថាគតកាលត្រួតមើលដោយសព្វញ្ញុតញ្ញាណ ក៏មិនសម្លឹងឃើញធម៌យ៉ាងដទៃ សូម្បីត្រឹមតែមួយ ដែលបុគ្គលអប់រំហើយ ដោយការឲ្យដល់ភាពជាវសី ដែលធ្វើឲ្យច្រើនហើយ ដោយធ្វើរឿយៗ យ៉ាងនោះ ក៏រមែងជាធម្មជាតិដ៏ទន់ ព្រោះដល់ភាពទន់បានយ៉ាងពិសេស និងគួរដល់ការងារ ព្រោះសមគួរដល់ការងារ ។ ដូចជាចិត្តនេះត្រាស់ទុកយ៉ាងនេះ ព្រោះ

ព្រះអង្គផ្ទាល់ និងកិក្ខុទាំងនោះបានឃើញប្រចក្សដូច្នេះឯង ។ សេចក្ដីថា ជាចិត្ត ដែលបានអប់រំទុកល្អហើយ ដោយប្រការដែលមានអាការទាំងឡាយ មានសេចក្ដី បរិសុទ្ធជាដើម តាមដែលពោលហើយ និងមិនប្រាសទៅ ។

ម្យ៉ាងទៀត ចិត្តដែលតាំងចុះក្នុងសេចក្ដីបរិសុទ្ធជាដើមពួកនេះ ពោលបានក្នុង ទីនេះថា តាំងនៅ គឺ ដល់នូវការមិនញាប់ញ័រ ព្រោះហេតុនោះ ទើបលោកអាចារ្យ ពោលថា ឈ្មោះថា **ឋិតេ**-តាំងនៅ ក៏ព្រោះតាំងនៅក្នុងសេចក្ដីបរិសុទ្ធជាដើមពួក នេះ ឈ្មោះថា **អានេញ្ជប្បត្តេ**-ដល់នូវការមិនញាប់ញ័រ ក៏ព្រោះការដែលតាំងនៅ នោះឯងដូច្នេះ ។ ភាពជារបស់ទន់ និងគួរដល់ការងារ បណ្ឌិតរមែងកំណត់បាន ដោយការដល់ភាពជាវសី យ៉ាងណា សូម្បីការដល់ភាពជាវសី ក៏រមែងកំណត់បាន ដោយភាពជារបស់ទន់ និងគួរដល់ការងារក៏ដូច្នោះ , ម្យ៉ាងទៀត ត្រាស់ថា **ឋិតេ**- តាំងនៅ ក៏ព្រោះការតាំងនៅក្នុងអំណាចរបស់ខ្លួន ដោយភាពជារបស់ទន់ និងគួរ ដល់ការងារ ។ ព្រោះថាបណ្ឌិតរមែងលើកយកផលតាមរយៈហេតុបាន យ៉ាងណា ក៏រមែងលើកយកហេតុ សូម្បីតាមរយៈផលបានក៏ដូច្នោះដែរ ការតាំងស៊ប់ដោយ ការមិនញាប់ញ័រ ឈ្មោះថា **អនេញ្ជប្បត្តិ**-ការដល់នូវភាពមិនញាប់ញ័រ ។ ការដល់ នូវភាពមិនញាប់ញ័រនោះ រមែងមានបានដោយអានុភាពនៃពលធម៌ទាំងឡាយ មាន សទ្ធាជាដើម ដែលមានប្រាកដដោយភាពជាធម៌ដ៏មាំទាំក្នុងសម្បយុត្តធម៌ទាំងឡាយ និងជាធម៌ ដែលបដិបក្ខធម៌ទាំងឡាយ មិនអាចធ្វើឲ្យកម្រើកបាន ព្រោះហេតុនោះ លោកអាចារ្យប្រាថ្នានឹងបើកបង្ហាញសេចក្ដី ដែលបានពោលមកហើយ ដោយ សង្ខេបថា ឈ្មោះថា **អានេញ្ជប្បត្តេ**-ដល់នូវការមិនញាប់ញ័រ ព្រោះការដែល ធម៌ទាំងឡាយ មានសទ្ធាជាដើមគ្រប់គ្រងហើយ ដូច្នេះ ទើបពោលថា ពិតហើយ

ចិត្តដែលសទ្ធាគ្រប់គ្រងល្អហើយដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ចិត្តដែលសទ្ធាគ្រប់គ្រងហើយ** គឺ ចិត្តដែលសទ្ធាប្រព្រឹត្តទៅយ៉ាងនេះថា ចិត្តដែលអប់រំល្អហើយ ដែលដល់ភាពជាវសីយ៉ាងនេះៗ និងប្រព្រឹត្តទៅព្រមដើម្បីការធ្វើឲ្យជាក់ច្បាស់ ដោយការដឹងដ៏ក្រៃលែងនូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយញាណយ៉ាងប្រាកដ គ្រប់គ្រងហើយ បានដល់ ចិត្តដែលសទ្ធាពលៈ តាមដែលពោលមកហើយឧបត្ថម្ភ ។ ពាក្យថា **ព្រោះការមិនមានសទ្ធា** គឺ រមែងមិនញាប់ញ័រ មិនកម្រើកព្រោះហេតុ គឺ ការមិនមានសទ្ធាដែលជាបដិបក្ខចំពោះសទ្ធានោះ , រមែងតាំងនៅជាហេតុនាំមកនូវគុណវិសេសជាន់លើបានជាពិតប្រាកដ ។ សូម្បីក្នុងពាក្យថា **ដែលវីរិយៈគ្រប់គ្រងហើយជាដើម** គប្បីជ្រាបអត្ថាធិប្បាយតាមន័យនេះចុះ ។ ចំណែកតទៅនេះចាត់ជាសេចក្តីផ្សេងគ្នា, ពាក្យថា **ចិត្តដែលវីរិយៈគ្រប់គ្រងហើយ** គឺចិត្តដែលវីរិយៈឧបត្ថម្ភហើយ ដោយការឲ្យដល់ភាពជាវសី និងឲ្យសម្រេចការហ្វឹកហាត់ ។ ពាក្យថា **ចិត្តដែលសតិគ្រប់គ្រងហើយ** គឺ ចិត្តដែលសតិអ្នកឲ្យសម្រេចការមិនវង្វេងក្នុងការអប់រំចិត្ត និងការបម្រើនតាមដែលបានពោលមកហើយព្រមទាំងស្វែងរកនូវគតិទាំងឡាយនៃកុសលធម៌ទាំងឡាយឧបត្ថម្ភហើយ ។ ពាក្យថា **ចិត្តដែលសមាធិគ្រប់គ្រងហើយ** គឺ ចិត្តដែលតាំងមាំដោយប្រពៃ សមាធិដែលឲ្យសម្រេចភាពមិនរាយមាយក្នុងការអប់រំ និងការបម្រើននោះៗឯងឧបត្ថម្ភហើយ ។ ពាក្យថា **ចិត្តដែលបញ្ញាគ្រប់គ្រងហើយ** គឺ ចិត្តដែលបញ្ញាមានលក្ខណៈដឹងច្បាស់នូវធម៌ ដែលជាឧបការ និងមិនជាឧបការចំពោះភាវនានោះៗឯង ឧបត្ថម្ភហើយ ។ ពាក្យថា **ចិត្តដែលប្រព្រឹត្តទៅនឹងពន្លឺភ្លឺស្វាង** បានដល់ ចិត្តដែលសហគតៈដោយពន្លឺភ្លឺស្វាង គឺ ញាណ ។ ពិតហើយ ព្រះយោគី កាលឃើញទៅតាមសេចក្តីពិតនូវ

ធម៌ដែលជាពួកនៃសង្កិលេសដោយញាណ ដែលក្ដីស្វាងដែលសម្ព័ន្ធនឹងការតាំងមាំ ដោយប្រពៃ សមាធិតាមដែលពោលមកហើយនោះឯង ក៏រមែងជាអ្នកភ័យ គឺ ខ្លាចចំពោះធម៌ដែលបក្ខពួកនៃកិលេសនោះហើយ គ្រប់សង្កត់ធម៌ដែលជាបក្ខពួកនៃ សង្កិលេសនោះ គឺ ធម៌ដែលជាបក្ខពួកនៃសង្កិលេសនោះគ្របសង្កត់មិនបាន ព្រោះ ហេតុនោះ ទើបលោកអាចារ្យពោលថា រមែងមិនញាប់ញ័រ ព្រោះភាពងងឹត គឺ កិលេស ។ ដោយពាក្យនេះ លោកសម្ដែងដល់ហិរិពលៈ និងឱត្តប្បពលៈ ត្រូវ ញាណគ្រប់គ្រងហើយ ។ ពាក្យថា **ចិត្តដែលដល់ព្រមដោយអង្គ ៨** គឺ ដល់ព្រម ដោយអង្គ ៨ ពួកនេះ គឺ ភាពជាចិត្តដែលតាំងមាំដោយប្រពៃ ដោយចតុត្ថជ្ឈាន សមាធិ១ សេចក្ដីបរិសុទ្ធ១ ភាពចាស់ក្លា១ ការមិនមានកិលេសដូចទីទួល១ ការ ប្រាសចាកឧបក្កិលេស១ ភាពជាធម្មជាតិទន់១ ភាពជាធម្មជាតិគួរដល់ការងារ១ ការតាំងនៅដោយការដល់នូវភាពមិនញាប់ញ័រ១ ,ម្យ៉ាងទៀត អង្គពួកនេះជាអង្គ នៃចិត្តដែលដល់នូវការតាំងមាំដោយប្រពៃ ព្រោះហេតុនោះ ក៏ជាចិត្តដែលដល់ព្រម ដោយអង្គ ៨ ពួកនេះ ដោយមិនកាន់យកបទថា **សមាហិតេ** គឺ តាំងមាំដោយ ប្រពៃនេះ ដោយភាពជាអង្គ ១ ហើយកាន់យក **ឋិតិ**-ការតាំងនៅ និង**អានេញ្ជប្បត្តិ** -ការមិនញាប់ញ័រ ដែលបែកគ្នាជាមួយអង្គៗ ។ ពាក្យថា **គួរដល់ការបង្អោនទៅ** គឺគួរដល់ការបង្អោនទៅដើម្បីឥទ្ធិវិធជាដើម បានដល់ សមគួរដល់ការធ្វើឲ្យឆ្ពោះមុខ តម្រង់ចំពោះឥទ្ធិវិធជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា ដើម្បីការធ្វើឲ្យ ជាក់ច្បាស់ដោយការដឹងដ៏ក្រៃលែងនូវធម៌ទាំងពួង ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយ ការដឹងដ៏ក្រៃលែង ។

ការសម្រេចបឋមជ្ឈាន រមែងមានព្រោះការគ្របសង្កត់នីវរណៈទាំងឡាយ

បានទោះឯង និងការសម្រេចទុតិយជ្ឈានជាដើម ព្រោះក្នុងការស្ងប់ធម៌ទាំងឡាយមានវិតក្កជាដើមបានទោះឯងក៏ពិត សូម្បីយ៉ាងនោះ សម្បយុត្តធម៌ទាំងឡាយនឹងនៅក្នុងទីឆ្ងាយ ឬទៅប្រាសចាកធម៌ដែលជាសត្រូវពួកនោះបានដូចចតុត្ថជ្ឈានក៏ទេ , ម្យ៉ាងទៀត សេចក្ដីបរិសុទ្ធ និងភាពផូរផង់នៃចិត្តនោះ នឹងត្រូវប្រើបាន ក៏ព្រោះការរួចផុតដោយល្អអំពីធម៌ដែលជាសត្រូវទាំងឡាយ មាននីវរណៈជាដើម ដែលជាធម៌ធ្វើនូវការត្រិះរិះ ដែលរាប់ថាជាការសៅហ្មង និងធ្វើឲ្យចិត្តត្រេកត្រអាល ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ឈ្មោះថា **បរិសុទ្ធ** ក៏ព្រោះការដែលឆ្ងាយចាកនីវរណៈ ឈ្មោះថា **ផូរផង់** ព្រោះការឈានកន្លងអង្គ មានវិតក្កជាដើមបានដូច្នេះ ។ ពាក្យថា ***ដែលមានការបានឈានជាបច្ច័យ*** គឺ ដែលមានការបានឈានជាហេតុ បានដល់ ដែលកើតឡើងព្រោះអាស្រ័យការបានឈាន ។ ពាក្យថា **បាបធម៌** គឺ ធម៌ដ៏ថោកទាប ។ ពាក្យថា ***ដែលប្រព្រឹត្តទៅព្រមនឹងសេចក្ដីប្រាថ្នា*** គឺ កិលេសទាំងឡាយមាន មានះ មាយា និងសាថេយ្យជាដើម ប្រព្រឹត្តទៅព្រមនឹងសេចក្ដីប្រាថ្នា គឺ ធ្លាក់ចុះដោយអំណាចសេចក្ដីប្រាថ្នា បានដល់ ប្រព្រឹត្តទៅដោយន័យថា ឱហ្ន៎ ព្រះសាស្ដាគប្បីត្រាស់សួរយើងប៉ុណ្ណោះ ហើយទើបសម្ដែងធម៌ដល់ភិក្ខុទាំងឡាយចុះ ដូច្នេះជាដើម ។ សូម្បីដោយ **អាទិ**-ស័ព្ទក្នុងបទថា **អភិជ្ឈាទីនំ**- មានអភិជ្ឈាជាដើម មានការរួមយកកិលេសពួកនោះៗឯង ។ បណ្ដាឧបក្កិលេសពួកនោះ គប្បីឃើញអភិជ្ឈាថា ជាអភិជ្ឈាដែលព្រះយោគីមិនអាចគ្របសង្កត់បានដោយបឋមជ្ឈាន និងគប្បីឃើញឧបក្កិលេសទាំងឡាយ មានមានះជាដើមថា ជាឧបក្កិលេសដែលតាំងនៅក្នុងឋានៈដូចគ្នានឹងអភិជ្ឈានោះ ព្រោះប្រព្រឹត្តទៅតាមពាក្យថា មានការបានឈានជាបច្ច័យ ។ សួរថា អភិជ្ឈាដែលអាចគ្របសង្កត់បាន

ត្រូវលោកកាន់យកហើយដោយស័ព្ទថា **នីវរណៈ** នោះឯង ចំណែកអភិជ្ឈាដែលមិនអាចគ្របសង្កត់បានដោយបឋមជ្ឈាន នឹងអស់ទៅក្នុងចតុត្ថជ្ឈាននេះបាន យ៉ាងដូចម្តេច ? ឆ្លើយថា កុសលធម៌ទាំងឡាយទាំងពួង រមែងជាបដិបក្ខចំពោះអកុសលធម៌ទាំងឡាយទាំងពួង ព្រោះហេតុនោះ ទើបលោកពោលទុកយ៉ាងនេះទាក់ទងនឹងសល្លេខបដិបត្តិ សម្តែងដល់ព្រះយោគីដែលមិនប្រកាន់មាំក្នុងឈាន ។ ចំណែកលោកអាចារ្យពួកណាបដិសេធបាឋៈ ដែលថា **ឈានបដិលាភបច្ចយានំ-** មានការបានឈានជាបច្ច័យ ហើយពោលថា បាឋៈថា **ឈានបដិលាភបច្ចនីកានំ-** ជាសត្រូវនៃការបានឈាន ព្រោះបំណងយកកិលេសទាំងឡាយ មានសេចក្តីក្រោធការមិនពេញចិត្ត កាមរាគៈ និងព្យាបាទជាដើម គឺ លោកកាន់យកហើយដោយបទពួកនេះថា **ឥច្ឆាវចរានំ អភិជ្ឈាទីនំ**-ដែលត្រាច់ទៅព្រមនឹងសេចក្តីប្រាថ្នា មានអភិជ្ឈាជាដើម ។ ពាក្យនោះ ត្រឹមតែជាមតិរបស់អាចារ្យទាំងនោះ ព្រោះបាឋៈដែលពោលនោះមិនមានឡើយ ។ ព្រោះការដែលលោកអាចារ្យទាំងនោះ ពោលដល់ភាពជាឈានដែលនៅក្នុងទីឆ្ងាយអំពីនីវរណៈ ដែលជាសត្រូវនៃការបានឈាន និងឆ្ងាយពីកិលេសទាំងឡាយ ដែលតាំងនៅក្នុងឋានៈដូចគ្នានឹងនីវរណៈ ដែលជាសត្រូវនៃការបានឈាន និងឆ្ងាយពីកិលេសទាំងឡាយ ដែលនៅក្នុងឋានៈដូចគ្នានឹងនីវរណៈនោះហើយ នៅសួរដល់ការអស់ទៅ គឺ ការមិនមានក្នុងចតុត្ថជ្ឈានទៀតជារឿងមិនត្រឹមត្រូវ ។ សួរថា ក៏ក្នុង **អនង្គណសូត្រ** និង **វត្ថសូត្រ** រមែងមិនបានក្នុងសេចក្តីនេះ ព្រោះក្នុងសូត្រពួកនោះ លោកបំណងយកបាបធម៌ទាំងឡាយដែលគ្រោតគ្រាតប៉ុណ្ណោះ មិនមែនឬ ? ឆ្លើយថា ប្រការដែលពោលនេះក៏ពិតហើយ តែព្រោះក្នុងទីនេះ លោកអាចារ្យពោលទុកទាក់ទងនឹងព្រះយោគី អ្នកបានសម្រេច

ចតុត្ថជ្ឈានហើយ ទើបលោកកាន់យកបាបធម៌ទាំងឡាយនោះដោយចំពោះដ៏ល្អិត ។

ម្យ៉ាងទៀត ក្នុងទីនេះមានការអាងព្រះសូត្រទាំងឡាយ ក៏ព្រោះមានភាពដូចជាទីទួល និងជាឧបក្កិលេសដូចគ្នា ។ ពិតយ៉ាងនោះ លោកបានពោលហើយថា តាមទំនងនៃព្រះសូត្រដូច្នេះ ។ តែមិនបានពោលថា ដោយអំណាចនៃព្រះសូត្រ ។ ក៏ពាក្យដែលលោកពោលទុកយ៉ាងនេះ នេះគប្បីព្រមទទួលបានជាពិតប្រាកដ ព្រោះព្រះយោគីទាំងឡាយ សូម្បីថាបានសម្រេចឈានហើយ ក៏នៅមានបាបធម៌ខ្លះដែលប្រព្រឹត្តទៅជាមួយនឹងសេចក្ដីប្រាថ្នា ។

ពាក្យថា **ព្រោះការចូលដល់ភាពជាឥទ្ធិបាទ** គឺព្រោះការចូលភាពជាបទដ្ឋាននៃឫទ្ធិ ។ ពាក្យថា **ព្រោះភាពបរិបូណ៌នៃភាវនា** គឺព្រោះភាពបរិបូណ៌នៃភាវនាដែលគួរដល់ការបង្អោនទៅដើម្បីឥទ្ធិវិធ ទាក់ទងនឹងការមិនមានកិច្ចដែលគប្បីធ្វើទៅទៀត ។ ពាក្យថា **ព្រោះការចូលដល់ភាពប្រណីត** គឺ ព្រោះការបរិបូណ៌នៃភាវនានោះៗឯង ទើបចូលដល់ភាពប្រណីត ដោយសេចក្ដីថា ខ្ពង់ខ្ពស់ ព្រោះការដែលនាំទៅកាន់ភាពជាប្រធាន , និងដោយសេចក្ដីថា ធ្វើមិនឲ្យឆ្អែត ព្រោះចូលដល់ភាពប្រណីត ។ បទទាំងពីរនេះ គឺ ព្រោះការចូលដល់ភាពប្រណីត ព្រោះភាពបរិបូណ៌នៃភាវនា ជាពាក្យនិយាយដល់ហេតុនៃការតាំងនៅ គឺ ឈ្មោះថា តាំងនៅ ព្រោះការដល់ភាពប្រណីត ព្រោះភាវនាដ៏បរិបូណ៌ ។ បទថា **អានេញ្ជប្បត្តេ**-ភាពមិនញាប់ញ័រ នេះជាវិសេសនពង្រីក **ឋិតិ**-ការតាំងនៅ ។ ព្រោះហេតុនោះ ទើបលោកពោលថា សេចក្ដីថា តាំងនៅដោយប្រការដែលជាធម្មជាតិដល់នូវភាពមិនញាប់ញ័រ ដូច្នេះ ។ ក្នុងផ្នែកពីរបទនេះ គឺ **ឋិតេ**-តាំងនៅ **អានេញ្ជប្បត្តេ**-ការមិនញាប់ញ័រ ចាត់ជាអង្គ១ , ចំណែកបទថា **សមាហិតេ**-តាំងមាំដោយប្រពៃនេះ

ចាត់ជាអង្គ១ ។ ព្រោះហេតុនោះៗឯង លោកអាចារ្យសំដៅយកការផ្សេងអំពីវិកប្ប ដំបូងនៃវិកប្បនេះ ពោលថា ចិត្តដែលដល់ព្រមដោយអង្គ ៨ តាមប្រការដូចពោល មកនេះ ដូច្នេះ ។

( ចប់ មហាដីកា )

## ឥទ្ធិ ១០ យ៉ាង

ឫទ្ធិនោះមាន ១០ យ៉ាង ដូចព្រះបាលីថា ពាក្យថា ឫទ្ធិទាំងឡាយសំដៅយក ឫទ្ធិ ១០ យ៉ាង និងពោលតទៅទៀតថា ឫទ្ធិ ១០ យ៉ាង គឺអ្វីខ្លះ ? ឫទ្ធិ ១០ យ៉ាងគឺ

| | | |
|---|---|---|
| អធិដ្ឋានា ឥទ្ធិ | ឫទ្ធិ គឺការអធិដ្ឋាន | ។ |
| វិកុព្វនា ឥទ្ធិ | ឫទ្ធិ គឺការធ្វើឲ្យប្លែក | ។ |
| មនោមយា ឥទ្ធិ | ឫទ្ធិ សម្រេចអំពីចិត្ត | ។ |
| ញាណវិប្ផារា ឥទ្ធិ | ឫទ្ធិ គឺការផ្សាយចេញនៃញាណ | ។ |
| សមាធិវិប្ផារា ឥទ្ធិ | ឫទ្ធិ គឺការផ្សាយចេញនៃសមាធិ | ។ |
| អរិយា ឥទ្ធិ | ឫទ្ធិ គឺភាពអ្នកខ្ពង់ខ្ពស់ | ។ |
| កម្មវិបាកជា ឥទ្ធិ | ឫទ្ធិ កើតអំពីផលកម្ម | ។ |
| បុញ្ញវតោ ឥទ្ធិ | ឫទ្ធិ របស់បុគ្គលអ្នកមានបុណ្យ | ។ |
| វិជ្ជាមយា ឥទ្ធិ | ឫទ្ធិ សម្រេចអំពីវិជ្ជា | ។ |

តត្ថ តត្ថ សម្មាបយោគប្បច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ ឫទ្ធិ ដោយអត្ថថា សម្រេច ព្រោះបច្ច័យនៃការប្រកបត្រូវក្នុងកិច្ចនោះៗ ។

## ១–អធិដ្ឋានាឥទ្ធិ

ក្នុងឫទ្ធិទាំងនោះ ឫទ្ធិដែលលោកចែកសម្តែងទុកថា ព្រះយោគីដោយប្រក្រតីជាមនុស្សតែម្នាក់ ប៉ុន្តែនឹកឲ្យជាមនុស្សច្រើននាក់ ចំនួន ១០០ ក្តី ១.០០០ ក្តី ១.០០០.០០០ ក្តី កាលនឹកហើយ ក៏អធិដ្ឋានដោយញាណថា យើងចូរជាមនុស្ស

ចំនួនច្រើនហើយ លោកក៏ក្លាយជាមនុស្សចំនួនច្រើនទៅ ដូច្នេះជាដើម ឈ្មោះថា **អធិដ្ឋានាឥទ្ធិ-ឫទ្ធិគឺការអធិដ្ឋាន** ព្រោះការសម្រេចដោយអំណាចការបានអធិដ្ឋាន ។

## ២-វិកុព្វនាឥទ្ធិ

ឫទ្ធិដែលពោលមកដោយព្រះបាលីថា ព្រះយោគីនោះ លះភេទប្រក្រតីរបស់ខ្លួនហើយ សម្តែងជាភេទក្មេងក្តី ភេទនាគក្តី ។ល។ សម្តែងជាក្បួនទ័ពផ្សេងៗ ក្តី ហៅថា **វិកុព្វនាឥទ្ធិ-ឫទ្ធិគឺការធ្វើឲ្យប្លែក** ពីព្រោះប្រព្រឹត្តទៅដោយលះភេទប្រក្រតីរបស់ខ្លួន និងធ្វើភេទឲ្យប្លែកពីភេទប្រក្រតីរបស់ខ្លួន ។

## ៣-មនោមយាឥទ្ធិ

ឫទ្ធិដែលពោលមកដោយន័យនេះថា ភិក្ខុក្នុងសាសនានេះ និម្មិតកាយដទៃ ( ១ ទៀត ) អំពីកាយដើមនេះ ឲ្យមានរូបរាងសម្រេចដោយចិត្ត ( ក្នុងអភិញ្ញា ) ដូច្នេះជាដើម ឈ្មោះថា **មនោមយាឥទ្ធិ-ឫទ្ធិសម្រេចអំពីចិត្ត** ពីព្រោះប្រព្រឹត្តទៅដោយកើតជារាងកាយឡើងមួយទៀត ដែលមានរូបរាងសម្រេចហើយអំពីចិត្ត ខាងក្នុងរាងកាយនេះ ។

## ៤-ញាណវិប្ផារាឥទ្ធិ

គុណវិសេសដែលកើតដោយអានុភាពនៃញាណក្នុងពេលមុន ឬពេលក្រោយ អំពីការប្រព្រឹត្តទៅនៃញាណក្តី ក្នុងខណៈដែលញាណនោះប្រព្រឹត្តទៅក្តី ឈ្មោះថា **ញាណវិប្ផារាឥទ្ធិ-ឫទ្ធិគឺការផ្សាយចេញនៃញាណ** សមដូចបាលីថា ផល គឺ ការលះនិច្ចសញ្ញា ( សេចក្តីសម្គាល់ថា ទៀង ) បានឈ្មោះថា **ញាណវិប្ផារាឥទ្ធិ** ព្រោះ

សម្រេចដោយអនិច្ចានុបស្សនា( បញ្ញាពិចារណាឃើញដោយភាពមិនទៀង ) ។ល។ ផល គឺការលះកិលេសទាំងអស់បាន ឈ្មោះថា **ញាណវិប្ផារឥទ្ធិ** ព្រោះសម្រេចដោយអរហត្តមគ្គញាណ បានដល់ ញាណវិប្ផារឥទ្ធិរបស់ព្រះពាកុលៈ ញាណ-វិប្ផារឥទ្ធិរបស់ព្រះសង្កិច្ច ញាណវិប្ផារឥទ្ធិរបស់ព្រះភូតបាល ។

## ញាណវិប្ផាររបស់ព្រះពាកុលៈ

ក្នុងបីអង្គនោះដំបូង ព្រះពាកុលៈ កាលនៅជាទារក ក្នុងថ្ងៃមង្គល ថ្ងៃមួយ គេនាំទៅងូតទឹកនៅក្នុងទន្លេយមុនា បានរបូតធ្លាក់ចុះទៅក្នុងក្រសែទឹក ព្រោះការធ្វេសប្រហែសរបស់ស្ត្រីចិញ្ចឹម ត្រីធំត្របាក់លេបលោកចូលទៅក្នុងពោះ ហើយហែលទៅរហូតដល់កំពង់ទឹកក្រុងពារាណសី អ្នករកត្រីម្នាក់ចាប់ត្រីនោះបានត្រង់កំពង់នោះហើយ នាំទៅលក់ឲ្យភរិយាសេដ្ឋី ភរិយាសេដ្ឋីនោះ កើតមានការជាប់ជំពាក់ក្នុងត្រីនោះ ទើបប្រាប់ពួកអ្នកបម្រើថា ខ្ញុំនឹងស្ងោរវាខ្ញុំឯង វះចេញ ក៏ឃើញទារករូបស្អាតដូចជាមាស នៅក្នុងពោះត្រី ក៏កើតសេចក្ដីត្រេកអរថា ខ្ញុំបានបុត្រ ការមិនឈឺចាប់នៅក្នុងពោះត្រីដូច្នេះ ចាត់ជាញាណវិប្ផារឥទ្ធិ-ឫទ្ធិគឺការផ្សាយចេញនៃញាណរបស់ព្រះពាកុលៈអ្នកជាបច្ឆិមភវិក( មានភពចុងក្រោយ ) ព្រោះការមិនឈឺចាប់នៅក្នុងពោះត្រីនោះ កើតដោយអានុភាពនៃអរហត្តមគ្គញាណ ដែលលោកត្រូវបានក្នុងអត្តភាពនោះ , រីឯ រឿងរបស់ព្រះពាកុលៈនេះ គួរពោលដោយពិស្ដារចុះ ។

## ញាណវិប្ផារឥទ្ធិរបស់ព្រះសង្កិច្ចៈ

រឿងមួយទៀត កាលព្រះសង្កិច្ចៈនៅក្នុងគភ៌ មាតាធ្វើ ( កាលកិរិយា មនុស្ស

ទាំងឡាយយល់ថា ស្លាប់អស់ហើយ ) កាលសពនាងត្រូវពួកអ្នកស៊ីឈ្នួលដុតខ្មោច លើកឡើងដាក់លើជើងថ្ករ ចាក់ទម្លាយពោះដោយដែកស្រួចសម្រាប់ដុត , ទារកត្រូវប្រហារត្រង់ត្របកភ្នែកដោយចុងដែកស្រួច ក៏ស្រែកឡើង ពេលនោះពួកអ្នកស៊ីឈ្នួលដុតខ្មោចដឹងថា ទារកនៅរស់ ទើបលើកសពនាងចុះមកវះពោះមើល បានឃើញទារកហើយ ប្រគល់ទារកឲ្យយាយទៅ ទារកនោះយាយចិញ្ចឹមមករហូតចម្រើនវ័យឡើង បានបព្វជ្ជា ហើយបានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ការមិនឈឺចាប់នៅលើជើងថ្ករ តាមន័យដែលពោលមកនេះ ចាត់ជាញាណវិប្ផារឥទ្ធិរបស់ព្រះសង្កិច្ចៈ ។

## ញាណវិប្ផារឥទ្ធិរបស់ព្រះភូតបាល

រឿងមួយទៀត បិតារបស់ក្មេងប្រុសភូតបាល ជាអ្នកក្រនៅក្នុងក្រុងរាជគ្រឹះ ថ្ងៃមួយ គាត់ និងកូនទៅព្រៃដោយរទេះ ដើម្បីទៅរកឧស ផ្ទុកឧសក្នុងរទេះរួចហើយ ត្រឡប់មកវិញ ដល់ជិតទ្វារក្រុងពេលល្ងាច ថែជន្សគោទាំងពីររបស់គាត់ក្រឡាប់នឹមរត់ចូលទៅក្នុងក្រុង គាត់ទើបឲ្យកូនតូចអង្គុយនៅក្រោមរទេះ គាត់ទៅតាមចាប់គោ កាលគាត់មិនទាន់ចេញមកវិញ ទ្វារក្រុងក៏បិទទៅ ( ចោលកូនតូចឲ្យដេកនៅក្រៅក្រុងតែម្នាក់ឯង ) ការដែលក្មេងមិនឈឺចាប់ រហូតអស់មួយយប់ទាំង ៣ យាម នៅខាងក្រៅក្រុង ទាំងដែលមានយក្ខកាចបំណងបៀតបៀន ចាត់ជាញាណ-វិប្ផារឥទ្ធិ ក្នុងន័យដូចពោលហើយដូចគ្នា ឯរឿងនេះគួរពោលឲ្យពិស្តារចុះ ។

## ៥ – សមាធិវិប្ផារឥទ្ធិ

គុណវិសេសដែលកើតដោយអានុភាពនៃសមថៈ គឺ ការដែលចិត្តស្ងប់ មុន ឬ

ក្រោយសមាធិក្តី ក្នុងខណៈនៃសមាធិនោះក្តី ឈ្មោះថា **សមាធិវិប្ផារឥទ្ធិ-ឫទ្ធិគឺការផ្សាយចេញនៃសមាធិ** សមដូចពាក្យបាលីថា ផល គឺ ការលះនីវរណៈទាំងឡាយ បានឈ្មោះថា **សមាធិវិប្ផារឥទ្ធិ** ព្រោះសម្រេចដោយបឋមជ្ឈាន ។ល។ ផល គឺ ការលះសញ្ញាក្នុងអាកិញ្ចញ្ញាយតនៈ បានឈ្មោះថា **សមាធិវិប្ផារឥទ្ធិ** ព្រោះសម្រេចដោយការចូលនេវសញ្ញានាសញ្ញាយតនៈ បានដល់ សមាធិវិប្ផារឥទ្ធិរបស់ព្រះសារីបុត្រ សមាធិវិប្ផារឥទ្ធិរបស់ព្រះសញ្ជីវៈ សមាធិវិប្ផារឥទ្ធិរបស់ព្រះខានុកោណ្ឌញ្ញៈ សមាធិវិប្ផារឥទ្ធិរបស់ឧត្តរាឧបាសិកា សមាធិវិប្ផារឥទ្ធិរបស់ព្រះនាងសាមាវតីឧបាសិកា ។

## សមាធិវិប្ផារឥទ្ធិរបស់ព្រះសារីបុត្រ

ក្នុងលោកទាំងនោះ កាលព្រះសារីបុត្រស្នាក់នៅក្នុងវិហារឈ្មោះកបោតកន្ទរាញកក្នុំសត្វព្រាប ជាមួយនឹងព្រះមហាមោគ្គល្លាន កោរសក់ថ្មីៗ អង្គុយនៅកណ្តាលវាល ក្នុងយប់ខែភ្លឺ យក្ខកំណាចមួយ សូម្បីយក្ខជាសម្លាញ់ហាម ក៏មិនស្តាប់ បានប្រហារទៅលើសីសៈរបស់ព្រះសារីបុត្រ មានសំឡេងលាន់ឮឡើង ដូចជាសំឡេងផ្គរលាន់ ពេលដែលយក្ខប្រហារព្រះថេរៈកំពុងចូលសមាបត្តិ គ្រានោះ អាពាធសូម្បីតិចតួចក៏មិនបានមានដល់លោក ព្រោះការប្រហារនោះឡើយ នេះជាសមាធិវិប្ផារឥទ្ធិរបស់ព្រះសារីបុត្រនោះ ចំណែករឿងពិស្តារមកក្នុងឧទាននោះឯង ។

## សមាធិវិប្ផារឥទ្ធិរបស់ព្រះសញ្ជីវៈ

ចំណែកព្រះសញ្ជីវត្ថេរចូលនិរោធ ពួកគោបាលសម្គាល់ថា លោកស្លាប់ ទើបគរស្មៅ ឈើ និងអាចម៍គោស្ងួត ដាក់លើលោក ហើយដុតភ្លើងឡើង សូម្បីតែខ្សែ

អំបោះក្នុងចីវររបស់លោកក៏មិនបានឆេះ ចាំបាច់ពោលថ្វីដល់រាងកាយរបស់លោក នេះជាសមាធិវិប្ផារឥទ្ធិរបស់ព្រះសញ្ជីវៈ ដែលកើតពីអានុភាពនៃសមថៈ ប្រព្រឹត្ត ទៅដោយអំណាចអនុបុព្វសមាបត្តិ ចំណែករឿងល្អិតមកក្នុងព្រះសូត្រនោះឯង ។

## សមាធិវិប្ផារឥទ្ធិរបស់ព្រះខានុកោណ្ឌញ្ញៈ

ចំណែកព្រះខានុកោណ្ឌញ្ញត្ថេរ លោកជាអ្នកច្រើនទៅដោយការចូលសមាបត្តិ ជាប្រក្រតី យប់មួយលោកអង្គុយចូលសមាបត្តិនៅក្នុងព្រៃមួយ ពួកចោរ ៥០០ លួចរបស់គេទៅ មកដាក់កន្លែងអង្គុយរបស់លោក គិតថា ពេលនេះមិនមានអ្នកណា តាមពួកយើងមកទេ ក៏ប្រាថ្នានឹងឈប់សម្រាក កាលនឹងដាក់របស់ចុះ សម្គាល់ព្រះ ថេរៈថា នេះជាដង្គត់ឈើ ទើបនាំគ្នាដាក់របស់ទាំងនោះចុះទៅលើព្រះថេរៈនោះឯង កាលពួកចោរសម្រាកហើយ លុះដល់វេលានឹងទៅ ក៏កាន់យករបស់របរដែលទុក ត្រង់ទីនោះ ក៏ដល់ពេលលោកចេញពីនិរោធសមាបត្តិតាមដែលកំណត់កាលទុក , ចោរឃើញអាការកម្រើករបស់ព្រះថេរៈក៏ខ្លាច ស្រែកភ្ញាត់សំឡេងឡើង ទើបព្រះ ថេរៈប្រាប់ថា កុំខ្លាចឡើយឧបាសកទាំងឡាយ អាត្មាជាភិក្ខុទេតើ ទើបពួកចោរ ទាំងនោះនាំគ្នាថ្វាយបង្គំ តមកបួសដោយសេចក្ដីជ្រះថ្លា បានប្រព្រឹត្តក្នុងឱវាទព្រះ ថេរៈ ក៏បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ការដែលព្រះថេរៈត្រូវរបស់ ដល់ ៥ រយដុំ សង្កត់លើខ្លួន ហើយមិនមានអាពាធ នេះជាសមាធិវិប្ផារឥទ្ធិ ។

## សមាធិវិប្ផារឥទ្ធិរបស់នាងឧត្តរា

រីឯ នាងឧត្តរាជាធីតារបស់បុណ្ណសេដ្ឋី ស្ត្រីគណិកាឈ្មោះ សិរិមា ត្រូវសេចក្ដី ប្រណែនគ្របសង្កត់ ស្រោចខ្លាញ់កំពុងពុះកញ្ជ្រោលក្នុងខ្ទះ ចុះទៅលើក្បាលរបស់

នាង នាងឧត្តរាបានមានមេត្តាក្នុងខណៈនោះ ខ្លាញ់ក៏ហូររអិលចុះទៅ ដូចដំណក់ទឹករអិលធ្លាក់អំពីស្លឹកឈូកដូច្នោះ នេះជាសមាធិវិប្ផារឥទ្ធិរបស់ឧត្តរាឧបាសិកា រឿងនេះបណ្ឌិតគប្បីពោលឲ្យពិស្តារចុះ ។

## សមាធិវិប្ផារឥទ្ធិរបស់នាងសាមាវតី

ព្រះអគ្គមហេសីរបស់ព្រះបាទឧទេន ព្រះនាមថា សាមាវតី , មាគណ្ឌិយព្រាហ្មណ៍ប្រាថ្នាតំណែងអគ្គមហេសីដល់( មាគណ្ឌិយា )ធីតារបស់ខ្លួន ទើបប្រាប់( ឧបាយ )ឲ្យធីតារបស់ខ្លួននោះ លាក់អសិរពិសក្នុងពិណរបស់ព្រះរាជា ហើយក្រែងទូលព្រះរាជាថា “ បពិត្រមហារាជ ព្រះនាងសាមាវតី ទ្រង់គិតនឹងផ្តាច់បង់ព្រះជន្មព្រះអង្គ ព្រះនាងបានយកអសិរពិសលាក់ទុកក្នុងពិណ ” ព្រះរាជាទតព្រះនេត្រឃើញអសិរពិសនោះហើយ ក៏ខ្ញាល់ ទ្រង់គិតថា នឹងសម្លាប់នាងសាមាវតីចោល ( ចាប់ព្រះនាង ព្រមទាំងបរិវារ ឲ្យឈរកណ្តាលវាល ) ហើយទ្រង់លើកធ្នូឡើងជ្រលក់កូនសរដោយថ្នាំពិស ( ត្រៀមបាញ់ ) , ព្រះនាងសាមាវតី ព្រមទាំងបរិវាររួមចិត្តផ្សាយមេត្តាទៅកាន់ព្រះជ្រា ព្រះរាជាមិនអាចលែងកូនសរបាន ដាក់ដងធ្នូចុះក៏មិនបាន ទ្រង់ឈរធ្មឹង ទើបព្រះនាងទូលសួរព្រះអង្គថា “ ទ្រង់លំបាកព្រះវរកាយឬ ? ” ព្រះរាជាត្រាស់សារភាពថា “ យើងកំពុងលំបាក ” ព្រះនាងទើបទូលថា “ បើដូច្នោះ សូមព្រះអង្គដាក់ធ្នូចុះ ” , ពេលចប់ព្រះតម្រាស់របស់ព្រះនាង កូនសរក៏បានធ្លាក់ចុះទៀបព្រះបាទរបស់ព្រះរាជានោះឯង បន្ទាប់ពីនោះព្រះនាងទ្រង់រំលឹកព្រះអង្គដោយសេចក្តីថា បុគ្គលមិនគួរប្រទូស៉ាយដល់អ្នកដែលមិនប្រទូស៉ាយឡើយ , ការដែលព្រះរាជាមិនអាចលែងកូនសរឲ្យចេញទៅបាន

ដូចពោលមកនេះ ជាសមាធិវិប្ផារឥទ្ធិ របស់ព្រះនាងសាមាវតីឧបាសិកាខ្ជុនងង ។

## ៦ - អរិយាឥទ្ធិ

រីឯឫទ្ធិ មានភាពជាអ្នកសម្គាល់ថា មិនជាបដិកូល ក្នុងវត្ថុបដិកូលជាដើម បានជាប្រក្រតីជាដើម ឈ្មោះថា **អរិយាឥទ្ធិ** ( ដូចពាក្យពោលក្នុងបដិសម្ភិទា ) ថា " អរិយាឥទ្ធិ ដូចម្តេច ភិក្ខុក្នុងធម្មវិន័យនេះ បើបំណងថា សូមឲ្យយើងជាអ្នកមានការសម្គាល់ថា មិនជាបដិកូលក្នុងវត្ថុដែលជាបដិកូល " ដូច្នេះសោតលោកនឹងជាអ្នកមានការសម្គាល់ថា ជាវត្ថុមិនបដិកូលក្នុងវត្ថុដែលជាបដិកូលនោះបាន ។ល។ ជាអ្នកមានសតិសម្បជញ្ញៈ ព្រងើយក្នុងវត្ថុបដិកូលនោះបាន , **ឥទ្ធិ** មានភាពជាអ្នកសម្គាល់ថា មិនបដិកូលក្នុងវត្ថុជាបដិកូលជាដើម ជាប្រក្រតីបានជាដើមនោះ ហៅថា **អរិយាឥទ្ធិ** ព្រោះមានចំពោះព្រះអរិយៈទាំងឡាយអ្នកបានចេតោវសីប៉ុណ្ណោះ ពិតហើយ ភិក្ខុជាខីណាស្រពដែលប្រកបដោយអរិយឥទ្ធិនោះ ពេលធ្វើការផ្សាយមេត្តាក្តី ធាតុមនសិការក្តី ក្នុងវត្ថុដែលបដិកូល គឺ ដែលមិនគួរប្រាថ្នា ឈ្មោះថា **អប្បដិកូសញ្ញា** ( ការសម្គាល់ថា មិនជាបដិកូលក្នុងវត្ថុដែលជាបដិកូល ) ពេលធ្វើការផ្សាយអាសុភក្តី មនសិការថា មិនទៀងក្តី ក្នុងវត្ថុដែលបដិកូលថា គួរប្រាថ្នា ឈ្មោះថា ជាអ្នកមានបដិកូលសញ្ញា ( ការសម្គាល់ថាបដិកូលក្នុងវត្ថុមិនបដិកូល ) ន័យដូចគ្នានោះដែរ ភិក្ខុកាលធ្វើការផ្សាយមេត្តាក្តីធាតុមនសិការក្តី ក្នុងវត្ថុទាំងបដិកូល និងមិនបដិកូល ក៏ឈ្មោះថា ជាអ្នកមានអប្បដិកូលសញ្ញាដែរ និងកាលធ្វើការផ្សាយអសុភក្តី មនសិការថា មិនទៀងជាដើមនោះក្តី ក្នុងវត្ថុទាំងបដិកូល និងមិនបដិកូល ក៏ឈ្មោះថា ជាអ្នកមានបដិកូល

សញ្ញាដែរ រីឯន័យថា កាលញ៉ាំងធម្មវិធីនុ៎ះឲ្យប្រព្រឹត្តទៅ ដែលបានពោលទុកដោយន័យថា **ភិក្ខុឃើញរូបដោយចក្ខុហើយ មិនត្រេកអរ...ឡើយ** ដូច្នេះជាដើមប្រព្រឹត្តទៅ វៀរអាការទាំងពីរ ( គឺ ត្រេកអរ និងមិនត្រេកអរ ) នោះចេញ ទាំងក្នុងវត្ថុដែលបដិកូល និងមិនបដិកូល ក៏ឈ្មោះថា ជាអ្នកមានសតិសម្បជញ្ញៈព្រងើយៗ ព្រោះក្នុងបដិសម្ភិទា បែកសេចក្តីនេះទុកដោយន័យថា “ សួរថា ភិក្ខុជាអ្នកមានការសម្គាល់ថា មិនបដិកូលក្នុងវត្ថុដែលបដិកូលនោះ តើដូចម្តេច ? ឆ្លើយថា ភិក្ខុផ្សាយទៅនូវមេត្តាក្តី ពិចារណាដោយសភាពជាធាតុក្តី ក្នុងវត្ថុដែលមិនគួរប្រាថ្នា...” ដូច្នេះជាដើម ។ **ឫទ្ធិ** មានភាពជាអ្នកសម្គាល់ថា មិនបដិកូលក្នុងវត្ថុបដិកូលជាដើម ជាប្រក្រតីបានជាដើមនេះ ហៅថា **អរិយាឥទ្ធិ** ព្រោះមានចំពោះតែព្រះអរិយៈប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

## ៧ – កម្មវិបាកជាឥទ្ធិ

ចំណែកឫទ្ធិដែលមានការទៅតាមអាកាសបានជាដើមនៃសត្វ មានបក្សីជាដើម ឈ្មោះថា **កម្មវិបាកជាឥទ្ធិ** ដូចព្រះបាលីថា សួរថា ឫទ្ធិកើតដោយវិបាកកម្មដូចម្តេច ? ឆ្លើយថា ឫទ្ធិរបស់បក្សីទាំងឡាយ របស់ទេវតាទាំងឡាយ របស់មនុស្សពួកខ្លះ របស់វិនិបាតពួកខ្លះ នេះជាឫទ្ធិកើតដោយវិបាកកម្ម ដូច្នេះ ពិតមែន ក្នុងសត្វទាំងនោះ ការទៅតាមអាកាសបានដោយវៀរចាកឈាន ឬវិបស្សនានៃបក្សីទាំងពួងជា**កម្មវិបាកជាឥទ្ធិ** ដូចគ្នា ការទៅតាមអាកាសបាននៃទេវតាទាំងពួង និងនៃមនុស្សដែលកើតក្នុងបឋមកប្បពួកខ្លះ ក៏ជាកម្មវិបាកជាឥទ្ធិដូចគ្នា ការទៅតាមអាកាសបាននៃវិនិបាតពួកខ្លះ ដូចយក្ខិនីបិយង្ករមាតា យក្ខិនីឧត្តរមាតា យក្ខិនីបុស្សមិត្តា យក្ខិនី

ធម្មគុត្តាជាដើម ក៏ជាកម្មវិបាកជាឥទ្ធិដែរ ។

## ៨-បុញ្ញវតោឥទ្ធិ

ចំណែកឫទ្ធិមានការទៅតាមអាកាសបានជាដើម នៃបុគ្គលអ្នកមានបុណ្យទាំងឡាយ មានព្រះបាទចក្រពត្តិជាដើម ឈ្មោះថា **បុញ្ញវតោឥទ្ធិ** ដូចព្រះបាលីថា សួរថា បុញ្ញវតោឥទ្ធិដូចម្តេច ? ព្រះបាទចក្រពត្តិរមែងយាងទៅតាមអាកាសបាន ព្រមទាំងចតុរង្គសេនា ដោយទីបំផុតរហូតដល់អ្នកចិញ្ចឹមសេះ អ្នកចិញ្ចឹមគោ ( ឫទ្ធិរបស់ព្រះបាទស្តេចចក្រពត្តិនេះជា **បុញ្ញវតោឥទ្ធិ** ) ឫទ្ធិរបស់ជោតិកគហបតីជាបុញ្ញវតោឥទ្ធិ ឫទ្ធិរបស់ជដិលគហបតីក៏ជាបុញ្ញវតោឥទ្ធិ ឫទ្ធិរបស់ឃោសកគហបតីក៏ជាបុញ្ញវតោឥទ្ធិ ឫទ្ធិរបស់មេណ្ឌកសេដ្ឋីក៏ជាបុញ្ញវតោឥទ្ធិ ឫទ្ធិរបស់អ្នកមានបុណ្យទាំង ៥ នាក់ ក៏ជាបុញ្ញវតោឥទ្ធិ ដូច្នេះ ពោលដោយសង្ខេប គុណវិសេសដែលសម្រឹតឡើង ក្នុងកាលបុញ្ញសម្ភារៈដល់នូវភាពចាស់ក្លាហើយ ឈ្មោះថា **បុញ្ញវតោឥទ្ធិ** ។

ឯបណ្តាលោកអ្នកមានបុណ្យទាំងនោះ សម្រាប់ជោតិកគហបតី មានប្រាសាទកែវមួយខ្នង និងកប្បព្រឹក្ស ៦៤ ដើម ទម្លាយផែនដីដុះឡើងមក នេះឯងបុញ្ញវតោឥទ្ធិរបស់ជោតិកគហបតីនោះ សម្រាប់ជដិលគហបតី មានភ្នំមាសកម្ពស់ប្រមាណ ៨០ ហត្ថ កើតឡើង ( នេះជាបុញ្ញវតោឥទ្ធិរបស់ជដិលគហបតីនោះ ) សូម្បីកាលគេធ្វើសេចក្តីព្យាយាមនឹងសម្លាប់ដល់ ៧ កន្លែង ឬ ៧ លើក តែក៏មិនឈឺចាប់អ្វីឡើយ នេះជាបុញ្ញវតោឥទ្ធិរបស់ឃោសកគហបតី ការដែលពពែមាសជាវិការនៃកែវ ៧ ប្រការ កើតប្រាកដឡើងក្នុងស្រែដែលទើបតែភ្ជួរបានមួយគន្លង នេះជា

បុញ្ញវតោឥទ្ធិរបស់មេណ្ឌកគហបតី ។

បុគ្គលគឺមេណ្ឌកសេដ្ឋី ភរិយារបស់លោកឈ្មោះ ចន្ទបទុមសិរី បុត្រឈ្មោះ ធនញ្ជយសេដ្ឋី កូនប្រសាស្រីឈ្មោះ សុមនាទេវី ទាសៈឈ្មោះថា បុណ្ណៈ ឈ្មោះថា អ្នកមានបុណ្យទាំង ៥ ក្នុងបុគ្គលទាំង ៥ នោះ ក្នុងកាលដែលលោកសេដ្ឋីកក់ក្បាលហើយ ងើយមើលអាកាស ជង្រុកស្រូវ ១២៥០ ជង្រុក ក៏ពេញដោយស្រូវសាលីក្រហម ធ្លាក់មកពីអាកាស កាលភរិយារបស់លោកកាន់យកបាយត្រឹមតែមួយនាឡិ ចិញ្ចឹមអ្នកជម្ពូទ្វីបទាំងអស់បាន ក៏បាយមិនអស់ កាលបុត្ររបស់លោកកាន់យកថង់ប្រាក់ ១០០០ កហាបណៈ ឲ្យទានដល់អ្នកជម្ពូទ្វីបគ្រប់គ្នា កហាបណៈក៏មិនអស់ឡើយ កាលកូនប្រសាស្រីរបស់លោក កាន់យកបបរមួយវែក ចែកដល់អ្នកជម្ពូទ្វីបគ្រប់គ្នា បបរក៏មិនអស់ កាលទាសៈរបស់លោកភ្ជួរស្រែដោយនង្គ័លមួយផាល ឬមួយជុំ ក៏បាន ១៤ គន្លង មួយផ្នែក ៧ គន្លង នេះជាបុញ្ញវតោឥទ្ធិរបស់បុគ្គលទាំង ៥ នាក់នោះ ។

## ៩ -វិជ្ជាមយាឥទ្ធិ

ចំណែកឫទ្ធិដែលមានការទៅតាមអាកាសបានជាដើម នៃទេពជាន់ទាប មានវិជ្ជាធរជាអាទិ៍ ឈ្មោះថា **វិជ្ជាមយាឥទ្ធិ** ដូចព្រះបាលីថា សួរថា វិជ្ជាមយាឥទ្ធិតើដូចម្តេច ? ឆ្លើយថា ពួកវិជ្ជាធររាយវិជ្ជាហើយ ទៅតាមអាកាសបាន សម្តែងដំរីខាងក្នុងអាកាស កណ្តាលវាលក៏បាន ។ ល ។ សម្តែងក្បួនសេនាផ្សេងៗ ក្នុងអាកាស កណ្តាលវាលក៏បាន ។

## ១០-តត្ថ តត្ថ សម្មាបយោគបច្ចយា ឥជ្ឈនដ្ឋេនឥទ្ធិ

ចំណែកការសម្រេចនៃកម្មនោះៗ ព្រោះសេចក្តីប្រកបត្រូវនោះៗ ឈ្មោះថា **តត្ថ តត្ថ សម្មាបយោគបច្ចយា ឥជ្ឈនដ្ឋេនឥទ្ធិ** ឫទ្ធិដោយការសម្រេច ព្រោះប្រកបត្រូវក្នុងកិច្ចនោះៗ ជាបច្ច័យ ដូចព្រះបាលីថា **ផល** គឺ ការលះកាមច្ឆន្ទៈ រមែង សម្រេចដោយនេក្ខម្មៈ ព្រោះហេតុនោះ ផលនោះ ទើបឈ្មោះថា **ឫទ្ធិ** ដោយសេចក្តីថា សម្រេច ព្រោះប្រកបត្រូវក្នុងកិច្ចនោះៗជាបច្ច័យ ។ល។ ផល គឺ ការលះកិលេសទាំងពួង រមែងសម្រេចដោយអរហត្តមគ្គ ព្រោះហេតុនោះ ផលនោះ ទើបឈ្មោះថា **ឫទ្ធិ** ដោយសេចក្តីថា សម្រេច ព្រោះប្រកបត្រូវក្នុងកិច្ចនោះៗ ជាបច្ច័យ ។

ក៏បាលីមកក្នុងនិទ្ទេសនៃឫទ្ធិទី ១០ នេះ ក៏ដូចគ្នានឹងបាលីក្នុងនិទ្ទេសនៃឫទ្ធិមុនៗ ( មានសមាធិវិប្ផារឥទ្ធិជាដើម ) ដោយសម្តែងសម្មាបយោគៈដែលបានដល់ការបដិបត្តិដូចគ្នា តែមកក្នុងអដ្ឋកថាថា ភាពពិសេសដែលកើតឡើងព្រោះការធ្វើនោះៗ គឺ សិល្បកម្ម ( សម្តែងថ្មីដែលណាមួយ ) , ម្យ៉ាងទៀត ដោយការធ្វើព្យូហៈ ( គឺ ក្បួនរៀបទ័ព ) មាន សកដព្យូហៈ( ក្បួនទ័ពរទេះ ) ជាដើម វេជ្ជកម្មណាមួយ ការរៀនត្រៃវេទ ការរៀនព្រះត្រៃបិដក ដោយហោចទៅការងារកសិកម្ម មានការភ្ជួររាស់ជាដើម ឈ្មោះថា **តត្ថ តត្ថ សម្មាបយោគបច្ចយា ឥជ្ឈនដ្ឋេនឥទ្ធិ** ឫទ្ធិដោយការសម្រេច ព្រោះការប្រកបត្រូវក្នុងកិច្ចនោះៗ ជាបច្ច័យ ។

## បទធិ៍ដែលលោកបំណាច់យកក្នុងបាលី

ក្នុងឥទ្ធិ ១០ ដូចពោលមកនេះ អធិដ្ឋានាឥទ្ធិប៉ុណ្ណោះមកក្នុងបាលី បទថា ឥទ្ធិវិធាយនេះ តែក្នុងអដ្ឋកថានេះ ត្រូវយកវិកុព្វនាឥទ្ធិ និងមនោមយាឥទ្ធិមកប្រកប

ផងដែរ ។

## អធិប្បាយ អត្ថចាលី

បទថា **ឥទ្ធិវិធាយ** ដើម្បីឫទ្ធិមួយប្រភេទនោះ គឺដើម្បីផ្នែកមួយនៃឫទ្ធិ ឬ ដើម្បីវិកប្ប ( មួយ ) នៃឫទ្ធិ , ពាក្យថា **នាំចិត្តឆ្ពោះទៅ** មានសេចក្តីថា ភិក្ខុនោះ កាលចិត្តនោះ គឺឈានដែលជាបាទនៃអភិញ្ញាកើតហើយ ដោយអំណាចនៃការហ្វឹកហាត់ចិត្ត មានប្រការដូចពោលហើយ នាំបរិកម្មចិត្តឆ្ពោះទៅដើម្បីប្រយោជន៍ដល់ការបានឫទ្ធិមួយប្រភេទ គឺ ដកចិត្តពីអារម្មណ៍កសិណហើយ បញ្ជូនចិត្តនោះឲ្យឆ្ពោះមុខចំពោះប្រភេទនៃឫទ្ធិ , បទថា **បង្អោនចិត្តឆ្ពោះទៅ** គឺធ្វើចិត្តឲ្យបង្អោនទៅចំពោះឫទ្ធិដែលនឹងគប្បីសម្រេច បង្អោនទៅរកឫទ្ធិដែលនឹងគប្បីសម្រេច បទថា " **សោ** " នោះ បានដល់ ភិក្ខុអ្នកមានការនាំចិត្តឆ្ពោះទៅ បានធ្វើហើយយ៉ាងនោះ , បទថា **អនេកវិហិតំ** ប្រែថា ច្រើនយ៉ាង ច្រើនប្រការ, បទថា **ឥទ្ធិវិធំ** ប្រែថា ចំណែកមួយនៃឫទ្ធិ , បទថា **បច្ចនុភោតិ** សេចក្តីថា បានសោយ គឺ បានប៉ះពាល់ បានធ្វើឲ្យជាក់ច្បាស់ បានសម្រេច ។

## ពហុភាវបដិហារិយៈ

### " ធ្វើមនុស្សម្នាក់ឲ្យជាមនុស្សច្រើន "

តពីនោះ កាលដែលទ្រង់សម្តែងដល់ឥទ្ធិវិធនោះ មានច្រើនយ៉ាង ទើបត្រាស់ពាក្យថា **ឯកោបិ ហុត្វា** ជាអាទិ៍ ក្នុងពាក្យទាំងនោះ ពាក្យថា **ឯកោបិ ហុត្វា** គឺដោយប្រក្រតីមុនអំពីការធ្វើឫទ្ធិ លោកជាមនុស្សម្នាក់នោះឯង, ពាក្យថា **ពហុធា ហោតិ** មានសេចក្តីថា លោកជាអ្នកប្រាថ្នាចង្រ្កម ឬ ប្រាថ្នានឹងធ្វើការស្វាធ្យាយ ឬ

ប្រាថ្នានឹងសួរបញ្ហាក្តី ក្នុងទីជិតភិក្ខុច្រើនរូប ក៏និម្មិតកាយខ្លួនឡើងជា ១០០ អង្គក៏បានជា ១០០០ អង្គក៏បាន ។

## ឥទ្ធិវិធី

សួរថា ក៏ភិក្ខុនេះនឹងធ្វើយ៉ាងនោះបានដោយវិធីដូចម្តេច ? ឆ្លើយថា លោកញ៉ាំងភូមិ ៤ នៃឫទ្ធិ និងបាទ ៤ , បទ ៨ , មូល ១៦ នៃឫទ្ធិឲ្យដល់ព្រមហើយអធិដ្ឋានដោយញាណទៅ រមែងធ្វើយ៉ាងនោះបាន ។

## ភូមិ៤នៃឫទ្ធិ

ក្នុងវិធីទាំងនោះ ឈាន ៤ គប្បីជ្រាបថា ឬហៅថា ភូមិ ៤ ពិតមែន ព្រះធម្មសេនាបតីបានពោលពាក្យនេះទុកថា សួរថា ភូមិ ៤ នៃឫទ្ធិ តើដូចម្តេច ? ឆ្លើយថា បឋមជ្ឈានជាវិវេកជភូមិ( ភូមិកើតពីវិវេក ) ទុតិយជ្ឈានជាបីតិសុខភូមិ ( ភូមិមានបីតិនិងសុខ ) តតិយជ្ឈានជាឧបេក្ខាសុខភូមិ( ភូមិឧបេក្ខានិងសុខ ) ចតុត្ថជ្ឈានជាអទុក្ខមសុខភូមិ( ភូមិអទុក្ខមសុខ ) នេះជាភូមិ ៤ នៃឫទ្ធិ ប្រព្រឹត្តទៅដើម្បីការបានឫទ្ធិ ដើម្បីការសម្រេចឫទ្ធិ ដើម្បីការធ្វើឫទ្ធិបានផ្សេងៗ ដើម្បីការបានទទួលអានិសង្សផ្សេងៗនៃឫទ្ធិ ដើម្បីភាពជំនាញនៃឫទ្ធិ ដើម្បីភាពក្លៀវក្លានៃឫទ្ធិដូច្នេះ ។

ក៏ព្រោះហេតុដែលព្រះយោគីចូលកាន់សុខសញ្ញា ( ការកំណត់ការប្រព្រឹត្តទៅព្រមគ្នានឹងសេចក្តីសុខក្នុងឈាន ) និងលហុសញ្ញា ( ការកំណត់ការប្រព្រឹត្តទៅព្រមគ្នាដោយភាពស្រាល ដែលប្រកបដោយសេចក្តីសុខនោះ ) ហើយជាអ្នកមាននាមកាយស្រាល ទន់ គួរដល់ការបានឫទ្ធិ ព្រោះភាពជ្រួតជ្រាបនៃបីតិក្នុងបឋមជ្ឈាន

និង ទុតិយជ្ឈាន ព្រោះភាពជ្រួតជ្រាបនៃសុខក្នុងទុតិយជ្ឈាន ព្រោះហេតុនោះ ក្នុងឈាន ៤ នោះ ឈាន ៣ ខាងដើម គប្បីជ្រាបថា ជាសម្ភារភូមិ ( ភូមិប្រកប ? ) ព្រោះប្រព្រឹត្តទៅដើម្បីការបានឫទ្ធិដោយបរិយាយនេះ ចំណែកចតុត្ថជ្ឈានជាប្រក្រតីភូមិ គឺ ភូមិតាមប្រក្រតី ដើម្បីការបានឫទ្ធិពិត ។

## បាទនៃឫទ្ធិ ៤

ឥទ្ធិបាទ ៤ គប្បីជ្រាបថា ឫហៅថា បាទ ៤ សមដូចព្រះបាលីថា សួរថា បាទ ៤ នៃឫទ្ធិដូចម្តេច ? ឆ្លើយថា ភិក្ខុក្នុងធម្មវិន័យចម្រើនឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកបដោយវិមង្សាសមាធិ និងបធានសង្ខារ នេះបាទ ៤ នៃឫទ្ធិ រមែងប្រព្រឹត្តទៅដើម្បីការបានឫទ្ធិ ។ល។ ដើម្បីភាពក្លៀវក្លានៃឫទ្ធិដូច្នេះ ។

ឯក្នុងនិទ្ទេសនៃឥទ្ធិបាទនេះ សមាធិដែលមានឆន្ទៈជាហេតុ ឫក្រៃលែងដោយឆន្ទៈ ឈ្មោះថា **ឆន្ទសមាធិ** ពាក្យនេះជាពាក្យហៅសមាធិ ដែលព្រះយោគីធ្វើឆន្ទៈគឺដោយការពេញចិត្តនឹងធ្វើឲ្យជាធំ ទើបបានសម្រេច ។

សង្ខារដែលជាតួសេចក្តីព្យាយាម ឈ្មោះថា **បធានសង្ខារ** ពាក្យនេះជាឈ្មោះនៃសេចក្តីព្យាយាម ពោលគឺ សម្មប្បធាន ដែលញុំាងកិច្ច ៤ ឲ្យសម្រេច ។

ពាក្យថា **ប្រកបដោយ...** គឺ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារទាំងឡាយផង ។

ពាក្យថា **ឥទ្ធិបាទ** បានដល់ គំនរចិត្ត និងចេតសិកដ៏សេស ដែលឈ្មោះ

ថា **បាទ** ព្រោះសេចក្តីថា ជាទីតាំងនៃឆន្ទសមាធិ និង បធានសង្ខារទាំងឡាយ ដែលសម្បយុត្តដោយអភិញ្ញាចិត្តដែលដល់នូវការរាប់ថា **ឥទ្ធិ** ព្រោះអត្ថថាសម្រេច ដោយបរិយាយថា កើតផល ឬ ន័យមួយទៀត ដល់នូវការរាប់ថា **ឥទ្ធិ** ព្រោះជា គ្រឿងសម្រេចនៃសត្វទាំងឡាយដោយបរិយាយនេះថា ជាគ្រឿងរុងរឿងចម្រើនខ្ពស់ ឡើងទៅនៃសត្វទាំងឡាយ សមដូចព្រះបាលីថា ពាក្យថា **ឥទ្ធិបាទ** បានដល់ កង វេទនា កងសញ្ញា កងសង្ខារ កងវិញ្ញាណនៃភិក្ខុអ្នកធ្វើយ៉ាងនោះ ។

ន័យមួយទៀត ឈ្មោះថា **បាទ** ព្រោះជាគ្រឿងដែលបុគ្គលដល់ មានសេចក្តី ថា ជាគ្រឿងឲ្យសម្រេច បាទនៃឫទ្ធិ ឈ្មោះថា **ឥទ្ធិបាទ** ពាក្យនេះជាឈ្មោះនៃធម៌ មានឆន្ទៈជាដើម ដូចព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអាស្រ័យឆន្ទៈ បាន សមាធិ បានភាពនៃចិត្តដែលមានអារម្មណ៍តែមួយ នេះហៅថា **ឆន្ទសមាធិ** ភិក្ខុ នោះញ៉ាំងឆន្ទៈឲ្យកើត ព្យាយាមប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តាំងចិត្ត ដើម្បី ញ៉ាំងបាបអកុសលធម៌ដែលនៅមិនទាន់កើត មិនឲ្យកើតឡើង ។ល។ អាការទាំង នេះហៅថា បធានសង្ខារដោយប្រការដូច្នេះ ឆន្ទៈនេះផង ឆន្ទសមាធិនេះផង បធានសង្ខារទាំងឡាយនេះផង នេះហៅថា ឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និង បធានសង្ខារដូច្នេះ សូម្បីក្នុងឥទ្ធិបាទដ៏សេស គប្បីជ្រាបសេចក្តីតាមន័យដូចពោល មកនេះផងចុះ ។

## បទ៨នៃឫទ្ធិ

បទ ៨ មានឆន្ទៈជាអាទិ គប្បីជ្រាបថា ឬហៅថា បទ ៨ សមដូចព្រះបាលី ក្នុងបដិសម្ភិទាមគ្គថា បទ ៨ នៃឫទ្ធិដូចម្តេច ? បទ ៨ នៃឫទ្ធិ គឺបើភិក្ខុអាស្រ័យ

*ឆន្ទៈ បានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយដូច្នោះ ឆន្ទៈមិនមែនសមាធិ សមាធិក៏មិនមែនឆន្ទៈ ឆន្ទៈដោយឡែក សមាធិក៏ដោយឡែក បើភិក្ខុអាស្រ័យវិរិយៈបានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយដូច្នោះ វិរិយៈមិនមែនសមាធិ សមាធិក៏មិនមែនវិរិយៈ វិរិយៈដោយឡែក សមាធិក៏ដោយឡែក បើភិក្ខុអាស្រ័យចិត្តបានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយដូច្នោះ ចិត្តមិនមែនសមាធិ សមាធិក៏មិនមែនចិត្ត ចិត្តដោយឡែក សមាធិក៏ដោយឡែក បើភិក្ខុអាស្រ័យវិមង្សាបានសមាធិ បានភាពដែលចិត្តមានអារម្មណ៍តែមួយ ដូច្នោះ វិមង្សាមិនមែនសមាធិ សមាធិក៏មិនមែនវិមង្សា វិមង្សាដោយឡែក សមាធិក៏ដោយឡែក បទ ៨ នៃឫទ្ធិពួកនេះ ប្រព្រឹត្តទៅដើម្បីបានឫទ្ធិ ។ល។ ដើម្បីភាពចាស់ក្លានៃឫទ្ធិ ។*

*ព្រោះហេតុដែលឆន្ទៈ គឺ ភាពជាអ្នកប្រាថ្នានឹងញុំាងឫទ្ធិឲ្យកើតឡើង ដែលប្រកបចូលជាមួយនឹងសមាធិហើយប៉ុណ្ណោះ ទើបប្រព្រឹត្តទៅដើម្បីឫទ្ធិ ឥទ្ធិបាទដ៏សេស មានវិរិយៈជាដើមក៏យ៉ាងនោះ ព្រោះហេតុនោះ បទ ៨ មានឆន្ទៈជាដើមនេះ គប្បីជ្រាបថា លោកហៅថា បទ ៨ ក្នុងព្រះបាលីនោះ ។*

## មូល ១៦ នៃឫទ្ធិ

*ភាពដែលចិត្តមិនញាប់ញ័រដោយអាការ ១៦ គប្បីជ្រាបថា ឬហៅថា មូល ១៦ សមដូចព្រះបាលីក្នុងបដិសម្ភិទាមគ្គថា សួរថា មូលនៃឫទ្ធិមានប៉ុន្មាន ? ឆ្លើយថា មូលមាន ១៦ គឺ :*

*១- ចិត្តដែលមិនធ្លាក់ចុះ ឈ្មោះថា* **អានេញ្ជ** *ព្រោះមិនញាប់ញ័រដោយកោសជ្ជៈ*

២- ចិត្តដែលមិនស្ទុះឡើង ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយឧទ្ធច្ចៈ

៣- ចិត្តដែលមិនងប់ជ្រប់ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយរាគៈ

៤- ចិត្តដែលមិនប្រានចេញ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយព្យាបាទ ។

៥- ចិត្តដែលមិនប្រកាន់ស្អិត ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយទិដ្ឋិ

៦- ចិត្តដែលមិនជាប់ជំពាក់ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយឆន្ទរាគៈ ។

៧- ចិត្តដែលរួចផុត ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយកាមរាគៈ។

៨- ចិត្តដែលមិនពាក់ព័ន្ធ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយកិលេស ។

៩- ចិត្តដែលធ្វើមិនឲ្យមានព្រំដែន ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយព្រំដែន គឺ កិលេស ។

១០- ចិត្តដែលមានអារម្មណ៍តែមួយ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយកិលេសផ្សេងៗ ។

១១- ចិត្តដែលសទ្ធាគ្រប់គ្រងហើយ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយអសទ្ធិយៈ ។

១២- ចិត្តដែលវីរិយៈគ្រប់គ្រងហើយ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយកោសជ្ជៈ ។

១៣- ចិត្តដែលសតិគ្រប់គ្រងហើយ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយសេចក្តីប្រមាទ ។

១៤- ចិត្តដែលសមាធិគ្រប់គ្រងហើយ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយឧទ្ធច្ចៈ ។

១៥- ចិត្តដែលបញ្ញាគ្រប់គ្រងហើយ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយអវិជ្ជា ។

១៦- ចិត្តដែលដល់ភាពភ្លឺស្វាងហើយ ឈ្មោះថា **អានេញ្ជ** ព្រោះមិនញាប់ញ័រដោយភាពងងឹត គឺ អវិជ្ជា ។

នេះមូល **១៦** នៃឫទ្ធិ ប្រព្រឹត្តទៅដើម្បីការបានឫទ្ធិ ។ល។ ដើម្បីភាពក្លៀវក្លានៃឫទ្ធិដូច្នេះ ។

សេចក្តីថា **ចិត្តមិនញាប់ញ័រព្រោះកោសជ្ជៈជាដើមនេះ** ជាការសម្រេចទៅហើយ សូម្បីដោយបាទ ( ព្រះបាលី ) ថា **ឯវំ សមាហិតេ ចិត្តេ**-កាលចិត្តតាំងមាំ.....យ៉ាងនេះហើយ ដូច្នេះជាដើម ដោយពិត តែថា លោកពោលទៀត ក៏ដើម្បីសម្តែងភាពដែលឈាន មានបឋមជ្ឈានជាអាទិ ជាភូមិ ជាបាទ ជាបទ និងជាមូលនៃឫទ្ធិ ម្យ៉ាងទៀត ន័យមុនជាន័យមកក្នុងព្រះសូត្រទាំងឡាយ ន័យនេះមកនៅក្នុងបដិសម្ភិទា លោកពោលទុកដើម្បីមិនវង្វេងក្នុងន័យទាំងពីរ ដូច្នេះក៏បាន ។

## អធិដ្ឋានដោយញាណ

ចំណែកពាក្យថា **អធិដ្ឋានដោយញាណ** មានអធិប្បាយថា ភិក្ខុនេះនោះកាលញុំាងធម៌ដែលជាភូមិ ជាបាទ ជាបទ និងជាមូលនៃឫទ្ធិទាំងនោះឲ្យដល់ព្រមហើយ ចូលឈានដែលជាបាទនៃអភិញ្ញា ចេញហើយ បើត្រូវការឲ្យខ្លួនជា ១០០ នាក់ បរិកម្មថា **សតំ ហោមិ សតំ ហោមិ**-យើងចូរជាមនុស្ស ១០០ នាក់ យើង

ចូរជាមនុស្ស ១០០ នាក់ ហើយចូលឈានដែលជាបាទនៃអភិញ្ញាទៀត ចេញហើយ ទើបអធិដ្ឋាន ទន្ទឹមនឹងចិត្តអធិដ្ឋាននោះឯង លោកក៏ជាមនុស្ស ១០០ នាក់បាន ន័យសូម្បីក្នុងការអធិដ្ឋានឲ្យជា ១០០០ នាក់ជាដើម ក៏មានន័យដូច្នេះ បើធ្វើយ៉ាងនោះទៅ នឹងមិនសម្រេច ដូច្នោះ គប្បីធ្វើបរិកម្មហើយចូលឈានជាវារៈទី ២ ចេញហើយ ទើបអធិដ្ឋានទៀតក៏បាន ព្រោះក្នុងអដ្ឋកថាសំយុត្តនិកាយពោលថា ចូលម្តង ២ វារៈ ក៏គួរ ដូច្នេះក្នុងការអធិដ្ឋាននោះ ចិត្តក្នុងឈានដែលជាបាទមានបដិភាគនិមិត្តជាអារម្មណ៍ ចិត្តក្នុងការបរិកម្មមានមនុស្សចំនួន ១០០ នាក់ ជាអារម្មណ៍ ឬមានមនុស្សចំនួន ១០០០ នាក់ ជាអារម្មណ៍( តាមតម្រូវការ ) តែថាអារម្មណ៍ទាំងនោះ ក៏ត្រឹមតែជាពណ៌ ( ភេទដែលនឹកកំណត់ឡើង ) មិនជាបញ្ញត្តិ ( ជាសត្វ មនុស្សពិតៗទេ ) សូម្បីចិត្តក្នុងអធិដ្ឋានក៏យ៉ាងនោះដូចគ្នា គឺ មានមនុស្សចំនួន ១០០ ជាអារម្មណ៍ ឬ មានមនុស្ស ១០០០ ជាអារម្មណ៍ , អធិដ្ឋានចិត្តនោះហើយ ជាចិត្តសម្បយុត្តដោយរូបាវចរចតុត្ថជ្ឈាន កើតឡើង ១ ដួងប៉ុណ្ណោះ ចំពោះគោត្រភូចិត្ត ដូចអប្បនាចិត្តដែលពោលមកពីមុន សូម្បីពាក្យដែលពោលក្នុងបដិសម្ភិទាថា ដោយប្រក្រតី ( ព្រះយោគី ) តែម្នាក់ឯង ( ប៉ុន្តែ ) នឹកឲ្យជាមនុស្សច្រើន ចំនួន ១០០ ក្តី ចំនួន ១.០០០ ក្តី ចំនួន ១០០.០០០ ក្តី កាលនឹកហើយក៏អធិដ្ឋានដោយញាណថា យើងចូរជាមនុស្សចំនួនច្រើន លោកក៏ជាមនុស្សចំនួនច្រើនឡើង ដូចព្រះចុល្លបន្ថកៈ ដូច្នោះ , ដូច្នេះ ពាក្យថា **អាវជ្ជតិ-នឹក** លោកក៏ពោលដោយជាបរិកម្មនោះឯង ( មិនមែនអាវជ្ជនៈ ) , ពាក្យថា **កាលនឹកហើយ ក៏អធិដ្ឋានដោយញាណ** នេះក៏ពោលដោយសម្ដៅយកញាណក្នុងអភិញ្ញា ( មិនមែនញាណដែលសម្បយុត្តដោយបរិកម្មចិត្ត ឬញាណជាកាមាវចរៈដទៃៗទេ )

ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញសេចក្តីក្នុងពាក្យថា **អធិដ្ឋានដោយញាណនោះ** គឺថា ព្រះយោគីនឹកឲ្យជាមនុស្សច្រើន ហើយក្នុងទីបំផុតនៃបរិកម្មចិត្តទាំងនោះ ក៏ចូលសមាបត្តិ ចេញចាកសមាបត្តិហើយ នឹកទៀតថា យើងចូរជាមនុស្សច្រើន ហើយទើបអធិដ្ឋានដោយញាណក្នុងអភិញ្ញា ដែលជាញាណ ១ ដួង កើតឡើងក្នុងលំដាប់នៃចិត្ត ដែលជាបុព្វភាគ ៣-៤ ដួង ដែលប្រព្រឹត្តទៅ តពីនោះ ក៏បានឈ្មោះថា **អធិដ្ឋាន**( ញាណ ) ដោយអំណាចជាហេតុឲ្យសម្រេច ដូច្នេះឯង ។

ចំណែកពាក្យដែលថា ដូចព្រះចូឡបន្ថកៈនោះ លោកពោលដើម្បីសម្តែងកាយសក្ខី ( ប្រចក្សច្បាស់ ) នៃបុព្វភាគ ( ការអធិដ្ឋានឲ្យជាមនុស្សច្រើន ) ក៏ពាក្យនោះគួរសម្តែងដោយរឿង ។

## រឿង ចូឡបន្ថកៈ

បានឮមកថា ពីរនាក់បងប្អូននោះ បាននាមថា បន្ថកៈ ព្រោះលោកកើតកណ្តាលផ្លូវ លោកទាំងពីរនោះ បងឈ្មោះថា មហាបន្ថកៈ លោកបួសហើយបានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា កាលជាព្រះអរហន្តហើយ ទើបឲ្យប្អូនប្រុសឈ្មោះ ចូឡបន្ថកៈបួស ហើយបានឲ្យទន្ទេញគាថានេះថា :

**បទុមំ យថា កោកនុទំ សុគន្ធំ　　　　បាតោ សិយា ផុល្លមវីតគន្ធំ**
**អង្គីរសំ បស្ស វិរោចមានំ　　　　តបន្តមាទិច្ចមិវន្តលិក្ខេ ។**

សូមគោរពសរសើរព្រះអង្គីរស ព្រះអង្គរីករាយ ក្រអូបដូចផ្កាបទុមពណ៌កោកនុទៈ ដែលរីកក្នុងពេលព្រឹក នៅមិនទាន់អស់ក្លិនឈ្ងុយដូច្នោះ ។

សូមគោរពសរសើរព្រះអង្គីរស ព្រះអង្គស្រស់ថ្លាដូចព្រះអាទិត្យ បំភ្លឺនៅ

កណ្តាលវេហាស៍ដូច្នេះ ។

ព្រះចូឡបន្ថកៈ ( ជាមនុស្សខ្សោយក្នុងការចងចាំ ) មិនអាចធ្វើការទន្ទេញគាថានោះឲ្យស្ទាត់បាន អស់ពេលដល់ ៤ ខែ ដូច្នោះ ព្រះថេរៈទើបប្រាប់លោកថា អាវុសោ ជាមនុស្សអកព្វក្នុងព្រះសាសនា ហើយដេញចេញពីវិហារ ក្នុងកាលនោះ ព្រះថេរៈជាព្រះភត្តុទ្ទេសកៈ ពេទ្យជីវកទៅរកព្រះថេរៈដោយនិមន្តថា បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃស្អែកនេះ សូមលោកម្ចាស់នាំភិក្ខុ ៥០០ អង្គ ព្រមទាំងព្រះមានព្រះភាគទៅទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះករុណា ខាងផ្នែកព្រះថេរៈទទួលនិមន្តដោយពោលថា អាត្មាទទួលនិមន្តសម្រាប់ភិក្ខុដ៏សេស វៀរតែព្រះចូឡបន្ថកៈ ព្រះចូឡបន្ថកៈខូចចិត្ត ទៅឈរយំត្រង់ខ្លោងទ្វារវត្ត ព្រះមានព្រះភាគទ្រង់ឃើញដោយទិព្វចក្ខុក៏ស្តេចយាងទៅរកលោក ត្រាស់សួរថា អ្នកយំរឿងអ្វី លោកក៏បានក្រាបទូលសេចក្តីដែលមានមកនោះ ឲ្យព្រះអង្គជ្រាប ហើយព្រះមានព្រះភាគត្រាស់លួងលោមលោកថា អ្នកមិនអាចចងចាំគាថាបាន នឹងរាប់ថាជាមនុស្សអកព្វក្នុងសាសនារបស់តថាគតក៏ទេ កុំសោកសៅឡើយភិក្ខុ ហើយទ្រង់ចាប់ត្រង់ដើមដៃនាំចូលទៅក្នុងវិហារ ទ្រង់និម្មិតសំពត់សមួយផ្ទាំងដោយឫទ្ធិ ប្រទានឲ្យព្រះចូឡបន្ថកៈទ្រង់ណែនាំថា ណ្ហើយចុះភិក្ខុ អ្នកទន្ទេញសំពត់នេះទៅមកឲ្យរហ័ស ទន្ទេញថា **រជោហរណំ រជោហរណំ**-ជូតធូលី ជូតធូលី ទៅចុះ កាលលោកធ្វើយ៉ាងនោះទៅសំពត់នោះ ក៏កើតមានពណ៌ខ្មៅឡើង លោកក៏បានបដិកូល និងអនិច្ចសញ្ញាឡើងថា សំពត់នេះស្អាត ទោសក្នុងសំពត់មិនមានទេ តែទោស គឺការមានពណ៌ខ្មៅឡើងនេះនេះជាទោសរបស់រាងកាយ ហើយញ៉ាំងញាណសម្ពឹងក្នុងបញ្ចក្ខន្ធ ចម្រើនវិបស្សនាទៅរហូតដល់ខណៈអនុលោមញាណ ជិតគោត្រភូញាណ ខណៈនោះព្រះមុនីត្រាស់

គាថាដល់ព្រះថេរៈថា :

**រាគៈ** ហៅថា ធូលី តែលម្អងខាងក្រៅ មិនហៅថាធូលីក្នុងអរិយវិន័យទេ ពាក្យថា ធូលីនោះ ជាពាក្យហៅ រាគៈ បុគ្គលទាំងឡាយ ដែលលះធូលី គឺរាគៈនោះបានហើយ ក៏ជាបណ្ឌិតនៅក្នុងសាសនារបស់តថាគត ជាអ្នកប្រាសចាកធូលី , **ទោសៈ** ហៅថាធូលី តែលម្អងមិនហៅថាធូលីទេ ពាក្យថា ធូលីនោះ ជាពាក្យហៅទោសៈ បុគ្គលទាំងឡាយអ្នកលះធូលី គឺទោសៈនោះបានហើយ ក៏ជាបណ្ឌិតនៅក្នុងសាសនារបស់តថាគត ជាអ្នកប្រាសចាកធូលី , **មោហៈ** ហៅថា ធូលី តែលម្អងមិនហៅថាធូលីទេ ពាក្យថា ធូលីជាពាក្យហៅមោហៈ បុគ្គលទាំងឡាយអ្នកដែលលះធូលី គឺមោហៈនោះបានហើយ ក៏ជាបណ្ឌិតនៅក្នុងសាសនារបស់តថាគតជាអ្នកប្រាសចាកធូលី ។

កាលចប់ព្រះគាថា នវលោកុត្តរធម៌នោះ ដែលមានចតុបដិសម្ភិទា និងឆឡភិញ្ញាជាបរិវារ ក៏បានកើតមានដល់ព្រះចូឡបន្ថកៈនោះដែរ ។

ថ្ងៃស្អែកឡើង ព្រះសាស្តាបានស្តេចទៅកាន់ផ្ទះពេទ្យជីវក ព្រមទាំងភិក្ខុសង្ឃទីបំផុតខាងក្រោយទក្ខិណោទក និងថ្វាយយាគូ ក៏ទ្រង់បិទបាត្រទុកដោយព្រះហស្ត ទេព្យជីវកទូលសួរថា តើហេតុអ្វី ព្រះពុទ្ធជាម្ចាស់ ទ្រង់តបថា ក្នុងវិហារនៅមានភិក្ខុសល់មួយរូបទៀត ទើបពេទ្យជីវកបញ្ជូនមនុស្សទៅប្រាប់ថា អ្នកចូរទៅទូលលោកម្ចាស់ មកឲ្យលឿន ។

កាលព្រះមានព្រះភាគ ស្តេចចេញពីវិហារទៅនោះ ព្រះបន្ថកៈបាននិម្មិតខ្លួនឡើង ១០០០ នាក់ គង់នៅក្នុងអម្ពវ័នដ៏រីករាយ រហូតដល់ពេលដែលគេមកប្រាប់ភត្តកាល ។

គ្រានោះ បុរសនោះបានទៅដល់ ឃើញចំការស្វាយរបស់ពេទ្យជីវកៈរុងរឿងតែម្យ៉ាងដោយសំពត់កាសាវៈទាំងឡាយ ទើបត្រឡប់មកក្រាបទូលថា ចំការពេញទៅដោយភិក្ខុទាំងឡាយ ព្រះពុទ្ធជាម្ចាស់ ខ្ញុំម្ចាស់មិនបានដឹងថា លោកម្ចាស់អង្គនោះគឺអង្គណាមួយទេ ដូច្នេះហើយ ព្រះមានព្រះភាគត្រាស់នឹងបុរសនោះថា អ្នកចូរទៅម្តងទៀត ជួបភិក្ខុអង្គណាមុន ចូរចាប់ភិក្ខុអង្គនោះទុកត្រង់ជាយចីវរ ហើយនិយាយឡើងថា ព្រះសាស្តាត្រាស់ឲ្យនិមន្តលោក ហើយនាំមកចុះ ទើបបុរសនោះត្រឡប់ទៅចាប់ត្រង់ជាយចីវររបស់ព្រះថេរៈ ភ្លាមនោះ ភិក្ខុនិម្មិតទាំងឡាយនោះក៏អន្តរធានទៅ ទើបព្រះថេរៈប្រាប់ថា អ្នកចូរទៅមុនចុះ បញ្ជូនគេទៅហើយ ធ្វើសរីរកិច្ច មានខ្ពុរមាត់ជាដើមស្រេចហើយ ទៅដោយឫទ្ធិដល់មុនបុរសនោះ គង់លើអាសនៈដែលគេចាត់ចែងត្រៀមទុកហើយ ។

ពាក្យថា ដូចព្រះចូឡបន្ថកៈនោះ ខ្ញុំពោលសំដៅយករឿងដែលលោកពោលមកនេះឯង ។

ភិក្ខុចំនួនច្រើន ដែលលោកអ្នកមានឫទ្ធិនិម្មិតហើយ ដោយមិនកំណត់ឲ្យមានអាការផ្សេងៗ គឺលោកអ្នកមានឫទ្ធិធ្វើកិរិយា ក្នុងឥរិយាបថ មានឈរ និងអង្គុយជាដើមក្តី ក្នុងអាការ មាននិយាយ និងស្ងៀមជាដើមក្តីណាៗ ភិក្ខុនិម្មិតទាំងនោះក៏ធ្វើកិរិយានោះៗ ដូចគ្នា តែបើលោកអ្នកមានឫទ្ធិប្រាថ្នានឹងធ្វើភិក្ខុនិម្មិតទាំងឡាយឲ្យមានភេទផ្សេងៗគ្នា គឺ ពួកខ្លះមានវ័យជាបឋមវ័យ ពួកខ្លះមជ្ឈិមវ័យ ពួកខ្លះបច្ឆិមវ័យ ដោយន័យនោះ ខ្លះក៏មានសក់វែង ខ្លះក៏មានព្រះសិរសៈត្រងោល គឺកោរហើយ ពាក់កណ្តាលនៅមិនទាន់សម្រេច ខ្លះក៏មានសក់កណ្តិបកណ្តុប គឺ ស្កូវកញ្ចិបកញ្ចុប ខ្លះក៏មានចីវរក្រហមពាក់កណ្តាល ខ្លះមានចីវរពណ៌លឿងស្លុទ្ធ ខ្លះ

កំពុងធ្វើកិច្ចផ្សេងៗ គ្នា មានបទភាណ ( សូធ្យទៅតាមព្រះបាលី ) ធម្មកថា ( ពោលអធិប្បាយធម៌ ) សរភញ្ញ ( សូធ្យគាថាដោយប្រើសំឡេងមានទំនង ) សួរបញ្ហា តបបញ្ហា និងអប់បាត្រ ដេរចីវរ បោកចីវរជាដើម ឬថា ជាអ្នកប្រាថ្នាធ្វើភិក្ខុនិម្មិតឲ្យមានច្រើនដោយប្រការដទៃៗទៀត ( ដូចខ្ពស់ ទាប ស្គម ធាត់ ) ក្តី លោកអ្នកមានឫទ្ធិនោះចេញចាកឈានដែលជាបាទហើយ គប្បីធ្វើបរិកម្មដោយន័យថា ភិក្ខុចំនួនប៉ុណ្ណោះ ចូរមានវ័យជាបឋមវ័យ ដូច្នេះជាដើមហើយចូលឈានទៀត ចេញហើយទើបអធិដ្ឋាន ភិក្ខុនិម្មិតទាំងនោះក៏នឹងប្រាកដដូចដែលលោកអ្នកមានឫទ្ធិប្រាថ្នាគ្រប់ប្រការ ទន្ទឹមនឹងចិត្តអធិដ្ឋាននោះឯង ។

ក្នុងប្រការថាជាមនុស្សច្រើនហើយ ត្រឡប់ជាមនុស្សម្នាក់ក៏បានជាដើម ក៏មានន័យដូច្នេះ តពីនេះជាសេចក្តីប្លែកគ្នាគឺ :

## ឯកភាវាធិដ្ឋានិយ

### “ ធ្វើមនុស្សច្រើន ឲ្យជាមនុស្សម្នាក់ ”

ឯភិក្ខុអ្នកមានឫទ្ធិនេះ កាលនិម្មិតខ្លួនឲ្យជាមនុស្សច្រើនយ៉ាងនោះហើយ គិតថា យើងនឹងត្រឡប់ជាមនុស្សម្នាក់ទៀត ហើយចង្ក្រម ធ្វើការស្វាធ្យាយ សួរបញ្ហាចុះ ឬគិតដោយការប្រាថ្នាតិចថា វិហារនេះតាមប្រក្រតីមានភិក្ខុតិច បើអ្នកណាៗមក ឃើញភិក្ខុច្រើន ក៏នឹងនឹកថា ភិក្ខុទាំងនេះមានចំនួនដល់ម្លេះ តែមានរូបដូចគ្នាទាំងអស់ នឹងមានបានអំពីណា ទុំះជាអានុភាពរបស់ព្រះថេរៈជាពិតប្រាកដ ហើយក៏ដឹងយើងថា ជាអ្នកមានឫទ្ធិដូច្នេះក្តី ហើយប្រាថ្នាថា យើងចូរត្រឡប់ជាមនុស្សម្នាក់ក្នុងរវាងនៃកាលកំណត់ទុកចុះ ក៏គប្បីចូលឈានដែលជាបាទ ចេញហើយធ្វើ

បរិកម្មទៅថា យើងចូរជាមនុស្សម្នាក់ ហើយចូលទៀត ចេញហើយទើបអធិដ្ឋានថា យើងចូរជាមនុស្សម្នាក់ ទន្ទឹមនឹងចិត្តអធិដ្ឋាននោះឯង លោកក៏នឹងត្រឡប់ជាមនុស្សម្នាក់ តែសូម្បីកាលមិនធ្វើយ៉ាងនោះ ក៏គង់ជាមនុស្សម្នាក់បានខ្លួនឯង ដោយអំណាចការដែលកំណត់ទុកនោះឯង ។

## អាវិភាវបាដិហារិយ តិរោភាវបាដិហារិយ

ក្នុងបទថា **អាវិភាវំ តិរោភាវំ** នោះ គប្បីជ្រាបសេចក្តីដូចនេះ គឺ **អាវិភាវំ ករោតិ តិរោភាវំ ករោតិ** ធ្វើអាវិភាវៈ ធ្វើតិរោភាវៈ ពិតហើយ ព្រះសារីបុត្រសំដៅយកការធ្វើអាវិភាវៈ និងតិរោភាវៈហ្នឹងឯង ពោលទុកក្នុងបដិសម្ភិទាថា បទថា **អាវិភាវំ** មានសេចក្តីថា ធ្វើឲ្យជាវត្ថុដែលអ្វីៗ មិនបានការពារទុក ជាវត្ថុមិនកំបាំង ជាវត្ថុបើកបង្ហាញប្រាកដ , បទថា **តិរោភាវំ** មានសេចក្តីថា ធ្វើឲ្យជាវត្ថុត្រូវការពារទុក ជាវត្ថុត្រូវបិទបាំង ជាវត្ថុត្រូវបិទទុក ជាវត្ថុត្រូវគ្របទុក ដូច្នេះ ។

## អាវិភាវបាដិហារិយ

### " ធ្វើវត្ថុកំបាំងឲ្យឃើញច្បាស់ "

ក្នុងបាដិហារិយ៍ ២ យ៉ាងនោះ ភិក្ខុអ្នកមានឫទ្ធិនេះ ប្រាថ្នានឹងធ្វើអាវិភាវ-បាដិហារិយ៍ រមែងធ្វើទីងងឹតឲ្យភ្លឺខ្លះ ធ្វើទីកំបាំងឲ្យឃើញខ្លះ ធ្វើវត្ថុដែលមិនមាននៅក្នុងក្រសែចក្ខុ ឲ្យនៅក្នុងក្រសែចក្ខុខ្លះ ធ្វើដូចម្តេច ? ក៏ភិក្ខុនេះប្រាថ្នានឹងធ្វើខ្លួន ឬមនុស្សដទៃក៏ដោយ ឲ្យជាទីដែលត្រូវវត្ថុដទៃបិទបាំង ឬសូម្បីនៅក្នុងទីឆ្ងាយក៏មើលឃើញបាន ចេញចាកឈានដែលជាបាទហើយ ក៏នឹកបរិកម្មទៅថា ទីងងឹតនេះចូរភ្លឺស្វាង ឬថា ទីកំបាំងនេះ ចូរជាទីមិនកំបាំង ឬថា វត្ថុដែលមិនមាននៅក្នុងក្រសែ

ចក្ខុនេះ ចូរជាវត្ថុដែលនៅក្នុងក្រសែចក្ខុ ហើយអធិដ្ឋានតាមន័យដូចពោលមកហើយ នោះឯង ទន្ទឹមនឹងចិត្តអធិដ្ឋាន វាក៏នឹងប្រាកដតាមដែលអធិដ្ឋានតែម្តង មនុស្សដទៃៗ សូម្បីនៅទីឆ្ងាយក៏មើលមកឃើញខ្លួន ចំណែកខ្លួនចង់ឃើញគេខ្លះ ក៏មើលឃើញ ។

សួរថា អាវិភាវបាដិហារិយ៍នេះអ្នកណាធ្លាប់ធ្វើ ? ឆ្លើយថា ព្រះមានព្រះភាគ ពិតហើយ ព្រះមានព្រះភាគ( ប្រថាប់នៅក្នុងក្រុងសាវត្ថី ) នាងចូឡសុភទ្ទា( នៅក្នុងក្រុងសាកេត ) ក្រាបទូលនិមន្តព្រមដោយភិក្ខុ ៥០០ កាលស្តេចចេញចាក ក្រុងសាវត្ថី ឆ្ពោះទៅក្រុងសាកេត ដែលមានរយៈផ្លូវ ៧ យោជន៍ តាមផ្លូវអាកាស ដោយផ្ទះកំពូល ៥០០ ខ្នង ដែលវិស្សុកម្មទេវបុត្តនិម្មិតថ្វាយ គ្រានោះ ទ្រង់បានអធិដ្ឋាន ឲ្យអ្នកក្រុងសាកេតមើលពួកអ្នកក្រុងសាវត្ថីបាន និង ពួកអ្នកក្រុងសាវត្ថីក៏មើល ឃើញពួកអ្នកក្រុងសាកេតបាន ស្តេចចុះចាកអាកាសត្រង់កណ្តាលក្រុងតែម្តង ហើយទ្រង់សម្តែងបើកផែនដីឲ្យឃើញចុះទៅ រហូតដល់អវិចី និងទ្រង់បើកអាកាស ឲ្យឃើញឡើងទៅ រហូតដល់ព្រហ្មលោក ។

ម្យ៉ាងទៀត ប្រការនេះ បណ្ឌិតគួរសម្តែងឲ្យជាក់ច្បាស់ដោយរឿង ទេវោ-រោហណៈ ទៀតក៏បាន បានឮមកថា ព្រះមានព្រះភាគទ្រង់ធ្វើយមកប្បាដិហារិយ៍ ដោះលែងសត្វប្រមាណ ៨៤.០០០ ចេញអំពីចំណង គឺ មិច្ឆាទិដ្ឋិ ហើយទ្រង់ត្រិះរិះ ថា ព្រះអតីតពុទ្ធទាំងឡាយ ស្តេចទៅទីណា ក៏ទ្រង់ឃើញថា ស្តេចទៅកាន់ស្ថាន តាវត្តិង្ស ដូចគ្នាដូច្នោះ ទើបទ្រង់ជាន់ផែនប្រឹថពីដោយព្រះបាទម្ខាង ដាក់ព្រះបាទ ខាងទីពីរចុះលើភ្នំយុគន្ធរ ហើយព្រះបាទដំបូងជាន់លើកំពូលភ្នំសិនេរុម្តងទៀត ទ្រង់ ចាំវស្សា ត្រង់ផ្ទៃព្រះទែនសិលាបណ្ឌុកម្ពល ( របស់ព្រះឥន្ទ្រ ) ត្រង់កំពូលភ្នំ សិនេរុ ( គឺ តាវត្តិង្ស ) នោះ ទ្រង់ផ្តើមសម្តែងអភិធម្មកថាតាំងអំពីដើមវស្សាទៅ

ដល់ទេវតា ក្នុងសែនចក្រវាឡដែលមកប្រជុំគ្នា ក្នុងពេលភិក្ខាចារ ទ្រង់និម្មិតព្រះពុទ្ធនិមិត្តឡើង ព្រះពុទ្ធនិម្មិតនោះសម្តែងធម៌ជំនួស ព្រះមានព្រះភាគទ្រង់ទំពាឈើស្ទន់ជំរះធ្មេញនាគលតា ( វល្លិ៍ពស់ ឬវល្លិ៍ម្ជូ ) ហើយស្តេចចុះទៅជំរះព្រះឱស្ឋត្រង់ស្រះអនោតត្តៈ ទ្រង់ទទួលបិណ្ឌបាតពីពួកជនឧត្តរកុរុទ្វីបហើយ ស្តេចត្រឡប់មកសោយ ត្រង់ស្រះអនោតត្តៈ ព្រះសារីបុត្តត្ថេរទៅថ្វាយបង្គំព្រះសម្ពុទ្ធនៅទីនោះរាល់ៗថ្ងៃ ព្រះមានព្រះភាគប្រោសប្រទានន័យដល់ព្រះថេរៈថា ថ្ងៃនេះតថាគតសម្តែងធម៌ប៉ុណ្ណេះ ព្រះអង្គត្រាស់ព្រះអភិធម្មកថាមិនឈប់ឡើយ រហូត ៣ ខែដោយប្រការ ព្រោះបានស្តាប់អភិធម្មកថានោះ ធម្មាភិសម័យបានកើតដល់ទេវតា ៨០ កោដិ ។

ទាំងពួកមនុស្សដែលប្រជុំគ្នានៅក្នុងក្រុងប្រមាណ ១២ យោជន៍ដែលជួបជុំគ្នាកាលថ្ងៃទ្រង់សម្តែងយមកប្បាដិហារិយ៍ គិតគ្នាថា ពួកយើងទាល់តែបានគាល់ព្រះអង្គហើយ ទើបនឹងត្រឡប់ទៅ ដូច្នេះ ទើបសាងជម្រកស្នាក់ចាំ , ចូឡអនាថ-បិណ្ឌិកសេដ្ឋីតែឯង ជួយឧបត្ថម្ភដល់អ្នកក្រុងទាំងនោះ ដោយបច្ច័យទាំងពួង ។

មនុស្សទាំងឡាយអង្វរព្រះអនុរុទ្ធត្ថេរ ដើម្បីធ្វើយ៉ាងណាឲ្យបានជ្រាបថា ព្រះមានព្រះភាគប្រថាប់នៅទីណា ព្រះថេរៈក៏ចម្រើនអាលោកកសិណ បានឃើញព្រះមានព្រះភាគទ្រង់ចូលវស្សានៅពិភពតាវត្តិង្សនោះដោយទិព្វចក្ខុ កាលឃើញហើយទើបប្រាប់មនុស្សទាំងឡាយនោះឲ្យជ្រាប ហើយពួកជនទាំងឡាយអង្វរព្រះមហាមោគ្គល្លាន ដើម្បីធ្វើយ៉ាងណាឲ្យពួកគេបានថ្វាយបង្គំព្រះមានព្រះភាគ ព្រះថេរៈក៏មុជចុះទៅក្នុងមហាប្រឹថពីត្រង់កណ្តាលពួកមនុស្សនោះឯង ហើយទៅជ្រែកភ្នំសិនេរុថ្វាយបង្គំព្រះយុគលបាទព្រះមានព្រះភាគ ផុសឡើងទៀបបាទមូលរបស់ព្រះតថាគត

តែម្តង ក្រាបទូលព្រះលោកនាថថា បពិត្រព្រះអង្គដ៏ចម្រើន ពួកអ្នកជម្ពូទ្វីបថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមានជោគ មកនិយាយគ្នាថា យើងទាំងឡាយទាល់តែបានឃើញព្រះអង្គសិន ទើបត្រឡប់ទៅ ព្រះមានព្រះភាគសួរថា ម្នាលមោគ្គល្លានឥឡូវនេះ ធម្មសេនាបតី បងប្រុសអ្នកនៅទីណា ក្រាបទូលថា នៅនគរសង្កស្សព្រះពុទ្ធជាម្ចាស់ទើបទ្រង់ត្រាស់ថា ម្នាលមោគ្គល្លានពួកជនណា ចង់ឃើញតថាគតពួកជននោះ ចូរទៅកាន់នគរសង្កស្សៈចុះ ក្នុងថ្ងៃព្រឹកស្អែកនេះ តថាគតនឹងចុះនៅត្រង់នគរសង្កស្សៈ ដែលជាថ្ងៃមហាបវារណា និងជាថ្ងៃឧបោសថ ព្រះថេរៈទទួលព្រះតម្រាស់ថ្វាយបង្គំព្រះទសពលហើយ ត្រឡប់ចុះមក តាមផ្លូវដែលមកនោះឯង លោកអធិដ្ឋានឲ្យមនុស្សទាំងឡាយឃើញលោកបាន ទាំងពេលទៅ និងទាំងពេលមក រហូតដល់ទីលំនៅរបស់មនុស្សទាំងឡាយ ព្រះមហាមោគ្គល្លានបានធ្វើអាវិការបាដិហារិយ៍នេះក្នុងពេលនោះ លោកបានដល់យ៉ាងនោះហើយ ទើបប្រាប់ដំណឹងនោះឲ្យជ្រាបគ្រប់គ្នា រួចពោលបញ្ជាក់ថា អ្នកទាំងឡាយកុំនាំគ្នាសម្គាល់ថាឆ្ងាយ កាលទទួលទានអាហារព្រឹកហើយ ចូរចេញដំណើរទៅចុះ ។

ព្រះមានព្រះភាគទ្រង់ពោលលាសក្កទេវរាជថា ម្នាលមហារាជ ថ្ងៃស្អែកនេះតថាគតនឹងត្រឡប់ទៅកាន់ស្ថានមនុស្សវិញ ទើបសក្កទេវរាជត្រាស់បញ្ជាវិស្សុកម្មទេវបុត្រថា នៃវិស្សុកម្មទេវបុត្រ ព្រះជិនស្រី មានបំណងស្តេចយាងទៅកាន់ស្ថានមនុស្សលោកវិញក្នុងថ្ងៃស្អែកនេះ អ្នកចូរនិម្មិតជណ្តើរឡើង ៣ ជួរ ជណ្តើរមួយសម្រេចដោយមាស ជណ្តើរមួយសម្រេចដោយប្រាក់ ជណ្តើរមួយសម្រេចដោយកែវ វិស្សុកម្មទេវបុត្រធ្វើតាមទេវបញ្ជា ។

លុះព្រឹកស្អែក ព្រះជិនស្រីប្រថាប់ឈរលើកំពូលភ្នំសិនេរុទតព្រះនេត្រមើល

លោកធាតុ ផ្នែកខាងកើតចក្រវាឡ ច្រើនសែនក៏បើកស្រឡះ ហាក់ដូចទីតែមួយ និងទតព្រះនេត្រឃើញវត្ថុដែលមិនកំបាំងគ្រប់វត្ថុក្នុងទិសខាងកើតយ៉ាងណា សូម្បី ទិសខាងលិច ទិសជើង ទិសខាងត្បូង ក៏ទតព្រះនេត្រឃើញវត្ថុ មិនកំបាំង សព្វ គ្រប់វត្ថុដូច្នោះ ខាងក្រោមសោតក៏ទតព្រះនេត្រឃើញរហូតដល់អវិចី ខាងលើដល់ អកនិដ្ឋកភព អាចហៅបានថា ថ្ងៃនោះ ឈ្មោះថា លោកវិវរណៈ( ថ្ងៃបើកលោក ) ខាងមនុស្សក៏ឃើញទេវតា ទេវតាសោតក៏ឃើញមនុស្ស ក្នុងការឃើញគ្នានោះ មិន មែនមនុស្សងើយមើល មិនមែនទេវតាឱនមើល គ្រប់គ្នាឃើញគ្នា និងគ្នាចំពោះមុខ តែម្តង ។

ព្រះមានព្រះភាគ ស្តេចយាងចុះមកតាមជណ្តើរកែវត្រង់កណ្តាល ដោយ ទេវតាកាមាវចរទាំង ៦ ជាន់ចុះខាងជណ្តើរមាសខាងឆ្វេង ពួកសុទ្ធាវាស និងមហា ព្រហ្មចុះតាមជណ្តើរប្រាក់ខាងស្តាំ សក្កទេវរាជទ្រង់កាន់បាត្រ និងចីវរ មហាព្រហ្ម កាន់ឆត្រសដែលមានបរិមណ្ឌលប្រមាណ ៣ យោជន៍ ស្តេចសុយាមកាន់វាលវិជនី បញ្ចសិខៈបុត្រគន្ធព្វកាន់ពិណពណ៌លឿងដូចផ្លែក្នោទំ ប្រវែងប្រមាណ ៣ គាវុត ធ្វើការបូជាចំពោះព្រះតថាគត ដោយសំឡេងពិណនោះចុះមក ឈ្មោះថា សត្វអ្នក បានឃើញព្រះមានព្រះភាគក្នុងថ្ងៃនោះហើយ មិនញុំាងសេចក្តីរីករាយចំពោះភាពជា ព្រះពុទ្ធឲ្យកើតឡើង ព្រងើយៗ មិនមានឡើយ ព្រះមានព្រះភាគទ្រង់បានធ្វើ អាវិការវបាដិហារិយ៍នេះក្នុងពេលនេះ ( ពេលដំបូងព្រះមហាមោគ្គល្លានធ្វើដូចពោល ហើយ ) ។

រឿងមួយទៀត មានព្រះថេរៈមួយអង្គឈ្មោះ **ធម្មទិន្ន** ជាអ្នកក្រុងតឡង្គរ ក្នុងតម្ពបណ្ណិទ្វីប គង់នៅក្នុងលានព្រះចេតិយ ក្នុងតិស្សមហាវិហារពោលសម្តែង

អបណ្ណកសូត្រ ដោយបាទថា **តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អបណ្ណកបដិបទំ បដិបន្នោ ហោតិ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៣ ប្រការ ឈ្មោះថា ជាអ្នកបដិបត្តិអបណ្ណកបដិបទា ( ការបដិបត្តិមិនខុស ) ដូច្នេះជាដើម រំពេចនោះផ្កាប់ផ្ងិតចុះ ស្រោប់តែតាំងអំពីអវិចីឡើងមក ក៏ប្រាកដនូវវាលល្ហល្ហេវ ដូចជាទីលានតែមួយ រួចផ្ងារផ្ងិតឡើង តាំងពីព្រហ្មលោកចុះមក ក៏ប្រាកដនូវវាលល្ហល្ហេវ ដូចជាទីលានតែមួយ ព្រះថេរៈសម្ដែងធម៌ដោយការគម្រាមដោយភ័យក្នុងនរក និងប្រលោមដោយសុខក្នុងស្ថានសួគ៌ ធ្វើឲ្យអ្នកស្ដាប់ពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាសកទាគាមី... ព្រះអនាគាមី... ព្រះអរហន្ត ដូច្នេះ ។

## តិរោភាវបាដិហារិយ

### “ ធ្វើវត្ថុប្រាកដឲ្យកំបាំង ”

ចំណែកភិក្ខុអ្នកប្រាថ្នាធ្វើតិរោភាវបាដិហារិយ៍ រមែងធ្វើទីភ្លឺស្វាងឲ្យងងឹតខ្លះ ធ្វើវត្ថុដែលមិនកំបាំងឲ្យជាវត្ថុកំបាំងខ្លះ ធ្វើវត្ថុដែលនៅក្នុងក្រសែចក្ខុឲ្យជាវត្ថុមិននៅក្នុងក្រសែចក្ខុខ្លះ ធ្វើដូចម្ដេច ភិក្ខុអ្នកមានឫទ្ធិនេះប្រាថ្នានឹងធ្វើខ្លួន ឬអ្នកដទៃក៏ដោយ ឲ្យដូចជាមិនមានអ្វីបិទបាំងឡើយ ឬសូម្បីឈរនៅជិតៗ ក៏មើលមិនឃើញ ចេញចាកឈានដែលជាបាទហើយ ក៏នឹកបរិកម្មថា កន្លែងភ្លឺនេះក្លាយជាទីងងឹតទៅ ឬថាទីមិនកំបាំងនេះ ចូរជាទីកំបាំងទៅ ឬវត្ថុដែលនៅក្នុងក្រសែចក្ខុនេះ ចូរជាវត្ថុដែលមិននៅក្នុងក្រសែចក្ខុទៅ ហើយអធិដ្ឋានដោយន័យដែលពោលនោះឯង ទន្ទឹមគ្នានឹងចិត្តអធិដ្ឋាន វត្ថុនោះក៏សម្រេចតាមការអធិដ្ឋានភ្លាម មនុស្សដទៃៗ សូម្បីឈរនៅជិតៗ

ខ្លួន ក៏មិនឃើញខ្លួន ចំណែកខ្លួនចង់មិនឃើញគេខ្លះ ក៏មិនឃើញបានដូចគ្នា ។

សួរថា តិរោភាវបាដិហារិយ៍នោះ អ្នកណាធ្លាប់ធ្វើ ? ឆ្លើយថា ព្រះតថាគត ពិតហើយ ព្រះមានព្រះភាគបានធ្វើយសកុលបុត្រ ដែលអង្គុយនៅជិតៗ នោះឯង មិនឲ្យបិតារបស់លោកមើលឃើញលោកបាន ។

ដូចគ្នានោះដែរ ព្រះមានព្រះភាគ ទ្រង់យាងទៅដើម្បីទទួលព្រះបាទមហាកបិន ចម្ងាយផ្លូវ ១២០ យោជន៍ ប្រោសឲ្យស្ដេចតាំងនៅក្នុងអនាគាមិផល និង អមាត្យ ១.០០០ នាក់ របស់ព្រះអង្គឲ្យតាំងនៅក្នុងសោតាបត្តិផលហើយ ទ្រង់ធ្វើ ព្រះនាងអនោជា ព្រមទាំងស្រីបរិវារ ១.០០០ នាក់ ដែលតាមមក តាមផ្លូវរបស់ ព្រះមហាកបិននោះ មកដល់ហើយប្រថាប់នៅជិតៗ ក៏មិនទតឃើញព្រះរាជា និង រាជបរិស័ទ កាលព្រះនាងទូលសួរថា ព្រះអង្គទ្រង់ឃើញព្រះរាជាដែរឬទេ ទ្រង់ត្រាស់ថា ព្រះនាងទ្រង់រកព្រះរាជាល្អជាង ឬថា ទ្រង់រកព្រះអង្គឯងល្អជាង ព្រះនាងទូលថា រកខ្លួនឯងល្អជាង ព្រះអង្គ ហើយប្រថាប់គង់ចុះ ទើបទ្រង់សម្ដែងធម៌ រហូតដល់( ចប់ព្រះធម្មទេសនា ) ព្រះនាង ព្រមទាំងស្រីបរិវារ ១.០០០ នាក់ តាំងនៅក្នុងសោតាបត្តិផល ពួកអមាត្យតាំងនៅក្នុងអនាគាមិផល ព្រះរាជាទ្រង់តាំងនៅក្នុងអរហត្តផល ។

រឿងមួយទៀត សូម្បីព្រះមហិន្ទត្ថេរ បានធ្វើឲ្យព្រះរាជាមិនអាចទតឃើញ ជនដ៏សេស ដែលមកជាមួយនឹងខ្លួន ក្នុងថ្ងៃដែលមកដល់តម្ពបណ្ណិទ្វីប ក៏ឈ្មោះថា បានធ្វើតិរោភាវបាដិហារិយ៍នេះដូចគ្នា ។

## អធិប្បាយ
## បាដិហារិយ៍ទាំងពីរក្នុងន័យតែមួយ

ន័យម្យ៉ាងទៀត **បាកដបាដិហារិយ** ( បាដិហារិយ៍ដែលប្រាកដខ្លួនអ្នកមានឫទ្ធិ )គ្រប់យ៉ាង ឈ្មោះថា **អាវិភាវបាដិហារិយ** , **អបាកដបាដិហារិយ** ( បាដិហារិយ៍ដែលមិនប្រាកដខ្លួនអ្នកមានឫទ្ធិ ) ឈ្មោះថា **តិរោភាវបាដិហារិយ** ក្នុងបាដិហារិយ៍ពីរយ៉ាងនោះ **បាកដបាដិហារិយ៍** ប្រាកដទាំងឫទ្ធិ ទាំងអ្នកមានឫទ្ធិ បាកដបាដិហារិយ៍នោះ គប្បីបង្ហាញឲ្យឃើញបានដោយយមកប្បាដិហារិយ៍ ពិតមែន ក្នុងយមកប្បាដិហារិយ៍នោះ ប្រាកដទាំងពីរយ៉ាងដូចគ្នាយ៉ាងនេះ ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារិយ៍ក្នុងកាលនេះ មិនទូទៅដល់សាវ័កទាំងឡាយ ( សាវ័កធ្វើមិនបាននេះអង្គមានឫទ្ធិប្រាកដ ) ទភ្លើងចេញអំពីព្រះវរកាយផ្នែកខាងលើ ទទឹកចេញអំពីព្រះវរកាយផ្នែកខាងក្រោម... នេះជាឫទ្ធិប្រាកដ ។

ក្នុងអបាកដបាដិហារិយ៍ ប្រាកដតែឫទ្ធិ អ្នកមានឫទ្ធិមិនប្រាកដទេ អបាកដបាដិហារិយ៍នោះ គប្បីចង្អុលបង្ហាញដោយមហាកសូត្រ និងព្រហ្មនិមន្តនិកសូត្រ ពិតមែន ក្នុងបាដិហារិយ៍ដែលពោលក្នុងព្រះសូត្រទាំងពីរនោះ ប្រាកដតែឫទ្ធិនៃព្រះមហាកៈ និងរបស់ព្រះមានព្រះភាគប៉ុណ្ណោះ នាគមានឫទ្ធិ គឺព្រះមហាកៈ និងអង្គព្រះមានព្រះភាគមិនប្រាកដទេ ដូចលោកពោលទុកក្នុងមហាកសូត្រថា ចិត្តគហបតីអ្នកគង់នៅក្នុងទីសមគួរម្ខាងហើយ បានពោលពាក្យនេះនឹងព្រះមហាកៈថា សាធុ សូមព្រះគុណម្ចាស់មហាកៈបានសម្តែងឫទ្ធិបាដិហារិយ៍ ដែលជាឧត្តរិមនុស្សធម៌ដល់ខ្ញុំម្ចាស់ផងចុះ ព្រះមហាកៈពោលថា គហបតី បើដូច្នោះ អ្នកចូរក្រាលសំពត់ឧត្តរាសង្គៈត្រង់របៀង ប្រមូលកំទេចស្មៅស្ងួតដាក់ចុះលើសំពត់នោះ ចិត្តគហបតីទទួល

ពាក្យព្រះមហាកៈហើយ ក្រាលសំពត់ឧត្តរាសង្គៈចុះត្រង់របៀងហើយ រោយបាច់ស្មៅចុះ ហើយព្រះមហាកៈទើបចូលទៅវិហារមិនឲ្យឃើញខ្លួន ក៏តាំងឫទ្ធាភិសង្ខារប្រភេទដែលមានអណ្តាតភ្លើងចេញតាមប្រហោងនុកទ្វារ និងប្រហោងសន្ទះទ្វារ ហើយឆេះតែស្មៅ មិនឆេះសំពត់ឧត្តរាសង្គៈ ។

សូត្រមួយទៀតថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតសម្តែងឫទ្ធាភិសង្ខារឲ្យ ពកព្រហ្ម ព្រហ្មបរិវារ និងព្រហ្មបារិសជ្ជា បានឮតែសំឡេងរបស់តថាគត មិនឃើញខ្លួនតថាគតដោយកាលកំណត់ត្រឹមប៉ុណ្ណោះ ដូច្នេះហើយ ទ្រង់បាត់ព្រះអង្គ ត្រាស់គាថានេះថា :

ភវេ វាហំ ភយំ ទិស្វា ភវញ្ច វិភវេសិនំ
ភវំ នាភិវទិំ កិញ្ចិ នន្ទិញ្ច ន ឧបាទិយឹ

តថាគតឃើញភ័យក្នុងភព និងឃើញភពនេះឯង ដែលបែរមុខទៅរកវិភព គឺការសាបសូន្យទៅនោះឯង ទើបមិនលើកតម្កើងនូវភពត្រឹមតែបន្តិច( **អភវទ** ) និងមិនប្រកាន់ដោយនន្ទិ គឺ ភវតណ្ហាឡើយ ។

## តិរោកុឌ្ឌាទិគមនបាដិហារិយ

“ ចូលវត្ថុរាំងមានជញ្ជាំងជាដើមទៅបាន ”

គប្បីជ្រាបវិនិច្ឆ័យក្នុងបាដិហារិយ៍ប្រការថា **តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ** ទៅខាងក្រៅជញ្ជាំង ក្រៅកំផែង ក្រៅភ្នំបានមិនជាប់ ដូចទៅក្នុងអាកាសក៏បាន នេះ ដូចតទៅនេះ :

បទថា **តិរោកុឌ្ឌំ** ប្រែថា ក្រៅជញ្ជាំង អធិប្បាយថា ផ្នែកខាងក្រៅនៃជញ្ជាំង

ក្នុងបទក្រៅពីនេះក៏មានន័យដូច្នេះ និងពាក្យថា **កុដ្ឌ** នោះ ជាពាក្យហៅ ជញ្ជាំងផ្ទះ ។

ពាក្យថា **បាការ** សំដៅយកកំផែងពទ្ធជុំវិញស្ថានទី មានផ្ទះ វិហារ និងស្រុកជាដើម , ពាក្យថា **បព្វត** បានដល់ ភ្នំដី ឬភ្នំថ្មក៏បាន បទថា **អសជ្ជមានោ** ប្រែថា មិនជាប់ , ពាក្យថា **សេយ្យថាបិ អាកាសេ** ប្រែថា ដូចទៅក្នុងអាកាស ។

ឯភិក្ខុអ្នកមានឫទ្ធិប្រាថ្នានឹងទៅយ៉ាងនោះ ចូលអាកាសកសិណ ចេញហើយនឹកដល់ជញ្ជាំង ឬកំផែង ឬភ្នំ សូម្បីក្នុងភ្នំសិនេរុ និងចក្រវាឡណាមួយក៏ដោយ ដែលខ្លួនត្រូវការនឹងឆ្លងទៅ ធ្វើបរិកម្មទៅ អធិដ្ឋានថា ចូរជាអាកាសៗ វាក៏ជាអាកាសទៅមួយរំពេច សម្រាប់អ្នកប្រាថ្នាចុះទៅខាងក្រោម ឬអ្នកប្រាថ្នានឹងឡើងទៅខាងលើ វាក៏ជាប្រហោងឲ្យ សម្រាប់អ្នកប្រាថ្នានឹងទម្លុះចូលទៅត្រង់ៗ វាក៏ជាប្រហោងរន្ធឲ្យ លោកក៏ទៅក្នុងប្រហោង ឬរន្ធនោះបានមិនទើសទាក់ ។

ចំណែកព្រះតិបិដកចូឡាភយត្ថេរ ពោលជំទាស់ក្នុងការធ្វើបាដិហារិយ៍នេះថា ម្នាលអាវុសោទាំងឡាយ ការចូលអាកាសកសិណមានប្រយោជន៍អ្វី ? អ្នកមានឫទ្ធិប្រាថ្នានឹងនិម្មិតរូបផ្សេងៗ មានដំរី និងសេះជាដើម ក៏នឹងត្រូវចូលកសិណសត្វមានកសិណដំរី កសិណសេះជាដើមផង ឬភាពជាអ្នកស្ទាត់ជំនាញក្នុងសមាបត្តិ ៨ ព្រោះធ្វើបរិកម្មក្នុងកសិណណាមួយនោះឯង ជាប្រមាណ អ្នកស្ទាត់ជំនាញក្នុងសមាបត្តិ ៨ ប្រាថ្នាឲ្យជាវត្ថុណាៗ វាក៏រមែងជាវត្ថុនោះៗ ឯងហើយ មិនមែនឬ ? ភិក្ខុទាំងឡាយពោលសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន អាកាសកសិណនោះឯងមកក្នុងព្រះបាលី ព្រោះហេតុនោះ ការចូលអាកាសកសិណ ( ក្នុងការធ្វើតិរោ-កុឌ្ឌាទិគមនបាដិហារិយ៍ )នោះ គួរពោលបានដោយពិត នេះបាលីក្នុងប្រការនោះគឺ :

ភិក្ខុអ្នកមានឫទ្ធិ ជាអ្នកបានអាកាសកសិណសមាបត្តិ នៅដោយប្រក្រតី

អាវជ្ជនាការដល់ទីខាងក្រៅជញ្ជាំង ខាងក្រៅកំផែង ខាងក្រៅភ្នំ បន្ទាប់មកអធិដ្ឋាន ដោយញាណថា ជញ្ជាំង កំផែងភ្នំ ចូរជាអាកាស វាក៏ជាអាកាសទៅ លោកក៏ទៅក្រៅជញ្ជាំង ក្រៅកំផែង ក្រៅភ្នំបានមិនទើស មនុស្សទាំងឡាយអ្នកមិនមានឫទ្ធិនៅដោយប្រក្រតី រមែងទៅក្នុងទីដែលមិនមានអ្វីរាំង មិនមានអ្វីព័ទ្ធជុំវិញបាន មិនទើសទាក់ យ៉ាងណា ភិក្ខុអ្នកមានឫទ្ធិ បានចេតោវសីនោះ ក៏ដូច្នោះដូចគ្នា រមែងទៅក្រៅជញ្ជាំង ក្រៅកំផែង ក្រៅភ្នំមិនទើស ដូចទៅក្នុងអាកាសក៏បាន ដូច្នោះ ។

សួរថា បើភិក្ខុនោះអធិដ្ឋានហើយ កំពុងទៅយ៉ាងនោះ ភ្នំ ឬ ដើមឈើក៏ដោយផុសឡើងរាំងក្នុងចន្លោះផ្លូវ លោកត្រូវចូលសមាបត្តិហើយអធិដ្ឋានទៀតឬ ? ឆ្លើយថា ទោសក្នុងការចូលសមាបត្តិហើយ អធិដ្ឋានទៀតនោះ មិនមាន ព្រោះថាការចូលសមាបត្តិហើយអធិដ្ឋានទៀត ក៏ដូចគ្នានឹងការកាន់យកនិស្ស័យក្នុងសម្នាក់ព្រះឧបជ្ឈាយ៍ បើមានភ្នំជាដើមផុសឡើងរាំងពិតៗ ព្រោះភិក្ខុនេះអធិដ្ឋានថា ចូរជាអាកាសៗ វាក៏គង់ជាអាកាសទៀតនោះឯង ឯការដែលថា ភ្នំ ឬ ដើមឈើដទៃនឹងកើតដោយរដូវផុសឡើង រាំងក្នុងវវាងផ្លូវ ដោយកម្លាំងនៃការអធិដ្ឋានគ្រាដំបូងរបស់លោកនោះឯង ទុំះមិនមែនឋានៈ គឺ ប្រព្រឹត្តទៅមិនបាន ក្នុងករណីដែលវត្ថុផុសឡើងក្នុងវវាងនោះ បើជាវត្ថុដែលអ្នកមានឫទ្ធិដទៃនិម្មិតឡើង ការនិម្មិតមុនរមែងមានកម្លាំងជាង វត្ថុដែលនិម្មិតតាមក្រោយ ត្រូវគេចទៅខាងលើ ឬខាងក្រោមវត្ថុដែលនិម្មិតមុននោះ ។

## បឋវីឧម្មុជ្ជនិម្មុជ្ជចាដិហារិយ

## “ ផុសឡើង និងមុជចុះក្នុងផែនដីក៏បាន ”

ក្នុងបាដិហារិយ៍ប្រការថា **បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ** ផុសឡើង និងមុជចុះក្នុងផែនដីក៏បាននេះ មានអធិប្បាយថា ការផុសឡើងហៅថា **ឧម្មុជ្ជ** , ការមុជចុះទៅហៅថា **និម្មុជ្ជ** , ទាំង **ឧម្មុជ្ជ** និងនិម្មុជ្ជ ហៅថា **ឧម្មុជ្ជនិម្មុជ្ជ** ឯភិក្ខុអ្នកប្រាថ្នាធ្វើយ៉ាងនោះ គប្បីចូលអាបោកសិណ ចេញហើយ ធ្វើបរិកម្មដោយកំណត់កាត់ផ្តាច់ផ្ទៃផែនដីថា ផែនដីក្នុងផ្ទៃប៉ុណ្ណេះ ចូរជាទឹក ហើយអធិដ្ឋានដោយន័យដូចពោលមក ហើយនោះឯង ទន្ទឹមនឹងការអធិដ្ឋាន ផែនដីក្នុងផ្ទៃប៉ុនដែលកំណត់កាត់ផ្តាច់ ក៏ជាទឹកតែម្តង លោកក៏ធ្វើការផុស និងមុជចុះក្នុងផែនដីត្រង់នោះបាន បាលីក្នុងប្រការនោះ គឺ :

ភិក្ខុអ្នកមានឫទ្ធិ ជាអ្នកបានអាបោកសិណសមាបត្តិតាមប្រក្រតី លោកអាវជ្ជនាការដល់ផែនដីស្រេចហើយ អធិដ្ឋានដោយញាណថា ផែនដីចូរជាទឹក វាក៏ជាទឹកទៅ លោកក៏ធ្វើការផុសឡើង និងមុជចុះក្នុងផែនដីបាន មនុស្សទាំងឡាយអ្នកមិនមានឫទ្ធិជាប្រក្រតី រមែងធ្វើការផុសឡើង និងការមុជចុះក្នុងទឹកបាន យ៉ាងណា ភិក្ខុអ្នកមានឫទ្ធិបានចេតោវសីនោះ ក៏ដូច្នោះដូចគ្នា រមែងធ្វើការផុសឡើង និងមុចចុះក្នុងផែនដី ដូចផុសឡើង និងមុចចុះក្នុងទឹកដែរ ។

ម្យ៉ាងទៀត មិនមែនតែផុសឡើង និងមុជចុះបានប៉ុណ្ណោះទេ ក្នុងកិច្ចដែលទាក់ទងដោយទឹកទាំងឡាយ ដូចងូត ផឹក លាងមុខ លាងរបស់របរ លោកត្រូវការធ្វើកិច្ចណាៗ ក៏ធ្វើកិច្ចនោះៗបាន , ម្យ៉ាងទៀតសោត មិនមែនត្រឹមអធិដ្ឋានឲ្យជាទឹកបានតែម្យ៉ាងក៏ទេ ក្នុងរបស់រាវទាំងឡាយ ដូចទឹកដោះថ្លា ប្រេង ទឹកឃ្មុំ ទឹកអំពៅ កាលលោកត្រូវការឲ្យជាវត្ថុណាៗ ក៏អាវជ្ជនាការដល់វត្ថុនោះៗ ធ្វើបរិកម្មទៅថា វត្ថុនេះៗ ចូរជាប៉ុណ្ណេះ ហើយអធិដ្ឋាន វាក៏ប្រាកដតាមការអធិដ្ឋានតែម្តង កាល

លោកដួសឡើងមក ធ្វើឲ្យវានៅក្នុងភាជន៍ទឹកដោះថ្លា ក៏ជាទឹកដោះថ្លាពិត វត្ថុដទៃមានប្រេងជាដើម ក៏ជាប្រេងជាដើមដោយពិត ទឹកក៏ជាទឹកដោយពិត ក្នុងទឹកនោះ លោកត្រូវការឲ្យសើមប៉ុណ្ណោះ ទើបសើម មិនត្រូវការឲ្យសើម ក៏មិនសើម ម្យ៉ាងទៀត ផែនដីត្រង់នោះ ជាទឹកសម្រាប់អ្នកមានឫទ្ធិនោះប៉ុណ្ណោះ សម្រាប់មនុស្សក្រៅពីនោះ កន្លែងនោះនៅជាផែនដីដដែល ពួកអ្នកថ្មើរជើងក៏ដើរទៅបាន ទៅដោយពាហនៈ មានយានជាដើមក៏បាន ធ្វើកិច្ចការមានកសិកម្មជាដើមក៏បានដោយពិត តែថា អ្នកមានឫទ្ធិនេះប្រាថ្នាថា ដីត្រង់នោះ ចូរជាទឹកសម្រាប់មនុស្សទាំងឡាយនោះផងចុះ វាក៏ជាទឹកដូចគ្នា វៀរទឹកក្នុងទីខាំងទឹកទាំងឡាយ មានថ្នាំងត្រពាំងជាដើម ដែលមានតាមប្រក្រតី , ហួសកាលដែលកំណត់ទុក កន្លែងដែលអ្នកមានឫទ្ធិកំណត់ពេលទុកនោះ ក៏ទៅជាដីដូចដើម ។

## អភិជ្ជមានេឧទកេគមនបាដិហារិយ

## “ ដើរលើទឹកមិនបែកក៏បាន ”

ក្នុងបាដិហារិយ៍ប្រការថា **ឧទកេបិ អភិជ្ជមានេ** ដើរទៅលើទឹកមិនបែក ក៏បាន មានពណ៌នាថា បុគ្គលជាន់ទឹកណាហើយលិច ទឹកនោះហៅថា **ភិជ្ជមាន**(បែក) ទឹកផ្ទុយគ្នា ហៅថា **អភិជ្ជមាន**( មិនបែក ) ឯភិក្ខុអ្នកប្រាថ្នានឹងដើរទៅលើទឹកដែលមិនបែក យ៉ាងនោះ គប្បីចូលបឋវីកសិណ ចេញហើយធ្វើបរិកម្ម ដោយកំណត់ទឹកថា ទឹកក្នុងទីប៉ុណ្ណេះចូរជាដី ហើយអធិដ្ឋានដោយន័យដូចពោលមកហើយនោះឯង ។ ទន្ទឹមគ្នានឹងការអធិដ្ឋានទឹកក្នុងទីប៉ុនដែលកំណត់ ទៅជាដី លោកក៏ដើរទៅលើទឹកនោះបាន បាលីក្នុងប្រការនោះ គឺ :

ភិក្ខុអ្នកមានឫទ្ធិជាអ្នកបានបឋវីកសិណសមាបត្តិដោយប្រក្រតី លោកអាវជ្ជ-នាការដល់ទឹកស្រេចហើយ អធិដ្ឋានដល់ញាណថា ទឹកចូរជាដី វាក៏ជាដីទៅ លោកក៏ដើរទៅបានលើទឹកមិនបែក មនុស្សទាំងឡាយអ្នកមិនមានឫទ្ធិដោយប្រក្រតី រមែងដើរលើផែនដីមិនបែកបានយ៉ាងណា ភិក្ខុអ្នកមានឫទ្ធិបានចេតោវសីនោះ ក៏ដូច្នោះដូចគ្នា រមែងដើរទៅលើទឹកមិនបែក ដូចដើរទៅលើផែនដីក៏បានដូច្នោះ ។

ម្យ៉ាងទៀត មិនមែនតែដើរបានប៉ុណ្ណោះទេ លោកត្រូវការឥរិយាបថណាៗ ក៏ធ្វើឥរិយាបថនោះៗបាន និងមិនមែនត្រឹមតែ(អធិដ្ឋាន)ឲ្យជាដីបានតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីក្នុងអវិញ្ញាណកវត្ថុទាំងឡាយ ដូចកែវ មាស ភ្នំ និងដើមឈើ លោកត្រូវការវត្ថុណាៗ ក៏អាវជ្ជនាការដល់វត្ថុនោះៗ ហើយអធិដ្ឋានដោយន័យដូចពោលមកហើយនោះ វាក៏ប្រព្រឹត្តតាមការអធិដ្ឋានទាំងនោះ ឯទឹកនោះ ជាដីសម្រាប់អ្នកមានឫទ្ធិនោះប៉ុណ្ណោះ នៅជាទឹកសម្រាប់មនុស្សក្រៅពីនោះ ត្រី អណ្តើក និងសត្វរកស៊ីក្នុងទឹក មានក្អែកទឹកជាដើម គង់ត្រាច់ទៅតាមការពេញចិត្ត តែអ្នកមានឫទ្ធិនេះប្រាថ្នានឹងធ្វើ ទឹកនោះឲ្យជាដីសម្រាប់មនុស្សទាំងឡាយដទៃផង ក៏ធ្វើបានដូចគ្នាកន្លងកាលដែលកំណត់ទុក វាទើបត្រឡប់ជាទឹកដូចដើម ។

## អាកាសេបល្លង្កេនកមថាដិហារិយ

## “ អង្គុយធ្វើសមាធិនៅក្នុងអាកាសក៏បាន ”

ពាក្យថា **បល្លង្កេន កមតិ** សេចក្តីថា ទៅទាំងភ្នែន ( គឺ អង្គុយ ធ្វើសមាធិទៅ ) , ពាក្យថា **បក្ខី សកុណោ** ប្រែថា សត្វដែលប្រកបដោយស្លាបទាំងពីរ ឯភិក្ខុអ្នកប្រាថ្នានឹងធ្វើបាដិហារិយ៍យ៉ាងនោះ គប្បីចូលបឋវីកសិណ ចេញហើយ បើ

លោកប្រាថ្នានឹងគង់ ក៏កំណត់ទីក្នុងអាកាស ខ្នាតប៉ុនបល្ល័ង្ក ( គឺ ល្មមអង្គុយធ្វើសមាធិបាន ) ធ្វើបរិកម្មទៅហើយ អធិដ្ឋានដោយន័យដូចពោលមកហើយ នោះឯង គប្បីកំណត់ទី(ក្នុងអាកាស)តាមគួរយ៉ាងនេះ គឺបើលោកជាអ្នកប្រាថ្នានឹងដេក ក៏កំណត់ទីក្នុងអាកាស ខ្នាតប៉ុនគ្រែដេក បើលោកប្រាថ្នា នឹងដើរទៅ ក៏កំណត់ទីក្នុងអាកាស ខ្នាតប៉ុនផ្លូវដើរ ហើយអធិដ្ឋានថា អាកាស ចូរជាផែនដីដោយន័យដូចពោលមកហើយដូចគ្នា ។ ទន្ទឹមនឹងការអធិដ្ឋាន វាក៏ទៅជាផែនដីពិតៗ បាលីក្នុងប្រការនោះ គឺ :

ប្រការថា **អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី សកុណោ** ទៅទាំងការអង្គុយពែនភ្នែន ( គឺការអង្គុយធ្វើសមាធិទៅ ) ក្នុងអាកាស ដូចបក្សីហើរទៅក្នុងអាកាសក៏បាននោះ មានសេចក្តីថា ភិក្ខុអ្នកមានឫទ្ធិជាអ្នកបានបឋវីកសិណសមាបត្តិដោយប្រក្រតី លោកអាវជ្ជនាការដល់អាកាសស្រេចហើយ អធិដ្ឋានដោយញាណថា អាកាសចូរជាដី វាក៏ជាដីទៅ លោកចង្ក្រមក៏បាន ឈប់ឈរក៏បាន អង្គុយក៏បាន ដេកក៏បាន ក្នុងអាកាសដែលរាប់ថា ល្ហល្ហេវ មនុស្សទាំងឡាយដែលមិនមានឫទ្ធិដោយប្រក្រតី រមែងដើរទៅមកក៏បាន ឈប់ឈរក៏បាន អង្គុយក៏បាន ដេកក៏បាន លើផែនដីយ៉ាងណា ភិក្ខុដែលមានឫទ្ធិបានចេតោវសីនោះ ក៏ដូច្នោះដូចគ្នា រមែងចង្ក្រមក៏បាន ឈរក៏បាន អង្គុយក៏បាន ដេកក៏បាន ក្នុងអាកាសដែលរាប់ថា កណ្តាលវេហាស៍ ។

តែថា ភិក្ខុអ្នកប្រាថ្នានឹងទៅក្នុងអាកាស ត្រូវជាអ្នកបានទិព្វចក្ខុផង សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះថា វត្ថុដែលរាំង មានភ្នំ និងដើមឈើជាដើម ដែលកើតឡើងដោយអំណាចឧតុមាននៅក្នុងវាងផ្លូវខ្លះ ពួកសត្វមានឫទ្ធិ ដូចនាគ

និងគ្រុឌដែលមានចិត្តឫស្យា បណ្តាលឡើងដើម្បីសម្តែងវត្ថុរាំងទាំងនោះខ្លះ សួរថា ជួបវត្ថុរាំងទាំងនោះហើយ គប្បីធ្វើយ៉ាងដូចម្តេច ? ឆ្លើយថា ចូលឈានដែលជាបាទ ចេញហើយធ្វើបរិកម្ម ហើយអធិដ្ឋានថា វត្ថុនោះចូរជាអាកាសទៅ ។

ចំណែកព្រះថេរៈ ( តិបិដកចូឡភយៈ ) ពោលជំទាស់ថា អាវុសោ ការចូលសមាបត្តិទៀត មានប្រយោជន៍អ្វី ចិត្តរបស់អ្នកមានឫទ្ធិនោះក៏ជាសមាធិស្រេចហើយ លោកប្រើចិត្តនោះអធិដ្ឋានក្នុងទីណាៗ ថា ចូរជាអាកាស ទីនោះៗ ក៏ក្លាយជាអាកាសទៅហើយ មិនមែនឬ លោកពោលយ៉ាងនោះក៏ពិតមែន សូម្បីដូច្នោះ ក៏គួរបដិបត្តិតាមន័យដែលពោលមកក្នុងតិរោកុឌ្ឌបាដិហារិយ៍នោះឯង ។

ប្រការមួយទៀត សូម្បីនឹងចុះក្នុងទីដែលជាឱកាស ( គឺទីសមគួរ ) ភិក្ខុនេះក៏ត្រូវជាអ្នកបានទិព្វចក្ខុផង ព្រោះបើលោកចុះក្នុងទីដែលមិនជាឱកាស(មិនសមគួរ) ជាកំពង់ទឹកក្តី ជាទ្វារស្រុកក្តី លោកក៏នឹងជាអ្នកប្រាកដដល់មហាជន ព្រោះហេតុនោះ លោកឃើញឱកាសដោយទិព្វចក្ខុហើយ ក៏វៀរទីដែលមិនជាឱកាស ចុះក្នុងទីដែលជាឱកាសបានដូច្នេះ ។

## ចន្ទិមសុរិយបរាមសនបាដិហារិយ

### “ ស្ទាបព្រះចន្ទ ព្រះអាទិត្យបាន ”

ក្នុងបាដិហារិយ៍នេះថា **ឥមេបិ ចន្ទិមសុរិយេ ឯវំ មហិទ្ធិកេ ឯវំ មហានុភាវេ បាណិនា បរាមសតិ បរិមជ្ជតិ** ស្ទាបព្រះចន្ទ និងព្រះអាទិត្យបាននេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយដៃក៏បាននេះ មានពណ៌នាថា ការមានឫទ្ធិច្រើននៃព្រះចន្ទ និង ព្រះអាទិត្យ គប្បីជ្រាបដោយការដែលចរទៅ

បានលើបឋពីដែលមានបរិមាណដល់ ៤២០០០ យោជន៍ ចំណែកការមានអានុភាពច្រើន គប្បីជ្រាបដោយការដែលធ្វើភាពក្ដីស្វាងក្នុងទ្វីប ៣ បាន ក្នុងខណៈដូចគ្នា ន័យម្យ៉ាងទៀត រាប់ថា មានឫទ្ធិច្រើន ដោយចរទៅលើបឋពី និងធ្វើភាពក្ដីស្វាងយ៉ាងនោះបាន ឈ្មោះថា មានអានុភាពច្រើន ក៏ដោយការមានឫទ្ធិច្រើននោះនុ៎ះឯង បទថា **បរាមសតិ** ប្រែថា ចាប់ ឬប៉ះពាល់ក្នុងឯកទេសនៃដួងចន្ទ្រាទិត្យ , បទថា **បរិមញ្ជតិ** គឺ អង្អែលទៅដោយជុំវិញ ដូចស្ទាបកញ្ចក់ ។

ឫទ្ធិនេះ រមែងសម្រេចដល់ភិក្ខុអ្នកមានឫទ្ធិនោះ ដោយអំណាចនៃឈានដែលជាបាទនៃអភិញ្ញាបុណ្ណោះ ភាពនិយមដោយកសិណសមាបត្តិ មិនមានក្នុងឫទ្ធិប្រការនេះទេ សមដូចបាលីក្នុងបដិសម្ភិទាមគ្គថា ក្នុងប្រការថា ស្ទាបព្រះចន្ទ និងព្រះអាទិត្យនេះ ។ ល ។ ក៏បាន នេះសេចក្ដីថា ភិក្ខុអ្នកមានឫទ្ធិបានចេតោវសីនោះ អាវជ្ជនាការដល់ព្រះចន្ទ និងព្រះអាទិត្យនោះ ស្រេចហើយអធិដ្ឋានដោយញាណថា ព្រះចន្ទ និងព្រះអាទិត្យ ចូរមាន គឺ មកនៅក្នុងហត្ថបាស ព្រះចន្ទ និងព្រះអាទិត្យក៏មាននៅក្នុងហត្ថបាស លោកអង្គុយ ឬដេកក៏ដោយ ក៏ចាប់ស្ទាបព្រះចន្ទ និងព្រះអាទិត្យដោយបាតដៃបាន មនុស្សទាំងឡាយអ្នកមិនមានឫទ្ធិដោយប្រក្រតី រមែងចាប់ស្ទាបអង្អែលវត្ថុដែលជារូបអ្វីៗ ដែលនៅក្នុងហត្ថបាសបានយ៉ាងណា ភិក្ខុអ្នកមានឫទ្ធិបានចេតោវសីនោះ ក៏ដូច្នោះដូចគ្នា រមែងចាប់ត្រូវព្រះចន្ទ និងព្រះអាទិត្យ ។ ល ។ បាន ។

ភិក្ខុអ្នកមានឫទ្ធិនោះ បើប្រាថ្នានឹងឡើងទៅចាប់ព្រះចន្ទ និងព្រះអាទិត្យ ក៏ឡើង ទៅចាប់បាន តែបើថា ប្រាថ្នានឹងជាអ្នកអង្គុយ ឬដេកចាប់ត្រង់ទីនេះឯង ក៏អធិដ្ឋានថា ព្រះចន្ទ និងព្រះអាទិត្យចូរមាន គឺមកនៅក្នុងហត្ថបាស លោកក៏ចាប់ត្រូវ

ព្រះចន្ទ និងព្រះអាទិត្យ ដែលមកនៅក្នុងហត្ថបាស ដោយកម្លាំងនៃការអធិដ្ឋានបាន ដូចផ្លែត្នោតជ្រុះចាកទង មកនៅក្នុងហត្ថបាសដូច្នោះ ឬមិនដូច្នោះ លូកដៃឡើងទៅចាប់ក៏បាន ។

សួរថា កាលពន្លឺតដែលចេញទៅនោះ ពន្លឺតផ្អែកជាឧបាទិន្នក ឬ ក៏ផ្អែកដែលជាអនុបាទិន្នក ? ឆ្លើយថា អាស្រ័យផ្អែកដែលជាឧបាទិន្នក ពន្លឺតផ្អែក អនុបាទិន្នកចេញទៅ ក្នុងប្រការនោះ ព្រះតិបិដកចូឡនាគត្ថេរពោលថា ម្នាលអាវុសោទាំងឡាយ ឧបាទិន្នកនឹងជារបស់តូចខ្លះ ធំខ្លះមិនបានឬ កាលណាភិក្ខុសម្ដែងឫទ្ធិចេញតាមរន្ធតូចៗ មានរន្ធរនុកទ្វារជាដើម កាលនោះឧបាទិន្នកក៏ជារបស់តូចបាន កាលណាភិក្ខុធ្វើអត្តភាពឲ្យធំ កាលនោះឧបាទិន្នកក៏ជារបស់ធំបាន ដូចឧបាទិន្នករបស់ ព្រះមហាមោគ្គល្លានត្ថេរដូច្នោះមិនមែនឬ ។

## មហាដីកា
## ពណ៌នាអំពី ឫទ្ធិ ១០ យ៉ាង

ពាក្យថា **ដោយសេចក្ដីថា បង្កើត** គឺដោយសេចក្ដីថា សម្រេច ។ ពាក្យថា ដោយសេចក្ដីថា **បានមក** គឺ ដោយសេចក្ដីថា សម្រេច ។ ពាក្យថា **វត្ថុនោះ** បានដល់ វត្ថុដែលត្រូវការ ។ បទថា **សមិជ្ឈតិ-សម្រេច** បានដល់ កើតផល ។ ចាប់តាំង ពីការបួសជាដើមទៅ រហូតដល់ឈាន និងមគ្គ ឈ្មោះថា នេក្ខម្មៈក្នុងទីនេះ ។ បទថា **ឥជ្ឈតិ-សម្រេច** គឺ ដែលបុគ្គលសម្រេច ។ បទថា **ឈ្មោះថា បាដិហារិយ** ព្រោះអត្ថថា នាំយកធម៌ដែលជាបដិបក្ខទៅ មានសេចក្ដីថា ព្រោះហេតុ

ដែលនាំទៅ គឺប្រាសទៅនូវធម៌ដែលជាបដិបក្ខដូច្នោះ ទើបឈ្មោះថា **បាដិហារិយ** ។ គុណ មានទេក្ខម្មៈជាដើម ឈ្មោះថា **បាដិហារិយ** ព្រោះអត្ថថា នាំយកធម៌ដែលជាបដិបក្ខរបស់ខ្លួនទៅ ។ **បាដិហារិយ** នោះឯងជា បាដិហារិយ៍ ដោយពាក្យថា **វេកតំ** និង **វេសមំ** ជាដើម ដូច្នេះ ។

ពាក្យថា **ដោយសេចក្ដីថា សម្រេច** គឺដោយសេចក្ដីថា កើតផល ។ ពាក្យថា **ការដល់ព្រមនៃឧបាយ** គឺ នៃឧបាយដែលដល់ព្រម មានសេចក្ដីថា ការប្រារព្ធដោយការដឹង ។ ពាក្យថា **ព្រះអរហត្តមគ្គ** ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច គឺ ឲ្យផល ។ ពាក្យថា **ជាអ្នកមានសីល** គឺជាអ្នកមានសីល ដោយអាចារសីល ។ ពាក្យថា **ជាអ្នកមានកល្យាណធម៌** គឺជាអ្នកមានធម៌ដ៏ស្អាត ដោយអំណាចនៃកុសលកម្មបថ ១០ ម៉្យាងទៀត ឈ្មោះថា ជាអ្នកមានសីល គឺការដល់ព្រមនៃសីល ឈ្មោះថា ជាអ្នកមានកល្យាណធម៌ គឺ ដោយអំណាចនៃបុញ្ញកិរិយាវត្ថុដ៏សេស មានទានជាដើម ។ បទថា **បណិទហិស្សតិ** ប្រែថា នឹងប្រាថ្នា ។

បទថា **ឥជ្ឈន្តិ** ប្រែថា ចម្រើន មានន័យថា ដល់នូវភាពខ្ពង់ខ្ពស់ ។ ពិតមែនលោកពោលដល់ឥទ្ធិក្នុងន័យថា បង្កើត(ឲ្យផល) បានមកធ្វើឲ្យសម្រេច និងជាហេតុចម្រើន បានយ៉ាងល្អក្រៃលែង ។ ពាក្យថា **ឥទ្ធិនោះ មាន ១០ យ៉ាង** លោកពោលទុកដើម្បីសម្ដែងឥទ្ធិដែលប្រាថ្នាក្នុងទីនេះ តាមរយៈការនាំយកឥទ្ធិទាំងអស់មកលើកអត្ថន័យ។ **ឥទ្ធិ ឬ ឫទ្ធិ** ឈ្មោះថា **អធិដ្ឋានា** ព្រោះអត្ថថា មានអធិដ្ឋាន គឺការតាំងចិត្តឲ្យខ្លួនទៅជាច្រើននាក់ជាដើម។ ឈ្មោះថា **វិកុព្វនា** ព្រោះអត្ថថា **វិកុព្វន** គឺការធ្វើផ្សេងៗ ពោលគឺ ការនិម្មិតរូបមានប្រការផ្សេងៗ ។ បទថា **មនោមយា**

គឺ ឈ្មោះថា សម្រេចដោយចិត្ត ព្រោះការបង្កើតឡើងដោយឈានចិត្ត ។ ឈ្មោះថា **ញាណវិប្ផារ** ព្រោះអត្ថថា មានការផ្សាយទៅ គឺ ការប្រព្រឹត្តទៅដោយកម្លាំងនៃញាណ ។ ឈ្មោះថា **អរិយា** ព្រោះអត្ថថា ជារបស់ព្រះអរិយបុគ្គលទាំងឡាយ ។ ឥទ្ធិដែលកើតអំពីវិបាករបស់កម្មណាមួយ ឈ្មោះថា **កម្មវិបាកជា** ។ ឥទ្ធិដែលបង្កើតឡើង ព្រោះបុណ្យដ៏ល្អក្រៃលែង ឈ្មោះថា **បុញ្ញវតោឥទ្ធិ** ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីផ្សេងគ្នានៃឥទ្ធិពីរយ៉ាងពួកនេះ យ៉ាងនេះថា កម្មវិបាកជាឥទ្ធិតាំងពីកើត ។ ឥទ្ធិក្រៅពីនេះ **បុញ្ញវតោឥទ្ធិ** មានក្នុងពេលដែលបុណ្យឲ្យវិបាកដូច្នេះចុះ ។ ឥទ្ធិកើតឡើងព្រោះ **អាថព្វណ វិជ្ជា** ឈ្មោះថា **វិជ្ជាមយា** ឈ្មោះថា ការប្រកបត្រូវ បានដល់ ការប្រកបដោយឧបាយ គឺ ប្រារព្ធដោយការដឹង ។

ពាក្យថា **ជាមនុស្សម្នាក់តាមប្រក្រតី** គឺជាមនុស្សម្នាក់តាមសភាវៈ ។ បទថា **ពហុកំ** ប្រែថា ច្រើននាក់ ។ លោកអាចារ្យកាលសម្តែងភាពជាមនុស្សច្រើននៃបុគ្គលដែលគប្បីអធិដ្ឋាន ដែលមិនបានកាន់យកការកំណត់ចំនួនទុក ដោយបទថា **ពហុកំ** នោះហើយ ប្រាថ្នាសម្តែងដោយការកំណត់ចំនួនទៀត ទើបពោលថា ជា ១០០ នាក់ខ្លះ ដូច្នេះជាដើម ។ ពាក្យថា **នឹក** គឺ រិះគិត ដោយការរិះគិតដែញហៅថា បរិកម្ម គឺធ្វើទុកក្នុងចិត្តដោយបរិកម្មមនសិការ ក្នុងរូបដែលធ្វើឲ្យកើត ( ដែលនិម្មិតនោះ ) ។ ពាក្យថា **អធិដ្ឋានដោយញាណ** គឺធ្វើបរិកម្មទុកយ៉ាងនោះហើយ ក៏តាំងចិត្តឲ្យជាច្រើននាក់តាមប្រាថ្នា ដោយអភិញ្ញាញាណ មានសេចក្តីថា កាលធ្វើឥទ្ធិវិធញ្ញាណឲ្យសម្រេចបានច្រើននាក់ គឺ ឲ្យសម្រេចបានច្រើននាក់ ប្រព្រឹត្តទៅទន្ទឹមនឹងចិត្តដែលអធិដ្ឋាននោះឯង ក៏ពោលបានថា អធិដ្ឋានទុកដោយប្រការនោះ ។ សូម្បីក្នុងញាណដ៏សេសក៏មានន័យដូច្នេះ ។ **ឯវំ** - ស័ព្ទ ក្នុងពាក្យថា **ឯវំ** ( ឫទ្ធិ

ដែលលោកចែកទុកយ៉ាងនេះ ) មានអត្ថថា ប្រការ , ដោយ **ឯវំ**-ស័ព្ទ លោករួមយកប្រការដែលអធិដ្ឋានទាំងពួង ។ ពាក្យថា **ដោយអំណាចការអធិដ្ឋាន** គឺ ព្រោះបង្កើតឡើងដោយអំណាចការអធិដ្ឋាន ដែលបានពោលហើយយ៉ាងនេះថា អធិដ្ឋានដោយញាណ ។

បទថា **បកតិវណ្ណំ** បានដល់ សណ្ឋានប្រក្រតី គឺរូបរាងតាមប្រក្រតីរបស់ខ្លួន។ ពាក្យថា **ដោយអំណាចការលះរូបរាងប្រក្រតី និងប្ដូរផ្លាស់រូបរាង** គឺ ដោយអំណាច ការប្ដូរផ្លាស់រូបរាងជារូបរាងកុមារជាដើម ដែលមានការលះរូបរាងប្រក្រតីរបស់ខ្លួនជាខាងដើម ។

ពាក្យថា **ចាកកាយនេះ** គឺចាកករជកាយរបស់ភិក្ខុ ដែលពោលដល់ថា នេះ ព្រោះមានជាប្រចក្សុ ។ ពាក្យថា **កាយដទៃ** គឺកាយដទៃដែលសម្រេចដោយឫទ្ធិ ។ ព្រោះហេតុនោះៗ ឯង ទើបឈ្មោះថា មានរូប ព្រោះការដែលមានរូបដែលសម្រេចដោយឫទ្ធិ ។ ឈ្មោះថា **សម្រេចដោយចិត្ត** ព្រោះបង្កើតឡើងដោយអភិញ្ញាចិត្ត ។ បទថា **និប្ផត្តិវសេន** ប្រែថា ដោយអំណាចការធ្វើឲ្យកើតឡើង ។ ក៏សេចក្ដីប្រព្រឹត្តទៅនៃអភិញ្ញាចិត្តដោយប្រការដែលកាយសម្រេចដោយចិត្ត និងបង្កើតឡើងបាន ឈ្មោះថា **មនោមយិទ្ធិ** សូម្បីក្នុងការសម្ដែងឫទ្ធិដ៏សេសទាំងឡាយ ក៏មានន័យដូច្នេះដែរ ។ សួរថា បើជាយ៉ាងនេះ ឫទ្ធិនេះនឹងឈ្មោះថា **មនោមយិទ្ធិ** បានដូចម្ដេច គប្បីជ្រាបថា ឈ្មោះថា **មនោមយិទ្ធិ** ឈ្មោះថា **មនោមយិទ្ធិ** គឺជាពាក្យហៅតាមនិយម ដូចពាក្យថា **មនោមយោ អត្តភាវោ** ( អត្តភាពដែលសម្រេចដោយចិត្ត ) ឬដូចពាក្យថា **គោសមញ្ញា វិសាណាទិមតិ បិណ្ឌេ**( សមញ្ញាថា គោ គប្បីរួមយកថា ជាឈ្មោះរបស់សត្វដទៃ មានរមាសជាដើម ដូច្នោះ ន័យម្យ៉ាងទៀត

គប្បីជ្រាបថា បញ្ញត្តថា **មនោមយ** គឺ សម្រេចដោយចិត្តដ៏ប្រពៃ ក្នុងឥទ្ធិនេះ ព្រោះអត្ថថា ភាវៈដែលកាយបង្កើតឡើងដោយចិត្ត ដែលចេញមកពីខាងក្នុង និងត្រូវប្រាកដច្បាស់ក្នុងការនិម្មិតនេះ ដូចគ្នានឹងលោកអ្នកមានឫទ្ធិយ៉ាងណា និងត្រូវប្រាកដច្បាស់ក្នុងឫទ្ធិយ៉ាងដទៃ គឺ អធិដ្ឋានាឥទ្ធិ និងវិកុព្វនាឥទ្ធិ ដែលមានសមញ្ញាដទៃដូច្នេះក៏ទេ ។ ពាក្យថា **ក្នុងកាលមុនអំពីការប្រព្រឹត្តទៅរបស់ញាណ** បានដល់ ក្នុងកាលមុនអំពីការឡើងនៃអរហត្តមគ្គញាណ ក្នុងខណៈនៃវិបស្សនា ឬក្នុងកាលមុនអំពីខណៈនៃវិបស្សនានោះ ចាប់តាំងពីការកាន់យកបដិសន្ធិនៃព្រះយោគី អ្នកជាអន្តិមភវិក ( មានភពនេះជាភពចុងក្រោយ ) ។ ឈ្មោះថា **ក្នុងខាងក្រោយក្តី** គឺក្នុងខាងក្រោយ រហូតដល់ការបរិនិព្វាននៃខ្លួន ។ ឈ្មោះថា ក្នុងខណៈនោះក្តី ក៏គឺក្នុងសម័យដែលមគ្គកើតឡើង ។ ពាក្យថា **គុណវិសេសដែលកើតឡើង ព្រោះអានុភាពនៃញាណ** បានដល់ គុណវិសេស ពោលគឺការលះធម៌ដែលគួរលះ ការចម្រើនធម៌ដែលគួរចម្រើន និងភាពបរិបូណ៌ដោយប្រការទាំងពួង ដែលបង្កើតឡើង ព្រោះអានុភាពនៃញាណនោះឯង ដូចអំណាចក្នុងការសាងពន្លឺភ្លឺស្វាងក្នុងទីដែលព្រះអាទិត្យរះឡើង និងដោយជុំវិញផ្ទែកនៃព្រះអាទិត្យដូច្នោះ ។ ចំណែករឿងរ៉ាវទាំងឡាយ គឺទាក់ទងនឹងលោកអ្នកមានឫទ្ធិមកហើយ ដោយទាក់ទងនឹងភាវៈដែលមិនមានអន្តរាយ ។ ពាក្យថា **ដោយអនិច្ចានុបស្សនា** គឺ ដោយវិបស្សនាដែលមានកម្លាំង តាមពិចារណាឃើញសង្ខារទាំងឡាយថាមិនទៀង ។ ពិតហើយ ព្រះយោគីអ្នកប្រារព្ធវិបស្សនា រមែងសម្រេច គឺ ការលះបង់និច្ចសញ្ញា គឺ ការសម្គាល់ថាទៀងបានក្នុងវារៈដែលពិចារណាបកិណ្ណកសង្ខារ ក្នុងខណៈដែលប្រព្រឹត្តទៅនៃវិបស្សនាតាមដែលពោលមកហើយ ក្នុងកាលមុនអំពីនោះ និងក្នុងខាងក្រោយ

ក្នុងបទទាំងពួងក៏មានន័យដូច្នេះដែរ លោកអាចារ្យបានប្រកាសអត្ថដែលប្រាថ្នាសូម្បីក្នុងពាក្យពោលដោយសង្ខេបត្រឹមប៉ុណ្ណេះក៏ពិត ។ សូម្បីយ៉ាងនោះ **អត្ថ** ត្រូវសំដៅយកឲ្យកាន់តែច្បាស់ដោយពាក្យពោលដោយពិស្តារ ព្រោះហេតុនោះ ទើបពោលថា គួរនឹងពោលរឿងរបស់លោកដោយពិស្តារដូច្នេះ ។

បទថា **គព្ភគតស្សេវ** ជាឆដ្ឋីវិភត្តិក្នុង **អនាទរ** ប្រែថា កាលនៅក្នុងផ្ទៃនោះឯង ។ ពាក្យថា **តាមន័យដែលបានពោលមក** គឺតាមន័យដែលបានពោលមកហើយ ក្នុងរឿងរបស់ព្រះពាកុលត្ថេរ ដោយពាក្យថា **បច្ឆិមភវិកស្ស-អ្នកជាបច្ឆិមភវិកសត្វជាដើម** ។ បទថា **ទារុភារំ កត្វា** មានសេចក្តីថា ធ្វើ គឺជញ្ជូនឧសធ្ងន់ទុកក្នុងរទេះ ។ ពាក្យថា **ក្រឡាប់នឹម** គឺ បម្រាសចេញ ។ ពាក្យថា **សកដមូលេ** ប្រែថា ទីជិតរទេះ ។ ក្នុងពាក្យថា **មានយក្ខកាចសាហាវពពាក់ពពូន** គឺកាលមានយក្ខកក្ខឡៈពាសពេញ ។ សេចក្តីពិតក្រុងរាជគ្រឹះមានយក្ខគ្រប់គ្រង ។

ពាក្យថា **អំពីសមាធិ** គឺអំពីសមាធិ មានបឋមជ្ឈានជាដើម ។ ពាក្យថា **ក្នុងកាលមុន** គឺក្នុងខណៈនៃឧបចារជ្ឈាន ។ ពាក្យថា **ក្នុងខាងក្រោយ** គឺ ក្នុងទីបំផុតដែលបានសន្សំហើយនៃសមាបត្តិ ។ ពាក្យថា **ក្នុងខណៈនោះ** គឺ ក្នុងខណៈដែលចូល ។ ពាក្យថា **គុណវិសេសដែលបង្កើតឡើង ព្រោះអានុភាពនៃសមថៈ** គឺគុណវិសេស មានការគ្របសង្កត់នីវរណៈបាន ការឈានកន្លងអង្គ មានវិតក្កៈជាដើមបាន ការរលត់សញ្ញា និងវេទនាបាន ការអត់ធន់ចំពោះអន្តរាយបានជាដើមដែលបង្កើតឡើងព្រោះតេជះនៃសមាធិក្នុងឈាននោះៗ ។

បទថា **កបោតកន្ទរាយ** គឺវិហារក្នុងព្រៃដែលមានឈ្មោះយ៉ាងនេះ ។ ពាក្យថា **ក្នុងយប់ខែភ្លឺ** គឺ ក្នុងយប់ដែលមានពន្លឺព្រះចន្ទ ។ បទថា **នវោរោបិតេហិ**

**កិសេហិ** ជាតតិយាវិភត្តិក្នុងឥត្ថម្ភូតលក្ខណៈ ប្រែថា មានសក់កោរថ្មីៗ ។ បទថា **យស្ស** បានដល់ **បហារស្ស** គឺការប្រហារ ។ បទថា **តស្ស** បានដល់ **យក្ខស្ស** គឺ យក្ខ ។ កាលយក្ខនោះកំពុងធ្វើការប្រហារនោះឯង ព្រះថេរៈក៏ចូលសមាបត្តិ ព្រោះភាពជាខិប្បនិសន្តិ ចូលឈានបានដោយរហ័ស ដល់ភាពខ្ពង់ខ្ពស់ហើយ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងសម័យដែលមានយក្ខវាយដំ ព្រះថេរៈចូលស៊ប់ក្នុងសមាបត្តិដូច្នេះ ។ ចំណែកក្នុងព្រះបាលីពោលទុកថា **និសិន្នោ ហោតិ អញ្ញតរំ សមាធឹ សមាបជ្ជិត្វា**-ព្រះថេរៈអង្គុយចូលសមាបត្តិណាមួយ , រីឯព្រះថេរៈទាំងឡាយពួកនេះ ហៅថា យក្ខនោះវាយប្រហារទន្ទឹមនឹងពេលដែលលោកចេញអំពីសមាបត្តិដូច្នេះ ។

ពាក្យថា **ព្រះសញ្ជីវត្ថេរ** លោកអាចារ្យពោលសំដៅយក ព្រះមហាថេរៈអ្នកជាព្រះអគ្គសាវកទាំងពីររបស់ព្រះមានព្រះភាគកកុសន្ធ ពិតមែន ព្រះសញ្ជីវត្ថេរនោះ គង់ក្នុងស្ថានទីមានព្រៃជាដើមណាមួយ ចូលនិរោធបានដោយមិនលំបាកឡើយ ។ ព្រោះដូច្នោះ ក្នុងថ្ងៃមួយ ទើបលោកចូលនិរោធនៅត្រង់គល់ឈើមួយដើម ។ លោកអាចារ្យសំដៅយកសេចក្តីនោះ ទើបពោលថា កំពុងចូលនិរោធដូច្នេះជាដើម , ភ្លើងមិនបានឆេះសូម្បីតែសរសៃអំបោះចីវរ ចាំបាច់និយាយថ្វីដល់សរីរៈនោះ ។ ក៏ព្រោះហេតុនោះៗ ទុំះឯង មនុស្សទាំងឡាយទើបស្គាល់ច្បាស់ឈ្មោះរបស់លោកបានថា សញ្ជីវៈនោះឯង ។ បទថា **អយមស្ស** ប្រកបសេចក្តីថា ការមិនមានអន្តរាយ គឺ ភ្លើងឯណាក្នុងពេលចូលនិរោធនៃព្រះសញ្ជីវៈនោះ នេះឈ្មោះថា **សមាធិវិប្ផារឥទ្ធិ** ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា តែថា នឹងមានការកើតភាពផ្សាយទៅនៃសមាធិ ក្នុងនិរោធសមាបត្តិបានយ៉ាងដូចម្តេច ដូច្នេះហើយ

ទើបពោលថា ដែលបង្កើតឡើងព្រោះ ។ ល ។ នៃអនុបុព្វសមាបត្តិរបស់លោក ដូច្នេះ ។

ពាក្យថា **វត្ថុដែលដាក់ទុកមុន** គឺ វត្ថុដែលទុកមុនវត្ថុដទៃបន្តិស់ ។ វត្ថុណាទុកមុន កាលពេលពួកចោរកាន់យកទៅ រមែងកាន់យកទៅក្រោយវត្ថុដទៃបន្តិស់។ ពាក្យថា **តាមដែលបានកំណត់កាលទុក** គឺតាមដែលបានធ្វើការកំណត់កាលទុកមុន ការចូលថា ដល់កាលត្រឹមនេះយើងនឹងចេញ ។ ក៏ខ្លាច ស្រែកឡើង គឺ ព្រោះ ឃើញរូបក្នុងភាពងងឹតនៃរាត្រី ទើបពួកចោរសម្គាល់ថា បិសាចនឹងក្រោកឡើងមក ព្រះថេរៈត្រូវរបស់ច្រើនដល់ម្លេះសង្កត់ហើយ ក៏មិនមានអ្វីចំឡែក , ចោរក៏បួស ដោយសេចក្តីជ្រះថ្លា ដែលប្រព្រឹត្តទៅក្នុងព្រះថេរៈថា ឱលោកជាអ្នកមានអានុភាព ច្រើន និងថា ឱលោកជាអ្នកមានវិវេក ដូច្នេះ ។

បទថា **តត្តតេលកដាហំ** លោកពោលដល់វត្ថុដែលត្រូវដាក់ប្រេងរក្សាទុក ដោយវត្ថុដែលទទួល គឺខ្ទះជាសំខាន់ អធិប្បាយថា ស្រោចប្រេងក្តៅក្នុងខ្ទះ គឺប្រើ ខ្ទះស្រោច ។ ពាក្យថា **ហូរចុះទៅ** គឺ ហូរចុះទៅដោយមិនជាប់នៅក្នុងទីកន្លែង ណាមួយឡើយ ។

ពាក្យថា **ព្រមទាំងបរិវារ** គឺ ព្រមទាំងបរិវារ ដោយស្ត្រី ៥០០ នាក់ ។ ពាក្យថា **ព្រះនាងផ្សាយមេត្តាទៅក្នុងព្រះរាជា** គឺ ព្រះនាងផ្សាយទៅក្នុងព្រះរាជា ដោយឱទិសកមេត្តាសមាបត្តិ( មេត្តាសមាបត្តិដែលផ្សាយទៅដោយចំពោះបុគ្គល )។ បទថា **ខិបិតុំ** កែជា **វិជ្ឈិតុំ** ។ ពាក្យថា **ដាក់ធ្នូ** គឺ ដោះស្រោមដាក់កូនសរ ។

ពាក្យថា **ក្នុងវត្ថុជាបដិកូលជាដើម** គឺក្នុងវត្ថុដែលមិនគួរប្រាថ្នាជាដើម ។ ក៏ វត្ថុដែលមិនគួរប្រាថ្នា លោកហៅថា បដិកូល , សូម្បីវត្ថុដែលមិនពេញចិត្តក៏ហៅ

ថា វត្ថុដែលជាបដិកូល ដោយ **អាទិ**-ស័ព្ទ ( ប្រែថា ជាដើម ) លោករួមយកវត្ថុដែលមិនបដិកូលជាដើមផង ។ បទថា **តត្ថ** បានដល់ ក្នុងអារម្មណ៍ដែលជាបដិកូល ។ ពាក្យថា **ជាអ្នកព្រងើយកន្តើយ** គឺជាអ្នកព្រងើយកន្តើយដោយឆឡង្គុបេក្ខា ( ការព្រងើយកន្តើយមានអង្គ ៦ ) ។ បទថា **តត្ថ** គឺ ក្នុងវត្ថុ មានប្រភេទជាបដិកូល និង មិនជាបដិកូល ។ ពាក្យថា **មានសតិ** គឺជាអ្នកមានសតិហេតុ គឺការដល់នូវភាពបរិបូណ៌នៃសតិ ។ ពាក្យថា **មានសម្បជញ្ញៈ** គឺជាអ្នកមានប្រក្រតីធ្វើសម្បជញ្ញៈ ហេតុ គឺ ការដល់នូវភាពបរិបូណ៌នៃបញ្ញា ។ បទថា **អយំ** បានដល់ ភាពជាឥស្សរៈនៃចិត្តដែលសម្រេចព្រោះការសម្រេចព្រះអរហត្ត-មគ្គ នៃព្រះខីណាស្រពទាំងឡាយ ដែលមានការសម្គាល់ក្នុងវត្ថុជាបដិកូលជាដើមថាមិនជាបដិកូល ជាវិហារធម៌ជាដើមនេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ភាវៈនេះលោកហៅថា ។ ល ។ អ្នកសម្រេចចេតោវសី ដូច្នេះ ។

គប្បីប្រកបពាក្យពោលថា កាលធ្វើការផ្សាយមេត្តាក្នុងវត្ថុដែលមិនគួរប្រាថ្នាដែលដឹងថា ជាសត្វ ឬការដាក់ចិត្តថា **ធាតុ** គឺការធ្វើទុកក្នុងចិត្តថា ធាតុ ក្នុងវត្ថុមានឈាមកជាដើម ដោយការពិចារណាថាជា ធាតុ ។ ពាក្យថា **រមែងជាអ្នកសម្គាល់ថា មិនជាបដិកូលបាន** គឺមិនជាអ្នកសម្គាល់ថា ជាបដិកូលដោយឥរិយាបថវិហារបាន ព្រោះភាពជាអ្នកស្វែងរកប្រយោជន៍ និងព្រោះការគិតថា ត្រឹមតែជាសភាវធម៌ ។ ក្នុងវត្ថុដែលគួរប្រាថ្នា គឺ ក្នុងញាតិ និងមិត្តជាដើម ។ ការធ្វើការផ្សាយទៅថា មិនល្អ ឬធ្វើការដាក់ចិត្តថា មិនល្អ ថា បណ្តាកោដ្ឋាសទាំងឡាយមានសក់ជាដើម ត្រឹមតែជាចំណែកដែលមិនស្អាតប៉ុណ្ណោះ ។ បណ្តាពាក្យពួកនោះ **ឥតិ**-ស័ព្ទ ក្នុងពាក្យថា រូបមិនទៀង មានអត្ថថា ជាដើម ។ ព្រោះហេតុនោះ ទើប

មានរាថា ប្រកបសេចក្តីថា ធ្វើមនសិការថា រូបធម៌មានការមិនទៀងជាទុក្ខ និង ជាអនត្តា មានការប្រែប្រួលទៅជាធម្មតា ។ ពាក្យថា **ក្នុងវត្ថុដែលជាបដិកូល និងដែលមិនជាបដិកូល** លោកពោលដល់វត្ថុដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាគ្រាន់តែមួយ ។ ក្នុងបទដ៏សេសក៏មានន័យដូច្នេះ ។ ម្យ៉ាងទៀត វត្ថុណា ដំបូងប្រាកដថា ជាបដិកូលដល់សត្វទាំងឡាយហើយ ក្នុងខាងក្រោយត្រឡប់ថា មិនជាបដិកូល និងវត្ថុណាប្រាកដថា មិនជាបដិកូលហើយ ក្នុងខាងក្រោយត្រឡប់ប្រាកដថា ជាបដិកូល , បើព្រះខីណាស្រពប្រាថ្នាវត្ថុដែលមានអាការទាំងពីរយ៉ាងនោះ , ក៏នឹងគប្បីជាអ្នកសម្គាល់ថា មិនជាបដិកូលខ្វះ ជាអ្នកសម្គាល់ជាបដិកូលខ្វះ តាមន័យដែលបានពោលមកហើយ ឫទ្ធិដូចពោលមកនេះៗ ហៅថា **អរិយាឥទ្ធិ** ។

ពាក្យថា **ឃើញរូបដោយភ្នែក** គឺឃើញរូបដោយចក្ខុវិញ្ញាណដែលអាចឃើញរូបបាន រោហារថា ចក្ខុដោយអំណាចនៃហេតុ ( ការណរោហារ ) ឬដោយចក្ខុដែលជាហេតុ ឬជាទ្វារ ។ ពាក្យថា **មិនជាអ្នកត្រេកអរ** នេះជាការបដិសេធគេហសិតសោមនស្ស ( សោមនស្សអាស្រ័យផ្ទះ ) មិនបានជាការបដិសេធសោមនស្សវេទនាដែលជាកិរិយាមានក្នុងចំណែកនៃទេក្ខម្មៈទេ ។ ពាក្យថា **ឧឡុក្ខបេក្ខា** បានដល់ តត្រមជ្ឈត្តុបេក្ខា ដែលមិនមានការមិនលះប្រក្រតីភាវៈដ៏បរិសុទ្ធជាលក្ខណៈគន្លងនៃអារម្មណ៍ ៦ ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ដែលបានឈ្មោះថា ឧឡុក្ខបេក្ខា ព្រោះប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ លោកអាចារ្យបំណាងនឹងធ្វើខ្លឹមសារដែលបានពោលហើយ ឲ្យច្បាស់លាស់ដោយព្រះបាលី ទើបពោលថា ក្នុងបដិសម្ភិទាមគ្គ ដូច្នេះជាដើម ។

ដោយ**អាទិ**-ស័ព្ទក្នុងបទថា **បក្ខីអាទីនំ** គឺ សត្វទាំងឡាយ មានចាបជាដើម

មានការរួមយកសត្វទាំងឡាយ មានទេវតាជាដើម ។ ដោយ**អាទិ**-ស័ព្ទក្នុងបទថា **វេហាសគមនាទិកា** ( ឫទ្ធិមានការទៅក្នុងអាកាសបានជាដើម ) លោករួមយកចក្ខុ-**វិសុទ្ធិ** ( ភ្នែកដែលអាចឃើញបានហ្មត់ចត់ជាដើម ) ។ សត្វឈ្មោះថា **វិនិបាតិក** ព្រោះសូម្បីកើតឡើងដោយកុសលកម្ម ក៏នៅប្រាសចាកអំពីសេចក្ដីសុខ ដោយអានុភាពនៃអកុសលវិបាក ។ ពាក្យថា **ឈាន** លោកពោលសំដៅយកឈានដែលដល់អភិញ្ញា ។ សូម្បីវិបស្សនាដែលដល់ភាពខ្ពង់ខ្ពស់ ប្រព្រឹត្តទៅទីងឧព្វេង្គាបីតិក៏រមែងប្រាកដត្រឹមតែជាហេតុឲ្យអណ្ដែតទៅក្នុងអាកាសបាន ព្រោះហេតុនោះ ទើបលោកពោលថា វិបស្សនាដូច្នេះ ។ បទថា **បឋមកប្បិកានំ** នេះ គប្បីឃើញថា ជាវិសេសនៈរបស់បទថា **ឯកច្ចានិ មនុស្សានំ** ប្រែថា នៃមនុស្សជំពូកខ្លះ គ្រាបឋមកប្ប ។ ដោយ**អាទិ**-ស័ព្ទក្នុងបទថា **ឯវមាទីនំ** ( ជាដើមយ៉ាងនេះ ) គប្បីឃើញថា មានការរួមយកពួកវិនិបាតទាំងឡាយ មាននាងបុនព្វសុមាតាជាដើម ។

បទថា **វេហាសំ** ជាទុតិយាវិភត្តិក្នុងអត្ថនៃសត្តមីវិភត្តិ ប្រែថា ក្នុងអាកាស ឬក្នុងអច្ចន្តសំយោគ ប្រែថា អស់អាកាស ។ ពិតហើយ ព្រះចៅចក្រពត្តិ ទ្រង់ធ្វើចក្ករ័ត្នទុកខាងមុខ ស្ដេចហោះឡើងទៅចាកស្ថានទីនៅរបស់ព្រះអង្គឯង ធ្វើប្រទ-ក្សិណ ភ្នំសិនេរុផ្លូវអាកាសនោះឯង ហើយស្ដេចទៅកាន់ចក្រវាឡទាំងអស់ដូច្នេះ ។ បទថា **អស្សពន្ធា** បានដល់ ពួកអ្នកចិញ្ចឹមសេះនោះឯង គឺ ពួកដែលឲ្យបាយដំណើបដល់សេះទាំងឡាយ ។ ឈ្មោះថា **គោពន្ធា** ក៏ដោយន័យដូចគ្នានោះឯង ។

កាលនឹងអធិប្បាយឫទ្ធិដែលកើតឡើងព្រោះបុណ្យនៃបុគ្គលទាំងឡាយ មានព្រះចៅចក្រពត្តិជាដើម ឲ្យពិស្ដារ កាន់តែធ្វើឲ្យវែងពេកទៅ ព្រោះហេតុនោះ លោកអាចារ្យអ្នកសម្ដែងបុញ្ញវតោឥទ្ធិ ដោយលក្ខណៈសូម្បីពោលថា គុណវិសេស

ដែលសម្រេច ព្រោះបុញ្ញសម្ភារៈដែលដល់នូវភាពចាស់ក្លា ដូច្នេះហើយ ប្រាថ្នាសម្ដែងឫទ្ធិដែលកើតឡើងព្រោះបុណ្យនៃបុគ្គលអ្នកមានបុណ្យទាំងឡាយ មានជោតិកសេដ្ឋីជាដើមដោយឡែក ទើបពោលថា ក្នុងបណ្ដាបុគ្គលពួកនេះ ដូច្នេះជាដើម ក្នុងពាក្យទាំងនោះ ពាក្យថា **ភ្នំមាស** គឺ ភ្នំដែលជាមាសសុទ្ធ ។ បានឮថា ក្នុងទីដែលបានកាន់យកហើយ កាន់ហើយនៃមាសនោះ មិនប្រាកដព្រំដែន ។ ក្នុងបទថា **ឯកកសិតមត្តេ** ( ក្នុងស្ថានទីដែលភ្ជួរបានមួយគន្លង ) នេះ គន្លងនង្គ័លដែលទាក់ទងនឹងការភ្ជួរ ឈ្មោះថា **កសិត** ។ ឈ្មោះថា **តុម្ពំ** បានដល់ មួយនាឡិៗ ពាក្យថា **១៤ គន្លង** គឺ ១៤ គន្លងនង្គ័ល ។

ពាក្យថា **រាយវិជ្ជា** មានសេចក្ដីថា រីវិជ្ជា គឺ ឧបចារៈ(មន្តវិធី) ដែលខ្លួនបានធ្វើទុក មានវិជ្ជាគន្ធារីជាដើម បានដល់ ស្វាធ្យាយទៅតាមលំដាប់នៃបទស្វាធ្យាយមន្ត ។

ពាក្យថា **ព្រោះការប្រកបត្រូវ** គឺ ព្រោះការប្រកបដោយឧបាយ បានដល់ ព្រោះការប្រារព្ធដោយការដឹង ដែលប្រព្រឹត្តទៅអាចនឹងមានការសម្រេចប្រយោជន៍តាមដែលត្រូវការបាន ។ ពាក្យថា **ការងារនោះៗ** បានដល់ ការងារដែលគប្បីធ្វើឲ្យសម្រេចបានតាមដែលប្រាថ្នា ។ បទថា **ឯត្ថ ច** គឺ សូម្បីក្នុងនិទ្ទេសនៃឫទ្ធិទី ១០ ថា **តត្ថ តត្ថ សម្មាបយោគប្បច្ចយា ឥជ្ឈនដ្ឋេនឥទ្ធិ** នេះ ពាក្យថា ដូចព្រះបាលីនិទ្ទេសនៃឫទ្ធិប្រការមុនៗ គឺដូចព្រះបាលីនិទ្ទេសខមុនៗ មានសមាធិវិប្ផារឥទ្ធិជាដើមនោះឯង ។ ពាក្យថា **ដោយទាក់ទងនឹងការចាត់ក្បួនទ័ព មានក្បួនទ័ពបែបរូបរទេះជាដើម** មានការភ្ជាប់សេចក្ដីថា អំណាចពិសេសដែលបង្កើតឡើងដោយការទាក់ទងនឹងការរៀបក្បួនទ័ព មានក្បួនទ័ពបែបរូបរទេះ ក្បួនទ័ពបែបរូបកង់រថ ក្បួន

ទ័ពបែបរូបបទុមជាដើម។ ការរាប់និងការលេងតន្ត្រីជាដើម ឈ្មោះថា សិប្បកម្ម ។ ការព្យាបាលជំងឺជាដើម ឈ្មោះថា វេជ្ជកម្ម ។ វេទ ៣ មានឥរុវេទជាដើម ឈ្មោះថា ត្រៃវេទ ។

លោកអាចារ្យពោលថា ចំពោះអធិដ្ឋានាឥទ្ធិប៉ុណ្ណោះដែលមកក្នុងបទថា **ឥទ្ធិវិធាយ** នេះ ដូច្នេះ ព្រោះលោកកាន់យកអធិដ្ឋានាឥទ្ធិប៉ុណ្ណោះ ដោយពាក្យថា សូម្បីតែម្នាក់ ក៏និម្មិតច្រើននាក់បានជាដើម ។ ពាក្យថា **ក៏ក្នុងសេចក្តីនេះ** គឺ ក្នុងសេចក្តីដែលពោលដល់អានិសង្សនៃអភិញ្ញា ឬដែលពោលដល់ឥទ្ធិវិធនេះ ។

**វិធ**-ស័ព្ទ ក្នុងប្រយោគថា **ឯកវិធេន ញាណវត្ថុ** ( ញាណវត្ថុ ៦ ) ចំណែកជាដើម មានអត្ថថា **កោដ្ឋាស**-ចំណែក **វិធ**-ស័ព្ទក្នុងប្រយោគថា **វិវិធម្បិ សេនាព្យូហំ ទស្សេតិ** ( រមែងធ្វើឲ្យប្រាកដជាក្បួនទ័ពបែបផ្សេងៗ ) គ្នាខ្លះជាដើម មានអត្ថថា វិកប្ប ( កំណត់ ) , លោកអាចារ្យកាលនឹងសម្តែងថា អត្ថទាំងពីររមែងប្រើបាន ក្នុងបទថា **ឥទ្ធិវិធាយ** ដើម្បីឥទ្ធិវិធនេះ ទើបពោលថា ពាក្យថា **ដើម្បីឥទ្ធិវិធ** គឺ ដើម្បីឫទ្ធិមួយចំណែក ឬដើម្បីឫទ្ធិមួយបែប ដូច្នេះ ។ ពិតមែនឫទ្ធិជាចំណែកមួយក្នុងអភិញ្ញាទាំងឡាយ និងមានប្រភេទជាអនេក ដោយប្រភេទដែលពោលដល់ ។ ពាក្យថា **ដោយអំណាចប្រការដែលបានពោលមកហើយ** គឺ ដោយអំណាចប្រការ ១៤ និងប្រការ មានការតាំងមាំដោយប្រពៃជាដើម នៃការហ្វឹកហាត់ចិត្តដែលបាន ពោលមកហើយ ។ បទថា **ឥទ្ធិវិធាយ** នោះ ជាពាក្យឲ្យមានប្រយោជន៍ **ចតុត្ថីវិភត្តិ** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដើម្បីប្រយោជន៍ដល់ការសម្រេចឥទ្ធិវិធញ្ញាណដូច្នេះ ។ ពាក្យថា **ចេញចាកអារម្មណ៍ គឺកសិណ** នេះលោកអាចារ្យពោលទុកថា ព្រោះចិត្តដែលជាបាទនៃអភិញ្ញាដែល

មានកសិណជាអារម្មណ៍ និងបរិកម្មចិត្តថា មានការជាប់តជៀបស្មើគ្នាបាន ។ មិនបានពោលទុកព្រោះបរិកម្មចិត្តមានកសិណជាអារម្មណ៍ទេ ។ ពាក្យថា **បញ្ជូនទៅចំពោះមុខនៃឥទ្ធិវិធ** គឺ ធ្វើឲ្យប្រព្រឹត្តទៅដោយការៈដែលឆ្ពោះមុខតម្រង់ឥទ្ធិវិធដែលគប្បីធ្វើឲ្យសម្រេច ។ ក៏ការធ្វើបរិកម្មចិត្តឲ្យប្រព្រឹត្តទៅដោយន័យថា **សតំ ហោមិ** ( សូមឲ្យយើងចូរជាមនុស្ស ១០០ នាក់ ) ជាដើម យ៉ាងណា ឈ្មោះថាការបង្អោនបរិកម្មចិត្តនេះទៅ និងការបញ្ជូនទៅចំពោះមុខនៃឥទ្ធិវិធក៏ដូច្នោះ ការធ្វើឥទ្ធិវិធឲ្យឈមទៅដោយការធ្វើឲ្យប្រព្រឹត្តទៅដោយប្រការនោះឯង ជាការបង្អោនទៅក្នុងឥទ្ធិវិធនៃបរិកម្មចិត្តក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកពោលថា គឺ ធ្វើឲ្យបង្អោនទៅកាន់ឫទ្ធិដែលគប្បីសម្រេច ឲ្យឈមទៅចំពោះឫទ្ធិដែលគប្បីសម្រេចដូច្នេះ ។ លោកអាចារ្យកាលនឹងសម្ដែងថា ការបានទទួល និងការសម្ផស្ស ចាត់ជាបរិយាយនៃការសម្រេច ការធ្វើឲ្យជាក់ច្បាស់ក្នុងឥទ្ធិវិធនេះនោះឯង ដូច្នេះទើបពោលថា សេចក្ដីថា រមែងសម្រេចដូច្នេះ ។ បទថា **អស្ស** បានដល់ ឥទ្ធិវិធ ។ **បិ**-ស័ព្ទក្នុងបទថា **ឯកោបិ**-សូម្បីតែម្នាក់ មានអត្ថថា រួបរួម សំដៅយកការនិម្មិតជាច្រើននាក់ ដែលកំពុងនឹងពោលដល់ ។ ក៏ **បិ**-ស័ព្ទនៃបទនេះ ជាបដិយោគី (ប្រកបតែ ១ បទ)យ៉ាងនេះថា **ឯកោបិ ហុត្វា ពហុធា ហោតិ**-សូម្បីមនុស្សតែម្នាក់ក៏និម្មិតជាច្រើននាក់បាន ។ **ពហុធាបិ ហុត្វា ឯកោ ហោតិ**-សូម្បីជាច្រើននាក់ក៏និម្មិតឲ្យជាមនុស្សម្នាក់បាន ។ ឯព្រះយោគីនោះ កាលនិម្មិតមនុស្សជាច្រើននាក់ហើយ ការតាំងនៅក៏មានការចូលដល់ភាពជាមនុស្សម្នាក់ក្នុងចន្លោះនោះឯង ។ តែថា ការចូលដល់ភាពជាមនុស្សម្នាក់តាមសភាពរបស់ខ្លួន តាមការកំណត់កាលលោកមិនបានប្រាថ្នាយកក្នុងឥទ្ធិវិធនេះទេ ព្រោះមិនមែនជាការនិម្មិតនៃឫទ្ធិ ។ អាចារ្យ

ពួកខ្លះពោលថា សូម្បីប្រការនោះក៏ចាត់ថា ជាអានុភាពនៃឫទ្ធិដូចគ្នា ព្រោះសម្រេច ទាក់ទងនឹងការកំណត់កាលជាដើម ។ ពាក្យថា **ឈានទៅ** គឺ ឈានចូលទៅដោយញាណ ។ លោកអាចារ្យពោលដល់ព្រះយោគីអ្នកដឹងចិត្តដួងខ្លះហើយ ដឹងចិត្តដួងដទៃអំពីចិត្តត្រង់នោះដោយវៀរការបរិកម្មថា ចេញអំពីចិត្តទៅកាន់ចិត្ត ដូច្នេះ ព្រោះហេតុនោះ ទើបពោលថា សូម្បីដោយវៀរការសម្លឹងមើលហទយរូបដូច្នេះ ។ សេចក្តីពិតថា វិធីការមានការសម្លឹងមើលហទយរូបជាដើម លោកពោលទុកដោយទាក់ទងនឹងព្រះយោគីអ្នកជាអាទិកម្មិក គឺ ផ្តើមបំពេញ ។ ព្រោះហេតុនោះ ទើបពោលថា សូម្បីខនេះក៏សមពិត ដូច្នេះជាដើម ។ ពាក្យថា **ក្នុងភពណាមួយ** គឺ ក្នុងបញ្ចវោការភពក៏បាន សូម្បីក្នុងចតុវោការភពក៏បាន ។ ភិក្ខុឈ្មោះថា **អកតាភិនិវេសោ** ព្រោះអត្ថថា មិនបានធ្វើការសន្សំ ពោលគឺ ការបំពេញអភិញ្ញាទុក បានដល់ ទាក់ទងនឹងភិក្ខុអ្នកមិនបានធ្វើការសន្សំទុកនោះ មានសេចក្តីថា ទាក់ទងនឹងភិក្ខុអ្នកជាអាទិកម្មិកៈ , ពាក្យថា **កថានេះ** គឺ កថាស្តីអំពីការបរិកម្ម ដែលបានពោលទុកដោយពាក្យថា ពង្រីកអាលោកកសិណដូច្នេះជាដើម ។

ពាក្យថា **ចិត្តដ៏សេស** គឺ ដែលនៅសល់អំពីដែលបានពោលមកហើយ ។ លោកអាចារ្យប្រាប្ថាសម្តែងចិត្តដែលនៅសល់ ដែលបានពោលទុកដោយនៅមិនទាន់ចែកយ៉ាងនេះ ដោយការចែក ទើបពោលថា កុសល និងអព្យាកតចិត្តក្នុងភូមិ ៤ ឈ្មោះថា **វីតរាគំ** ( ចិត្តដែលប្រាសចាករាគៈ ) ដូច្នេះ ។ ពិតហើយ កុសល និងអព្យាកតចិត្តនោះ រមែងបាននូវភាពជាចិត្តដែលគួរនឹងហៅថា **វីតរាគំ** ព្រោះមិនមានការវង្វៀស ព្រោះការប្រកបជាមួយនឹងរាគៈ ព្រោះមានយោនិសោមនសិការជាបច្ច័យ មានយោនិសោមនសិការនោះជាហេតុជាដើម ។ សម្រាប់កុសលចិត្តដែល

នៅសល់ ៤ ដួង មិនមានភាពជាសរាគចិត្ត( ចិត្តដែលមានរាគៈឡើយ ) ព្រោះមិនមានការប្រកបជាមួយនឹងរាគៈ ហេតុនៃចិត្តដែលប្រព្រឹត្តទៅជាមួយនឹងរាគៈនោះគប្បីមានបាន ក៏ព្រោះជាចិត្តដែលមាននិមិត្តកំណត់ដោយរាគៈនោះ ព្រោះហេតុនោះក៏រមែងមិនមានភាពជាវីតរាគចិត្ត គឺ ចិត្តដែលប្រាសចាករាគៈឡើយ ព្រោះហេតុនោះ ទើបប្រពៃពិត ព្រោះភាពជាចិត្តដែលផុតហើយចាកទុក្ខៈ ព្រោះហេតុនោះលោកលើកបទថា **ឥទ្ធិវិសវិតាយ** ប្រែថា ដើម្បីការប្រសពអានិសង្សផ្សេងៗគ្នានៃឫទ្ធិ ។ ពាក្យថា **ដើម្បីភាពជាវសីនៃឫទ្ធិ** គឺដើម្បីភាពជាវសីដែលជាហេតុនាំមកនូវភាពជាវិប្បនិសន្ទិ គឺការចូលឈានបានឆាប់រហ័សជាដើមនៃឫទ្ធិ ។ ពាក្យថា **ដើម្បីភាពក្លៀវក្លានៃឫទ្ធិ** គឺដើម្បីភាពក្លៀវក្លាដោយល្អនៃឫទ្ធិ ព្រោះការដែលប្រាសចាកសង្កិលេសដោយការៈដែលនៅឆ្ងាយពីធម៌ ដែលជាបដិបក្ខ ។ លោកអាចារ្យធ្វើពាក្យជជីកសួរទុកក្នុងចិត្តថា ជាបឋមចតុត្ថជ្ឈានចាត់ជាភូមិនៃឫទ្ធិបាន ព្រោះព្រះយោគីត្រូវតាំងនៅក្នុងចតុត្ថជ្ឈាននោះ ហើយទើបធ្វើឲ្យសម្រេចបាន ។ តែថា ឈានក្រៅពីនេះចាត់ថាជាភូមិនៃឫទ្ធិបានយ៉ាងដូចម្ដេច ដូច្នេះហើយ ទើបពោលថា ម្យ៉ាងទៀត ក្នុងបណ្ដាឈានពួកនេះដូច្នេះជាដើម ។ ក្នុងបណ្ដាបទទាំងនោះ មានការភ្ជាប់សេចក្ដីថា **តីនិ ឈានានិ សម្ភារភូមិយោតិ វេទិតព្វានិ** គឺគប្បីជ្រាបថា ឈាន ៣ ជាសម្ភារភូមិ ។ មានពាក្យប្រកបសេចក្ដីតាមសមគួរថា ព្រោះការផ្សាយទៅនៃសុខក្នុងឈានទី ៣ ព្រោះការផ្សាយទៅនៃបីតិ និងព្រោះការផ្សាយទៅនៃសុខដែលជាហេតុ ក្នុងឈានទី ១ និងឈានទី ២ ។ ក៏ឈ្មោះថា ការផ្សាយទៅក្នុងទីនេះ បានដល់ ភាពស្រស់ស្អាតនៃនាមកាយដែលកើតរួមគ្នាដោយបច្ច័យ មានឈានប្បច្ច័យជាដើម ដោយអំណាចបីតិ និង សុខដ៏ល្អក្រៃលែង ព្រោះព្រះយោគាវចរបានអប់រំ

ឈានទុកល្អហើយ បានដល់ ភាវៈនៃរូបកាយត្រូវបណីតរូប មាននាមកាយនោះជាសមុដ្ឋាន ផ្សាយទៅដោយជុំវិញហើយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **បីតិ សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ** ប្រែថា ភិក្ខុនោះរមែងធ្វើកាយនេះៗឯង ឲ្យជ្រួតជ្រាបចំពោះមុខ ឲ្យជ្រាបទៅដោយជុំវិញ ឲ្យពេញប្រៀប ឲ្យផ្សាយទៅដោយជុំវិញដោយបីតិ និងសុខដែលកើតពីវិវេក ។ ដូច្នេះពាក្យថា **សុខ សញ្ញា** បានដល់ សញ្ញាដែលសហគតដោយសុខក្នុងឈាន ។ ពាក្យថា **លហុសញ្ញា** បានដល់ សញ្ញាដែលសហគតដោយលហុតា( ភាពស្រាលដែលជាចេតសិក ) សម្បយុត្តនឹងឈាននោះ ។ ពាក្យថា **ឈានចុះ** បានដល់ តាមចូលទៅ ពិតហើយ ព្រះយោគីកាលធ្វើសុខដែលសម្បយុត្តនឹងលហុតាដ៏មានភាពល្អក្រៃលែង ក្នុងឈានទាំងនោះឲ្យប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា ហាក់ដូចជាឈានចុះកាន់លហុតា ឬ សុខនោះដោយល្អ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលទុកយ៉ាងនេះ ។ លោកធ្វើនិទ្ទេស ( ពាក្យសម្តែងអធិប្បាយលហុតា និងសុខ ) ដោយមានសញ្ញា ។ ពិតហើយ លហុតាដែលសម្បយុត្តដោយឈានរមែងហាក់ដូចជាដល់ថ្នាក់ធ្វើឲ្យស្ទុះទៅក្នុងអាកាសបាន សូម្បីថា វៀរចាកឫទ្ធិ ។ ក្នុងទីនេះដោយស័ព្ទថា **លហុភាវ** គឺ លហុតានោះឯង គឺលោកកាន់យកមុទុភាវៈ គឺ មុទុតា( ភាពទន់ ) និងកម្មញ្ញភាវៈ គឺ កម្មញ្ញតា( ភាពគួរដល់ការងារ )ដែរ ។ ព្រោះហេតុនោះ ទើបលោកពោលថា ជាអ្នកមានកាយស្រាល ទន់ គួរដល់ការងារដូច្នេះ ។

ពាក្យថា **ដោយបរិយាយនេះ** គឺដោយបរិយាយនេះថា កាលព្រះយោគីអ្នកមាននាមកាយ និងរូបកាយដល់សុខ និងលហុភាវៈ គឺភាពស្រាល ដោយការចូល

ឈាន ៣ មានការហ៊ឹកហាត់ចិត្ត ចតុត្ថជ្ឈានរមែងប្រព្រឹត្តទៅព្រម ដើម្បីការបាន ចំពោះនូវឫទ្ធិដោយងាយតែម្តង ដូច្នេះ ។ ពិតមែន សម្ភារភូមិ ជាទីតាំងនៃបកតិភូមិ ដូចផ្នែកក្របក្រៅនៃកំផែង ជាទីតាំងដែលហ៊ុមជុំវិញនៃកំផែង ដូច្នេះឯង ។

ក្នុងឥទ្ធិបាទនិទ្ទេស មានអធិប្បាយថា បទថា **ចត្តារោ** ( ៤ ) ជាពាក្យកំណត់ចំនួន ។ ពាក្យថា **ឥទ្ធិបាទ** មានសេចក្តីថា ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា ជាទីសម្រេច គឺជាទីសន្សំឫទ្ធិឲ្យកើតឡើង ។ ម្យ៉ាងទៀត ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា ជាហេតុឲ្យសត្វទាំងឡាយសម្រេច គឺជាអ្នកចម្រើនរុងរឿងដល់ភាពខ្ពង់ខ្ពស់ ។ ដោយន័យដំបូង **បាទ** គឺ **ឥទ្ធិ** ព្រោះហេតុនោះ ទើបឈ្មោះថា **ឥទ្ធិបាទ** , សេចក្តីថា ចំណែកនៃឥទ្ធិដោយន័យទី ២ ឈ្មោះថា **ឥទ្ធិបាទ** ព្រោះអត្ថថា ជាបាទនៃឥទ្ធិ ពាក្យថា **ជាបាទ** គឺជាទីតាំង , សេចក្តីថា ជាឧបាយឲ្យសម្រេច ។ ពិតហើយ សត្វទាំងឡាយរមែងដល់ គឺ រមែងសម្រេចឥទ្ធិ ពោលគឺគុណវិសេសដ៏ខ្ពស់ៗឡើងទៅបាន ដោយឧបាយសម្រេចនោះ ។ នេះជាន័យក្នុងអដ្ឋកថា ។ ក្នុងអដ្ឋកថាពោលថា **ឥទ្ធិ-ស័ព្ទ** មានសេចក្តីថា **កត្តុ** ( អ្នកធ្វើ ) ន័យដំបូង មានសេចក្តីថា **ករណ** ( ការធ្វើ , ហេតុធ្វើ ) ជាសេចក្តីទី ២ ។ **បាទ-ស័ព្ទ** មានសេចក្តីថា ជាករណៈតែម្យ៉ាងប៉ុណ្ណោះ ។ លោកពោលដល់វត្ថុដែលគប្បីដល់នោះឯងថា ឥទ្ធិ មិនបានពោលដល់ការសម្រេចថា ឥទ្ធិ , ក៏ឥទ្ធិដែលគប្បីដល់មិនមានអធិករណៈស្មើគ្នានឹង( បាទ )ដែលជាហេតុធ្វើការដល់ទេ ព្រោះហេតុនោះ អ្នកណាៗ ទើបមិនអាចពោលថា “ **ឥទ្ធិ** នោះឯងជា **បាទ** ទើបឈ្មោះថា **ឥទ្ធិបាទ** ” ដូច្នេះបានដោយន័យដំបូង ។ យ៉ាងនោះដូចគ្នា **ឥទ្ធិ** ពោលគឺ ឥទ្ធិដែលគប្បីធ្វើឲ្យសម្រេច ព្រោះករណៈ គឺ ការធ្វើសេចក្តីសម្រេចនោះឯង គប្បីជាឥទ្ធិដែលគប្បីដល់ ព្រោះ

ករណៈគឺការធ្វើដល់ ព្រោះហេតុនោះ ករណៈទាំងពីរនឹងមានភាពជាអធិករណៈមិនស្មើគ្នារកមិនបាន ព្រោះហេតុនោះ នរណាៗ ទើបមិនអាចពោលថា “ **បាទ** នៃឫទ្ធិឈ្មោះថា **ឥទ្ធិបាទ** ” ដូច្នេះបាន ដោយន័យទី ២ ។ ព្រោះដូច្នោះ ពាក្យសមាសមានអធិករណៈស្មើគ្នា( ថា **ឥទ្ធិឯវ បាទោ ឥទ្ធិបាទោ** )ដោយន័យដំបូង ពាក្យសមាសមានពាក្យជាឆដ្ឋីវិភត្តិថា **ឥទ្ធិយាបាទោ ឥទ្ធិបាទោ** ដោយន័យទី ២ រមែងប្រើមិនបាន ពាក្យសមាសថា **ឥទ្ធិយា បាទោ ឥទ្ធិបាទោ** ដោយន័យដំបូង , **ឥទ្ធិឯវបាទោ ឥទ្ធិបាទោ** ដោយន័យទី ២ ដូច្នេះ ឬ សូម្បីតាមដែលបានពោលទុករមែងជាការត្រឹមត្រូវ ព្រោះភាពដែល( **បាទ** ) ជាចំណែកដែលសម្រេច និងជាឧបាយធ្វើឲ្យសម្រេច ។

**សមាធិ** ឈ្មោះថា មានឆន្ទៈជាហេតុ ដោយទាក់ទងនឹងឆន្ទៈដែលជាចំណែកខាងដើម ។ ឈ្មោះថា មានឆន្ទៈក្រៃលែង ក៏ទាក់ទងនឹងឆន្ទៈដែលប្រកបរួមគ្នា ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបភាវៈដ៏ក្រៃលែងនៃឆន្ទៈដែលកើតរួមគ្នា ដោយទាក់ទងនឹងអភិសង្ខារ ( ការចាត់ចែង )ទុកក្នុងកាលមុននោះឯង ។ ម្យ៉ាងទៀត តាមព្រះបាលីថា **ឆន្ទញ្ចេ ភិក្ខុអធិបតីករិត្វា លភតិ សមាធឹ , លភតិ ចិត្តស្សេកគ្គតំ , អយំ វុច្ចតិ ឆន្ទសមាធិ** “ បើថាភិក្ខុធ្វើឆន្ទៈឲ្យជាធំ បានសមាធិ បានឯកគ្គតានៃចិត្តដែរ **សមាធិ** នេះហៅថា **ឆន្ទសមាធិ** ” ដូច្នេះ នេះបណ្ឌិតគប្បីជ្រាបបានថាត្រាស់ទុកជាពាក្យសមាស លុប **អធិបតិ**-ស័ព្ទថា **ឆន្ទាធិបតិសមាធិ**-ឆន្ទសមាធិ គឺ សមាធិដែលមានឆន្ទៈជាធំ ឈ្មោះថា **ឆន្ទសមាធិ** ។ ចំណែកក្នុងអដ្ឋកថាលោកពោលទុកដោយទាក់ទងនឹងការសម្តែងអត្ថនៃ **អធិបតី**-ស័ព្ទថា **ឆន្ទហេតុកោ ឆន្ទាធិកោ វា សមាធិ** គឺ សមាធិដែលមានឆន្ទៈជាហេតុ ឬ មានឆន្ទៈក្រៃលែង

ឈ្មោះថា **ឆន្ទសមាធិ** ។ ព្រោះហេតុនោះ ទើបលោកពោលថា " **ព្រោះធ្វើឆន្ទៈឲ្យជាធំ** " ដូច្នេះជាដើម ។ ពាក្យថា **សង្ខារដែលជាប្រធាន** លោកអាចារ្យជាច្រើនពោលថា បានដល់សង្ខារដែលជាការព្យាយាម ។ ក៏ស័ព្ទថា **បធាន** មានសេចក្ដីថា ហាម ឬ( បដិសេធ ) សង្ខតសង្ខារ( សង្ខារ គឺ សង្ខតធម៌ ) ។ ន័យម្យ៉ាងទៀត ឈ្មោះថា **សង្ខារ** ព្រោះអត្ថថាតាក់តែងគុណវិសេសនោះៗ បានដល់ ការព្យាយាមទាំងអស់ ។ ស័ព្ទថា **បធាន** មានសេចក្ដីថា ហាមសេចក្ដីព្យាយាមយ៉ាងដទៃអំពីការព្យាយាមដែលឲ្យសម្រេចកិច្ច ៤ យ៉ាង ក្នុងបណ្ដាការព្យាយាមទាំងអស់នោះ ។ ឈ្មោះថាជា **ប្រធាន** មានន័យថា ជាវត្ថុប្រសើរ ។ លោកធ្វើនិទ្ទេសជាពហុវចនៈទុក ព្រោះបំណងយកវីរិយៈដែលមាន ៤ យ៉ាង ។ ចំណែកលោកអាចារ្យពោលដល់ន័យនៃពាក្យថា ឥទ្ធិបាទណាមានការកាន់យកន័យត្រង់ ( ពាក្យថា ) **បាទ** ( បាទ ) មានសេចក្ដីថា ជាឧបាយដោយអំណាចនៃការប្រកប ពាក្យសមាសយ៉ាងនេះថា **ឥទ្ធិយា បាទោ ឥទ្ធិបាទោ** ( បាទនៃឫទ្ធិឈ្មោះថា **ឥទ្ធិបាទ** )ដូច្នេះ , គប្បីជ្រាបសេចក្ដីនៃពាក្យថា **ឥទ្ធិបាទ** នោះថា លោកពោលសំដៅយកសេចក្ដីដែល **ឥទ្ធិបាទ** ដែលជាចំណែកខាងដើមនៃការបានមកនូវឥទ្ធិ ជាឥទ្ធិដែលជាកត្តុ គឺអ្នកធ្វើ អ្នកសម្រេច និងជាករណៈ ( ការធ្វើ ) ឬហេតុធ្វើ ម្យ៉ាងទៀត ព្រោះមកក្នុងព្រះអភិធម្មហើយ ដោយពាក្យថា **ឆន្ទិទ្ធិបាទោ** ជាដើម ទើបជាការពោលសំដៅយក **ពុទ្ធិ** ( ការដឹង ) ដែលគប្បីធ្វើឲ្យសម្រេចបាន ដោយឥទ្ធិបាទទាំងឡាយមានឆន្ទៈជាដើម ជាឥទ្ធិដែលជាកត្តុ និងភាពដែលធម៌ទាំងឡាយ មានឆន្ទៈជាដើម ជាឥទ្ធិដែលជាករណៈ ។

ក្នុងវីរិយិទ្ធិបាទ វីរិយៈមកហើយដល់ពីរវារៈ ក្នុងបទថា **វីរិយសមាធិបធាន**

**សង្ខារសមន្នាគតំ** ( ដែលដល់ព្រមដោយវីរិយសមាធិ និងបធានសង្ខារ ) ។ ក្នុងពាក្យនោះ វីរិយៈដំបូង ជាវីរិយៈដែលធ្វើសមាធិឲ្យពិសេសទៅថា **វីរិយាធិបតិសមាធិ** វីរិយសមាធិ គឺសមាធិដែលមានវីរិយៈជាអធិបតី( ជាធំ )ឈ្មោះថា **វីរិយសមាធិ** ដូច្នេះ ។ វីរិយៈទី ២ ជាវីរិយៈសម្តែងដល់អង្គដែលដល់ព្រម ។ ពិតហើយធម៌ ២ យ៉ាង គឺសមាធិ ដែលហៅថា វីរិយសមាធិ និងបធានសង្ខារនោះឯង ជាអង្គដែលដល់ព្រមក្នុងឥទ្ធិបាទទាំងពួង ។ ធម៌ទាំងឡាយ មានឆន្ទៈជាដើម ជាអង្គដែលធ្វើសមាធិឲ្យពិសេសទៅ, ចំណែកបធានសង្ខារលោកក៏បានធ្វើឲ្យពិសេសទៅហើយ ដោយពាក្យ **បធាន** នោះឯង, មិនមែនដោយធម៌ទាំងឡាយមានឆន្ទៈជាដើម ព្រោះហេតុនោះ ក្នុងទីនេះភាពជាអធិបតីនៃវីរិយៈ ទើបលោកមិនបានពោលទុកសម្រាប់បធានសង្ខារ ។ ម្យ៉ាងទៀត លោកពោលដល់វីរិយៈដែលតាំងនៅ ធ្វើសមាធិឲ្យពិសេសទៅនោះឯង ទុកដោយពាក្យថា **បធានសង្ខារ** ដោយទាក់ទងនឹងអង្គដែលដល់ព្រម ព្រោះហេតុនោះ ទើបពោលថា លោកមិនបានពោលដល់ការព្រមដោយវីរិយៈទាំងពីរទេ គឺពោលការដល់ព្រមដោយវីរយៈម្យ៉ាងប៉ុណ្ណោះឯង ។ តែព្រោះហេតុសមាធិមានភាពពិសេសដោយធម៌ទាំងឡាយ មានឆន្ទៈជាដើម និងបធានសង្ខារ ព្រមទាំងធម៌ដ៏សេសទាំងឡាយ ក៏មានការសម្បយុត្តនឹងសមាធិនោះដ៏ពិសេសយ៉ាងនោះៗឯង , ដូច្នោះ ទើបលោកពោលដល់ឥទ្ធិបាទទុក ៤ យ៉ាង ដោយអំណាចនៃធម៌ទាំងឡាយ( មានឆន្ទៈជាដើម ) ដែលធ្វើសមាធិឲ្យពិសេស ។ ក៏ការៈដែលធ្វើឲ្យពិសេសនៃធម៌ទាំងឡាយ មានឆន្ទៈជាដើមរមែងមាន បានដោយទាក់ទងនឹងភាពជាទីតាំងនៃសមាធិនោះៗ ។

ដោយពាក្យថា ន័យម្យ៉ាងទៀតជាដើម លោកពោលដល់ធម៌ទាំងឡាយមាន

ឆន្ទៈជាដើម ជាឥទ្ធិបាទ ដោយសេចក្តីថា ជាឧបាយ សូម្បីកាល **បាទ**-ស័ព្ទ មានសេចក្តីថា ជាទីអាស្រ័យ ។ ព្រោះហេតុនោះឯង ក្នុងឧត្តរមូលកាជនីយបទ ក្នុងព្រះអភិធម្ម ទើបត្រាស់សេចក្តីជាឥទ្ធិបាទទុក សម្រាប់ធម៌ មានឆន្ទៈជាដើម ប៉ុណ្ណោះ ដោយពាក្យថា **ចត្តារោ ឥទ្ធិបាទា ឆន្ទិទ្ធិបាទោ** - ឥទ្ធិបាទមាន ៤ គឺ ឆន្ទិទ្ធិបាទ ដូច្នេះជាដើម ។ និងក្នុងបញ្ហា **បុច្ឆក** សូម្បីទ្រង់ធ្វើឧទ្ទេសទុកដោយពាក្យថា **ចត្តារោ ឥទ្ធិបាទា ឥធ ភិក្ខុ ឆន្ទសមាធិ** ( ឥទ្ធិបាទមាន ៤ ភិក្ខុក្នុងព្រះសាសនានេះ រមែងចម្រើនឥទ្ធិបាទដែលដល់ព្រមដោយសមាធិ និងបធានសង្ខារ ) ដូច្នេះជាដើម ហើយទ្រង់ក៏បានចែកសេចក្តីជាកុសលជាដើមនៃធម៌ មានឆន្ទៈជាដើម នោះឯងទុកទៀត ។ ពិតហើយ ពាក្យសម្តែងដល់ឥទ្ធិបាទ ដែលជាទីអាស្រ័យ ក្នុងព្រះសូត្រ និងព្រះអភិធម្ម ទ្រង់ធ្វើទុកក៏ដើម្បីសម្តែងដល់ឥទ្ធិបាទដែលជាឧបាយ នោះឯង ជា ៤ យ៉ាង ( នៃឥទ្ធិបាទ ) មិនមានដោយប្រការដទៃទេ ដូច្នេះ ។

ពាក្យថា **បទ ៨ មានឆន្ទៈជាដើម** បានដល់ បទ ៨ មានឆន្ទៈជាដើមយ៉ាងនេះ គឺឆន្ទសមាធិ វីរិយសមាធិ ចិត្តសមាធិ វិមំសាសមាធិ ។ ក៏ក្នុងបទ ៨ ពួកនេះ សមាធិក្នុងស្ថានទាំង ៤ ក៏គឺសមាធិនោះឯងក៏ពិត សូម្បីយ៉ាងនោះ សមាធិដែលប្រព្រឹត្តទៅរួមគ្នានឹងឆន្ទៈ ដោយសេចក្តីប្រាថ្នានឹងធ្វើឥទ្ធិឲ្យកើតឡើងប៉ុណ្ណោះ រមែងប្រព្រឹត្តទៅព្រមដើម្បីការបានមកនូវឥទ្ធិ មិនមែនសមាធិតែម្យ៉ាងប៉ុណ្ណោះទេ ។ សូម្បីសមាធិដ៏សេស មានវីរិយសមាធិជាដើម ក៏យ៉ាងនេះដូចគ្នា ។ ព្រោះដូច្នោះ ធម៌ ៨ យ៉ាង គឺ សមាធិ ៤ យ៉ាង ពួកនេះ ដែលប្រព្រឹត្តទៅរួមគ្នានឹងឆន្ទៈជាដើម និងធម៌ ៤ យ៉ាង មានឆន្ទៈជាដើម ទើបលោកពោលថា **បទ** ព្រោះអត្ថថា រមែងប្រព្រឹត្តទៅ គឺ ជាហេតុឲ្យសម្រេចឥទ្ធិ ។ ឬព្រោះអត្ថថា រមែងទៅ គឺ រមែងដល់

ព្រមដើម្បីការបានមកនូវឫទ្ធិនោះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា រមែងប្រព្រឹត្តទៅព្រមដើម្បីការបានមកនូវឫទ្ធិ ដូច្នេះ ។ ចំណែកក្នុងព្រះបាលីថា **ឆន្ទោ ន សមាធិ** ( ឆន្ទៈមិនមែនសមាធិ ) ដូច្នេះជាដើមឯណា សូម្បីថា ធម៌ទាំងឡាយ មានឆន្ទៈជាដើម ដែលប្រព្រឹត្តទៅព្រមនឹងសមាធិនោះឯង រមែងធ្វើឥទ្ធិនោះឲ្យសម្រេចក៏ដោយ សូម្បីដូច្នេះ ពាក្យនោះក៏ជាពាក្យសម្ដែងដល់ភាវៈដែលធម៌ពួកនោះជាបទមួយផ្នែក ។ អធិប្បាយថា ឈ្មោះថា ប្រកបព្រមគ្នានោះឯង ក៏គឺ មិនបានប្រកបព្រមគ្នា ។ បទថា **និយុត្តោវ** បានដល់ ប្រកបព្រមគ្នា នោះឯងមិនមែនបែកគ្នា ។

បទថា **អនោនតំ** គឺ មិនមែនចិត្តដែលធ្លាក់ចុះ , សេចក្ដីថា មិនរួញរាព្រោះវិរិយៈផ្គងទុកហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា មិនញាប់ញ័រព្រោះកោសជ្ជៈ ដូច្នេះ , សេចក្ដីមិនញាប់ញ័រព្រោះកោសជ្ជៈជាហេតុ ។ ចិត្តដែលតោងឡើងឈ្មោះថា **ឧន្នតំ** បានដល់ ចិត្តរាយមាយ ។ ពិតមែន **ឧន្នតំ** ឈ្មោះថា **អនុន្នតំ** បានដល់ ចិត្តដែលមិនរសាត់រសាយ មានសេចក្ដីថា ចិត្តដែលតាំងមាំដោយប្រពៃហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា មិនញាប់ញ័រព្រោះឧទ្ធច្ចៈដូច្នេះ ។ ចិត្តដែលបង្អោនទៅដោយអំណាចការជាប់ជំពាក់ ឈ្មោះថា **អភិនតំ**, មិនមែន **អភិនតំ** ឈ្មោះថា **អនភិនតំ** ( ចិត្តដែលមិនរួបរឹត ) បានដល់ចិត្តដែលមិនត្រេកអរ ។ ចិត្តដែលបង្អោនទៅដោយអំណាចនៃការគេចចេញ ឈ្មោះថា **អបនតំ** បានដល់ ចិត្តដែលជាមុខ ដោយអំណាចនៃសេចក្ដីក្រោធ ។ មិនមែន **អបនតំ** ឈ្មោះថា **អនបនតំ**-មិនស្ទុះចេញ បានដល់ ចិត្តដែលមិនប្រទូសរ៉ាយ ។ ចិត្តដែលមិនអាស្រ័យដោយភាពជាទីអាស្រ័យនៃទិដ្ឋិថា " យើង របស់យើង "

ព្រោះហេតុនោះ ទើបឈ្មោះថា **អនិស្សិតំ** , **ចិត្ត** ឈ្មោះថា **អប្បដិពទ្ធំ** ព្រោះអត្ថថា មិនជាប់ជំពាក់ដោយអំណាចនៃឆន្ទរាគៈ ។ ឈ្មោះថា **រាគ** គឺ ត្រឹមតែជាតម្រេកម្យ៉ាង តែឈ្មោះថា **ឆន្ទរាគ** គឺជាកិលេសយ៉ាងក្រាស់ ។ ពិតហើយ អារម្មណ៍សូម្បីតាំងនៅទីឆ្ងាយ ចិត្តនេះក៏នៅជាប់ជំពាក់បាន ។ បទថា **វិប្បមុត្តំ** ប្រែថា រួចផុតដោយវិសេស ។ លោកអាចារ្យពោលថា មិនញាប់ញ័រព្រោះកាមរាគៈ ដូច្នេះ ព្រោះឈានជាបដិបក្ខចំពោះកាមរាគៈ ។ បទថា **វិសំយុត្តំ** បានដល់ ប្រាសចាកសង្កិលេស ឬថា មិនប្រកបដោយយោគៈទាំង ៤ ។ **ចិត្ត** ឈ្មោះថា ធ្វើឲ្យមិនមានព្រំដែន ដោយព្រំដែន គឺកិលេស បានដល់ ចិត្តដែលបដិបត្តិហើយ ដោយប្រការដែលមិនមានព្រំដែន គឺ កិលេសសូម្បីត្រឹមតែមួយ ។ បទថា **ឯកត្តគតំ** គឺ ចូលដល់ភាពមានអារម្មណ៍តែមួយ បានដល់ តាំងមាំដោយប្រពៃពិតប្រាកដនោះឯង ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា មិនញាប់ញ័រព្រោះកិលេសដែលមានសភាវៈផ្សេងៗ គឺ ព្រោះកិលេសដែលមានសភាវៈប្លែកផ្សេងគ្នា ។

ពាក្យថា **ក៏សេចក្តីប្រការនេះ** គឺថា ចិត្តនេះមិនមានការញាប់ញ័រ ព្រោះកោសជ្ជៈជាដើម ត្រូវការសម្រេចហើយ ព្រោះការដល់ភាពមិនញាប់ញ័រ លោកបានសម្តែងទុកដោយទាក់ទងនឹងពាក្យប្រកាស ។ ពាក្យថា **លោកក៏នៅពោលទុកទៀត** គឺ លោកក៏នៅពោលទុកទៀត ដើម្បីសម្តែងភាពជាមូលថា ពួកនេះឈ្មោះថាមូលដូច្នេះ ដោយទាក់ទងនឹងការសម្តែង ភូមិ បាទ និងបទនៃឫទ្ធិ ។ ពាក្យថា **ន័យមុន** គឺ ន័យដែលបានសម្តែងទុកជា ៦ យ៉ាង ក្នុងពេលមុនដោយពាក្យថា ព្រោះសទ្ធាជាដើមគ្រប់គ្រង ដូច្នេះជាដើម ។ ពាក្យថា **ន័យនេះ** គឺន័យដែលបានសម្តែងទុកជា ១៦ យ៉ាង ក្នុងឥឡូវនេះ ។ កាលបានសម្តែងន័យព្រះសូត្រ និង

ន័យបដិសម្ភិទាមគ្គហើយ ក៏រមែងមិនមានការវង្វេងក្នុងន័យទាំងពីរនោះ ការមិនបានសម្តែងទុក និងមិនមានការវង្វេងវង្វាន់មិនមាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដើម្បីភាពមិនវង្វេងក្នុងន័យទាំងពីរដូច្នេះ ។

ពាក្យថា **អធិដ្ឋានដោយញាណ** លោកលើកបទដែលខ្លួនឯងបានពោលទុកក្នុងខាងដើម ក្នុងពាក្យថា **កថំ បនាយំ ឯវំ ហោតិ** ( រមែងជាច្រើននាក់យ៉ាងនេះ បានយ៉ាងដូចម្តេច ) ដូច្នេះនេះ ដើម្បីសម្តែងវិធីអធិដ្ឋាន ។ អាចារ្យពួកខ្លះពោលថា ក្នុងពាក្យថា ចូលឈានដែលជាបាទនៃអភិញ្ញាហើយចេញ ដូច្នេះនេះ បានដល់ ចូលឈាន ៤ តាមលំដាប់ ហើយចេញចាកចតុត្ថជ្ឈាន ដូច្នេះ ពាក្យនោះ មិនត្រឹមត្រូវ ព្រោះថា ការហ្វឹកហាត់ចិត្ត មានការចូលឈានបានតាមដែលត្រូវការជាប្រយោជន៍ និងចតុត្ថជ្ឈានប៉ុណ្ណោះជាបាទនៃអភិញ្ញាបាន ។ មិនមែនឈានក្រៅពីនេះទេ ។ ពាក្យថា **ធ្វើបរិកម្ម** មានសេចក្តីថា ចេញចាកឈានដែលជាបាទហើយ ក៏មានការធ្វើបរិកម្មក្នុងអារម្មណ៍នេះ គឺមានការជាប់ដោយកាមាវចរចិត្ត ដោយន័យថា សូមឲ្យយើងចូរជាមនុស្ស ១០០ នាក់ ដូច្នេះជាដើមនោះឯងនិងមានអាវជ្ជនៈ គឺ ការនឹកដល់ដោយប្រការនោះ ។ **បិ**-ស័ព្ទក្នុងបទថា **ទុតិយម្បិ** ( ជាលើកទី ២ ) មានអត្ថថា បន្ថែម , ដោយ **បិ**-ស័ព្ទនោះ លោកសម្តែងប្រការនេះថា ( ជាលើក ទី ៣ ) សូម្បីក្រៃលែងជាងនោះដូច្នេះ ។ ពិតមែន ការចម្រើនឈាន រមែងមានបានដោយប្រការណា សូម្បីការចម្រើនអភិញ្ញា ក៏រមែងមានបានដោយប្រការនោះ ។ សូម្បីពាក្យថា **មួយវារៈ ពីរវារៈនេះ** គប្បីឃើញថាត្រឹមតែជាឧទាហរណ៍ ។ ពាក្យថា **មាននិមិត្តជាអារម្មណ៍** គឺមានបដិភាគនិមិត្តជាអារម្មណ៍ ។ ក្នុងពាក្យថា **បរិកម្មចិត្តមានមនុស្ស ១០០ នាក់ជាអារម្មណ៍នេះ** គប្បី

ឃើញបរិកម្មចិត្តតែ ១ ដួង ជាចិត្តដែលមានមនុស្ស ១០០ នាក់ ជាអារម្មណ៍ ព្រោះប្រព្រឹត្តទៅថា ដូចជា មនុស្ស ១០០ នាក់ , សូម្បីក្នុងពាក្យថា មានមនុស្ស ១០០០ នាក់ជាអារម្មណ៍នេះ ក៏មានន័យនេះឯង ។ ពាក្យថា **ដោយទាក់ទងជារូបព្រហ្ម** គឺ ទាក់ទងនឹងរូបពណ៌ដែលខ្លួនគិតឡើង ។ ពាក្យថា **មិនមែនដោយទាក់ទងនឹងបញ្ញត្តិ** គឺ មិនទាក់ទងនឹងសត្វបញ្ញត្តិ ។ ពាក្យថា **នោះ** គឺ អធិដ្ឋានចិត្ត ។ សព្ទថា **ឥវ** ក្នុងបទថា **អប្បនាចិត្តមិវ**-ដូចគ្នានឹងអប្បនាចិត្ត លោកពោលទុកព្រោះអភិញ្ញាចិត្ត ដូចការកើតឡើងជាលើកដំបូងនៃឈានចិត្ត មិនពោលទុកព្រោះអភិញ្ញាចិត្តនោះជាអប្បនា ។ បទថា **រូបាវចរចតុត្ថជ្ឈានិកំ** គឺជាចិត្តដែលមានរូបាវចរចតុត្ថជ្ឈាន បានដល់ ជាចិត្តដែលសម្បយុត្តគ្នានឹងរូបាវចរចតុត្ថជ្ឈាននោះ ។

លោកអាចារ្យធ្វើពាក្យជញ្ជឹងសួរទុកក្នុងចិត្តថា ប្រសិនបើដូច្នោះ ពាក្យនិយាយក្នុងបករណបដិសម្ភិទាមគ្គ ដែលថាកាលនឹកហើយ ក៏អធិដ្ឋានដោយញាណដូច្នេះ នឹងមានបានយ៉ាងដូចម្ដេច ដូច្នេះហើយ ទើបពោលថា **យម្បិហិ** ជាដើម ។ បទថា **តត្រាបិ** គឺ សូម្បីក្នុងបដិសម្ភិទាមគ្គ ។ បទថា **អាវជ្ជតិ**( នឹក ) សេចក្ដីថា បាទថា **ពហុកំ អាវជ្ជតិ** គឺ នឹកឲ្យជាមនុស្សច្រើន នេះលោកពោលទុកដោយទាក់ទងនឹងការបរិកម្មនោះឯង មិនមែនពោលទុកតាមរយៈអាវជ្ជនៈទេ ។ ពាក្យថា **កាលនឹកហើយក៏អធិដ្ឋានដោយញាណ** លោកពោលទុកដោយទាក់ទងនឹងអភិញ្ញាញាណ គឺ មិនបានពោលទុកដោយទាក់ទងនឹងញាណដែលសម្បយុត្តនឹងបរិកម្មចិត្ត ឬ កាមាវចរញាណយ៉ាងដទៃទេ ។ ព្រោះថា ញាណដែលសម្បយុត្តនឹងបរិកម្មចិត្ត ឬ កាមាវចរញាណយ៉ាងដទៃនោះ មិនមានអានុភាពធំដូច្នោះទេ ។ ពាក្យថា **ព្រោះ**

**ដូច្នោះ** គឺ ព្រោះហេតុដែលមានការអធិដ្ឋាន រមែងមានបានដោយអំណាចនៃអភិញ្ញាញាណ ដែលមកដល់អប្បនានោះប៉ុណ្ណោះ ។ ដូច្នោះ លោកអាចារ្យកាលនឹងសម្តែងថា នេះជាលំដាប់នៃការអធិដ្ឋានដូច្នេះ ទើបពោលថា ភិក្ខុរមែងនឹកឲ្យជាមនុស្សច្រើនដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សន្និដ្ឋាបនវសេន** គឺ ទាក់ទងនឹងជាការធ្វើឲ្យសម្រេច ។

ពាក្យថា **ដើម្បីសម្តែងកាយសក្ខី** សេចក្តីថា មិនមែនត្រឹមតែជាពាក្យនិយាយតែម្យ៉ាងប៉ុណ្ណោះទេ ។ តែថា ដើម្បីសម្តែងសក្ខី ដែលឈ្មោះថា កាយសក្ខី ព្រោះបានធ្វើផលនេះឲ្យជាក់ច្បាស់ បានដោយកាយរបស់ខ្លួននេះ ។

បទថា **កោកនុទំ** ជាវិសេសនរបស់បទថា **បទុមំ** ដូចបទថា **កោកាសក** ដូច្នេះ ។ បានឮថា ផ្កាបទុមកោកនុទនោះ ជាផ្កាបទុមដែលមានត្របកផ្កាច្រើនដល់ព្រមដោយពណ៌ និងមានក្លិនក្រអូបហួសនឹងប្រៀបបាន ។ បទថា **អំពីព្រឹក** គឺតាំងអំពីព្រលឹម ។ សេចក្តីក្នុងព្រះគាថានេះ មានដូច្នេះថា ប្រៀបដូចជាផ្កាបទុមដែលហៅថា កោកនុទបានៈ គឺ រីកអំពីព្រឹក ក្នុងពេលដែលព្រះអាទិត្យរះឡើងក៏នៅមិនទាន់អស់ក្លិន រុងរឿងយ៉ាងណា សូមលោកចូរសរសើរព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានក្លិនក្រអូប ដោយក្លិនព្រះសរីរៈ និងដោយក្លិន គឺ ព្រះគុណទ្រង់មានព្រះនាមថា **អង្គីរស** ព្រោះទ្រង់មានពន្លឺផ្លៀលផ្លាត់ ចេញអំពីព្រះអវយវៈទាំងឡាយ ដូចព្រះអាទិត្យដែលបញ្ចេញពន្លឺដោយតេជៈរបស់ខ្លួន ក្នុងកណ្តាលវេហាស៍ ក្នុងរដូវក្តៅដូច្នេះ ។

ពាក្យថា **ជាមនុស្សអកព្វ** អធិប្បាយថា ព្រះសាសនានេះ មានបដិបត្តិជាសារៈ , ម្យ៉ាងទៀត បដិបត្តិមានបរិយត្តិជាមូល , ក៏ខ្លួនលោកដែលជាអ្នកមិនអាច

រៀនបរិយត្តិបាន ព្រោះដូច្នោះ ទើបឈ្មោះថាជាការអេកព្វ ។ ឈ្មោះថាមិនជាមនុស្ស ព្រោះការដែលមានធុរៈ គឺការអប់រំនោះឯង ជាប្រធាន ។

ពាក្យថា **ភិក្ខុ** ត្រាស់ទុកជាពាក្យហៅអ្នកជាបព្វជិត ឬត្រាស់ទុកអាស្រ័យភិក្ខុភាវៈនៃបុគ្គលអ្នកមានប្រក្រតីធ្វើឲ្យកើត ដូចជាពាក្យថា **អគមារាជគហំ ពុទ្ធោ** ( ព្រះពុទ្ធស្ដេចទៅកាន់ក្រុងរាជគ្រឹះ ) ដូច្នេះ ។ ពាក្យថា **សំពត់មួយផ្ទាំង** បានដល់ សំពត់មួយផ្ទាំងដ៏ស្អាតល្អ ។ សំពត់ឈ្មោះថា **រជោហរណំ** ព្រោះអត្ថថា នាំធូលីទៅ ឬជូតធូលី ។ ឈ្មោះថា **ទ្រង់និម្មិតប្រគល់ឲ្យទៅ** ព្រោះក្នុងកាលមុន ព្រះថេរៈបានធ្វើអធិការ គឺ បុញ្ញាធិការទុកហើយក្នុងសំពត់នោះ ។ ពិតយ៉ាងនោះ ព្រះថេរៈកាលស្ទាបអង្អែលសំពត់ទៅដោយឧបាយឃើញថា នេះជាទោសរបស់អត្តភាព បានមកនូវអសុភសញ្ញា និងអនិច្ចសញ្ញាហើយ ក៏ញ៉ាំងញាណចុះក្នុងខន្ធ ៥ ដោយការកំណត់នាមរូបជាដើម ចម្រើនវិបស្សនាទៅតាមលំដាប់ញាណ មានញាណដែលពិចារណាកលាបៈជាដើម ធ្វើវិបស្សនាឲ្យដល់ទីជិតនៃអនុលោមញាណ និងគោត្រភូញាណ តាមលំដាប់នៃញាណ មានឧទយព្វយញ្ញាណជាដើម ។ គាថា ដែលទ្រង់ភាសិតទុក ដែលមានការបញ្ចេញឱភាស គឺ ពន្លឺជាខាងដើម ឈ្មោះថា ឱភាសគាថា ។

ក្នុងធម្មវិន័យរបស់ព្រះអរិយៈ **រាគៈ** ហៅថា ធូលី មិនហៅលំអងថា ធូលីទេ ព្រោះហេតុអ្វី ព្រោះរាគៈប៉ុណ្ណោះធ្វើចិត្តឲ្យសៅហ្មង ។ ពាក្យថា **ធូលីនេះ** ជាឈ្មោះហៅ រាគៈ ។ ពាក្យថា **ធូលីនេះ** បានដល់ ធូលី ពោលគឺរាគៈនេះ ។ ពាក្យថា ព្រោះលះ គឺព្រោះហេតុដែលលះបានដោយវិសេស ដោយអរហត្តមគ្គ ។ ពាក្យថា **ពួកគេរមែងជាបណ្ឌិត** គឺ ពួកគេអ្នកលះបាន រមែងជាបណ្ឌិតនៅក្នុងសាសនា

របស់ព្រះមានព្រះភាគ អ្នកប្រាសចាកធូលី គឺ ពួកអ្នកលះធូលី មានរាគៈជាដើម បានហើយដោយប្រការទាំងពួង ។ ពិតយ៉ាងនោះមែន ទ្រង់ត្រាស់ទុកថា :

**ព្រះមហេសីជាម្ចាស់ត្រាស់ទុកថា សត្វទាំងឡាយ រមែងសៅហ្មងព្រោះចិត្តសៅហ្មង រមែងបរិសុទ្ធព្រោះចិត្តផូរផង់ ដូច្នេះ ។**

កាលបានកាន់យកអភិញ្ញា ៦ ហើយ ដោយសព្ទថា **ឆឡភិញ្ញា** លោកអាចារ្យកាលនឹងរួមយកព្រះអរិយមគ្គទាំងឡាយ ដែលបានចម្រើនហើយចូលគ្នាជាមួយផល និងព្រះនិព្វាន ព្រោះជាអនុត្តរធម៌ស្មើគ្នាទើបពោលថា លោកុត្តរធម៌ ៩ ដូច្នេះ ។

លោកអាចារ្យពោលដល់ព្រះមានព្រះភាគទ្រង់ដាក់ព្រះហស្តទុក ដោយអាការដែលបិទបាត្រថា **ហត្ថំ បិទហិ** ដូច្នេះ ។ ម្យ៉ាងទៀត បទថា **ហត្ថំ** ជាទុតិយាវិភត្តិក្នុងអត្ថនៃតតិយាវិភត្តិ មានសេចក្តីថា **ហត្ថេន បិទហិ** គឺ ទ្រង់ប្រើព្រះហស្តបិទ ។

បទថា **សហស្សក្ខត្តុំ** បានដល់ ១.០០០ ចំណែក ។ លោកអាចារ្យប្រាថ្នាសម្តែងសេចក្តីនេះថា ពិតហើយ ព្រះថេរៈកាលនិម្មិតឡើង ១.០០០ ចំណែក ដោយចិត្តដួងមួយប៉ុណ្ណោះ ក៏រមែងដូចជា និម្មិតដល់ ១.០០០ លើក ។ សូម្បីមិនមានសេចក្តីព្យាយាមធ្វើ ព្រោះបានសម្រេចផលនោះហើយ ទើបពោលថា **សហស្សក្ខត្តុំ** ដូច្នេះ ។ ពាក្យថា **ក្នុងសួនអម្ពវ័ន** គឺក្នុងវិហារដែលគេសាងទុកក្នុងចម្ការស្វាយ ។ បទថា **រម្មេ** ប្រែថា គួររីករាយ ។ មានពាក្យប្រកបសេចក្តីថា **យាវ កាលប្បវេទនំ , តាវ និសីទតិ** ( អង្គុយនៅរហូតដល់គេប្រាប់វេលា ) ។

ពាក្យថា **មិនបានកំណត់** គឺ មិនបានធ្វើការកំណត់ទុកដោយចំណែកនៃពណ៌ ចំណែកនៃសរីរៈ **បរិក្ខារ** កិរិយាដ៏ប្លែក ៗគ្នា ជាដើម ។ ពាក្យថា **មានវណ្ណរូប**

**ប្លែកផ្សេងគ្នា** គឺមានអាការផ្សេងៗ គ្នា បានដល់ មានបែបយ៉ាងផ្សេងៗ គ្នា ដោយទាក់ទងនឹងពណ៌ជាដើម តាមដែលបានពោលមកហើយ ។ ពាក្យថា **មានសក់ចំរុះ** គឺ មានសក់ចំរុះដោយសក់ស្កូវ ។ ពាក្យថា **មានចីវរ ក្រហមពាក់កណ្តាលយ៉ាងនេះ** គឺ មានពណ៌ណាមួយ ក្នុងបណ្តាចីវរដែលមានពណ៌ ក្រហមពាក់កណ្តាល ពណ៌លឿងពាក់កណ្តាលជាដើម ។ ការសូត្រព្រះបាលីដែល ទាក់ទងនឹងការដឹងសេចក្តីដោយអំណាចនៃបទ ឈ្មោះថា **បទភាណ** ។ ការពោលធម៌ ដោយទាក់ទងជាបរិកថាជាដើម ឈ្មោះថា **ធម្មកថា** ។ ការសូត្រ គឺ ការបន្លឺសំឡេងសូត្រព្រះសូត្រជាដើមដោយប្រែសំឡេង ឈ្មោះថា **សរភញ្ញ** ។ ពាក្យថា **សូម្បីយ៉ាងដទៃ** គឺឲ្យមានប្រការផ្សេងៗ មានខ្ពស់ ទាប ស្គម ធាត់ជាដើម សូម្បីផ្សេងអំពីអាការដែលបានពោលហើយ ។ ពាក្យថា **រមែងកើតជាបុគ្គលតាមដែលអ្នកមានឫទ្ធិប្រាថ្នា** គឺ អ្នកមានឫទ្ធិប្រាថ្នាហើយដោយប្រការណាៗ ក៏រមែងកើតជាបុគ្គលមានប្រការនោះៗឯង ។ ពិតហើយ លោកអ្នកមានឫទ្ធិប្រាថ្នាអាការផ្សេងៗគ្នាទុកចំនួនប៉ុនណា ទាក់ទងនឹងរូបរាងជាដើមក្នុងបុគ្គលនិមិត្តពួកនោះ ។ បុគ្គលនិមិត្តពួកនោះ ក៏រមែងជាអ្នកមានអាការផ្សេងៗ គ្នាចំនួនប៉ុណ្ណោះដែរ ។ អធិដ្ឋានចិត្តដូងមួយប៉ុណ្ណោះ រមែងប្រព្រឹត្តទៅធ្វើបុគ្គលទាំងនោះ សូម្បីដែលមានអាការប្លែកគ្នាជាច្រើនយ៉ាងនោះ ទាក់ទងនឹងរូបរាងជាដើមឲ្យជាអារម្មណ៍ ។ នេះជាអានុភាពនៃបរិកម្មចិត្តនោះ , ដូចចេតនាតែមួយប៉ុណ្ណោះ រមែងធ្វើអត្តភាពដែលមានអាការប្លែកៗ គ្នាឲ្យកើតឡើងបាន ដូច្នោះ ។ បើមានពាក្យសួរថា ក្នុងការធ្វើអត្តភាពឲ្យកើតឡើងនោះ ការប្រាថ្នាកពរមែងជាបច្ច័យនៃការផ្សេងគ្នារបស់កម្ម ។ ក៏កម្ម និង វិបាកជារឿងអចិន្តេយ្យ ( មិនគួរគិត ) ។ បណ្ឌិតគប្បីកាន់យកសេចក្តី

ថាសូម្បីក្នុងការនិម្មិតជាមនុស្សច្រើននេះ បរិកម្មចិត្តរមែងជាបច្ច័យនៃការផ្សេងគ្នា ។ និងឥទ្ធិវិស័យ គឺវិស័យនៃឫទ្ធិ ក៏ជារឿងអចិន្តេយ្យដូច្នេះចុះ ។ ពាក្យថា **ក៏មានន័យដូច្នេះ** មានសេចក្តីថា ន័យក្នុងការអធិដ្ឋានដូចបានពោលមកហើយ ក្នុងការនិម្មិតជាមនុស្សច្រើនដោយពាក្យថា ចូលឈានដែលជាបាទនៃអភិញ្ញាជាដើមនេះឯណា ក្នុងការអធិដ្ឋានសូម្បីដែលនៅសល់ក៏មានន័យដូច្នេះដែរ ។

លោកអាចារ្យ កាលសម្តែងដោយការចង្អុលបង្ហាញដល់សេចក្តីមិនប្លែកគ្នាយ៉ាងនេះហើយ ប្រាថ្នាសម្តែងការដែលប្លែកគ្នាដោយសភាវៈដែលមានប្រាកដ ទើបពោលថា ចំណែកដែលពោលតទៅនេះ ជាប្រការប្លែកគ្នាដូច្នេះជាដើម ។ ក្នុងបទទាំងនោះ មានការភ្ជាប់សេចក្តីថា **ឥមិនា ភិក្ខុនា ឥច្ឆន្តេន** ( ភិក្ខុរូបនោះកាលប្រាថ្នា ) ។ ពាក្យថា **ស្គាល់យើងច្បាស់** គឺ ស្គាល់យើងច្បាស់ថា ជាអ្នកមានឫទ្ធិ ពាក្យថា **ក្នុងវាងនោះឯង** គឺខាងក្នុងពេលដែលបានកំណត់ទុកនោះឯង ។ ពាក្យថា **គប្បីចូលឈានដែលជាបាទជាដើម** លោកពោលទុកដើម្បីសម្តែងអាការដែលធ្វើបរិកម្ម ចំណែកពាក្យដទៃ លោកបានបើកបង្ហាញទុកដោយការចង្អុលបង្ហាញនោះឯង ។ ពាក្យថា **កាលមិនធ្វើយ៉ាងនេះ** គឺកាលមិនធ្វើការអធិដ្ឋានក្នុងវាងថាសូមឲ្យយើងជាមនុស្សម្នាក់ចុះ ។ ដោយពាក្យថា **ដោយអំណាចនៃពេលវេលាតាមដែលបានកំណត់ទុក** នេះលោកសម្តែងថា ឯភិក្ខុកាលធ្វើការអធិដ្ឋានដោយន័យថាសូមឲ្យយើងជាមនុស្ស ១០០ នាក់ជាដើម ក៏គប្បីធ្វើដោយអំណាចការកំណត់ពេលវេលាទុកនោះឯង ។ ឈ្មោះថា នឹងត្រឡប់ជាមនុស្សម្នាក់បានខ្លួនឯង ក៏ព្រោះបានរំងាប់ការអធិដ្ឋានទៅហើយ ។ ក៏ក្នុងការត្រឡប់ជាមនុស្សម្នាក់នេះ លោកអ្នកមានឫទ្ធិរមែងជាអារម្មណ៍ ទាក់ទងនឹងរូបរាងជាដើមនៃបរិកម្មចិត្ត និងអធិដ្ឋានចិត្តខ្លួនឯង

តែម្យ៉ាង ។ លោកអាចារ្យទាំងឡាយពោលថា ក្នុងបណ្ដាចិត្តទាំងនោះ បរិកម្មចិត្តទាំងឡាយ ជាចិត្តដែលមានអារម្មណ៍ជាសន្តតិបច្ចុប្បន្ន ។ អធិដ្ឋានចិត្ត ជាចិត្តមានអារម្មណ៍ដែលកំពុងប្រព្រឹត្តទៅនៅក្នុងបច្ចុប្បន្ន ព្រោះការអធិដ្ឋានមានត្រឹមតែ ១ ខណៈចិត្តប៉ុណ្ណោះ ។

ការសម្ព័ន្ធ ឬការភ្ជាប់សេចក្ដីបទថា **អាវិភាវំ** ចូលនឹង **ហោតិ-ស័ព្ទ** ដែលបានពោលទុកក្នុងខាងក្រោយ រមែងមិនត្រឹមត្រូវ ព្រោះលោកពោលទុកដោយទាក់ទងជាមួយទុតិយាវិភត្តិ ។ ការសម្ព័ន្ធចូលនឹង **គច្ឆតិ-ស័ព្ទ** ដែលកំពុងពោលដល់ក៏មិនត្រឹមត្រូវដូចគ្នា ព្រោះលោកប្រាថ្នាអាវិភាវៈនៃខ្លួន និងអ្នកដទៃ ក៏នាមបទ ជាបទដែលសំដៅដល់កិរិយាបទ ព្រោះហេតុនោះ លោកអាចារ្យទើបប្រកបចូលទុកនឹង **ករោតិ-ស័ព្ទ** ដែលមានសេចក្ដីជាកិរិយាសាមញ្ញ ពោលថា **អាវិភាវំ ករោតិ** ( ធ្វើអាវិភាវៈ ) ។ សូម្បីក្នុងបទថា **តិរោភាវំ** នេះ ក៏មានន័យនេះដូចគ្នា ។ លោកអាចារ្យសំដៅយកពាក្យជញ្ជីងសួរ ប្រសិនបើយ៉ាងនេះ ពាក្យដែលលោកពោលទុកក្នុងបករណបដិសម្ភិទាមគ្គនោះ តើដូចម្ដេច ដូច្នេះ ពោលថា **ឥទមេវ ហិ** ជាដើម ។ ក្នុងបដិសម្ភិទាមគ្គ អាវិភាវៈជាដើម មកហើយដោយពាក្យថា **អាវិភាវន្តិ កេនចិ អនាវដំ ហោតិ** ( បទថា **អាវិភាវំ** បានដល់ ជាវត្ថុដែលមិនមានអ្វីរាំង ដូច្នេះក៏ពិត សូម្បីពាក្យនោះ ព្រះសារីបុត្តត្ថេរក៏បានពោលសំដៅយកការធ្វើអាវិភាវៈ និងការធ្វើតិរោភាវៈដូច្នេះឯង ។ សូម្បីបទដ៏សេស ក៏ជាពាក្យវេវចនៈរបស់បទថា **អាវិភាវំ** ជាដើមនោះដែរ ។ ពាក្យថា **ការងងឹត** បានដល់ ការងងឹតក្នុងពេលកណ្ដាលអាធ្រាត ឬ ការងងឹតដែលប្រព្រឹត្តទៅក្នុងគុហាជាដើម សូម្បីក្នុងពេលថ្ងៃត្រង់ ។ ពាក្យថា **វត្ថុដែលត្រូវបិទបាំងទុក** បានដល់ ត្រូវជញ្ជាំង

និងបន្ទះទ្វារជាដើមបិទបាំងទុក ។ ពាក្យថា **វត្ថុដែលនៅមិនទាន់ដល់គន្លង** គឺមិនមែនវត្ថុដែលដល់គន្លង ព្រោះភាពដែលនៅឆ្ងាយ និងព្រោះភាពដ៏ល្អិតក្រៃលែងជាដើម ។ ពាក្យថា **ភិក្ខុនេះ** គឺ ភិក្ខុអ្នកមានឫទ្ធិ ។ បណ្ឌិតគប្បីប្រកបពាក្យពោលប្តូរវិភត្តិទៅថា **បដិច្ឆន្នោបិ ទូរេ ឋិតោបិ អត្តា វា បរេ វា យថា ទិស្សន្តិ** ( ភិក្ខុអ្នកប្រាថ្នាធ្វើខ្លួន ឬអ្នកដទៃ តាមប្រការដែលខ្លួន ឬអ្នកដទៃត្រូវបិទបាំងក្តី ឈរ នៅទីឆ្ងាយក្តី គេនៅអាចឃើញបាន ដូច្នេះចុះ ។ បទថា **អាលោកជាតំ** បានដល់ ជាទីភ្លឺស្វាង ឬ ជាទីកើតនៃពន្លឺភ្លឺស្វាង ។

ពាក្យថា **បាដិហារិយ៍ប្រការនេះ** លោកពោលដល់អាវិភាវបាដិហារិយ៍ ។ លោកអាចារ្យកាលសួរដល់បុគ្គលអ្នកជាកាយសក្ខី ( ប្រចក្សច្បាស់ )ក្នុងបាដិហារិយ៍ប្រការនោះថា អ្នកណាធ្លាប់ធ្វើដូច្នេះហើយ កាលនឹងសម្តែងថា ព្រះសាស្តាទ្រង់ជាកាយសក្ខី ដូច្នេះទើបពោលឆ្លើយថា **ព្រះមានព្រះភាគ** ហើយពោលថា សេចក្តីពិត គឺព្រះមានព្រះភាគដូច្នេះជាដើម ដើម្បីបើកបង្ហាញសេចក្តីនោះ ។ គប្បីមានការនាំពាក្យនិយាយមកសម្ពន្ធគ្នាថា **សាវត្ថិវាសិកេ បស្សន្តិ** ( នឹងមើលឃើញក្រុងសាវត្ថីបាន ) គប្បីមានការនាំពាក្យនិយាយមកសម្ពន្ធយ៉ាងនោះដូចគ្នាថា **យាវ អវីចឹ ទស្សេតិ** ( ធ្វើឲ្យឃើញទៅរហូតដល់អវិចី ) ។ កាលទ្រង់ញែកវិមានថ្នាក់ទាបៗដែលនៅក្នុងអាកាស ដែលទ្រវិមានថ្នាក់ខ្ពស់ៗ អាកាសដែលប្រព្រឹត្តទៅក្នុងទីនោះ ក៏ឈ្មោះថា **ត្រូវបើក** ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ទ្រង់បើកអាកាស ដូច្នេះ ។

ពាក្យថា **សេចក្តីប្រការនេះ** គឺ ព្រះសាស្តាទ្រង់ធ្វើអាវិភាវបាដិហារិយ៍ ។ ការនឹកដល់បដិបទារបស់ព្រះពុទ្ធអង្គមុន ៗ រមែងមានដើម្បីការរក្សាទុកនូវព្រះពុទ្ធ-

ប្រពៃណី ។ ពាក្យថា **ទ្រង់ប្រើព្រះបាទម្ខាងជាដើម** ជាពាក្យសំដៅដល់ការឈាន ទៅ ៣ ជំហាន ។ ឈ្មោះថា **ប្រទានន័យ** គឺទ្រង់ប្រទានគន្លងការសួច្បតាមទំនងនៃន័យ ។

ប្អូនតូចរបស់អនាថបិណ្ឌិកសេដ្ឋី ឈ្មោះថា ចូឡអនាថបិណ្ឌិក ។ ពាក្យថា **បើកកន្ទុំសិនេរុ** គឺ បើកភ្នំសិនេរុនោះ ធ្វើឲ្យមានរូបដែលពួកបរិស័ទអាចឃើញបានតែម្តង ។ បទថា **នំ** បានដល់ ភ្នំសិនេរុ ។

បាដិហារិយ៍ មានការធ្វើឱកាសលោក ដែលរាប់បានច្រើនសែន និងសត្វលោកអ្នកអាស្រ័យនៅក្នុងឱកាសលោកទាំងនោះ ឲ្យបើកជាវាល ឈ្មោះថា **លោកវិវរណ** គឺការបើកលោក ។ ពាក្យថា **មហាព្រហ្ម** បានដល់ សហម្បតីព្រហ្ម ។

ព្រះធម្មទិន្នត្ថេរធ្វើឲ្យភ័យខ្លាចដោយភ័យក្នុងនរកថា អ្នកទាំងឡាយចូរមើលផលនៃអបណ្ណកប្បដិបទាចុះ ដូច្នេះជាដើម ប្រលោមចិត្តដោយសុខក្នុងស្ថានសួគ៌ដោយន័យនៃអនុបុព្វិកថារបស់ព្រះសាស្ដា តែមិនមែនដោយការធ្វើការបង្អោនចិត្តទៅក្នុងស្ថានសួគ៌សម្បត្តិឲ្យកើតទេ ។

ក្នុងការធ្វើអាវិភាវៈ ភិក្ខុគប្បីចូលអាលោកកសិណ ដើម្បីនិម្មិតពន្លឺ យ៉ាងណា , ក្នុងការធ្វើតិរោភាវៈ ក៏គប្បីចូលនីលកសិណដើម្បីនិម្មិតភាពងងឹតក៏ដូច្នោះ។ ការធ្វើតិរោភាវៈនេះ មិនបានមកដោយជាសភាវៈ មាននៅប្រចាំក្នុងព្រះបាលីក៏ពិតទោះដូច្នោះក៏ឈ្មោះថា មកហើយដោយអត្ថ ដោយពាក្យពោលថា **វិវដំ អាវដំ** គឺ បើកបង្ហាញ , ត្រូវរាំងជាដើម ។ ម្យ៉ាងទៀត អត្ថនេះ លោកពោលហើយថាអាលោកកសិណទាក់ទងក្នុងឱទាតកសិណ ដូច្នេះ ។ បទថា **អន្ធការំ** បានដល់ដែលមានភាពងងឹត ។

- ២៩៤ - មហាដីកា ឥទ្ធិវិធនិទ្ទេស ឫទ្ធិ១០យ៉ាង

ពាក្យថា **ភិក្ខុដ៏សេស** បានដល់ ភិក្ខុទាំងឡាយ មានព្រះឥន្ទិយត្ថេរជាដើម។ ឈ្មោះថា **ប្រាកដ** ព្រោះអត្ថថា មានលោកអ្នកមានឫទ្ធិប្រាកដ ។ **បាដិហារិយ** នោះផង ជា **បាកដ** ផង ព្រោះហេតុនោះ ទើបឈ្មោះថា **បាកដបាដិហារិយ** ។ ឈ្មោះថា **អបាកដ** ព្រោះអត្ថថា ដែលលោកអ្នកមានឫទ្ធិមិនប្រាកដ , **បាដិហារិយ** នោះផង ជា **អបាកដ** ផង ព្រោះហេតុនោះ ទើបឈ្មោះថា **អបាកដបាដិហារិយ** ។ ពិតហើយ លោកអ្នកមានឫទ្ធិនោះឯង មានសេចក្ដីផ្សេងគ្នាដោយភាពជា **បាកដ** គឺអ្នកប្រាកដ និង **អបាកដ** គឺអ្នកមិនប្រាកដ មិនមែនបាដិហារិយ៍ក៏ទេ ។ ព្រោះថា បាដិហារិយ៍ដែលមិនប្រាកដនោះមិនមាន ។

ពាក្យថា **ឧត្តរិមនុស្សធម៌** មានសេចក្ដីថា “ ធម៌ គឺ កុសលកម្មបថ ១០ លោកហៅថា មនុស្សធម៌ ” បានដល់ ធម៌ដែលក្រៃលែងជាងមនុស្សធម៌នោះ ។ បាដិហារិយ៍ដែលរាប់ថាជាឥទ្ធិ ឈ្មោះថា ឥទ្ធិបាដិហារិយ៍ ។ បទថា **អាលិន្ទេ**-របៀង ឬ ត្រង់រានហាល ។ ពាក្យថា **ចូរធ្វើរាបស្មើ** គឺ ចូរពង្រាប ។ ពាក្យថា **ឥទ្ធាភិសង្ខារ** បានដល់ ប្រយោគនៃឫទ្ធិ( វិធីប្រកបឫទ្ធិ ) ។ បទថា **អភិសង្ខារេសិ** គឺបានតាក់តែង មានសេចក្ដីថា បានធ្វើ ។ ពាក្យថា **ប្រហោងរន្ធកូទ្វារ** គឺ រន្ធកូនសោរ ។ ពាក្យថា **ប្រហោងគន្លឹះ** គឺ ប្រហោងសន្ទះទ្វារទាំងពីរ ។

ពាក្យថា **អ្នកបំបាំងខ្លួន** គឺត្រូវការបំបាំងកាយ ។ ព្រះមានព្រះភាគទ្រង់ធ្វើឲ្យពួកព្រហ្មមិនអាចបំបាំងខ្លួនបាន ហើយព្រះអង្គឯងក៏ទ្រង់ជាអ្នកបំបាំងព្រះវរកាយបាន ឲ្យដល់នូវការៈដែលមិនជាគន្លងនៃពួកព្រហ្ម និងគណៈព្រហ្មអ្នកសម្លឹងមើលនៅទីនោះ ទ្រង់ត្រិះរិះថា គណៈព្រហ្មចូរកុំមានឱកាសនិយាយបាន យ៉ាងនេះថា ពួក យើងមិនអាចនឹងជ្រាបបានថា ព្រះសមណគោតមមាន ឬមិនមាន ក្នុងស្ថានទី

នេះដូច្នេះឡើយ ហើយទើបត្រាស់ព្រះគាថាថា **ភវេវាហំ** ជាដើមនេះ ។ ក្នុងព្រះគាថានោះ សេចក្តីថា **ភវេវាហំ ភយំ ទិស្វា** យើងបានឃើញភ័យក្នុងភព មានសេចក្តីថា យើងបានឃើញភ័យផ្សេងៗ មាន ជាតិ ជរា ជាដើមក្នុងភព គឺ ក្នុងសង្សារហើយ ។ ប្រការថា **ភវញ្ច វិភវេសិនំ** និងភព ដែលស្វែងរកតែវិភព មានសេចក្តីថា នឹងបានឃើញភព គឺ សត្វទាំងបីយ៉ាង មានកាមភពជាដើមនេះ , ដែលស្វែងរក គឺស្រាវជ្រាវ ទាំងស្វែងរកតែវិភពក្នុងភពនោះឯងរឿយៗ ។ បទថា **ភវំនាភិវទិ**-ទើបមិនរីករាយក្នុងភព គឺទើបមិនត្រេកអរ បានដល់ មិនកាន់យកភពណាៗ ដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ សេចក្តីថា **នន្ទិញ្ច ន ឧបាទិយឹ** គឺ មិនចូលដល់នន្ទិ គឺ មិនចូលដល់ភវតណ្ហា មានសេចក្តីថា មិនប្រកាន់ ។

ពាក្យថា **មិនទើសទាក់** គឺ មិនទើសទាក់នៅត្រង់ជញ្ជាំងជាដើមណាៗ គឺ អាចទម្លុះធ្លុងទៅបាន ។ ពាក្យថា **នឹកដល់... ធ្វើបរិកម្ម** សេចក្តីថា ភិក្ខុអ្នកមានឫទ្ធិនឹកដល់ស្ថានទីដែលត្រូវការនឹងទម្លុះធ្លុងទៅផ្នែកខាងក្រោយ ហើយក៏ធ្វើបរិកម្មយ៉ាងនេះថា ចូរជាអាកាសៗ ដូច្នេះ ព្រោះសំដៅដល់ **បាការោ** គឺ កំផែង និង **បព្វតោ** គឺ ភ្នំ ទើបលោកពោលទុកដោយទាក់ទាងនឹងបុំលិង្គថា **សុសិរោ** គឺ ប្រហោង , **ឆិទ្ទោ** គឺ រន្ធ ។ ចន្លោះទទេដែលប្រព្រឹត្តទៅផ្នែកខាងលើ ឈ្មោះថា **សុសិរំ**-ប្រហោង ។ ដែលប្រព្រឹត្តទៅផ្នែកខាងទទឹង ឈ្មោះថា **ឆិទ្ទំ**-រន្ធ ។

ពាក្យថា **ព្រោះបានធ្វើបរិកម្មទុកក្នុងកសិណណាមួយ** មានសេចក្តីថា ស្ថានទីមានកំផែងជាដើម ភិក្ខុគប្បីអធិដ្ឋានថា សូមឲ្យជាអាកាសដូច្នេះបាន ក៏ព្រោះបានចូលឈាន ធ្វើបរិកម្មទុកក្នុងកសិណណាមួយ មានបឋវីកសិណជាដើម ។ លោកអាចារ្យពោលដល់ហេតុក្នុងការអធិដ្ឋានឲ្យជាអាកាសនោះថា ភាពជំនាញក្នុងសមា-

បត្តិ ៨ នោះ ឯងរមែងជាប្រមាណដូច្នេះ ព្រោះដូច្នោះ ភិក្ខុត្រូវការឲ្យជាវត្ថុណាៗ ក៏នឹងជាវត្ថុនោះៗឯង ។ ដោយពាក្យនេះថា គឺ ព្រះតិបិដកចូឡកយត្ថេរពោល អធិប្បាយថា ក្នុងការផុសឡើង និងការមុជចុះក្នុងផែនដីមិនត្រូវការ ការចូលអាបោកសិណតែម្យ៉ាងទេ ។ ក្នុងការនិម្មិតផែនដីឡើងក្នុងស្ថានទីមានទឹកជាដើម មិនត្រូវការចូលបឋវីកសិណតែម្យ៉ាងទេ ។ បទថា **ឯតំ** មានសេចក្ដីថា ការចូលអាកាសកសិណក្នុងពេលធ្វើបាដិហារិយ៍ ដោយទម្លុះទៅក្រៅជញ្ជាំងជាដើមនេះ ចាំបាច់ត្រូវពោលដល់ជាពិតប្រាកដ ព្រោះជារបស់សមគួរ ។ ព្រោះធ្វើអធិប្បាយយ៉ាង នេះ ការៈមានអាទិថា សូម្បីមនុស្សម្នាក់ ក៏និម្មិតជាច្រើននាក់បាន ដោយអំណាចនៃបឋវីកសិណ ទើបត្រូវប្រើបានដូចគ្នានឹងពាក្យថា ធ្វើវត្ថុដែលបិទបាំងឲ្យបង្ហាញឡើង ដោយអំណាចនៃអាកាសកសិណ ។ ពាក្យណាលោកពោលទុកក្នុងបកិណ្ណកន័យថា និម្មិតផែនដីឡើងក្នុងអាកាសខ្លះ ក្នុងទឹកខ្លះ ហើយសម្រេចការទៅដោយជើង ដូច្នេះ ជាដើម សូម្បីពាក្យនោះ ក៏ប្រើបាន ។

លោកអាចារ្យពោលថា ទោសមិនមានទេ ដូច្នេះ ដោយមានសេចក្ដីសំដៅយកអត្ថថា កាលចូលឈានហើយអធិដ្ឋានម្ដងទៀត ឈ្មោះថា ជាការធ្វើឲ្យមាំទាំ ដូចរបស់ ដែលចងទុកពីរផ្នត់ ឈ្មោះថា ត្រូវចងទុកដោយល្អ ដូច្នេះហើយ ប្រាថ្នាសម្ដែងសេចក្ដីដែលមិនមានប្រយោជន៍ ដោយការចូលឈានហើយអធិដ្ឋានម្ដងទៀតនោះ ទើបពោលថា **បុន សមាបជ្ជិត្វា** ដូច្នេះជាដើម ។ ពាក្យថា **ព្រោះភិក្ខុនេះបានអធិដ្ឋានទុកហើយ ក៏រមែងទៅជាអាកាស** មានសេចក្ដីថា បើគប្បីមានវត្ថុណាៗ មានភ្នំប្រាកដឡើងជាដើមក្នុងរវាងដូច្នោះ វត្ថុណាៗ មានភ្នំជាដើមនោះ ក៏រមែងទៅជាអាកាស ព្រោះភិក្ខុបានអធិដ្ឋានទុកមុនហើយថា សូមឲ្យជាអាកាសចុះ

លោកអាចារ្យពោលថា **អន្ត្តរា** ជាដើម ( សេចក្តីថា ក្តុំក្តី... នឹងផុសឡើងមក ក្នុងរវាង ) ដើម្បីសម្តែងថា សូម្បីប្រការដែលពោលនេះ ក៏ត្រឹមតែជាការកំណត់ ដែលមិនមានហេតុផល ។ ការប្រាកដវត្ថុណាៗ មានក្តុំជាដើមដូច្នោះ មិនមាន ឡើយ ។

ពាក្យថា **កំណត់ទី** គឺ កំណត់ស្ថានទីតាមដែលត្រូវការដោយញាណ ។ បទ ថា **តត្រ** គឺ ក្នុងការអធិដ្ឋានឲ្យផែនដីជាទឹកនោះ តទៅនេះគឺព្រះបាលីដែលបង្ហាញ ខបដិបត្តិតាមដែលបានពោលមកហើយ ។ សូម្បីក្នុងទីដែលមកហើយថា **តត្រាយំ** បាលីខាងមុខ បណ្ឌិតក៏គប្បីជ្រាបតាមសេចក្តីនេះចុះ ។

ពាក្យថា **ភិក្ខុនោះ** គឺភិក្ខុអ្នកមានឫទ្ធិក្នុងពេលដែលអធិដ្ឋាន ភិក្ខុរមែងធ្វើការ កំណត់កាលទុកហើយ ទើបអធិដ្ឋាន ព្រោះហេតុនោះ ទើបលោកពោលថា តែល្មម កន្លងកាលដែលបានកំណត់ទុក ដូច្នេះជាដើម ។ ឈ្មោះថា **ទឹកតាមប្រក្រតី** បាន ដល់ ទឹកដែលមិនបាននិម្មិតឡើង ។ ពាក្យថា **ទឹកដែលខុសគ្នា** គប្បីឃើញថា ជា ទឹកដែលភិក្ខុអ្នកជាន់ៗ ហើយក៏មិនលិច ដោយអំណាចនៃការប្រើឫទ្ធិ និម្មិតផែនដី ឡើងក្នុងទឹកនោះ ។ ពាក្យថា **គប្បីចូលបបរិកសិណ** បានដល់ គប្បីចូលឈាន ក្នុងបបរិកសិណ ។

បទថា **បល្លង្កំ** បានដល់ ការអង្គុយពែនភ្នែន ។ លោកអាចារ្យធ្វើទុកក្នុង ចិត្តថា សត្វដែលបាក់ស្លាប ឬថា មិនមានស្លាបកើតឡើង រមែងមិនអាចនឹងហើរ ទៅបាន ព្រោះហេតុនោះ ក្នុងព្រះបាលីទើបលោកពោលដល់សត្វ ដោយការធ្វើ ឲ្យពិសេសដោយស័ព្ទ **ដែលមានស្លាប** ថា **បក្ខី សកុណោ** គឺ សត្វស្លាប ដូច្នេះ ហើយ ពោលអធិប្បាយថា គឺសត្វដែលប្រកបដោយស្លាបទាំងពីរដូច្នេះ ។ ពាក្យថា

ធ្វើបរិកម្ម គឺ ធ្វើបរិកម្មថា សូមឲ្យជាផែនដីចុះ ។

ពាក្យថា **ក្នុងអាកាសល្ហល្ហេវ** គឺ បានឈ្មោះថា កណ្ដាលអាកាស ពិតហើយ ទីណាៗមិនមានគ្រឿងរារាំង ទីនោះៗហៅថា អាកាស ។ លោកអ្នកមានឫទ្ធិនេះ មិនបានទៅក្នុងអាកាសដែលនៅជិតៗផែនដីទេ តែថា រមែងទៅក្នុងអាកាសជាទីដែលពួកសត្វស្លាបមិនគោចរទៅ ។ ក៏អាកាសដូច្នោះ ក្នុងផ្លូវលោកហៅ ថា **អន្តលិក្ខំ** ( អាកាសល្ហល្ហេវ ) ព្រោះហេតុនោះ ទើបខ្ញុំពោលថា គឺ ក្នុងអាកាសដែលបានឈ្មោះថា អាកាសល្ហល្ហេវ ដូច្នេះ ។

ពាក្យថា **ព្រះថេរៈ** គឺព្រះតិបិដកចូឡាភយត្ថេរ ដែលបានពោលដល់ក្នុងពេលមុន ។ ពាក្យថា **ការចូលសមាបត្តិ** គឺការចូលសមាបត្តិតែម្ដង ។ ពាក្យថា **ចិត្តរបស់ភិក្ខុអង្គនេះតាំងមាំដោយល្អហើយ មិនមែនឬ** អធិប្បាយថា ចិត្តរបស់ភិក្ខុអ្នកមានឫទ្ធិ អ្នកកំពុងប្រព្រឹត្តទៅដោយអំណាចនៃបាដិហារិយ៍ ជាចិត្តដែលតាំងមាំដោយល្អក្រៃលែងហើយ តែមួយលើក មិនមែនជាចិត្តដែលមិនតាំងមាំដោយល្អដូចក្នុងកាលដទៃទេ , ក៏ពាក្យនោះ ត្រឹមតែជាមតិរបស់ព្រះថេរៈ ។ ពិតមែនក្នុងពេលដំបូង ភិក្ខុចូលបឋវីកសិណ អធិដ្ឋានឲ្យជាផែនដីហើយ ទើបដើរទៅ , តែថា ឥឡូវនេះ ត្រូវការឲ្យជាអាកាស , ព្រោះដូច្នេះ ក៏គប្បីចូលអាកាសកសិណទៀត ។ ព្រោះហេតុនោះ ទើបលោកពោលថា **កិញ្ចាបិ** គឺ ព្រះថេរៈពោលយ៉ាងនេះក៏ពិត ដូច្នេះជាដើម ។ ពាក្យថា **គប្បីបដិបត្តិតាមន័យដែលបានពោលទុកក្នុងតិរោកុឌ្ឌបាដិហារិយ៍នោះ** មានន័យថា ក្នុងតិរោកុឌ្ឌបាដិហារិយ៍នោះ វត្ថុមានជញ្ជាំងជាដើម រមែងទៅជាអាកាសដោយការអធិដ្ឋានថា សូមឲ្យជាអាកាសចុះ យ៉ាងណា សូម្បីបាដិហារិយ៍នេះ ភិក្ខុក៏គប្បីធ្វើវត្ថុ មាន ភ្នំ ដើមឈើ ជាដើម ឲ្យជាអាកាស

ដោយការអធិដ្ឋាន ហើយទើបទៅក៏ដូច្នោះ ។ ម្យ៉ាងទៀត ពាក្យថា **តាមន័យដែលបានពោលទុកក្នុងតិរោកុឌ្ឍបាដិហារិយ៍នោះឯង** គឺ តាមន័យដែលបានពោលហើយក្នុងតិរោកុឌ្ឍបាដិហារិយ៍នោះ ដោយពាក្យថា ប្រសិនបើភិក្ខុនេះអធិដ្ឋានហើយកំពុងទៅដូច្នេះជាដើម ។ ដោយពាក្យថា ដោយអំណាចនៃការអធិដ្ឋានដែលមានរួចហើយនោះឯង ប្រការថា ភ្នំក្តី ដើមឈើក្តីដែលសម្រេចព្រោះឧតុ នឹងផុសឡើងមកក្នុងរវាងដល់ភិក្ខុអង្គនេះ ព្រោះហេតុនោះ ការនេះទើបជាឋានៈដែលមានមិនបានឡើយ ដូច្នេះលោកសម្តែងថា វត្ថុរាំងសត្វអ្នកមានឫទ្ធិ មានពួកនាគជាដើមសាងឡើង មិនធ្វើអន្តរាយដល់ការទៅក្នុងអាកាសបានទេ ។

ពាក្យថា **ធ្លាក់ចុះក្នុងអាកាស** គឺ ក្នុងទីដ៏សមគួរ ដែលស្ងាត់ពួកមនុស្ស ។ លោកអ្នកមានឫទ្ធិនេះ ឈ្មោះថា នឹងត្រូវប្រាកដដល់មហាជនថា សមណៈនេះជាអ្នកត្រាច់ទៅក្នុងអាកាសបាន ។

ស័ព្ទថា ៤២.០០០ យោជន៍ លោកធ្វើទុកទាក់ទងនឹងកាលជាបឋមកប្ប ។ តែថា បន្ទាប់ពីនោះទៅ នឹងមានការកប់ជ្រៅទៅជាងនោះ ២-៣ យោជន៍ ព្រោះផែនដីខ្ពស់ឡើងទៅតាមលំដាប់ ម្យ៉ាងទៀត យោជន៍ដែលលើស ឬ ខ្វះបន្តិចបន្តួចមិនចាំបាច់រាប់ចូលទេ ព្រោះហេតុនោះ ទើបលោកពោលទុកយ៉ាងនេះ ។ ពាក្យថា **ដោយការធ្វើឲ្យភ្លឺក្នុងខណៈតែមួយក្នុងទ្វីបទាំង ៣** គឺ ក្នុងពេលណាតាំងនៅត្រង់កណ្តាលទ្វីបណា ពេលនោះ ក៏ដល់ការរលត់ទៅក្នុងទ្វីបនោះ គឺក្នុងទ្វីបមុនអំពីទ្វីបនោះ ហើយញ៉ាំងពន្លឺ រក្សាទ្វីបចុងក្រោយនោះឯង ។ ម្យ៉ាងទៀត ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថា **មានឫទ្ធិច្រើន** ក៏ព្រោះការគ្របសង្កត់ពន្លឺដទៃៗ និងព្រោះបុគ្គលទាំងឡាយ សម្លឹងមើលបានដោយលំបាក ឈ្មោះថា មានអានុភាពច្រើន ក៏

ព្រោះស្ងប់ភាពត្រជាក់ និងក្តៅដល់សត្វទាំងឡាយបាន និងព្រោះការធ្វើឲ្យកូនឈើ និងស្មៅ និងឈើធំឲ្យលូតលាស់បាន ។

បទថា **ធុបតិ** ប្រែថា ប៉ះពាល់ ។ បទថា **បរិមជ្ជតិ** គឺ ស្ទាបអង្អែល គឺ ជុសខាត់ បង្អួសដៃទៅខាងនោះខាងនេះ ។ ពាក្យថា **ដោយអំណាចនៃឈានដែលជាបាទនៃអភិញ្ញានោះឯង** គឺដោយអំណាចនៃឈានដែលជាបាទនៃអភិញ្ញាណាមួយ ។ ដោយ **ឯវ**-អក្ខរៈ លោកហាមបដិសេធឈានដែលជាបាទដោយឡែក មិនមែនហាមការអធិដ្ឋានទេ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងបាដិហារិយ៍នេះ មិនមានការកំណត់ពិតប្រាកដក្នុងការចូលកសិណសមាបត្តិ ដូច្នេះ ។ សេចក្តីថា ភិក្ខុគប្បីចូលឈានក្នុងកសិណឈ្មោះនេះ ហើយទើបអធិដ្ឋានដូចក្នុងបាដិហារិយ៍ដទៃមានតិរោកុឌ្ឌបាដិហារិយ៍ជាដើម ព្រោះហេតុនោះ ទើបមិនមានការកំណត់ពិតប្រាកដឡើយ ក្នុងបាដិហារិយ៍នេះ ។ ពិតយ៉ាងនោះ ក្នុងព្រះបាលីលោកពោលថា ភិក្ខុអ្នកមានឫទ្ធិក្នុងព្រះសាសនានោះ ដូច្នោះជាដើម មិនប្រកាន់មាំសមាបត្តិណាឡើយ ។ ឈ្មោះថា **រមែងមាននៅក្នុងហត្ថបាស** បានដល់ ព្រះចន្ទ និងព្រះអាទិត្យ ដែលលោកពោលទុកយ៉ាងនេះថា **ចន្ទិមសុរិយេ** ដូច្នេះ ។ បទថា **រូបគតំ ហត្ថបាសេ** បានដល់ រូបដែលតាំងនៅក្នុងហត្ថបាស ឬ រូបក្នុងហត្ថបាស ។ មានពាក្យប្រកបសេចក្តីថា **ហត្ថំ វា វឌ្ឍេត្វា បរាមសតិ** គឺ លូកដៃទៅចាប់ពាល់ក៏បាន ។

លោកពោលដល់ការអាស្រ័យដៃ ដែលជាឧបាទិន្នកៈ លូកដៃដែលជាអនុឧបាទិន្នកៈ តែដោយ **យុត្តិឆាយា** ថា លូកដៃសូម្បីដែលឧបាទិន្នកៈ ក៏ឃើញប្រើក្នុងបាដិហារិយ៍នេះ ។ លោកអាចារ្យប្រាថ្នានឹងសម្តែងសេចក្តីនោះ ដោយនាំយកវាទៈរបស់ព្រះថេរៈមកព្រមទាំងរឿងរ៉ាវដែលប្រព្រឹត្តទៅ យ៉ាងនេះថា ក្នុងការធ្វើខ្លួនឯងឲ្យ

ដល់ភាពជារបស់តូច និងភាពជារបស់ធំ រមែងបានសូម្បីការពង្រីកខន្ធ ដែលជាឧបាទិន្នកៈ ដូចគ្នានឹងការបង្រួមដែរ ។ ដូចក្នុងពេលដែលព្រះមហាមោគ្គល្លានទូន្មាននន្ទោបនន្ទនាគរាជដូច្នោះ ដូច្នេះ ទើបផ្តើមពាក្យថា ព្រះតិបិដកចូឡនាគត្ថេរពោលហើយដូច្នេះជាដើម ។ ឈ្មោះថា ឧបាទិន្នកខន្ធជារបស់តូចខ្លះ ធំខ្លះ មិនបានឬ ? អធិប្បាយថា រមែងកើតបានផងដែរ ។ ពាក្យបដិសេធពីរផ្លូវ រមែងធ្វើឲ្យដល់ប្រក្រតីដូច្នេះ ។ ពាក្យថា **ក្នុងពេលនោះ ឧបាទិន្នកខន្ធ ក៏រមែងជារបស់ធំ ដូចជាឧបាទិន្នកខន្ធរបស់ព្រះមហាមោគ្គល្លានត្ថេរដូច្នោះ** នេះលោកពោលទុក ដោយទាក់ទងជាពាក្យសម្តែងដល់ផល តាមដែលបានចាត់ចែងទុក ក៏ក្នុងបាដិហារិយ៍នេះ រមែងបានការធ្វើឲ្យដល់ភាពជារបស់តូចផងដែរ ។

( ចប់ មហាដីកា )

- ៣០៣ - វិសុទ្ធិមគ្គ ឥទ្ធិវិធនិទ្ទេស ឫទ្ធិ១០យ៉ាង

## រឿងព្រះមហាមោគ្គល្លានទូន្មាននន្ទោបនន្ទនាគរាជ

បានឮថា ក្នុងសម័យមួយ អនាថបិណ្ឌិកគហបតីស្ដាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគហើយ ក្រាបទូលនិមន្តថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃស្អែកនេះសូមព្រះអង្គ ព្រមទាំងភិក្ខុ ៥០០ អង្គ ទ្រង់ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គចុះ ហើយត្រឡប់ទៅ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ទ្រង់សម្រេចសម្រាននៅក្នុងថ្ងៃនោះ ញ៉ាំងចំណែករាត្រីកាលឲ្យកន្លងទៅ ( ដោយពុទ្ធកិច្ចដទៃៗ ) ហើយដល់បច្ចូសសម័យ ទើបទ្រង់ត្រួតមើលម៉ឺនលោកធាតុ គ្រានោះ នន្ទោបនន្ទនាគរាជមកចំពោះក្រសែពុទ្ធចក្ខុ ក្នុងផ្លូវនៃព្រះញាណរបស់ព្រះអង្គ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា នាគរាជនេះមកកាន់គន្លងនៃញាណរបស់តថាគត ឧបនិស្ស័យរបស់គេមានឬហ្ន៎ ក៏ទ្រង់ឃើញថា នាគរាជនេះ ជាមិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះរតនត្រៃ ទើបទ្រង់រំពឹងតទៅថា អ្នកណាហ្ន៎ នឹងគប្បីដោះនាគរាជនេះ អំពីមិច្ឆាទិដ្ឋិបាន ក៏បានទ្រង់ឃើញព្រះមហាមោគ្គល្លានត្ថេរ( ថានឹងអាចធ្វើយ៉ាងនោះបាន ) តពីនោះ ពេលរាត្រីភ្លឺស្វាង ទ្រង់ជម្រះព្រះកាយហើយ ទើបត្រាស់ហៅព្រះអានន្ទថា ម្នាលអានន្ទអ្នកចូរប្រាប់ដល់ភិក្ខុ ៥០០ អង្គថា តថាគតនឹងចារិកទៅកាន់ទេវលោក ។

ល្មមថ្ងៃនោះ នាគរាជបានចាត់តែងអាបានភូមិ ( កន្លែងជប់លៀង ) សម្រាប់នន្ទោបនន្ទនាគរាជ នាគរាជនោះមានស្វេតច្ឆត្រទិព្វការពារ មានពួករបាំ ៣ ពួក និងនាគបរិស័ទព័ទ្ធជុំវិញ អង្គុយសរសើរបាយទឹកផ្សេងៗ ដែលគេចាត់ចែងទុកក្នុងភាជនទិព្វទាំងឡាយ នៅលើរតនបល្ល័ង្កទិព្វ គ្រានោះ ព្រះមានព្រះភាគទ្រង់ធ្វើឲ្យនាគរាជមើលឃើញ ស្ដេចឆ្ពោះទៅកាន់ស្ថានតាវត្តិង្សទេវលោក ព្រមដោយភិក្ខុ ៥០០ អង្គ ( រំលងទៅ )ផ្លូវខាងលើពិតាន( អាបានភូមិ )របស់នាគរាជនោះឯង ។

ក៏សម័យនោះ ទិដ្ឋិអាក្រក់ដូច្នេះកើតឡើងដល់នន្ទោបនន្ទនាគរាជថា ហ៊ឺះ ពួកសមណៈក្បាលត្រងោលនេះ ចូលៗ ចេញៗ ភពតាវត្តិង្សរបស់ពួកទេវតា ដោយធ្វើអំណាចលើពួកយើងគ្រប់កន្លែងទៅ ពេលនេះ យើងមិនត្រូវឲ្យសមណៈពួកនេះ រោលធូលីដាក់លើក្បាលពួកយើងបានតទៅទៀតឡើយ ថាហើយ ក៏ក្រោកចាកបល្ល័ង្ក ទៅនៅជើងភ្នំសិនេរុ លះអត្តភាពដើមនោះចេញ ហើយនិម្មិតជានាគរាជធំសម្បើម រុំឱបភ្នំសិនេរុដោយរង្វែល ៧ ជុំ បើកពពាររឡើងលើភ្នំសិនេរុ ហើយក្តោបយកភពតាវត្តិង្សទុកដោយពពារដែលផ្កាប់ចុះ រហូតដល់មើលមិនឃើញភពតាវត្តិង្ស ។

គ្រានោះ ព្រះរដ្ឋបាលបានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលមុនខ្ញុំព្រះអង្គឈរនៅត្រង់នេះ រមែងមើលឃើញភ្នំសិនេរុ ឃើញបរិភណ្ឌ ( ភ្នំដែលព័ទ្ធជុំវិញភ្នំសិនេរុ ) ឃើញភពតាវត្តិង្ស ឃើញវេជយន្តប្រាសាទ ឃើញទង់លើកំពូលវេជយន្តប្រាសាទ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ឥឡូវនេះ ខ្ញុំព្រះអង្គមើលមិនឃើញភ្នំសិនេរុ ។ ល ។ មិនឃើញទង់នៅលើកំពូលភ្នំ វេជ្ជយន្តប្រាសាទ ។

ព្រះមានព្រះភាគត្រាស់ប្រាប់ថា ម្នាលរដ្ឋបាល នេះនាគរាជឈ្មោះនន្ទោបនន្ទខឹងក្រោធអ្នកទាំងឡាយ រុំឱបភ្នំសិនេរុដោយរង្វែលដល់ ៧ ជុំហើយ បាំងខាងលើដោយពពារ ទើបធ្វើឲ្យងងឹត ។

ព្រះរដ្ឋបាលក្រាបទូលថា នឹងទូន្មាននាគរាជនោះ តែព្រះមានព្រះភាគមិនទ្រង់អនុញ្ញាត លំដាប់នោះ ភិក្ខុទាំងពួង ដូចព្រះភទ្ទិយៈ ព្រះរាហុលជាដើមក្រោកឡើងទូលសូត្រគ្រប់ចិត្តដោយលំដាប់ ព្រះមានព្រះភាគក៏ត្រង់មិនអនុញ្ញាត ទីបំផុតព្រះមហា

មោគ្គល្លានក្រាបទូលស្មគ្រចិត្តថា ខ្ញុំព្រះអង្គសូមទូន្មានដោយខ្លួនឯង ទើបព្រះភគវា ទ្រង់អនុញ្ញាតថា ទូន្មានចុះ មោគ្គល្លាន ។

ព្រះថេរៈក៏លះអត្តភាពដើមចេញហើយ និម្មិតជាភេទនាគរាជធំក្រៃលែងជាង នន្ទោបនន្ទនាគរាជ រុំព័ទ្ធខ្លួននន្ទោបនន្ទទុកដោយវង្វេលដល់ទៅ ១៤ ជុំ តាំងពពារ របស់ខ្លួនទុកលើពពារនន្ទោបនន្ទនាគរាជនោះ រួតរឹតចូលហ្នឹងភ្នំសិនេរុ នាគរាជបង្ហុយ ផ្សែងឡើងដាក់ព្រះថេរៈ ទើបព្រះថេរៈពោលថា មិនមែនផ្សែងមាននៅតែក្នុងរាង កាយរបស់អ្នកម្នាក់ទេ យើងក៏មានដូចគ្នា ហើយបង្ហុយផ្សែងឡើងដែរ ផ្សែងរបស់ នាគរាជមិនបៀតបៀនព្រះថេរៈ តែផ្សែងរបស់ព្រះថេរៈបៀតបៀននាគរាជ លំដាប់ នោះ នាគរាជបណ្តាលភ្លើងឡើងដាក់លើព្រះថេរៈ ព្រះថេរៈពោលថា មិនមែនភ្លើង មានតែក្នុងរាងកាយរបស់អ្នកម្នាក់ទេ យើងក៏មានដូចគ្នា ហើយបណ្តាលភ្លើងឡើង ភ្លើងរបស់នាគរាជមិនធ្វើព្រះថេរៈឲ្យលំបាក តែភ្លើងរបស់ព្រះថេរៈធ្វើនាគរាជឲ្យ លំបាក នាគរាជគិតថា បុគ្គលនេះរួតរឹតយើងចូលហ្នឹងភ្នំសិនេរុទុកហើយ ទាំងព្រួស ផ្សែង ទាំងបណ្តាលភ្លើង ធ្វើយើងឲ្យលំបាកទៀត ( យើងនឹងក្លែងនិយាយចរចា ដោយល្អ ឲ្យស្ងាប់ចិត្ត ) ទើបក្លែងសួរឡើងថា ព្រះករុណាម្ចាស់ជានរណា ? ព្រះ ថេរៈប្រាប់ថា យើងគឺមោគ្គល្លាន ននូនាគរាជលួងលោមថា ព្រះគុណម្ចាស់ សូម ព្រះគុណម្ចាស់ ប្រោសតាំងនៅជាភិក្ខុដូចដើមចុះ ព្រះថេរៈក៏លះអត្តភាពនាគនោះ ចេញហើយនិម្មិត អត្តភាពដ៏ល្អិត ចូលតាមរន្ធត្រចៀកឆ្វេងរបស់នាគរាជនោះ ហើយចេញតាមរន្ធត្រចៀកស្តាំ ចូលតាមរន្ធត្រចៀកស្តាំ ចេញតាមរន្ធត្រចៀកឆ្វេង ដោយន័យដូចនោះ ចូលតាមរន្ធច្រមុះឆ្វេង ចេញតាមរន្ធច្រមុះស្តាំ ចូលតាមរន្ធ ច្រមុះស្តាំ ចេញតាមរន្ធច្រមុះឆ្វេង លុះនាគរាជហាមាត់ហើយ ព្រះថេរៈក៏ចូលតាម

មាត់ដើរចង្ក្រមទៅខាងកើត និងខាងលិច នៅខាងក្នុងពោះរបស់នាគរាជ ព្រះមានព្រះភាគត្រាស់ ដាស់តឿនថា “ មោគ្គល្លាន ចូរដឹងថា នាគនោះមានឫទ្ធិច្រើន ព្រះថេរៈនៅក្នុងពោះនាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥទ្ធិបាទ ៤ ខ្ញុំព្រះអង្គបានចម្រើន បានធ្វើឲ្យច្រើន ធ្វើឲ្យដូចជាយានដែលទឹមហើយ ធ្វើឲ្យដូចជារបស់ប្រើ ដែលត្រៀមរួចហើយ តែងតាំងទុកមិនឲ្យសាបសូន្យ ស្ទាត់ជំនាញធ្វើបានដោយរហ័ស បពិត្រព្រះអង្គដ៏ចម្រើន កុំថាឡើយត្រឹមនន្ទោបនន្ទមួយ ខ្ញុំព្រះអង្គអាចនឹងទូន្មាននាគរាជដូចនន្ទោបនន្ទនេះទាំងរយ ទាំងពាន់ ទាំងសែនក៏បាន ” ។

ចំណែកនាគរាជ គិតថា កាលចូលទៅយើងមិនទាន់ឃើញ ណ្ហើយចុះ ពេលចេញមកវិញ យើងនឹងត្រូវញាត់វាចូលប្រហោងចង្កូម ត្របាក់ស៊ីឲ្យបាន ទើបក្លែងនិយាយអង្វរថា និមន្តចេញមកចុះព្រះគុណម្ចាស់ ប្រោសកុំដើរទៅមកនៅក្នុងពោះធ្វើខ្ញុំឲ្យលំបាកឡើយ ព្រះថេរៈក៏ចេញមកឈរនៅត្រង់ខាងក្រៅ នាគរាជលុះឃើញថា នេះគឺព្រះថេរៈ ក៏បណ្តាលខ្យល់នាសវាត( ផ្លុំខ្យល់តាមច្រមុះយ៉ាងខ្លាំង ) អាចបក់យកសត្រូវទៅបាន ព្រះថេរៈចូលចតុត្ថជ្ឈានមួយរំពេច ខ្យល់នោះមិនអាចធ្វើសូម្បីតែសរសៃរោមរបស់ព្រះថេរៈឲ្យកម្រើកបានឡើយ ។

ន័យថា ភិក្ខុក្រៅពីនោះអាចធ្វើបាដិហារិយ៍គ្រប់យ៉ាងតាំងពីដើមមកបាន តែដល់ឋានៈ ( គឺ ការបញ្ចេញខ្យល់នាសវាតនេះហើយ ) នឹងមិនអាចចូលសមាបត្តិជាខិប្បនិសន្តិ( ចូលបានឆាប់រហ័ស )យ៉ាងនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបមិនទ្រង់អនុញ្ញាតការទូន្មាននាគរាជដល់ភិក្ខុទាំងនោះ ។

នាគរាជគិតតូចចិត្តថា យើងមិនអាចធ្វើ សូម្បីតែសរសៃរោមរបស់សមណៈនេះឲ្យកម្រើកបាន ដោយខ្យល់នាសវាត សមណៈនេះមានឫទ្ធិច្រើន ឃើញថាតស៊ូ

មិនបាន ក៏ខ្ចាចគេចទៅ ព្រះថេរៈទើបលះអត្តភាពនោះ និម្មិតជារូបគ្រុឌ សម្តែងសុបណ្ណវាត ( ខ្យល់ស្លាបគ្រុឌ គឺ ទទះស្លាបធ្វើឲ្យកើតខ្យល់យ៉ាងខ្លាំងឡើង ) ជាប់តាមនាគរាជទៅ នាគរាជឃើញថា នឹងគេចឲ្យផុត ទើបលះអត្តភាពនោះចេញហើយ និម្មិត្តជាមាណពពោលថា បពិត្រលោកម្ចាស់ ខ្ញុំសូមដល់លោកម្ចាស់ជាទីពឹង បានក្រាបទៀបព្រះបាទរបស់ព្រះថេរៈៗ ឃើញនាគអស់យស ទើបពោលថា នន្ទៈ ព្រះសាស្តាក៏ស្តេចយាងមកដែរ មកយើងនឹងទៅគាល់ព្រះអង្គជាមួយគ្នា ទូន្មាននាគរាជធ្វើឲ្យអស់ពិសហើយ ក៏នាំគ្នាទៅកាន់សម្នាក់ព្រះមានព្រះភាគ នាគរាជថ្វាយបង្គំព្រះលោកនាថពោលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់ព្រះអង្គជាទីពឹង ព្រះមានជោគត្រាស់ប្រទានពរថា **សុខី ហោហិ នាគរាជ** ចូរជាសុខចុះនាគរាជ ហើយមានភិក្ខុសង្ឃហែហមព្រះមហាមុនី ផ្ទោះទៅកាន់និវេសន៍របស់អនាថបិណ្ឌិកសេដ្ឋី ។

អនាថបិណ្ឌិកសេដ្ឋីក្រាបទូលសួរថា ហេតុអ្វីទើបព្រះអង្គស្តេចយាងមកយឺត ព្រះជិនស្រីត្រាស់ថា មោគ្គល្លាន និងនន្ទោបនន្ទនាគរាជជាប់ធ្វើសង្គ្រាមគ្នា ក្រាបទូលសួរថា អ្នកណាឈ្នះ អ្នកណាចាញ់ ព្រះអង្គ ? ព្រះសម្ពុទ្ធត្រាស់ប្រាប់ថា មោគ្គល្លានឈ្នះ នន្ទោបនន្ទចាញ់ ទើបអនាថបិណ្ឌិកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានបុណ្យទ្រង់ទទួលនិមន្តទទួលភត្តរបស់ខ្ញុំព្រះអង្គដោយលំដាប់គឺមិនវៀរ រហូត ៧ ថ្ងៃចុះ ខ្ញុំព្រះអង្គនឹងធ្វើសក្ការៈដល់ព្រះថេរៈ ៧ ថ្ងៃ ហើយបានធ្វើមហាសក្ការៈដល់ភិក្ខុ ៥០០ អង្គ មានព្រះពុទ្ធជាប្រធានរហូតអស់ ៧ ថ្ងៃ ។

ពាក្យថា **កាលណាភិក្ខុធ្វើអត្តភាពឲ្យធំ កាលនោះ ឧបាទិន្នកក៏ជារបស់ធំបាន ដូចឧបាទិន្នករបស់ព្រះមហាមោគ្គល្លានដូច្នោះនោះ** ព្រះតិបិដកចូឡនាគត្ថេរពោល

សំដៅយកអត្តភាពធំ ដែលព្រះមហាមោគ្គល្លានធ្វើក្នុងការទូន្មាននន្ទោបនន្ទនាគរាជនោះឯង សូម្បីលោកពោលយ៉ាងនោះ ភិក្ខុទាំងឡាយក៏នៅនាំគ្នាប្រកាន់ពោលថា អនុបាទិន្នកៈនោះឯង អាស្រ័យឧបាទិន្នកៈរីកចេញទៅ វាទៈរបស់ភិក្ខុទាំងឡាយនោះឯង ជាយុត្តិក្នុងបាដិហារិយ៍នេះ ។

ភិក្ខុអ្នកមានឫទ្ធិនោះ កាលធ្វើបានយ៉ាងនេះ ( ក៏លាតដៃទៅ ឬធ្វើឲ្យព្រះចន្ទ និង ព្រះអាទិត្យមកនៅក្នុងហត្ថបាស ) មិនមែនត្រឹមតែចាប់ព្រះចន្ទ និងព្រះអាទិត្យប៉ុណ្ណោះទេ បើលោកប្រាថ្នានឹងធ្វើព្រះចន្ទ និងព្រះអាទិត្យនោះ ឲ្យជាទ្រនាប់ជើង ហើយជាន់លើព្រះចន្ទ និងព្រះអាទិត្យនោះក៏បាន ធ្វើឲ្យជាតាំងហើយអង្គុយក៏បាន ធ្វើឲ្យជាគ្រែហើយដេកក៏បាន ធ្វើឲ្យជាផ្អែកបង្អែក ហើយផ្អែកក៏បាន និងអ្នកមានឫទ្ធិម្នាក់ធ្វើបានយ៉ាងណា សូម្បីអ្នកមានឫទ្ធិដទៃក៏ធ្វើបានដូច្នោះ ពិតហើយ សូម្បីភិក្ខុច្រើនសែនអង្គ នាំគ្នាធ្វើយ៉ាងនោះព្រមៗគ្នា បាដិហារិយ៍រមែងសម្រេចដល់ភិក្ខុទាំងនោះមួយរូបៗ ដូចគ្នា ដោយការគោចរទៅក្តី ការធ្វើភាពភ្លឺស្វាងនៃព្រះចន្ទ និងព្រះអាទិត្យ ក៏គង់មានប្រាកដដូចដើមនោះឯងដែរ ប្រៀបដូចកាលពាង ១០០០ ពាងពេញដោយទឹក វង់ព្រះចន្ទរមែងប្រាកដនៅក្នុងគ្រប់ពាង តែការគោចរទៅក្តី ការធ្វើភាពភ្លឺស្វាងក្តី ក៏គង់មានតាមប្រក្រតីនោះឯង យ៉ាងណា បាដិហារិយ៍នេះ ក៏មានឧបមេយ្យដូច្នោះ ។

## កាយេនវសវត្តនបាដិហារិយ

### “ ញ៉ាំងកាយឲ្យទៅដល់ព្រហ្មលោក ”

ពាក្យថា *យាវ ព្រហ្មលោកាបិ*-ត្រឹមតែព្រហ្មលោកក៏បាន មានន័យថា ធ្វើ

ព្រហ្មលោកឲ្យជាទីកំណត់ក៏បាន ។ ពាក្យថា **កាយេនវសំវត្តេតិ**-ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ មានសេចក្តីថា ប្រើអំណាចរបស់ខ្លួនដោយកាយទៅក្នុងព្រហ្មលោកនោះ សេចក្តីនៃបាឋៈនោះ គប្បីជ្រាបទៅតាមព្រះបាលីចុះ ។

ឯបាទតទៅនេះ ជាបាលីក្នុងបាដិហារិយ៍ខនេះ គឺ បាលីថា **យាវ ព្រហ្មលោកាបិ កាយេនវសំវត្តេតិ** ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅដោយកាយរហូតដល់ព្រហ្មលោកក៏បាន មានអធិប្បាយថា បើភិក្ខុអ្នកមានឫទ្ធិបានចេតោវសីនោះ ជាអ្នកប្រាថ្នានឹងទៅព្រហ្មលោកដូច្នោះ លោកអធិដ្ឋានកន្លែងដែលនៅឆ្ងាយ ឲ្យជាកន្លែងដែលនៅជិតក៏បានថា កន្លែងដែលនៅឆ្ងាយ ចូរជាកន្លែងដែលនៅជិត វាក៏ជាកន្លែងដែលនៅជិតទៅ អធិដ្ឋានកន្លែងដែលនៅជិត ឲ្យជាកន្លែងដែលនៅឆ្ងាយក៏បានថា កន្លែងដែលនៅជិត ចូរជាកន្លែងដែលនៅឆ្ងាយ វាក៏ទៅជាកន្លែងដែលនៅឆ្ងាយទៅ អធិដ្ឋានរបស់ច្រើន ឲ្យជារបស់តិចក៏បានថា របស់ច្រើននោះ ចូរជារបស់តិច វាក៏ជារបស់តិចទៅ អធិដ្ឋានរបស់តិច ឲ្យជារបស់ច្រើនក៏បានថា របស់តិចនោះចូរជារបស់ច្រើន វាក៏ជារបស់ច្រើនទៅ លោករមែងឃើញរូបរបស់ព្រហ្មនោះបានដោយទិព្វចក្ខុ រមែងបានឮសំឡេងព្រហ្មនោះបាន ដោយសោតធាតុជាទិព្វ រមែងដឹងចិត្តព្រហ្មនោះបានដោយចេតោបរិយញ្ញាណ បើភិក្ខុអ្នកមានឫទ្ធិបានចេតោវសីនោះ ជាអ្នកប្រាថ្នានឹងទៅព្រហ្មលោក ដោយទិស្សមានកាយ( កាយដែលប្រាកដ ) សោត លោកបង្អោនចិត្តទៅតាមអំណាចកាយ អធិដ្ឋានចិត្តទៅតាមអំណាចកាយ ការបង្អោនចិត្តទៅតាមអំណាចកាយ អធិដ្ឋានចិត្តទៅតាមអំណាចកាយហើយ ឈានចុះកាន់សុខសញ្ញា ( សេចក្តីសម្គាល់ថា ជាសុខ ) និង លហុសញ្ញា ( ការកំណត់ថា ស្រាល ) ក៏ទៅព្រហ្មលោកបាន ដោយទិស្សមានកាយ បើភិក្ខុអ្នកមាន

ឫទ្ធិបាទចេតោវសីនោះ ជាអ្នកប្រាថ្នានឹងទៅព្រហ្មលោក ដោយអទិស្សមានកាយ ( កាយដែលមិនប្រាកដ ) ដូច្នោះ លោកក៏បង្អោនកាយទៅតាមអំណាចចិត្ត អធិដ្ឋានកាយទៅតាមអំណាចចិត្ត កាលបង្អោនកាយទៅតាមអំណាចចិត្ត អធិដ្ឋានកាយទៅតាមអំណាចចិត្តហើយ ឈានចុះចំពោះសុខសញ្ញា និងលហុសញ្ញា ក៏ទៅព្រហ្មលោកបានដោយអទិស្សមានកាយ លោកនិម្មិតរូបមនោមយៈ មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយ ដូចជា ភ្នែក ត្រចៀក មិនខ្វះខាតចំពោះមុខព្រហ្មនោះ បើអ្នកមានឫទ្ធិនោះចង្ក្រម ភិក្ខុនិមិត្តក៏ចង្ក្រមនៅក្នុងព្រហ្មលោកនោះដែរ បើលោកអ្នកមានឫទ្ធិនោះឈរ អង្គុយ ដេក ភិក្ខុនិមិត្តនោះក៏ឈរ អង្គុយ ដេកនៅក្នុងព្រហ្មលោកនោះដែរ បើលោកអ្នកមានឫទ្ធិនោះបញ្ចេញផ្សែង បណ្តាលភ្លើង សម្តែងធម៌ សួរបញ្ហា ត្រូវសួរបញ្ហាហើយដោះស្រាយ ភិក្ខុនិមិត្តក៏បញ្ចេញផ្សែង បណ្តាលភ្លើង សម្តែងធម៌ សួរបញ្ហា ត្រូវសួរបញ្ហាហើយនោះ ដោះស្រាយនៅក្នុងព្រហ្មលោកនោះដែរ បើលោកអ្នកមានឫទ្ធិនោះ សម្តែងកិរិយាឈរជាមួយគ្នា សម្តែងកិរិយាប្រាស្រ័យគ្នា សម្តែងកិរិយាសន្ទនាធម៌គ្នានឹងព្រហ្មនោះ ភិក្ខុនិមិត្តក៏ឈរជាមួយគ្នា ប្រាស្រ័យគ្នា សន្ទនាធម៌គ្នា នឹងព្រហ្មនោះ ក្នុងព្រហ្មលោកនោះដែរ មានសេចក្តីថា ភិក្ខុមានឫទ្ធិនោះ ធ្វើកិច្ចណាៗ ភិក្ខុនិមិត្តនោះក៏ធ្វើកិច្ចនោះៗ ដូចគ្នាទាំងអស់ដូច្នោះឯង ។

## អធិប្បាយសេចក្តីនៃបាលី និង រឿងនិទស្សនៈ

ក្នុងបាឋៈទាំងនោះ បាឋៈថា **ទូរេបិ សន្តិកេ អធិដ្ឋាតិ** អធិដ្ឋានកន្លែងដែលនៅឆ្ងាយ ឲ្យជាកន្លែងដែលនៅជិតក៏បាន នោះមានសេចក្តីថា ភិក្ខុអ្នកមានឫទ្ធិនោះ ចេញចាកឈានជាបាទហើយ អាវជ្ជនាការដល់ទេវលោក ឬ ព្រហ្មលោកក៏ដោយ

ដែលនៅក្នុងទីឆ្ងាយថា ចូរមកនៅក្នុងទីជិត កាលអាវជ្ជនាការហើយធ្វើបរិកម្មទៅ ចូលឈានទៀត ហើយអធិដ្ឋានដោយញាណថា ទេវលោក ឬព្រហ្មលោកនោះ ចូរមកនៅក្នុងទីជិត វាក៏មកនៅក្នុងទីជិត ន័យនេះគប្បីជ្រាបសូម្បីក្នុងបទដ៏សេស ។

## ធ្វើទីឆ្ងាយឱ្យជិត

សួរថា ក្នុងបាដិហារិយ៍ទាំងនោះ អ្នកណាចាប់យកទីឆ្ងាយមកធ្វើឲ្យជាទីជិត?

ឆ្លើយថា “ ព្រះមានព្រះភាគ ” ពិតហើយ ព្រះមានព្រះភាគ កាលសម្រេចការសម្តែងយមកប្បាដិហារិយ៍ ស្តេចក៏ទៅកាន់ទេវលោក ក៏ទ្រង់ធ្វើភ្នំយុគន្ធរ និងភ្នំសិនេរុឲ្យមកនៅជិត ទៀបផែនដី ទ្រង់ដាក់ព្រះបាទម្ខាងលើភ្នំយុគន្ធរ ហើយដាក់ព្រះបាទម្ខាងទៀតលើភ្នំសិនេរុ ។

សួរថា អ្នកដទៃអ្នកណាធ្វើបានទៀតខ្លះ ? ឆ្លើយថា ព្រះមហាមោគ្គល្លានត្ថេរពិតមែន ព្រះថេរៈបំព្រួញផ្លូវទៅកាន់នគរសង្កស្សៈ ដែលមានប្រមាណ ៣០ យោជន៍ ញុំាងបរិស័ទដ៏ពេញក្នុងផ្ទៃដី ១២ យោជន៍ ធ្វើភត្តកិច្ចហើយ ចេញអំពីក្រុងសាវត្ថី ឲ្យដល់ព្រមគ្នាក្នុងមួយរំពេចនោះឯង ។

រឿងមួយទៀត សូម្បីព្រះចូឡសមុទ្ទត្ថេរ ក្នុងតម្ពបណ្ណិទ្វីបក៏បានធ្វើ បានឮមកថា ក្នុងកាលកន្តារបាយមួយគ្រា ភិក្ខុ ៧០០ អង្គ បាននាំគ្នាមកកាន់សម្នាក់ព្រះថេរៈអំពីព្រលឹម ព្រះថេរៈត្រិះរិះគិតមើលថា ភិក្ខុសង្ឃជាក្រុមធំ កាលភិក្ខាចារនឹងមានបានក្នុងទីណា ទើបនឹងបានភិក្ខាគ្រប់គ្នា ក៏មើលមិនឃើញក្នុងតម្ពបណ្ណិទ្វីបទាំងអស់ ឃើញថា នឹងមានបានក្នុងក្រុងបាដលីបុត្រ ត្រើយទន្លេខាងនោះ ទើបឲ្យភិក្ខុទាំងអស់កាន់បាត្រចីវរ ប្រាប់ថា មកអាវុសោទាំងឡាយ យើងនឹងទៅភិក្ខាចារ

ជាមួយគ្នា ហើយបំពេញផែនដីនាំភិក្ខុទាំងឡាយ ទៅដល់ក្រុងបាដលីបុត្រក្នុងមួយរំពេច ភិក្ខុទាំងឡាយសួរថា នេះក្រុងអ្វី ព្រះករុណា ? ក៏ឆ្លើយថា ក្នុងក្រុងបាដលីបុត្រ អាវុសោ ភិក្ខុទាំងឡាយប្រាប់ថា ក្រុងបាដលីបុត្រនៅឆ្ងាយណាស់ ព្រះករុណា លោកប្រាប់ថា អាវុសោ ព្រះថេរៈចាស់ក៏ចាប់យកកន្លែងដែលនៅឆ្ងាយធ្វើឲ្យនៅជិតក៏បាន ភិក្ខុទាំងឡាយសួរថា មហាសមុទ្រនៅឯណា ព្រះករុណា ? ទើបលោកពោលថា អាវុសោ ពួកលោកបានឆ្លងក្រុងទឹកខៀវមួយកន្លែងក្នុងរវាងផ្លូវមិនមែនឬ ? ភិក្ខុទាំងឡាយឆ្លើយថា មែន ព្រះករុណា តែថា មហាសមុទ្រធំណាស់ លោកក៏ថា ព្រះថេរៈចាស់ៗណា ធ្វើរបស់ធំឲ្យជារបស់តូចក៏បាន ។

ម្យ៉ាងទៀត ព្រះចូឡសមុទ្ទត្ថេរ នេះយ៉ាងណា សូម្បីព្រះតិស្សទត្តត្ថេរក៏ដូច្នោះ ក្នុងពេលត្រជាក់ ស្រង់ទឹក គ្រងឧត្តរាសង្គៈហើយ លុះការគិតថា យើងនឹងថ្វាយបង្គំមហាពោធិព្រឹក្សកើតឡើង ក៏ធ្វើព្រះមហាពោធិដែលនៅឆ្ងាយឲ្យមកនៅជិតបាន ។

## ធ្វើទីជិតឱ្យឆ្ងាយ

សួរថា ផ្នែកមួយទៀត អ្នកណាចាប់យកទីជិតឲ្យមកធ្វើជាទីឆ្ងាយបាន ? ពិតមែន ព្រះមានព្រះភាគ ទ្រង់បានធ្វើទីរវាងព្រះអង្គ និងចោរអង្គុលិមាលដែលនៅទីជិតឲ្យជាទីឆ្ងាយក៏បាន ។

## ធ្វើរបស់ច្រើនឱ្យជារបស់តិច

សួរថា អ្នកណាធ្វើរបស់ច្រើនឲ្យជារបស់តិច ? ឆ្លើយថា ព្រះមហាកស្សបៈបានជ្រាបថា ក្នុងថ្ងៃនក្ខត្តឫក្ស ( ថ្ងៃមួយ ) នៅក្នុងក្រុងរាជគ្រឹះ កុមារិកាប្រមាណ

៥០០ នាក់ កាន់នំលោកខែ នាំគ្នាដើរទៅដើម្បីនឹងលេងនក្ខត្តឫក្ស ជួបព្រះមានព្រះភាគ ហើយមិនបានថ្វាយអ្វីឡើយ តែលុះជួបព្រះថេរៈដែលនិមន្តមកខាងក្រោយ ក៏និយាយគ្នាថា ព្រះថេរៈរបស់ពួកយើងមក ពួកយើងនឹងថ្វាយនំ ហើយគ្រប់គ្នាកាន់នំចូលទៅរកព្រះថេរៈៗ នាំបាត្រចេញមកទទួលនំ បានធ្វើនំទាំងអស់ឲ្យល្មមចុះក្នុងបាត្រតែមួយ ព្រះលោកនាថប្រថាប់គង់ចាំព្រះថេរៈនៅខាងមុខ ព្រះថេរៈក៏នាំនំនោះទៅថ្វាយដល់ព្រះមានបុណ្យដូច្នេះឯង ។

## ធ្វើរបស់តិចឱ្យជារបស់ច្រើន

រីឯ ក្នុងរឿងឥល្លិសសេដ្ឋី ព្រះមហាមោគ្គល្លានត្ថេរ បានធ្វើរបស់តិចឲ្យជារបស់ច្រើន ។ ម្យ៉ាងទៀត ក្នុងរឿងកាកវលិយៈ ព្រះមានព្រះភាគក៏ទ្រង់បានធ្វើ បានឮមកថា ព្រះមហាកស្សបៈប្រើពេលចូលនិរោធសមាបត្តិ ៧ ថ្ងៃ ចេញហើយនឹងធ្វើការសង្គ្រោះដល់អ្នកកម្សត់ ទើបទៅឈរនៅត្រង់ទ្វារផ្ទះអ្នកកម្សត់ម្នាក់ឈ្មោះកាកវលិយៈ ប្រពន្ធរបស់គេឃើញព្រះថេរៈក៏លើកយកបបរដែលមិនមានរសជូរប្រៃអ្វីឡើយ ដែលដាំទុកដើម្បីប្ដី ទៅដាក់បាត្រ ព្រះថេរៈទទួលបបរនោះ នាំទៅថ្វាយព្រះមានព្រះភាគ ទ្រង់អធិដ្ឋានធ្វើបបរនោះឲ្យច្រើនឡើងគ្រប់គ្រាន់ដល់ភិក្ខុសង្ឃក្រុមធំ បបរដែលព្រះថេរៈនាំមកត្រឹមតែមួយបាត្រ ក៏គ្រប់គ្រាន់ដល់ភិក្ខុគ្រប់អង្គ ចំណែកខាងកាកវលិយៈក៏បានតំណែងជាសេដ្ឋីក្នុងថ្ងៃទី ៧ ដូច្នេះ ។

## ធ្វើរបស់មិនឆ្ងាញ់ឱ្យឆ្ងាញ់។ល។ ក៏បាន

មិនមែន ត្រឹមតែធ្វើរបស់តិចឲ្យជារបស់ច្រើនបានប៉ុណ្ណោះទេ សូម្បីការធ្វើផ្សេង ៗ មានការធ្វើរបស់ឆ្ងាញ់ឲ្យជារបស់មិនឆ្ងាញ់ ធ្វើរបស់មិនឆ្ងាញ់ឲ្យជារបស់

ឆ្ងាញ់ដូច្នេះជាដើម អ្នកមានឫទ្ធិប្រាថ្នាធ្វើការយ៉ាងណាៗ ធ្វើយ៉ាងនោះៗ ក៏សម្រេចដល់អ្នកមានឫទ្ធិទាំងអស់ ពិតយ៉ាងនោះមែន ព្រះមហាអនុរុទ្ធត្ថេរនោះ លោកឃើញភិក្ខុជាច្រើនត្រាច់បិណ្ឌបាតបានអាហារអន់ៗ មកនាំគ្នាអង្គុយឆាន់ នៅត្រង់មាត់ប្រាំងស្ទឹង ក៏អធិដ្ឋានថា ទឹកក្នុងស្ទឹងចូរជាសប្បិមណ្ឌៈ ហើយឲ្យសញ្ញាដល់សាមណេរទាំងឡាយ ( គឺពន្យល់ប្រាប់ឲ្យសាមណេរយល់ថា ទឹកក្នុងស្ទឹងក្លាយជាទឹកដោះហើយ ) ទើបសាមណេរទាំងនោះប្រើចានដួសមកប្រគេនភិក្ខុសង្ឃ ភិក្ខុទាំងពួងក៏បានឆាន់អាហារ និងសប្បិមណ្ឌៈដ៏ឆ្ងាញ់នោះ ។

*" **ពាក្យថា.....ដោយចក្ខុទិព្វ** " ជាដើម មានសេចក្តីថា ភិក្ខុអ្នកមានឫទ្ធិនោះស្ថិតនៅក្នុងមនុស្សលោកនេះឯង ចម្រើនអាលោកកសិណ ក៏មើលឃើញរូបរបស់ព្រហ្មនោះ និងលោកក៏ស្ថិតនៅក្នុងមនុស្សលោកនេះឯង កាលព្រហ្មនោះនិយាយក៏បានឮសំឡេង និងដឹងចិត្តរបស់ព្រហ្មនោះបាន ។*

## កាយវសេន ចិត្តបរិណាមនធាដិហារិយ

## " ទៅដោយទិស្សមានកាយក៏បាន "

ពាក្យថា **បង្អោនចិត្តទៅតាមអំណាចកាយ** នោះ មានអត្ថាធិប្បាយថាបង្អោនចិត្តទៅតាមអំណាចរបស់ករជកាយ គឺ កាន់យកចិត្តក្នុងឈានដែលជាបាទលើកទុកក្នុងកាយ គឺ ធ្វើចិត្តនោះឲ្យមានគតិតាមកាយ គឺថា ឲ្យទៅយឺត ដោយថាការទៅនៃកាយរមែងយឺត ព្រោះពាក្យថា ឈានចុះកាន់សុខសញ្ញា ដែលកើតព្រមនឹងឥទ្ធិចិត្ត ដែលមានបាទកឈានជាអារម្មណ៍ សញ្ញាដែលសម្បយុត្តនឹងឧបេក្ខាឈ្មោះថា **សុខសញ្ញា និងលហុសញ្ញា** មានន័យថា ឈានចុះ គឺ ចូលទៅ ពាល់

ត្រូវចូលដល់នូវសុខសញ្ញា និងលហុសញ្ញា ព្រោះឧបេក្ខាលោកពោលថា ជាសុខដ៏ល្អិត និងសញ្ញានោះៗឯង គប្បីជ្រាបថា ឈ្មោះលហុសញ្ញាខ្លះ ព្រោះជាសញ្ញាដែលផុតចាកនីវរណៈទាំងឡាយ និងចាកធម្មៈដែលជាសត្រូវទាំងឡាយ មានវិតក្កជាដើម ( ដែលជារបស់ធ្ងន់ផង ) កាលលោកឈានចុះកាន់សញ្ញានោះ សូម្បីករជកាយក៏រមែងស្រាលដូចប៉ុយសំឡី ដូច្នោះ លោកក៏ទៅព្រហ្មលោកបានដោយទិស្សមានកាយដ៏ស្រាល ដូចប៉ុយសំឡី ត្រូវខ្យល់ផាត់ឡើងទៅ និងកាលខណៈទៅយ៉ាងនោះ បើលោកត្រូវការ លោកនិម្មិតផ្លូវឡើងលើអាកាសដោយអំណាចបឋវីកសិណ ហើយដើរទៅក៏បាន បើលោកត្រូវការ លោកនឹងអធិដ្ឋានឲ្យជាព្យុះឡើង ដោយអំណាចវាយោកសិណ ហើយទៅដោយព្យុះនោះដូចសំឡី រសាត់ទៅដោយខ្យល់ក៏បាន តែតម្រូវការនឹងទៅនោះឯង ជាប្រមាណក្នុងការទៅដោយទិស្សមានកាយនេះ ព្រោះសេចក្តីប្រាថ្នានឹងទៅមានពិត លោកអ្នកមានចិត្តអធិដ្ឋានដែលធ្វើហើយយ៉ាងនោះ នឹងជាអ្នកត្រូវកម្លាំងនៃការអធិដ្ឋានបន្សាត់ឡើងទៅ ក៏ទៅព្រហ្មលោកបាន ទាំងដែលពពួកជនមើលឃើញខ្លួនបាន ដូចសរដែលនាយខ្មាន់ធ្នូបាញ់ចេញទៅដូច្នោះ ។

## ចិត្តវសេនកាយបរិណាមនថាដិហារិយ

### “ ទៅដោយអទិស្សមានកាយក៏បាន ”

ពាក្យថា " **បង្អោនកាយទៅតាមអំណាចចិត្ត** " នោះ អធិប្បាយថា កាន់យកកាយលើកឡើងទុកក្នុងចិត្ត គឺ ធ្វើកាយឲ្យមានគតិតាមចិត្ត គឺថា ធ្វើឲ្យទៅលឿន ព្រោះថា ការទៅនៃចិត្តរមែងលឿន , ពាក្យថា **ឈានចុះចំពោះសុខសញ្ញា និង**

*លហុសញ្ញាក្នុងប្រការនេះ មានសេចក្តីថា ឈានចុះកាន់សុខសញ្ញា និងលហុសញ្ញាដែលកើតព្រមនឹងឥទ្ធិចិត្ត ដែលមានរូបកាយជាអារម្មណ៍ ពាក្យដែលនៅសល់គប្បីជ្រាបតាមន័យដែលពោលហើយនោះចុះ ។*

*ពិតមែន ការ ( បាដិហារិយ៍ ) ទៅក្នុងប្រការនេះ គឺ ការទៅនៃចិត្តនោះឯង តែកាលកើតបញ្ហាឡើងថា អ្នកមានឫទ្ធិនេះ កាលទៅដោយអទិស្សមានកាយយ៉ាងនោះ ទៅក្នុងឧប្បាទក្ខណៈនៃអធិដ្ឋានចិត្តនោះឬ ឬថា ក្នុងឋិតិក្ខណៈ ឬ ក្នុងភង្គក្ខណៈនៃការអធិដ្ឋានចិត្ត ? ព្រះថេរៈក៏ពោលថា “ ទៅបានទាំង ៣ ខណៈ កាលសួរទៀតថា ក៏អ្នកមានឫទ្ធិទៅដោយខ្លួនឯង ឬថា បញ្ជូនរូបនិម្មិតទៅ ? លោកក៏ឆ្លើយថា ធ្វើបានតាមការពេញចិត្ត ” តែការពិត ការទៅដោយខ្លួនឯងនៃអ្នកមានឫទ្ធិនោះៗ មកក្នុងបាទដែលពោលដល់បាដិហារិយ៍ទៅព្រហ្មលោកនេះ ពាក្យថា* **មនោមយ** *គឺ រូបនោះ ឈ្មោះថា* **មនោមយ** *ព្រោះជារូបដែលអ្នកមានឫទ្ធិនិម្មិតឡើងដោយចិត្តអធិដ្ឋាន , ពាក្យថា* **មានឥន្ទ្រិយមិនខ្វះខាត** *នេះ លោកពោលដោយការតាំងនៅព្រមនៃអង្គាវយវៈ មានភ្នែកត្រចៀកជាដើម តែប្រសាទក្នុងរូបនិម្មិតមិនមាន , ពាក្យទាំងពួង* **មានពាក្យថា បើភិក្ខុអ្នកមានឫទ្ធិចង្ក្រម ភិក្ខុនិម្មិតក៏ចង្ក្រមនៅក្នុងព្រហ្មលោកនោះដែរជាដើម** *លោកពោលសំដៅដល់ព្រះសាវកនិម្មិត ចំណែកព្រះពុទ្ធនិម្មិត ព្រះទសពលទ្រង់ធ្វើកិច្ចណាៗ ក៏រមែងធ្វើកិច្ចនោះដែរ រមែងធ្វើកិរិយាដទៃតាមការពេញព្រះទ័យរបស់ព្រះលោកនាថផងដែរ ។*

*ឯក្នុងបាដិហារិយ៍ ប្រើអំណាចដោយកាយនេះ កិរិយាដែលអ្នកមានឫទ្ធិនោះស្ថិតនៅក្នុងមនុស្សលោកនេះឯង ឃើញរូបព្រហ្មបានដោយទិព្វចក្ខុ បានឮសំឡេងព្រហ្ម ដោយទិព្វសោតធាតុ ដឹងចិត្តរបស់ព្រហ្មបានដោយចេតោបរិយញ្ញាណ ត្រឹម*

ប៉ុណ្ណោះនេះនៅមិនឈ្មោះថា ប្រើអំណាចដោយកាយ សូម្បីដែលអ្នកមានឫទ្ធិនោះស្ថិតនៅក្នុងមនុស្សលោកនេះឯង សម្តែងកិរិយាទៅឈរជាមួយគ្នា ប្រាស្រ័យគ្នាសន្ទនាធម៌គ្នានឹងព្រហ្មនោះបាន ត្រឹមនោះក៏នៅមិនឈ្មោះថា ប្រើអំណាចដោយកាយ សូម្បីលោកអធិដ្ឋានបានផ្សេងៗ មានអធិដ្ឋានទីឆ្ងាយឲ្យជាទីជិតក៏បានជាដើម ត្រឹមប៉ុណ្ណោះក៏នៅមិនឈ្មោះថា ប្រើអំណាចដោយកាយ សូម្បីត្រឹមការដែលអ្នកមានឫទ្ធិនោះទៅព្រហ្មលោកដោយទិស្សមានកាយក្តី ដោយអទិស្សមានកាយក្តី ដល់ត្រឹមប៉ុណ្ណោះក៏នៅមិនឈ្មោះថា ប្រើអំណាចដោយកាយ ចំណែកការដែលអ្នកមានឫទ្ធិនោះមកដល់វិធីសម្តែងឫទ្ធិ ដែលពោលទុកដោយន័យថា និម្មិតរូបឡើងចំពោះមុខព្រហ្មនោះបានជាដើម ត្រឹមប៉ុណ្ណោះ ទើបឈ្មោះថា ប្រើអំណាចដោយកាយ ចំណែកវិធីដែលនៅសល់ ( ដូចពោលមកខាងដើម ) លោកពោលទុក ដើម្បីសម្តែងបុព្វភាគនៃការប្រើអំណាចដោយកាយនោះឯង ។

នេះ **អធិដ្ឋានឥទ្ធិ** ឫទ្ធិ គឺ ការអធិដ្ឋានជាលំដាប់ដំបូង ។

## វិកុព្វនាឥទ្ធិ

### “ ឫទ្ធិធ្វើឲ្យប្រែប្រួលចាករូបដើម ”

ចំណែកវិកុព្វនាឥទ្ធិ និងមនោមយាឥទ្ធិ មានសេចក្តីផ្សេងគ្នាដូច្នេះ :

ភិក្ខុអ្នកមានឫទ្ធិកាលធ្វើវិកុព្វនឫទ្ធិមុន ក្នុងរូបរាងទាំងឡាយ មានរាងក្មេងកំលោះជាដើម ដែលលោកពោលទុកក្នុងបដិសម្ភិទាមគ្គយ៉ាងនេះថា ភិក្ខុអ្នកមានឫទ្ធិនោះ លះរូបរាងប្រក្រតីចេញ សម្តែងជារូបក្មេងកំលោះ ឬ សម្តែងជារូបនាគ... រូបគ្រុឌ... រូបអសុរ ឬ សម្តែងជាភេទព្រះឥន្ទ្រ... ភេទទេវតា... ភេទព្រហ្ម

ឬសម្ដែងជារូបសមុទ្រ... រូបភ្នំ ឬ សម្ដែងជារូបសីហៈ... រូបខ្លាដំបង... ខ្លារខិន សម្ដែងជាពលដំរីខ្លះ សម្ដែងជាពលសេះខ្លះ សម្ដែងជាពលថ្មើរជើងខ្លះ សម្ដែងជាពាហនៈខ្លះ សម្ដែងជាក្បួនព័ទ្ធខ្លះ ដូច្នេះ លោកប្រាថ្នារូបរាងណាៗ ក៏គប្បីអធិដ្ឋានរូបរាងនោះៗឡើង ក៏កាលអធិដ្ឋាន ចេញចាកឈានជាបាទនៃអភិញ្ញា មានកសិណក្នុងបណ្ដាកសិណ មានបឋវីកសិណជាដើមណា មួយជាអារម្មណ៍ហើយ គប្បីនឹកដល់ទ្រង់ទ្រាយក្មេងកំលោះរបស់ខ្លួន ហើយក្នុងទីបំផុតនៃបរិកម្ម គប្បីចូលឈានទៀត ចេញហើយទើបអធិដ្ឋានថា យើងចូរជាក្មេងកំលោះមានរូបយ៉ាងនេះចុះ ទន្ទឹមនឹងចិត្តអធិដ្ឋាន លោកក៏ទៅជាក្មេងកំលោះ ដូចព្រះទេវទត្តដូច្នោះ ក្នុងបទទាំងពួង មាន ***នាគវណ្ណំ ទស្សេតិ*** សម្ដែងជារូបនាគជាដើម ក៏មានន័យដូច្នេះ ចំណែកបទថា ***ហត្ថិមបិ ទស្សេតិ*** សម្ដែងជាពលដំរីខ្លះ ក្នុងបាលីនោះ លោកពោលថា សម្ដែងជាពលដំរីជាដើម ឡើងក្នុងខាងក្រៅខ្លះ ក្នុងការសម្ដែងខាងក្រៅនោះ លោកមិនអធិដ្ឋានថា ***ហត្ថី ហោមិ*** យើងចូរជាដំរី តែគប្បីអធិដ្ឋាន ថា ***ហត្ថី ហោតុ*** ដំរីចូរកើតឡើង ន័យសូម្បីក្នុងការអធិដ្ឋានជាសេះជាដើមក៏មានន័យដូច្នេះ ។ នេះ ***វិកុព្វនាឥទ្ធិ*** ឫទ្ធិ គឺ ការធ្វើឲ្យប្រែប្រួលចាករូបដើម ។

## មនោមយាឥទ្ធិ

### *" ឫទ្ធិ គឺ មនោមយៈ "*

ចំណែកភិក្ខុអ្នកប្រាថ្នានឹងធ្វើមនោមយាឥទ្ធិ ចេញចាកឈានដែលជាបាទហើយ ដំបូងក៏នឹកដល់កាយហើយ អធិដ្ឋានដោយន័យដូចពោលហើយនោះឯងថា កាយចូរជាប្រហោង វាក៏ទៅជាប្រហោង ហើយនឹកដល់កាយដទៃ កាយមួយមួយ

តម្រូតឡើងក្នុងខាងក្នុងកាយនោះ ធ្វើបរិកម្មទៅ ហើយអធិដ្ឋានតាមន័យដូចពោល ហើយនោះឯងថា កាយដទៃ គឺ កាយមួយទៀតចូរមានឡើងក្នុងកាយនេះ លោកក៏ដកកាយនោះចេញមកបាន ដូចដកបណ្តូលស្មៅចេញអំពីស្មៅយាប្លង ដូចដកដាវចេញអំពីស្រោម និងដូចទាញពស់ចេញចាកសំណកដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលទុកក្នុងបដិសម្ភិទាមគ្គថា ភិក្ខុក្នុងធម្មវិន័យនេះនិម្មិតកាយដទៃឡើង គឺ កាយមួយទៀតចាកកាយនេះ ឲ្យជាកាយមានរូបមនោមយៈ មានអវយវៈតូចធំគ្រប់គ្រាន់ មានឥន្ទ្រិយមិនខ្វះខាត ប្រៀបដូចបុរសដែលដកបណ្តូលស្មៅចេញអំពីស្មៅយាប្លង កាលទឹកយ៉ាងនេះ ក៏គប្បីមានដល់បុរសនោះឯងថា នេះស្មៅយាប្លងនេះបណ្តូលវា ស្មៅយាប្លងក៏ជាផ្នែកមួយ បណ្តូលវាក៏ជាផ្នែកមួយ តែថាបណ្តូលវាយើងក៏ដកចេញអំពីស្មៅយាប្លងនោះឯង ដូច្នេះជាដើម ក៏ឧបមាក្នុងបាលីនោះលោកពោល ដើម្បីសម្តែងថា បណ្តូលស្មៅជាដើមរមែងមានរូបរាងដូចគ្នានឹងស្មៅយាប្លងជាដើម យ៉ាងណា រូបមនោមយៈក៏មានរូបរាងដូចគ្នានឹងអ្នកមានឫទ្ធិដូច្នោះឯង ។ នេះ **មនោមយាឥទ្ធិ** ឫទ្ធិ គឺ មនោមយៈ ។

# មហាដីកា

## ពណ៌នាកថាស្តីអំពីការទូន្មាននន្ទោបនន្ទនាគរាជ

ព្រះមានព្រះភាគ ទ្រង់ទតមើលទាក់ទងនឹងកិច្ចដែលព្រះពុទ្ធទ្រង់សន្សំ គឺជាព្រះពុទ្ធប្បវេណីថា អ្នកនេះមានឧបនិស្ស័យឬហ្ន៎ ដូច្នេះ ។ លោកអាចារ្យពោលសំដៅយកការធ្លាក់ចុះកាន់ព្រះសាសនា ប្រាកដដូចជាលោកិយ ដែលមានសេចក្តីជ្រះថ្លាក្នុងព្រះរតនត្រៃជាលក្ខណៈ ទើបពោលថា មិនជ្រះថ្លាក្នុងព្រះរតនត្រៃដូច្នេះ ។ អធិប្បាយថា នាគរាជជាអ្នកដែលបុគ្គលត្រូវដោះចាកមិច្ឆាទិដ្ឋិ ហើយទើបធ្វើឲ្យជ្រះថ្លាក្នុងព្រះរតនត្រៃបាន ។ ព្រោះហេតុនោះ ទើបទ្រង់គិតថា អ្នកណាហ្ន៎ នឹងគប្បីជាអ្នកដោះនាគរាជនោះចាកទិដ្ឋិបានដូច្នេះ ។

ពាក្យថា **ក្នុងថ្ងៃនោះ** គឺក្នុងកណ្តាលថ្ងៃ ថ្ងៃនោះដែលជាពេលដែលព្រះមានព្រះភាគត្រូវភិក្ខុសង្ឃព័ទ្ធជុំវិញ ស្តេចតម្រង់ព្រះភក្ត្រទៅកាន់ពិភពតាវត្តិង្ស ។ ពាក្យថា **បានចាត់ត្រៀមអាបានភូមិ** មានសេចក្តីថា នាគរាជនោះអង្គុយធ្វើភោជនកិច្ច គឺការស៊ីផឹកក្នុងទីណា នាគរាជទាំងឡាយក៏ធ្វើស្ថានទីស៊ីផឹកនោះ ឲ្យត្រជាក់រីករាយ និងភ្លឺព្រោងព្រាត ហើយចាត់ត្រៀម គឺត្រៀមការទុកដោយប្រការផ្សេងៗ ។ មានការនាំឧបករណ៍សម្រាប់ធ្វើការស៊ីផឹកចូលទៅជាដើម ។ ពាក្យថា **នាគអ្នករាំ ៣ ជំពូក** គឺ នាគដែលជានាគកញ្ញាអ្នករបាំ ៣ ជំពូក ដែលមានការកំណត់ដោយស្រីក្រមុំ ក្មេងស្រី និងក្មេងតូច ។ ពាក្យថា **អង្គុយសប្បាយ** គឺ អង្គុយមើល ឬពិចារណាដល់របស់ស៊ី និងរបស់ផឹក ។

ពាក្យថា **បរិវេណដែលនៅជិតៗ** គឺលើក្បាល ។ បទថា **ភវនេន** គឺបរិវេណ

ទីលំនៅ ។ ពាក្យថា **រង្វេល** គឺ រង្វេលសរីរៈ ។ បទថា **អវកុជ្ជន** ប្រែថា ផ្កាប់ចុះ ។ ពាក្យថា **ប្រកាន់យក** គឺ គ្របសង្កត់ដោយប្រការដែលមិនឲ្យនៅសល់កពតាវត្តិង្សសូម្បីបន្តិចបន្តួច ។

ពាក្យថា **សិនេរុបរិភណ្ឌ** គឺគ្រឿងប្រដាប់ភ្នំសិនេរុ ។ ឮថា មានបរិមណ្ឌល ៤ យ៉ាង ប្រមាណ ៥០០០ យោជន៍ កំពស់ និងដោយជុំវិញភ្នំសិនេរុ ដែលពួកនាគ ពួកគ្រុឌ ពួកកុម្ភណ្ឌ និងពួកយក្ខទាំងឡាយគ្រប់គ្រង ដើម្បីរក្សាកពតាវត្តិង្សលោករួមបរិភណ្ឌ ៤ យ៉ាង ពួកនោះតែម្យ៉ាង ព្រោះភាពជាបរិភណ្ឌ ដូចគ្នា ពោលថា **បរិភណ្ឌំ** ដូច្នេះ ។

បានឮមកថា បរិភណ្ឌពាក់កណ្តាលនៃភ្នំសិនេរុ ត្រូវពួកនាគទាំងនោះគ្រប់គ្រងទុក ។

ពាក្យថា **ព្រះថេរៈលះអត្តភាព** គឺធ្វើរូបមនុស្សឲ្យរលាយបាត់ទៅ ។ ពាក្យថា **មិនធ្វើឲ្យលំបាក** គឺមិនធ្វើសូម្បីត្រឹមតែការលំបាកឲ្យកើតឡើងបានទេ ។

ពាក្យថា **លះអត្តភាព** គឺលះរូបនាគចេញដោយការនិម្មិតជាអត្តភាពដ៏ល្អិតតូច ។ នាគរាជហាមាត់ឡើងដោយពាក្យថា យើងនឹងទំពាស៊ីសមណៈអ្នកនៅក្នុងមាត់ , ពាក្យថា **ទិសខាងកើត និងទិសខាងលិច** លោកពោលទុកព្រោះនាគដេកដោយអាការយ៉ាងនោះ ។ ព្រះមានព្រះភាគត្រាស់ថា " អ្នកចូរដឹងជាដើម " ទ្រង់បំណងឲ្យតាំងសតិទុកចំពោះមុខដោយល្អ ។

ពាក្យថា **បាដិហារិយ៍ទាំងអស់តាំងពីដើម** លោកពោលសំដៅយកបាដិហារិយ៍ដែលព្រះថេរៈបានធ្វើហើយយ៉ាងនោះ ។ ពាក្យថា **តែលុះដល់ឋានៈនេះ** លោកពោលសំដៅយកហេតុ គឺ ការផុតខ្យល់ច្រមុះ ។ ពាក្យថា **ជាប់តាម** គឺ ដេញតាម

នាគរាជដែលគេចទៅព្រោះខ្លាចថា យើងមិនអាចទម្លាយសមណៈនេះ ដែលមានឫទ្ធិច្រើន យ៉ាងនេះបាន ។

បទថា **ឯកបដិបាដិយា** ប្រែថា ដោយលំដាប់ ១ មានសេចក្តីថា មិនមានរវាង ។ ពាក្យថា **នេះឯង** គឺការអាស្រ័យឧបាទិន្នកសង្ខារ លូកអនុបាទិន្នកសង្ខារទៅឯណា នេះឯងជាខយុត្តិ គឺបែបបទដ៏ត្រឹមត្រូវក្នុងបាដិហារិយ៍ មានការលូកដៃទៅជាដើម ខនេះគឺប្រាកដដូច្នេះ ព្រោះឧបាទិន្នកទាំងឡាយមិនកើតអំពីចិត្ត ឬ ឧតុន័យម្យ៉ាងទៀត ពាក្យថា **ឧបាទិន្នខន្ធ** សំដៅយកខន្ធដែលទាក់ទងដោយឥន្ទ្រិយទាំងអស់នោះឯង ។ សូម្បីកាលជាយ៉ាងនេះ ការប្រកាន់ឧបាទិន្នខន្ធនោះទៅដោយប្រការយ៉ាងនោះ ទើបមិនត្រឹមត្រូវឡើយ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបដល់ការប្រកាន់ទៅតាមន័យដែលបានពោលមកហើយប៉ុណ្ណោះ ។ ឧបាទិន្នខន្ធ និងអនុបាទិន្នខន្ធ សូម្បីជាប្រព្រឹត្តទៅក្នុងសេចក្តីជាប់គ្នា ដូចលាយឡំគ្នា តែដោយសភាវៈមិនលាយឡំគ្នាទេ ។ ក្នុងខន្ធទាំងពីរយ៉ាងនោះ ដូចជា កាលគេស្រោចទឹកដោះដែលមានត្រឹម ១ អាឡ្ហកៈ ( មួយអាឡ្ហកស្មើនឹងបីនាឡិមគធៈ ) ចុះលើទឹកដែលមានច្រើនអាឡ្ហកៈ ទឹកដោះនោះលាយឡំទៅជាមួយនឹងទឹកគ្រប់ចំណែក តាំងនៅជារបស់មានគ្រប់ចំណែកនោះឯង ក៏ពិត សូម្បីយ៉ាងនោះ ទឹកដោះ និងទឹកនោះ ក៏មិនរីកខួន ( មិនចម្រើនឡើង ) ។ ទឹកប៉ុណ្ណោះដែលរីកខួន( ចម្រើនឡើង ) យ៉ាងណា ឧបាទិន្នខន្ធ និងអនុបាទិន្នខន្ធ ក៏រមែងប្រព្រឹត្តទៅ ដូចលាយឡំគ្នាយ៉ាងនេះក៏ពិត ។ សូម្បីយ៉ាងនោះ ឧបាទិន្នខន្ធក៏រីកមិនបាន គប្បីឃើញថា រូបដែលកើតអំពីចិត្ត រមែងរីកទៅបាន ព្រោះឥទ្ធានុភាព និងរូបដែលកើតអំពីឧតុ ក៏រមែងរីកទៅបាន ដោយអនុលោមតាមរូបដែលកើតអំពីចិត្តនោះ ដូច្នេះ ។

ពាក្យថា **ភិក្ខុអង្គនោះ** គឺភិក្ខុអ្នកមានឫទ្ធិច្រើននោះ ។ ពាក្យថា **កាលធ្វើយ៉ាងនេះហើយ** គឺកាលលូកដៃទៅដោយអាការដែលពោលមកហើយ ឬកាលធ្វើព្រះចន្ទ និងព្រះអាទិត្យទាំងនោះឲ្យមកតាំងនៅក្នុងហត្ថបាសហើយ ។ សូម្បីកិរិយាមានការដាក់ជើងជាដើម បណ្ឌិតក៏គប្បីជ្រាបតាមន័យដែលបានពោលមកហើយនោះឯង ។ ឈ្មោះថា **ភិក្ខុសូម្បីអង្គដទៃ** គឺភិក្ខុអ្នកមានឫទ្ធិសូម្បីអង្គដទៃ ។ ពាក្យថា **គង់មានយ៉ាងនោះឯង** គឺគង់នៅមាន ដូចក្នុងកាលមុនអំពីការធ្វើបាដិហារិយ៍ ។ ពាក្យថា **បាដិហារិយ៍ប្រការនេះ** ក៏មានឧបមាដូច្នេះ អធិប្បាយថា ប្រៀបដូចជាកាលបុគ្គលជាច្រើន ឃើញដួងព្រះចន្ទផ្សេងៗ នៅក្នុងពាងផ្សេងៗដ៏ពេញដោយទឹក ព្រះចន្ទក៏មិនមានការឈប់ ការញុំាងកិច្ច មានការគោចរទៅជាដើម ព្រោះហេតុនោះទេ ។ និងបុគ្គលទាំងឡាយជាច្រើន ម្នាក់ៗ ក៏សម្រេចការមើលឃើញដូចព្រះចន្ទបានយ៉ាងណា ។ បាដិហារិយ៍នេះក៏មានឧមេយ្យដូច្នេះ ព្រោះព្រះចន្ទ និងព្រះអាទិត្យ មិនមានការឈប់ ញុំាងកិច្ច មានគោចរទៅជាដើម និងព្រោះលោកអ្នកមានអ្នកមានឫទ្ធិទាំងឡាយជាច្រើន ក៏មានសេចក្តីសម្រេចបយោគ គឺ វិធីការនៃឫទ្ធិក្នុងបាដិហារិយ៍ប្រការនេះបានតាមដែលប្រាថ្នា ។

ពាក្យថា **ធ្វើឲ្យជាក្របខណ្ឌ** គឺ ធ្វើឲ្យមានដែនកំណត់ ដោយទាក់ទងនឹងអភិវិធី( ដែន ) មិនមែនទាក់ទងនឹងបរិយាទ គឺ ព្រំដែនទេ ។ ពិតយ៉ាងនោះ លោកអ្នកមានឫទ្ធិនោះ រមែងធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយរបស់ខ្លួនក្នុងព្រហ្មលោកបាន ។ ពាក្យថា **ព្រះបាលី** គឺ ព្រះបាលីបដិសម្ភិទាមគ្គ ។

ក្នុងពាក្យថា **ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយរហូតដល់ព្រហ្មលោកខ្លះ** នេះ មានន័យថា ព្រោះហេតុដែលមិនបានបំណងយកការទៅកាន់ព្រហ្មលោក ទាំងមិន

បានបំណងចំពោះការទៅកាន់ព្រហ្មលោក , តែថា ប្រាថ្នាយកអាការធ្វើសូម្បីយ៉ាងដទៃដោយប្រការដទៃ ។ ក៏ពាក្យថា **រហូតព្រហ្មលោកនេះ** ត្រឹមជាពាក្យសម្ដែងផែនដីដែលនៅឆ្ងាយ ដូច្នេះ ព្រះថេរៈពោលថា បើជាអ្នកត្រូវការទៅកាន់ព្រហ្មលោកដូច្នោះ ដូច្នេះហើយ ប្រាថ្នាសម្ដែងការធ្វើសូម្បីក្រៅពីនេះ ទើបពោលថា ក៏រមែងអធិដ្ឋានទីទាំងដែលនៅឆ្ងាយឲ្យជាទីនៅជិត ដូច្នេះជាដើម ។ **បិ**-ស័ព្ទ ក្នុងបទថា **ទូរេបិ** ( ទាំងទីនៅឆ្ងាយនោះ ) មានអត្ថថា **សមុច្ចយ** ( ថែម , រួបរួម ) ។ ដោយបិ-ស័ព្ទនោះ បណ្ឌិតគប្បីឃើញថា មានការរួមយកកិច្ចទាំងអស់ ដែលគប្បីធ្វើឲ្យសម្រេចបានដោយអធិដ្ឋានាឥទ្ធិ ដ៏សេសអំពីការដែលបានពោលមកហើយមិនមែនចំពោះកិច្ចដែលពោលមកហើយប៉ុណ្ណោះ ។

ដោយពាក្យថា **ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារិយ៍ជាដើម** លោកពោលដល់ការៈដែលស្ដេចយាងទៅស្ថានសួគ៌ សម្រេចបានដោយអធិដ្ឋានាឥទ្ធិ ។ ចំណែកសេចក្ដីជាលក្ខណានិសង្ស គឺលក្ខណៈដែលជាអានិសង្ស លោកបានពោលទុកក្នុងបាដិហារិយ៍យ៉ាងដទៃ ។ បណ្ឌិតគប្បីវិចារបាដិហារិយ៍ទាំងពីរនោះ ដោយប្រការដែលមិនខុសគ្នានិងគ្នា ហើយសឹមកាន់យកចុះ ។

បទថា **នីលមាតិកំ** គឺ ប្រឡាយទឹកដែលមានពណ៌ខៀវ ។

ពាក្យថា **ព្រះមហាពោធិ៍** គឺព្រះមហាពោធិ៍ដែលជាបល្ល័ង្កដែលមារធ្វើឲ្យខ្ចាត់ខ្ចាយមិនបាន ។ ពាក្យថា **កាលកើតការគិត** គឺបានធ្វើឲ្យនៅក្នុងទីជិត គឺបានបំព្រួញផែនដី , ធ្វើឲ្យសមុទ្រនៅក្នុងទីជិតព្រះមហាពោធិ៍ ក្នុងលំដាប់ការគិតដែលកើតឡើងយ៉ាងនោះៗ ឯង ។

ពាក្យថា **ក្នុងថ្ងៃនក្ខត្តឫក្ស** គឺ ក្នុងថ្ងៃដែលមានការលេងនក្ខត្តឫក្ស ។

ពាក្យថា **នំលោកវែខ** គឺ នំដែលដូចព្រះចន្ទ គឺ មានអាការតាំងនៅដូចដួងចន្ទ ។ ពាក្យថា **បានធ្វើឲ្យនៅសល់ត្រឹមតែមួយបាត្រ** គឺ បានធ្វើឲ្យនំទាំងនោះដាក់ចូលក្នុងបាត្រមួយ ដោយបំព្រួញខ្នាតនោះឯង ។

គប្បីនាំពាក្យពោលមកសម្ពន្ធគ្នាថា **កាកវឡិយវត្ថុស្មិញ្ច ភគវា ថោកំ ពហុំ អកាសិ** ( ក្នុងរឿងកាកវឡិយ ព្រះមានព្រះភាគក៏ទ្រង់ធ្វើរបស់ដែលតិចតួច ឲ្យជារបស់ដែលមានច្រើន )។ ក៏ដើម្បីសម្តែងរឿងនោះដោយបំព្រួញនោះឯង ទើបលោកអាចារ្យពោលថា មានរឿងថា ព្រះមហាកស្សបៈដូច្នេះជាដើម ។ ពាក្យថា **ដោយសមាបត្តិ** គឺ ដោយនិរោធសមាបត្តិ ។

ពាក្យថា **ត្រង់ប្រាំងស៊ីង** គឺត្រង់ប្រាំងនៃស៊ីងគង្គាក្នុងតម្ពបណ្ណិទ្វីប ។ ពាក្យថា **បានឲ្យសញ្ញា** គឺ បានឲ្យសញ្ញាដែលធ្វើឲ្យសាមណេរទាំងនោះ នឹងមើលឃើញទឹកដោះថ្លាតាមដែលអធិដ្ឋានទុកនោះ ។

បទថា **តស្ស** មានសេចក្តីថា ភិក្ខុអ្នកមានឫទ្ធិជាអ្នកត្រូវការឃើញរូបរបស់ព្រហ្មណា ក៏រមែងឃើញរូបរបស់ព្រហ្មនោះបាន ។ ពាក្យថា **បានឮសំឡេង** គឺបានឮសំឡេងព្រហ្មដោយសោតធាតុដែលជាទិព្វ ។ ពាក្យថា **រមែងដឹងចិត្ត** គឺរមែងដឹងចិត្តរបស់ព្រហ្មដោយចេតោបរិយញ្ញាណ ។ ពាក្យថា **តាមអំណាចនៃករជកាយ** គឺ តាមអំណាចនៃរូបកាយប្រកបដោយមហាភូត ៤ ។ ក្នុងពាក្យថា **ធ្វើចិត្តឲ្យបង្អោនទៅនេះ** លោកអាចារ្យធ្វើទុកក្នុងចិត្តថា ចិត្តដូងនេះ គឺ ចិត្តអ្វី , ម្យ៉ាងទៀត តើដូចម្តេចទើបឈ្មោះថា ធ្វើឲ្យបង្អោនទៅដូច្នោះ ហើយទើបពោលថា បានដល់ការកាន់យកឈានចិត្តដែលជាបាទ លើកឡើងទុកក្នុងកាយ ដូច្នេះ ។ លោកធ្វើទុកក្នុងចិត្តថា តែថាលើកឡើងទុកក្នុងកាយដូចម្តេច ដូច្នេះហើយ ទើបពោលថា គឺ

ធ្វើឲ្យបណ្តោយតាមកាយ ដូច្នេះ ។ លោកអាចារ្យកាលនឹងកាត់គន្លងនៃពាក្យពោលថា **ឯវម្បិ សទ្ទូនេ វាយំ** ដូច្នេះទើបពោលថា **ទន្ធគមនំ**( ឲ្យជាចិត្តដែលមានការទៅយឺតយូរ ) សម្ពន្ធចូលនឹងបទថា **ករោតិ** គឺ ធ្វើ ។ អធិប្បាយថា ពិតហើយ ការទៅដោយកាយ រមែងជាការយឺតយូរ ព្រោះមានមហាភូតរូបដែលយឺតយូរ គឺ ធ្ងន់ ជាបច្ច័យ ។ ក៏អត្ថាធិប្បាយក្នុងសេចក្តីខនេះ មានដូច្នេះ ព្រះយោគី អ្នកធ្វើទុកក្នុងចិត្តឲ្យបង្អោនទៅដោយអំណាចនៃសេចក្តីត្រូវការនឹងទៅដោយកាយ ដែលអ្នកណាៗ មើលឃើញបាន តែងចូលឈានដែលជាបាទហើយ ក៏ធ្វើបរិកម្មថា ចិត្តនេះចូរមានការទៅបានយឺតៗ ដូចគ្នានឹងកាយចុះដូច្នេះ ។ ក៏លោកអាចារ្យសំដៅយកការធ្វើ បរិកម្មទុកយ៉ាងនោះ ពោលថា បានដល់ កាន់យកឈានចិត្តដែលជាបាទដូច្នេះ ។ ក៏ព្រះយោគីកាលធ្វើបរិកម្មហើយ កាលចូលឈានម្តងទៀត ហើយអធិដ្ឋានដោយញាណ ក៏ឈ្មោះថា លើកចិត្តនោះចូលទុកក្នុងកាយ គឺធ្វើឲ្យជាចិត្តបណ្តោយតាមកាយ ឲ្យជាចិត្តដែលមានការទៅយឺតៗ ។

ពាក្យថា **សុខសញ្ញា** បានដល់ សញ្ញាដែលសហគតៈជាមួយពាក្យសម្តែងខៃដោយមានសញ្ញាជាប្រធាន ។ ឈ្មោះថា **លហុសញ្ញា** ព្រោះអត្ថថា កំណត់ដឹងដោយភាពជារបស់ស្រាល ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ក៏សុខសញ្ញាមានការកើតឡើងព្រមជាមួយនឹងឥទ្ធិចិត្តបានដូចម្តេច ដូច្នេះហើយ ទើបពោលថា សញ្ញាដែលសម្បយុត្តនឹងឧបេក្ខា ឈ្មោះថា **សុខសញ្ញា** ដូច្នេះ ។ ម្យ៉ាងទៀត ឈ្មោះថា **សុខសញ្ញា** ព្រោះអត្ថថា កំណត់ដឹងជាសុខ ។ ព្រោះហេតុនោះឯង ទើបលោកពោលថា ពិតមែន ឧបេក្ខាលោកពោលថាជាសុខដ៏ស្ងប់ ដូច្នេះ ។ លោកអាចារ្យកាលសម្តែងថា ការប្រាសចាកនីវរណៈទាំងឡាយ ទើបជារបស់ធ្ងន់តែម្យ៉ាង និង

ចាកអង្គគ្រោតគ្រាតទាំងឡាយ មានវិតក្កជាដើម ដែលមានសភាវៈមិនស្ងប់ ជាហេតុនៃភាពស្រាលរបស់ចិត្ត និងចេតសិកទាំងឡាយ ដូច្នេះ ទើបពោលថា ***សាយេវ ។ បេ ។ វេទិតព្វា*** ដូច្នេះ ។ ពាក្យថា ***របស់ព្រះយោគីអ្នកឈានចុះកាន់សុខសញ្ញា និងលហុសញ្ញានោះ*** គឺរបស់ភិក្ខុអ្នកដល់សុខសញ្ញា លហុសញ្ញានោះតាមលំដាប់ ។ បទថា ***អស្ស*** បានដល់ព្រះយោគី ។ ក្នុងពាក្យថា ***សេចក្តីត្រូវការទឹងទៅនោះឯង ជាប្រមាណនោះឯងក្នុងទីនេះ*** មានអធិប្បាយថា ក្នុងការទៅដោយកាយដែលពពួកជន មើលឃើញបាន នេះព្រះយោគីជាអ្នកត្រូវទឹងទៅក្នុងស្ថានទីណា នៅត្រូវការទឹងទៅដរាប , ការបរិកម្ម និងការអធិដ្ឋានដែលប្រព្រឹត្តទៅដោយអំណាចសេចក្តីត្រូវការទឹងទៅកាន់ស្ថានទីនោះឯង ជាប្រមាណ ។ ព្រោះដូច្នោះ ការទៅដល់ស្ថានទីដែលត្រូវការរមែងមានបាន សូម្បីដោយការវៀរចាកការនិម្មិតផ្លូវ និងការអធិដ្ឋានឲ្យមានខ្យល់ដូច្នេះ ។ ឥឡូវនេះ ដើម្បីនឹងធ្វើសេចក្តីនោះៗឯងឲ្យកាន់តែជាក់ច្បាស់ក្រៃលែងឡើងទៅ ទើបលោកពោលថា ពិតហើយ កាលមានសេចក្តីត្រូវការទឹងទៅដូច្នេះជាដើម ។

ពាក្យថា ***កាន់យកកាយ*** គឺកាន់យករជកាយដោយបរិកម្មចិត្ត ដោយទាក់ទងនឹងការធ្វើបានឲ្យជាអារម្មណ៍ ។ ពាក្យថា ***លើកឡើងទុកក្នុងចិត្ត*** គឺលើកឡើងទុកក្នុងឈានចិត្តដែលជាបាទ គឺ ធ្វើឲ្យប្រព្រឹត្តទៅតាមឈានចិត្តនោះថា កាយនេះចូរដូចជាចិត្តនេះចុះ ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា បានដល់ធ្វើឲ្យបណ្តោយតាមចិត្ត ឲ្យជាកាយដែលមានការទៅបានលឿន ដូច្នេះ ។ ពាក្យថា ***ការទៅដោយចិត្ត*** លោកពោលដល់ការប្រព្រឹត្តទៅនៃចិត្ត ។ ក៏ឈ្មោះថា ***បាដិហារិយ៍នេះ*** បានដល់ បាដិហារិយ៍ គឺ ធ្វើកាយឲ្យស្រេបទៅតាមចិត្ត ។ ពាក្យថា ***ជាការ***

**ទៅដោយចិត្តនោះ** គឺជាការទៅព្រមគ្នានឹងចិត្តនោះ ។ សួរថា កាយមានការប្រព្រឹត្តទៅយឺតៗ និងមានការប្រព្រឹត្តទៅព្រមគ្នានឹងចិត្តដែលផ្លាស់ប្តូរបានរហ័សដូចម្តេច ? ឆ្លើយថា កាយមិនមែនមានការប្រព្រឹត្តទៅព្រមគ្នានឹងចិត្តគ្រប់ប្រការទាំងពួងទេ ។ ដូចជាក្នុងការធ្វើចិត្តឲ្យបង្អោនទៅតាមអំណាចកាយ ចិត្តមិនបានមានការប្រព្រឹត្តទៅព្រមគ្នានឹងកាយដោយប្រការទាំងពួងទេ ។ ព្រោះថា ក្នុងពេលនោះចិត្តមិនបានប្រព្រឹត្តទៅតាមខណៈរបស់ខ្លួន ដែលសម្រេចដោយសភាវៈ ទើបមិនបានប្រព្រឹត្តទៅតាមខណៈរបស់រូបធម៌ ដែលមានការប្រព្រឹត្តទៅធ្ងន់ ឬ យូរទេ ។ តែដោយការអធិដ្ឋានថា ចិត្តនេះចូរដូចជាកាយនេះចុះ ដូច្នេះ ចិត្តដែលកំពុងប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា ដោយអនុលោមតាមការប្រព្រឹត្តទៅនៃកាយនោះឯង រមែងឈ្មោះថា ជាការបង្អោនទៅតាមការប្រព្រឹត្តទៅនៃកាយ ដរាបដែលនៅមានការទៅកាន់ស្ថានទី ដែលត្រូវការដោយប្រព្រឹត្តទៅតាមកាយ ដែលមានការប្រព្រឹត្តទៅយឺតយូរយ៉ាងណា ដោយការអធិដ្ឋានថា កាយនេះ ចូរដូចជាចិត្តនេះចុះ ដូច្នេះ កាយដែលមិនបានប្រព្រឹត្តទៅយឺតយូរ ដូចការប្រព្រឹត្តទៅនៃឥទ្ធិបាទដែលមិនបានអប់រំ ព្រោះសុខសញ្ញា លហុសញ្ញាធ្វើឲ្យដល់ព្រមហើយ កំពុងប្រព្រឹត្តទៅដោយការទៅកាន់ស្ថានទីដែលត្រូវការបាន ដោយវារៈចិត្តដ៏លឿន ២-៣ វារៈប៉ុណ្ណោះ រមែងឈ្មោះថា ជាការដែលបង្អោនទៅតាមការប្រព្រឹត្តទៅនៃចិត្ត មិនឈ្មោះថាជាការបង្អោនទៅតាមការប្រព្រឹត្តទៅនៃចិត្ត ព្រោះការទៅដល់ស្ថានទីដែលប្រាថ្នាបានដោយខណៈចិត្តមួយទេ ដូច្នេះ ។

ព្រោះធ្វើអធិប្បាយយ៉ាងនេះ ពាក្យឧបមាដែលថា ប្រៀបដូចបុរសអ្នកមានកម្លាំង គប្បីលាតដៃដែលបត់ ឬថា គប្បីបត់ដៃដែលលាត យ៉ាងណា នេះទើបជា

ការផ្ចង់ហើយដោយបរិយាយនោះឯង ។ បណ្ឌិតគប្បីទទួលពាក្យអត្ថាធិប្បាយនេះបាន ដោយប្រការដូចពោលនេះជាពិតប្រាកដ ប្រសិនបើដោយប្រការដទៃ ក៏នឹងគប្បី មានសេចក្ដីខុសគ្នានឹងបាទក្នុងព្រះសូត្រ និងព្រះអភិធម្ម ព្រមទាំងព្រះអដ្ឋកថាព្រះវិន័យ និងមិនស្របតាមធម្មតា ។ ពិតមែន ក្នុងពាក្យថា **នាហំ ភិក្ខវេ អញ្ញំ ឯក ធម្មម្បិ** ( ម្នាលភិក្ខុទាំងឡាយ តថាគតរកមើលមិនឃើញធម៌យ៉ាងដទៃសូម្បីត្រឹមតែមួយ ) ជាដើមនេះ ដោយស័ព្ទថា **អញ្ញំ**( យ៉ាងដទៃ ) ទ្រង់កាន់យកពួករូបធម៌ទាំងឡាយ ព្រោះមិនមានការផ្លាស់ប្ដូរបានរហ័ស ។ ម្យ៉ាងទៀត ក្នុងព្រះអភិធម្មពោលដល់បុរេជាតប្បច្ច័យថាជារូបប៉ុណ្ណោះ និងពោលជាបច្ឆាជាតប្បច្ច័យនៃនាម ដល់រូបនោះៗឯង ។ ធម៌ទាំងឡាយរមែងកើតក្នុងទីណាៗ ក៏រមែងបែកធ្លាយទៅក្នុងទីនោះៗឯង ។ មិនមានការឃ្លាតទៅកាន់ស្ថានទីដទៃ ។ និងមិនមានដោយប្រការដទៃអំពីសភាវៈដូច្នេះ ។ សេចក្ដីពិតថា ពពួកជនមិនអាចប្រើកម្លាំងឫទ្ធិធ្វើលក្ខណៈរបស់ធម៌ទាំងឡាយឲ្យមានភាពជាយ៉ាងដទៃបានឡើយ , តែអាចនឹងធ្វើភាវៈ ការប្រាកដ ឲ្យមានភាពជាយ៉ាងដទៃបាន ។ លោកអាចារ្យជាច្រើនពោលថា សូម្បីពាក្យក្នុងខណៈទាំង ៣ នេះ លោកពោលសំដៅយកការផ្ដើមទៅមិនបានពោលយកការសម្រេចអស់ការទៅ ។ ពាក្យថា **ព្រះថេរៈ** បានដល់ ព្រះថេរៈមួយអង្គក្នុងបណ្ដាព្រះអដ្ឋកថាទាំងឡាយ ។ ពាក្យថា **ក្នុងបាទនេះ** គឺ ក្នុងបាទដែលពោលចែក **វិកុព្វនបាដិហារិយ៍នេះ** ។ ឈ្មោះថា ការទៅនោះឯង ជាការមកហើយ ព្រោះលោកបានពោលទុកហើយថា **ព្រហ្មលោកំ គច្ឆតិ** គឺ រមែងទៅកាន់ព្រហ្មលោក ដូច្នេះ ។

ពាក្យថា **ចក្ខុសោតាទីនំ** ប្រែថា នៃអវយវៈទាំងឡាយ មានភ្នែក ត្រចៀក

ជាដើម ។ ពិតយ៉ាងនោះ លោកពោលទុកថា **សព្វង្គប្បច្ចង្គំ** មានសេចក្ដីថា **សព្វង្គបច្ចង្គវន្តំ**-បរិបូរណ៍ដោយអវយវៈតូចធំ ។ ម្យ៉ាងទៀត ដោយពាក្យថា ឈ្មោះថា ប្រសាទរមែងមិនមាន នេះគប្បីឃើញថា លោកពោលដល់ការមិនមាននៃឥន្ទ្រិយ គឺ ភាវៈ និងជីវិត ។ បទថា **រុចិរសេន** គឺដោយទាក់ទងនឹងព្រះបំណង។ ពាក្យថា **កិរិយាជវេ** គឺ រមែងធ្វើកិរិយាជវទៃពីព្រះកិរិយាដែលព្រះមានព្រះភាគទ្រង់ធ្វើ ។ សេចក្ដីដែលពោលមកនេះ ជាពុទ្ធានុភាពក្នុងបាដិហារិយ៍នេះ ។ សួរថា បើក្នុងរូបទាំងឡាយដែលសាវកនិម្មិតឡើងហើយ មិនមានប្រការផ្សេងៗគ្នា , ពាក្យណាដែលលោកពោលទុកក្នុងបទក្រោយថា បើភិក្ខុជាអ្នកត្រូវការធ្វើឲ្យជាអ្នកមានរូបរាងផ្សេងៗគ្នាដូច្នោះ ដូច្នេះជាដើម ពាក្យនោះមានអត្ថាធិប្បាយ យ៉ាងដូចម្ដេច ? ឆ្លើយថា ពាក្យនោះលោកពោលទុក ធ្វើអត្ថាធិប្បាយថា កាលភិក្ខុធ្វើបរិកម្មទុកដោយប្រការនោះ ហើយអធិដ្ឋានរូបនិម្មិតទាំងនោះ ដែលផ្សេងគ្នាដោយរូបរាង វ័យជាដើម រមែងសម្រេចបានតាមសមគួរដល់បរិកម្ម ។ គឺលោកសម្ដែងអត្ថាធិប្បាយប្រការនេះថា ក្នុងរូបនិម្មិតតាមដែលបានអធិដ្ឋានទុកហើយយ៉ាងនេះ បើពួកសាវកប្រាថ្នាថា សូមរូបនិម្មិតទាំងនោះចូរមានការខុសប្លែកគ្នាចុះ ដូច្នេះ រមែងមិនសម្រេច តែសម្រាប់ព្រះពុទ្ធរមែងសម្រេច ព្រោះហេតុនោះ ពាក្យដែលលោកពោលទុកក្នុងពេលក្រោយនោះ ទើបមិនមានការភ្ញាំងភ្ញាត់ឡើយ ។

ឥឡូវនេះ បាដិហារិយ៍ ១៤ យ៉ាង មានប្រការថា រមែងអធិដ្ឋានទីទាំងដែលទីឆ្ងាយឲ្យជាទីដែលនៅជិត ដូច្នេះជាដើម ដែលលោកអាចារ្យបានចែកទុកដោយតាមរយៈពាក្យសម្ដែងអត្ថនៃព្រះបាលីថា ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយរហូតដល់ព្រហ្មលោកខ្លះ ដូច្នេះជាដើម ពួកនោះឯណាក្នុងបាដិហារិយ៍ ១៤

យ៉ាងនោះ លោកអាចារ្យប្រាថ្នាសម្ដែងបាដិហារិយ៍ ប្រការដែលមានការធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដល់កំពូល ទើបផ្ដើមពាក្យថា ម្យ៉ាងទៀតក្នុងឋានៈនេះ ដូច្នេះជាដើម ។ ក្នុងបណ្ដាបទទាំងនោះ បទថា **យំ** ជាកិរិយាបរាមាស , ដោយបទថា **យំ** នោះ គប្បីឃើញថា ប្រកាន់យកកិរិយាមើលឃើញរូបដែលស្ដាប់សំឡេង ដែលដឹងចិត្ត ដែលមានទិព្វចក្ខុ ទិព្វសោត និងចេតោបរិយញ្ញាណជាអ្នកធ្វើយ៉ាងនេះថា ការមើលឃើញរូបនេះឯណា ក្នុងកិរិយាបទថា **រូបំ បស្សតិ** ( រមែងមើលឃើញរូប ) ការស្ដាប់សំឡេងនេះឯណា ក្នុងកិរិយាបទថា **សទ្ទំ សុណាតិ** ( រមែងស្ដាប់សំឡេង ) ការដឹងចិត្តនេះឯណា ក្នុងកិរិយាបទថា **ចិត្តំ បជានាតិ** ( រមែងដឹងចិត្ត )ដូច្នេះ។ សូម្បីក្នុងកិរិយាបទដទៃពីបទនេះ មានបទថា **សន្តិដ្ឋតិ**( ឈរ )ជាដើម ក៏មានន័យដូច្នេះ ។ បទថា **យម្បិស្ស** កាត់ជា **យម្បិ អស្ស** ។ សម្ពន្ធនឹងពាក្យថា **យោគិនោ អធិដ្ឋានំ** - ប្រែសេចក្ដីពេញថា សូម្បីប្រការថា យោគីភិក្ខុមានការអធិដ្ឋាន ។ **ខោ**-ស័ព្ទ ក្នុងពាក្យថា **យញ្ច ខោ** នេះ មានអត្ថថា ជាអវធារណៈ ឬ មានអត្ថថា ជាវិសេសនៈ ដោយ **ខោ**-ស័ព្ទនោះ លោកសម្ដែងថា ក្នុងបណ្ដាបាដិហារិយ៍ដែលជាការធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយទាំងឡាយនេះ បាដិហារិយ៍( និម្មិតរូបឡើងខាងមុខព្រហ្ម )នេះប៉ុណ្ណោះ ជាបាដិហារិយ៍ដ៏ឧក្រិដ្ឋក្រៃលែង ។ ព្រោះហេតុអ្វី ព្រោះធ្វើការសង្ស័យក្នុងចិត្តឲ្យកើតដល់ព្រហ្មអង្គខ្លះបានថា នេះគឺអ្នកមានឫទ្ធិឬហ្ន៎ នេះគឺរូបនិម្មិតឬហ្ន៎ ដូច្នេះ ។ វិធីការដែលអធិដ្ឋានទុកនេះ លោកហៅឲ្យប្លែកទៅថា **មនោមយំ** គឺ សម្រេចដោយចិត្ត ព្រោះហេតុប្រធានឯណា គប្បីជ្រាបថា ជាវិធីការដ៏ឧក្រិដ្ឋក្រៃលែង ព្រោះហេតុជាប្រធាននោះ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ដោយការធ្វើបានត្រឹម

ប៉ុណ្ណោះ ទើបឈ្មោះថា រមែងធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដូច្នេះ ។ លោកអាចារ្យធ្វើពាក្យជញ្ជីងទុកក្នុងចិត្តថា ប្រសិនបើដូច្នេះ ព្រោះហេតុអ្វី ក្នុងបាដិហារិយ៍នេះ ទើបលោកបានកាន់យកវិធីការដែលនៅសល់ដែរ ដូច្នេះ ហើយទើបពោលថា **សេសំ ។ បេ ។ វុត្តំ** ដូច្នេះជាដើម ។

ពាក្យថា **ចំណែកតទៅនេះជាប្រការផ្សេងគ្នា** សេចក្ដីថា ឫទ្ធិ ២ យ៉ាងទាំងនេះ រមែងសម្រេចបានដោយអំណាចការអធិដ្ឋានក៏ពិត សូម្បីយ៉ាងនោះ ឫទ្ធិដែលកំពុងពោលដល់ក្នុងឥឡូវនេះ ពួកនេះក៏មានដូចតទៅនេះ ជាប្រការផ្សេងគ្នា គឺ ប្លែកគ្នា ។ ពាក្យថា **លះរូបរាងតាមប្រក្រតី** គឺលះបានកម្ចាត់រូបរាងតាមប្រក្រតីចេញ មានសេចក្ដីថា មិនធ្វើឲ្យប្រាកដដល់អ្នកដទៃ ។ ពាក្យថា **ធ្វើឲ្យប្រាកដ** គឺកាលនឹងធ្វើជាប្រការផ្សេងៗ យ៉ាងនោះ ក៏ធ្វើឲ្យប្រាកដក្នុងខ្លួន ។ ពាក្យថា **រូបរាងកុមារ** គឺ សណ្ឋានកុមារ ។ សូម្បីក្នុងពាក្យថា ឬធ្វើឲ្យប្រាកដជារូបរាងនាគជាដើម ក៏មានន័យដូច្នេះ ។ ពាក្យថា **ធ្វើឲ្យប្រាកដពលដំរីខ្លះ** គឺ ធ្វើខ្លួនឯងឲ្យប្រាកដជាពលដំរីខ្លះ ធ្វើឲ្យប្រាកដជាពលដំរីឡើង សូម្បីក្នុងខាងក្រៅ ។ លោកមិនបានពោលថា ឬធ្វើឲ្យប្រាកដដូចជារូបរាងដំរីដូច្នេះ ទុកក្នុងទីនេះ ត្រឡប់ពោលថា ធ្វើឲ្យប្រាកដជាពលដំរីដូច្នេះ ក៏ដើម្បីកំណត់បំណងក្នុងការដែលពោលនេះនោះឯង ។ ចំណែកអាចារ្យពួកខ្លះពោលថា ពាក្យថា ធ្វើឲ្យប្រាកដជាពលដំរីជាដើមឡើងក្នុងខាងក្រៅឯណា រមែងខុសនឹងភាពជាវិកុព្វនាឥទ្ធិ ព្រោះមានពាក្យនិយាយថា លះរូបរាងតាមប្រក្រតីចេញដូច្នេះ ពាក្យរបស់អាចារ្យពួកនោះមិនត្រឹមត្រូវទេ ។ ព្រោះហេតុអ្វី ព្រោះឈ្មោះថា ការលះរូបរាងតាមប្រក្រតីជាការមិនធ្វើរូបតាមប្រក្រតីរបស់ខ្លួនឲ្យប្រាកដដល់អ្នកដទៃ មិនមែនជាការធ្វើគ្រប់វត្ថុនៃព្រះយោគីនោះឲ្យរលត់

ទៅដោយអស់ជើងទេ ។ កាលបើដូច្នេះ គឺកាលពោលថា ព្រះយោគីកាលមិនបាន ធ្វើខ្លួនឲ្យប្រាកដ ហើយធ្វើឲ្យប្រាកដជារូបដំរីឡើងក្នុងខាងក្រៅ ឈ្មោះថា លះរូបរាងតាមប្រក្រតីចេញ ហើយធ្វើឲ្យប្រាកដជាដំរីដូច្នេះ នឹងមានការឃ្លៀងឃ្លាតដូចម្ដេចក្នុងពាក្យដែលពោលនេះ ពាក្យដែលត្រូវពោលក្នុងព្រះយោគីអ្នកដែលខ្លួនឯងជាអ្នកមានរូបរាងដូចដំរីហើយ នៅធ្វើឲ្យប្រាកដជាដំរីបាន សូម្បីក្នុងខាងក្រៅមិនមានសោះឡើយ , ព្រោះហេតុនោះៗឯង ទើបខ្ញុំពោលថា លោកពោលទុកទាក់ទងនឹងការធ្វើឲ្យប្រាកដជាដំរីជាដើមឡើង សូម្បីក្នុងខាងក្រៅដូច្នេះ ក៏ព្រោះធ្វើអធិប្បាយយ៉ាងនេះឯង ទើបមិនមានការខុសអំពីសេចក្ដីជាវិកុព្វនាឥទ្ធិ ។

ម្យ៉ាងទៀត ពាក្យថា **វា**-ស័ព្ទ ប្រែថា ឬ ក្នុងបទថា **កុមារកវណ្ណំ វា** ជាដើម ក្នុងព្រះបាលីមានអត្ថថា មិនកំណត់ពិតប្រាកដ លោកពោលទុកដើម្បីសម្ដែងការធ្វើឲ្យជារូបរាងតែម្យ៉ាង ក្នុងបណ្ដារូបរាងពួកនោះ ។ ចំណែក **បិ**-ស័ព្ទ ក្នុងបទថា **ហត្ថិម្បិ** ជាដើម មានអត្ថថា រួបរួម លោកពោលទុកដើម្បីសម្ដែងដល់សភាវៈដែលគួររួបរួមរូបរាងទាំងឡាយ មានរូបរាងដំរីជាដើម ដែលមានជាច្រើនឲ្យជារូបរាងដូចគ្នាបាន ( ទើបប្រែថា ពលដំរី ) ។ ព្រោះហេតុនោះ បណ្ឌិតគប្បីកាន់យកអត្ថាធិប្បាយក្នុងបទថា **ហត្ថិម្បិ ទស្សេតិ** ( ធ្វើឲ្យប្រាកដជាពលដំរី ) ជាដើម តាមន័យដែលបានពោលមកហើយក្នុងន័យទី ២ នោះឯង ។

ការធ្វើអាការដែលជាកុមាររបស់ខ្លួនឲ្យប្រាកដដល់អ្នកដទៃ នៃលោកអ្នកមានឫទ្ធិ ឈ្មោះថា ការនិម្មិតជារូបរាងកុមារ , ក្នុងការនិម្មិតជារូបរាងកុមារនេះ ព្រះយោគីត្រូវធ្វើវត្ថុ មានផែនដីណាៗ ដែលមិនធ្លាប់ឲ្យកើតឡើង ព្រោះហេតុនោះ ទើបលោកពោលថា ដែលមានអារម្មណ៍ណាមួយ ក្នុងបណ្ដាកសិណទាំងឡាយ មាន

បឋវីកសិណជាដើម ព្រោះមិនមានប្រយោជន៍ដោយការកំណត់ពិតប្រាកដនៃកសិណ ។ ម្យ៉ាងទៀត សូម្បីថា នឹងមានការធ្វើវត្ថុ មានផែនដីជាដើមឲ្យកើតឡើង ការនិម្មិតនោះ ក៏គង់សម្រេចបានដោយអំណាចកសិណ មានបឋវីកសិណជាដើម តាមសមគួរនោះឯង ព្រោះហេតុនោះ សូម្បីតាមប្រការដូចពោលមកនេះ ក៏មិនមានប្រយោជន៍ ដោយខកំណត់ពិតប្រាកដនៃកសិណ ក្នុងបណ្ដានិម្មិតជារូបរាងកុមារនេះឡើយ ។ ពិតមែន ព្រះយោគីកាលនឹងធ្វើឲ្យប្រាកដជារូបរាងកុមារ គប្បីមានការត្រូវធ្វើឲ្យជារូបរាងដែលមានពណ៌ខៀវជាដើមក្ដី ។ គប្បីមានការធ្វើឲ្យជារូបរាងដែលមានពណ៌លឿងជាដើមណាមួយក្ដី , កាលបើដូច្នោះ ក៏ត្រូវចូលកសិណ មាននីលកសិណជាដើម ព្រោះហេតុនោះ ក៏ត្រូវមានការកំណត់ពិតប្រាកដនៃកសិណ ។ សូម្បីក្នុងការនិម្មិតដ៏សេសក៏មានន័យដូច្នេះ ។ សូម្បីកាលបានកំណត់ទុកយ៉ាងនេះប្រការថា អាចារ្យមួយពួកនឹងសង្ស័យក្នុងចិត្តដល់សេចក្ដីថា ដែលមានអារម្មណ៍ណាមួយ ក្នុងបណ្ដាកសិណទាំងឡាយ មានបឋវីកសិណជាដើម ក្នុងវិកុព្វនាឥទ្ធិនិទ្ទេសនេះខុសគ្នានឹងកសិណនិទ្ទេស , ដែលប្រព្រឹត្តទៅយ៉ាងនេះថា **បឋវី-កសិណវសេន ឯកោបិ ហុត្វា ពហុធា ហោតិ តិអាទិកាវោ** ( គុណទាំងឡាយមានអាទិយ៉ាងនេះ គឺ ការៈដែលថា សូម្បីមនុស្សម្នាក់ ក៏និម្មិតជាច្រើននាក់បានជាដើម រមែងសម្រេចបានដោយអំណាចបឋវីកសិណដូច្នេះឯង ) គប្បីឃើញថានោះមិនមែនឱកាសឡើយ ។ ឈ្មោះថា **រូបរាងកុមាររបស់ខ្លួន** ព្រោះអត្ថថា ខ្លួនប្រាថ្នាដោយភាពជារូបរាងដែលគប្បីនិម្មិតឡើង តែថា មិនមែនរូបរាងកុមារក្នុងកាលដែលនៅក្មេងខ្ចីរបស់ខ្លួនទេ ។ ន័យនេះមានការផ្សាយទៅបាន សូម្បីក្នុងរូបរាងទាំងឡាយ មានរូបរាងនាគជាដើម ព្រោះហេតុនោះ លោកអាចារ្យមួយពួកពោល

ពាក្យថា **ន័យនេះហាក់ដូចជាប្រើបាននឹងការនិម្មិតជានាគជាដើមដូច្នេះឯណា** គប្បីឃើញថា ពាក្យរបស់អាចារ្យពួកនោះៗប្រើបានផងដែរ ។

ដោយ **បិ**-ស័ព្ទ ក្នុងបទថា **ពហិទ្ធាបិ**( ក្នុងខាងក្រៅខ្លះ ) រួមយកខាងក្នុងៗ តទៅនេះជាអត្ថាធិប្បាយក្នុងបទនេះ ពាក្យថា **ធ្វើឲ្យប្រាកដជាពលដំរីខ្លះជាដើម ដែលពោលទុកក្នុងខាងក្នុង** លោកពោលទុកដោយទាក់ទងនឹងការធ្វើពលដំរីជាដើម ឲ្យប្រាកដសូម្បីខាងក្រៅ ។ មិនបានពោលទុកដោយទាក់ទងនឹងការធ្វើរូបរាង ទាំងឡាយ មានរូបរាងកុមារជាដើមឲ្យប្រាកដខាងក្នុងខ្លួន ដូចពាក្យថា ឬ ធ្វើឲ្យប្រាកដជារូបរាងកុមារជាដើមទេ ដូច្នេះ ។ ក្នុងឫទ្ធិនេះមានវិធីការអធិដ្ឋានដែលគប្បីពោលដល់ឯណា វិធីការអធិដ្ឋាននោះ ខ្ញុំបានពោលទុកក្នុងខាងដើមហើយ ។

ពាក្យថា **ទឹកដល់កាយ** គឺ ទឹកដល់ករជកាយរបស់ខ្លួន ។ ដោយពាក្យថា តាមន័យដែលបានពោលមកហើយនោះឯង លោកបានធ្វើបរិកម្មថា សូមកាយនេះចូរជាប្រហោងចុះ ដូច្នេះហើយ ទើបពោលដល់គន្លងន័យដែលបានពោលមកហើយក្នុងពេលក្រោយនេះទៀតថា ចូលឈានដែលជាបាទម្តងទៀត ចេញហើយដូច្នេះ ។ ពាក្យថា **កាយដទៃ** មានសេចក្តីថា ព្រះយោគីជាអ្នកត្រូវការនិម្មិតកាយដែលសម្រេចដោយចិត្តណា ក៏បានដល់កាយនោះ ។ បទថា **មុញ្ជម្ហា** ប្រែថា ចាកស្មៅយាប្លង ។ បទថា **ឦសិកំ** បានដល់ បណ្តូលស្មៅយាប្លងនោះ ។ បទថា **កោសិយា** ប្រែថា ចាកស្រោមដាវ ។ បទថា **ករណ្ឌាយ** បានដល់ ចាកត្របក តែលោកអាចារ្យជាច្រើនពោលថា បានដល់ ចាកសំណាកពស់ ។ ពាក្យថា **រមែងទាញ** គឺ រមែងដក ។ បទថា **បវាហេយ្យ** ប្រែថា គប្បីដល់ ។

# បរិច្ឆេទទី ១២

## ឈ្មោះ ឥទ្ធិវិធនិទ្ទេស ក្នុងបករណ៍វិសេស

ឈ្មោះវិសុទ្ធិមគ្គ ដែលខ្ញុំធ្វើដើម្បីប្រយោជន៍ដល់កាពបាមោជ្ជនៃសាធុជនដូច្នេះ ។

# អភិញ្ញានិទ្ទេស

## ទិព្វសោតធាតុកថា

ឥឡូវនេះ លំដាប់និទ្ទេសនៃទិព្វសោតធាតុមកដល់ហើយ អត្ថនៃព្រះបាលី ( **អភិញ្ញា** ) មានពាក្យថា “ **សោ ឯវំ សមាហិតេ ចិត្តេ** ភិក្ខុនោះកាលចិត្តជាសមាធិ... យ៉ាងនេះហើយ ” ជាដើម ក្នុងទិព្វសោតធាតុនិទ្ទេសនោះក្តី ក្នុងអភិញ្ញា ៣ តពីនោះទៅក្តី គប្បីជ្រាបដោយន័យដែលបានពោលហើយខាងដើម ក្នុងឥទ្ធិវិធនិទ្ទេសចុះ ខ្ញុំពណ៌នាអំពីពាក្យដែលប្លែកគ្នាប៉ុណ្ណោះក្នុងអភិញ្ញាទាំងឡាយ ។

### អធិប្បាយសព្ទបាលី ទិព្វសោតធាតុ

ក្នុងបាលីទិព្វសោតនោះ គប្បីជ្រាបអត្ថាធិប្បាយក្នុងពាក្យថា “ **ទិព្វាយ សោតធាតុយា** ដើម្បីសោតធាតុដែលជាទិព្វ ” នេះ សោតធាតុនោះ ឈ្មោះថា **ទិព្វ** ព្រោះដូចជារបស់ទិព្វ ពិតមែន ជាតុ គឺសោតប្បសាទរបស់ទេវតាទាំងឡាយជាធម្មជាតិ ដែលកើតដោយសុចរិតកម្ម ដែលទោសទាំងឡាយ មានទឹកប្រមាត់ ស្លេស្ម និងលោហិតជាដើមមិនរារាំង អាចទទួលអារម្មណ៍សូម្បីក្នុងទីឆ្ងាយបាន ព្រោះផុតចាកទោសដែលជាគ្រឿងសៅហ្មង ទើបជាទិព្វ , សូម្បីធាតុ គឺ **ញាណសោតៈ** ( ត្រចៀកដែលសម្រេចដោយញាណ ) ដែលកើតដោយកម្លាំងនៃវីរិយភាវនារបស់ភិក្ខុនេះ ក៏ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបជាទិព្វ ព្រោះដូចជារបស់ទិព្វ ម្យ៉ាងទៀត ឈ្មោះថា **ជាទិព្វ** ព្រោះបានមកចំពោះដោយអំណាចទិព្វវិហារ គឺឈានដែលជាបាទ និងព្រោះអាស្រ័យទិព្វវិហាររបស់ខ្លួន គឺ អាស្រ័យទិព្វវិហារជា

និស្ស័យបច្ច័យខ្លះ ។

ធម្មជាតិនោះ ឈ្មោះថា **សោតធាតុ** ព្រោះអត្ថថា បានឮ និងព្រោះអត្ថថា មិនមែនជីវៈ( ត្រឹមតែជាធាតុ ) ម្យ៉ាងទៀត ឈ្មោះថា **សោតធាតុ** ព្រោះដូចនឹងសោតធាតុ ព្រោះធ្វើកិច្ចនៃសោតធាតុដូច្នេះខ្លះ ( សេចក្ដីនៃបាលីថា **ទិព្វាយ សោតធាតុយា** នោះ ក៏គឺ ) ដើម្បីសោតធាតុដែលជាទិព្វនោះ ។

បទថា **វិសុទ្ធាយ**-ហ្មត់ចត់ គឺ បរិសុទ្ធ ប្រាសចាកទោសដែលជាគ្រឿងសៅហ្មង ។ បទថា **អតិក្កន្តមានុសិកាយ** កន្លងសោតធាតុដែលជារបស់មនុស្ស សេចក្ដីថា កន្លង គឺ រំលងមំសសោតៈដែលជារបស់មនុស្ស ព្រោះបានឮសំឡេងហួសឧបចារៈរបស់មនុស្ស ។ ពាក្យថា **ឧភោ សទ្ទេ សុណាតិ** ប្រែថា បានឮសំឡេងទាំងពីរ សំឡេងទាំងពីរ គឺអ្វីខ្លះ គឺ សំឡេងទិព្វផង សំឡេងមនុស្សផង អធិប្បាយថា សំឡេងរបស់ពួកទេវតាទាំងឡាយ និងរបស់មនុស្សទាំងឡាយផង , ដោយពាក្យថា **ឧភោ សទ្ទេ** នេះ គប្បីជ្រាបថា ជាការកំណត់យកសំឡេងតាមទីកន្លែង( គឺ ត្រឹមសំឡេងទេវតា និងសំឡេងមនុស្ស ) , ពាក្យថា **យេ ទូរេ សន្តិកេ ច** អធិប្បាយថា សំឡេងពួកណាក្នុងទីឆ្ងាយ សូម្បីក្នុងចក្រវាឡដទៃ និងសំឡេងពួកណាក្នុងទីជិត ដោយទីបំផុតសូម្បីសំឡេងសត្វដែលអាស្រ័យនៅក្នុងរាងកាយរបស់ខ្លួន ក៏បានឮសំឡេងពួកនោះ ដោយពាក្យថា **យេ ទូរេ សន្តិកេ ច** នេះ គប្បីជ្រាបថា ជាការកំណត់កាន់យកសំឡេង មិនមានព្រំដែន ។

## វិធីចម្រើនទិព្វសោត

សួរថា ក៏ទិព្វសោតនេះ ព្រះយោគីភិក្ខុ គប្បីឲ្យកើតឡើងបានយ៉ាងដូចម្ដេច?

វិសជ្ជនាថា ភិក្ខុនោះចូលឈានដែលជាបាទនៃអភិញ្ញា ចេញហើយ គប្បីអាវជ្ជនាការដល់សំឡេងសត្វ មានសំឡេងសីហៈជាដើមក្នុងព្រៃ ដែលជាសំឡេងគ្រោតគ្រាតក្នុងចម្ងាយឆ្ងាយ ឆ្ពោតសោតវិស័យប្រក្រតីចូលជាមុន ដោយសមាធិចិត្ត ដែលជាបរិកម្មនៃទិព្វសោតញ្ញាណ តពីនោះ គប្បីអាវជ្ជនាការដល់សំឡេងដ៏ល្អិតៗ ចូលតាមលំដាប់ចាប់ពីសំឡេងដ៏គ្រោតគ្រាតជាងគ្នាដូច្នេះ គឺ សំឡេងរគាំងក្នុងវិហារ សំឡេងស្គរ សំឡេងស័ង្ខ សំឡេងសូត្ររបស់សាមណេរ និងភិក្ខុកំលោះអ្នកសូត្រពេញកម្លាំង សំឡេងសួរគ្នាថា អ្វីលោក អ្វីព្រះករុណាម្ចាស់ជាដើម របស់ភិក្ខុសាមណេរទាំងនោះ អ្នកនិយាយគ្នាជាប្រក្រតី សំឡេងសត្វ សំឡេងខ្យល់ សំឡេងជើង សំឡេងគ្រុកៗរបស់ទឹកពុះ សំឡេងស្លឹកត្នោតប្រើបៗ ក្នុងកម្ដៅថ្ងៃ សំឡេងសត្វល្អិត មានស្រមោចខ្មៅ ស្រមោចក្រហមជាដើម ភិក្ខុនោះគប្បីមនសិការដល់សទ្ទនិមិត្តនៃសំឡេងទាំងឡាយក្នុងទិសខាងកើត គប្បីមនសិការដល់សទ្ទនិមិត្តនៃសំឡេងទាំងឡាយក្នុងទិសខាងលិច... ទិសខាងជើង... ទិសខាងត្បូង ... ទិសខាងក្រោម... ទិសខាងលើ... ទិសខាងកើតឆៀងខាងជើង គឺ ទិសឦសាន ... ទិសនារតី... ទិសពាយព្យ... ទិសបូព៌ា គប្បីមនសិការដល់សទ្ទនិមិត្តនៃសំឡេងទាំងឡាយ ទាំងគ្រោតគ្រាត ទាំងល្អិត សំឡេងទាំងនោះ រមែងប្រាកដច្បាស់ដល់លោក សូម្បីអ្នកមានចិត្តប្រព្រឹត្តទៅតាមប្រក្រតី តែវារមែងប្រាកដច្បាស់យ៉ាងក្រៃលែងដល់អ្នកមានសមាធិចិត្តក្នុងបរិកម្ម ។ កាលលោកមនសិការដល់សទ្ទនិមិត្តនោះឯង មនោទ្វារាវជ្ជនៈធ្វើសំឡេងទាំងនោះ ណាមួយឲ្យជាអារម្មណ៍ ឲ្យកើតឡើងថា ទិព្វសោតធាតុនឹងកើតឡើងក្នុងឥឡូវនេះ កាលមនោទ្វារាវជ្ជនៈរលត់ទៅហើយ ជវន ៤ ឬ ៥ ដួង រមែងប្រព្រឹត្តទៅ ក្នុងជវនពួកនោះ ជវន ៣ ឬ ៤ ដួង

ដំបូង ជាកាមាវចរៈ មានឈ្មោះថា បរិកម្ម ឧបចារ អនុលោម និងគោត្រភូដួងទី ៤ ឬ ៥ ជាអប្បនាចិត្តរូបាវចរថ្នាក់ចតុត្ថជ្ឈានក្នុងជវននោះ ញាណណាដែលកើតឡើងព្រមទាំងនឹងអប្បនាចិត្តនោះ **ធាតុ** គឺ ញាណនេះ គប្បីជ្រាបថា ឈ្មោះថា **ទិព្វសោតធាតុ** បន្ទាប់ពីនោះទៅ ទិព្វសោតធាតុនោះក៏ចាត់ចូលទៅក្នុងសោតៈ គឺត្រចៀកដែលសម្រេចដោយញាណនោះ ។ ព្រះយោគាវចរភិក្ខុ កាលនឹងធ្វើទិព្វសោតធាតុនោះឲ្យមានកម្លាំងខ្លាំងក្លាឡើង គប្បីពង្រីក( អារម្មណ៍នៃបាទកឈាន គឺ កសិណនិមិត្ត ) កំណត់យកត្រឹមតែមួយអង្គុលីសិន ដោយតាំងចិត្តថា យើងនឹងស្តាប់សំឡេងក្នុងរវាងឱកាសនេះ បន្ទាប់មក គប្បីពង្រីកដោយកំណត់ចេញទៅតាមលំដាប់ខ្នាតដូចជា ២ ធ្នាប់ ៤ ធ្នាប់ ៨ ធ្នាប់ ១ គក់ ១ ហត្ថ ខាងក្នុងបន្ទប់ របៀងប្រាសាទបរិវេណ( សង្ឃាវាស ) សង្ឃារាម( វត្ត ) គោចរគ្រាម( ស្រុកដែលត្រាច់បិណ្ឌបាត ) និងជនបទ ទៅរហូតដល់មួយចក្រវាឡ ឬសូម្បីក្រៃលែងទៅជាងនោះ ភិក្ខុអ្នកមានអភិញ្ញាដែលបានសម្រេចហើយយ៉ាងនេះនោះ រមែងបានឮសំឡេងដែលត្រាច់ទៅខាងក្នុងអាកាស ដែលជាអារម្មណ៍នៃបាទកឈានដែលពាល់ត្រូវបានដោយពិត និងកាលបានឮយ៉ាងនោះ ប្រសិនបើមានសំឡេងគឹកកងជាមួយគ្នានឹងសំឡេងគ្រឿងប្រគំ មានស័ង្ខ ស្គរ និងស្គរតូចជាដើម ( ដូចឡើងទៅដល់ ) ព្រហ្មលោកក្តី កាលមានបំណងនឹងកំណត់ចែកសំឡេងមានពិត លោកនៅអាចកំណត់ចែកថា នេះសំឡេងស័ង្ខជាដើមបានផង ។

# មហាដីកា

## អភិញ្ញានិទ្ទេស

## អធិប្បាយអំពី ទិព្វសោតធាតុ

បទថា **តត្ថ** ប្រែថា ក្នុងទិព្វសោតធាតុនិទ្ទេស ។ ក៏លោកបានចាត់ចែងវិធីធ្វើអភិញ្ញាទាំងឡាយឲ្យកើតឡើង ដោយមានការសម្ដែងខែព្រះបាលី ដែលពោលដោយអភិញ្ញាជាគន្លង ។ ព្រះបាលីដែលពោលដោយអភិញ្ញា ក្នុងទិព្វសោតនិទ្ទេសនេះ លោកពោលទុកដោយមានអភិញ្ញាជាប្រធាន ។ ព្រោះហេតុនោះ ទើបលោកពោលថា និងក្នុងអភិញ្ញា ៣ បន្ទាប់ពីនោះទៅ ដូច្នេះ ។ ពាក្យថា **បន្ទាប់ពីនោះទៅ** លោកពោលសំដៅយកលំដាប់ទេសនារបស់ព្រះសាស្ដា ។ លំដាប់ឧទ្ទេសរបស់ខ្លួន មិនបានពោលសំដៅយកលំដាប់ការបដិបត្តិទេ , ព្រោះថា យោគីទាំងឡាយកាលនឹងបដិបត្តិក៏មិនបដិបត្តិតាមលំដាប់នោះទេ ។ ពាក្យថា **ក្នុងព្រះបាលីទាំងពួង** បានដល់ ក្នុងព្រះបាលីទាំងពួង គឺក្នុងព្រះបាលីពោលដោយទិព្វសោតធាតុ ។ និងក្នុងព្រះបាលីពោលអំពីអភិញ្ញាដែលនៅសល់ ។ បទថា **តត្រ** ត្រឹមតែជានិបាត ក្នុងសេចក្ដីថា ធ្វើឲ្យដឹងពាក្យនិយាយ ម្យ៉ាងទៀត បទថា **តត្រ** បានដល់ក្នុងបាទតាមដែលពោលមកហើយ ។ ពាក្យថា **ព្រោះដូចជារបស់ទិព្វ** មានសេចក្ដីថា សោតធាតុរបស់ទេវតាទាំងឡាយឈ្មោះថារបស់ទិព្វ ព្រោះអត្ថថា មានក្នុងសួគ៌ា , ព្រោះដូចជារបស់ទិព្វនោះ ។ ឥឡូវនេះ លោកអាចារ្យប្រាថ្នាបើកផ្សារភាពដូចជារបស់ទិព្វនោះ ទើបពោលថា **ទេវានញ្ហិ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដែលកើតឡើងដោយសុចរិតកម្ម** គឺដែលកើតឡើងដោយកម្មដែល

ជាបុណ្យឲ្យកើតភាពជាឧប្បត្តិក្នុងទេវលោក ទើបឈ្មោះថា **សុចរិត** ព្រោះភាពជាកម្មដែលប្រព្រឹត្តដោយល្អហើយ ហេតុព្រោះសម្បត្តិមានភាពជាអ្នកច្រើនទៅដោយសទ្ធា ភាពជាអ្នកមានការឃើញហ្មត់ចត់ ភាពជាអ្នកសម្លឹងឃើញអានិសង្សជាដើម , ដោយ **អាទិ**-ស័ព្ទ ។

ក្នុងបទថា **បិត្តសេម្ហរុហិរាទីហិ** ដោយប្រមាត់ ស្លេស្ម លោហិតជាដើម មានការរួមយកវត្ថុដែលធ្វើឲ្យវិនាសទាំងឡាយ មានរោគខ្យល់ជាដើម ។ ពាក្យថា **មិនរារាំង** គឺ មិនត្រូវធ្វើឲ្យវិនាស ។ គប្បីជ្រាបដល់ការផុតចាកវត្ថុធ្វើឲ្យសៅហ្មង ព្រោះភាពដែលមិនត្រូវកោដ្ឋាស មានប្រមាត់ជាដើមធ្វើឲ្យខូចខាត និងព្រោះភាពប្រសើរនៃកម្ម ។ ពិតហើយ កម្មដែលវៀរចាកទោស គឺ វត្ថុធ្វើឲ្យសៅហ្មង រមែងជាកម្មដែលមានផលខ្ពង់ខ្ពស់ មិនសៅហ្មង ដូចសំណាបដែលវៀរចាកទោស មានស្មៅជាដើម ។ ក៏លោកពោលដល់ផលនៃកម្មនេះទុកយ៉ាងនោះ ដោយជា **ការណុបចារវោហារ**( ពាក្យពោលអាស្រ័យហេតុ ) ដូចពាក្យថា **សុក្កំ សុក្កវិបាកំ** កម្មសមានវិបាកសជាដើម ដោយ **បិ**-ស័ព្ទ ក្នុងបទថា **ទូរេបិ**( សូម្បីក្នុងទីឆ្ងាយ ) លោករួមយកអំណាចក្នុងការទទួលអារម្មណ៍ សូម្បីដ៏ល្អិត គឺ តូចឆ្មារ ។ ពាក្យថា **សោតធាតុប្បសាទ** គឺ សោតធាតុដែលមានសភាពថ្លានៃមហាភូតរូប ៤ ជាលក្ខណៈ ។ ការចម្រើនកុសលគ្រប់យ៉ាង ឈ្មោះថា **វិរិយភាវនា** ព្រោះសម្រេចដោយអំណាចការប្រារព្ធសេចក្តីព្យាយាមនោះឯង ម្យ៉ាងទៀត ការចម្រើនឥទ្ធិបាទដែលដល់ព្រមដោយបធានសង្ខារ ឈ្មោះថា **វិរិយភាវនា** យ៉ាងពិសេស , សោតធាតុដែលសម្រេចដោយញាណ ដែលកើតឡើងដោយអានុភាពនៃវិរិយភាវនានោះ ឈ្មោះថា កើតឡើងដោយកម្លាំងវិរិយភាវនា ។ ពាក្យថា **ក៏ដូច្នោះដូចគ្នា** គឺ

ក៏ដូច្នោះដូចគ្នា ព្រោះការផុតចាកវត្ថុដែលធ្វើឲ្យសៅហ្មង និងព្រោះការដែលអាចទទួលអារម្មណ៍សូម្បីក្នុងទីឆ្ងាយដ៏ល្អិតបាន ។ ពាក្យថា **ព្រោះបានមកដោយអំណាចនៃទិព្វវិហារ** ព្រោះបានមកដោយអំណាចនៃភូមិ ៤ ដែលហៅថា ទិព្វ-វិហារ , ដោយពាក្យនេះ លោកពោលដល់ទិព្វសោតធាតុនេះជារបស់ទិព្វ ដោយអំណាចនៃហេតុ ។ ក្នុងសេចក្តីនេះ មានពាក្យណាគួរពោលអធិប្បាយ ពាក្យនោះមានន័យដែលបានពោលហើយ ក្នុងខាងដើមនោះឯង ។ ពាក្យថា **ព្រោះអាស្រ័យទិព្វវិហារ** គឺ ព្រោះប្រព្រឹត្តទៅអាស្រ័យទិព្វវិហារ ពោលគឺឈានដែលជាបាទ ដែលដល់ភាពដ៏ខ្ពង់ខ្ពស់ ព្រោះភាពដល់ព្រមដោយអង្គ ៨ , ម្យ៉ាងទៀតបណ្ឌិតគប្បីឃើញអត្ថាធិប្បាយក្នុងពាក្យនេះយ៉ាងនេះថា ព្រោះអាស្រ័យរូបាវចរ-ចតុត្ថជ្ឈានដែលសម្បយុត្តនឹងខ្លួន ទាក់ទងក្នុងទិព្វវិហារដែលជានិស្សយបច្ច័យ ។ ពាក្យថា **ដោយសេចក្តីថា ស្តាប់** គឺ ដោយសេចក្តីថា កាន់យកសំឡេង ព្រោះការដឹងសភាវៈនៃស័ព្ទ ដែលមានការចូលទៅកាន់យកសំឡេងបានតាមសេចក្តីពិត ឈ្មោះថា **សវន**-ការស្តាប់ ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា កាលអត្ថនៃធាតុយ៉ាងដទៃ មានអត្ថថា ទ្រទ្រង់ទុកនូវសភាវៈជាដើម និងមានការពិត ធាតុទេសនារបស់ព្រះសាស្តា ក៏ជាទេសនាដែលមានការសម្តែងដល់ភាពជារបស់សូន្យទទេចាកអត្តាដូច្នេះ ហើយទើបពោលថា និងដោយសេចក្តីថា មិនមែនជីវៈ ។ ឈ្មោះថា **កិច្ចនៃសោតធាតុ** បានដល់ ការទទួលសំឡេង និងភាពជាបច្ច័យ គឺ ជាទីតាំងនៃសំឡេង ។

សេចក្តីបរិសុទ្ធនៃញាណរមែងមានបាន ព្រោះការប្រាសទៅនៃគ្រឿងសៅហ្មងនោះឯង ព្រោះហេតុនោះ ទើបលោកពោលថា គឺ មិនមានគ្រឿងសៅហ្មងដូច្នេះ ។

ឈ្មោះថា **មានុសិកា** បានដល់ មំសសោតធាតុដែលជារបស់មនុស្ស , ឈ្មោះថា ឈានកន្លងសោតធាតុរបស់មនុស្សព្រោះអត្ថថា ឈានកន្លងមំសសោតធាតុដែលជារបស់មនុស្សដោយកិច្ចពិសេសរបស់ខ្លួន ពោលគឺ ការកាន់យកអារម្មណ៍ដែលជាទិព្វ និងក្នុងទីសែនឆ្ងាយជាដើមបាន ។ ព្រោះហេតុនោះ ទើបលោកពោលថា ដោយការស្តាប់សំឡេងបាន ហួសឧបចារៈរបស់មនុស្សដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ឧបចាររបស់មនុស្ស** បានដល់ ស្ថានទីដែលមនុស្សទាំងឡាយគប្បីត្រាច់ទៅជិត , អធិប្បាយថា ជាអារម្មណ៍ដែលគប្បីកាន់យកបានតាមសោតទ្វារតាមប្រក្រតី ។ ព្រោះហេតុនោះ ទើបលោកពោលថា ដោយការស្តាប់សំឡេងបានដូច្នេះ ។ ពាក្យថា **គឺសំឡេងទិព្វ** បានដល់ គឺ សំឡេងដែលទាក់ទងក្នុងទេវលោក ។ ក៏សំឡេងទាំងនោះ ដោយពិសេសជាសំឡេងនិយាយរបស់ទេវតាទាំងឡាយ ព្រោះហេតុនោះ ទើបលោកពោលថា សំឡេងរបស់ទេវតាទាំងឡាយដូច្នេះ ។ សំឡេងទាំងនេះរមែងមានដល់ពួកមនុស្សទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា **មានុសា-សំឡេងមនុស្ស** បានដល់ រមែងស្តាប់សំឡេងមនុស្សទាំងនោះ ព្រោះកាន់យកតែសំឡេងរបស់ទេវតា និងមនុស្សប៉ុណ្ណោះ តាមប្រការដូចពោលមកនេះ ទើបលោកពោលថា ជាការកំណត់កាន់យកត្រឹមតែចំណែកខ្លះ , មានសេចក្តីថា ជាការកាន់យកត្រឹមតែមួយចំណែក ឈ្មោះថា **សទេហ-សន្និស្សិតា** បានដល់ សត្វដែលអាស្រ័យនៅក្នុងរាងកាយរបស់ខ្លួន ។ ឈ្មោះថា ជាការកាន់យកអស់ជើង ព្រោះជាការរួមយកសំឡេងដែលផ្សេងគ្នាដោយការផ្សេងគ្នានៃសំឡេង ដែលប្រព្រឹត្តទៅនឹងវិញ្ញាណជាដើម ដោយការកាន់យកភាពផ្សេងគ្នាដោយស្ថានទីជាគន្លងផ្លូវ ដោយមិនមានទៅសល់ ។

ឈ្មោះថា **អយំ** បានដល់ ទិព្វសោតធាតុ ។ ពាក្យថា **ដោយសមាធិចិត្ត ដែលជាបរិកម្ម** គឺដោយសមាធិចិត្តមួយផ្នែកដែលជាបរិកម្ម ។ សេចក្តីថា ដោយចិត្តដែលតាំងមាំដោយប្រពៃ ដោយខណិកសមាធិដែលប្រព្រឹត្តទៅទាក់ទងនឹងបរិកម្មនៃទិព្វសោតញ្ញាណ ។ អាចារ្យជាច្រើនពោលថា វិធីដែលតាំងចុះជិតទិព្វ-សោតធាតុ ឈ្មោះថា បរិកម្មសមាធិដូច្នេះក៏មាន ។ វិធីដែលតាំងចុះជិតទិព្វសោតធាតុនោះ គប្បីឃើញថា លោកពោលទុកដោយទាក់ទងនឹងវិធីដែលមានអាវជ្ជនៈផ្សេងគ្នា ( សេចក្តីថា ជាវិធីច្រើនវិធី ) លោកកាន់យកសំឡេងរបស់សត្វ ឬវត្ថុទាំងឡាយ មានសីហៈជាដើមសិន ក៏ដើម្បីសម្តែងសំឡេងដ៏គ្រោតគ្រាតជាងសំឡេងទាំងពួង បានឮថា ការបន្លឺសំឡេងរបស់សីហៈ សូម្បីក្នុងទីចុងបំផុត ៣ យោជន៍ មនុស្សទាំងឡាយក៏អាចឮបាន ។ ដោយ **អាទិ**-ស័ព្ទ( ប្រែថា ជាដើម ) គប្បីឃើញថា រួមយកសំឡេងគ្រោតគ្រាតទាំងឡាយ មានសំឡេងផ្គរលាន់ សំឡេងខ្លាដំបងជាដើម ។ ម្យ៉ាងទៀត ក្នុងបណ្តាសំឡេងទាំងនេះ លោកអាចារ្យប្រារព្ធនឹកដល់សំឡេងដ៏គ្រោតគ្រាតទុក ក៏ដើម្បីសំដែងឧបាយនៃការនឹកដល់សំឡេងដ៏ល្អិតៗប៉ុណ្ណោះ ព្រោះការកាន់យកសំឡេងដ៏ល្អិតក្រៃលែងឡើងទៅ មានការសម្រេចបានដោយកម្លាំងនៃភាវនា ដែលមានការកាន់យកសំឡេងដោយប្រការនោះ យ៉ាងណា , ដើម្បីសម្តែងការកាន់យកសំឡេងដែលនៅឆ្ងាយ ដែលនៅឆ្ងាយក្រៃលែងឡើងទៅ រមែងសម្រេចបានតាមរយៈនៃការកាន់យកសំឡេងដែលនៅជិតដូច្នេះ ទើបផ្តើមវិធីមនសិការសំឡេងទាំងឡាយ ដោយទាក់ទងនឹងការពាក់ព័ន្ធនឹងទិសដោយពាក្យថា **ទិសខាងកើត** ដូច្នេះជាដើមទុកដូច្នោះ ។ ក្នុងពាក្យនោះ ពាក្យថា **សទ្ទនិមិត្ត** មានសេចក្តីថា សំឡេងនោះឯងឈ្មោះថា សទ្ទនិមិត្ត ព្រោះជាហេតុកើត

ឡើងនៃញាណ ម្យ៉ាងទៀត អាការដ៏គ្រោតគ្រាត និងល្អិតនៃសំឡេងទាំងឡាយ តាមដែលពោលមកហើយ ដែលព្រះយោគីបានជួប ព្រោះបានប្រៀបផ្ទឹមគ្នាយ៉ាងណា នោះឈ្មោះថា **សទ្ទនិមិត្ត** , ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលថា គប្បីមនសិការសទ្ទនិមិត្តនៃសំឡេងទាំងឡាយ ដូច្នេះ ចំណែកពាក្យដែលលោកពោលថា គប្បីមនសិការសទ្ទនិមិត្តនៃសំឡេងទាំងឡាយ ទាំងគ្រោតគ្រាតទាំងល្អិត ដូច្នេះយ៉ាងណា គប្បីឃើញថា ពាក្យនោះ លោកពោលទុកដើម្បីសម្តែងថា សូម្បីក្នុងសំឡេងទាំងឡាយដែលរាប់ថា គ្រោតគ្រាត ឬល្អិត ក៏មានទាំងភាពគ្រោតគ្រាត និងល្អិត ។ និងគប្បីឃើញថា លោកពោលពាក្យទាំងអស់នោះទុក ដើម្បីសម្តែងការសទ្ទញាណដ៏ល្អិត ។ អាចារ្យពួកខ្លះពោលថា រីឯ សំឡេងនោះឯង ឈ្មោះថា **សទ្ទនិមិត្ត** នេះប៉ុណ្ណោះដែលឲ្យដល់ការដឹងបាន ( ដែលធ្វើឲ្យយល់បាន ) ព្រោះសទ្ទនិមិត្តមិនមែនជាសភាវៈបច្ចុប្បន្នដូច្នេះ ពាក្យនោះមិនត្រឹមត្រូវទេ ព្រោះសំឡេងគ្រោតគ្រាត និងល្អិតទាំងឡាយ ព្រះយោគីគប្បីកាន់យកបានដោយប្រការយ៉ាងនោះប៉ុណ្ណោះ ( មនសិការនូវអាការដែលគ្រោតគ្រាត ឬ ល្អិតប៉ុណ្ណោះ ) ដូចត្រូវកាន់យកពណ៌ទាំងឡាយ មានពណ៌ខៀវ ពណ៌លឿងជាដើមបានដោយញាណដែលមានពណ៌ជាអារម្មណ៍ដូច្នោះ ។ ភាវៈដ៏គ្រោតគ្រាត ឬល្អិតនៃសំឡេង លោកបំណងយកថា ឈ្មោះថា **សទ្ទនិមិត្ត** ក្នុងទីនេះ ។ បទថា **តស្ស**-ដល់ភិក្ខុនោះ គឺដល់ព្រះយោគីអ្នកបដិបត្តិដោយវិធី តាមដែលបានពោលមកហើយ ។ ពាក្យថា **សំឡេងទាំងនោះ** បានដល់ សំឡេងដ៏ល្អិតៗទាំងឡាយ ដែលព្រះយោគីអ្នកវេៀកដល់ វេៀកមកហើយតាមលំដាប់ ផ្តើមតាំងពីសំឡេងដែលគ្រោតគ្រាតជាងសំឡេងទាំងអស់ ។ ពាក្យថា **សូម្បីអ្នកមានចិត្តជាប្រក្រតី** គឺ សូម្បីអ្នកមានចិត្តប្រព្រឹត្ត

ទៅក្នុងកាលមុន បន្ទាប់ពីការចូលឈានដែលជាបាទ ។ ពាក្យថា **អ្នកមានសមាធិចិត្តដោយអំណាចនៃបរិកម្ម** គឺ អ្នកចូលឈានដែលជាបាទ ដើម្បីការធ្វើទិព្វសោតធាតុឲ្យកើតឡើង ចេញហើយ មានខណិកសមាធិចិត្ត ដែលប្រព្រឹត្តទៅដោយអំណាចការធ្វើបរិកម្ម ប្រារព្ធសំឡេង ។ សម្ពន្ធសេចក្តីបានថា រមែងជាធម្មជាតិប្រាកដច្បាស់ក្រៃលែងឡើង ព្រោះបានញ៉ាំងញាណបន្ថែមទុកក្នុងកាលមុន ។

ពាក្យថា **ក្នុងសំឡេងទាំងនោះ** គឺក្នុងសំឡេងច្រើនយ៉ាង ដែលលោកបានពោលទុកដើម្បីសម្តែងអារម្មណ៍នៃបរិកម្ម ។ ពាក្យថា **សំឡេងណាមួយ** មានសេចក្តីថា ព្រះយោគីនេះមានមនសិការប្រព្រឹត្តទៅរឿយៗ ដោយការទាក់ទងនឹងការធ្វើបរិកម្មក្នុងសំឡេងឯណា បានដល់សំឡេងនោះតែម្យ៉ាង ។ ពាក្យថា **បន្ទាប់ពីនោះទៅ** បានដល់ បន្ទាប់ពីការឧប្បត្តិនៃអប្បនានោះទៅ ។ ពាក្យថា **ក្នុងសោតនោះ** បានដល់ ក្នុងសោត គឺ ញាណនោះ ។ ពាក្យថា **ជាការចាត់ចូលទៅ** គឺ ទិព្វសោតធាតុត្រូវទាក់ទងក្នុងខាងក្នុង ។ សេចក្តីថា ចាប់ផ្តើមអំពីអប្បនាចិត្តកើតឡើង ព្រះយោគីក៏ឈ្មោះថា ជា **ទិព្វសោតញ្ញាណលាភី** ( អ្នកបានទិព្វសោតញាណ ) តទៅនេះ ការប្រកបក្រៃលែងនូវភាវនា ដើម្បីទិព្វសោតញ្ញាណនោះ ក៏មិនមែនវត្ថុ ដែលព្រះយោគីរូបនេះប្រាថ្នាទៀត ។ បទថា **តំ** បានដល់ ទិព្វសោតធាតុ ។ ពាក្យថា **មានកម្លាំង** គឺមានកម្លាំងដែលកើតហើយ បានដល់ ដល់នូវភាពមាំទាំ ។ ឈ្មោះថា **គប្បីកំណត់ ឬ ពង្រីក** បានដល់ អារម្មណ៍នៃឈានដែលជាបាទ ។ លោកអាចារ្យជញ្ជឹងគិតទុកក្នុងចិត្តថា គប្បីកំណត់ពង្រីកទៅត្រឹមប៉ុនណាសោត ដូច្នេះហើយ ទើបពោលថា គប្បីកំណត់ពង្រីកទៅត្រឹម ១អង្គុលី ២អង្គុលី ដោយការគិតថា យើងនឹងស្តាប់សំឡេងក្នុងរវាងទីនេះ ដូច្នេះ ។ ពិតហើយ កាល

ព្រះយោគីមនសិការកសិណនិមិត្ត ដែលជាអារម្មណ៍នៃឈានដែលជាបាទថា ចូរផ្សាយទៅរហូតទីប៉ុណ្ណេះចុះ ដូច្នេះ ហើយចូលឈានដែលជាបាទ កសិណនិមិត្តរមែងតាំងនៅ ផ្សាយទៅរហូតទីប៉ុណ្ណោះបាន ។ ព្រះយោគីនោះចេញចាកសមាបត្តិហើយ នឹកដល់សំឡេងទាំងឡាយដែលប្រព្រឹត្តទៅនៅក្នុងទីនោះ ព្រោះលោកអប់រំការនាទុកល្អហើយ ជវន ៤ ឬ ៥ ខណៈ រមែងកើតឡើងក្នុងលំដាប់នៃអាវជ្ជនៈដែលកើតឡើង ប្រារព្ធសំឡេងណាមួយ ក្នុងបណ្តាសំឡេងទាំងនោះ ។ ក្នុងបណ្តាជវន ៤ ឬ ៥ ខណៈនោះ ជវនខណៈចុងក្រោយជាឥទ្ធិចិត្ត ។ ព្រះយោគីត្រូវចូលឈានដែលជាបាទដើម្បីការបានឮសំឡេងដទៃទៀត ។ ព្រោះហេតុនោះឯងទើបលោកពោលពាក្យដែលនៅមានសេចក្តីសង្ស័យថា រមែងស្តាប់សំឡេងទាំងឡាយ ដែលប្រព្រឹត្តទៅខាងក្នុងឱកាស ដែលអារម្មណ៍នៃឈាន ដែលជាបាទពាល់ត្រូវហើយតែម្តងដូច្នេះ ។ ក៏ស័ព្ទថា **ឯកង្គុល** គឺ មួយអង្គុលី **ទ្វង្គុល** គឺពីរអង្គុលីជាដើម លោកធ្វើទុកក្នុងទីនេះ សំដៅដល់សំឡេងដ៏ល្អិត ។

ពាក្យថា **ម្យ៉ាងទៀត កាលនឹងស្តាប់យ៉ាងនេះ** មានសេចក្តីថា ព្រះយោគីអ្នកមានអភិញ្ញាដែលបានធ្វើវសីទុកហើយ កាលនឹងស្តាប់សំឡេងទាំងឡាយតាមដែលនឹកទុកដោយការកំណត់ហើយ ហើយទើបស្តាប់យ៉ាងនេះនោះឯង ។ ពាក្យថា **ត្រឹមតែសំឡេង** មានសេចក្តីថា កាលមានសេចក្តីត្រូវការនឹងកំណត់បែកសំឡេងទាំងនោះ សូម្បីកំពុងប្រព្រឹត្តទៅព្រមគ្នា ត្រឹមតែសំឡេង តាមសេចក្តីផ្សេងគ្នានៃវត្ថុ ។

( ចប់មហាដីកា អធិប្បាយ ទិព្វសោតធាតុ )

# ចេតោបរិយញ្ញាណ

## អធិប្បាយ ស័ព្ទបាលីចេតោបរិយញ្ញាណ

ក្នុងបទថា **ចេតោបរិយញ្ញាណាយ**( ដើម្បីចេតោបរិយញ្ញាណ ) នេះ ក្នុងចេតោបរិយញ្ញាណកថា មានអត្ថាធិប្បាយថា **ញាណ** ឈ្មោះថា **បរិយ** ព្រោះទៅដោយជុំវិញ មានសេចក្តីថា កំណត់បានញាណដែលកំណត់បាននូវចិត្ត ( របស់អ្នកដទៃ ) ឈ្មោះថា **ចេតោបរិយ** , ញាណនោះផងកំណត់បាននូវចិត្តរបស់អ្នកដទៃផង ព្រោះហេតុនោះ ទើបឈ្មោះថា **ចេតោបរិយញ្ញាណ**( ញាណដែលកំណត់ចិត្តរបស់អ្នកដទៃបាន ) , បទថា **ចេតោបរិយញ្ញាណាយ** មានអធិប្បាយថា ដើម្បីប្រយោជន៍ដល់ចេតោបរិយញ្ញាណនោះ , បទថា **បរសត្តានំ**( របស់សត្វដទៃ ) គឺ របស់សត្វដ៏សេសទាំងឡាយ វៀរខ្លួនឯងចេញ , សូម្បីបទថា **បរបុគ្គលានំ** របស់បុគ្គលដទៃនេះ ក៏មានសេចក្តីដូចគ្នានឹងបទនេះដែរ តែទ្រង់ធ្វើព្យញ្ជនៈផ្សេងគ្នា ឲ្យទៅតាមប្រភេទនៃវេនេយ្យ និងដោយទេសនាវិលាស , ពាក្យថា **ចេតសា ចេតោ** ( នៅជិតរបស់សត្វដទៃ បុគ្គលដទៃពួកនោះ ដោយចិត្តរបស់ខ្លួន , បទថា **បរិច្ច** ប្រែថា កំណត់ , បទថា **បជានាតិ** គឺដឹងដោយប្រការផ្សេងៗ ) ដោយប្រការនៃចិត្តទាំងឡាយ មានចិត្តមានរាគៈជាដើម ។

## វិធីធ្វើចេតោបរិយញ្ញាណ

សួរថា ញាណនេះ ព្រះយោគាវចរនឹងគប្បីឲ្យកើតឡើងបាន ដូចម្តេច ? វិសជ្ជនាថា ព្រោះថា ញាណនេះរមែងសម្រេចដោយអំណាចទិព្វចក្ខុញាណ ទិព្វ-ចក្ខុញាណនោះទើបដូចនឹងការបរិកម្មនៃញាណនោះឯង ព្រោះហេតុនោះ ភិក្ខុអ្នកបាន

ទិព្វចក្ខុញ្ញាណហើយ ប្រាថ្នានឹងធ្វើចេតោបរិយញ្ញាណនេះឲ្យកើតឡើងនោះ គប្បីចម្រើនអាលោកកសិណផ្ទុះបំភ្លឺមើលចិត្ត មើលពណ៌របស់លោហិតដែលអាស្រ័យហទយរូបរបស់អ្នកដទៃដោយទិព្វចក្ខុ សោមនស្សចិត្តប្រព្រឹត្តទៅក្នុងកាលណា ក្នុងកាលនោះលោហិតមានពណ៌ក្រហមដូចផ្លែជ្រៃទុំ , ទោមនស្សចិត្តប្រព្រឹត្តទៅក្នុងកាលណា ក្នុងកាលនោះលោហិតមានពណ៌ខ្មៅដូចផ្លែព្រីងទុំ , ឧបេក្ខាចិត្តប្រព្រឹត្តទៅក្នុងកាលណា ក្នុងកាលនោះលោហិតថ្លាដូចប្រេងល្ង ព្រោះដូច្នោះ លោកអ្នកផ្ទុះបំភ្លឺមើលចិត្ត ដោយរំពឹងមើលពណ៌របស់លោហិតក្នុងហទយៈរបស់អ្នកដទៃថា រូបនេះមានសោមនស្សិន្ទ្រិយជាសមុដ្ឋាន រូបនេះមានទោមនស្សិន្ទ្រិយជាសមុដ្ឋាន រូបនេះមានឧបេក្ខិន្ទ្រិយជាសមុដ្ឋាន និងគប្បីធ្វើចេតោបរិយញ្ញាណឲ្យដល់នូវភាពក្លៀវក្លាបាន ព្រោះថា កាលចេតោបរិយញ្ញាណនោះដល់នូវភាពក្លៀវក្លាយ៉ាងនោះហើយ លោករមែងដឹងនូវកាមាវចរចិត្ត និងរូបាវចរចិត្ត អរូបាវចរចិត្តទាំងអស់បានតាមលំដាប់ ចេញអំពីចិត្តទៅកាន់ចិត្តបានផងដែរ សូម្បីវៀរចាកការមើលហទយរូបក្តី ពិតហើយ សូម្បីក្នុងអដ្ឋកថាក៏បានពោលពាក្យនេះទុកថា សួរថា យោគាវចរភិក្ខុអ្នកប្រាថ្នានឹងដឹងចិត្តរបស់អ្នកដទៃក្នុងថ្នាក់អរូបភព នឹងឃើញហទយរូបរបស់អ្នកណានឹងមើលការប្រែប្រួលនៃឥន្ទ្រិយរបស់អ្នកណា ឆ្លើយថា មិនត្រូវមើលរបស់អ្នកណា ប្រការដែលជាអាវជ្ជនាការដល់ចិត្តរបស់អ្នកដទៃក្នុងភពណាមួយដែលជាបញ្ចវោការភព ឬ ចតុវោការភពទៅ រមែងដឹងចិត្ត ១៦ ប្រភេទបាន នោះជាវិស័យរបស់ភិក្ខុអ្នកមានឫទ្ធិទៅហើយ ចំណែកកថា( ការពោលដល់ការធ្វើបរិកម្មផ្តើមពីការចម្រើនអាលោកកសិណជាដើម )នេះនោះ ពោលសម្រាប់ភិក្ខុអ្នកនៅមិនបានអភិនិវេសៈ គឺ ការចាប់ផ្តើមធ្វើដោយហ្មត់ចត់ក្នុងការបំពេញអភិញ្ញា ។

# អធិប្បាយ ចិត្ត ១៦ ប្រភេទ

*វែងក្នុងបាទមាន “ **សរាគំ វា ចិត្តំ**-ចិត្តប្រកបដោយរាគៈ... ឬ ជាដើម ” មានអត្ថាធិប្បាយថា ចិត្តដែលសហគតៈដោយលោភៈ ៨ ដួង គប្បីជ្រាបថា ឈ្មោះថា **សរាគចិត្ត** គឺ ចិត្តប្រកបដោយរាគៈ ចិត្តដែលនៅសល់ គឺ ចិត្តដែលជាកុសល និងអព្យាកតៈ ប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា **វីតរាគចិត្ត** គឺចិត្តដែលប្រាសចាករាគៈ , ចំណែកចិត្ត ៤ ដួងនេះ គឺ ទោមនស្សចិត្ត ២ វិចិកិច្ឆាចិត្ត និងឧទ្ធច្ចចិត្ត មិនដល់នូវការសង្គ្រោះ ( រួមចូល )ក្នុងទុកៈនេះទេ តែព្រះថេរៈរូបខ្លះក៏សង្គ្រោះចិត្តទាំង ៤ នោះចូលផងដែរ ។*

*ចំណែកទោមនស្សចិត្ត ២ ឈ្មោះថា **សទោសចិត្ត** គឺ ចិត្តប្រកបដោយទោសៈ , ចិត្តដែលជាកុសល និងអព្យាកតៈប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងពួង ឈ្មោះថា **វីតទោសចិត្ត** ចិត្តដែលប្រាសចាកទោសៈ ចិត្តដែលនៅសល់ទាំងឡាយ គឺ អកុសលចិត្ត ១០ មិនដល់នូវការសង្គ្រោះចូលក្នុងទុកៈនេះ តែព្រះថេរៈពួកខ្លះក៏សង្គ្រោះអកុសលចិត្ត ១០ នោះចូលផងដែរ ។*

*ចំណែកក្នុងទុកៈ គឺ **សមោហំ វីតមោហំ** នេះពោលដោយបដិបុគ្គលិកន័យ ( ន័យចំពោះខ្លួន មិនលាយឡំ គឺជាមោហៈពិត មិនលាយឡំដោយលោភៈទោសៈ ) ក៏ចិត្តដែលសហគតៈដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ២ ដួងប៉ុណ្ណោះ ឈ្មោះថា **សមោហចិត្ត** គឺ ចិត្តដែលមានមោហៈ តែសូម្បីអកុសលចិត្ត ១២ ដួង ក៏គប្បីជ្រាបថាជា សមោហចិត្តដែរ ព្រោះមោហៈមាននៅក្នុងអកុសលចិត្តទាំងពួង ចិត្តដ៏សេស ឈ្មោះថា **វីតមោហចិត្ត** គឺ ចិត្តដែលប្រាសចាកមោហៈ ។*

*ចំណែកចិត្តដែលប្រកបដោយថីនមិទ្ធៈ ឈ្មោះថា **សង្ខិត្តចិត្ត** - ចិត្តរួញរា ,*

ចិត្តដែលប្រកបដោយឧទ្ធច្ចៈ ឈ្មោះថា **វិក្ខិត្តចិត្ត**-ចិត្តរាយមាយ ។

ចិត្តដែលជារូបាវចរ និងអរូបាវចរ ឈ្មោះថា **មហគ្គតចិត្ត**-ចិត្តដល់នូវភាពជាធំ ដោយអំណាចគ្របសង្កត់កិលេសបាន ចិត្តដ៏សេស( ជាកាមាវចរៈ ) ឈ្មោះថា **អមហគ្គតចិត្ត**-ចិត្តមិនដល់នូវភាពជាធំ ។

ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ឈ្មោះថា **សឧត្តរចិត្ត**-ចិត្តនៅមានចិត្តដ៏ទៃក្រៃលែងជាង , ចិត្តដែលជាលោកុត្តរ ឈ្មោះថា **អនុត្តរចិត្ត**-ចិត្តមិនមានចិត្តដ៏ទៃក្រៃលែងជាង ។

ចិត្តដែលដល់នូវឧបចារ និងដល់អប្បនាផង ឈ្មោះថា **សមាហិតចិត្ត**-ចិត្តដែលជាសមាធិ , ចិត្តដែលមិនដល់ចំណែកទាំងពីរយ៉ាង ឈ្មោះថា **អសមាហិតចិត្ត**-ចិត្តមិនជាសមាធិ ។

ចិត្តដែលដល់តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ គប្បីជ្រាបថា ឈ្មោះថា **វិមុត្តចិត្ត**-ចិត្តដែលរួចផុត , ចិត្តដែលមិនទាន់ដល់វិមុត្តិទាំង ៥ យ៉ាងនោះ ឈ្មោះថា **អវិមុត្តចិត្ត**-ចិត្តនៅមិនទាន់រួចផុត ។

ភិក្ខុអ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តគ្រប់ប្រការថា ចិត្តនេះជាចិត្តមានរាគៈ ឬ ។ល។ ឬថា ជាចិត្តនៅមិនទាន់រួចផុតដោយប្រការដូច្នេះឯង ។

# មហាដីកា

## អធិប្បាយអំពី ចេតោបរិយញ្ញាណ

បទថា **បរិយាតិ-ការកំណត់ដឹង** បានដល់ ការកំណត់ដឹងដោយការចែកចិត្ត មានចិត្តដែលមានរាគៈជាដើម ។ ព្រោះហេតុនោះ ទើបលោកពោលថា សេចក្តីស្មើនឹងបរិច្ឆិន្ទតិ( កំណត់ ) ដូច្នេះ ។ ពិតហើយ ធាតុពួកណាមានអត្ថថា **ទៅ** ធាតុពួកនោះ ក៏មានអត្ថថា **ដឹង** ដែរ ។ **បរ-ស័ព្ទ** ក្នុងបទថា **បរសត្តានំ** នេះ មានអត្ថថា **ដទៃ** ព្រោះហេតុនោះ ទើបលោកពោលថា គឺ របស់សត្វដ៏សេស វៀរខ្លួនឯង ដូច្នេះ ពិតយ៉ាងនោះមែន អ្នកដែលមិនមែនអ្នកដទៃ រមែងជាខ្លួនឯង ។ អ្នកដែលមិនបានជាខ្លួនឯង រមែងជាអ្នកដទៃដូច្នេះ ។ ក្នុងពាក្យថា **របស់សត្វទាំងឡាយនេះ** មានសេចក្តីថា សត្វ( សត្ត ) ព្រោះអត្ថថា ជាអ្នកជាប់ជំពាក់ក្នុងខន្ធទាំងឡាយ មានរូបជាដើម ។ តែថា លោកអ្នកមិនមានឆន្ទរាគៈទាំងឡាយ ក៏ត្រូវហៅថា សត្វដែរ ព្រោះបញ្ញត្តិថាសត្វនោះ ជាបញ្ញត្តិដែលនិយមប្រើក្នុងខន្ធសន្តានដែលមានវិញ្ញាណ ឬព្រោះគតិថា ធ្លាប់ ។ **នរក** ហៅថា **បុំ** គឺ សត្វទាំងឡាយអ្នកមានប្រក្រតីធ្វើកម្មអាក្រក់, ឈ្មោះថា **បុគ្គល** ព្រោះអត្ថថា **ទៅ** គឺ ធ្លាក់ទៅក្នុងនរកនោះ ។ សត្វទាំងឡាយអ្នកត្រាច់រង្គាត់ទៅក្នុងសង្សារវដ្តដទៃ ក៏ហៅថា បុគ្គលបានដូចគ្នា ព្រោះនៅមិនទាន់កន្លងសភាវៈនោះ ។ ម្យ៉ាងទៀត ពួកអ្នកស្តាប់ **និរុកតិ** ពោលថា ឈ្មោះថា **បុគ្គល** ព្រោះមានការធ្វើសត្តនិកាយនោះៗ ឲ្យពេញដោយការកើតឡើងក្នុងទីនោះៗ និងព្រោះមានការឃ្លាតទៅ ដោយអំណាចនៃភាពជារបស់មិនទៀង ។

*ហិ*-ស័ព្ទ ក្នុងបទថា **ឯតញ្ហិ** នេះ មានអត្ថថា **ហេតុ**( ប្រែថា ព្រោះថា )។ គប្បីធ្វើពាក្យប្រកបសេចក្តីយ៉ាងនេះថា ព្រោះហេតុដែលចេតោបរិយញ្ញាណនេះ សម្រេចបានដោយអំណាចទិព្វចក្ខុ ព្រោះហេតុនោះ ទិព្វចក្ខុនោះ ទើបចាត់ជាបរិកម្ម ក្នុងការធ្វើចេតោបរិយញ្ញាណនេះឲ្យកើតឡើង ព្រោះដូច្នោះ ភិក្ខុអ្នកត្រូវការធ្វើ ចេតោបរិយញ្ញាណឲ្យកើតឡើងនោះ គប្បីជាអ្នកសម្រេចទិព្វចក្ខុញ្ញាណដូច្នេះ ។ ពាក្យថា **ហទយរូប** លោកមិនបានពោលដល់ហទយវត្ថុទេ តែថា ពោលដល់ដុំសាច់បេះដូង ។ ក៏លោហិតដែលលោកកំពុងពោលដល់ក្នុងខណៈនេះ រមែងតាំងនៅអាស្រ័យដុំសាច់បេះដូង ដែលលោកពោលថា ផ្នែកក្រៅ មានសណ្ឋានដូចផ្កាឈូកក្រពុំ ផ្នែកខាងក្នុងដូចផ្លែននោងព្រៃ ។ ចំណែកហទយវត្ថុរមែងប្រព្រឹត្តទៅអាស្រ័យលោហិតនេះ ។ លោកអាចារ្យធ្វើពាក្យជញ្ជីងក្នុងចិត្តថា ក៏ព្រះយោគីនឹងរកមើលចិត្ត ដែលមាននាមដោយការប្រើទិព្វចក្ខុសម្លឹងមើលពណ៌របស់លោហិតបាន ដូចម្តេច ដូច្នេះហើយទើបពោលថា **យទា ហិ**-ពិតហើយ ក្នុងពេលណាដូច្នេះជាដើម ។ សួរថា ក៏លោហិតដែលកើតអំពីកម្ម និងមានការដល់ភាពមានពណ៌ផ្សេងៗគ្នា តាមការប្រព្រឹត្តទៅនៃចិត្ត មានចិត្តដែលសហគតៈដោយសោមនស្សជាដើមបាន យ៉ាងដូចម្តេច ? ម្យ៉ាងទៀត អ្នកណាពោលបានយ៉ាងនេះថា លោហិតនោះជារបស់កើតអំពីកម្មប៉ុណ្ណោះ ព្រោះក្នុងលោហិតនោះ សូម្បីរូប ៤ សន្តតិក៏មាន ។ ព្រោះហេតុនោះឯង ទើបលោកអាចារ្យពោលឆ្លើយថា កាលរំពឹងមើលថា រូបនេះមានសោមនស្សិន្ទ្រិយជាសមុដ្ឋានដូច្នេះជាដើម ។ សួរថា សូម្បីថាយ៉ាងនេះ ក្នុងលោហិតនោះ រូបណាជារូបដែលមិនបានកើតអំពីចិត្ត រូបនោះក៏មិនមានភាពផ្សេងគ្នាដោយពណ៌តាមដែលពោលមកហើយបានឡើយឬ ? ឆ្លើយថា គួរមានបាន

ព្រោះរូប ៣ សន្តតិដ៏សេស( ជារូបមិនបានកើតអំពីចិត្ត ) មានការបណ្តោយតាមរូបដែលកើតអំពីចិត្តនោះ ។ ប្រៀបដូចជាក្នុងកិរិយាទាំងឡាយ មានការដើរទៅជាដើម មានរូបដែលមានឧតុជាសមុដ្ឋាន ដែលមានកម្មជាសមុដ្ឋាន និងដែលមានអាហារជាសមុដ្ឋាន រមែងបណ្តោយតាមរូបដែលកើតអំពីចិត្តទាំងឡាយ , ការកើតក្នុងចំណែកដទៃនៃរាងកាយ ដោយប្រការដទៃមិនមានឡើយយ៉ាងណា សូម្បីក្នុងលោហិតនេះ រូប ៣ សន្តតិដ៏សេស រមែងប្រព្រឹត្តទៅស្របតាមរូបដែលកើតអំពីចិត្តក៏ដូច្នោះ ។ ក្នុងពេលដែលជ្រះថ្លា និងពេលដែលក្រោធខឹង ចក្ខុមានការដល់ភាពផ្សេងគ្នាដោយពណ៌បានផងដែរ គប្បីឃើញថាជាឧទាហរណ៍នៃសេចក្តីនេះបាន ។

ពាក្យថា **រំពឹងមើល** មានសេចក្តីថា ដំបូងបញ្ជូនញាណទៅតាមរក ដោយការអនុមានជាមុន ព្រះយោគីអ្នកត្រូវធ្វើចេតោបរិយញ្ញាណឲ្យកើតឡើង គប្បីជាអ្នកធ្វើបុរាចរចតុត្ថជ្ឈានដែលកើតព្រមដោយអង្គ ៨ ឲ្យមានការគួរដល់អភិនីហារ ( ការធ្វើចិត្តឲ្យបង្អោនទៅ ) តាមន័យដែលបានពោលមកហើយ ក្នុងខាងដើមហើយជាភិក្ខុអ្នកបានទិព្វចក្ខុញាណ កំណត់ចែកសូម្បីដោយទាក់ទងនឹងការកាន់យក មានន័យថា ក្នុងខណៈនេះ អ្នកនេះមានចិត្តសហគតៈដោយសោមនស្សខ្វះ , ថា មានចិត្តដែលសហគតៈដោយទោមនស្សខ្វះ , ថាមានចិត្តដែលសហគតៈដោយឧបេក្ខាខ្វះ ដោយការពង្រីកអាលោកកសិណហើយ ប្រើទិព្វចក្ខុសម្លឹងមើលពណ៌របស់លោហិត ដែលប្រព្រឹត្តទៅអាស្រ័យដុំសាច់បេះដូងរបស់អ្នកដទៃ ចូលឈានដែលជាបាទ ចេញហើយ ធ្វើបរិកម្មថា យើងនឹងដឹងចិត្តរបស់បុគ្គលនេះដូច្នេះចុះ ។ គប្បីចូលឈានដែលជាបាទ ចេញហើយ បដិបត្តិយ៉ាងនោះឯងរឿយៗទៅ សូម្បីអស់កាល ១០០ ដង សូម្បីអស់កាល ១០០០ ដង ។ កាលព្រះយោគីនោះបដិបត្តិ

ដោយវិធីប្រើទិព្វចក្ខុសម្លឹងមើលពណ៌របស់លោហិតក្នុងបេះដូង ជាដើមយ៉ាងនេះ មនោទ្វារាវជ្ជនៈ រមែងកើតឡើងដោយអាការដែលគប្បីពោលបានថា ចេតោបរិយញ្ញាណនឹងកើតឡើងក្នុងឥឡូវនេះ ដូច្នេះ ធ្វើចិត្តដែលកំណត់បានថា កំពុងប្រព្រឹត្តទៅក្នុងពេលនោះឲ្យជាអារម្មណ៍ , កាលមនោទ្វារាវជ្ជនៈនោះរលត់ទៅហើយ ជវន ៤ ឬ ៥ ខណៈ រមែងស្ទុះទៅ បណ្តាជវនទាំងនោះ ជវនដែលមាន ៣ ខណៈ ឬ ៤ ខណៈខាងដើម ជាកាមាវចរ មានសមញ្ញាថា បរិកម្មជាដើម ជវនខណៈទី ៤ ឬ ខណៈទី ៥ ជាអប្បនាចិត្តថ្នាក់រូបាវចរចតុត្ថជ្ឈាន ។ ក្នុងជវនទាំងនោះ ញាណដែលកើតឡើង ព្រមជាមួយនឹងអប្បនាចិត្តនោះឯណា ញាណនេះឈ្មោះថា ចេតោបរិយញ្ញាណ ព្រះយោគីនេះបានធ្វើបរិកម្មទុកក្នុងចិត្តណា ចេតោបរិយញ្ញាណនោះ រមែងប្រព្រឹត្តទៅដឹងចិត្តរបស់អ្នកដទៃ ដែលចាក់ធ្លុះដោយប្រចក្សនោះឯង ដូចទិព្វចក្ខុញ្ញាណប្រព្រឹត្តទៅឃើញរូប និងទិព្វសោតញ្ញាណប្រព្រឹត្តទៅឮសំឡេង ដូច្នោះ ។ តពីនោះទៅ រមែងមានការកំណត់ចិត្ត មានចិត្តដែលមានរាគៈជាដើម ដោយកាមាវចរចិត្ត ដូចការកំណត់សំពត់ មានពណ៌ខៀវជាដើមដូច្នេះ ។ ដើម្បីសម្តែងថា សូម្បីវិធីត្រឡប់មកនៃចេតោបរិយញ្ញាណដែលសម្រេចហើយយ៉ាងនេះ ក៏ដូចគ្នា នឹងវិធីសម្រេចនោះឯង ដូច្នេះ ទើបលោកអាចារ្យពោលថា ព្រោះដូច្នោះ ភិក្ខុនោះ ។ ល ។ ក៏គប្បីធ្វើចេតោបរិយញ្ញាណឲ្យមានកម្លាំងបានដូច្នេះ ។

ពាក្យថា **កាលចេតោបរិយញ្ញាណនោះ មានកម្លាំងហើយយ៉ាងនេះជាដើម** ជាពាក្យសម្តែងអានិសង្សនៃចេតោបរិយញ្ញាណដ៏មានកម្លាំង ។ ពាក្យថា **កាមាវចរចិត្តគ្រប់ដួង** គឺ កាមាវចរចិត្តទាំង ៥៤ ដួង ។ គប្បីនាំបទថា **សព្វម្បិ** គឺ គ្រប់ដួងមកភ្ជាប់សេចក្តីក្នុងបទថា **រូបាវចរារូបាវចរចិត្តំ** នេះ ។ ដោយបទថា **សព្វម្បិ**

នោះ ជាការដែលពោលអធិប្បាយថា រូបាវចរចិត្តទាំង ១៥ ដួង អរូបាវចរចិត្តទាំង ១២ ដួង ។ ពាក្យថា **រមែងដឹង** គឺ ដឹងដោយប្រការទាំងឡាយ មានប្រការថា រាគៈជាដើម ។ អធិប្បាយថា ចាក់ធ្លុះដោយប្រចក្ស ។ អភិញ្ញាកថានេះ លោកពោលទុកដោយទាក់ទងនឹងព្រះយោគីអ្នកជាបុថុជ្ជន ព្រោះហេតុនោះ ទើបលោកមិនលើកលោកុត្តរចិត្តទុកក្នុងទីនេះ ។ ក៏ព្រះអរិយបុគ្គលថ្នាក់ខ្ពស់ជាង ឬថា ថ្នាក់ស្មើគ្នា រមែងដឹងចិត្តសូម្បីដែលជាលោកុត្តរនោះរបស់ព្រះអរិយបុគ្គលថ្នាក់ទាបជាង និងថ្នាក់ស្មើគ្នាបានផងដែរ ។ ព្រោះហេតុនោះ ទើបត្រាស់ទុកថា **អនុត្តរំ វា ចិត្តំ** ( រមែងដឹងអនុត្តរចិត្ត គឺ លោកុត្តរចិត្តខ្លះ ) ដូច្នេះ ។

ពាក្យថា **ឈានទៅ** គឺឈានចូលទៅដោយញាណ ។ លោកអាចារ្យពោលដល់ព្រះយោគីអ្នកដឹងចិត្តដួងខ្លះ ហើយដឹងចិត្តដួងដទៃបន្ទាប់ពីចិត្តដួងនោះ ដោយវៀរការបរិកម្មថា ចេញពីចិត្តទៅកាន់ចិត្ត ដូច្នេះ ។ ព្រោះហេតុនោះ ទើបពោលថា សូម្បីវៀរការសម្លឹងមើលហទយរូប ដូច្នេះ ។ សេចក្តីពិតថា វិធីការមានការសម្លឹងមើលហទយរូបជាដើម លោកពោលទុកទាក់ទងនឹងព្រះយោគីអ្នកជាអាទិកម្មិកៈ គឺផ្តើមបំពេញ ។ ព្រោះហេតុនោះ ទើបលោកពោលទុកថា សូម្បីប្រការនេះ ក៏សមពិតដូច្នេះជាដើម ។ ពាក្យថា **ក្នុងភពណាមួយ** គឺ ក្នុងបញ្ចវោការភពក៏បាន សូម្បីក្នុងចតុវោការភពក៏បាន ។ ភិក្ខុ ឈ្មោះថា **អកតា ភិនិវេសោ** ព្រោះអត្ថថា មិនបានធ្វើការសន្សំ ពោលគឺការបំពេញអភិញ្ញាទុក បានដល់ ទាក់ទងនឹងភិក្ខុអ្នកមិនបានធ្វើការសន្សំទុកនោះ មានសេចក្តីថា ទាក់ទងនឹងភិក្ខុអ្នកជាអាទិកម្មិក ។ ពាក្យថា **កថានេះ** គឺកថាស្តីពីការបរិកម្មដែលបានពោលទុកដោយពាក្យថា ពង្រីកអាលោកកសិណ ដូច្នេះជាដើម ។

ពាក្យថា **ចិត្តដ៏សេស** គឺ នៅសល់អពីពោលហើយ ។ លោកអាចារ្យប្រាថ្នាសម្ដែងចិត្តដែលនៅសល់ ដែលបានពោលទុកដោយមិនទាន់បានចែក យ៉ាងនេះ ដោយការចែក ទើបពោលថា កុសល និងអព្យាកតចិត្តក្នុងភូមិ ៤ ឈ្មោះថា **វីតរាគំ** ( ចិត្តដែលប្រាសចាករាគៈ )ដូច្នេះ ។ ពិតហើយ កុសល និងអព្យាកតចិត្តនោះ រមែងបាននូវភាពជាចិត្តដែលគួរនឹងហៅថា **វីតរាគំ** ព្រោះមិនមានការគួរឲ្យរង្កៀស ដោយការប្រកបរួមគ្នានឹងរាគៈ ព្រោះហេតុមានយោនិសោមនសិការជាបច្ច័យ មានយោនិសោមនសិការនោះជាហេតុជាដើម ។ សម្រាប់កុសលចិត្តដែលនៅសល់ ៤ ដួង មិនមានភាពជាសរាគចិត្ត ( ចិត្តប្រកបដោយរាគៈឡើយ ) ព្រោះមិនមានការប្រកបរួមគ្នានឹងរាគៈ ព្រោះចិត្តដែលប្រព្រឹត្តទៅនឹងរាគៈនោះ គប្បីមានបាន ក៏ព្រោះជាចិត្តដែលមាននិមិត្តសម្គាល់ដោយរាគៈនោះ ព្រោះហេតុនោះក៏រមែងមិនមានសូម្បីភាពជាវីតរាគចិត្ត គឺ ចិត្តដែលប្រាសចាករាគៈឡើយ ព្រោះហេតុនោះ ទើបត្រូវផុតអំពីទុកៈ ព្រោះហេតុនោះ លោកទើបពោលថា រមែងមិនដល់នូវការសង្គ្រោះចូលក្នុងទុកៈនេះ ដូច្នេះ ។ សួរថា បើយ៉ាងនេះ ក៏រមែងដល់ភាពជាចេតោបរិយញ្ញាណដែលដឹងបានដោយចំណែកខ្លះឬ ? ឆ្លើយថា មិនដល់ទេ ព្រោះអកុសលដែលមិនដល់ការសង្គ្រោះចូលទុកក្នុងទុកៈនេះទាំងនោះ ក៏មានទាក់ទងក្នុងទុកៈដទៃ ។ ចំណែកអាចារ្យពួកណាគិតថា កាលមិនមានភាពជាបដិបក្ខការមិនមានការប្រកបរួមគ្នានឹងរាគៈនោះឯង ជាប្រមាណក្នុងចិត្តពួកនេះ ដូចការមិនមានការប្រកបរួមគ្នានឹងរាគៈនៃអព្យាកតចិត្តទាំងឡាយដួងខ្លះ ដូច្នោះ ដូច្នេះហើយ អះអាងថា សូម្បីអកុសលចិត្តដទៃដែលនៅសល់ទាំងឡាយ ក៏មានភាពជាចិត្តដែលប្រាសចាករាគៈ លោកអាចារ្យសំដៅយកអាចារ្យទាំងនោះពោលថា

តែព្រះថេរៈទាំងឡាយអង្គខ្លះ ក៏សង្គ្រោះយកចិត្ត ៤ ដួង ពួកនោះដែរ ដូច្នេះ ។ សូម្បីក្នុង សទោសទុកៈ គឺ ចិត្ត ២ ដួង មានចិត្តដែលមានទោសៈជាដើម បណ្ឌិតគប្បីជ្រាបអត្ថាធិប្បាយដូចគ្នាចុះ ។

ពាក្យថា **ដោយបាដិបុគ្គលិកន័យ** គឺ ដោយន័យដែលពោលចំពោះ **ចិត្ត** មានសេចក្ដីថា ដោយភាវៈដែលមោហៈមិនលាយគ្នានឹងលោភៈ និងទោសៈ ដូចក្នុងអកុសលចិត្តដួងដទៃពីមោហមូលចិត្ត ២ ដួងនោះ ក៏មានពិត ។ បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នាក្នុងន័យទាំង ២ ដោយមានពាក្យ**អាវេណិកៈ**( ឯរ-ស័ព្ទ ) ត្រង់បទដើម និងបទចុងយ៉ាងនេះ គឺ ក្នុងបណ្ដាចិត្តដែលរាប់ថា មានអកុសលជាមូលទាំងឡាយ ក្នុងន័យដំបូង **សហមោហេនេវាតិ សមោហំ** ចិត្តឈ្មោះថាប្រកបដោយមោហៈ ព្រោះអត្ថថា ប្រព្រឹត្តព្រមគ្នានឹងមោហៈប៉ុណ្ណោះ មិនបានប្រព្រឹត្តទៅព្រមនឹងលោភៈ ឬទោសៈទេ ចំណែកក្នុងន័យទី ២ **សហេវមោហេនាតិ សមោហំ ចិត្ត** ឈ្មោះថា ប្រកបដោយមោហៈ ព្រោះអត្ថថា ប្រព្រឹត្តទៅព្រមគ្នាប៉ុណ្ណោះនឹងមោហៈ ។ ចិត្តដែលទៅ គឺ ប្រព្រឹត្តទៅដោយអំណាចការបណ្ដោយតាមថីនៈ និងមិទ្ធៈដែលសម្បយុត្តនឹងខ្លួន ឈ្មោះថា **ថីនមិទ្ធានុគតំ** ( ចិត្តដែលទៅតាមថីនៈ និងមិទ្ធៈ ) ។ អកុសលចិត្តដែលជាសសង្ខារិក ៥ ដួង ឈ្មោះថា **សង្ខិត្តំ**( ចិត្តរួញរា ) ព្រោះប្រព្រឹត្តទៅដោយអំណាចការរួញរាក្នុងអារម្មណ៍ ។ គប្បីជ្រាបនូវចិត្តដែលជា **ឧទ្ធច្ចានុគតំ** ( ទៅតាមឧទ្ធច្ចៈ ) តាមន័យដែលបានពោលហើយ ។ ចិត្តដែលទៅតាមឧទ្ធច្ចៈនោះ បានដល់ ចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ឬថា បានដល់ ចិត្តជាទីដែលឧទ្ធច្ចៈប្រព្រឹត្តទៅ ជាធម្មជាតិមានកម្លាំងដោយបច្ច័យពិសេស , ចិត្តឈ្មោះថា **មហគ្គតំ** ព្រោះអត្ថថា ទៅកាន់ភាពដ៏ធំក្រៃលែង ព្រោះមានអំណាចក្នុង

ការគ្របសង្កត់កិលេស ព្រោះជាចិត្តដែលមានផលបរិបូរណ៍ និងព្រោះជាចិត្តដែលមានការបន្តគ្នាបានយូរ ឬ ព្រោះអត្ថថា **ទៅ** គឺ ព្រះយោគាវចរធ្វើឲ្យប្រព្រឹត្តទៅ ( បដិបត្តិ )ដោយធម៌ដ៏ធំក្រៃលែង គឺ ឆន្ទៈ វីរិយៈ ចិត្ត និងបញ្ញាដ៏ឧឡារិក ។ ពាក្យថា **ចិត្តដ៏សេស** បានដល់ បរិត្តចិត្ត គឺ កាមាវចរចិត្ត និងអប្បមាណចិត្ត គឺ លោកុត្តរចិត្ត ។ **ចិត្ត** ឈ្មោះថា **សឧត្តរំ** ( ចិត្តនៅមានចិត្តដទៃក្រៃលែងជាង ) ព្រោះអត្ថថាមានឧត្តរចិត្តប្រសើរជាង ដែលអាចរើខ្ជួនឡើងបាន ។ **ចិត្ត** ឈ្មោះថា **ឧត្តរំ** ព្រោះអត្ថថា ឆ្លងបានហើយ ។ **ចិត្ត** ឈ្មោះថា **លោកុត្តរំ** ( លោកុត្តរចិត្ត ) ព្រោះអត្ថថា ឆ្លងផុតលោក ព្រោះជាចិត្តដែលមិនជាប់ក្នុងលោក ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា **អនុត្តរំ** ព្រោះអត្ថថា មិនមានចិត្តដែលក្រៃលែងជាង ។ **ចិត្ត** ឈ្មោះថា **សមាហិតំ** ព្រោះអត្ថថា តាំងមាំដោយប្រពៃនោះឯង ដោយសមាធិដែលមានសភាវៈ គឺ លក្ខណៈដែលចូលទៅសម្ងំងអារម្មណ៍ ។ ឈ្មោះថា **ចិត្ត** ដែលដល់តទង្គវិមុត្តិ បានដល់ កាមាវចរចិត្ត ។ **ចិត្ត** ដែលដល់វិក្ខម្ភនវិមុត្តិ បានដល់ មហគ្គតចិត្ត ។ **ចិត្ត** ដែលដល់សមុច្ឆេទវិមុត្តិ បានដល់ មគ្គចិត្ត ។ ឈ្មោះថា ចិត្តដែលដល់បស្សទ្ធិវិមុត្តិ បានដល់ ផលចិត្ត , សូម្បីឈ្មោះថា ចិត្តដែលដល់និស្សរណវិមុត្តិ ក៏បានដល់ មគ្គចិត្ត និងផលចិត្តទាំងពីរយ៉ាងនោះឯង ។ ចិត្តដួងខ្លះមានបច្ចវេក្ខណចិត្តជាដើម ជាចិត្តដែលមានព្រះនិព្វានជាអារម្មណ៍ក៏ពិត សូម្បីដូច្នោះក៏មិនឈ្មោះថា ជាចិត្តដែលដល់នូវនិស្សរណវិមុត្តិ ព្រោះមិនប្រកបដោយកិច្ចដែលប្រាកដដូច្នោះ ។ ភិក្ខុអ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តគ្រប់ប្រការ ដោយទាក់ទងនឹងការផ្សេងគ្នានៃចិត្ត មានចិត្តដែលមានរាគៈជាដើម ដែលមកហើយក្នុងព្រះបាលី និងដោយទាក់ទងនឹងការផ្សេងគ្នា ក្នុងខាងក្នុងនៃចិត្តពួកនោះ ។

ចប់មហាដីកា

( ចប់ការអធិប្បាយ ចេតោបរិយញ្ញាណ )

# បុព្វេនិវាសានុស្សតិញ្ញាណ

## អត្ថាធិប្បាយ ស័ព្ទចាលីក្នុងញាណនេះ

*ក្នុងបុព្វេនិវាសានុស្សតិញ្ញាណកថា មានអត្ថាធិប្បាយថា បទថា* ***បុព្វេនិវា-សានុស្សតិញ្ញាណាយ****-ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺញាណណាគប្បីប្រព្រឹត្ត ទៅក្នុងបុព្វេនិវាសានុស្សតិ ដើម្បីប្រយោជន៍ដល់ញាណនោះ ពាក្យថា* ***បុព្វេនិវាស*** *សំដៅដល់ខន្ធដែលខ្លួនអាស្រ័យនៅក្នុងគ្រាមុន គឺក្នុងជាតិដែលកន្លងទៅហើយទាំង ឡាយ ពាក្យថា* ***និវុដ្ឋ-ដែលខ្លួនអាស្រ័យនៅ*** *មានសេចក្តីថា ដែលខ្លួនគ្រប់គ្រង មក ដែលខ្លួនសោយមក ដែលវាកើតរលត់នៅក្នុងសន្តានរបស់ខ្លួន ម្យ៉ាងទៀត* ***និវុដ្ឋធម៌*** *( រឿង ឬអាការផ្សេងៗ ដែលអាស្រ័យខន្ធ ដូចកំណើត ឈ្មោះ គោត្រ ភេទ ពណ៌សម្បុរទាំងឡាយក៏ឈ្មោះ* ***និវុដ្ឋ*** *សំដៅយកវត្ថុដែលអាស្រ័យ ព្រោះជា គោចរ ( គឺជាអារម្មណ៍សម្រាប់រលឹក ) កំណត់ដឹងបានដោយវិញ្ញាណ គឺ ការដឹង របស់ខ្លួន ម្យ៉ាងទៀត សូម្បីដែលកំណត់ដឹងដោយវិញ្ញាណ គឺ ការដឹងរបស់លោក អ្នកដទៃ ក៏ឈ្មោះថា* ***និវុដ្ឋ*** *គប្បីឃើញក្នុងការឭកដល់លោកអ្នកជា* ***ឆិន្នវដ្តមក*** *( អ្នកកាត់វដ្តសង្សារ គឺ បរិនិព្វានហើយ ) និវុដ្ឋធម៌ទាំងនោះ រមែងមានចំពោះតែ ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ។*

*ពាក្យថា* ***បុព្វេនិវាសានុស្សតិ*** *គឺកិក្ខុរលឹកបុព្វេនិវាសាបានដោយសតិណា សតិនោះឈ្មោះថា បុព្វេនិវាសានុស្សតិ , ពាក្យថា* ***ញាណ*** *សំដៅយកញាណដែល សម្បយុត្តនឹងសតិនោះ ។*

*ដើម្បីប្រយោជន៍ដល់បុព្វេនិវាសានុស្សតិញ្ញាណនេះ ដូចដែលពោលមកដូច្នេះ*

ឈ្មោះថា ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ អធិប្បាយថា ដើម្បីសម្រេចដល់ញាណនោះ ។

បទថា **អនេកវិហិតំ** ប្រែថា មិនមែនតែមួយ ន័យម្យ៉ាងទៀត ឲ្យប្រព្រឹត្តទៅ គឺពណ៌នាបានដោយប្រការជាច្រើន បទថា **បុព្វេនិវាសំ** បានដល់ ខន្ធសន្តានដែលជាទីអាស្រ័យមកក្នុងភពនោះៗ ផ្តើមតាំងអំពីភពដែលជាអតីតជិតបំផុតទៅ , បទថា **អនុស្សរតិ** គឺ រលឹកតាមទៅ តាមលំដាប់នៃខន្ធ ឬថា ដោយចុតិបដិសន្ធិ ។

## បុគ្គលអ្នករឭកបុព្វេនិវាសបាន៦ប្រភេទ

ក៏ជន ៦ ប្រភេទរមែងរឭកបុព្វេនិវាសនេះបាន គឺតិត្ថិយទាំងឡាយ ព្រះបកតិសាវ័កទាំងឡាយ ព្រះមហាសាវ័កទាំងឡាយ ព្រះអគ្គសាវ័កទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះពុទ្ធទាំងឡាយ ។

## រយៈកាលផ្សេងគ្នា

ក្នុងជន ៦ ប្រភេទនោះ តិត្ថិយទាំងឡាយរឭកបានត្រឹម ៤០ កប្ប មិនក្រៃលែងជាងនោះ ព្រោះហេតុអ្វី ព្រោះមានបញ្ញាទន់ខ្សោយ ពិតហើយ បញ្ញារបស់តិត្ថិយទាំងនោះចាត់ថាជាបញ្ញាទន់ខ្សោយ ព្រោះប្រាសចាកការកំណត់នាមរូប ព្រះបកតិសាវ័ករឭកបាន ១០០ កប្បក៏មាន ១០០០ កប្បក៏មាន ព្រោះជាអ្នកមានបញ្ញាចាស់ក្លា ព្រះអសីតិមហាសាវ័ករឭកបានមួយសែនកប្ប ព្រះអគ្គសាវ័កទាំងពីររឭកបាន ១អសង្ខេយ្យ១សែនកប្ប ព្រះបច្ចេកពុទ្ធរឭកបាន ២អសង្ខេយ្យ១សែនកប្ប ព្រោះថា អភិនីហាររបស់លោកទាំងនោះមានប៉ុណ្ណេះ តែសម្រាប់ព្រះពុទ្ធទាំងឡាយមិនមានកំណត់កាលទេ ។

## សមត្ថភាពក្នុងការរឭកជាតិផ្សេងគ្នា

ម្យ៉ាងទៀត តិរ្ថិយទាំងឡាយរឭកបានតែតាមលំដាប់ខន្ធ មិនអាចរំលងលំដាប់ មករឭកដោយចុតិបដិសន្ធិបាន ព្រោះការឈានចុះដោយញាណ ត្រង់កន្លែងដែលត្រូវការ រមែងមិនមានដល់តិរ្ថិយទាំងនោះ ដែលដូចជាមនុស្សខ្វាក់ភ្នែក ម្យ៉ាងទៀត មនុស្សភ្នែកខ្វាក់ទាំងឡាយ មិនលែងឈើច្រត់ចោល ទើបដើរទៅបាន យ៉ាងណា តិរ្ថិយទាំងនោះក៏មិនលែងលំដាប់នៃខន្ធចោល ទើបរឭកទៅបានក៏ដូច្នោះ ព្រះបកតិសាវកទាំងឡាយរឭកតាមលំដាប់ខន្ធខ្លះ រឭកឆ្លងទៅដោយចុតិបដិសន្ធិខ្លះ ព្រះអសីតិមហាសាវកទាំងឡាយក៏យ៉ាងនោះ តែសម្រាប់ព្រះអគ្គសាវកទាំងពីរ កិច្ចដោយការរឭក តាមលំដាប់ខន្ធមិនមាន លោករឭកឆ្លងទៅដោយចុតិបដិសន្ធិតែម្តង ដូច្នេះ គឺ ឃើញចុតិនៃអត្តភាពមួយហើយ ក៏ឃើញបដិសន្ធិ( ក្នុងអត្តភាពដទៃតទៅ ) ឃើញចុតិនៃអត្តភាពដទៃទៀតហើយ ក៏ឃើញបដិសន្ធិក្នុងអត្តភាពដទៃតទៅទៀត...ព្រះបច្ចេកពុទ្ធទាំងឡាយក៏ដូច្នោះ តែសម្រាប់ព្រះពុទ្ធទាំងឡាយ កិច្ចដោយការរឭកតាមលំដាប់ មិនមានឡើយ កិច្ចរឭកទៅដោយឆ្លងចុតិបដិសន្ធិ មិនមានឡើយ ការពិតព្រះពុទ្ធទាំងឡាយ មានព្រះបំណងនឹងទ្រង់ជ្រាបត្រង់ទីណាៗ ក្នុងខាងក្រោម ឬខាងលើក៏ដោយ ក្នុងកាលច្រើនកោដិកប្ប ទីនោះៗក៏រមែងប្រាកដចំពោះព្រះអង្គដោយពិត ព្រោះហេតុនោះ ព្រះពុទ្ធទាំងឡាយនោះ ទើបដូចគ្នានឹងទ្រង់បង្ហាញកប្បរាប់កោដិ ចូលដូចបេយ្យាលបាលី គឺ បាលីដែលលះទុកដោយបេយ្យាល ហើយទ្រង់ព្រះបំណងនឹងទ្រង់ជ្រាបត្រង់ទីណាៗ ក្នុងកប្បណា ក្នុងភពណា ក៏ឈានចុះដោយព្រះញាណក្នុងទីនោះៗ ( ក្នុងកប្បនោះក្នុងភពនោះ ) ទ្រង់ញុំាងព្រះញាណឲ្យប្រព្រឹត្តទៅបានយ៉ាងស្ទាត់ជំនាញ ដោយអាការដូចរាជសីហ៍ជួប

សត្វ ក៏កាលទ្រង់ញ៉ាំងព្រះញាណទៅយ៉ាងនោះ ព្រះញាណរបស់ព្រះអង្គរមែងមិនទើសទាក់នៅក្នុងជាតិជាចន្លោះៗ រមែងមិនខុស កាលមិនទើសទាក់មិនខុស ក៏ត្រូវទ្រង់ចាប់យកទីតាមព្រះបំណងបានដោយពិត ប្រៀបដូចកូនសរដែលនាយខ្មាន់ធ្នូអ្នកហ្វឹកហាត់បានស្ទាត់ជំនាញក្នុងការបាញ់រោមទ្រាយមកហើយ ដូចសរគន្ធពោធិសត្វបាញ់ចេញទៅមិនទើសទាក់ដើមឈើ និងពួកវល្លិជាដើមក្នុងទីចន្លោះ រមែងធ្លាក់ត្រូវទីដៅ មិនទើសទាក់មិនខុសដូច្នោះ ។

## ប្រៀបធៀបអានុភាពនៃញាណ

ក្នុងជនអ្នករឭកក្នុងបុព្វេនិវាសបានពួកនេះ ការឃើញបុព្វេនិវាសនៃតិរ្ថិយទាំងឡាយ ប្រាកដដូចពន្លឺអំពិលអំពែក... នៃព្រះបកតិសាវកទាំងឡាយ ដូចពន្លឺចង្កៀង... នៃព្រះមហាសាវកទាំងឡាយ ដូចពន្លឺគប់ភ្លើង... នៃអគ្គសាវក... ដូចពន្លឺផ្កាយព្រឹក... នៃព្រះបច្ចេកពុទ្ធទាំងឡាយ... ដូចពន្លឺព្រះចន្ទ... នៃព្រះពុទ្ធទាំងឡាយ... ដូចដួងព្រះអាទិត្យ ១.០០០ ដួង ក្នុងសរទរដូវ ដែលមួយដួងៗ ប្រដាប់ទៅដោយសហស្សរស្មី ១.០០០ ពន្លឺ នេះប្រការមួយ ។

ប្រការមួយទៀត ការរឭកបុព្វេនិវាសានុស្សតិបាននៃតិរ្ថិយទាំងឡាយ ដូចជាដើរស្ទាបៗ ដោយចុងជើងនៃពួកមនុស្សខ្វាក់ភ្នែក... នៃបកតិសាវកទាំងឡាយ ដូចដើរលើស្ពានកំណាត់ឈើ គឺដើរបានម្នាក់... នៃព្រះមហាសាវកទាំងឡាយ ដូចដើរលើស្ពានថ្មើជើង គឺក្រាលក្តារ មនុស្សដើរបានច្រើននាក់... នៃព្រះអគ្គសាវក ដូចដើរលើស្ពានរទេះ... នៃព្រះបច្ចេកពុទ្ធទាំងឡាយ ដូចដើរលើផ្លូវថ្មើជើង... នៃព្រះពុទ្ធដូចដើរក្នុងផ្លូវរទេះធំ ។

## ការរឭកដែលប្រាថ្នា

តែក្នុងអធិការនៃសមាធិការនានេះ ប្រាថ្នាយកការរឭកបុព្វេនិវាសនៃសាវក ទាំងឡាយ ព្រោះដូច្នោះ ទើបខ្ញុំពោលទុកថា បទថា **អនុស្សរតិ** គឺ រឭកតាមទៅ ដោយលំដាប់នៃខន្ធ ឬថា ដោយចុតិបដិសន្ធិដូច្នេះ ។

## វិធីចម្រើនបុព្វេនិវាសានុស្សតិ

ព្រោះហេតុនោះ ភិក្ខុអាទិកម្មិកអ្នកប្រាថ្នានឹងរឭកបានយ៉ាងនោះ ពេលក្រោយ អាហារ ត្រឡប់ពីបិណ្ឌបាតហើយ គប្បីទៅនៅក្នុងទីស្ងាត់ សំងំនៅតែម្នាក់ឯងចូល ឈាន ៤ តាមលំដាប់ ចេញចាកចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញាហើយ អាវជ្ជនាការ ដល់ការអង្គុយចុងក្រោយ គឺការអង្គុយលើកនេះឯង តពីនោះ គប្បីអាវជ្ជនាការ ដល់កិច្ចដែលធ្វើទាំងយប់ និងទាំងថ្ងៃ តាមលំដាប់លំដោយដូច្នេះ ( ការក្រាល អាសនៈមុននឹងអង្គុយ ) ការចូលមកកាន់សេនាសនៈ ការទុកបាត្រ ចីវរពេលឆាន់ ពេលមកពីស្រុក ពេលត្រាច់បិណ្ឌបាតក្នុងស្រុក ពេលចូលស្រុកដើម្បីបិណ្ឌបាត ពេលចេញពីវិហារ ពេលថ្វាយបង្គំព្រះចេតិយ និងព្រះពោធិព្រឹក្ស ទីលានព្រះ ចេតិយ និងព្រះពោធិព្រឹក្ស ពេលជម្រះបាត្រ ពេលចាប់បាត្រ កិច្ចដែលធ្វើបន្ទាប់ពី ការចាប់បាត្រ រហូតដល់លប់លាងមុខ កិច្ចដែលធ្វើក្នុងពេលជិតភ្លឺ កិច្ចដែលធ្វើក្នុង មជ្ឈិមយាម កិច្ចដែលធ្វើក្នុងបឋមយាម ។

ក៏កិច្ចត្រឹមប៉ុណ្ណោះរមែងប្រាកដដល់បកតិចិត្ត សមាធិចិត្តក្នុងបរិកម្ម ប្រាកដ ច្បាស់ក្រៃលែង តែថា ក្នុងកិច្ចទាំងនោះកិច្ចណាមួយមិនប្រាកដដូច្នោះ ក៏គប្បីចូល ឈានដែលជាបាទ ចេញហើយអាវជ្ជនាការជាថ្មីដោយវិធីប៉ុណ្ណោះ កិច្ចនោះ ក៏រមែង

នឹងប្រាកដដូចក្នុងទីងងឹត កាលប្រទីបឆេះឡើងហើយ វត្ថុគ្រប់យ៉ាងក៏ប្រាកដ ។

ភិក្ខុគប្បីអាវជ្ជនាការដល់កិច្ចដែលធ្វើមកតាមលំដាប់លំដោយយ៉ាងនេះ សូម្បីក្នុងថ្ងៃទី២ ថ្ងៃទី៣ ទី៤ ទី៥ ទី១០ សូម្បីក្នុងកន្លះខែ សូម្បីក្នុងមួយខែ សូម្បីដល់មួយឆ្នាំដោយឧបាយនេះឯង ភិក្ខុកាលអាវជ្ជនាការដោយលំដាប់លំដោយទៅ បាន ១០ឆ្នាំ ២០ឆ្នាំ ជាដើម ទៅរហូតដល់ការបដិសន្ធិរបស់ខ្លួនក្នុងភពនេះបាន ក៏គប្បីអាវជ្ជនាការដល់នាមរូបដែលប្រព្រឹត្តទៅក្នុងខណៈចុតិ ក្នុងភពមុន( តទៅ ) ឯភិក្ខុអ្នកមានបញ្ញាមែងអាចដកបដិសន្ធិចេញ ធ្វើនាមរូបក្នុងខណៈចុតិឲ្យជាអារម្មណ៍បានដោយភារៈដំបូងតែម្តង តែព្រោះនាមរូបក្នុងភពមុន ក៏រលត់ទៅហើយមិនមាននៅសល់ នាមរូបដទៃកើតឡើងថ្មី ព្រោះហេតុនោះ ឋានៈនោះទើបមិនប្រាកដ ដូចទីងងឹតឈឹង អ្នកមានបញ្ញាទន់ខ្សោយមើលឃើញបាន សូម្បីដូច្នោះ ភិក្ខុនោះក៏មិនគួរធ្វើការដាក់ធុរៈថា យើងមិនអាចដកបដិសន្ធិចេញ ធ្វើនាមរូបដែលប្រព្រឹត្តទៅក្នុងខណៈចុតិឲ្យជាអារម្មណ៍បាន តែថា គួរចូលឈានដែលជាបាទនោះឯងរឿយៗ និងចេញចាកឈាននោះហើយ ក៏គប្បីអាវជ្ជនាការដល់ស្ថាននោះរឿយៗទៅចុះ ព្រោះថា កាលធ្វើយ៉ាងនោះ ក៏ប្រៀបដូចមនុស្សមានកម្លាំង កាលកាត់ដើមឈើធំដើម្បីប្រយោជន៍ និងធ្វើជាជហ្វានៃដំបូលផ្ទះ កាលមុខពូថៅឆែបខូច ដោយត្រឹមតែកាត់មែកឈើបាន មិនអាចកាត់ដើមឈើធំបាន ក៏មិនធ្វើការដាក់ធុរៈចោលឡើយ គប្បីកាន់ពូថៅនោះទៅរោងជាងដែក ឲ្យជាងដែកធ្វើពូថៅនោះឲ្យមុត ហើយមកកាត់ទៀត និងកាលវាឆែបទៀត ក៏ឲ្យជាងធ្វើយ៉ាងនោះហើយ មកកាត់ទៀតនោះឯង បុរសនោះព្យាយាមកាត់ទៅយ៉ាងនោះ មិនយូរប៉ុន្មាន ក៏នឹងអាចផ្តួលដើមឈើធំចុះបាន ព្រោះសាច់ឈើដែលកាត់ហើយ មិនជាវត្ថុដែលនឹងត្រូវកាត់ទៀត និងព្រោះ

កាត់តែកន្ទេងដែលនៅមិនទាន់បានកាត់ យ៉ាងណាក្តី ភិក្ខុចេញចាកឈានដែលជាបាទហើយ មិនអាវជ្ជនាការដល់កិច្ចដែលអាវជ្ជនាការមកពីមុនហើយ អាវជ្ជនាការតែបដិសន្ធិតែម្យ៉ាង មិនយូរប៉ុន្មានក៏នឹងគប្បីដកបដិសន្ធិ ធ្វើនាមរូបដែលប្រព្រឹត្តទៅក្នុងខណៈចុតិឲ្យជាអារម្មណ៍បានក៏ដូច្នោះដូចគ្នា ។

សេចក្តីខនេះបណ្ឌិតគប្បីសម្តែងដោយរឿងដទៃៗ មានរឿងមនុស្សពុះឧសនិងជាងកាត់សក់ជាដើមខ្លះក៏បាន ។

## ការដឹងពេលដែលជាបុព្វេនិវាសញ្ញាណ

ក្នុងកិច្ចទាំងនោះ ញាណដែលធ្វើកិច្ចចាប់ផ្តើមពីការអង្គុយលើកក្រោយបំផុតរហូតដល់ការធ្វើបដិសន្ធិឲ្យជាអារម្មណ៍ មិនឈ្មោះថា **បុព្វេនិវាសញ្ញាណ** ទេ តែញាណនោះចាត់ជាបរិកម្មសមាធិញ្ញាណ( ញាណដែលប្រកបនឹងបរិកម្មសមាធិ ) អាចារ្យមួយពួកហៅថា **អតីតំសញ្ញាណ** ក៏មានពាក្យរបស់ពួកអាចារ្យ មួយពួកនោះមិនត្រឹមត្រូវ ព្រោះអតីតំសញ្ញាណសំដៅរូបាវចរៈ ចំណែកបរិកម្មសមាធិញ្ញាណជាកាមាវចរៈ ។

កាលណាមនោទ្វារាវជ្ជនៈឈានកន្លងបដិសន្ធិ( ក្នុងភពនេះ )ចេញ ធ្វើនាមរូបដែលប្រព្រឹត្តទៅក្នុងខណៈចុតិអំពីភពមុន ឲ្យជាអារម្មណ៍កើតឡើងដល់ភិក្ខុនោះ និងកាលមនោទ្វារាវជ្ជនៈនោះរលត់ទៅហើយ ជវ័ន ៤-៥ ដួង ធ្វើនាមរូបនោះឯងឲ្យជាអារម្មណ៍ស្ទុះទៅ ដែលជវ័នដួងដើមៗ ក៏មានឈ្មោះថា បរិកម្មជាដើមជាកាមាវចរៈដួងចុងក្រោយ គឺ ដួងទី ៤-៥ ជារូបាវចរៈ ប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈានជាអប្បនាចិត្ត តាមន័យដូចពោលមកហើយក្នុងកាលមុននោះឯង កាលនោះញាណ

ឯណាកើតឡើងដល់ភិក្ខុនោះ ព្រមទាំងចិត្តនោះ ញាណនេះទើបឈ្មោះថា បុព្វេនិវា-សានុស្សតិញាណ ភិក្ខុនោះរមែងរឭកបុព្វេនិវាសបានច្រើនយ៉ាង ដោយសតិដែលសម្បយុត្តនឹងញាណនោះ ច្រើនយ៉ាង គឺ ដូចម្តេច គឺ ភិក្ខុរលឹកបុព្វេនិវាសបានច្រើនប្រការ ព្រមទាំងអាការ( ដូចជា ពណ៌សម្បុរ ) ព្រមទាំងឧទ្ទេស( ដូចជា ឈ្មោះ គោត្រ ) គ្រប់កាលដូច្នេះ គឺ ១ជាតិក៏មាន ២ជាតិក៏មាន ។ ល ។ ដូច្នេះ ។

## សេចក្តីនៃពាក្យថា ជាតិ និងកប្ប

ក្នុងបាទទាំងនោះ ពាក្យថា **១ជាតិក៏មាន** បានដល់ ខន្ធសន្តានចំណែកមួយដែលមានបដិសន្ធិជាខាងដើម មានចុតិជាខាងចុង នៅក្នុងភពមួយក៏មាន សូម្បីក្នុងពាក្យថា **២ជាតិក៏មាន** ជាដើម ក៏មានន័យដូច្នេះ ។

## សំវដ្តកប្ប វិវដ្តកប្ប

ចំណែកក្នុងពាក្យថា ច្រើនសំវដ្តកប្បក៏មានជាដើម កប្បវិនាសគប្បីជ្រាបថាឈ្មោះ **សំវដ្តកប្ប** កប្បចម្រើនគប្បីជ្រាបថា ឈ្មោះថា **វិវដ្តកប្ប** ក្នុងពីរកប្បនោះ **សំវដ្តដ្ឋាយីកប្ប** ត្រូវកាន់យកដោយសំវដ្តកប្ប ព្រោះអ្វី ? ព្រោះសំវដ្ត-ដ្ឋាយីកប្ប មានសំវដ្តកប្បនោះជាមូល , **វិវដ្តដ្ឋាយីកប្ប** ក៏ត្រូវកាន់យកដោយវិវដ្តកប្ប ព្រោះវិវដ្តដ្ឋាយីកប្ប មានវិវដ្តកប្បជាមូលដូចគ្នា កាលបើយ៉ាងនោះ អសង្ខេយ្យកប្បពួកណា ដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អសង្ខេយ្យនៃកប្បមាន ៤ , អសង្ខេយ្យនៃកប្ប ៤ គឺអ្វីខ្លះ ? គឺសំវដ្តកប្ប ១ , សំវដ្តដ្ឋាយីកប្ប ១ , វិវដ្តកប្ប ១ , វិវដ្តដ្ឋាយីកប្ប ១ ដូច្នេះ អសង្ខេយ្យកប្បទាំងនោះ ក៏ត្រូវបានកាន់យកទាំងអស់ ។

## សំវដ្តកប្ប ៣

*ក្នុងកប្បទាំងនោះ សំវដ្តកប្បមានដល់ ៣ គត់ គឺ អាបោសំវដ្តៈ( វិនាសដោយទឹក ) , តេជោសំវដ្តៈ( វិនាសដោយភ្លើង ) , វាយោសំវដ្តៈ( វិនាសដោយខ្យល់ ) ។*

## សំវដ្តសីមា-ដែននៃសេចក្តីវិនាស

*ដែននៃសំវដ្តខាងលើ មាន ៣ គឺ ព្រហ្មលោកជាន់អាភស្សរា ជាន់សុភកិណ្ហា ជាន់វេហប្ផលា កាលកប្បវិនាសដោយភ្លើង លោកជាន់ក្រោមអាភស្សរាចុះមក ត្រូវភ្លើងឆេះទាំងអស់ , កាលកប្បវិនាសដោយទឹក លោកជាន់ក្រោមសុភកិណ្ហាចុះមក ត្រូវវិនាសដោយទឹកទាំងអស់ , កាលកប្បវិនាសដោយខ្យល់ លោកជាន់ក្រោមវេហប្ផលាចុះមក ត្រូវវិនាសដោយខ្យល់ទាំងអស់ តែកាលពោលដោយដែនផ្នែកទទឹង លោក ១ ពុទ្ធខេត្តរមែងវិនាសគ្រប់ពេល ។*

## ពុទ្ធខេត្ត ៣

*ពុទ្ធខេត្តនោះមាន ៣ យ៉ាង គឺ **ជាតិខេត្ត អាណាខេត្ត** និង**វិសយខេត្ត** ក្នុងពុទ្ធខេត្ត ៣ នោះ **ជាតិខេត្ត**មានព្រំដែនមួយម៉ឺនចក្កវាឡ ដែលជាខេត្តកម្រើកញ័រព្រោះហេតុអស្ចារ្យទាំងឡាយ មានការចុះកាន់បដិសន្ធិនៃអង្គព្រះតថាគតជាដើម , **អាណាខេត្ត**មានព្រំដែន១សែនកោដិចក្រវាឡ ជាហេតុដែលអានុភាពនៃព្រះបរិត្តពួកនេះ គឺ រតនបរិត្ត ខន្ធបរិត្ត ធជគ្គបរិត្ត អាដានាដិយបរិត្ត និងមោរបរិត្តប្រព្រឹត្តទៅ , **វិសយខេត្ត**មិនមានទីបំផុត មិនមានប្រមាណ ដូចព្រះមានព្រះភាគត្រាស់ថា តថាគត គប្បីប្រាថ្នាចង់ដឹងដោយទីប៉ុណ្ណោះ ដូច្នេះជាដើម ជាខេត្តដែលព្រះតថាគត*

ជាម្ចាស់ប្រាថ្នាចង់ជ្រាបវត្ថុណាៗ ក៏រមែងទ្រង់ជ្រាបវត្ថុនោះៗ ។

ក្នុងពុទ្ធខេត្ត ៣ ដូចពោលមកនេះ ខេត្តមួយ គឺ អាណាខេត្តរមែងវិនាសទៅ តែថា កាលអាណាខេត្តនោះវិនាសទៅ សូម្បីជាតិខេត្តក៏ត្រូវវិនាសផងដែរ ឯពុទ្ធខេត្តទាំងពីរនោះ កាលវិនាសរមែងវិនាសជាមួយគ្នា កាលតាំងឡើងជាថ្មីសោត ក៏តាំងឡើងជាមួយគ្នា ។

ការវិនាស និងការតាំងឡើងជាថ្មីនៃពុទ្ធខេត្តនោះ គប្បីជ្រាបដូចតទៅនេះ ។

## តេជោសំវដ្ដៈ

ក្នុងសម័យដែលកប្បវិនាសដោយភ្លើង ដំបូងមហាភ្លៀងរំលាយកប្បតាំងឡើង ញ៉ាំងភ្លៀងធំមួយមេឲ្យធ្លាក់ទូទាំងសែនកោដិចក្កវាឡ មនុស្សទាំងឡាយសប្បាយចិត្ត នាំយកពូជទាំងឡាយទៅសាបព្រោះ តែកាលសំណាបសន្ទូងទាំងឡាយ ដុះបានវែង ល្មមគោស៊ីបាន មេឃនោះក៏លាន់ឮជាសំឡេងលា មិនញ៉ាំងភ្លៀងឲ្យធ្លាក់សូម្បីត្រឹមតែមួយដំណក់ ភ្លៀងត្រូវរាំងទៅក្នុងកាលនោះ ព្រះមានព្រះភាគទ្រង់សំដៅដល់ ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សម័យនោះតែងមានជាសម័យដែលភ្លៀងមិនធ្លាក់ច្រើនឆ្នាំ... ច្រើនរយឆ្នាំ... ច្រើនពាន់ឆ្នាំ... ច្រើនសែនឆ្នាំដូច្នេះ សត្វទាំងឡាយអ្នកជាវិស្សុបជីវី គឺ អាស្រ័យភ្លៀងរស់នៅ ក៏ធ្វើកាលកិរិយាទៅកើតក្នុងព្រហ្មលោក ទេវតាជំពូកដែលជាបុប្ផផលុបជីវិនី គឺ អាស្រ័យផ្កាឈើនិងផ្លែឈើរស់នៅ ក៏ចុតិទៅកើតក្នុងព្រហ្មលោកដែរ កាលមិនមានភ្លៀងអស់កាលដ៏យូរអង្វែងយ៉ាងនេះ ទឹកក្នុងទីនោះៗ ក៏ដល់នូវការអស់ទៅ ត្រី និងអណ្ដើកទាំងឡាយ ក៏ត្រូវស្លាប់បន្តបន្ទាប់ទៅកើតក្នុងព្រហ្មលោក សូម្បីពួកសត្វ

នរក( ក៏ចុតិទៅកើតក្នុងព្រហ្មលោកដែរ ) អាចារ្យមួយពួកពោលថា ក្នុងសត្វទាំងនោះ ពួកសត្វនរកក៏រមែងវិនាស ព្រោះការប្រាកដឡើងនៃសុរិយៈដួងទី ៧ ។

មានបញ្ហាសួរថា វៀរឈានចេញ ការកើតក្នុងព្រហ្មលោកមិនមានទេ និងបណ្ដាសត្វដែលពោលមកនោះ ពួកខ្លះក៏ត្រូវទុរ្ភិក្ខបៀតបៀន ពួកខ្លះក៏នៅអភព្វ មិនអាចនឹងសម្រេចឈានបាន សត្វពួកនោះ នឹងទៅកើតក្នុងព្រហ្មលោកបានដូចម្ដេច? មានពាក្យឆ្លើយថា សត្វពួកនោះទៅកើតក្នុងព្រហ្មលោកបានដោយអំណាចឈានដែលខ្លួនទៅបានក្នុងទេវលោក ពិតហើយ ដោយពួកកាមាវចរទេព ពួកដែលឈ្មោះថា លោកព្យូហៈ ដឹងថា កន្លងទៅមួយសែនឆ្នាំ កប្បនឹងវិនាស ក៏ដោះឆ្នួតក្បាលរំសាយសក់ ស្រែកយំ ទឹកភ្នែកដោកមុខ ជូតទឹកភ្នែកដោយដៃ ស្លៀកសំពត់ក្រហម ទ្រទ្រង់ភេទនៃបុគ្គលអ្នកមានរូបវិកលដ៏ក្រៃលែង ត្រាច់រង្គាត់ស្រែកប្រាប់ទៅក្នុងតំបន់មនុស្សយ៉ាងនេះថា ពួកយើងអើយ ពីពេលនេះកន្លងទៅមួយសែនឆ្នាំកប្បនឹងវិនាស លោកនេះនឹងវិនាស មហាសមុទ្រសោតក៏នឹងរីងស្ងួត មហាប្រឹថពីនេះ និងភ្នំសិនេរុក៏ត្រូវភ្លើងឆេះវិនាសអស់ ការវិនាសនឹងមានឡើងទៅដល់ព្រហ្មលោក ពួកយើងអើយ អ្នកទាំងឡាយ ចូរចម្រើន មេត្តា ករុណា មុទិតា និងឧបេក្ខាចុះ ចូរទំនុកបម្រុងមាតាបិតា ចូរជាអ្នកឱនលំទោនចំពោះអ្នកធំក្នុងត្រកូលចុះ បានស្ដាប់ពាក្យរបស់ព្យូហទេវតាពួកនោះហើយ ពួកមនុស្ស និងភុម្មទេវតាដ៏ច្រើន កើតសេចក្ដីតក់ស្លុតចិត្តយ៉ាងខ្លាំង ក៏ជាអ្នកមានចិត្តទន់ភ្លន់ចំពោះគ្នានិងគ្នា នាំគ្នាធ្វើបុណ្យទាំងឡាយ មានមេត្តាជាដើម ស្លាប់ហើយ ទើបទៅកើតក្នុងទេវតា បានបរិភោគភោគទិព្វសុធាភោជនហើយ ធ្វើបរិកម្មក្នុងវាយោកសិណ ទើបបានឈានក្នុងទេវលោកនោះ ចំណែកសត្វដទៃអំពីនោះ គឺ ពួកអបាយ ក៏ទៅកើតក្នុង

ទេវលោកបានដោយអំណាចអបរាបរិយវេទនីយកម្ម ពិតមែន ឈ្មោះថា សត្វអ្នកត្រាច់វន្តត់ទៅក្នុងវដ្តសង្សារដែលប្រាសចាកអបរាបរិយវេទនីយកម្ម រមែងមិនមានសូម្បីសត្វពួកនោះ ក៏រមែងបានឈានក្នុងទេវលោកនោះៗ បានដូចគ្នា សូម្បីសត្វទាំងពួង ក៏រមែងកើតក្នុងព្រហ្មលោកបាន ដោយអំណាចឈានដែលខ្លួន( ទៅ ) បានក្នុងទេវលោក ដូច្នេះឯង ។

## កើតសុរិយៈ៧ដួង

ម្យ៉ាងទៀត បន្ទាប់ពីអស់ភ្លៀង កន្លងកាលដ៏យូរអង្វែង សុរិយៈដួងទី ២ ក៏កើតប្រាកដឡើង ពិតហើយ ប្រការនេះព្រះមានព្រះភាគ ក៏បានត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សម័យនោះមានពិត ដូច្នេះជាដើម សត្តសុរិយសូត្របណ្ឌិតគប្បីនាំមកពោលឲ្យពិស្តារចុះ ដូច្នេះ កាលសុរិយៈដួងទី ២ នោះ កើតប្រាកដឡើងហើយ ក៏មិនបានដឹងថា ជាពេលយប់ និងពេលថ្ងៃឡើយ សុរិយៈដួងមួយរះឡើង ដួងមួយលិច លោកមានភាពក្តៅអំពីសុរិយៈមិនបានដាច់រយៈឡើយ និងក្នុងកប្បវិនាសក-សុរិយៈ ( សុរិយៈវិលាយកប្ប ) មិនមានសុរិយទេវបុត្រ ដូចដែលមានក្នុងបកតិសុរិយៈទេ ក្នុងសុរិយៈ ២ យ៉ាងនោះ មានបកតិសុរិយៈនៅប្រព្រឹត្តទៅ ដុំពពកខ្លះ អ័ព្ទខ្លះ នៅមានអណ្តែតនៅក្នុងអាកាស កាលកប្បវិនាសកសុរិយៈប្រព្រឹត្តទៅ ផ្ទៃមេឃប្រាសចាកអ័ព្ទ ដុំពពកថ្លាដូចកញ្ចក់ឆ្លុះមុខ វៀរបញ្ចមហានទីហើយ ទឹកក្នុងទីទាំងឡាយ មានស្ទឹងតូចដ៏សេសជាដើម រីងស្ងួតអស់ ។

តពីនោះទៅទៀត កន្លងកាលដ៏យូរ សុរិយៈដួងទី ៣ ក៏កើតប្រាកដឡើង ព្រោះការកើតប្រាកដឡើងនៃសុរិយៈដួងទី ៣ នោះ សូម្បីបញ្ចមហានទីក៏រីងស្ងួត ។

តពីនោះទៅទៀត កន្លងកាលដ៏យូរ សុរិយៈដួងទី ៤ ក៏កើតប្រាកដឡើង ព្រោះការកើតប្រាកដឡើងនៃសុរិយៈដួងទី ៤ នោះ មហាស្រះទាំង ៧ នេះ គឺ ស្រះសីហបាតនៈ ស្រះហង្សបាតនៈ ស្រះកណ្ណមុណ្ឌកៈ ស្រះរថការ ស្រះអនោតត្តៈ ស្រះឆទ្ទន្ត ស្រះកុណាល ដែលជាប្រភពទឹករបស់បញ្ចមហានទីនៅក្នុងហិមពាន្តក៏រីងស្ងួត ។

តពីនោះទៅទៀត កន្លងកាលដ៏យូរ សុរិយៈដួងទី ៥ ក៏កើតប្រាកដឡើង ព្រោះការកើតឡើងនៃសុរិយៈដួងទី ៥ ទឹកក្នុងមហាសមុទ្រ សូម្បីតែល្មមសើមថ្នាំងអង្គុលីក៏មិនសល់ ស្ងួតទៅអស់ដោយលំដាប់ ។

តពីនោះទៅទៀត កន្លងកាលដ៏យូរ សុរិយៈទី ៦ ក៏កើតប្រាកដឡើង ព្រោះការកើតប្រាកដឡើងនៃសុរិយៈដួងទី ៦ នោះ សកលចក្កវាឡ ក៏កើតជាផ្សែងខ្លួលខ្លាញ់ទៅរហូតដល់អស់ជ័រ( គឺ អាបោធាតុ ) , ផ្សែងរុំចក្កវាឡនេះយ៉ាងណា សូម្បីសែនកោដិចក្រវាឡក៏ដូច្នោះ ។

តពីនោះទៅទៀត កន្លងកាលដ៏យូរ សុរិយៈដួងទី ៧ ក៏កើតប្រាកដឡើង ព្រោះការកើតប្រាកដឡើងនៃសុរិយៈដួងទី ៧ នោះ សកលចក្កវាឡក៏ឆេះសន្ធោសន្ធៅឡើង ព្រមទាំងសែនកោដិចក្រវាឡ សូម្បីកំពូលភ្នំសិនេរុទាំងឡាយ ដែលមានចំនួនច្រើន មានខ្នាតផ្សេងៗ មានកំពូលកម្ពស់ ១០០ យោជន៍ជាដើម ក៏រលាយបាត់ទៅក្នុងអាកាសនោះឯង អណ្តាតភ្លើងនោះឆេះទៅដល់ទេវលោកជាន់ចាតុម្មហារាជិកា ដុតវិមានមាស វិមានកែវ វិមានពេជ្រក្នុងជាន់ចាតុម្មហារាជិកាអស់ហើយ ក៏ឆេះភពតាវត្តិង្សដោយវិធីនោះឯង វាឆេះរហូតដល់ព្រហ្មលោកភូមិបឋមជ្ឈាន ដុតព្រហ្មលោកទាំង ៣ ជាន់ ក្នុងភូមិបឋមជ្ឈាននោះហើយ ដល់ជាន់

អាកស្សរាទើបរលត់ អណ្តាតភ្លើងនោះ រត្តជាសង្ខារសូម្បីប្រមាណត្រឹមមួយអណូ នៅមានសល់ត្រឹមណា ក៏មិនព្រមរលត់ត្រឹមនោះ លុះគ្រាអស់សង្ខារទាំងពួងទើបរលត់ទៅ មិនឲ្យអ្វីនៅសល់សូម្បីត្រឹមតែផេះ ដូចអណ្តាតភ្លើងដែលឆេះទឹកដោះថ្លា និងប្រេងដូច្នោះ អាកាសខាងលើ និងអាកាសខាងក្រោម ក៏កើតការងងឹតឈឹងដូចគ្នា ។

## ចន្លោះកាលដែលសាបសូន្យដល់ការកើត

កន្លងមកអស់កាលដ៏យូរ មហាភ្លៀងតាំងឡើង ដំបូងញុំាងភ្លៀងតិចៗ ឲ្យធ្លាក់ចុះមកហើយ ញុំាងភ្លៀងឲ្យធ្លាក់ដោយដំណក់ទឹកធំឡើងប៉ុនដើមឈូក ប៉ុនឈើប្រត់ ប៉ុនអង្រែ និងប៉ុនដើមត្នោតជាដើមដោយលំដាប់ រហូតញុំាងទីដែលភ្លើងឆេះទាំងពួង ក្នុងសែនកោដិចក្កវាឡឲ្យពេញហើយទើបបាត់ទៅ ខ្យល់ទ្រអន្ទង់ទឹកពីខាងក្រោម និងខាងទទឹង គឺ បក់ទៅជុំវិញទឹក មិនឲ្យទឹកខ្ចាយទៅ ធ្វើរហូតឲ្យទឹកនោះខាប់ជាដុំ ទឹកដុំនោះមូលដូចគ្នានឹងដំណក់ទឹកលើស្លឹកឈូក ។

បើមានពាក្យសួរថា ខ្យល់ធ្វើគំនរទឹកធំដូច្នោះ ឲ្យជាដុំបានដូចម្តេច ? ពាក្យឆ្លើយគប្បីមានថា ធ្វើបានដោយទឹកបើកចន្លោះឲ្យ ពិតមែន ទឹកនោះរមែងឲ្យចន្លោះដល់ខ្យល់នោះ ក្នុងទីនោះៗ( គឺឲ្យខ្យល់ជ្រែកចូលទៅ ធ្វើឲ្យខាប់បាន )ទឹកនោះត្រូវខ្យល់ប៉ាន់ធ្វើឲ្យជាដុំយ៉ាងនោះ ក៏ស្រកចុះជាលំដាប់ កាលទឹកស្រកចុះរឿយៗព្រហ្មលោកក៏កើតប្រាកដឡើងក្នុងកន្លែងដែលធ្លាប់ជាព្រហ្មលោក និង ទេវលោកទាំងឡាយក៏កើតប្រាកដឡើងក្នុងកន្លែងដែលធ្លាប់ជាកាមាវចរទេវលោក ៤ ជាន់ខាងលើ តែកាលស្រុតចុះមកដល់កន្លែងដែលធ្លាប់ជាផែនដីអំពីមុន ខ្យល់ខ្លាំងក៏កើត

ឡើង ខ្យល់នោះទ្រទឹកនោះទុក ធ្វើមិនឲ្យហៀរហូរទៅបាន ដូចទឹកដែលនៅក្នុងធម្មក្រក ដែលគេបិទប្រហោង គឺរន្ធប្រហោងអាកាសទុកដូច្នោះ ទឹកមានរសផ្អែមដល់នូវការរីងហួតទៅ ធ្វើឲ្យកើតជាផែនដី ជាផ្ទាំងឡើង ផែនដីនោះជាវត្ថុដែលដល់ព្រមដោយពណ៌ និងដល់ព្រមដោយក្លិន និងរស ដូចបាយបាយាសដែលដាំមិនប្រើទឹក ( គឺ ដាំដោយទឹកដោះដូច្នោះ ) ។

## អាភស្សរព្រហ្មចុះមកកើត និងស៊ីក្រមដីជាអាហារ

ក្នុងកាលនោះ សត្វទាំងឡាយអ្នកកើតពីដំបូង ក្នុងអាភស្សរព្រហលោក ចុតិចាកអាភស្សរព្រហ្មលោកនោះ ព្រោះអស់អាយុខ្លះ ព្រោះអស់បុណ្យខ្លះ មកកើតក្នុងលោកនេះ ជាឱបបាតិកៈ ព្រហ្មសត្វពួកនោះ ជាអ្នកមានពន្លឺក្នុងខ្លួន ត្រាច់រន្ធាត់ទៅក្នុងផ្ទៃមេឃបាន( ហោះបាន ) អ្នកទាំងឡាយនោះបានលិទ្ធភ្លក្សផែនដីនោះ ក៏កើតសេចក្ដីត្រេកត្រអាល យកដៃពូតជាពុំនូតៗស៊ី ដោយន័យដូចពោលទុកក្នុងអគ្គញ្ញសូត្រនោះឯង កន្លងកាលដ៏យូរមក ពន្លឺក្នុងខ្លួនរបស់គេទាំងឡាយក៏អន្តរធានទៅ ភាពងងឹតក៏ប្រាកដឡើង មនុស្សទាំងឡាយនោះបានឃើញសភាពងងឹត ក៏ខ្លាចតក់ស្លុត ។

## កើតព្រះអាទិត្យ

តពីនោះ ដួងសុរិយៈទំហំ ៥០ យោជន៍ ក៏ញុំាងការភ័យខ្លាចឲ្យបាត់ ហើយញុំាងភាពកក់ក្ដៅឲ្យកើតដល់សត្វពួកនោះ បានកើតប្រាកដឡើង មនុស្សទាំងឡាយនោះឃើញដួងសុរិយៈនោះហើយ ក៏ស្ទុះស្ទាត្រេកអរថា ពួកយើងត្រឡប់បានពន្លឺភ្លឺស្វាងវិញហើយ នាំគ្នាដាក់ឈ្មោះដួងពន្លឺនោះថា សុរិយៈនោះឯង ព្រោះទាក់ទង

នឹងពាក្យដែលគេនាំគ្នាពោលថា ដួងពន្លឺដែលញុំាងការភ័យខ្លាចរបស់ពួកយើង អ្នកខ្លាចហើយឲ្យបាត់ទៅ ញុំាងភាពកក់ក្តៅឲ្យកើតប្រាកដដល់ពួកយើង រះឡើងមក ព្រោះដូច្នោះ ដួងពន្លឺនោះចូរមានឈ្មោះថា **សុរិយៈ** គឺ អ្នករះឡើងមកញុំាងភាពក្លាហានឲ្យកើតឡើងចុះ ដូច្នេះ ។

## កើតដួងព្រះចន្ទ

តមក កាលសុរិយៈបំភ្លឺក្នុងពេលថ្ងៃ ហើយអស្តង្គតទៅ មនុស្សទាំងឡាយក៏ទួញយំថា ពួកយើងបានពន្លឺភ្លឺស្វាងដួងនោះ ពន្លឺភ្លឺស្វាងដួងនោះរបស់យើងក៏បាត់ទៅហើយ ក៏កើតការភ័យខ្លាចឡើងមកទៀត ពួកគេបានតែគិតរំពឹងគ្នាទៅថា នឹងជាការល្អណាស់ បើពួកយើងបានពន្លឺមួយដួងទៀត កាលនោះដួងព្រះចន្ទទំហំ ៥០ យោជន៍ខ្វះមួយ ហាក់ដូចជាដឹងទឹកចិត្តរបស់ពួកគេ ក៏កើតប្រាកដឡើង ពួកគេបានឃើញដួងព្រះចន្ទនោះ រីតតែរីករាយត្រេកអរឡើង នាំគ្នាតាំងឈ្មោះដួងព្រះចន្ទនោះថា **ចន្ទ** នោះឯង ព្រោះទាក់ទងដោយពាក្យដែលពួកគេពោលថា ដួងពន្លឺនោះហាក់ដូចជាដឹងឆន្ទៈ គឺ បំណងប្រាថ្នារបស់ពួកយើង កើតឡើងមក ព្រោះដូច្នោះ ដួងពន្លឺនោះចូរឈ្មោះ **ចន្ទ** គឺ អ្នកហាក់ដូចជាដឹងឆន្ទៈរបស់សត្វ រះឡើង ដូច្នេះ ។

## កើតដួងនក្ខត្តឫក្ស យប់ ថ្ងៃ... ទ្វីប

កាលចន្ទសុរិយៈកើតប្រាកដយ៉ាងនោះហើយ ដួងផ្កាយនក្ខត្តឫក្សទាំងឡាយក៏កើតប្រាកដឡើង ចាប់ផ្តើមតាំងអំពីនោះ យប់ ថ្ងៃ ក៏ប្រាកដឡើង ព្រមទាំង ខែ កន្លះខែ រដូវ ឆ្នាំ ក៏នាំគ្នាដឹងឡើងជាលំដាប់ ។

ម្យ៉ាងទៀត ក្នុងថ្ងៃដែលចន្ទសុរិយៈកើតប្រាកដឡើងនោះឯង ភ្នំសិនេរុ ភ្នំចក្កវាឡ និងភ្នំហិមពាន្តក៏កើតប្រាកដឡើង ឯភ្នំទាំង ៣ នោះ កើតប្រាកដឡើងក្នុងថ្ងៃពេញបូណ៌មី ខែផល្គុន ( ខែ ៤ ) មិនមុនមិនក្រោយគ្នាឡើយ សួរថា ប្រាកដយ៉ាងដូចម្តេច ? ឆ្លើយថា កាលថ្លៅត្រូវដាំ កាលពុះហើយប៉ុណ្ណោះ ផ្ទៃបាយកន្លែងខ្លះក៏ប៉ោងឡើង កន្លែងខ្លះក៏ស្រុតចុះ កន្លែងខ្លះក៏រាបស្មើយ៉ាងណា វត្ថុពួកនោះ ត្រង់ទីដែលខ្ពស់ឡើងក៏ជាភ្នំ កន្លែងដែលស្រុតចុះក៏ជាសមុទ្រ ដែលរាបស្មើក៏ជាទ្វីប គឺ ផែនដីធំ ដូច្នោះដូចគ្នា ។

## អាហារប្រណីតសាបសូន្យ អាហារគ្រោតគ្រាតកើតឡើង

កន្លងកាលយូរមក កាលសត្វពួកនោះស៊ីផែនដី ពួកខ្លះមានពណ៌សម្បុរស្អាត ពួកខ្លះ ក៏មានពណ៌សម្បុរអាក្រក់ទៅតាមលំដាប់ ក្នុងពីរពួកនោះ ពួកមានពណ៌សម្បុរស្អាត មើលងាយពួកមានពណ៌សម្បុរអាក្រក់ ព្រោះការមើលងាយគ្នាជាបច្ច័យ រសផែនដីនោះក៏វិនាសទៅ ក្រមដីកើតប្រាកដឡើងជំនួស តមកដោយន័យ ( ការមើលងាយគ្នា )នោះឯង សូម្បីក្រមដីនោះក៏វិនាសទៅទៀត បទាលតា( វល្លិដី ) ក៏កើត ប្រាកដឡើងជំនួស តាមន័យដូចគ្នានោះ សូម្បីវល្លិដីក៏វិនាសទៅទៀតដែរ ស្រូវសាលីដែលមិនត្រូវដាំដោយភ្លើងឱស ជាគ្រាប់អង្ករមិនមានកន្ទក់ មិនមានអង្កាម មានក្លិនក្រអូបក៏កើតប្រាកដឡើងជំនួស តពីនោះ ភាជនៈទាំងឡាយក៏កើតឡើងដល់សត្វទាំងឡាយនោះ ពួកគេដាក់ស្រូវសាលីក្នុងភាជនៈហើយ តាំងទុកលើជុំថ្ម អណ្តាតភ្លើងឆេះឡើងដាំស្រូវសាលីនោះឯង ហើយវាក៏ជាបាយឆ្ងាញ់ ដូចផ្កាម្លិះក្រពុំ កិច្ចដោយសម្ល ឬ ម្ហូបក៏ដោយ មិនមានដល់បាយនោះទេ សត្វ

ទាំងឡាយប្រាថ្នានឹងស៊ីបាយមានរសយ៉ាងណាៗ វាក៏ជាបាយមានរសយ៉ាងនោះៗ ឯង ។

## កើតមូត្រ ករីស ទ្វារ និងមេថុន

កាលសត្វទាំងនោះ ស៊ីអាហារគ្រោតគ្រាតនោះចូលទៅ តពីនោះ មូត្រ និង ករីសៈក៏កើតមក ពេលនោះ មុខដំបៅ( ទ្វារទាំង ៩ ) ក៏ផ្លាយ ដើម្បីប្រយោជន៍ ដល់ការបន្ទោបង់មូត្រ និងករីសៈនោះរបស់សត្វទាំងនោះ ភាពជាប្រុសក៏កើត ប្រាកដឡើងដល់បុរស ភាពជាស្រីក៏កើតប្រាកដឡើងដល់ស្ត្រីដែរ ក្នុងបុរស និង ស្ត្រីនោះនិយាយគ្នា ស្ត្រីសម្លឹងមើលបុរស និងបុរសក៏សម្លឹងមើលស្រីហួសវេលា គឺយូរពេកទៅ ព្រោះការសម្លឹងមើលគ្នានោះជាបច្ច័យ ភាពក្តៅរោលរាលដោយកាម ក៏កើតឡើងដល់សត្វទាំងនោះ តពីនោះ ក៏នាំគ្នាសេពមេថុនធម្ម ព្រោះការសេព អសទ្ធម្មជាបច្ច័យ ពួកគេ ត្រូវពួកអ្នកប្រាជ្ញនិន្ទាតិះដៀល ក៏ធ្វើផ្ទះឡើងដើម្បីនឹងបិទ បាំងអសទ្ធម្មនោះ ។

## កើតអធិដ្ឋាទាន

សត្វទាំងនោះនៅគ្រប់គ្រងផ្ទះទៅ បានត្រាប់តាមសត្វមានជាតិខ្ជិលច្រអូស ម្នាក់ ទើបធ្វើសន្និធិ គឺការសន្សំស្រូវទុកដោយលំដាប់ តាំងពីពេលនោះ ទាំងកន្ទក់ ទាំងអង្កាមក៏កើតស្រោបគ្រាប់អង្ករ ស្ទូម្បីកន្លែងដែលត្រូវច្រូតហើយ ក៏មិនដុះ ឡើងវិញ ពួកគេក៏ប្រជុំគ្នាញត្តិរប្រាប់គ្នាថា លោកអ្នកដ៏ចម្រើនទាំងឡាយ ធម៌ លាមកកើតប្រាកដឡើងក្នុងពួកសត្វហើយហ្ន៎ ពួកយើងពីពេលមុន ជាសត្វមាន មនោមយៈ គឺ សម្រេចដោយចិត្ត ដូច្នេះជាដើម ពាក្យទាំងពួងគប្បីនាំមកពោលឲ្យ

ពិស្តារតាមន័យដូចពោលក្នុងអគ្គញ្ញសូត្រចុះ តពីនោះ ពួកគេបានបោះព្រំដែនស្រែគ្នា បន្ទាប់មក សត្វណាមួយទៅកាន់យកស្រូវចំណែករបស់អ្នកដទៃ ដែលមានម្ចាស់របស់គេមិនបានឲ្យ ពួកគេប្រមានសត្វពួកនោះពីរដង ( បើមិនស្តាប់ ) ក្នុងលើកទី ៣ ទើបប្រហារដោយអាវុធ មានបាតដៃ ដុំដី និងដំបងជាដើម ។

## ដំបូងកើតព្រះរាជា

កាលលួចទ្រព្យហើយ ការតិះដៀលទោស ការនិយាយកុហក និងការចាប់ដំបង( ជាអាវុធ ) កើតឡើងយ៉ាងនោះហើយ ពួកគេទើបនាំគ្នាប្រជុំគិតថា ប្រសិនបើដូច្នេះយើងទាំងឡាយ គប្បីសន្មតសត្វម្នាក់ឡើងក្នុងពួកយើងទាំងឡាយ សត្វណាគួរតិះដៀល ត្រូវតិះដៀល គួរដាក់ទោស ត្រូវដាក់ទោស គួរបណ្តេញ ត្រូវបណ្តេញ ដោយត្រឹមត្រូវ , ម្យ៉ាងទៀត យើងទាំងឡាយនឹងថែមឲ្យនូវចំណែកស្រូវសាលីដល់សត្វនោះ ដូច្នេះ បើក្នុងសត្វទាំងឡាយដែលធ្វើសេចក្តីព្រមព្រៀងគ្នាយ៉ាងនេះ ព្រះមានព្រះភាគអង្គនេះហើយ ជាព្រះពោធិសត្វក្នុងកប្បនេះមុនគេក្នុងសម័យនោះ ទ្រង់ជាអ្នកមានរូបស្អាតជាងអ្នកណាទាំងអស់ ជាទីគាប់ភ្នែកក្រៃលែងជាងគេទាំងអស់ និងជាមហេសក្ខ គឺអ្នកដែលមនុស្សទាំងឡាយលើកតម្កើងថា ជាអ្នកដ៏ក្រៃលែងជាងគេទាំងអស់ក្នុងបណ្តាសត្វទាំងឡាយនោះ ជាអ្នកដល់ព្រមដោយពុទ្ធិ( បញ្ញា ) អាចនឹងធ្វើនិគ្គហៈ និងបគ្គហៈ ( គឺមនុស្សក្នុងការគ្រប់គ្រងបាន ) គេទាំងឡាយទើបចូលទៅរកលោកអង្វរឲ្យលោកទទួលតំណែង ហើយសន្មតឡើង ព្រះពោធិសត្វនោះប្រាកដដោយព្រះនាម ៣ គឺ ព្រះនាមថា **ព្រះបាទមហាសម្មត** ជាអ្នកដែលជនទាំងឡាយនោះសម្មតិឡើង ព្រះនាមថា **ក្សត្រ** ព្រោះ

ទ្រង់ជាម្ចាស់ជាធំនៃក្សត្រទាំងឡាយ ព្រះនាមថា **រាជា** ព្រោះទ្រង់ញុំាងអ្នកដទៃឲ្យត្រេកអរដោយធម៌ស្មោះស្មើគ្នា ក៏តំណែងណាៗ រាប់ថាជាតំណែងអច្ឆរិយៈក្នុងព្រះពោធិសត្វនោះ ទ្រង់ជាអាទិបុរស( មនុស្សដំបូង ) ក្នុងតំណែងនោះឯង កាលវង្សក្សត្រ លើកព្រះពោធិសត្វជាដើម ផ្តើមតាំងឡើងយ៉ាងនោះហើយ សូម្បីវណ្ណៈទាំងឡាយ មានព្រាហ្មណ៍ជាដើម ក៏តាំងឡើងជាលំដាប់ ។

## កំណត់រយៈកាលនៃអសង្ខេយ្យកប្ប ក្នុងតេជោសំវដ្តៈ

ក្នុងកប្ប ៤ នោះ រយៈកាលបន្ទាប់ពីមហាភ្លៀងវិលាយកប្បទៅ រហូតដល់អណ្តាតភ្លើងរលត់អស់ ជាអសង្ខេយ្យមួយ ហៅថា **សំវដ្តកប្ប** បន្ទាប់ពីអណ្តាតភ្លើងបំផ្លាញកប្បរលត់ទៅអស់រហូតដល់ការកើតមហាភ្លៀងបង្កើតលោក ដែលញុំាងសែនកោដិចក្កវាឡឲ្យពេញដោយទឹក នេះជាអសង្ខេយ្យទី ២ ហៅថា **សំវដ្តដ្ឋាយីកប្ប** បន្ទាប់ពីមហាភ្លៀងបង្កើតលោក រហូតដល់ការកើតប្រាកដឡើងនៃចន្ទ និងសុរិយៈ នេះជាអសង្ខេយ្យទី ៣ ហៅថា **វិវដ្តកប្ប** បន្ទាប់ពីការកើតប្រាកដឡើងនៃព្រះចន្ទ និងសុរិយៈ រហូតកើតមហាភ្លៀងវិលាយកប្បទៀត នេះជាអសង្ខេយ្យទី ៤ ហៅថា **វិវដ្តដ្ឋាយីកប្ប** រួម ៤ អសង្ខេយ្យនេះ បានមហាកប្បមួយ ។ ការវិនាសដោយភ្លើង និងការតាំងឡើងថ្មីនៃពុទ្ធខេត្ត បណ្ឌិតគប្បីជ្រាបដោយន័យ ដូចបានពោលមកនេះ ជាលំដាប់ដំបូង ។

## អាបោសំវដ្តៈ

ចំណែកក្នុងសម័យដែលកប្បវិនាសដោយទឹក ( ពាក្យពណ៌នាទាំងពួង ) បណ្ឌិត គប្បីពោលដោយពិស្តារតាមន័យដែលពោលក្នុងន័យមុន គឺ ( ក្នុងពេល

តេជោសំវដ្ដៈ )ថា ដំបូងមហាភ្លៀងរំលាយកប្បតាំងឡើង ដូច្នេះជាដើមនោះចុះ តែសេចក្ដីតទៅនេះជាការប្លែកគ្នា មហាភ្លៀងទឹកក្រូត ដែលជាភ្លៀងរំលាយកប្ប ក្នុងអាបោសំវដ្ដកប្បនេះ តាំងឡើងប្រៀបដូចសុរិយៈដួងទី ២ ក្នុងតេជោសំវដ្ដៈ នោះ មហាភ្លៀងទឹកក្រូតនោះ ពីដំបូងក៏ធ្លាក់មកជារ៉ុយៗ រួចក៏ធ្លាក់ជាដំណក់ទឹកធំឡើងជាលំដាប់ រហូតញ៉ាំងសែនកោដិចក្កវាឡឲ្យពេញ វត្ថុទាំងពួងមានផែនដី និងភ្នំជាដើមដែលទឹកក្រូតធ្លាក់ត្រូវហើយ រមែងរលាយទៅអស់ ទឹកនោះខ្យល់ទ្រជុំវិញ ( ខ្យល់ទ្រទឹក ) ចាប់ពីផែនដីឡើងទៅរហូតដល់ព្រហ្មលោកជាន់ទុតិយជ្ឈានភូមិ វាញ៉ាំងព្រហ្មលោកទាំង ៣ ជាន់ ក្នុងទុតិយជ្ឈានភូមិនោះឲ្យរលាយហើយ ឡើងទៅឈប់ត្រឹមជាន់សុភកិណ្ហា , ទឹករំលាយកប្បនោះ វត្ថុដែលរាប់ថាជាសង្ខារសូម្បីត្រឹមមួយអណូ នៅមានសល់ដរាបណា ក៏នៅមិនរំងាប់ដរាបនោះ គ្របសង្កត់ គឺរំលាយវត្ថុដែលរាប់ថា សង្ខារទាំងពួងដែលត្រូវទឹកហើយ ឲ្យរលាយទៅអស់ហើយ ទើបរំងាប់ គឺដល់នូវការរីងហួតទៅដោយឆាប់រហ័ស អាកាសខាងលើ និងអាកាសខាងក្រោម ក៏ងងឹតស្លុបដូចគ្នា តទៅនេះ ពាក្យដែលនៅសល់ទាំងពួង ក៏ដូចដែលបានពោលមកហើយក្នុងតេជោសំវដ្ដៈ គ្រាន់តែក្នុងអាបោសំវដ្ដៈនេះ( ពេលកើតលោកថ្មី ) លោករាប់យកអាភស្សរព្រហ្មជាដើម កើតប្រាកដឡើង ព្រោះអាភស្សរព្រហ្ម ក៏ទឹកក្រូតរំលាយដែរ និងសត្វទាំងឡាយចុតិអំពីសុភកិណ្ហា ចុះមកកើតក្នុងទីផ្សេងៗ មានកន្លែងដែលធ្លាប់ជាព្រហ្មលោកជាន់អាភស្សរៈជាដើម ។

## កំណត់រយៈកាលនៃអសង្ខេយ្យកប្ប ក្នុងអាបោសំវដ្ដៈ

ក្នុងកប្ប ៤ នោះ ( រយៈកាល )អំពីការកើតមហាភ្លៀងរំលាយកប្បទៅរហូត

ដល់ទឹកក្រុតរំលាយកប្បដាច់ខ្សែបាត់ទៅ នេះជាអសង្ខេយ្យមួយ បន្ទាប់ពីទឹកក្រុតរីងអស់ទៅ រហូតដល់កើតមហាភ្លៀងបង្កើតលោក នេះជាអសង្ខេយ្យទី ២ បន្ទាប់ពីការកើតមហាភ្លៀងបង្កើតលោក រហូតដល់ការកើតឡើងប្រាកដនៃព្រះចន្ទ និងសុរិយៈ នេះជាអសង្ខេយ្យទី ៣ តាំងអំពីការកើតប្រាកដឡើងនៃព្រះចន្ទ និងសុរិយៈទៅរហូតដល់កើតមហាភ្លៀងរំលាយកប្បទៀត នេះជាអសង្ខេយ្យទី ៤ រួម ៤ អសង្ខេយ្យនេះ ជាមហាកប្ប ១ ។

ការវិនាសដោយទឹក និងការតាំងឡើងថ្មីនៃពុទ្ធខេត្ត បណ្ឌិតគប្បីជ្រាបតាមន័យដូចដែលពោលមកនេះចុះ ។

## វាយោសំវដ្ដ:

ក្នុងសម័យដែលកប្បវិនាសដោយខ្យល់ ពាក្យពណ៌នាទាំងពួង បណ្ឌិតគប្បីពោលឲ្យពិស្តារតាមន័យដែលបានពោលមកហើយក្នុងពេលមុន ( ក្នុងតេជោសំវដ្ដៈ ) ថា ដំបូងមហាភ្លៀងរំលាយកប្បតាំងឡើង ដូច្នេះជាដើមនោះចុះ តែសេចក្តីតទៅនេះជាការប្លែកគ្នា ខ្យល់តាំងឡើងដើម្បីរំលាយកប្ប ក្នុងវាយោសំវដ្ដនេះ ប្រៀបបាននឹងសុរិយៈដួងទី ២ ក្នុងតេជោសំវដ្ដៈនោះ ខ្យល់នោះ ដំបូងក្ជួចយកធូលីគ្រោតគ្រាតឡើងទៅ តពីនោះ ក៏ក្ជួចយកធូលីល្អិតដែលជាប់ផែនដី... ខ្សាច់ល្អិត... ខ្សាច់គ្រោតគ្រាត... វត្ថុដែលរសាត់ឡើងទៅ មានថ្មគ្រួសជាដើម ដូចនេះ រហូតដល់ដុំថ្មប៉ុនផ្ទះកំពូល និងដើមឈើធំ ដែលដុះនៅក្នុងទីគោកឡើងទៅ វត្ថុទាំងនោះឡើងអំពីដីទៅកាន់ផ្ទៃមេឃ ហើយមិនធ្លាក់ចុះមកវិញទេ វាបែកល្អិតខ្ទេចទៅក្នុងផ្ទៃមេឃនោះឯងលំដាប់នោះ ខ្យល់តាំងឡើងក្រោមមហាប្រឹថពី ត្រឡប់ផែនដីខាងក្រោមឡើងលើ

ហើយបន្សាត់ទៅក្នុងអាកាស ដែលចំណែកមួយៗ នៃផែនដី ១០០ យោជន៍ក៏មាន ២០០ យោជន៍ក៏មាន ៣.០០០-៤.០០០-៥.០០០ យោជន៍ក៏មាន បែកចេញហើយ ត្រូវកម្លាំងខ្យល់បន្សាត់ឡើងទៅ បែកល្អិតខ្ទេចទៅក្នុងអាកាសដូចគ្នា សូម្បីចក្កវាឡ ភ្នំសិនេរុ ខ្យល់លើកឡើងហើយបន្សាត់ទៅក្នុងអាកាស វាប៉ះខ្ទប់គ្នានឹងបែកខ្ទេចទៅ ខ្យល់ដែលធ្វើវិមានរបស់ភុម្មដ្ឋកទេវតាទាំងឡាយ និងវិមានរបស់អាកាសដ្ឋកទេវតាទាំងឡាយឲ្យវិនាសទៅដោយឧបាយ គឺវិធីដូចគ្នានោះ ទៅធ្វើកាមាវចរទេវលោក ៦ ជាន់ឲ្យវិនាសហើយ ធ្វើសែនកោដិចក្កវាឡឲ្យវិនាសទៅ ភ្នំចក្កវាឡទាំងឡាយ និង ភ្នំចក្កវាឡ ភ្នំហិមពាន្ត និងភ្នំហិមពាន្ត ភ្នំសិនេរុ និងភ្នំសិនេរុទាំងឡាយ សែនកោដិចក្រវាឡនោះ ប៉ះទង្គិចគ្នានឹងគ្នាបែកខ្ទេចខ្ទីវិនាសទៅ ខ្យល់ចាប់ពីផែនដីឡើងទៅដល់ព្រហ្មលោកតតិយជ្ឈានភូមិ ញុំាងព្រហ្មលោក ៣ ជាន់ ក្នុងតតិយជ្ឈានភូមិនោះឲ្យវិនាសហើយ ទៅស្ងប់ត្រឹមព្រហ្មលោកជាន់វេហប្ផលា ខ្យល់នោះធ្វើវត្ថុជាសង្ខារទាំងពួងឲ្យវិនាសទៅយ៉ាងនេះហើយ ខ្លួនឯងក៏វិនាសទៅដែរ អាកាសខាងលើ និងអាកាសខាងក្រោម ក៏ងងឹតស្លុបដូចគ្នា តពីនេះ ពាក្យដ៏សេសទាំងពួងក៏ដូចដែលបានពោលហើយ ក្នុងតេជោសំវដ្ដៈ គ្រាន់តែក្នុងវាយោសំវដ្ដៈនេះ ពេលកើតលោកថ្មី លោករាប់សុភកិណ្ហព្រហ្មជាដើមកើតប្រាកដឡើង ( ព្រោះសុភកិណ្ហព្រហ្មក៏ត្រូវខ្យល់ធ្វើឲ្យវិនាសទៅដែរ ) និងសត្វទាំងឡាយចុតិពីជាន់វេហប្ផលាចុះមកកើតក្នុងកន្លែងផ្សេងៗ មានកន្លែងដែលធ្លាប់ជាព្រហ្មលោកថ្នាក់សុភកិណ្ហជាដើមប៉ុណ្ណោះ ។

## កំណត់រយៈកាលនៃអសង្ខេយ្យកប្បក្នុងវាយោសំវដ្ដៈ

ក្នុងកប្ប ៤ នោះ រយៈកាលអំពីការកើតមហាភ្លៀងវិលាយកប្បទៅរហូតដល់ខ្យល់វិលាយកប្បស្ងប់ ជាអសង្ខេយ្យមួយ បន្ទាប់ពីខ្យល់ស្ងប់ទៅ រហូតដល់កើតមហាភ្លៀងបង្កើតលោក នេះជាអសង្ខេយ្យទី ២ បន្ទាប់ពីការកើតមហាភ្លៀងបង្កើតលោក ទៅរហូតដល់ការកើតប្រាកដឡើងនៃព្រះចន្ទ និងសុរិយៈ នេះជាអសង្ខេយ្យទី ៣ បន្ទាប់ពីការកើតឡើងប្រាកដនៃព្រះចន្ទ និងសុរិយៈ រហូតដល់កើតមហាភ្លៀងវិលាយកប្បទៀត នេះជាអសង្ខេយ្យទី ៤ , រួម ៤ អសង្ខេយ្យនេះ បានមហាកប្ប ១ ។

ការវិនាសដោយខ្យល់ និងការតាំងឡើងថ្មីនៃពុទ្ធខេត្ត បណ្ឌិតគប្បីជ្រាបតាមន័យដូចពោលមកហើយដូច្នេះ ។

## លោកវិនាសដោយអកុសលមូលជាហេតុ

សួរថា លោកវិនាសទៅយ៉ាងនោះ ព្រោះអ្វីជាហេតុ ? ឆ្លើយថា ព្រោះអកុសលមូលជាហេតុ ពិតហើយ កាលអកុសលមូលទាំងឡាយក្រាស់ឡើង លោកទើបវិនាសទៅយ៉ាងនោះ ឯលោកនោះ កាលរាគៈក្រាស់ជាងអកុសលដទៃ រមែងវិនាសដោយភ្លើង កាលទោសៈក្រាស់ជាង រមែងវិនាសដោយទឹក តែអាចារ្យពួកខ្លះពោលថា កាលទោសៈក្រាស់ជាង រមែងវិនាសដោយភ្លើង កាលរាគៈក្រាស់ជាងរមែងវិនាសដោយទឹក កាលមោហៈក្រាសជាង រមែងវិនាសដោយខ្យល់ និងកាលវិនាសយ៉ាងនេះសោត វាវិនាសដោយភ្លើងយ៉ាងនេះ ៧ វារៈ ជាប់តគ្នាទៅក្នុងវារៈទី ៨ ទើបវិនាសដោយទឹក ( ម្ដង ) វិនាសដោយភ្លើង ៧ វារៈ ក្នុងវារៈទី

៨ វិនាសដោយទឹកទៀត... ដោយន័យដូច្នេះ លោកកាលវិនាសយ៉ាងនោះ វិនាសដោយទឹក ៧ ដង គ្រប់វារៈទី ៨ ហើយ វិនាសដោយភ្លើងថែម ៧ វារៈទៀត ដោយកាលប៉ុណ្ណេះ ក៏ត្រូវកន្លងទៅដល់ ៦៣ កប្ប , ក្នុងវាង ៦៣ កប្ប នោះ វារៈដែលត្រូវវិនាសដោយខ្យល់ទើបមានម្ដង ហើយទើបបានឱកាសទម្លាយដល់ពួកសុភកិណ្ហព្រហ្ម ដែលមានកំណត់អាយុ ៦៤ កប្បពេញ , ញ៉ាំងលោកឲ្យវិនាសបាន ។

## អធិប្បាយ ចាលីដែលសម្ដែងអាការរឭក

ឯភិក្ខុអ្នករឭកបានអស់កប្ប សូម្បីការរឭកដល់បុព្វេនិវាសក្នុងកប្បពួកនោះ រមែងរឭកបានច្រើនសំវដ្តកប្បក៏មាន ច្រើនវិវដ្តកប្បក៏មាន ច្រើនសំវដ្តវិវដ្តកប្ប ក៏មាន រឭកបានដោយអាការដូចម្ដេច ? រឭកដោយព្រះបាលីថា **អមុត្រាសឹ** ជាអាទិ ។

ក្នុងបាទទាំងនោះ ពាក្យថា **អមុត្រាសឹ**-ក្នុងទីនោះ យើងបានកើតជា...ហើយ មានសេចក្ដីថា ក្នុងសំវដ្តកប្បនោះ ឬថា ក្នុងភពនោះ ឬថា ក្នុងកំណើត... ក្នុងគតិ ... ក្នុងវិញ្ញាណដ្ឋិតិ... ក្នុងសត្តាវាស... ក្នុងសត្តនិកាយនោះ ខ្លួនយើងបានកើតជា... ហើយ, ពាក្យថា **ឯវំនាមោ**-មានឈ្មោះយ៉ាងនេះ គឺឈ្មោះតិស្សៈ ឬឈ្មោះបុស្សៈជាដើម, ពាក្យថា **ឯវំគោត្តោ**-មានគោត្រយ៉ាងនេះ គឺមានគោត្រកច្ចាយនៈ ឬគោត្រកស្សបៈជាដើម ពីរពាក្យនេះត្រាស់ដោយជាការរឭកដល់ឈ្មោះ និងគោត្ររបស់ខ្លួន ក្នុងអតីតភពនៃភិក្ខុនោះ តែថាលោកជាអ្នកប្រាថ្នានឹងរឭកដល់ការដល់ព្រមនៃពណ៌សម្បត្តិ ជាអ្នកចិញ្ចឹមជីវិតយ៉ាងអន់ថយ ឬ យ៉ាងប្រណីតក្ដី ជាអ្នកច្រើនទៅដោយសេចក្ដីសុខ ឬសេចក្ដីទុក្ខក្ដី ភាពជាអ្នកមានអាយុខ្លី ឬអាយុវែងក្ដី របស់

ខ្ទួនក្នុងកាលនោះ លោកក៏រមែងរឭកដល់ការៈនោះបានដោយពិត ព្រោះហេតុនោះ ទើបត្រាស់តទៅថា **ឯវំវណ្ណោ**-មានពណ៌សម្បុរយ៉ាងនេះ ។ ល ។ **ឯវមាយុបរិយន្តោ**-មានកំណត់អាយុយ៉ាងនេះ ។

ក្នុងបាទទាំងនោះ ពាក្យថា **ឯវំវណ្ណោ**-មានពណ៌សម្បុរយ៉ាងនេះ គឺជាមនុស្សស្រ ឬជាមនុស្សខ្មៅជាដើម, ពាក្យថា **ឯវមាហារោ**-មានអាហារយ៉ាងនេះ គឺបរិភោគបាយនៃស្រូវសាលី ដែលតាក់តែងដោយមំសៈ ឬបរិភោគផ្លៃឈើ ដែលប្រព្រឹត្តទៅ គឺដែលមាននៅក្នុងទីនោះជាដើម , ពាក្យថា **ឯវំ សុខទុក្ខបដិសំវេទី**-សោយសុខទុក្ខយ៉ាងនេះ គឺសោយសុខ និងទុក្ខដែលប្រព្រឹត្តទៅផ្លូវកាយ និងផ្លូវចិត្ត ឬមានប្រភេទផ្សេងៗ ដូចជាសាមិស និងនិរាមិស ដោយអនេកប្បការ ពាក្យថា **ឯវមាយុបរិយន្តោ**-មានកំណត់អាយុយ៉ាងនេះ គឺមានកំណត់អាយុប្រមាណ ១០០ ឆ្នាំ ឬថា មានកំណត់អាយុ ៨៤.០០០ កប្ប យ៉ាងនេះជាដើម , សេចក្តីថា **សោ តតោ ចុតោ អមុត្រ ឧទបាទឹ** ( យើងនោះចុតិចាកទីនោះហើយ កើតក្នុងទីនោះ ) មានសេចក្តីថា ម្យ៉ាងទៀត យើងចុតិចាកភព ឬចាកកំណើត ចាកគតិ ចាកវិញ្ញាណដ្ឋិតិ ចាកសត្តាវាស ចាកសត្តនិកាយហើយ ទៅកើតក្នុងភព ឬក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ ក្នុងសត្តាវាស ក្នុងសត្តនិកាយ ឈ្មោះនោះ , ពាក្យថា **តត្រាបាសឹ** ( ក្នុងទីនោះ យើងបានកើតជា...ហើយ ) មានសេចក្តីថា តមក សូម្បីក្នុងភព ឬក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណដ្ឋិតិ ក្នុងសត្តាវាស ក្នុងសត្តនិកាយនោះ យើងបានកើតជា... ហើយពាក្យថា **ឯវំ នាមោ**-មានឈ្មោះយ៉ាងនេះជាដើម តទៅនេះ ក៏មានន័យដូចពោលហើយនោះឯង ។

ម្យ៉ាងទៀត ព្រោះហេតុដែលពាក្យថា **អមុត្រាសឹ** ( ក្នុងទីនោះយើងបានកើត

ជា ... ហើយ ) នេះត្រាស់សំដៅយកការរឭកបានតាមដែលត្រូវការនៃភិក្ខុនោះអ្នកឡើងកាន់បុព្វេនិវាសបន្តឡើងទៅតាមលំដាប់ ពាក្យថា **សោ តតោ ចុតោ**( យើងនោះចុតិពីទីនោះ ) ត្រាស់សំដៅយកការពិចារណាបុព្វេនិវាសដែលរឭកបានហើយរបស់លោកអ្នករឭកថយក្រោយ ព្រោះហេតុនោះ ពាក្យថា **អមុត្រ ឧទបាទឹ**( កើតក្នុងទីនោះ ) នេះគប្បីជ្រាបថា ត្រាស់សំដៅដល់ទីកើតរបស់លោក មុនអំពីការកើតក្នុង**ឥធភព**( ភពនេះ )ដែលត្រាស់ក្នុងបទថា **ឥធុបបន្នោ** នេះ ដេញឡើងមក , ចំណែកពាក្យថា **តត្រាបាសឹ**( ក្នុងទីនោះ ) យើងបានកើតជា... ហើយ ដូច្នេះជាដើម ត្រាស់ដើម្បីសម្តែងការរឭកបាននូវឈ្មោះ និងគោត្រជាដើមក្នុងទីកើតរបស់លោក ខាងក្នុងការឧប្បត្តិម្តងនោះក្នុងភពនោះ ពាក្យថា **សោ តតោ ចុតោ ឥធុ-ប្បន្នោ**-យើងនោះចុតិពីទីនោះមកកើតក្នុងទីនេះ មានសេចក្តីថា យើងនោះឃ្លាតចាកទីនោះ គឺ ពីទីកើតនោះបន្តបន្ទាប់មក ហើយមកកើតក្នុងទីនេះ គឺក្នុងត្រកូលក្សត្រ ឬ ក្នុងត្រកូលព្រាហ្មណ៍ ឈ្មោះនោះជាដើម ។

ពាក្យថា **ឥតិ** គឺ **ឯវំ** ប្រែថា ដោយប្រការដូចពោលមកនេះ , ពាក្យថា **សាការំ សឧទ្ទេសំ**( នូវបុព្វេនិវាស ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ) អធិប្បាយថា នូវបុព្វេនិវាស រាប់ថា ព្រមទាំងឧទ្ទេស ក៏ដោយអំណាចឈ្មោះ និងគោត្ររាប់ថា ព្រមទាំងអាការ ក៏ដោយអំណាចគ្រឿងប្រាកដដទៃៗ មានពណ៌សម្បុរជាដើម , ពិតហើយ ដោយឈ្មោះនិងគោត្រនៃសត្វមនុស្សយើងនេះ ទើបបង្ហាញខ្លួនបានថា នាយតិស្សៈ កស្សបគោត្រជាដើម ដោយប្រការដទៃៗ មានពណ៌សម្បុរជាដើម គេទើបដឹងផ្សេងៗគ្នាថា មនុស្សខ្មៅ មនុស្សសជាដើម ព្រោះដូច្នោះ ឈ្មោះនិងគោត្រ ទើបជាឧទ្ទេស( គ្រឿងណែនាំខ្លួន ) ប្រការដទៃជាអាការ ( សភាពនៃ

រាងកាយ ) , ពាក្យថា ***អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ*** ( រឭកបុព្វេនិវាសបានច្រើនយ៉ាង ) នេះ មានអត្ថងាយទាំងអស់ ។

## មហាដីកា

## អធិប្បាយ បុព្វេនិវាសានុស្សតិញ្ញាណ

***បុព្វេនិវាសំ អនុស្សរតិ*** ( សតិដែលតាមរឭកបុព្វេនិវាសា ) , ***តស្ស វា អនុស្សរណំ*** ( ម្យ៉ាងទៀត ការតាមរឭកបុព្វេនិវាសនោះ ) , ឈ្មោះថា ***បុព្វេនិវាសានុស្សតិ*** លោកអាចារ្យកាលនឹងបើកបង្ហាញសេចក្តីដែលបានពោលទុកដោយសង្ខេបថា ដើម្បីប្រយោជន៍ដល់ញាណក្នុងបុព្វេនិវាសានុស្សតិ បំណងសម្តែងបុព្វេនិវាសជាមុន ហើយទើបសម្តែងសតិ និងញាណក្នុងបុព្វេនិវាសនោះ ទើបពោលថា ***បុព្វេនិវាសា*** ជាដើម ព្រោះអាស្រ័យសតិដែលជាបច្ច័យ មាននិស្សយប្បច្ច័យជាដើមនោះកើតឡើងៗ ក្នុងបទទាំងនោះ បទថា ***បុព្វេ*** នេះ សូម្បីក្នុងទីនេះ លោកបំណងយកវិស័យក្នុងភពអតីត តាមព្រះតម្រាស់ថា ***ឯកម្បិ ជាតឹ***( រមែងរឭកបានមួយជាតិខ្លះ ) ជាដើម ព្រោះហេតុនោះ ទើបពោលថា គឺក្នុងជាតិអតីតទាំងឡាយដូច្នេះ ។ ***និវាស-ស័ព្ទ*** ជាកម្មសាធនៈ ( ដែលខ្លួនបានអាស្រ័យ ) ធម៌ដែលខ្លួនធ្លាប់អាស្រ័យ ដែលផុតអំពីខន្ធ មិនមាន ព្រោះហេតុនោះ ទើបលោកពោលថា បានដល់ ខន្ធទាំងឡាយដែលខ្លួនបានអាស្រ័យ ។ ភាពជាខន្ធដែលអាស្រ័យហើយក្នុងទីនេះ បានដល់ ភាពជាខន្ធដែលប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន , ខ្លួនដែលប្រាកដយ៉ាងនោះ ពួកនោះមានហើយ កើតហើយ ប្រព្រឹត្តទៅហើយរឿយៗ កើតឡើងក្នុងជាតិនោះហើយ ក៏ត្រូវប្រាសទៅហើយ ព្រោះហេតុនោះ ទើបលោកពោល

ថា បទថា **និវុដ្ឋា** បានដល់ ដែលខ្លួនបានគ្រប់គ្រង គឺ ដែលបានសោយដែលកើតឡើងហើយ រលត់ទៅហើយក្នុងសន្តានរបស់ខ្លួនដូច្នេះ ។ លោកអាចារ្យកាលបានពោលដល់សេចក្ដីនៃ **និវាស-សទ្ទ** ដោយអាស្រ័យនឹងធម៌ដែលជាប់ទាក់ទងក្នុងការបន្តនៃខន្ធនេះហើយ , ឥឡូវនេះ កាលពោលដល់វត្ថុដោយមិនប្លែកគ្នាថាម្យ៉ាងទៀត ធម៌ដែលបានអាស្រ័យទាំងឡាយ ក៏ឈ្មោះថា **និវុដ្ឋា** ដូច្នេះហើយ ប្រាថ្នានឹងបើកបង្ហាញវត្ថុនោះ ទើបពោលថា គឺ ដែលបានអាស្រ័យ ដោយជាទីអាស្រ័យ គឺជាអារម្មណ៍ ដូច្នេះជាដើម ។ ពិតហើយ សូម្បីធម៌ដែលជាអារម្មណ៍ទាំងឡាយ ដែលបានសេពហើយ ព្រោះជាការសេពអារម្មណ៍ដែលបានសោយហើយ ដោយទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ ក៏ឈ្មោះថាជា **និវុដ្ឋា** ដែរ ។ ក៏ធម៌ទាំងនោះមាន ២ យ៉ាង ដោយភាពជាអារម្មណ៍នៃវិញ្ញាណរបស់ខ្លួន និងរបស់អ្នកដទៃ ព្រោះហេតុនោះ ដើម្បីសម្ដែងធម៌ទាំងនោះសូម្បីទាំងពីរយ៉ាង ទើបលោកអាចារ្យពោលថា **បានដល់... ដោយវិញ្ញាណរបស់ខ្លួន** ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យដែលលោកពោលទុកថា “ បានដល់ ដែលបានដឹងហើយ ដោយវិញ្ញាណរបស់ខ្លួន ហើយពោលថា ដែលបានកំណត់ទុកហើយដូច្នេះ ” លោកពោលទុកដើម្បីសម្ដែងដល់សេចក្ដីនេះថា ធម៌ដែលបានអាស្រ័យ ព្រោះជាទីអាស្រ័យ គឺជាអារម្មណ៍ទាំងនោះឯង ធម៌ទាំងនោះនឹងប្រាកដត្រឹមតែវត្ថុដែលវិញ្ញាណបានដឹងហើយតែម្យ៉ាងប៉ុណ្ណោះក៏ទេ , តែថា ជាវត្ថុដែលបញ្ញា ដែលមានប្រក្រតីធ្វើការកំណត់ បានកំណត់កាន់យកហើយ តាមការផ្សេងគ្នានៃជាតិ នាម គោត្រ វណ្ណៈ លិង្គ និងអាហារជាដើមក្នុងភពមុន , ញាណនេះ ( គឺ បុព្វេនិវាសានុស្សតិញ្ញាណ ) គឺកំណត់កាន់យកដោយប្រការនោះដូចគ្នា ដូច្នេះ ។ មានការ

ភ្ជាប់សេចក្ដីថា **បរវិញ្ញាណេន វិញ្ញាណាតាបិ វា និវុដ្ឋា** ឬសូម្បីដែលវិញ្ញាណរបស់អ្នកដទៃបានដឹងហើយ ។ សេចក្ដីថា មិនមែនវិញ្ញាណរបស់ខ្លួនបានដឹងហើយតែម្យ៉ាងប៉ុណ្ណោះទេ តែថា ឬសូម្បីដែលវិញ្ញាណរបស់អ្នកដទៃទាំងឡាយបានដឹងហើយ ។ សូម្បីក្នុងបទថា **បរវិញ្ញាណេន** នេះ គប្បីនាំបទថា **បរិច្ឆិន្នា** ( បានកំណត់ហើយ ) មកភ្ជាប់ទុកថា ឬសូម្បី ដែលវិញ្ញាណរបស់អ្នកដទៃបានដឹងហើយបានកំណត់ហើយ ដូច្នេះ ។ ក៏បណ្ឌិតគប្បីពោលដល់ប្រយោជន៍ក្នុងការកាន់យកវិញ្ញាណនោះ តាមន័យដែលបានពោលមកហើយនោះឯង ។ ក៏ធម៌ទាំងនោះឯងព្រោះហេតុដែលបុគ្គលដទៃក៏បានដឹងហើយ កំណត់ហើយក្នុងជាតិអតីតទាំងឡាយនោះឯង , ដែលបុគ្គលទាំងនោះ បរិនិព្វានហើយក៏មាន ។ លោកអាចារ្យប្រាថ្នាសម្ដែងបុព្វេនិវាសាដែលជាអារម្មណ៍ នៃបុព្វេនិវាសានុស្សតិញ្ញាណ ដែលដល់កំពូលថា ធម៌ដែលបានដឹងហើយទាំងនោះឯណា ញាណរមែងដឹងការប្រព្រឹត្តទៅក្នុងអតីតនៃធម៌ទាំងនោះ តាមជួរនៃសន្តាន ដែលប្រព្រឹត្តទៅជាប់តគ្នានៅក្នុងពេលនោះនៃបុគ្គលទាំងនោះ ដូច្នេះ ទើបពោលថា ក្នុងពេលតាមរឭកដល់លោកអ្នកកាត់វដ្ដៈបានហើយជាដើមដូច្នេះ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កាត់វដ្ដៈបានហើយ ការតាមរឭកដល់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ឈ្មោះថា ការតាមរឭកដល់អ្នកកាត់វដ្ដៈបានហើយ ។ លោកអាចារ្យជាច្រើន ពោលថា ដោយ**អាទិ**-ស័ព្ទ ( ប្រែថា ជាដើម ) លោកកាន់យកការតាមរឭកដល់ព្រះបច្ចេកពុទ្ធ និងសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ ។ ឈ្មោះថា **អ្នកកាត់វដ្ដៈបានហើយ** បានដល់ លោកដែលបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុគ្រប់អង្គនោះឯង ។ ឈ្មោះថា **ការតាមរឭកដល់លោកទាំងនោះ** បានដល់ ការតាមរឭកដល់ការបដិបត្តិ ឬ បដិបទានោះ

ពោលដោយសង្ខេប បានដល់ការបដិបត្តិ ឬបដិបទាដែលមានការកាន់យកអារម្មណ៍ ៦ ជាលក្ខណៈ ។ ការតាមរឭកទាំងនោះ ក្នុងទីនេះបានដល់ការតាមរឭកដែលបាន កាន់យកហើយ ដោយសំពួថា ដែលវិញ្ញាណរបស់អ្នកដទៃបានដឹងហើយ , ម្យ៉ាង ទៀត ធម៌ទាំងនេះនោះ ជាវិស័យរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយប៉ុណ្ណោះ មិនបាន ជាវិស័យរបស់បុគ្គលដទៃទេ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ធម៌ ដែលបានអាស្រ័យទាំងនោះ រមែងបានដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ។ សេចក្តី ពិត **គតិ**-ការទៅ គឺការដឹងនៃញាណក្នុងប្រការថា ព្រះមានព្រះភាគទាំងឡាយក្នុង អតីត ទ្រង់បានឃើញច្បាស់ហើយយ៉ាងនេះ ទ្រង់បានចម្រើនមគ្គហើយយ៉ាងនេះ ទ្រង់បានធ្វើផល និងព្រះនិព្វានឲ្យជាក់ច្បាស់ហើយយ៉ាងនេះ ទ្រង់បានណែនាំ វេនេយ្យសត្វហើយយ៉ាងនេះដូច្នេះ នេះមិនមានដល់បុគ្គលដទៃ អស់កាលទាំងពួង ដូច្នេះឯង ។ គប្បីនាំបទមកភ្ជាប់គ្នាថា **យាយ សតិយា បុព្វេនិវាសំ អនុស្សរតិ , សា បុព្វេនិវាសានុស្សតិ** ( កិក្ខុរមែងតាមរឭកដល់បុព្វេនិវាសបានដោយសតិ ឯណា សតិនោះ ឈ្មោះថា **បុព្វេនិវាសានុស្សតិ** ) ។

ពាក្យថា **មានប្រការផ្សេងៗ ជាអនេក** គឺ មានប្រការផ្សេងៗ យ៉ាងច្រើន ដោយទាក់ទងនឹងកព **យោនិ គតិ វិញ្ញាណដ្ឋិតិ សត្តាវាស** ជាដើមផ្សេងៗ ។ បទថា **បការេហិ** ( ព្រមទាំងប្រការទាំងឡាយ ) គឺ ព្រមទាំងអាការទាំងឡាយ មានឈ្មោះ និង គោត្រជាដើម ។ បទថា **បការេហិ** នេះ ជាតតិយាវិភត្តិក្នុង សហយោគ ។ ឈ្មោះថា **ធ្វើឲ្យប្រព្រឹត្តទៅ** គឺ តាមរយៈការទេសនា ។ ព្រោះ ហេតុនោះ ទើបលោកពោលថា គឺ សំវណ្ណនា មានសេចក្តីថា ធ្វើឲ្យពិស្តារ ។ បទថា **និវាសំ** នេះ ជាពាក្យពោលដល់ការស្មើគ្នា ដោយប្រភេទនៃខន្ធសន្តាន

ដែលទាក់ទងក្នុងខាងក្នុង ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងប្រភេទទាំងនោះរួមទុក តាមតម្រូវការដែលផ្សព្វផ្សាយទៅនៃញាណ ទើបពោលថា បានដល់ សន្តានដែលធ្លាប់អាស្រ័យនៅក្នុងភពនោះៗដូច្នេះ សេចក្តីនេះជាការតាមរឭករបស់ព្រះសាវ័ក មិនមែនរបស់ព្រះសាស្តាទេ ព្រោះហេតុនោះ ទើបលោកពោលថា ដោយទាក់ទងនឹងលំដាប់ខន្ធ ឬ ដោយទាក់ទងនឹងចុតិ និងបដិសន្ធិ ដូច្នេះ ។ ឈ្មោះថា **ខន្ធបដិបាទា** បានដល់ លំដាប់នៃខន្ធទាំងឡាយ ។ ក៏លំដាប់នៃខន្ធទាំងឡាយនោះ លោកពោលទុកតាមរយៈជាលំដាប់ក្រៃលែងឡើងទៅ ចាប់តាំងពីចុតិទៅ ។ ចំណែកអាចារ្យពួកខ្លះ ពោលទុកក្នុងសេចក្តីនេះថា ជាលំដាប់ខន្ធដោយលំដាប់ឥរិយាបថ ដូច្នេះ ។ ពាក្យថា **តាមៗទៅ** គឺ តាមៗ ទៅដោយញាណគតិ ។ ពាក្យថា **ពួកតិត្ថិយ** បានដល់ ពួកអញ្ញតិត្ថិយ គឺ អ្នកកាន់លទ្ធិដទៃ ក៏ពួកតិត្ថិយទាំងនោះ បានដល់ ពួកបុគ្គលទាំងឡាយ មានពួកតាបសជាដើម អ្នកជាកម្មវាទី(មានប្រក្រតីពោលអាងកម្ម) ជាកិរិយវាទី(មានប្រក្រតីពោលអាងការធ្វើ)។ លើកលែងព្រះអគ្គសាវ័ក និង ព្រះមហាសាវ័កទាំងឡាយចេញ សាវ័កដទៃរបស់ព្រះសាស្តា ឈ្មោះថា ព្រះបកតិសាវ័ក ។

ព្រោះហេតុដែលការតាមរឭកសំវដ្តវិវដ្តកប្ប ៤០ របស់ពួកតិត្ថិយទាំងនោះមកហើយក្នុងព្រះសូត្រទាំងឡាយ មានព្រហ្មជាលសូត្រជាដើម ដូច្នោះ លោកអាចារ្យកាលពោលថា មិនក្រៃលែងទៅជាងនោះ ដូច្នេះហើយ កាលនឹងពោលដល់ហេតុនោះ ទើបពោលថា ព្រោះជាអ្នកមានបញ្ញាទុព្វល ដូច្នេះជាដើម ដោយពាក្យនោះ លោកសម្តែងថា ការបំពេញក្រៃលែងក្នុងវិបស្សនា ជាហេតុពិសេសនៃបុព្វេនិវាសានុស្សតិញ្ញាណ ។ ក្នុងពាក្យថា **ជាអ្នកមានបញ្ញាដ៏មានកម្លាំងនេះ** គប្បីឃើញ

ថា ញាណកំណត់នាមរូបជាដើមនោះឯង ជាហេតុឲ្យបញ្ញាមានកម្លាំង ។ បណ្តាជនទាំងនោះ ប្រការដែលបញ្ញាមានកម្លាំងនោះ ជាហេតុសាធារណៈនៃលោកទាំងនោះ ។ ពាក្យថា **មានអភិនីហារត្រឹមប៉ុណ្ណោះ** មានសេចក្តីថា អភិនីហារនៃបុណ្យគឺញាណ គឺ សាវកពោធិបារមី និងបច្ចេកពោធិបារមី ដែលដល់ព្រមហើយនៃព្រះមហាសាវក និងព្រះអគ្គសាវក និងព្រះបច្ចេកពុទ្ធទាំងឡាយពួកនោះ មានបរិមាណដោយទាក់ទងនឹងកាលតាមលំដាប់យ៉ាងនេះ គឺ ១សែនកប្ប , ១អសង្ខេយ្យ ១សែនកប្បនោះ និង ២ អសង្ខេយ្យ ១ សែនកប្ប ដូច្នេះ ។ លោកអាចារ្យធ្វើពាក្យសួរទុកក្នុងចិត្តថា បើការចែកអភិញ្ញារបស់ព្រះអរិយបុគ្គលទាំងនោះ មានការកំណត់ទុកដោយកាល ដែលសន្សំពោធិសម្ភារៈដូច្នេះ , កាលបើយ៉ាងនេះក៏មានការដល់ការៈថាវិស័យនៃអភិញ្ញាញាណ សូម្បីរបស់ព្រះពុទ្ធ ក៏មានព្រំដែន ដូច្នេះហើយ ទើបពោលថា ចំណែកសម្រាប់ព្រះពុទ្ធទាំងឡាយ ជាធម្មតាថា មិនមានព្រំដែនដូច្នេះ ។ ឈ្មោះថា ព្រំដែនក្នុងវិស័យនៃអភិញ្ញាញាណទាំងឡាយរបស់ព្រះពុទ្ធទាំងឡាយមិនមានទេ ដូចគ្នានឹងព្រះសព្វញ្ញុតញ្ញាណ ព្រោះមានពាក្យនិយាយថា **យាវត្តកំ ញេយ្យំ , តាវត្តកំ ញាណំ** វត្ថុដែលគួរដឹងមានប្រមាណប៉ុនណា ព្រះញាណក៏មានប្រមាណប៉ុណ្ណោះដូច្នេះ ។ ព្រះពុទ្ធទាំងឡាយទ្រង់ប្រាថ្នានឹងដឹងវត្ថុណាៗ ក៏ទ្រង់ដឹងវត្ថុនោះៗ បានតែម្តង ។ ន័យម្យ៉ាងទៀត លោកអាចារ្យធ្វើទុកក្នុងចិត្តថា សូម្បីថា ព្រំដែននៃកាលនឹងមានបាន , ឈ្មោះថា ព្រំដែននៃអានុភាពដែលប្រព្រឹត្តទៅដោយព្រះបញ្ញាបារមី មិនមាន ព្រោះព្រះមហាពោធិសម្ភារៈ ( អង្គគុណគ្រឿងប្រកបនៃការត្រាស់ដឹងដ៏ធំក្រៃលែងទាំងឡាយ ) មានភាពប្រសើរលើស ដោយកិច្ចមានការកំណត់កាន់យកសេចក្តីច្លាតក្នុងឧបាយនៃ

ការធ្វើជាដើម អភិញ្ញាទាំងឡាយដែលកើតឡើងព្រោះអានុភាពនោះ នឹងមានព្រំដែនពីទីណា ដូច្នេះហើយ ទើបពោលថា ចំណែកសម្រាប់ព្រះពុទ្ធទាំងឡាយ ជាធម្មតាថា មិនមានព្រំដែនដូច្នេះ ។ ព្រំដែននៃកាលរបស់ព្រះអភិញ្ញាញាណ ក្នុងអតីតយ៉ាងនេះថា ទ្រង់ដឹងបានច្រើនអសង្ខេយ្យកប្បប៉ុណ្ណេះ ដូច្នេះ មិនមានទេ ដូចព្រំដែននៃកាលនៃព្រះអនាគតំសញ្ញាណក្នុងអនាគតដូច្នោះ ។

លោកអាចារ្យកាលសម្តែងការតាមរឭកបុព្វេនិវាសនៃជន ៦ ជំពូក ដោយការចែកតាមកាល ( រយៈពេលដែលអាចរឭកបាន ) យ៉ាងនេះហើយ ឥឡូវនេះប្រាថ្នាសម្តែងការតាមរឭកបុព្វេនិវាសដោយការកាន់យកអារម្មណ៍ ដោយអានុភាពពិសេស និងដោយអាការដែលប្រព្រឹត្តទៅ ទើបពោលថា ម្យ៉ាងទៀត ពួកតិរ្ថិយជាដើម ។ ពាក្យថា **តាមរយៈការចុតិ និងបដិសន្ធិ** គឺ តាមរយៈការដែលឃើញចុតិ គឺ ការឃ្លាតចាកភព ក្នុងអត្តភាពនោះៗរបស់ខ្លួន ឬ របស់អ្នកដទៃ ហើយមិនប្រកាន់ខន្ធណាៗ ក្នុងរវាង ក៏កាន់យកបដិសន្ធិបានតែម្តង ។ ដើម្បីនឹងបើកបង្ហាញសេចក្តីដែលបានពោលទុកជាពាក្យជំទាស់ និងដោយជាពាក្យសម្រេចតាម ទើបពោលថា ពិតហើយ តិរ្ថិយទាំងនោះដូច្នេះជាដើម ។ សេចក្តីដែលថា ព្រះបកតិសាវកទាំងឡាយ រមែងឈានទៅដោយទាក់ទងនឹងចុតិ និងបដិសន្ធិខ្លះ ដូច្នេះនេះ បណ្ឌិតគប្បីធ្វើឲ្យជាក់ច្បាស់ដោយហេតុដែលថា ព្រោះជាអ្នកមានបញ្ញាមានកម្លាំង តាមន័យដែលបានហើយក្នុងខាងដើមចុះ ។ ក៏ការឈានទៅដោយទាក់ទងនឹងចុតិ និងបដិសន្ធិ លោកពោលទុកក្នុងទីនេះ ដើម្បីសម្តែងកម្លាំងរបស់ញាណ គឺការដឹងដោយមិនមានការប្រកបក្នុងការនឹងឃើញក្នុងកណ្តាល ( រវាងចុតិ និងបដិសន្ធិ ) ។

ពាក្យថា **ឋានៈនោះៗ នឹងត្រូវប្រាកដ** គឺ ត្រូវប្រាកដច្បាស់ដល់បុគ្គលអ្នកមានភ្នែកល្អ ក្នុងផ្ទះមានទទឹងត្រឹម ៤ រតនៈ ( ៤ ហត្ថ ) ក្នុងពេលថ្ងៃត្រង់ក្នុងរដូវក្តៅដូច្នោះ ប្រការដែលពោលមកនេះៗ សម្រេចដល់ពពួកលោកហើយ , តែថា សម្រាប់បុរសនោះ រូបដែលមានប្រភេទជារូបដ៏ល្អិតក្រៃលែងជាងរូបដែលតាំងនៅ ខាងក្រៅ( ជញ្ជាំង កំផែង )ជាដើម គប្បីជាអារម្មណ៍មិនបាន ។ សម្រាប់ព្រះពុទ្ធទាំងឡាយ វត្ថុគួរដឹង ដែលទ្រង់ប្រាថ្នានឹងដឹង និងជាអារម្មណ៍មិនបាន មិនមាន , តែថា វត្ថុនោះទ្រង់ប្រើពន្លឺគឺព្រះញាណបញ្ចាំងហើយ ក៏ត្រូវប្រាកដច្បាស់ចែងចាំងល្អ ដូចផ្លែកន្ទួតព្រៃក្នុងដៃដូច្នោះ ព្រោះលះធម៌ដែលជាគ្រឿងរារាំងវត្ថុដែលគួរដឹងយ៉ាងនោះ បានល្អហើយ ។ ពាក្យថា **ដូចជាបំប្រួញព្រះបាលីក្នុងផ្នែកដែលជាបេយ្យាល** មានសេចក្តីថា ប្រៀបដូចជាភិក្ខុទាំងឡាយ កាលនឹងតាំងព្រះបាលីដែលមានបេយ្យាល រមែងកាន់យកខាងដើម និងខាងចុងប៉ុណ្ណោះ សូត្របំប្រួញទៅថា **បឋមំ ឈានំ ។ បេ ។ បញ្ចមំ ឈានំ ( បឋមឈាន ។ ល ។ បញ្ចមឈាន** ជាដើម មិនសូធ្យទៅតាមលំដាប់បទយ៉ាងណា ព្រះពុទ្ធក៏ទ្រង់បំព្រួញកោដិកប្បទាំងឡាយសូម្បីជាអនេកក៏ដូច្នោះ ។ ពាក្យថា **ទ្រង់ប្រាថ្នាឋានៈណា** គឺ ទ្រង់ប្រាថ្នានឹងជ្រាបឋានៈណាៗ ក្នុងភពណា ក្នុងកប្បណា ក៏នឹងស្តេចឈានចុះទៅក្នុងឋានៈនោះៗឯង ដែលទ្រង់ប្រាថ្នានឹងជ្រាបនោះ ដោយព្រះញាណ ។ ឈ្មោះថា **ស្តេចទៅ** គឺ ដោយការទៅដោយញាណ ដោយអាការដូចជារាជសីហ៍សន្ធ្រប់ចាប់ គឺដោយអាការដូចជារាជសីហ៍បោះពួយទៅ ។ នាយខ្មាន់ធ្នូ ឈ្មោះថាអ្នកមានភាពជំនាញក្នុងការបាញ់រោមទ្រាយ គឺ បាញ់បំបែកចុងរោមទ្រាយជា ១០០ចំណែក ទល់ចុងគ្នាបាន ។ បទថា **សរភង្គសទិសស្ស** ប្រែថា ធ្លាតដូចព្រះសរភង្គ

ពោធិសត្វ ។ ឈ្មោះថា នឹងជាប់ជំពាក់ ទាក់ទងនឹងការទៅមិនដល់គោលដៅក៏ទេ។ ឈ្មោះថា ឃៀងឃ្លាត ខុសគោលដៅ ឬ ផ្លាតទៅម្ខាង មិនមាន ។

ពាក្យថា **រមែងប្រាកដដូចពន្លឺអំពិលអំពែក** មានសេចក្តីថា បុព្វេនិវាសា-នុស្សតិញ្ញាណ រមែងប្រាកដជារបស់ស្មើដោយពន្លឺនៃអំពិលអំពែក ព្រោះជាញាណមានអានុភាពតិចតួច ។ សូម្បីក្នុងបទទាំងឡាយដ៏សេសក៏មានន័យដូច្នេះ ។ ពាក្យថា **ប្រាកដដូចពន្លឺចង្កៀង** គឺ ប្រាកដដូចពន្លឺចង្កៀងតាមប្រក្រតី ។ ឈ្មោះថា ភ្លឺដូចគប់ភ្លើង បានដល់ ពន្លឺនៃដុំឧសធំៗ ។ បទថា **ឱសធីតារកប្បភា** - ពន្លឺនៃផ្កាយព្រឹក គឺ ពន្លឺនៃផ្កាយដែលបានឈ្មោះយ៉ាងនេះថា **ឱសធិ** ( ផ្កាយព្រឹក ) ព្រោះអត្ថថា ជាពន្លឺដ៏រុងរឿង ឬដែលបានឈ្មោះយ៉ាងនេះថា **ឱសធិ** ព្រោះអត្ថថា តាមផ្តល់កម្លាំងដល់ **ឱសធី** ( ម្ចាស់ពន្លឺ ) ទាំងឡាយ ។ ឈ្មោះថា ដូចព្រះអាទិត្យ ១.០០០ ដួង ក្នុងរដូវក្តៅ ក៏ព្រោះការកម្ចាត់ភាពងងឹតក្នុងវិស័យរបស់ខ្លួនបានដោយប្រការទាំងពួង ។

ឈ្មោះថា ដូចការទៅដោយឈើប្រត់ ក៏ព្រោះការមិនរំលងលំដាប់ខ្លួន ។ ស្ពានតូចដែលធ្វើដោយបន្ទះក្តាមួយប៉ុណ្ណោះសាងឡើង ដើម្បីការឆ្លងកំពង់ទឹកទាំងឡាយ ឈ្មោះថា **ទណ្ឌកសេតុ** ( ស្ពានឈើ ) ។ ស្ពានចម្លងដែលគេក្រាលដោយបន្ទះក្តារ ហើយដំកន្ទាស់សាងឡើងត្រឹមជន ៤-៥ នាក់ អាចនឹងដើរទៅបាន ឈ្មោះថា **ជង្ឃសេតុ**( ស្ពានថ្មើរជើង ) ។ ស្ពានចម្លងដែលពួកអ្នកថ្មើរជើងគួរនឹងទៅបាន ឈ្មោះថា **ជង្ឃសេតុ**( ស្ពានថ្មើរជើង ) ដូចគ្នានឹង **ជង្ឃមគ្គ**( ផ្លូវថ្មើរជើង ) ដូច្នោះ ។ ស្ពានចម្លងដែលរទេះគួរនឹងទៅបាន ឈ្មោះថា **សកដសេតុ**( គឺស្ពានរទេះ ) ដូចគ្នានឹង **សកដមគ្គ** គឺ ផ្លូវរទេះដូច្នោះ ។ ផ្លូវដែលពួកអ្នកថ្មើរជើង

ក្រុមធំអាចដើរទៅបាន ឈ្មោះថា **មហាជង្ឃមគ្គ**( ផ្លូវថ្មើរជើងធំ ) ។ ផ្លូវដែលរទេះជាច្រើន ២០-៣០អាចទឹងបរបានព្រមគ្នា ឈ្មោះថា **មហាសកដមគ្គ**( ផ្លូវរទេះធំ ) ។

ពាក្យថា **ក៏ក្នុងអធិការនេះ** គឺក្នុងរឿងការចម្រើនសមាធិនៃព្រះសាវ័កដែលលោកបានសម្ដែងខទុកដោយពាក្យថា ចិត្តជាសំខាន់ថា " **ចិត្តំ បញ្ញញ្ច ភាវយំ** " ( ចម្រើនចិត្ត និងបញ្ញា ) ដូច្នេះ ។

ពាក្យថា **ព្រោះដូច្នោះ** មានសេចក្ដីថា ព្រោះហេតុដែលក្នុងទីនេះ លោកបំណងយកការតាមរឭកបុព្វេនិវាសរបស់ព្រះសាវ័កដូច្នោះ , ពាក្យថា **យ៉ាងនេះ** មានសេចក្ដីថា ភិក្ខុអ្នកត្រូវការតាមរឭក តាមដូចដែលបុគ្គលទាំងនោះតាមរឭក លោកពោលថា ចូលឈាន ៤ តាមលំដាប់ ដូច្នេះ ដើម្បីការធ្វើកាយឲ្យឆ្អែតដោយបីតិ និងសុខក្នុងឈាន ៣ ខាងក្រោមតាមសមគួរ , ប្រសិនបើដោយប្រការដទៃ ក៏ត្រូវចូលឈានដែលជាបាទ ( ដែលជាឈានទី ៤ ប៉ុណ្ណោះ ) តែម្យ៉ាង ។ កាលព្រះយោគីអង្គុយចុះដោយការអង្គុយណា ហើយមានការផ្ដើមរឭក ការអង្គុយនោះ ឈ្មោះថា ការអង្គុយគ្រាចុងក្រោយបង្អស់ក្នុងទីនេះ ។ បទថា **តតោ អាសនបញ្ញាបនំ** មានការភ្ជាប់សេចក្ដីថា **តតោ និសជ្ជាយ បុរិមកំ អាសនបញ្ញាបនំ អាវជ្ជិតព្វំ** ( បន្ទាប់ពីការអង្គុយនោះទៅ ក៏គប្បីនឹកដល់កិច្ច គឺការក្រាលអាសនៈជាកិច្ចដំបូង ) ។ សូម្បីក្នុងបទដ៏សេសទាំងឡាយក៏មានន័យដូច្នេះ ។ ក្នុងពាក្យថា **ពេលឆាន់ជាដើម** លោកពោលដល់កិច្ចដែលគប្បីធ្វើក្នុងពេលនោះៗ ដោយពាក្យថា **ពេល** ជាសំខាន់ ។ ក្នុងពាក្យថា **ពេលដែលក្រាបថ្វាយបង្គំលានព្រះចេតិយ និងលានព្រះពោធិព្រឹក្ស** គឺ ពេលដែលក្រាបថ្វាយបង្គំចេតិយ និងពោធិព្រឹក្សក្នុងលានព្រះចេតិយ និងលានព្រះពោធិព្រឹក្ស ។ បទថា **សកលំ រត្តិន្ទិវំ** ជា

ទុតិយាវិកត្តិក្នុងអច្ចន្តសំយោគ ប្រែថា អស់យប់ និងថ្ងៃទាំងអស់ ។

ឈ្មោះថា **កិញ្ចិ** ( ណាមួយ ) បានដល់ កិច្ច ។ ពាក្យថា **ដោយហេតុត្រឹមប៉ុណ្ណោះ** គឺដោយការចូលឈានដែលជាបាទ ។ ពិតមែន ឈានដែលជាបាទរមែងជាហេតុធ្វើឲ្យសតិ និងបញ្ញាកាន់តែមុតខ្លាំង ដូចថ្មសំលៀងកាំបិត ជាហេតុធ្វើឲ្យសស្ត្រាកាន់តែមុត ដូច្នោះ ។ សតិ និងបញ្ញាទាំងនោះ នឹងដល់នូវការមុតស្រួចបានក៏ព្រោះព្រះយោគីនោះចូលឈានដែលជាបាទនោះ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ក៏ត្រូវប្រាកដបានដូចកាលប្រទីបឆេះឡើង ដូច្នោះ , អធិប្បាយថាដូចកាលប្រទីបឆេះឡើងក្នុងទីងងឹត ។ ពាក្យថា **ក្នុងភពមុន** គឺ ក្នុងភពមុន ក្នុងលំដាប់នៃភពនេះ ។ ពាក្យថា **នាមរូបដែលប្រព្រឹត្តទៅ** គឺ នាមរូបដែលប្រព្រឹត្តទៅព្រោះបច្ច័យទាំងឡាយរបស់ខ្លួន ។ ព្រះយោគីគប្បីនឹកដល់រូបនោះមុន ដូច្នេះហើយទើបនឹកដល់នាម ។ អាចារ្យមួយពួកទៀតពោលថា គប្បីនឹកដល់នាមមុនហើយទើបនឹកដល់រូបជាខាងក្រោយ ។ បទថា **បហោតិ** កែជា **សក្កោតិ** ( ទើបអាច ) ។ ព្រះយោគីអ្នកធ្វើបុញ្ញាធិការទុកក្នុងអភិញ្ញាភាវនានេះ ឈ្មោះថា បណ្ឌិត ។

ពាក្យថា **នាមរូបដទៃកើតឡើងនេះ** លោកពោលទុកព្រោះធ្វើអធិប្បាយថាឧប្បត្តិភពដទៃកើតឡើងពីកម្មភពដទៃ ព្រោះមានក្នុងរវាងអទ្ធាបច្ចុប្បន្ន បើដោយប្រការដទៃ , នាមរូបតែម្យ៉ាងៗនោះឯង រមែងកើតឡើងសូម្បីក្នុងភពជាមួយគ្នា , និងដែលរលត់ទៅហើយ ក៏មិនត្រឡប់មកបន្តវិញ ។ ព្រោះហេតុនោះ ទើបលោកពោលថា :

ខន្ធពួកណាដែលរលត់ទៅហើយ របស់សត្វអ្នកស្លាប់ហើយក៏ដោយ អ្នកនៅមានជីវិតរស់ក៏ដោយ ក្នុងបវត្តិកាលនេះ ខន្ធទាំងនោះសូម្បីទាំងអស់ ប្រាកដដូច

គ្នា គឺ ទៅប្រាសហើយ គឺ មិនត្រឡប់មកបន្តវិញទេ ដូច្នេះ ។

ពាក្យថា **ឋានៈនោះ** គឺឋានៈដែលតាំងចុះនៃនាមរូបនោះ ។ បទថា **អាហុន្ទរិកំ** បានដល់ ជាទីតូចចង្អៀត ដែលបិទបាំងជុំជិត ដោយជុំវិញទាំងខាងលើ ។ បទថា **អន្ធតមមិវ** ប្រែថា ដូចទីងងឹតស្លុង ។

ពាក្យថា **ដើម្បីប្រយោជន៍ដល់ជហ្វាកំពូល** គឺដើម្បីប្រយោជន៍ដល់ជហ្វានៃផ្ទះកំពូល ។ បណ្ឌិតគប្បីជ្រាបការប្រៀបធៀប និងការឧបមាយ៉ាងនេះថា បុព្វេនិវាសានុស្សតិញ្ញាណ ដូចជាជហ្វាផ្ទះកំពូល ។ នាមរូបដែលប្រព្រឹត្តទៅក្នុងចុតិខណៈ ក្នុងភពមុនដូចជាដើមឈើធំ , បដិសន្ធិចិត្តក្នុងភពនេះ ដែលសម្ព័ន្ធនឹងនាមរូបនោះ ដូចជាមែក និងស្លឹក , បរិកម្មភាវនាដូចជាមុខពូថៅ , ឈានដែលជាបាទ ដូចជារោងដ៏រឹតូចដូច្នេះចុះ ។ សូម្បីឧបមារឿងមនុស្សពុះឧស បណ្ឌិតក៏គប្បីជ្រាបតាមទំនងនៃន័យដែលបានពោលមកហើយថា ប្រៀបដូចបុរសអ្នកមានកម្លាំងកាលនឹងពុះឧសដុំធំដើម្បីដាំបាយជាដើម កាលមិនអាចដើម្បីនឹងប្រើមុខពូថៅដែលថែបហើយដើម្បីពុះអុសដុំធំ សូម្បីត្រឹមតែសំបក និងខ្ទឹមបាន ក៏មិនដាក់ចុះនូវធុរៈដូច្នេះជាដើម ។ សូម្បីឧបមារឿងជាងកាត់សក់ក៏យ៉ាងនោះ ។

ឈ្មោះថា **មិនទាន់ឈ្មោះថាជាបុព្វេនិវាសញ្ញាណ** ព្រោះមិនមានធម៌ដែលអាស្រ័យនៅក្នុងជាតិអតីតទាំងឡាយជាអារម្មណ៍ ។ ពាក្យថា **ញាណនោះ** គឺញាណ ដែលប្រព្រឹត្តទៅតាំងពីការអង្គុយចុងក្រោយបង្អស់រហូតដល់បដិសន្ធិ បានដល់ ញាណដែលសម្បយុត្តនឹងសមាធិ ដែលប្រព្រឹត្តទៅដោយភាពជាបរិកម្មនៃបុព្វេនិវាសានុស្សតិញ្ញាណ ឈ្មោះថា ជាបរិកម្មសមាធិញ្ញាណ ។ ឈ្មោះថា ពាក្យនោះមិនត្រឹមត្រូវ ព្រោះ( អតីតំសញ្ញាណ ) សំដៅយករូបាវចរញ្ញាណ មានសេចក្តី

ថា ពាក្យរបស់អាចារ្យទាំងនោះ នោះមិនត្រឹមត្រូវប្រសិនបើថាជាអតីតំសញ្ញាណ , ដែលលោកប្រាថ្នាយករូបាវចរញាណ ព្រោះបរិកម្មសមាធិញ្ញាណ ជាកាមាវចរញ្ញាណ ។ សេចក្តីពិតថា ពាក្យពោលដែលមកក្នុងព្រះបាលី ឬក្នុងអដ្ឋកថាថា រូបាវចរចិត្ត រមែងកើតឡើងប្រាវព្ធខន្ធទាំងឡាយ ដែលប្រព្រឹត្តទៅមុនចុតិចិត្តក្នុងលំដាប់ដូច្នេះ មិនមាន ។ មានពាក្យប្រកបសេចក្តីថា **យេសំ ជវនានំ បុរិមានិ** ដែលជាបណ្តាជវនៃត្រង់ខណៈខាងដើមៗ ។ ភ្ជាប់សេចក្តីថា **យទា បន អប្បនាចិត្តំ ហោតិ , តទាស្ស** ។ ពាក្យថា **ញាណនេះ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ** លោកសម្តែងដល់ញាណដែលប្រព្រឹតទៅ ធ្វើនាមរូបដែលប្រព្រឹត្តទៅក្នុងខណៈចុតិនៃភពមុនបន្ទាប់ ឲ្យទៅជាអារម្មណ៍ក៏ពិតមែន សូម្បីដូច្នោះ គប្បីឃើញថាពាក្យនោះគ្រាន់តែជាឧទាហរណ៍ ព្រោះការដែលបំភ្លឺដល់ន័យដទៃ ក៏ជាញាណដូចគ្នា ។ ដូចជាខន្ធអតីតទាំងឡាយទាំងពួង និងវត្ថុដែលទាក់ទងនឹងខន្ធ ចាប់តាំងពីនាមរូបនោះទៅ ឈ្មោះថា បុព្វេនិវាសទាំងអស់យ៉ាងណា ញាណដែលប្រព្រឹត្តទៅទាក់ទងនឹងការចាក់ចុះបុព្វេនិវាសនោះ ក៏ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណទាំងអស់ដូច្នោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ភិក្ខុរមែងតាមរឭកដល់បុព្វេនិវាសដែលមានប្រការផ្សេងៗជាច្រើន បានដោយសតិដែលសម្បយុត្តនឹងញាណនោះ ដូច្នេះ ។

ពាក្យថា **មួយជាតិខ្លះ** គឺភពមួយខ្លះ ។ ក៏ភពនោះ បានដល់ ការបន្តគ្នានៃខន្ធដែលកើតឡើងព្រោះកម្មដូចគ្នា កំណត់ទុកដោយ **អាទាន**( ការកាន់យក បានដល់ បដិសន្ធិ ) និង**និក្ខេប**( ការលះបង់ បានដល់ ចុតិ ) ដែលមានប្រភេទនៃធម៌ដែលរួមចុះខាងក្នុង ដែលលោកសំដៅយកថាជា **ជាតិ** ក្នុងពាក្យថា **មួយជាតិខ្លះ**

នេះ ។ ព្រោះហេតុនោះ ទើបពោលថា បានដល់ ការបន្តនៃខន្ធដែលទាក់ទង ក្នុងភពជាមួយគ្នា ដែលមានបដិសន្ធិជាមូល មានចុតិជាទីបំផុត ដូច្នេះ ។ ពាក្យថា **ដែលកំពុងវិនាស** បានដល់ កំពុងអស់ទៅ ដែលកំពុងវិនាសទៅ ។ ពាក្យថា **កប្ប** បានដល់ អសង្ខេយ្យកប្ប ។ ក៏កប្បនោះ ពោលដោយសេចក្តីក៏គឺ **កាល** គប្បីជ្រាបដល់ការសាបសូន្យនៃកប្បនេះ ដោយទាក់ទងនឹងសង្ខារដែលប្រព្រឹត្តទៅ ក្នុងពេលនោះ សូម្បីក្នុងពាក្យថា កប្បដែលចម្រើន ឈ្មោះថា វិវដ្តកប្បនេះ ក៏មានន័យដូច្នេះដែរ ការអស់ទៅនៃកាលដែលលោកពោលទុកក្នុងពាក្យថា **យោ បន កាលំ ខេបេតិ** គឺបុគ្គលណាធ្វើកាលឲ្យអស់ទៅ និងថា **កាលោ ឃសតិ ភូតានិ , សព្វានេវ សហត្តនា** ( កាលវេលារមែងទំពាស៊ីសព្វសត្វ ព្រមទាំងខ្លួន ឯងផង ដូច្នេះជាដើម ) ។ ការអស់ទៅនៃកាលនោះ លោកមិនប្រាថ្នាយកក្នុងទីនេះ ព្រោះជាពាក្យពោលទាក់ទងនឹងកាលដែលមិនគួរប្រាថ្នា ។ ការសាបសូន្យ គឺ ការវិនាស ឈ្មោះថា **សំវដ្តកប្ប** ។ កប្បដែលតាំងនៅបន្ទប់ពីសំវដ្តកប្បដោយ ប្រការនោះ ឈ្មោះថា **សំវដ្តដ្ឋាយី** ។ ពាក្យថា **ព្រោះមានសំវដ្តកប្បនោះជាមូល** គឺព្រោះមានសំវដ្តកប្បនោះជាខាងដើម ។ ការចម្រើន គឺ ការកើតឡើង ឬការរីល ទៅ ឈ្មោះថា វិវដ្តៈ ។

កាលលោកគួរនឹងពោលដល់សំវដ្តកប្ប ទៅតាមលំដាប់ព្រំដែននៃការសាប សូន្យយ៉ាងនេះថា តេជោសំវដ្តកប្ប អាបោសំវដ្តកប្ប វាយោសំវដ្តកប្ប ដូច្នេះ លោកអាចារ្យមិនពោលយ៉ាងនោះ ត្រឡប់ពោលថា **អាបោសំវដ្តកប្ប តេជោសំវដ្ត កប្ប វាយោសំវដ្តកប្ប** ដូច្នេះ ។ អាចារ្យពួកខ្លះពោលថា ជាទេសនាដែលប្រព្រឹត្ត ទៅតាមលំដាប់នៃទេសនាមហាភូត ដែលធ្វើកប្បឲ្យសាបសូន្យ ។ អាចារ្យមួយពួក

ទៀតពោលថា ជាទេសនាដែលប្រព្រឹត្តទៅតាមលំដាប់នៃការសាបសូន្យ ។ កប្ប ដែលសាបសូន្យព្រោះអាបោ គឺ ទឹក ឈ្មោះថា អាបោសំវដ្តកប្ប ។ ពាក្យថា **សំវដ្តសីមា** បានដល់ ព្រំដែនដែលសាបសូន្យ ។

បទថា **សំវដ្តតិ**-សាបសូន្យ បានដល់ វិនាស ។ ពាក្យថា **សូម្បីគ្រប់ពេល** គឺ ក្នុងកាលទាំងពួង មានសេចក្តីថា ក្នុងកាលដែលវិនាសទាំង ៣ កាល ។

ក្នុងពាក្យថា **ពុទ្ធខេត្តមួយ** នេះលោកអាចារ្យពោលសំដៅយកពុទ្ធខេត្តណា , ដើម្បីសម្តែងពុទ្ធខេត្តនោះឲ្យពិតប្រាកដ ទើបលោកពោលថា ឈ្មោះថា ពុទ្ធខេត្ត មាន ៣ យ៉ាង ដូច្នេះជាដើម ។ អានុភាពនៃព្រះញាណ មានព្រះញាណដែលដឹង បដិសន្ធិជាដើមនៃព្រះតថាគត ដែលផលនៃបុណ្យឧបត្ថម្ភហើយ រមែងរុងរឿង ដោយសភាវៈរបស់ខ្លួននោះឯង បានក្នុងទីនេះត្រឹមណា ទីសូម្បីទាំងអស់នោះ ឈ្មោះ ថា ជាខេត្តដែលកើតឡើងនៃលោកជាពន្លកព្រះពុទ្ធ ព្រោះហេតុនោះ ទើបលោក អាចារ្យពោលថា ជាតិខេត្ត មានព្រំដែន ១ ម៉ឺន ចក្កវាឡ ដូច្នេះ ។ ក្នុងពាក្យថា អានុភាពនៃព្រះបរិត្តរមែងប្រព្រឹត្តទៅនេះ មានសេចក្តីថា លោកអ្នកមានឫទ្ធិអ្នកបាន បោតោវសីបិតនៅក្នុងចក្កវាឡណាមួយ ដែលរាប់ទាក់ទងក្នុងអាណាខេត្ត ហើយ ធ្វើព្រះបរិត្តដើម្បីប្រយោជន៍ដល់ខ្លួនឯង សូម្បីទៅចក្កវាឡដទៃក្នុងអាណាខេត្តនោះ ឯង ក៏នៅឈ្មោះថា ជាអ្នកដែលបានធ្វើព្រះបរិត្តនោះទុក ។ ន័យម្យ៉ាងទៀត អានុភាព នៃព្រះបរិត្ត រមែងសម្រេចដល់សព្វសត្វបានផងដែរ ក្នុងអាណាខេត្តដែលមានព្រះ ពុទ្ធទ្រង់ធរមាននៅ ក្នុងចក្កវាឡមួយ ក្នុងអាណាខេត្តនោះ ហើយបានទ្រង់ធ្វើបរិត្ត ដើម្បីប្រយោជន៍ដល់សព្វសត្វទុក ព្រោះក្នុងអាណាខេត្តនោះ ទេវតាទាំងឡាយក៏ គប្បីទទួលយកអំណាចនៃព្រះបរិត្តបាន ។ ព្រះមានព្រះភាគទ្រង់ឃើញប្រពៃ ក្នុង

ការប្រើសូរសៀងពន្យល់ឲ្យដឹង និងឲ្យឃើញព្រះរូបរបស់ព្រះអង្គឯង ក្នុងខណៈជាមួយគ្នានោះៗ ឯង ត្រាស់ពាក្យថា **យាវតា វា បន អាកង្ខេយ្យ** ( ឬថា តថាគតប្រាថ្នានឹងដឹងត្រឹមប៉ុនណាដូច្នេះជាដើម ទ្រង់សំដៅយកខេត្តដែលជាវិស័យខេត្ត ។ បទថា **យត្ថ** មានន័យថា ជាវិស័យខេត្តដែលមានបរិមាណមិនមានទីបំផុត ។ ឈ្មោះថា ព្រះតថាគតទ្រង់ប្រាថ្នាវត្ថុណាៗ ក៏ទ្រង់ជ្រាបវត្ថុនោះៗ បាន ក៏ព្រោះសេចក្ដីដែលព្រះពុទ្ធញ្ញាណប្រព្រឹត្តទៅទាក់ទងដោយហេតុត្រឹមតែថា មានព្រះបំណងប៉ុណ្ណោះ ។ ពាក្យថា **កាលនឹងតាំងឡើង** បានដល់ កាលនឹងចម្រើន គឺ កាលនឹងកើត ។

ពាក្យថា **ត្រឹមតែគោស៊ីបាន** គឺមានប្រវែងដែលគោអាចនឹងគប្បីខាំស៊ីបាន ។ បទថា **យំ** បានដល់ **យស្មឹ សមយេ** ( ក្នុងសម័យណា ) ។ ភ្ជាប់សេចក្ដីថា **បុប្ផផលឧបជីវិនិយោ ច ទេវតា ព្រហ្មលោកេ និព្វត្តតិ** ( ទេវតាទាំងឡាយអ្នកអាស្រ័យផ្កា និងផ្លែឈើចិញ្ចឹមជីវិត រមែងកើតក្នុងព្រហ្មលោក ) ។

បទថា **ឯតេសំ - បណ្ដាសត្វពួកនេះ** បានដល់ បណ្ដាសត្វដែលបានពោលដល់ដោយពាក្យថា អ្នកអាស្រ័យភ្ញៀងចិញ្ចឹមជីវិតជាដើម ។ បទថា **តត្ថ** បានដល់ក្នុងព្រហ្មលោក ។ ក៏ព្រហ្មលោកនោះឯង គប្បីឃើញថា ជាព្រហ្មលោកជាន់បរិត្តាភាជាដើម ។ លោកអាចារ្យកាលពោលថា កើតឡើងក្នុងព្រហ្មលោកបាន ដោយអំណាចនៃឈានដែលមកបានក្នុងទេវលោក ហើយប្រាថ្នាសម្ដែងការដែលកើតការបានមកនូវឈាន ទើបពោលថា ពិតមែន ក្នុងពេលនោះដូច្នេះជាដើម ។ ទេវតាឈ្មោះថា **លោកព្យូហ** ព្រោះអត្ថថា គ្រប់គ្រង គឺ រក្សាលោក ។ បានឮមកថា មនុស្សទាំងឡាយ លុះបានឃើញទេវតាពួកនោះហើយ សូម្បីថា ឈរនៅ សូម្បីថា អង្គុយនៅក្នុងទីនោះៗ ក៏ជាអ្នកកើតការតក់ស្លុតចិត្ត និងដល់នូវការបង្រួនទៀល

ក្រាបនៅក្នុងទីជិតទេវតាទាំងនោះ ។ ឈ្មោះថា **ជាអ្នកលែងក្បាល** ក៏ព្រោះជាអ្នកដោះសំពត់ជូតក្បាល ។ ឈ្មោះថា **ជាអ្នករំសាយសក់** ក៏ព្រោះភាពជាអ្នកមានសក់របួត ទៅខាងនោះទៅខាងនេះ ។

ឈ្មោះថា **ទ្រង់ភេទជាមនុស្សអប្បលក្ខណៈយ៉ាងក្រៃលែង** ក៏ព្រោះភាពជាអ្នកមានចិត្ត មានតែការសោកសៅ ព្រោះការខ្លាចអំពីការវិនាសទៅនៃលោក ។ បទថា **មារិសា**-ពួកយើងអើយ ជាពាក្យបន្ទឺដោយសេចក្តីស្រឡាញ់( បិយវាចា ) របស់ពួកទេវតា ។ សួរថា ក៏ពួកទេវតាទាំងនេះ ដឹងដល់ការវិនាសកប្បបានយ៉ាងដូចម្តេច លោកអាចារ្យជាច្រើនប្រាប់ថា ទេវតាទាំងនោះត្រូវសភាពជាធម្មតារំឭកដាស់តឿន អាចារ្យមួយពួកពោលថា ព្រោះឃើញនិមិត្តដែលប្រាកដដូច្នោះ ។ មួយទៀតពោលថា ទេវតាទាំងនោះត្រូវពួកទេវតាដែលជាព្រហ្មប្រាប់ឲ្យដឹង ។

ពាក្យថា **បុណ្យទាំងឡាយ មានមេត្តាជាដើម** គឺជាបុណ្យថ្នាក់កាមាវចរទាំងឡាយ មានការមនសិការមេត្តាជាដើម ។ ពាក្យថា **ក្នុងទេវលោក** គឺក្នុងកាមទេវ-លោក ។ បានឮមកថា ឈានទាំងឡាយក្នុងវាយោកសិណ រមែងសម្រេចដល់ពួកទេវតាបានដោយងាយ ព្រោះមានភាពទម្លាប់ មានការកាន់យកខ្យល់ដែលជាបច្ច័យនៃសម្ផស្សដែលជាសុខ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ធ្វើបរិកម្មក្នុងវាយោកសិណហើយ ទើបបានឈានដូច្នេះ ។ ពាក្យថា **ចំណែកសត្វដទៃពីនោះ** លោកពោលសំដៅយកសត្វក្នុងអបាយ ។ បទថា **តត្ថ** បានដល់ ក្នុងទេវលោក ។

បទថា **ទុតិយោ សហរិយោ** បានដល់ ព្រះអាទិត្យដួងទី ២ ។ ពាក្យថា **សត្តសុរិយសូត្រ** បានដល់ ព្រះសូត្រសម្តែងពីការប្រាកដនៃព្រះអាទិត្យ ៧ ដួង ។

ពាក្យថា **ក្នុងព្រះអាទិត្យបកតិ** គឺក្នុងសុរិយវិមានដែលកើតឡើង មុនកាលអស់កប្ប ។ ក៏ក្នុងកាលអស់កប្ប សូម្បីសុរិយទេវបុត្រក៏ធ្វើឈានឲ្យកើតឡើង ហើយចូលដល់ព្រហ្មលោក ដូចជាកាមាវចរទេវតាពួកដទៃ ប៉ុន្តែព្រះអាទិត្យក៏នៅប្រព្រឹត្តទៅជាវត្ថុមានរស្មីផ្សាយទៅក្រៃលែង និងមានតេជៈដ៏ក្រៃលែង ។ អាចារ្យមួយទៀតពោលថា ព្រះអាទិត្យដួងដទៃនោះឯង រមែងកើតឡើង ធ្វើដួងនោះឲ្យអន្តរធានទៅ ។ ទន្លេទាំងនេះ គឺ គង្គា យមុនា សរភូ អចិរវតី មហី ឈ្មោះថា ទន្លេធំទាំង៥ ។ ពាក្យថា **ដែលជាដើមកំណើត** គឺដែលជាទីកើតឡើង។ ពាក្យថា **ស្រះហង្សបាតនៈ** លោកពោលដល់ស្រះមន្ទាកិនី ។

បទថា **ន សណ្ឋាតិ** ប្រែថា តាំងនៅមិនបាន ។

បទថា **បរិយាទិន្នសិនេហំ** ប្រែថា មានជ័រអស់ទៅ ។ សេចក្ដីថា បឋវីធាតុក្នុងទីនោះៗ នៅតាំងរួមគ្នាបាន ព្រោះត្រូវអាបោធាតុណាមួយសម្ព័ន្ធទុក ។ អាបោធាតុនោះ រមែងមានការអស់ទៅ ព្រោះព្រះអាទិត្យប្រាកដ ៦ ដួង ។ បទថា **យថាចិទំ** ប្រែថា ក៏ចក្កវាឡនេះប្រាកដយ៉ាងណា ។ ពាក្យថា **សូម្បីសែនកោដិចក្រវាឡក៏ប្រាកដដូច្នោះ** លោកបង្ហាញដល់ការវិនាសកប្បទាំងអស់ ដែលបានពោលទុកក្នុងទីនេះ ចាប់តាំងពីមានមហាភ្លៀងដែលធ្វើកប្បឲ្យវិបត្តិកើតឡើង ក្នុងសែនកោដិចក្កវាឡនោះ ។

ពាក្យថា **វិនាស** គឺ ខូចខាត ។ ពាក្យថា **វត្ថុដែលជាសង្ខារ** បានដល់សង្ខារដែលកើតឡើង ដែលមានប្រភេទជាភូតរូប និងឧបាទាយរូប ។ ពាក្យថា **ព្រោះសង្ខារទាំងពួងអស់ទៅ** គឺព្រោះសង្ខារទាំងពួងដែលគួរឆេះ អស់ទៅ ។ ក៏បណ្ដាភ្លើងនេះ តែងធ្វើវត្ថុដែលជាសង្ខារមិនឲ្យនៅសល់ សូម្បីត្រឹមតែផេះឡើយ ក៏

រមែងឈប់ស្ងប់ទៅ ព្រោះមិនមានអណ្ដាតភ្លើង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ក៏រមែងរលត់ទៅ ។ល។ ដូចអណ្ដាតភ្លើងដែលឆេះទឹកដោះថ្លា និងប្រេងដូច្នោះ ។

បទថា **ទីឃស្ស អទ្ធុនោ** ដោយការកន្លងទៅនៃកាលដ៏យូរលង់ដែលហៅថា សំវដ្តដ្ឋាយីអសង្ខេយ្យកប្ប ។ ដោយ**អាទិ**-ស័ព្ទក្នុងបទថា **តាលក្ខន្ធាទិ**-ដើមត្នោតជាដើម រួមយកដើមឈើ មានបន្ទៃ ដើមសាលៈជាដើម ។ ពាក្យថា **ធ្វើឲ្យជាដុំ** គឺ ធ្វើឲ្យរួមគ្នា មិនឲ្យបែកខ្ញែក ។ ព្រោះហេតុនោះ ទើបពោលថា មូលដូច្នេះ ។ បទថា **តំ** បានដល់ ទឹកដែលកាត់ដោយការៈដែលមូល ។ បទថា **អស្ស** បានដល់ **វាតស**-ដល់ខ្យល់នេះ ។ ពាក្យថា **រមែងឲ្យចន្លោះ** គឺ រមែងឲ្យចន្លោះក្នុងទីត្រង់នោះ ដោយប្រការដែលខ្យល់នឹងធ្វើឲ្យជាដុំ គឺរួមចូលគ្នាបាន ។ ពាក្យថា **អស់ទៅសន្សឹមៗ** គឺដល់នូវការអស់ទៅ ព្រោះត្រូវខ្យល់ដែលប្រមូលឲ្យជាដុំរួមគ្នាតាំងពីដើមមករហូតដល់ព្រហ្មលោក ធ្វើឲ្យហួតហែងទៅសន្សឹមៗ ។ ប្រកបសេចក្ដីថា **ព្រហ្មលោកោ បាតុភាវតិ** គឺ ព្រហ្មលោកក៏រមែងប្រាកដ ។ ពាក្យថា **ព្រហ្មលោក** លោកពោលដល់បឋមជ្ឈានភូមិ ។ ពាក្យថា **ត្រង់ទីដែលធ្លាប់មានកាមាចរទេវលោក ៤ ជាន់ខាងលើ** គឺត្រង់ទីដែលជាទីតាំងនៃកាមាវចរទេវលោក ៤ ជាន់ មានទេវលោកជាន់យាមាជាដើម ។ ក៏ទីដែលជាទីតាំងនៃភព ចាតុម្មហារាជិកា និងភពតាវត្តិង្សនៅមិនប្រាកដទេ ព្រោះជាភពដែលនៅជិតនឹងផែនដី ។ ពាក្យថា **ទ្រទ្រុក** គឺ ធ្វើមិនឲ្យហូរចុះក្រោម ។ ពាក្យថា **អ្នកកើតមុនគេនេះ** ជាពាក្យសម្ដែងសេចក្ដីមានការអស់អាយុ ដោយពាក្យថា អ្នកកើតឡើងមុនគេនោះ លោកសម្ដែងថា ជាសត្វអ្នកកើតឡើងក្នុងពេលដើមនៃកប្ប២ , កប្ប៤ ឬថា កប្ប៨ ។

បទថា **តតោ** គឺ ឃ្លាតចាកព្រហ្មលោកជាន់អកសុរា ។ សូម្បីជាន់បរិត្តាភា និងជាន់អប្បមាណាភា ក៏រមែងដល់នូវការរួមចូលជាមួយសព្ទថា អាភស្សរា នោះឯង ។ ពាក្យថា **សត្វទាំងនោះជាអ្នកមានរស្មីក្នុងខ្លួនឯង ត្រាច់ទៅក្នុងកណ្តាលវេហាស៍** នេះលោកពោលទុកដោយភាពជាអានុភាពដ៏ធំធេងនៃបុណ្យ គឺ ឧបចារឈាន ។ បទថា **អាលុប្បការកំ** លោកអាចារ្យជាច្រើនពោលថា បានដល់ ធ្វើឲ្យជាពំនូតៗ មានសេចក្តីថា ធ្វើឲ្យជាពំនូតធំ ពំនូតតូច ។

ពាក្យថា **ជាអ្នករីករាយត្រេកអរ** គឺជាអ្នករីករាយដល់នូវការសប្បាយចិត្តយ៉ាងក្រៃលែង ។ ពាក្យថា **នាំគ្នាតាំងឈ្មោះ** គឺ នាំគ្នាហៅយ៉ាងនោះ ។

ក្នុងពាក្យថា ភ្នំសិនេរុ ភ្នំចក្កវាឡ និងភ្នំហិមពាន្តនេះ ពាក្យថា សូម្បីទ្វីបសមុទ្រក៏គួរពោលទុកដែរ ។ ពិតយ៉ាងនោះ លោកនឹងពោលថា ត្រង់ទីខ្ពង់ៗ ចុះទៅ ក៏ជាសមុទ្រ ត្រង់ទីរាបៗ ក៏ជាទ្វីបដូច្នេះ ។ បទថា **ថូបថូបា-ទីទួល** ។

បទថា **អតិមញ្ញន្តិ** គឺ មើលងាយ ឬ បន្តុះបង្អាប់ មានសេចក្តីថា មើលងាយមើលថោក ។ ពាក្យថា **តាមន័យនោះៗ ឯង** គឺតាមន័យដែលបានពោលទុកដោយពាក្យថា ពួកខ្លះក៏ជាអ្នកមានពណ៌សម្បុរល្អជាដើម ។ បទថា **បទាលតា** បានដល់ វល្លិដីមួយប្រភេទដែលឈ្មោះថាយ៉ាងនេះ ។ លោកអាចារ្យជាច្រើនពោលថា បានឮមកថា ដីនោះក៏មានវល្លិ គឺជារបស់ត្រាំនៅត្រង់ប្រាំងទឹកមួយប្រភេទ ។ ស្រូវសាលីឈ្មោះថា ដុះនបានដោយមិនបាច់ប្រើឧស ព្រោះក្នុងភូមិប្រទេសដែលមិនមានឧស ក៏ដុះនបាន ។ បទថា **អកណោ** បានដល់ ប្រាសចាកសំបក ។

សដូចផ្កាឈើមួយប្រភេទដែលហៅថាផ្កាម្ទិះ ។ បាយឆ្ងាញ់ឈ្មោះថា **យំ យំ រសោ** គឺបាយរសឆ្ងាញ់ឯណាៗ ព្រោះអត្ថថា មានរសណាៗ បានដល់ ជាអ្នកត្រូវ

ការនឹងបរិភោគបាយរសឆ្ងាញ់នោះ មានសេចក្តីថា បាយឆ្ងាញ់ដែលមានរសយ៉ាងណា ៗ ក្រមដី បំណែកដី និងវល្លិដីដែលសត្វទាំងឡាយបរិភោគហើយ រមែងតាំងនៅ បន្ទាប់ការស្រែកឃ្លានបានហើយ ក៏បានចម្រើនឡើងដោយរសនោះឯងដែលជ្រាបទៅតាមសរសៃនាំរស ដូចសុធាហារ( អាហារទិព្វ ) ដូច្នោះ, ជារបស់ភាវល្អិត ព្រោះវត្ថុល្អិតនោះ ជាអាហារត្រូវរំលាយដោយភ្លើងធាតុ ដោយភាពជាឱជាដ៏ភាវ និងល្អិតនោះឯង ។ ចំណែកបាយដែលសត្វបរិភោគ សូម្បីថា បរិបូរណ៍ដោយរស ក៏នៅបញ្ចេញរបស់ភាវចេញមក ព្រោះជារបស់គ្រោតគ្រាត ធ្វើឲ្យកើតបស្សាវៈ និងកាកសំណល់ឡើង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ចាប់ផ្តើមអំពីនោះ មូត្រ និងករីសៈក៏កើតឡើងដូច្នេះ ។ ដរាបណាដែលកម្លាំងនៃការសង្កត់សង្កិនកាមរាគៈក្នុងសន្តានរបស់សត្វ ដោយអានុភាពនៃឧបចារឈានដែលប្រព្រឹត្តទៅក្នុងអត្តភាពមុនៗ មិនទាន់ស្ងប់ ដរាបនោះឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយដែលមានកាមរាគៈដ៏ក្រាស់ជាឧបនិស្ស័យ ក៏ប្រាកដមិនបាន ។ តែថា ក្នុងពេលណាកាមរាគៈដ៏ក្រាស់កើតមានបាន ដោយអំណាចសត្វនោះ មិនទាន់បានលះបង់ក្នុងពេលឥន្ទ្រិយទាំងនោះ ដែលមានកាមរាគៈដ៏ក្រាស់នោះជាឧបនិស្ស័យ ក៏កើតឡើងក្នុងអត្តភាពរបស់សត្វទាំងឡាយបាន ។ ព្រោះដូច្នោះ ទើបលោកពោលថា ភាវៈដែលជាបុរសនៃបុរស ក៏កើតប្រាកដឡើងដូច្នោះ ព្រោះហេតុនោះឯង ទើបលោកពោលថា បណ្តាបុរស និងស្ត្រីនោះ លោកពោលដូច្នេះជាដើម ។

ពាក្យថា **មនុស្សអ្នកមានជាតិខ្ជិលច្រអូស** គឺមនុស្សអ្នកមានជាតិខ្ជិលច្រអូសដោយការដែលមិនកាន់យកអង្ករសម្រាប់តែថ្ងៃនេះប៉ុណ្ណោះ ត្រឡប់កាន់យកដើម្បីប្រយោជន៍ថ្ងៃដទៃ ។

ពាក្យថា **ត្អូញត្អែរ** បានដល់ សោកសៅរឿយៗ ។ ពាក្យថា **គប្បីសម្មតិ** បានដល់ គប្បីឃើញត្រូវ ។ បទថា **នោ** ប្រែថា ក្នុងក្រុមពួកយើង ។ បទថា **សម្មា** បានដល់ ដោយប្រពៃនោះឯង គឺតាមសមគួរ ។ ពាក្យថា **អ្នកគប្បីតិះដៀល** បានដល់ អ្នកដែលគេគប្បីតិះដៀល គឺ គួរជេរស្តី ។ ពាក្យថា **អ្នកគប្បីទិតៀន** បានដល់ គួរមើលងាយ ។

សេចក្តីប្រកបថា **អយមេវ ភគវា បដិពលោ និគ្គហបគ្គហំ កាតុំ** ( ព្រះមានព្រះភាគ ទ្រង់ជាអ្នកអាចគ្របសង្កត់ និងលើកតម្កើង ។ ពាក្យថា **ទ្រង់ញុំាងឲ្យត្រេកអរ** គឺ ទ្រង់ញុំាងឲ្យរីករាយ បានដល់ ឲ្យឆ្អែតឆ្អន់ដោយប្រពៃនោះឯង ដោយសង្គហវត្ថុទាំងឡាយ ។ វិវដ្តដ្ឋាយីអសង្ខេយ្យកប្ប មានការសង្គ្រោះបានដោយ ៦៤ អន្តរកប្ប ។ អាចារ្យពួកខ្លះពោលថា មានការសង្គ្រោះបានដោយ ២០ អន្តរកប្ប ។ អសង្ខេយ្យកប្បដ៏សេសមានប្រមាណប៉ុនគ្នា ដោយកាល និងអន្តរកប្បនោះ ។

ពាក្យថា **ជាតំណក់** គឺជាដំណក់ទឹកក្រុតធំ មានខ្នាតប៉ុនដើមត្នោត និងដើមសាលៈជាដើម ។ ពាក្យថា **ដោយជុំវិញ** គឺដោយគ្រប់ចំណែក ។ ពាក្យថា **តាំងពីផែនដី** គឺផ្តើមតាំងពីចំណែកខាងក្រោមនៃផែនដី ។ អាចារ្យពួកខ្លះពោលថា វត្ថុទាំងឡាយ មានផែនដី ភ្នំជាដើម ត្រូវទឹកក្រុតនោះពាល់ត្រូវហើយ ក៏រមែងរលាយទៅតែម្តង ដូចអំបិល ឬស្ករត្នោត ដែលគេដាក់ទៅក្នុងទឹក , ព្រោះដូច្នោះ ទឹកក្រុតនោះទើបលាយចូលជាមួយគ្នានឹងទឹកទ្រផែនដី ដូច្នេះ ។ អាចារ្យមួយពួកទៀតពោលថា ទឹកក្រុតធ្វើផ្ទៃទឹកដែលទ្រផែនដីទុក និងធ្វើគំនរខ្យល់ដែលទ្រទឹកទុកឲ្យវិនាសទៅដោយមិនសល់ ហើយតាំងនៅជាអន្លង់ទឹកមួយដោយខ្លួនឯងតែម្តង គ្រប់

ទឹកនៃទន្លេនដូច្នេះ, ពាក្យដែលពោលនោះត្រឹមត្រូវហើយ ។ ពាក្យថា **ព្រហ្មលោកទាំងបីជាន់** បានដល់ ព្រហ្មលោកជាន់បរិត្តាភា ជាន់អប្បមាណាភា និងជាន់អាភស្សរា។ ពាក្យនេះនោះ លោកអាចារ្យពោលទុក ព្រោះលោកបានផ្ដើមទុកហើយថា ចំណែកតទៅនេះជាសេចក្ដីផ្សេងគ្នា ដូច្នេះ ។ ប្រសិនបើនឹងកាន់យកសេចក្ដីដោយប្រការដទៃ ក៏គប្បីមានការត្រូវពោលថា ព្រហ្មលោកទាំង ៦ ជាន់ដូច្នេះ , មានការផ្ដោះកំណត់យកព្រហ្មលោកជាន់តតិយជ្ឈានភូមិទុក ដោយពាក្យដែលសម្ដែងខែទុកដ៏យ៉ាងខ្ពង់ខ្ពស់ថា **សុភកិណ្ហា** ។ ព្រោះថា ទឹករមែងតាំងនៅទល់នឹងព្រហ្មលោកជាន់បរិត្តសុភា និងជាន់អប្បមាណាភាដែរ ។ សូម្បីក្នុងពាក្យថា ជាប់ដល់ជាន់អាភស្សរាហើយទើបឈប់ ក្នុងខាងក្រោយ នេះក៏មានន័យដូច្នេះដែរ គឺ រហូតដល់ជាន់បរិត្តាភា និងជាន់អប្បមាណសុភា ។ បទថា **តំ** បានដល់ ទឹកដែលធ្វើកប្បឲ្យវិនាសនោះ ។ បទថា **ឧទកានុគតំ** គឺ វត្ថុដែលជាសង្ខារ ដែលត្រូវទឹកជាប់តាមបានដល់ ត្រូវទឹកសម្ពស្ស ។ ពាក្យថា **គ្របសង្កត់** បានដល់ ធ្វើឲ្យរលាយទៅ ។

ពាក្យថា **នេះជាអសង្ខេយ្យមួយ** គឺនេះហៅថា អសង្ខេយ្យមួយនៃកប្បដែលហៅថា **សំវដ្ដ** ។

កាលធូលីគ្រោតគ្រាតប្រាសទៅហើយនោះឯង ធូលីល្អិតដែលជាប់នៅនឹងដីទើបនឹងប្រាសទៅបាន ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **តតោ សណ្ហរជំ** មានការភ្ជាប់នឹងបទថា **សមុដ្ឋាបេតិ** ( ទៅជា **តតោ សណ្ហរជំ សមុដ្ឋាបេតិ** ) ប្រែថា បន្ទាប់ពីនោះ ទើបបក់យកផង់ធូលីឡើងទៅ ។ ពាក្យថា **ដើមឈើធំដែលដុះនៅក្នុងទីរដិបរដុបនេះ** លោកពោលសំដៅយកភាពជាវត្ថុដែលខ្យល់គប្បីបក់ឡើងទៅមុន ( ផែនដី ភ្នំជាដើម ) ។

ពាក្យថា **ទាំងភ្នំចក្កវាឡ ទាំងភ្នំសិនេរុ** មានសេចក្តីថា ខ្យល់ក្តួចយកទាំងភ្នំចក្កវាឡ ទាំងភ្នំសិនេរុឲ្យត្រឡប់ទៅហើយ តាមការត្រឡប់ទៅនៃផែនដីធំ ឡើងទៅ ហើយបន្សាត់ទៅក្នុងអាកាស ។ ពាក្យថា **វត្ថុទាំងនោះ** បានដល់ វត្ថុទាំងឡាយ មានភ្នំចក្កវាឡជាដើម ។ បទថា **អភិហន្ត្វា** ប្រែថា ទង្គិច ។ ពាក្យថា **នូវគ្នានិងគ្នា** មានន័យថា ទង្គិចគ្នាដោយការប៉ះគ្នានិងគ្នាយ៉ាងនេះ គឺ ភ្នំចក្កវាឡ ភ្នំហិមពាន្ត និងភ្នំសិនេរុរបស់លោកធាតុមួយ ទង្គិចគ្នានិងគ្នាជាមួយនឹងភ្នំចក្កវាឡជាដើមនៃលោកធាតុដទៃដូច្នេះ ។ ពាក្យថា **ធ្វើវត្ថុដែលជាសង្ខារទាំងពួងឲ្យវិនាស** មានសេចក្តីថា ធ្វើវត្ថុដែលជាសង្ខារទាំងពួង គឺ ទឹកដែលទ្រផែនដី និងខ្យល់ទ្រទឹកនោះឲ្យវិនាសទៅ សូម្បីខ្លួនក៏វិនាសទៅ ព្រោះមិនមានហេតុដែលជាទីតាំង ។

លោកអាចារ្យធ្វើទុកក្នុងចិត្តថា ការរលត់ទៅតាមសភាវៈរបស់ខ្លួននៃសង្ខារទាំងឡាយ មិនមានហេតុ ព្រោះមិនមានអ្នកធ្វើឲ្យវិនាសក៏ពិត សូម្បីយ៉ាងនោះ ការរលត់ទៅនៃការជាប់តគ្នា( នៃសង្ខារទាំងឡាយ ) ដែលប្រាសចាកហេតុមិនមានប្រការនោះក៏ដូចនឹងការរលត់ទៅនៃការជាប់តគ្នាក្នុងពួកសត្វទាំងឡាយ ព្រោះហេតុនោះ ការរលត់ទៅនៃភាជនៈលោក( ឱកាសលោក ) ក៏គួរជាវត្ថុមានហេតុ ដូច្នេះហើយ ទើបសួរដល់ហេតុថា លោកវិនាសទៅយ៉ាងនេះ ព្រោះអ្វីជាហេតុ ដូច្នេះ ។ លោកអាចារ្យដទៃ កាលនឹងសម្តែងថា ដំបូងលោករមែងចម្រើន ព្រោះកម្លាំងនៃបុណ្យរបស់សត្វអ្នកកើតឡើងក្នុងទីនោះ យ៉ាងណា ក៏រមែងសាបសូន្យទៅ ព្រោះកម្លាំងនៃបាបរបស់សត្វទាំងនោះ ដូច្នេះ ដូចនេះទើបពាក្យថា ព្រោះអកុសលមូលជាហេតុ ដូច្នេះ ។ លោកអាចារ្យកាលសម្តែងថា អន្តរកប្ប ៣ យ៉ាងពួកនេះ គឺ

រោគអន្តរកប្ប សត្ថអន្តរកប្ប ទុភិក្ខអន្តរកប្ប រមែងកើតបានក្នុងវិវដ្ដដ្ឋាយី-អសង្ខេយ្យកប្ប ព្រោះការដែលរាគៈ ទោសៈ និងមោហៈកាន់តែក្រាស់ឡើងជាលំដាប់ យ៉ាងណា ការវិនាស ៣ យ៉ាង មានការវិនាសព្រោះភ្លើងជាដើម តាមដែលពោលមកហើយទាំងនេះ រមែងមានបាន ព្រោះសេចក្ដីដែលអកុសលមូលមានរាគៈជាដើមកាន់តែក្រាស់ឡើងនោះឯង ។ ទើបពោលថា សេចក្ដីពិតថា កាលអកុសលមូលទាំងឡាយ ដូច្នេះជាដើម ។ ពាក្យថា **កាន់តែក្រាស់ឡើង** គឺ កាន់តែក្រាស់ហួសនឹងប្រៀបបាន ។ កាលទោសៈកាន់តែក្រាស់ឡើង ក៏សមគួរវិនាសដោយទឹកក្រុតដ៏ខ្លាំងក្លា ដូចទោសៈកាន់តែក្រាស់ឡើងដូច្នោះ ។ ព្រោះហេតុនោះទើបលោលពោលថា កាលទោសៈក្រាស់ជាង រមែងវិនាសទៅព្រោះទឹក ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបអធិប្បាយនៃវាទៈ របស់លោកអាចារ្យទាំងឡាយពួកខ្លះថា កាលទោសៈក្រាស់ក្រៃលែងជាង រមែងវិនាសទៅព្រោះភ្លើង កាលរាគៈក្រាស់ក្រៃលែងជាង រមែងវិនាសទៅព្រោះទឹកដូច្នេះ បានដោយអត្ថន័យរបស់លោកថា ភាវៈដែលទោសៈដូចជាសត្រូវប្រាកដ បង្ហាញខ្លួនដូចជាភ្លើង , និងភាវៈដែលរាគៈដូចសត្រូវមិនប្រាកដ( មិនបង្ហាញខ្លួន ) ដូចគ្នានឹងទឹកក្រុតសមគួរហើយ ។ រាគៈរមែងប្រព្រឹត្តទៅច្រើនដល់សត្វទាំងឡាយ ព្រោះហេតុនោះ ការវិនាសទៅនៃលោក រមែងមានដោយអំណាចនៃរាគៈដោយច្រើន ។

លោកអាចារ្យកាលប្រកាសកប្បទាំងឡាយ មានសំវដ្ដកប្បជាដើម តាមសេចក្ដីជាប់តគ្នាយ៉ាងនេះហើយ ឥឡូវនេះប្រាថ្នាសម្ដែងអាការតាមរឭកនៃភិក្ខុអ្នកមានឫទ្ធិទាំងនោះ តាមដែលបានសម្រេចហើយ ទើបផ្ដើមពាក្យថា សូម្បីកាលនឹងតាមរឭកដល់បុព្វេនិវាសដូច្នេះជាដើម ។

ក្នុងពាក្យថា ក្នុងសំវដ្ដកប្បនោះ នេះលោកអាចារ្យពោលទុកក្នុងព្រះបាលីក៏បានកាន់យកសំវដ្ដកប្បមកតាំងពីផ្ដើមៗ ពិតមែន សូម្បីក្នុងសំវដ្ដកប្បនោះ ភិក្ខុអង្គនេះក៏បានត្រាច់ទៅក្នុងឱកាសទាំងឡាយ មានភពជាដើមអស់កាលបន្តិចបន្តួចដូច្នេះៗ ម្យ៉ាងទៀត កាលឱកាសទាំងឡាយ មានភពជាដើមប្រព្រឹត្តទៅក្នុងសំវដ្ដកប្ប ភិក្ខុអង្គនេះក៏បានឧប្បត្តិ , គប្បីឃើញថា ប្រការដែលពោលនោះ មានរឿងបង្ហាញឲ្យឃើញបាន ។ ន័យម្យ៉ាងទៀត គប្បីឃើញថា ក្នុងបទថា **អមុត្ថិ សំវដ្ដកប្បេ**-ក្នុងសំវដ្ដកប្បនោះ នេះបានសម្ដែង **វា**-សព្ទ ទុកដោយជាសព្ទដែលលុបចោល , ក៏ដោយ **វា**-សព្ទមានអត្ថថា មិនកំណត់ពិតប្រាកដ ( ប្រែថា ឬ , ឬថា )នុ៎ះ ជាការសម្រេច ការរួមយក សូម្បីអសង្ខេយ្យកប្បទាំងឡាយក្រៅពីនេះ ។ ក្នុងបទថា **ភវេ វា** ជាដើម មានសេចក្ដីថា ក្នុងភព មានកាមភពជាដើម ឬ ក្នុងកំណើតមានអណ្ឌជកំណើតជាដើម ឬ ក្នុងគតិ មានទេវគតិជាដើម ឬ ក្នុងវិញ្ញាណដ្ឋិតិ ឬ ក្នុងសត្តាវាស មាននានត្តកាយនានត្តសញ្ញីជាដើម ឬ ក្នុងសត្តនិកាយ មានខត្តិយនិកាយជាដើម ។ បទថា **អាសិ** ប្រែថា បានមានហើយ ។ ដោយ**វា**-សព្ទក្នុងបទថា **វណ្ណសម្បត្តី វា**( ការដល់ព្រមដោយពណ៌សម្បុរក្ដី ) រមែងសម្ដែងដល់បទថា **វណ្ណវិបត្តី វា** ការវិបត្តិនៃពណ៌សម្បុរក្ដីទុក ។ ភិក្ខុឈ្មោះថា ជាអ្នកមានស្រូវសាលី សាច់ ឬបាយជាអាហារក្នុងកាលដែលនៅជាគ្រហស្ថខ្វះ ឈ្មោះថាជាអ្នកមានផ្លៃឈើដែលប្រព្រឹត្តទៅជារបស់ស៊ី ក្នុងកាលនៅជាតាបសខ្វះជាដើម ។ សោមនស្សជាដើម ដែលអាស្រ័យផ្ទះ ឈ្មោះថា លាយដោយអាមិស ។ ដែលអាស្រ័យនេក្ខម្មៈឈ្មោះថា មិនលាយដោយអាមិស ។ ដោយ**អាទិ**-សព្ទ ( ប្រែថា ជាដើម ) មានការរួមយកសុខដែលកើតអំពីវិវេក និងដែលកើតអំពីសមាធិជាដើម

ជាដើមផង ។

លោកអាចារ្យកាលសម្ដែងការតាមរឭក តាមដែលត្រូវការទាំងពួង ដោយពាក្យថា **អមុត្រាសឹ**( យើងបានកើតហើយក្នុងទីនោះ ) ដូច្នេះជាដើមហើយ ឥឡូវនេះ ប្រាថ្នានឹងសម្ដែងសេចក្ដីដោយប្រការដទៃ ទើបពោលថា **អបិ ច** ន័យម្យ៉ាងទៀត ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អមុត្រាសឹ** ( យើងបានកើតហើយក្នុងទីនោះ ) នេះជាពាក្យសម្ដែងខែសាមញ្ញ ។ ឬថា ជាពាក្យសម្ដែងខែដែលមានការលុបបទដែលប្រាថ្នានឹងនិយាយផ្ទួន , គឺជាការត្រាស់ទុកថា **អមុត្រ អមុត្រ អាសឹ** ( យើងបានកើតហើយក្នុងទីនោះ ក្នុងទីនោះ ) ។ ក្នុងពាក្យថា ការតាមរឭកតាមដែលត្រូវការ នៃភិក្ខុអ្នកឈានឡើងតាមលំដាប់នេះ ពាក្យថា **នៃភិក្ខុអ្នកឈានឡើង** គឺ ភិក្ខុអ្នកនឹងឈានឡើងកាន់បុព្វេនិវាស ដោយញាណដោយបដិលោម ។ ពាក្យថា **ការពិចារណា** បានដល់ ការពិចារណាបុព្វេនិវាសដែលបានតាមរឭកហើយ តាមរឭកទៀត ។ មិនមែនការតាមរឭក ។ ស័ព្ទថា **ឥតិ** ជាពាក្យសម្ដែងសេចក្ដីដែលបានពោលហើយ ។ លោកអាចារ្យកាលនឹងសម្ដែងថា ក៏ពាក្យថា ព្រមទាំងឧទ្ទេស ព្រមទាំងអាការនោះឯង ត្រាស់ទុកព្រោះជាភាវៈដែលមានតាមសមគួរ ។ មិនមែនត្រាស់ទុកដោយភាវៈដែលមានតាមលំដាប់ទេ ទើបពោលថា ( សេចក្ដីថា ឈ្មោះថា ព្រមទាំងឧទ្ទេស ) ក៏ដោយទាក់ទងនឹងឈ្មោះ នឹងគោត្រ ដូច្នេះជាដើម ។ ពាក្យថា **ប្រការដទៃ មានពណ៌សម្បុរជាដើម** បានដល់ ប្រការដទៃ គឺ ពណ៌សម្បុរ អាហារ វេទនា កំណត់អាយុ ។

**ឥតិ**-ស័ព្ទ ក្នុងបទថា **ឧទាតោតិ** នេះ មានអត្ថថា **អាទិ** គឺ មនុស្សជាដើម

ឬមានអត្ថថា ប្រការ , ដោយ ឥតិ-ស័ព្ទ ជាដើម ត្រូវលោកសម្ដែងថា រមែងប្រាកដដោយភាពផ្សេងគ្នា មានអាទិយ៉ាងនោះ មានប្រការយ៉ាងនេះ ។

( ចប់ មហាដីកា )

( ចប់ការពណ៌នាកថា ស្ដីពីបុព្វេនិវាសានុស្សតិញ្ញាណ )

# ចុតូបបាតញ្ញាណ

*ពណ៌នាសេចក្ដីក្នុងរឿងការដឹងចុតិ និងឧបបាតៈនៃសត្វទាំងឡាយ គប្បីជ្រាបដូចតទៅនេះ :*

## អធិប្បាយអត្ថបាលី ចុតូបបាតញ្ញាណ

*ពាក្យថា **ដើម្បីចុតូបបាតញ្ញាណ** គឺដើម្បីការដឹងក្នុងចុតិ និងឧបបាតៈ មានអត្ថាធិប្បាយថា ចុតិ និងបដិសន្ធិនៃសត្វទាំងឡាយ ដែលព្រះយោគាវចរដឹងបានដោយញាណឯណា ដើម្បីញាណនោះ គឺដើម្បីទិព្វចក្ខុញ្ញាណ , ពាក្យថា **នាំចិត្តឆ្ពោះទៅ បង្អោនចិត្តទៅកាន់** បានដល់ ការនាំបរិកម្មចិត្តទៅ និងបង្អោនបរិកម្មចិត្តទៅ , ពាក្យថា **សោ** គឺ ភិក្ខុអ្នកមានការនាំ ចិត្តឆ្ពោះទៅ បានធ្វើមកហើយនោះ ចំណែកក្នុងពាក្យទាំងឡាយ មានពាក្យថា **ទិព្វេន** ( ជា **ទិព្វ** ) ជាដើម មានការពណ៌នាដូច្នេះ :*

## ទិព្វចក្ខុ

***ចក្ខុ** ឈ្មោះថាជា **ទិព្វ** ព្រោះដូចជារបស់ទិព្វ ពិតមែន បសាទចក្ខុរបស់ទេវតាទាំងឡាយ ជាធម្មជាតិកើតដោយកម្មជាសុចរិត ទោសទាំងឡាយ មានទឹកប្រមាត់ ស្លេស្ម និងឈាមជាដើមមិនរារាំង អាចទទួលអារម្មណ៍សូម្បីក្នុងទីឆ្ងាយបាន ព្រោះផុតចាកទោសដែលជាគ្រឿងសៅហ្មងទើបជាទិព្វ សូម្បីញាណចក្ខុដែលកើតព្រោះកម្លាំងនៃវិរិយភាវនានេះសោត ក៏ដូច្នោះដូចគ្នា ព្រោះហេតុនោះ ទើបថាជាទិព្វ ព្រោះដូចជារបស់ទិព្វ , ន័យមួយទៀត ឈ្មោះថាជា **ទិព្វ** ព្រោះបានមកចំពោះដោយអំណាចទិព្វវិហារ ( ឈានដែលជាបាទ ) និងព្រោះអាស្រ័យទិព្វវិហារ*

របស់ខ្លួន គឺ អាស្រ័យទិព្វវិហារជានិស្សយបច្ច័យខ្លះ ឈ្មោះថាជា **ទិព្វ** ព្រោះមានពន្លឺដ៏រុងរឿង ព្រោះកំណត់អាលោកកសិណបានមកខ្លះ ឈ្មោះថាជា **ទិព្វ** ព្រោះការមានទីទៅជាធំ ព្រោះឃើញរូបដែលនៅក្នុងទីកំបាំង មានទីក្រៅជញ្ជាំងជាដើមបានខ្លះ , ពាក្យថា **ទិព្វទាំងពួងនោះ** បណ្ឌិតគប្បីជ្រាបអត្ថតាមគម្ពីរស័ព្ទសាស្ត្រនោះចុះ ។

ញាណនោះ ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា **ឃើញ** , មួយទៀត ឈ្មោះថា **ចក្ខុ** ព្រោះប្រាកដដូចភ្នែក ព្រោះធ្វើកិច្ចរបស់ភ្នែក គឺ ឃើញ ។

ញាណ ឬ ចក្ខុនោះ ចាត់ថា ហ្មត់ចត់ ព្រោះជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយការឃើញទាំងចុតិ និងឧបបាតៈ ព្រោះថា បុគ្គលណាឃើញតែចុតិតែម្យ៉ាង មិនឃើញឧបបាតៈ បុគ្គលនោះរមែងប្រកាន់យកឧច្ឆេទទិដ្ឋិ( ការឃើញថា ដាច់សូន្យ ) បុគ្គលណាឃើញឧបបាតៈតែម្យ៉ាង មិនឃើញចុតិ បុគ្គលនោះរមែងប្រកាន់ដោយសស្សតទិដ្ឋិ គឺការឃើញថាទៀង ព្រោះក្នុងការកើតប្រាកដឡើងនៃសត្វថ្មី , ចំណែកបុគ្គលណាឃើញទាំងពីរខាងនោះ បុគ្គលនោះព្រោះឈានកន្លងនូវការឃើញខុស បានទាំងពីរ ការឃើញរបស់គេនោះ ទើបជាហេតុនៃទិដ្ឋិវិសុទ្ធិដែលភិក្ខុពុទ្ធបុត្រទាំងឡាយរមែងឃើញចុតិ និងឧបបាតៈនោះបានទាំងពីរជាពិតប្រាកដ ព្រោះហេតុនោះ ទើបថា ញាណ ឬ ចក្ខុនោះ ចាត់ថា ហ្មត់ចត់ ព្រោះជាហេតុនៃទិដ្ឋិវិសុទ្ធិ ដោយការឃើញទាំងចុតិ និងឧបបាតៈដូច្នេះ , ញាណចក្ខុនោះ បណ្ឌិតគប្បីឃើញថា កន្លងចក្ខុរបស់មនុស្ស ព្រោះឃើញរូបបានកន្លងឧបចាររបស់មនុស្សទៅបាន ឬថា កន្លងចក្ខុរបស់មនុស្ស ព្រោះដុំភ្នែកសាច់ជារបស់មនុស្ស ( គឺ សេចក្តីនៃបាលីពេលនេះក៏ថា ឃើញ ) ដោយចក្ខុទិព្វដ៏ហ្មត់ចត់កន្លងចក្ខុរបស់មនុស្ស ដូចអត្ថាធិប្បាយមក

នោះ ។

ពាក្យថា **រមែងឃើញសត្វទាំងឡាយ** គឺមើលឃើញសត្វទាំងឡាយ ដូចជាឃើញដោយភ្នែកសាច់របស់មនុស្ស ក្នុងពីរពាក្យថា **ចវមានេ ឧបបជ្ជមានេ** ដែលកំពុងចុតិ កំពុងឧប្បត្តិនោះ មានអត្ថាធិប្បាយថា ក្នុងខណៈចុតិក្តី ក្នុងខណៈឧប្បត្តិក្តី មិនអាចឃើញសូម្បីដោយទិព្វចក្ខុ តែសត្វពួកណាជិតនឹងចុតិ ពោលបានថា នឹងចុតិឥឡូវនេះ សត្វពួកនោះ ព្រះមានព្រះភាគទ្រង់បំណងយកថា កំពុងចុតិ និងសត្វពួកណាកាន់យកបដិសន្ធិហើយ ពោលបានថា កើតឥឡូវនេះ សត្វពួកនោះ ទ្រង់បំណងយកថា កំពុងឧប្បត្តិ ដោយបទទាំងពីរនោះ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីថា ភិក្ខុនោះរមែងឃើញសត្វទាំងឡាយ ដែលកំពុងចុតិ និងកំពុងឧប្បត្តិ ដូចដែលទ្រង់បំណងយកនោះ ។

ពាក្យថា **ហីនេ**-ថោកទាប គឺ ដែលគេតិះដៀល មើលងាយដោយអំណាចនៃឋានៈ មានជាតិត្រកូល និងភោគៈជាដើម ដែលរាប់ថា ថោកទាប ព្រោះប្រកបដោយផលនៃមោហៈ , ពាក្យថា **បណីតេ**-ប្រណីត គឺផ្ទុយគ្នានឹងថោកទាប ព្រោះប្រកបដោយផលនៃអមោហៈ , ពាក្យថា **សុវណ្ណេ**-ពណ៌សម្បុរល្អ គឺប្រកបដោយពណ៌សម្បុរដែលគួរឲ្យប្រាថ្នា ដែលគួរឲ្យស្រឡាញ់ ដែលគួរឲ្យពេញចិត្ត ព្រោះប្រកបដោយផលនៃអទោសៈ ពាក្យថា **ទុព្វណ្ណេ**-មានពណ៌សម្បុរអាក្រក់ គឺប្រកបដោយពណ៌សម្បុរមិនគួរប្រាថ្នា មិនគួរស្រឡាញ់ មិនគួរពេញចិត្ត ព្រោះប្រកបដោយផលនៃទោសៈ មានសេចក្តីថា មានរូបមិនស្អាត មានរូបគួរស្អប់ , ពាក្យថា **សុគតេ**-បានល្អ គឺ ដល់សុគតិ ឬជាអ្នកមាំទាំ មានទ្រព្យច្រើន ព្រោះប្រកបដោយផលនៃអលោភៈ , ពាក្យថា **ទុគ្គតេ**-លំបាកលំបិន គឺ ដល់ទុគ្គតិ ឬ

ខ្វះខាតអត្តខាត់បាយទឹក ព្រោះប្រកបដោយផលនៃលោភៈ , ពាក្យថា **យថាកម្មូបគេ** ចូលដល់ គតិតាមកម្ម គឺ កម្មណាៗដែលខ្លួនសាងទុក ចូលដល់គតិតាមកម្មនោះៗ ។

## យថាកម្មូបគញ្ញាណ

ក្នុងបទទាំងនោះ កិច្ចនៃទិព្វចក្ខុ ព្រះមានព្រះភាគត្រាស់បទទាំងឡាយខាងដើម មានបទថា **ចវមានេ** ជាដើម ចំណែកកិច្ចនៃយថាកម្មូបគញ្ញាណ ( គឺការដឹងថា សត្វចូលដល់គតិតាមកម្មរបស់ខ្លួន ) ត្រាស់ដោយបទ **យថា កម្មូបគេ** នេះ និង សេចក្តីតទៅនេះ ជាលំដាប់ការកើតឡើងនៃញាណនោះ ។

ភិក្ខុក្នុងព្រះសាសនានេះ ពង្រីកអាលោកកសិណចុះទៅខាងក្រោម ទៅកាន់នរក រមែងឃើញសត្វទាំងឡាយអ្នកកើតនៅក្នុងនរក ដែលកំពុងសោយទុក្ខធ្ងន់ ការឃើញនោះជាកិច្ចនៃទិព្វចក្ខុប៉ុណ្ណោះ ភិក្ខុនោះធ្វើទុកក្នុងចិត្តយ៉ាងនេះតទៅថា សត្វទាំងនេះសន្សំកម្មអ្វីហ្ន៎ ទើបបានសោយទុក្ខនោះ លំដាប់នោះ ញាណដែលមានកម្មនោះជាអារម្មណ៍ ទើបកើតឡើងដល់ភិក្ខុនោះថា **សត្វទាំងនោះសន្សំកម្មឈ្មោះនេះ...** ន័យដូចគ្នានោះ ភិក្ខុពង្រីកអាលោកកសិណឡើងទៅខាងលើ ទៅកាន់ទេវតា រមែងឃើញសត្វទាំងឡាយដែលកំពុងសោយមហាសម្បត្តិ នៅក្នុងទិព្វស្ថានមាននន្ទវ័ន មិស្សកវ័ន និងបារុសកវ័នជាដើម សូម្បីការឃើញនោះ ក៏ជាកិច្ចនៃចក្ខុទិព្វ នោះឯង លោកធ្វើទុកក្នុងចិត្តយ៉ាងនេះតទៅថា សត្វទាំងនេះសន្សំកម្មអ្វីហ្ន៎ ទើបសោយសម្បត្តិនោះ លំដាប់នោះ ញាណដែលមានកម្មនោះជាអារម្មណ៍ ទើបកើតឡើងដល់លោកថា សត្វទាំងនោះសន្សំកម្មឈ្មោះនេះ... ការដឹងនេះ ឈ្មោះថា

**យថាកម្មូបគញ្ញាណ** ដែលបរិកម្មផ្សេងគ្នានៃញាណនេះមិនមាន ទាំងបរិកម្មដោយឡែកនៃញាណនេះមិនមានយ៉ាងណា សូម្បីបរិកម្មដោយឡែកនៃអនាគតំសញ្ញាណក៏មិនមានដូច្នោះ ព្រោះញាណដែលមានទិព្វចក្ខុជាបាទ( ជាភូមិឋាន )ទាំងឡាយនោះឯង ក៏រមែងសម្រេចមកព្រមនឹងទិព្វចក្ខុញ្ញាណនោះឯង ។

## ទុច្ចរិត

ក្នុងបទទាំងឡាយ មានបទថា **កាយទុច្ចរិតេន**( ដោយកាយទុច្ចរិតជាដើម ) មានពណ៌នាសេចក្ដីថា ការប្រព្រឹត្តអាក្រក់ ឬប្រព្រឹត្តខូច ព្រោះជាការប្រព្រឹត្តដែលស្អុយទៅដោយអំណាចកិលេស ព្រោះហេតុនោះ ទើបឈ្មោះថា **ទុច្ចរិត** ការប្រព្រឹត្តអាក្រក់ដោយកាយ ឬ ការប្រព្រឹត្តអាក្រក់ដែលកើតឡើងតាមផ្លូវកាយ ព្រោះហេតុនោះ ទើបឈ្មោះថា **កាយទុច្ចរិត** ន័យសូម្បីក្នុងពីរបទដទៃ ក៏មានន័យដូច្នេះ , បទថា **សមន្នាគតា**-មកតាមព្រម គឺ **សមង្គីភូតា**-ជាអ្នកព្រមព្រៀងដោយ ។

## អរិយុបវាទ

ប្រការថា **អរិយានំ ឧបវាទកា**-អ្នកតិះដៀលព្រះអរិយៈទាំងឡាយ មានសេចក្ដីថា ជាអ្នកបែមុខទៅកាន់ភាពសាបសូន្យ ជេរស្ដី ឬតិះដៀល អធិប្បាយថា ជេរ ឬ ពោលទោសដល់ព្រះអរិយៈទាំងឡាយ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវកទាំងឡាយដោយហោចទៅ សូម្បីព្រះសោតាបន្នជាគ្រហស្ថ ដោយអន្តិមវត្ថុក៏ដោយ ដោយការលុបគុណក៏ដោយ ក្នុងអាការពីរយ៉ាងនោះ អ្នកពោលថា សមណធម៌របស់បុគ្គលពួកនេះមិនមាន បុគ្គលទាំងនោះមិនមែនជាសមណៈដូច្នេះ គប្បីជ្រាបថា តិះដៀលដោយអន្តិមវត្ថុ លោកអ្នកពោលមិនពិត ជាដើមថា

ឈានក្តី វិមោក្ខក្តី មគ្គក្តី ផលក្តី របស់បុគ្គលទាំងនេះមិនមាន ដូច្នេះ គប្បីជ្រាបថា តិះដៀលដោយបំណងលុបគុណ ក៏ឯបុគ្គលអ្នកតិះដៀលនោះដឹងច្បាស់ថា លោកជាព្រះអរិយៈ ហើយតិះដៀលលោកក៏ដោយ មិនដឹងថាលោកជាព្រះអរិយៈ ហើយតិះដៀលលោកក៏ដោយ ក៏គង់ជាអរិយុបវាទទាំងពីរស្ថាន អរិយុបវាទកម្មនេះជាកម្មធ្ងន់ ទាំងហាមស្ថានសួគ៌ ទាំងហាមមគ្គ ដូចគ្នានឹងអនន្តរិយកម្ម តែនៅជា **សតេកិច្ឆា**( អាចកែខៃបាន ) ដើម្បីអរិយុបវាទកម្មនោះច្បាស់លាស់ឡើង បណ្ឌិតគប្បីជ្រាបរឿងតទៅនេះ ។

## រឿងភិក្ខុកំលោះតិះដៀលព្រះអរិយៈ

បានឮមកថា ព្រះថេរៈមួយអង្គ និងភិក្ខុកំលោះមួយអង្គ ទៅបិណ្ឌបាតក្នុងស្រុកមួយកន្លែង លោកទាំងពីរអង្គនោះបានយាគូនៅក្តៅៗប្រមាណមួយវែក ក្នុងផ្ទះខ្នងទី ១ តែម្តង លុះខ្យល់ក្នុងពោះចាក់ដោតព្រះថេរៈ ទើបលោកគិតថា យាគូនេះជារបស់សប្បាយសម្រាប់យើង យើងនឹងហុតវា មុនពេលវានៅមិនទាន់ត្រជាក់ចុះ ដូច្នេះហើយ ទើបលោកគង់ចុះលើកំណាត់ឈើដែលមនុស្សទាំងឡាយ នាំមកដើម្បីនឹងធ្វើធរណីទ្វារ ហើយឆាន់យាគូនោះ ចំណែកមួយអង្គទៀត លោករង្កៀសនឹងលោក( ដែលគង់ឆាន់កណ្តាលស្រុក )ដូច្នោះ ក៏ស្តីថា មនុស្សកញ្ចាស់ ហេវណាស់ឬ ទើបបានធ្វើការលក់មុខដល់យើងផងដែរ ព្រះថេរៈនិមន្តបិណ្ឌបាត ក្នុងស្រុកហើយត្រឡប់ទៅដល់វិហារ ទើបនិយាយនឹងភិក្ខុកំលោះនោះថា ទីពឹងក្នុងព្រះសាសនានេះរបស់លោកមានដែរឬ អាវុសោ ? ភិក្ខុកំលោះនោះឆ្លើយថា មានលោកម្ចាស់ ខ្ញុំករុណាជាសោតាបន្ន ព្រះថេរៈទើបពោលថា អាវុសោ បើដូច្នោះអ្នក

កុំធ្វើការព្យាយាមដើម្បីមគ្គជាន់ខ្ពស់តទៅឡើយ ភិក្ខុកំលោះសួរតទៅថា ព្រោះហេតុអ្វីលោកម្ចាស់ ទើបលោកប្រាប់ថា ព្រះឧីណាស្រេពត្រូវអ្នកតិះដៀលហើយ ភិក្ខុកំលោះអង្គនោះ ទើបបានរលឹកសូមខមាទោសលោក ដោយការសូមខមាទោសនោះ កម្មរបស់លោកទើបបានត្រឡប់ជាប្រក្រតីវិញ ។

## វិធីសូមខមាទោស

ព្រោះដូច្នោះ អ្នកដទៃណាក៏ដោយ ដែលបានតិះដៀលព្រះអរិយៈ អ្នកនោះគប្បីទៅរកលោក បើលោកជាអ្នកខ្ចីវស្សាជាងខ្លួន ក៏គប្បីអង្គុយប្រហោង មិនត្រូវថ្វាយបង្គំ ហើយត្រូវសូមខមាទោសដោយពាក្យថា **អហំ អយស្មន្តំ ឥទញ្ចិទញ្ច អវចំ តម្មេ ខមាហិ** ( ខ្ញុំព្រះករុណាបានពោលពាក្យនេះៗ នឹងលោក សូមលោកអត់ទោសនោះដល់ខ្ញុំផងចុះ ) , បើលោកចាស់វស្សាជាង គប្បីថ្វាយបង្គំលោក អង្គុយប្រហោងផ្គងអញ្ជលីឡើង សូមខមាទោសដោយពាក្យថា **អហំ ភន្តេ តុម្ហេ ឥទញ្ចិទញ្ច អវចំ តម្មេ ខមថ** ( លោកម្ចាស់ ខ្ញុំបានពោលពាក្យនេះៗ ដល់លោកម្ចាស់ សូមលោកម្ចាស់មេត្តាអត់ទោសនោះៗ ដល់ខ្ញុំផងចុះ ) ។

ប្រសិនបើលោកចៀសចេញទៅកាន់ទិស គឺទៅទីដទៃហើយ គប្បីទៅខ្លួនឯង ឬ បញ្ជូនភិក្ខុ មានសទ្ធិវិហារិកជាដើមទៅសូមខមាទោសលោក តែបើមិនអាចទៅដោយខ្លួនឯង ទាំងមិនអាចបញ្ជូនអ្នកណាមួយទៅបាន ដូច្នោះ ភិក្ខុពួកណានៅក្នុងវិហារជាមួយនឹងខ្លួននោះ គប្បីចូលទៅរកពួកភិក្ខុនោះ បើលោកទាំងឡាយជាអ្នកខ្ចីវស្សាជាង ក៏គប្បីអង្គុយប្រហោង គឺ មិនត្រូវថ្វាយបង្គំ បើលោកទាំងឡាយជាអ្នកចាស់វស្សាជាង ក៏គប្បីបដិបត្តិដោយន័យនៃវត្តដែលគប្បីធ្វើចំពោះលោកអ្នកចាស់

វស្សាជាន ដូចពោលមកហើយនោះឯង ហើយពោលសូមខមាទោសថា **អហំ ភន្តេ អសុកំ នាម អាយស្មន្តំ ឥទញ្ចិទញ្ច អវចំ ខមតុ មេ សោ អាយស្មា** ( លោកម្ចាស់ ខ្ញុំបានពោលពាក្យនេះៗ នឹងលោកដ៏មានអាយុឈ្មោះនោះ សូមលោកដ៏មានអាយុនោះ អត់ទោសដល់ខ្ញុំផងចុះ សូម្បីកាលមិនបានសូមខមាទោសចំពោះមុខលោក ក៏គប្បីធ្វើវត្តនោះដូចគ្នា ។

បើព្រះអរិយៈនោះជាឯកចារិកភិក្ខុ( ភិក្ខុអ្នកចារិកទៅតែម្នាក់ឯង ) ទីនៅរបស់លោកមិនមានអ្នកណាដឹង ស្ថានទីរបស់លោកសោតក៏មិនប្រាកដដូច្នោះ ក៏គប្បីទៅរកភិក្ខុដែលជាបណ្ឌិតមួយអង្គ ហើយប្រាប់លោកថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំបានពោលពាក្យនេះៗ នឹងលោកដ៏មានអាយុឈ្មោះនោះ វិប្បដិសារៈកើតឡើងដល់ខ្ញុំគ្រប់ពេលដែលរឭកដល់លោក ខ្ញុំធ្វើយ៉ាងណាល្អ ភិក្ខុបណ្ឌិតនោះនឹងពោលថា លោកកុំគិតអ្វីឡើយ ព្រះថេរៈរមែងអត់ទោសឲ្យដល់លោក លោកចូរធ្វើចិត្តឲ្យស្ងប់ចុះ ឯលោកក៏គប្បីតម្រង់មុខចំពោះទិសដែលព្រះថេរៈទៅ ផ្គងអញ្ជលីឡើងពោលថា **ខមតុ** សូមព្រះថេរៈនោះអត់ទោសចុះ ។

បើព្រះថេរៈនោះជាអ្នកបរិនិព្វានទៅហើយ លោកគប្បីទៅឲ្យដល់ស្ថានទីគ្រែដែលលោកបរិនិព្វាន រហូតដល់ព្រៃខ្មោចស្រស់ក្តី សូមខមាទោសលោកចុះ ។

កាលបានធ្វើការសូមខមាទោសយ៉ាងនេះហើយ កម្មនោះក៏មិនជាសគ្គាវរណៈ ( មិនហាមសួគ៌ ) មិនជាមគ្គាវរណៈ( មិនហាមមគ្គ ) ត្រឡប់ជាប្រក្រតីវិញ ។

## មិច្ឆាទិដ្ឋិ

បទថា **អ្នកមានការឃើញខុស** គឺអ្នកមានការឃើញវិបរិត ( ខុសគន្លងធម៌ )

បទថា **អ្នកមានកម្មសមាទានដោយអំណាចមិច្ឆាទិដ្ឋិ** មានសេចក្ដីថា អ្នកមានកម្មផ្សេងៗ ដែលកាន់យកដោយអំណាចការឃើញខុស ដែលជាអ្នកដឹកនាំអ្នកដទៃក្នុងកម្មទាំងឡាយ មានកាយកម្មជាដើម ដែលមានការឃើញខុសជាមូលផង ។

ដូច្នេះ ក្នុងអរិយុបវាទ និងមិច្ឆាទិដ្ឋិនេះ សូម្បីកាលអរិយុបវាទត្រូវសង្គ្រោះរួមទុកហើយដោយសព្ទ គឺ វចីទុច្ចរិត និងមិច្ឆាទិដ្ឋិ ក៏ត្រូវសង្គ្រោះទុកហើយដោយសព្ទ គឺមនោទុច្ចរិត តែការត្រាស់ពីរបទនេះទៀត បណ្ឌិតគប្បីជ្រាបថា ដើម្បីសម្ដែងភាពដែលអរិយុបវាទ និងមិច្ឆាទិដ្ឋិនោះមានទោសច្រើន អរិយុបវាទនោះ មានទោសច្រើនពិតមែន ព្រោះទោសដូចអនន្តរិយកម្ម មែនពិត សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនេះទុកថា ម្នាលសារីបុត្រ ភិក្ខុអ្នកដល់ព្រមដោយសីល ដោយសមាធិ ដល់ព្រមដោយបញ្ញា ដល់ព្រមដោយអរហត្តផល ឲ្យសម្រេចបានក្នុងទិដ្ឋធម៌នេះពិត ឧបមាយ៉ាងណា ឧបមេយ្យនេះក៏ដូច្នោះ សារីបុត្រ តថាគតពោលថា បុគ្គលមិនបញ្ឈប់ពាក្យនិយាយនោះ មិនលះការគិតនោះ មិនលះបង់ការឃើញខុសនោះហើយ រមែងជាអ្នកត្រូវធ្លាក់ទៅក្នុងនរក ដូចគេត្រូវនាំខ្លួនទៅទម្លាក់ដូច្នោះ ម្យ៉ាងទៀតទោសដទៃដែលឈ្មោះថា មានទោសច្រើនជាងមិច្ឆាទិដ្ឋិរកមិនបាន ដូចព្រះវិជិតមារត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញធម៌ដទៃត្រឹមតែមួយ ដែលមានទោសច្រើនក្រៃលែងជាងនេះ ដូចជាមិច្ឆាទិដ្ឋិនេះឡើយ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានមិច្ឆាទិដ្ឋិជាទោសយ៉ាងក្រៃលែងដូច្នេះ ។

## អបាយ ទុគ្គតិ វិនិបាត និរយ

ពាក្យថា ព្រោះការបែកធ្លាយទៅនៃកាយ គឺព្រោះការលះបង់នូវឧបាទិន្នខន្ធ

( ខន្ធដែលវិញ្ញាណគ្រប់គ្រង ) , ពាក្យថា **ខាងមុខអំពីស្លាប់ទៅ** គឺក្នុងការកាន់យកខន្ធដែលកើតថ្មី ក្នុងលំដាប់នៃឧបាទិន្នក្ខន្ធ ដែលលះទៅនោះ ឬន័យមួយទៀត ពាក្យថា **ព្រោះការបែកធ្លាយទៅនៃកាយ** គឺព្រោះការបាត់បង់នៃជីវិតិន្ទ្រិយ ពាក្យថា **ខាងមុខអំពីស្លាប់ទៅ** គឺ បន្ទាប់ពីចុតិចិត្តទៅ ។

ពាក្យថា **អបាយដូច្នេះជាដើម** គ្រប់ពាក្យជាវេវចនៈរបស់ពាក្យនិរយៈនោះឯង ពិតមែន និរយៈចាត់ជាអបាយ ព្រោះប្រាសចាកអាយៈ ដែលគ្រប់គ្នាដឹងថា បុណ្យ ដែលជាហេតុនៃសគ្គៈ និងនិព្វាន ឬថា ព្រោះការមិនមាននៃអាយៈ ( ដំណើរមក ) នៃសេចក្តីសុខទាំងឡាយ ។

និរយៈចាត់ជាទុគ្គតិ ព្រោះជាគតិ គឺជាទីទៅនៃទុក្ខ, មួយទៀតចាត់ជា ទុគ្គតិ ព្រោះជាគតិដែលកើតដោយកម្មអាក្រក់ ព្រោះជាកម្មច្រើនទៅដោយទោស ។

និរយៈចាត់ជាវិនិបាត ព្រោះជាទីធ្លាក់ចុះទៅយ៉ាងអស់អំណាចនៃអ្នកធ្វើអាក្រក់ទាំងឡាយ , មួយទៀត ចាត់ជាវិនិបាត ព្រោះជាទីធ្លាក់ចុះដ៏យ៉ាងក្រៃលែង គឺមានអវយវៈតូចធំត្រូវវិនាសទៅនៃអ្នកធ្វើអាក្រក់ទាំងឡាយដូច្នេះក៏បាន ។

អាយៈដែលតែងហៅថា **អស្សាទ**( សេចក្តីត្រេកអរ ) មិនមានក្នុងទីនោះ ហេតុដូច្នេះ ទីនោះឈ្មោះថា និរយៈ ។

ន័យម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់បញ្ជាក់ដល់កំណើតតិរច្ឆាន ដោយ **អបាយ**-ស័ព្ទ ពិតមែន កំណើតតិរច្ឆានឈ្មោះថា អបាយ ព្រោះប្រាសចាកសុគតិ តែមិនចាត់ជាទុគ្គតិ ព្រោះជាទីសម្ភពនៃតិរច្ឆានជំពូកមហេសក្ខ មាននាគរាជជាដើម ។

ទ្រង់បញ្ជាក់ដល់បេតវិស័យដោយ**ទុគ្គតិ**-ស័ព្ទ ពិតមែន បេតវិស័យនោះចាត់ជាអបាយផង ជាទុគ្គតិផង ព្រោះប្រាសចាកសុគតិ និងព្រោះជាគតិនៃទុក្ខ តែមិន

បាត់ជាវិនិបាត ព្រោះបេតវិស័យមិនបានធ្លាក់ចុះដ៏យ៉ាងក្រៃលែង ដូចជាអសុរកាយដែលនឹងពោលតទៅ :

ទ្រង់បញ្ជាក់ដល់អសុរកាយដោយ**វិនិបាត**-ស័ព្ទ ពិតមែន អសុរកាយនោះបាត់ជាអបាយ និងជាទុគ្គតិផងដែរ ដោយអត្ថតាមដែលពោលមកហើយ និងនៅហៅថា វិនិបាតផង ព្រោះអសុរកាយនោះ ធ្លាក់ទៅអំពីការចម្រើនដោយសម្បត្តិគ្រប់យ៉ាង ។

ទ្រង់បញ្ជាក់ដល់និរយៈ គឺ នរកច្រើនប្រភេទ មានអវិចីនរកជាដើមនោះឯងដោយ**និរយ**-ស័ព្ទដូច្នេះ ។

បទថា **ឧបបន្នា** គឺ **ឧបគតា** ចូលដល់អធិប្បាយថា កើតក្នុងអបាយជាដើមនោះ ។

## សុគតិលោកស្វគ៌

*សុក្កបក្ខ*( ផ្នែកខាងល្អ ) បណ្ឌិតគប្បីជ្រាបបរិយាយដែលខុស ឬផ្ទុយគ្នាពីផ្នែកខាងអាក្រក់ដែលបានពោលហើយនោះចុះ តែសេចក្តីតទៅនេះ ជាការប្លែកគ្នាគឺ

ក្នុងពាក្យថាសុគតិជាដើមនោះ ដោយ***សុគតិ***-ស័ព្ទ លោករួមយកមនុស្សគតិចូលផង តែដោយ***សគ្គ***-ស័ព្ទ លោកកាន់យកតែទេវគតិតែម្យ៉ាងប៉ុណ្ណោះ ចំណែកសេចក្តីតទៅនេះជាសេចក្តីនៃពាក្យ គឺក្នុងពាក្យថា សុគតិលោកនោះ ភូមិដែលឈ្មោះថា***សុគតិ*** ព្រោះជាគតិល្អ , ឈ្មោះថា ***ស្វគ៌*** ព្រោះប្រសើរលើសដោយអារម្មណ៍ទាំងឡាយ មានរូបជាដើមទាំងអស់នោះ បានឈ្មោះថា ***លោក*** ព្រោះសេចក្តីថាមានការបែកធ្លាយ ។

ពាក្យថា **ឥតិ ទិព្វេន ចក្ខុនា** ជាដើមទាំងអស់ជាពាក្យនិគម សេចក្តីតាម

ដែលពោលមកនេះ ជាសេចក្ដីសង្ខេបក្នុងព្រះបាលីថា ឃើញ...ដោយទិព្វចក្ខុនោះ ដោយប្រការដូច្នេះ ។

## ផ្ដើមចម្រើនទិព្វចក្ខុ

ដូច្នេះ អាទិកម្មិកកុលបុត្រអ្នកប្រាថ្នានឹងឃើញដោយទិព្វចក្ខុយ៉ាងនោះ គប្បីធ្វើឈានដែលជាបាទនៃអភិញ្ញា ដែលមានកសិណជាអារម្មណ៍ឲ្យគួរដល់ការនាំចិត្តទៅដើម្បីទិព្វចក្ខុញ្ញាណដោយអាការទាំងពួងហើយ ធ្វើបណ្ដាកសិណ ៣ នេះ គឺ តេជោកសិណ ឱទាតកសិណ អាលោកកសិណ ណាមួយឲ្យជិត ដែលនាំឲ្យកើតទិព្វចក្ខុញ្ញាណ គប្បីធ្វើឧបចារឈានឲ្យជាគោចរ ពង្រីកកសិណារម្មណ៍ ហើយទប់ទុក អធិប្បាយថា អប្បនាមិនគួរឲ្យកើតឡើងក្នុងអារម្មណ៍ដែលពង្រីកហើយនោះ ព្រោះបើឲ្យកើតឡើង អារម្មណ៍នោះក៏ជាទីអាស្រ័យនៃបាទកឈាន មិនជាទីអាស្រ័យនៃបរិកម្ម ។

ក៏ក្នុងកសិណ ៣ នេះ អាលោកកសិណនោះឯងល្អជាងគេ ព្រោះហេតុនោះ គប្បីញុំាងអាលោកកសិណនោះ ឬកសិណដទៃយ៉ាងណាមួយក៏ដោយ ឲ្យកើតឡើងជាឧបចារឈាន តាមន័យដែលបានពោលក្នុងកសិណនិទ្ទេសហើយ តាំងនៅក្នុងឧបចារភូមិនោះឯង ទើបពង្រីកកសិណារម្មណ៍ចុះ សូម្បីន័យក្នុងការពង្រីកអារម្មណ៍នោះ ក៏គប្បីជ្រាបតាមន័យដែលបានពោលក្នុងកសិណនិទ្ទេសនោះដូចគ្នា ។

ព្រះយោគាវចរគប្បីមើលរូប ដែលមានក្នុងខាងក្នុងកន្លែងនៃកសិណារម្មណ៍ដែលពង្រីកទៅប៉ុនណាៗ ( មិនគប្បីមើលទៅខាងក្រៅ ) ដូច្នេះ កាលលោកមើលរូប វារៈនៃបរិកម្មរមែងកន្លងទៅ តពីនោះ ពន្លឺភ្លឺស្វាងក៏បាត់ទៅ កាលពន្លឺនោះបាត់

ទៅហើយ រូបក៏មិនប្រាកដ កាលបើដូច្នោះ ព្រះយោគីនោះគប្បីចូលបាទកឈាន នោះឯង ចេញចាកឈាននោះហើយ ទើបផ្សាយពង្រីកពន្លឺទៅរឿយៗចុះ កាលធ្វើទៅយ៉ាងនោះ ពន្លឺរមែងដល់ភាពខ្លាំងក្លា គឺនៅបានយូរដោយលំដាប់ដូច្នេះ តពីនោះទៅលោកអធិដ្ឋានថា ពន្លឺចូរមាននៅក្នុងទីនេះ កំណត់ទីទុកប៉ុនណា ពន្លឺក៏គង់នៅក្នុងទីប៉ុណ្ណោះ ការឃើញរូបរមែងមានដល់អ្នកអង្គុយមើលទាំងថ្ងៃក៏បាន ក៏បុរសអ្នកធ្វើដំណើរក្នុងកណ្តាលអធ្រាត្រដោយគប់ភ្លើងស្មៅ ជាការឧបមាបានក្នុងពាក្យដែលពោលនេះ ។

បានឮថា បុរសម្នាក់ធ្វើដំណើរក្នុងកណ្តាលយប់ដោយគប់ស្មៅ កាលដើរទៅ គប់ភ្លើងស្មៅនោះរបស់គេក៏ឆេះអស់ កន្លែងដែលរាប និងមិនរាបក៏មិនប្រាកដដល់គេ គេទើបប្រមូលគប់ភ្លើងគប់ស្មៅនោះដាក់លើផែនដី ធ្វើឲ្យវាឆេះឡើងទៀត ដូច្នេះ គប់ភ្លើងស្មៅនោះកាលឆេះឡើងហើយ បានធ្វើពន្លឺភ្លឺជាងពន្លឺក្នុងកាលមុនទៅទៀត កាលគេធ្វើគប់ភ្លើងស្មៅ ដែលឆេះអស់ហើយ ឲ្យឆេះឡើងបានរឿយៗទៅយ៉ាងនោះ ថ្ងៃក៏ចាប់ផ្តើមរះឡើងមក កាលថ្ងៃរះឡើងហើយ ការប្រើគប់ ភ្លើងក៏មិនចាំបាច់ ដូច្នោះទើបគេបោលគប់ភ្លើងនោះ ហើយដើរទៅបានពេញមួយថ្ងៃ ។

ក្នុងឧបមាទាំងឡាយនោះ ពន្លឺកសិណក្នុងពេលបរិកម្ម គឺក្នុងឧបចារឈាន ប្រៀបដូចពន្លឺរបស់គប់ភ្លើង ការដែលពន្លឺបាត់ទៅ ព្រោះហេតុដែលព្រះយោគាវចរកំពុងមើលរូប វារៈនៃបរិកម្មកន្លងទៅ ក៏មិនឃើញរូបទាំងឡាយ ប្រៀបដូចកាលគប់ភ្លើងឆេះសុសហើយ បុរសនោះក៏មិនឃើញទីរាប និងទីមិនរាបក៏ដូច្នោះ កាលចូលបាទកឈានរឿយៗ ប្រៀបដូចប្រមូលគប់ភ្លើងរឿយៗ កាលដែលព្រះយោគីធ្វើបរិកម្មទៀត ពន្លឺភ្លឺស្វាងខ្លាំងក្លាជាងពន្លឺចាស់ផ្សាយទៅ ប្រៀបដូចកាលដែលគប់

ភ្លើងត្រូវប្រមូលឲ្យឆេះឡើង ធ្វើពន្លឺឲ្យភ្លឺជាងពន្លឺកាលមុន ការដែលពន្លឺដ៏ខ្លាំងក្លា គង់នៅតាមដែលកំណត់ទុក ប្រៀបដូចកាលដែលថ្ងៃរះឡើង កាលព្រះយោគាវចរ លះបង់ពន្លឺដែលតូចតាចហើយ ឃើញរូបបានពេញមួយថ្ងៃដោយពន្លឺដ៏ខ្លាំងក្លា ប្រៀប ដូចការដែលបុរសនោះបោលគប់ភ្លើងស្មៅហើយ ដើរទៅបានពេញមួយថ្ងៃ ដោយ ពន្លឺថ្ងៃដូច្នោះ ។

## កាលទិព្វចក្ខុកើត

ក្នុងការឃើញរូបនោះ កាលណារូបនេះ គឺរូបដែលនៅក្នុងពោះ និងរូបដែល អាស្រ័យនៅក្នុងហទយៈ រូបដែលអាស្រ័យនៅក្រោមផ្ទៃដី រូបនៅក្រៅជញ្ជាំង ក្រៅភ្នំ ក្រៅកំផែង និងរូបដែលនៅក្នុងចក្កវាឡដទៃ ដែលមិនមកកាន់គន្លង មំសចក្ខុរបស់ភិក្ខុនោះ គឺភិក្ខុនោះមើលមិនឃើញដោយភ្នែកសាច់ មកកាន់គន្លងនៃ ញាណចក្ខុរបស់លោក ហាក់បីដូចជាប្រាកដដល់មំសចក្ខុ កាលនោះគប្បីជ្រាបថា ទិព្វចក្ខុកើតឡើងហើយ និងបណ្តាចិត្តដែលប្រារព្ធរូបនេះ ទិព្វចក្ខុប៉ុណ្ណោះអាចក្នុង ការឃើញរូប បុព្វភាគចិត្តទាំងឡាយមិនអាចទេ ។

## ចក្ខុទិព្វកើតអន្តរាយដល់បុថុជ្ជន

ឯទិព្វចក្ខុនេះនោះ រមែងកើតអន្តរាយដល់បុថុជ្ជនបាន ព្រោះហេតុអ្វី ព្រោះ ហេតុថា បុថុជ្ជននោះអធិដ្ឋានថា ឲ្យពន្លឺមានក្នុងទីណាៗ ទីនោះៗ កើតមានពន្លឺជា វង្វង់មួយចូលទៅក្នុងផែនដី សមុទ្រ និងភ្នំក៏បាន ពេលនោះ កាលគេឃើញរូប អមនុស្ស មានយក្ខ និងអារក្ខទឹកជាដើម ដែលជារូបគួរឲ្យខ្លាចក្នុងទីទាំងឡាយនោះ ការខ្លាចកើតឡើង ដែលជាហេតុឲ្យគេដល់វិកលចារិក ក្លាយជាឈានវិវកន្តកៈ គឺ

ន្ធតព្រោះឈានទៅក៏បាន ព្រោះហេតុនោះ ព្រះយោគាវចរគប្បីជាអ្នកមិនប្រមាទក្នុងការមើលរូប ។

## លំដាប់ការកើតឡើងនៃទិព្វចក្ខុ

ក្នុងពេលទិព្វចក្ខុកើតនោះ នេះជាលំដាប់ការកើតឡើងនៃទិព្វចក្ខុ គឺពាក្យទាំងពួង ដែលសម្តែងលំដាប់ការកើតនៃទិព្វចក្ខុថា កាលមនោទ្វារាវជ្ជនៈធ្វើរូប មានប្រការដូចពោលហើយនោះ ឲ្យជារូបារម្មណ៍កើតឡើងហើយរលត់ទៅ ជវន ៤-៥ ដួង ធ្វើរូបនោះឯងជាអារម្មណ៍កើតឡើង ដូច្នេះជាអាទិ៍ គប្បីជ្រាបដោយន័យដែលមានមកក្នុងពេលខាងដើមនោះចុះ សូម្បីក្នុងញាណនេះ កាមាវចរចិត្តទាំងឡាយដែលនៅមានវិតក្ក មានវិចារៈ រាប់ថាជាបុព្វភាគចិត្ត គឺចិត្តដែលជាចំណែកខាងដើមនៃញាណនេះ រូបាវចរចិត្តដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន ជាអត្ថសាធកចិត្ត គឺចិត្តដែលញុំាងប្រយោជន៍ គឺញាណនេះឲ្យសម្រេចក្នុងបរិយោសាន ញាណដែលកើតព្រមនឹងរូបាវចរចិត្តនោះឯង លោកហៅថា **សត្តានំ ចុតូបបាតញ្ញាណ** ខ្លះថា **ទិព្វចក្ខុញ្ញាណ** ខ្លះដូច្នេះ ។

# មហាដីកា

# អធិប្បាយ ចុតូបបាតញ្ញាណ

ពាក្យថា **ក្នុងចុតិ** គឺ ក្នុងការឃ្លាត ។ ពាក្យថា **ឧបបាត** គឺក្នុងពេលកើតឡើង ។ ក៏ពីរពាក្យនេះជាសត្តមីវិភត្តិ ក្នុងអត្ថថា ជិត , មានការពោលអធិប្បាយបានថា ជិតខណៈចុតិ និងជិតខណៈឧប្បត្តិ ។ ពិតហើយ លោកនឹងពោលថា តែថា

សត្វពួកណាជាអ្នកជិតនឹងឃាត ដូច្នេះជាដើម ។ កិត្តុរមែងដឹងចុតិ និងឧប្បត្តិរបស់សត្វទាំងឡាយបានដោយទិព្វចក្ខុញ្ញាណនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា មានការពោលអធិប្បាយបានថា កិត្តុរមែងដឹងចុតិ... គឺដើម្បីទិព្វចក្ខុញ្ញាណ ។ ពាក្យណាក្នុងបណ្តាពាក្យថា ព្រោះប្រាកដដូចជារបស់ទិព្វជាដើម ជាពាក្យដែលគួរពោលអធិប្បាយ ពាក្យនោះ ខ្ញុំបានពោលហើយក្នុងខាងដើមនោះឯង ។ ប៉ុន្តែតទៅនេះ ជាការប្លែកគ្នា គឺក្នុងទិព្វសោតញ្ញាណនោះ លោកសំដៅដល់បទថា **សោតធាតុ** ទើបពោលទុកដោយទាក់ទងជា **ឥត្ថីលិង្គ** ថា **ទិព្វា**-ជាទិព្វ ក្នុងចុតូបបាតញ្ញាណនេះ គួរនឹងពោលទុកដោយទាក់ទងជា នបុំសកលិង្គថា **ទិព្វំ**-ជាទិព្វ ។ ម្យ៉ាងទៀត ក្នុងទិព្វសោតធាតុញ្ញាណនោះ ប្រយោជន៍ដោយការកំណត់កាន់យកដោយអាលោកកសិណមិនមាន , ក្នុងចុតូបបាតញ្ញាណនេះមាន ព្រោះហេតុនោះ ទើបលោកពោលថា ឈ្មោះថាជាទិព្វ ព្រោះមានពន្លឺខ្លាំង ព្រោះមានការកំណត់កាន់យកដោយអាលោកកសិណ ដូច្នេះ , សេចក្តីថា ព្រោះការដែលមានពន្លឺខ្លាំង ព្រោះជាញាណដែលគប្បីសម្រេចបានដោយការអនុគ្រោះនៃពន្លឺដែលជាកសិណ និងការផ្សាយទៅនៃពន្លឺ គឺ ញាណ ។ ពិតហើយ សូម្បីវត្ថុដែលមានពន្លឺខ្លាំង ក៏លោកហៅថា របស់ទិព្វ ដូចក្នុងប្រយោគថា **ទិព្វមិទំ ព្យម្ហំ**-របស់ទិព្វនេះគួរអស្ចារ្យដូច្នេះជាដើម ។ បទថា **មហាគតិកត្តា** ប្រែថា ព្រោះមានការទៅគួរបូជា សេចក្តីថា ព្រោះមានការប្រព្រឹត្តទៅគួរអស្ចារ្យ ។ ពិតមែន ការប្រព្រឹត្តទៅនៃញាណនេះ ឈ្មោះថា គួរអស្ចារ្យ ព្រោះឃើញរូបដែលនៅខាងក្រៅជញ្ជាំងជាដើមបាន ។ ក៏ពាក្យថា **ព្រោះប្រាកដដូចជារបស់ទិព្វនេះ** ជាពាក្យសម្តែងការប្រៀបធៀបជាមួយវត្ថុដែលអាក្រក់ជាង ព្រោះទិព្វចក្ខុញ្ញាណនេះ មានអានុភាព

ច្រើនជាង សូម្បីទិព្វចក្ខុរបស់ពួកទេវតាទាំងឡាយ ។ ព្រោះហេតុនោះ ការធ្វើបរិកម្មរបស់ព្រះយោគី ដើម្បីការបានទិព្វចក្ខុញ្ញាណ ទើបឈ្មោះថា ជាការបំណាងយកការប្រសើរជាងទិព្វចក្ខុរបស់ទេវតានោះ ដោយសភាវៈដែលគ្របសង្កត់ធម៌ជាបដិបក្ខនោះបាន , លោកអ្នកមានឫទ្ធិ អ្នកបានទិព្វចក្ខុ គប្បីប្រព្រឹត្តក្នុងវោហារការពោលប្រាប់ដែលមានការកំណត់ដល់ការទទួលយកទានបាន ដូចលោកអ្នកមានឫទ្ធិ មានព្រះមហាមោគ្គល្លានជាដើម ដោយទាក់ទងនឹងការឲ្យធម៌ គឺ ធម្មទានដ៏សមគួរដល់ការទទួលយកទុកបាន ដោយការពោលប្រាប់ដល់ពួកទេវតាទាំងឡាយផង ព្រោះអភិញ្ញាញាណនេះ សម្រេចភាពជាទិព្វចក្ខុ ដោយអំណាចនៃអត្ថទាំងឡាយ ពោលគឺ វិហារ ( ទិព្វវិហារ ដែលជាហេតុឲ្យបានមក **វិជយិច្ឆា** គឺ ការបំណងយកភាពប្រសើរជាងទិព្វចក្ខុរបស់ទេវតា ដែលជាហេតុឲ្យសម្រេចវោហារគឺការសម្តែងធម៌ប្រាប់ដល់ទេវតាបាន , **ជុតិ** គឺពន្លឺដ៏ខ្លាំង , **គតិ** គឺការទៅកន្លែងដែលគួរបូជា តាមប្រការដូចពោលមក ដូច្នេះ ។ ក៏អាចារ្យអ្នកចេះសទ្ទសាស្ត្រទាំងឡាយ រមែងប្រាថ្នា **ទិវុ**-ស័ព្ទ( ប្រែថា ទិព្វ ) ក្នុងអត្ថទាំងនេះនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ពាក្យទាំងអស់នោះបណ្ឌិត គប្បីជ្រាបតាមផ្លូវនៃគម្ពីរសទ្ទសាស្ត្រនោះចុះដូច្នេះ ។

ពាក្យថា **ព្រោះថា ព្រោះអត្ថថាឃើញ** គឺព្រោះភាវៈដែលឃើញរូប ។ ព្រោះថា សត្វទាំងឡាយរមែងឃើញរូបបានដោយចក្ខុ ។ ប្រៀបដូចជា **មំសចក្ខុ**( ភ្នែកសាច់ ) ដែលវិញ្ញាណតាំងនៅហើយ រមែងប្រព្រឹត្តទៅ ហាក់ដូចជាប្រាប់ដល់ទីរាបនិងទីរដិបរដុបយ៉ាងណា ទិព្វចក្ខុញ្ញាណមិនបានប្រព្រឹត្តទៅដូច្នោះទេ ។ បើទិព្វចក្ខុញាណនេះ ជាអ្នកធ្វើកិច្ចនៃចក្ខុដោយខ្លួនឯង ល្អក្រៃលែងជាងមំសចក្ខុនោះណាស់

ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ម្យ៉ាងទៀត ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា ប្រាកដដូចជាចក្ខុ ដោយការធ្វើកិច្ចនៃចក្ខុដូច្នេះ ។ លោកអាចារ្យពោលថា ពិតមែន បុគ្គលណាដូច្នេះជាដើម ដើម្បីនឹងបើកបង្ហាញសេចក្តីដែលបានពោលទុកដោយសង្ខេបថា ព្រោះហេតុនៃការឃើញដ៏បរិសុទ្ធ ឈ្មោះថារមែងប្រកាន់ឧច្ឆេទទិដ្ឋិ គឺរមែងប្រកាន់ថា សត្វនេះបានដាច់សូន្យទៅក្នុងភពនេះហើយ សូម្បីសត្វទាំងឡាយដទៃក៏ដូចគ្នាដូច្នេះ ព្រោះមិនឃើញការកើតឡើងតទៅទៀត ឈ្មោះថារមែងប្រកាន់សស្សតទិដ្ឋិ ព្រោះការប្រាកដនៃសត្វថ្មីៗ គឺដូចគ្នានឹងបុគ្គលអ្នកបានឈានប្រកាន់ថាកើតឡើងឯងៗ ( មិនមានហេតុប្បច្ច័យ ) ។ គប្បីមានពាក្យអវធារណៈ ពាក្យកំណត់សេចក្តី គឺ **ឯវ**-ស័ព្ទត្រង់បទដើមថា **ពុទ្ធបុត្តា បសន្តិយេវ** ( ភិក្ខុអ្នកជាពុទ្ធបុត្រទាំងឡាយរមែងឃើញពិតប្រាកដ ) មិនមែនមានពាក្យអវធារណៈត្រង់បទមុខ ។ ព្រោះថា កាលយ៉ាងនេះ ក៏នឹងត្រូវសម្រេចភាពមិនខុសគ្នានឹង **ជយទ្ទិសជាតក** ជាដើម ។

ឈ្មោះថា **មានុសកំ** ព្រោះអត្ថថា ជារបស់មនុស្ស បានដល់ រូបារម្មណ៍ដែលជាគោចររបស់មនុស្សទាំងឡាយ ។ ក៏ទិព្វចក្ខុ ឈ្មោះថា **អតិក្កន្តមានុសកំ** ព្រោះមានការឃើញរូបយ៉ាងដទៃពីរូបដែលជារបស់មនុស្សនោះ និងរូបដែលមានប្រភេទជារូបដែលជាទិព្វ រូបដែលប្រព្រឹត្តទៅខាងក្រោយជញ្ជាំងជាដើម រូបដ៏ល្អិតក្រៃលែងជាដើមបាន ។ ការឃើញរូបដែលមានសភាពយ៉ាងនេះ ឈ្មោះថា ជាការឃើញរូបដែលហួសឧបចាររបស់មនុស្ស ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះការឃើញរូបកន្លងហួសឧបចារៈរបស់មនុស្ស ។ លោកអាចារ្យកាលសម្តែងទិព្វចក្ខុដោយអារម្មណ៍ជាសំខាន់ យ៉ាងនេះហើយ ឥឡូវនេះ បំណងសម្តែង

ដោយធម៌ដែលមានអារម្មណ៍( កាន់យកអារម្មណ៍ជាសំខាន់ ) ទើបពោលថា **មានុសកំ វា** ដូច្នេះជាដើម ។ បណ្ឌិតគប្បីឃើញការឈានកន្លងមំសចក្ខុសម្បីក្នុងទិព្វចក្ខុនោះបាន ដោយមានការឈានកន្លងកិច្ចនៃមំសចក្ខុនោះបាននោះឯង ។

ពាក្យថា **ដោយទិព្វចក្ខុ ( ប្រើទិព្វចក្ខុ )** គឺ ដោយទិព្វចក្ខុញ្ញាណ ។ ឈ្មោះថា មិនអាចសម្លឹងមើលរូបរបស់សត្វពួកខ្លះបាន ព្រោះភាពជារូបដ៏ល្អិតក្រៃលែង ព្រោះហេតុមានខណៈតិចហួសពេក ។ ន័យម្យ៉ាងទៀត ទិព្វចក្ខុក៏មានរូបជាអារម្មណ៍ដែលជាបច្ចុប្បន្ន រូបដែលជាអារម្មណ៍នោះ ក៏ជាបុរេជាតប្បច្ច័យផងដែរ, មហគ្គតចិត្តក៏មិនមានការប្រព្រឹត្តទៅដោយប្រាសចាកអាវជ្ជនៈ និងបរិកម្មផងដែរ , ទាំងរូបដែលកំពុងកើតនោះក៏ដោយ កំពុងរលត់ក៏ដោយ មិនអាចជាអារម្មណប្បច្ច័យបាន ។ ព្រោះដូច្នោះ ពាក្យថា **មិនអាចប្រើទិព្វចក្ខុសម្លឹងមើលរូបក្នុង ចុតិខណៈ និងឧបបាតខណៈបាន** ដូច្នេះនេះ ទើបជាការដែលលោកពោលទុកល្អហើយ ។ សួរថា បើទិព្វចក្ខុញ្ញាណមានតែរូបជាអារម្មណ៍ប៉ុណ្ណោះ, កាលបើដូច្នោះ ព្រោះហេតុអ្វីទើបទ្រង់ត្រាស់ថា រមែងឃើញសត្វទាំងឡាយដូច្នេះហ្ន៎ ? ឆ្លើយថា ទ្រង់ត្រាស់ទុកយ៉ាងនេះ ព្រោះដោយច្រើនមានការឃើញរូបដែលប្រព្រឹត្តទៅក្នុងសន្តានរបស់សត្វ ។ អាចារ្យទាំងឡាយខ្លះពោលថា ឬថា ជាពាក្យដែលត្រាស់ទុកដោយទាក់ទងនឹងវោហារ( បញ្ញត្តិ ) ព្រោះភាពដែលរូបជាអារម្មណ៍ជាហេតុនៃការកាន់យកថាសត្វ ដូច្នេះក៏មាន ។ ក្លាប់សេចក្ដីថា **តេ ចវមានាតិ អធិប្បេតា** ( សត្វទាំងនោះទ្រង់បំណងយក ការកំពុងឃ្លាតចាក ) ។ ពាក្យថា **ដែលមានរូបបែបយ៉ាងនេះ** សំដៅដល់ មិនមែនសត្វដែលព្រមព្រៀងដោយចុតិខណៈ និងឧបបាតខណៈ ។

ឈ្មោះថា **កម្មដែលមានមោហៈជាឧបនិស្ស័យ** រមែងជាកម្មដ៏ថោកទាប មានផលថោកទាប ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះភាពជាវត្ថុដ៏សមគួរដល់ផលនៃមោហៈ , ពាក្យថា **ដែលផ្ទុយគ្នានឹងអាក្រក់នោះ** គឺដែលផ្ទុយគ្នានឹងការៈដែលត្រូវមើលងាយជាដើមនោះ, បានដល់ ដែលគេមិនមើលងាយ មិនតិះដៀល មិនមើលថោក មិនមើលស្រាល សេចក្តីថា ដែលគេធ្វើការកោតក្រែង ។ បទថា **សុវណ្ណោ** ប្រែថា មានពណ៌សម្បុរល្អ ។ បទថា **ទុព្វណ្ណោ** ប្រែថា មានពណ៌សម្បុរមិនល្អ ។ ក៏ភាពជាអ្នកមានពណ៌សម្បុរល្អ និងភាពជាអ្នកមានពណ៌សម្បុរមិនល្អនោះ រមែងមានបានព្រោះភាពនៃកម្ម មានអទោសៈ និងទោសៈជាឧប-និស្សយប្បច្ច័យតាមលំដាប់ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះភាពជាវត្ថុដ៏សមគួរដល់ផលនៃអទោសៈ ដូច្នេះជាដើម ។ សត្វអ្នកទៅកាន់គតិដ៏ល្អ ឈ្មោះថា អ្នកទៅល្អ ព្រោះហេតុនោះ ទើបលោកពោលថា បានដល់ ដែលទៅកាន់សុគតិ ដូច្នេះ មានសេចក្តីថា ដែលទៅដល់សុគតិ ។ សត្វទាំងឡាយអ្នកមានអធ្យាស្រ័យក្នុងអលោភៈ មានចិត្តទូលំទូលាយ ប្រាសចាកការកំណាញ់ រមែងជាអ្នកជោគជ័យ គឺមាំទាំ ព្រោះកម្មដែលមានអលោភៈជាឧបនិស្សយប្បច្ច័យ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ឬដែលស្តុកស្តម្ភ មានទ្រព្យច្រើន ព្រោះជាវត្ថុដែលសមគួរដល់ផលនៃអលោភៈដូច្នេះ ។ សត្វអ្នកទៅកាន់គតិដែលជាទុក្ខ ឈ្មោះថា អ្នកទៅមិនល្អ ព្រោះដូច្នោះ ទើបលោកពោលថា គឺ ដែលទៅទុគ្គតិដូច្នេះ ។ សត្វទាំងឡាយអ្នកមានអធ្យាស្រ័យក្នុងលោភៈ គឺចង់បាន មានការកំណាញ់ រមែងជាទុគ្គតៈ គឺអត្តខាត់ ព្រោះកម្មដែលមានលោភៈជាឧបនិស្សយប្បច្ច័យ ព្រោះហេតុនោះ ទើបលោកពោលថា ឬថា ដែលលំបាកក្រីក្រ មានបាយទឹកតិច

ព្រោះជាវត្ថុដ៏សមគួរដល់ផលនៃលោកៈ ដូច្នេះ ។

ពាក្យថា **សន្និ** គឺ ធ្វើទុកដោយភាពជាហេតុនាំមកនូវផល ។ ពិតមែន កម្ម ដែលសត្វធ្វើទុកដោយប្រការដែលធ្វើទុកហើយ ក៏មានអំណាចអាចឲ្យផលបាន ឈ្មោះថា ជាកម្មដែលសត្វបានសន្និទុកហើយ ។ ដោយពាក្យថា ដោយបទទាំង នេះថា **ចវមានេ**-កំពុងឃ្លាតចាកជាដើម ខាងដើម គឺ ត្រាស់ដល់កិច្ចនៃទិព្វចក្ខុ លោកអាចារ្យពោលដល់ការព្យាយាមនៃធម៌ដែលជាវិសយី( ធម្មជាតិដឹងអារម្មណ៍ , ធម្មជាតិកាន់យកអារម្មណ៍ ) ដោយវិសយៈ( អារម្មណ៍ )ជាសំខាន់ ។ម្យ៉ាងទៀត បទថា **បុរិមេហិ**-ខាងដើម លោកអាចារ្យពោលសំដៅយកបទទាំងឡាយដែលថា **ទិព្វេន ចក្ខុនា** ជាដើម ។ ក្នុងបទថា **អាទីហិ** ជាដើមនេះមាន **ច**-ស័ព្ទដែលបាន សម្តែងទុក ដោយជាស័ព្ទដែលលុបចោល ។ ព្រោះដូច្នោះ ទើបមានសេចក្តីថា **ទិព្វេន ។ បេ ។ បស្សតីតិ ឥមេហិ ចវមានេតិ អាទីហិ ច ទិព្វចក្ខុកិច្ចំ វុត្តំ** ( ដោយបទទាំងនេះថា រមែងឃើញ ។ល។ ដោយចក្ខុដែលជាទិព្វ និងដោយបទ ទាំងនេះថា អ្នកកំពុងឃ្លាតចាកជាដើម គឺត្រាស់ដល់កិច្ចនៃទិព្វចក្ខុ ) ។

ពាក្យថា **ចំណែកដោយបទនេះ** គឺ ដោយពាក្យពោលថា **យថាកម្មុបគេ សត្តេ បជានាតិ** ( រមែងដឹងសត្វទាំងឡាយអ្នកចូលដល់តាមកម្ម ) នេះ ។ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុក្នុងសាសនានេះសំដៅដល់ ភិក្ខុអ្នកបានទិព្វចក្ខុញាណ ។ ភិក្ខុបានទិព្វចក្ខុញាណនោះ ជាអ្នកមើលឃើញសត្វនរកទាំងឡាយដោយប្រចក្ស ។ ពាក្យថា **រមែងមនសិការយ៉ាងនេះ** មានសេចក្តីថា ចូលឈានដែលជាបាទ ចេញ ហើយក៏មនសិការដោយទាក់ទងនឹងការបរិកម្ម ដោយអំណាចនៃសេចក្តីត្រូវការ នឹងដឹងកម្ម ដែលគួរដល់ការធ្វើនរកឲ្យប្រព្រឹត្តទៅព្រមនៃសត្វនរកទាំងនោះ ។

បទថា **កិន្នុខោ** ជាដើម ជាបទដែលសម្ដែងវិធីការនៃមនសិការ ។ ពាក្យទាំងអស់ដែលថា សម្រាប់ព្រះយោគីអ្នកធ្វើបរិកម្ម ចូលឈានដែលជាបាទ ចេញហើយយ៉ាងនេះ អាវជ្ជនៈរមែងកើតឡើងធ្វើកម្មនោះឲ្យជាអារម្មណ៍, កាលអាវជ្ជនៈរលត់ ទៅហើយ ជវន ៤ ឬថា ៥ ខណៈ រមែងស្ទុះទៅដូច្នេះជាដើម ក៏មានន័យដូចពោលមកហើយនោះឯង ។ ក៏ពាក្យថា ឈ្មោះថា នឹងមានការបរិកម្មជាផ្នែកមួយទៀតដោយឡែកក៏មិនមែន នេះលោកពោលទុកសំដៅដល់ **យថាកម្មុបគ-ញ្ញាណ** មិនមានការបរិកម្មជាផ្នែកមួយទៀតដោយឡែក វៀរចាកទិព្វចក្ខុញ្ញាណទេ ។ ពាក្យដែលលោកពោលយ៉ាងនេះ នេះគួរត្រូវការ , បើកាន់យកសេចក្ដីដោយប្រការដទៃ **យថាកម្មុបគញ្ញាណ** ក៏នឹងរកភាពជាមហគ្គតៈមិនបាន ។ សូម្បីក្នុងការប្រើទិព្វចក្ខុសម្លឹងមើលទេវតាទាំងឡាយ ក៏មានន័យដូច្នេះ ។ ការដែលលោកកាន់យកតែពួកសត្វនរក និងពួកទេវតាទាំងឡាយក្នុងទីនេះ គប្បីឃើញថាគ្រាន់តែជាឧទាហរណ៍ ។ ព្រោះថា ភិក្ខុអ្នកបានទិព្វចក្ខុនៅសង្ឃឹម រមែងបដិបត្តិយ៉ាងនេះក្នុងសត្វទាំងឡាយ អ្នកមានគតិយ៉ាងដទៃអំពីនិរយគតិ និងទេវគតិបានផងដែរ ។ ពិតយ៉ាងនោះ លោកនឹងពោលតទៅថា ដោយសព្ទថា **អបាយ** សំដៅដល់កំណើតតិរច្ឆានជាដើម , នឹងថា ដោយសព្ទថា **សុគតិ** រមែងសង្គ្រោះបានសូម្បីមនុស្សគតិ ដូច្នេះ ។ ញាណឈ្មោះថា **តំ កម្មារម្មណំ** ព្រោះអត្ថថា មានកម្មដែលគួរដល់ការធ្វើនរកឲ្យប្រព្រឹត្តទៅនោះ ជាអារម្មណ៍ ។ ដោយ**អាទិ**-សព្ទក្នុងបទថា **បារុសកវនាទីសុ**-សួនបារុសកវ័នជាដើម មានការរួមយកសួនចិត្តលតា-វ័នជាដើមផង ។

បទថា **យថា ចិមស្ស**( ដូចជាកម្មុបគញ្ញាណនេះ ) ដែរ លោកសម្ដែងដល់

ភាពមិនមាននៃការបរិកម្មជាផ្នែកមួយទៀត ដោយឡែកថា យថាកម្មុបគញ្ញាណនេះ មិនមានការបរិកម្មផ្នែកមួយទៀតដោយឡែក យ៉ាងណា សូម្បីអនាគតំសញ្ញាណក៏មិនមានការបរិកម្មជាផ្នែកមួយទៀតដោយឡែកដូច្នោះ ។ លោកពោលដល់ហេតុក្នុងការមិនមាននៃការបរិកម្មនោះទុកថា សេចក្ដីពិតថា ញាណពីរដែលមានទិព្វចក្ខុជាបាទនោះឯង រមែងសម្រេចព្រមនឹងទិព្វចក្ខុនេះតែម្ដង ដូច្នេះ ។ តទៅនេះជាពាក្យអធិប្បាយក្នុងពាក្យដែលពោលនោះ ដូចជា ភិក្ខុអ្នកបានទិព្វចក្ខុ ពង្រីកអាលោកកសិណាឆ្ពោះមុខទៅកាន់នរកជាដើម ឃើញសត្វទាំងឡាយ មានសត្វនរកជាដើមហើយ កាលបានត្រៀមចិត្តរបស់ខ្លួនទុក ដោយសមាទានការតាំងចិត្តនឹងដឹងកម្មដែលប្រាកដដូច្នោះ និងដោយមនសិការដែលកើតពីការសមាទាននោះ ក៏រមែងដឹងតាមសេចក្ដីពិតនូវកម្ម មានកម្មដែលគួរដល់ការធ្វើនរកឲ្យប្រព្រឹត្តទៅជាដើមដែលសត្វទាំងនោះប្រមូលទុកហើយក្នុងជាតិមុនបាន យ៉ាងណា ភិក្ខុអ្នកត្រូវការដឹងអត្តភាពអនាគត ក្នុងជាតិបន្ទាប់ទៅរបស់សត្វណាៗ ក៏ពង្រីកអាលោកកសិណាចោះចំពោះសត្វនោះៗ ឃើញកម្មដែលធ្វើអត្តភាពនោះឲ្យកើតឡើង ដែលសត្វនោះៗបានប្រមូលទុកក្នុងជាតិអតីតខ្លះ ក្នុងជាតិបច្ចុប្បន្ននេះខ្លះ ដោយយថាកម្មុបគញ្ញាណ ហើយកាលបានចាត់ត្រៀមទុកដោយការសមាទានដែលប្រាកដដូច្នោះ និងដោយមនសិការដែលកើតពីការសមាទាននោះហើយ ភិក្ខុអ្នកត្រូវការនឹងដឹងអត្តភាពអនាគតដែលកម្មនោះ គប្បីធ្វើឲ្យកើតឡើង ក៏រមែងដឹងតាមសេចក្ដីពិតបានដូច្នោះៗ ក្នុងអត្តភាពសូម្បីដទៃពីអត្តភាពនោះ ក៏មានន័យដូច្នេះដែរ ។ ញាណនេះ ឈ្មោះថា **អនាគតំសញ្ញាណ** ព្រោះហេតុដែលញាណទាំងពីរនេះរមែងសម្រេច កាលមានទិព្វចក្ខុញ្ញាណនោះឯង កាលមិនមានទិព្វចក្ខុញ្ញាណ ក៏រមែងសម្រេចមិនបាន ព្រោះ

ហេតុនោះ ទើបលោកអាចារ្យពោលថា ញាណទាំងនេះ រមែងសម្រេចព្រមនឹងទិព្វចក្ខុផងដែរ ។

គប្បីប្រកបសេចក្ដីយ៉ាងនេះថា ការប្រព្រឹត្តមិនល្អក្នុងកាយ , ឬការប្រព្រឹត្តមិនល្អ ព្រោះមានការស្អុយ គឺ កិលេសដែលកើតឡើងតាមផ្លូវកាយ ឈ្មោះថា កាយទុច្ចរិត ។ ក្នុងពាក្យថា **កាយនេះ** លោកបំណងយក **ចោបនកាយ** ( ការកម្រើកកាយ ) ។ កាយកម្មដែលជាអកុសល ដែលប្រព្រឹត្តទៅដោយអំណាចកាយវិញ្ញត្តិ ឈ្មោះថា កាយទុច្ចរិត ។ ពាក្យថា **ក្នុងបទដទៃ** គឺក្នុងវចីទុច្ចរិត និងមនោទុច្ចរិត ។ ពួកសត្វបានសន្សំកម្មទុកក្នុងសន្តានណា កាលកម្មនេះនៅមិនទាន់មានការដាច់ខ្សែទៅក្នុងរវាង ព្រោះនៅមិនទាន់ប្រាសចាកភាពជារបស់គួរដល់វិបាក, ក៏គួរពោលដល់សន្តាននោះថា ប្រព្រឹតទៅព្រមជាមួយកម្មនោះដូច្នេះបានផងដែរ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា " បទថា **យថា សមន្នាគតា** គឺជាអ្នកព្រមព្រៀង " ដូច្នេះ ។ ដោយពាក្យថា ជាអ្នកប្រាថ្នាហាយនភាពនេះជាដើមនេះ លោកសម្ដែងថា សត្វទាំងឡាយនឹងជាអ្នកប្រាថ្នាប្រយោជន៍ មិនជាអ្នកតិះដៀល ជេរស្ដី ដូចមាតាបិតាជាអ្នកប្រាថ្នាប្រយោជន៍ដល់បុត្រទាំងឡាយ ឬដូចអាចារ្យ និងឧបជ្ឈាយ៍ ជាអ្នកប្រាថ្នាប្រយោជន៍ដល់សិស្សទាំងឡាយ អ្នកអាស្រ័យនៅដូច្នោះ ។ ពាក្យថា **ដោយការញ៉ាំញីនូវគុណធម៌** គឺ ដោយការញ៉ាំញីនូវគុណធម៌ទាំងឡាយដែលមានប្រាកដ មានសេចក្ដីថា ធ្វើឲ្យសាបសូន្យ ។ សួរថា ការជេរស្ដីដោយរឿងអន្តិមវត្ថុ ក៏ជាការញ៉ាំញីគុណធម៌នោះឯង មិនមែនឬ ? ឆ្លើយថា សេចក្ដីដែលពោលមកនេះក៏ជាការពិត តែក្នុងពាក្យថា គុណធម៌នេះ លោកបំណងយកគុណវិសេសទាំងឡាយ មានឈានជាដើមដែលជាឧត្តរិមនុស្សធម៌ ព្រោះហេតុ

នោះ ទើបលោកកាន់យកការញ៉ាំញីគុណធម៌ គឺ សីល ទុកជាប្រការមួយដោយឡែក ។ ព្រោះហេតុនោះ ទើបលោកពោលថា មនុស្សទាំងនេះមិនមានសមណធម៌ទេ ដូច្នេះជាដើម ។ ពាក្យថា **សមណធម៌** លោកពោលសំដៅយកការសង្រួមក្នុងសីល ។ ពាក្យថា **ដឹងក៏ដោយ** មានសេចក្តីថា ជេរស្តីបុគ្គលណា ដឹងថាបុគ្គលនោះជាព្រះអរិយបុគ្គលក៏ដោយ ។ បទថា **អជានំ វា** កែជា **អជានន្តោ វា** ( មិនដឹងក៏ដោយ ) ។ ការដែលដឹង និងមិនដឹង មិនជាប្រមាណក្នុងកម្មនេះទេ ភាពជាព្រះអរិយបុគ្គលប៉ុណ្ណោះជាប្រមាណ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ក៏ចាត់ជាអរិយុបវាទទាំងពីរប្រការ ។ អាចារ្យជាច្រើនពោលថាសម្រាប់បុគ្គលអ្នកមិនដឹងថា ជាព្រះអរិយបុគ្គល មិនមានចិត្តប្រទូស្តឡើយ ប្រកាសការមិនមាននៃអរិយគុណក្នុងព្រះអរិយបុគ្គលនោះ មិនឈ្មោះថា មានការញ៉ាំញីគុណធម៌ ព្រោះហេតុនោះ អរិយុបវាទទើបមិនមានដល់បុគ្គលនោះដូច្នេះ ។ ឈ្មោះថា ប៉ុន្តែជាកម្មដែលមានការកែខៃបាន គឺ ដោយការសូមខមាទោស និងជាកម្មដែលកែខៃមិនបាន ដូចអនន្តរិយកម្មក៏ទេ ។

បទថា **វុដ្ឋតិ** ប្រែថា ចាក់ដោត មានសេចក្តីថា ធ្វើទុក្ខវេទនាឲ្យកើតឡើង ។ បទថា **តំ** បានដល់ ព្រះថេរៈនោះ ឬកិរិយាដែលអង្គុយធាន់លើកំណាត់ឈើនោះ ។ ព្រះថេរៈនោះដឹងហើយ ក៏នៅសួរថា អ្នកមានទីពឹងឬទេដូច្នេះ ។ ភិក្ខុកំលោះនោះដឹងថា ការត្រាស់ដឹងសច្ចធម៌ ចាត់ជាទីពឹងក្នុងព្រះសាសនា ទើបពោលថា ខ្ញុំជាព្រះសោតាបន្នដូច្នេះ ។ ព្រះថេរៈអាណិតភិក្ខុកំលោះ ទើបបង្ហាញខ្លួនឯងថា លោកបានតិះដៀលព្រះខីណាស្រពហើយ ដូច្នេះ ។

ឈ្មោះថា បើពួកលោកជាអ្នកខ្ជីវស្សាជាង ក៏បានដល់ពួកភិក្ខុក្នុងវិហារនោះ ។

ពាក្យថា **កាលមិនបានសូមខមាទោសចំពោះមុខ** គឺ កាលមិនមានការសូមខមាទោសនៅចំពោះមុខបាន ។ បាឋៈថា **អខមន្តេ**( កាលលោកមិនបានអត់ទោស ) ឲ្យដូច្នេះក៏បាន ។ បណ្ឌិតគប្បីជ្រាបពាក្យដែលពោលនោះ ដែលទាក់ទងនឹងលោកដែលជាព្រះសោតាបន្នចុះ ។

ពាក្យថា **ទីតាំងត្រៃដែលលោកបរិនិព្វាន** លោកអាចារ្យសំដៅយកស្ថានទីដែលធ្វើការបូជា ។ ឈ្មោះថា **សមាទាន** ដោយសេចក្ដីថា ជាវត្ថុដែលសត្វគប្បីកាន់យកដោយប្រពៃ សត្វពួកណាមានកម្មជាវត្ថុសមាទាន សត្វពួកនោះឈ្មោះថា **កម្មសមាទានា** សត្វទាំងឡាយមានកម្មជាវត្ថុ សមាទានដោយអំណាចនៃមិច្ឆាទិដ្ឋិ , ឬថា ព្រោះធ្វើជាហេតុឲ្យធ្លាក់ចុះក្នុងសត្វទាំងឡាយ អ្នកញុំាងសត្វដទៃឲ្យកាន់យកដោយប្រពៃក្នុងកម្មទាំងឡាយ ដោយអំណាចនៃមិច្ឆាទិដ្ឋិ ឈ្មោះថា **មិច្ឆាទិដ្ឋិកម្មសមាទានា**( មានកម្មជាវត្ថុដែលសមាទានដោយអំណាចនៃមិច្ឆាទិដ្ឋិ ) ។ លោកអាចារ្យកាលនឹងសម្ដែងដល់សេចក្ដីនេះនោះ ទើបលោកពោលថា **មិច្ឆាទិដ្ឋិវសេន** ដូច្នេះជាដើម ។ ពាក្យថា **ភិក្ខុអ្នកដល់ព្រមដោយសីលជាដើម** លោកពោលទុកដោយទាក់ទងនឹងបុគ្គលអ្នកដល់ព្រមដោយមគ្គ អ្នកមានឥន្ទ្រិយចាស់ក្លាដោយជុំវិញហើយ ។ ចំណែកក្នុងលោកអ្នកដែលតាំងនៅក្នុងមគ្គជាន់កំពូល( អរហត្តមគ្គ ) មិនមានពាក្យដែលត្រូវពោលឡើយ ។ បទថា **អញ្ញំ** បានដល់ ព្រះអរហត្តផល ។ ពាក្យថា **ឧបមេយ្យក៏ដូច្នោះ** មានសេចក្ដីថា ប្រការនោះ រមែងមានបានជាពិតប្រាកដយ៉ាងណា សូម្បីប្រការនេះ ក៏រមែងមានបានជាពិតប្រាកដយ៉ាងដូច្នោះ ។ ក្នុងពាក្យថា មិនលះវាចានោះជាដើម កាលសម្ដែងយកអរិយុបវាទពោល ថាយើងនឹងមិនពោលវាចាបែបនេះទៀត ក៏ឈ្មោះថា លះវាចា , កាលគិតថា យើងនឹងមិន

ធ្វើការគិតដូច្នេះឲ្យកើតឡើងទៀតដូច្នេះ ក៏ឈ្មោះថា លះចិត្ត( ការគិត ) , កាលគិតថា យើងនឹងមិនប្រកាន់ទិដ្ឋិដូច្នេះទៀត ដូច្នេះហើយលះបោល ក៏ឈ្មោះថា លះទិដ្ឋិ , កាលមិនធ្វើតាមប្រការដូចពោលមកនោះ ក៏ឈ្មោះថាមិនលះនោះឯង មិនបោះបង់ ។ ពាក្យថា **រមែងជាអ្នកត្រូវធ្លាក់ទៅក្នុងនរកដូចប្រានទម្លាក់** មានសេចក្តីថា រមែងជាអ្នកតាំងនៅ ដូចត្រូវពួកនិរយបាលទាំងឡាយក្រៀកខ្លួន ទៅតាំងទុកនៅក្នុងនរកដូច្នោះ ។ ឈ្មោះថា **បាបដែលមិនត្រូវធ្វើ ដោយអំណាចមិច្ឆាទិដ្ឋិមិនមាន** ដែលជាហេតុឲ្យឈ្មោះថា ជាតំណាននៃសង្សារវដ្ត ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានមិច្ឆាទិដ្ឋិជាទោសយ៉ាងក្រៃលែង ដូច្នេះ ។

**កាយ**-ស័ព្ទក្នុងបទថា **កាយស្ស ភេទា** នេះ មានខន្ធ ៥ ជាវិស័យ ដូចក្នុងប្រយោគយ៉ាងនេះថា **ឧច្ឆិន្ន ភវនេត្តិកោ ភិក្ខវេ តថាគតស្ស កាយោ តិដ្ឋតិ** ប្រែថា ម្នាលភិក្ខុទាំងឡាយ កាយរបស់តថាគតតាំងនៅ ជាកាយដែលកាត់ផ្តាច់ភវតណ្ហា អ្នកនាំទៅចំពោះភពបានហើយ និងក្នុងប្រយោគថា **អយញ្ចេវ កាយោ ពហិទ្ធា ច នាមរូបំ** ( ប្រែថា កាយនេះក្តី នាមរូបក្នុងខាងក្រៅក្តី ) ដូច្នេះជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា បទថា **កាយស្ស ភេទា** គឺ ព្រោះការលះបង់ឧបាទិនខន្ធ ដូច្នេះ ។ ឈ្មោះថា ក្រោយពីការស្លាប់នៃបុគ្គលអ្នកនៅមិនទាន់ប្រាសចាកភគៈ គឺ ការប្រកាន់ភពបន្ទាប់ទៅនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា បទថា **បរម្មរណា** គឺ ក្នុងការកាន់យកខន្ធដែលកើតឡើងហើយក្នុងលំដាប់នៃឧបាទានក្ខន្ធ ដែលបានលះបង់ទៅនោះ ដូច្នេះ ។ កាយតាំងនៅបាន ព្រោះជីវិតិន្ទ្រិយណា ព្រោះជីវិតិន្ទ្រិយនោះដាច់ទៅនោះឯង កាយទើបបែកធ្លាយ

ទៅ ព្រោះហេតុនោះ ទើបលោកពោលថា ន័យមួយទៀត បទថា **កាយស្ស ភេទា** គឺ ព្រោះការដាច់ទៅនៃជីវិតិន្ទ្រិយ ដូច្នេះ ។

បុណ្យ ឈ្មោះថា **អាយ** ព្រោះអត្ថថា ជាដែនមកនៃសេចក្ដីសុខ ព្រោះហេតុនោះ ទើបលោកពោលថា **អាយ** ដែលពួកជនតែងដឹងថាបុណ្យដូច្នេះ ។ ហេតុឲ្យសម្រេចសេចក្ដីសុខ មានកម្មដែលជាបុណ្យជាដើម ក៏ឈ្មោះថា **អាយ** ព្រោះអត្ថថា ជាហេតុមកនៃសេចក្ដីសុខទាំងឡាយ , ព្រោះហេតុនោះ ទើបលោកពោលថា ព្រោះមិនមានអាយៈ គឺ ហេតុមកនៃសេចក្ដីសុខទាំងឡាយដូច្នេះ ។ **អស្សាទ** គឺ សេចក្ដីត្រេកអរ ឈ្មោះថា **អាយ** ព្រោះអត្ថថា ដែលសត្វសម្រេច គឺ ត្រេកអរ ព្រោះហេតុនោះ ទើបលោកពោលថា **អស្សាទ សញ្ញិតោ អាយោ** អាយៈដែលពួកជនតែងថា ជាសេចក្ដីត្រេកអរ ដូច្នេះ ។

ដោយ**អាទិ**-ស័ព្ទក្នុងបទថា **នាគរាជាទីនំ**-សត្វអ្នកមានស័ក្ដិធំ មានស្ដេចនាគជាដើម មានការរួមយកសត្វអ្នកមានស័ក្ដិធំទាំងឡាយ មានគ្រុឌជាដើមផង។ ពាក្យថា **ដូចពួកអសុរកាយ** គឺដូចពួកអសុរកាយដែលជាប្រេត ។ បទថា **សោ** បានដល់ អសុរកាយ ។ បទថា **សព្វសមុស្សយេហិ** គឺ អំពីភោគសម្បត្តិទាំងពួង ។ ពាក្យថា **ដោយបរិយាយផ្ទុយគ្នាតាមដែលពោលមកហើយ** គឺដោយបរិយាយផ្ទុយគ្នាចំពោះអត្ថដែលបានពោលហើយនៃបទថា **កាយទុច្ចរិតេន** ជាដើម ដោយន័យថា ឈ្មោះថា សុចរិត ព្រោះអត្ថថា ជាការប្រព្រឹត្តល្អ ឬជាការប្រព្រឹត្តត្រូវ ព្រោះមិនមានទោសជាដើម ។

ឈ្មោះថា **ពាក្យនិគម** ព្រោះធ្វើអធិប្បាយថា ជាពាក្យដែលពោលដល់សេចក្ដីដែលបានពោលមកហើយនោះឯងទៀត ។ ពាក្យថា **សេចក្ដីសង្ខេបនេះ ក្នុងពាក្យ**

**និគមនេះ** គឺ សេចក្ដីសង្ខេបតាមដែលបានពោលទុកនេះ ក្នុងពាក្យនេះថា **ទិព្វេន ចក្ខុនា ។ បេ ។ បស្សតិ** ( ប្រើទិព្វចក្ខុសម្លឹងមើល ។ ល ។ ) ដូច្នេះ ។

ពាក្យថា **មានកសិណជាអារម្មណ៍** គឺមានកសិណដោយទាក់ទងនឹងកសិណទាំង ៨ ជាអារម្មណ៍ ។ ពាក្យថា **ដោយអាការទាំងពួង** គឺ ដោយប្រការទាំងពួងដែលថា ភិក្ខុអ្នកមានការហ្វឹកហាត់ចិត្តដោយអាការ ១៤ អ្នកប្រកបព្រមដោយអង្គ ៨ អ្នកមានការធ្វើភូមិ បាទ បទ និងមូលនៃឫទ្ធិឲ្យដល់ព្រម ដូច្នេះ ។ ពាក្យថា **ឲ្យគួរដល់ការបង្អោនទៅ** គឺធ្វើឲ្យគួរដល់ការបញ្ជូនទៅ ឲ្យសមគួរដល់ការបញ្ជូនទៅចំពោះមុខទិព្វចក្ខុញាណ ។ ពាក្យថា **គប្បីធ្វើឲ្យនៅជិត** គឺគប្បីធ្វើឲ្យនៅក្នុងទីជិតចំពោះការឧប្បត្តិនៃទិព្វចក្ខុញាណ ។ គប្បីធ្វើឧបចារឈានក្នុងកសិណនោះ ឲ្យស្ងាត់ជំនាញក្រៃលែង ហើយពង្រីកអារម្មណ៍ផង ។ ព្រោះហេតុនោះ ទើបលោកពោលថា គប្បីធ្វើឧបចារឈានឲ្យជាគោចរ ពង្រីកកសិណារម្មណ៍ ហើយទប់ទុកដូច្នេះ ។ បទថា **តត្ថ** គឺ ក្នុងកសិណារម្មណ៍ដែលបានពង្រីកទុកនោះ ។ ពាក្យថា **អប្បនា** បានដល់ អប្បនាដោយទាក់ទងនឹងឈាន ។ ព្រោះថា ព្រះយោគីដែលមិនបានធ្វើបរិកម្មទុក មិនសម្រេចអប្បនាដោយទាក់ទងនឹងអភិញ្ញាទេ ។ ព្រោះហេតុនោះ ទើបលោកពោលថា អារម្មណ៍នោះនឹងជាទីអាស្រ័យនៃឈានដែលជាបាទទៅ ដូច្នេះ មានសេចក្ដីថា នឹងជាអារម្មណ៍នៃឈានដែលជាបាទ ។ ពាក្យថា **មិនជាទីអាស្រ័យនៃបរិកម្ម** គឺ កសិណារម្មណ៍នោះមិនជាទីអាស្រ័យនៃបរិកម្ម ។ កាលបើយ៉ាងនោះ ក៏មិនមានការឃើញរូបបាន ។ ពាក្យថា **ក្នុងកសិណទាំងនេះ** បានដល់ ក្នុងកសិណ ៣ យ៉ាង មានតេជោកសិណជាដើមតាមដែលពោលហើយ។ ពាក្យថា **ធ្វើឲ្យកើតឡើង** គឺ ធ្វើឲ្យកើតឡើងដោយការធ្វើឧបចារឈានឲ្យកើត

ឡើង ។ ព្រោះថា ការឧប្បត្តិនៃបដិភាគនិមិត្ត រមែងមានព្រមនឹងការប្រព្រឹត្តទៅនៃឧបចារឈាន ។ បទថា **តត្ថ** បានដល់ ក្នុងកសិណនិទ្ទេស ។

ឈ្មោះថា **គប្បីសម្លឹងមើលរូបខាងក្នុងប៉ុណ្ណោះ** គឺ មិនគប្បីសម្លឹងមើលរូបខាងក្រៅ ព្រោះជាហេតុនាំឲ្យរាយមាយ ។ ក្នុងពាក្យថា **វារៈនៃបរិកម្មក៏កន្លងទៅនេះ** មានសេចក្ដីថា ឧបចារឈានក្នុងកសិណារម្មណ៍តាមដែលបានពោលហើយ ឈ្មោះថា **បរិកម្ម** កាលព្រះយោគីសម្លឹងមើលរូប បរិកម្មនោះក៏រមែងមិនប្រព្រឹត្តទៅ ។ម្យ៉ាងទៀត ការសម្លឹងមើលរូបរមែងមានបានដោយអំណាចនៃពន្លឺដែលជាកសិណ និងពន្លឺដែលជាកសិណក៏រមែងមានបាន ដោយអំណាចនៃការបរិកម្ម ព្រោះហេតុនោះ ព្រោះបរិកម្មមិនប្រព្រឹត្តទៅ ការមើលរូប និងពន្លឺដែលជាកសិណរួមពីរយ៉ាងនោះ ក៏មិនមាន ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះហេតុនោះ ពន្លឺក៏វិនាសបាត់ទៅ កាលពន្លឺនោះវិនាសបាត់ទៅហើយ រូបក៏មិនប្រាកដ ។ កាលលោកអាចារ្យធ្វើទុកក្នុងចិត្តថា កាលព្រះយោគីកំពុងសម្លឹង មើលរូប វារៈនៃបរិកម្មកន្លងផុតទៅ , សម្រាប់ព្រះយោគីអ្នកមានបរិកម្មកន្លងទៅហើយ រមែងមិនមានញាណដែលមានកសិណជាអារម្មណ៍ ព្រោះហេតុនោះ រូបក៏មិនប្រាកដ ។ ក៏ព្រះយោគីគប្បីបដិបត្តិយ៉ាងដូចម្ដេចហ្ន៎ ដូច្នេះហើយ ទើបពោលថា កាលបើដូច្នោះ ព្រះយោគាវចរនេះ ដូច្នេះជាដើម ។ ពាក្យថា **តាមលំដាប់ដោយប្រការនេះ** មានសេចក្ដីថា ពន្លឺនឹងមានកម្លាំងតាំងនៅបានយូរ ក៏ដោយអំណាចនៃការដែលព្រះយោគីចូលឈាន ដែលជាបាទម្ដងហើយម្ដងទៀត ចេញពីឈាននោះៗហើយ ក៏ផ្សាយពន្លឺទៅរឿយៗ ។ កាលបើយ៉ាងនោះ រមែងមើលឃើញរូបក្នុងពន្លឺនោះបានស្ទើរអស់កាលយូរ ។ ព្រោះហេតុនោះ ទើបលោកពោលថា លោកកំណត់ស្ថានទី

ប៉ុនណាថា សូមឲ្យពន្លឺចូរមានក្នុងស្ថានទីនេះចុះ ។ល។ ការឃើញរូបរមែង មាន ដល់លោកអ្នកអន្ទុយសម្លឹងមើល សូម្បីអស់មួយថ្ងៃ ។

លោកអាចារ្យកាលនឹងសម្តែងថា សេចក្តីខនេះនោះ គប្បីឲ្យជាក់ច្បាស់បាន ដោយរឿងគប់ភ្លើងស្មៅជាឧបមា ដូច្នេះទើបពោលថា បុរសម្នាក់ធ្វើដំណើរអស់ ១ យប់ ដោយគប់ភ្លើងស្មៅដូច្នេះជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា **ការចូលរឿយៗ** គឺការចូលឈានដែលជាបាទរឿយៗ ។ ពាក្យថា **ការតាំងនៅនៃពន្លឺដ៏មានកម្លាំងតាមស្ថានទីដែលកំណត់ទុក** មានសេចក្តីថា ការដែលកំណត់ស្ថានទីប៉ុនណាទុកហើយ ពន្រឹកកសិណ ពន្លឺដ៏មានកម្លាំងក៏តាំងចុះ ផ្សាយទៅរហូតទីប៉ុណ្ណោះ ។

ពាក្យថា **មិនដល់គន្លង** លោកពោលទុកដោយទាក់ទងនឹងភាពជារូបដែលគួរដល់ការមកកាន់គន្លងមំសចក្ខុបាន ។ ចំណែករូបដែលនៅខាងក្នុងជាដើម ជារូបដែលគប្បីធ្វើឲ្យពិសេសទៅពីរូបដែលគួរដល់ការមកកាន់គន្លងនោះឯង ព្រោះមិនមានភាពជារូបដែលគួរដល់ការមកកាន់គន្លងនោះ ។ បទថា **តទេវ** ប្រែថា ទិព្វចក្ខុប៉ុណ្ណោះ ។ បទថា **ឯត្ថ** គឺ ក្នុងបណ្តាចិត្តទាំងនេះ ដែលប្រព្រឹត្តទៅប្រារព្ធរូប ។ ពាក្យថា **ជាចិត្តអាចឃើញរូប** គឺជាចិត្តដែលអាចរមិលមើលរូបបាន ដោយសភាវៈដូចចក្ខុវិញ្ញាណដូច្នោះ ។ ពាក្យថា **ចិត្តដែលជាចំណែកខាងដើមទាំងឡាយ** បានដល់ ចិត្តដែលជាចំណែកខាងដើមទាំងឡាយ ដែលរាប់ថាជាការនឹក និងការបរិកម្ម ។ ពិតហើយ ចិត្តទាំងនោះ សូម្បីកាលធ្វើរូបឲ្យជាអារម្មណ៍បាន ក៏មិនបានប្រព្រឹត្តទៅរមិលមើលរូបនោះបាន តាមសេចក្តីពិត ដូចអាវជ្ជនចិត្ត និងសម្បដិច្ឆន្នចិត្តដូច្នោះ ។

បទថា **តំ បនេតំ** បានដល់ ទិព្វចក្ខុ ។ ពាក្យថា **អន្តរាយ** គឺ មានអន្តរាយ ។

ពាក្យថា **មនុស្សភ្លួត** ព្រោះឈាន បានដល់ មនុស្សភ្លួតព្រោះឈាន គឺដល់ការភ្លួត ព្រោះការចម្រើនឈានជាហេតុ ។ ពាក្យថា **ត្រូវជាអ្នកមិនប្រមាទ** គឺកុំត្រេកអរនឹងរបស់ដែលមានថា យើងបានសម្រេចទិព្វចក្ខុហើយដូច្នេះ ត្រូវជាអ្នកមិនប្រមាទ គឺ ដោយអំណាចការប្រកបរឿយៗនូវវិបស្សនា ឬ ដោយអំណាចការត្រាស់ដឹងសច្ចៈ ។

លោកអាចារ្យបំណងសម្ដែងថា ដោយពាក្យថា កុលបុត្តអ្នកជាអាទិកម្មិកៈអ្នកត្រូវការនឹងឃើញយ៉ាងនេះជាដើម ជាការសម្ដែងបរិកម្មដែលមានអាវជ្ជនៈផ្សេងៗគ្នានៃទិព្វចក្ខុ និងទិព្វចក្ខុញ្ញាណ មិនមែនជាការសម្ដែងលំដាប់ការកើតឡើងនៃទិព្វចក្ខុនោះ ដូច្នេះទើបពោលថា ក្នុងការកើតឡើងនៃទិព្វចក្ខុនោះតទៅនេះដូច្នេះជាដើម ។ ពាក្យនោះ បណ្ឌិតគប្បីដឹងបានងាយតែម្ដង ព្រោះមានន័យដូចដែលបានពោលហើយក្នុងខាងដើម ។

( ចប់ ការពណ៌នា ស្ដីពីចុតូបបាតញ្ញាណ )

## បកិណ្ណកកថា

ម្យ៉ាងទៀត ព្រះលោកនាថទ្រង់ត្រាស់ដឹងខន្ធ ៥ បានត្រាស់អភិញ្ញា ៥ ឯណាទុកដោយប្រការដូចពោលមកហើយនេះ បណ្ឌិតបានជ្រាបអភិញ្ញា ៥ នោះហើយ គប្បីជ្រាបបកិណ្ណកកថាក្នុងអភិញ្ញា ៥ នោះដូចតទៅនេះខ្លះទៀត ។

ក៏ក្នុងអភិញ្ញា ៥ នោះ **ទិព្វចក្ខុ** ពោលគឺ **ចុតូបបាតញ្ញាណ**នោះ មានបរិកណ្ឌញ្ញាណ ( ញាណជាបរិវារ ) ពីរយ៉ាង គឺ អនាគតំសញ្ញាណ និងយថាកម្មូបគញ្ញាណ ព្រោះដូច្នោះ អភិញ្ញាញាណមកក្នុងទីនេះ ទើបជាញាណ ៧ គឺ បរិកណ្ឌញ្ញាណពីរនេះ និងតួអភិញ្ញាញាណ ៥ មានឥទ្ធិវិធញ្ញាណជាដើម , ឥឡូវនេះ

**បណ្ឌិតគប្បីសម្តែងការប្រព្រឹត្តទៅនៃអភិញ្ញាញាណ ៧ ក្នុងអារម្មណតិកៈ ៤ ដែលព្រះមហាឥសីត្រាស់ទុក ។**

ដើម្បីមិនឲ្យវង្វេងក្នុងការចែកអារម្មណ៍នៃអភិញ្ញាញាណទាំងនោះ នេះជាការសម្តែងក្នុងអារម្មណតិកៈនោះ ។

អារម្មណតិកៈ( ពួក ៣ នៃអារម្មណ៍ ) ៤ យ៉ាង , ព្រះមហាឥសីត្រាស់ទុកអារម្មណតិកៈ ៤ យ៉ាង គឺអ្វីខ្លះ គឺ បរិត្តារម្មណតិកៈ( ពួក ៣ នៃបរិត្តារម្មណ៍ ) មគ្គារម្មណតិកៈ( ពួក ៣ នៃមគ្គារម្មណ៍ ) អតីតារម្មណតិកៈ( ពួក ៣ នៃអតីតារម្មណ៍ ) អជ្ឈត្តារម្មណតិកៈ( ពួក ៣ នៃអជ្ឈត្តារម្មណ៍ ) ។

## ឥទ្ធិវិធញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍៧

ក្នុងអភិញ្ញាញាណទាំងនោះ ឥទ្ធិវិធញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍ ៧ ដែលជាបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អតីតារម្មណ៍ អនាគតារម្មណ៍ បច្ចុប្បន្នារម្មណ៍

អជ្ឈត្តារម្មណ៍ និងពហិទ្ធារម្មណ៍ សួរថា ប្រព្រឹត្តទៅយ៉ាងដូចម្តេច ? ឆ្លើយថា ក៏ឥទ្ធិវិធញ្ញាណនោះ ចាត់ជាបរិត្តារម្មណ៍ ក៏ព្រោះមានរូបកាយជាអារម្មណ៍ ដោយធ្វើអត្ថន័យដល់ សេចក្តីថា កាលណាព្រះយោគីធ្វើកាយឲ្យអាស្រ័យចិត្ត ប្រាថ្នានឹងទៅដោយអទិស្សមានកាយ( កាយមិនប្រាកដ គឺ គ្មានអ្នកណាមើលឃើញ ) ក៏បង្អោនកាយទៅតាមអំណាចចិត្ត ដាក់រូបកាយចុះទៅក្នុងមហគ្គតចិត្ត ធ្វើរូបកាយចុះទៅក្នុងមហគ្គតចិត្ត កាលនោះ រូបកាយក៏ជាអារម្មណ៍ដែលបានឧបយោគ គឺ ប្រើការបានដូចចិត្ត ដូច្នេះ ។

ចាត់ជាមហគ្គតារម្មណ៍ ក៏ព្រោះមានមហគ្គតចិត្តជាអារម្មណ៍ ដោយធ្វើអត្ថន័យដល់សេចក្តីថា កាលណាព្រះយោគីធ្វើចិត្តឲ្យអាស្រ័យកាយ ប្រាថ្នានឹងទៅដោយទិស្សមានកាយ( កាយប្រាកដ គឺអ្នកណាៗ ក៏មើលឃើញ ) ក៏បង្អោនចិត្តទៅតាមអំណាចកាយ ដាក់បាទកឈានចិត្តចុះទៅក្នុងរូបកាយ ធ្វើបាទកឈានចិត្តចុះទៅក្នុងរូបកាយ កាលនោះបាទកឈានចិត្តក៏ជាអារម្មណ៍ដែលបានឧបយោគ( ប្រើការបានដូចរូបកាយ ) ដូច្នេះ ។

ម្យ៉ាងទៀត ចាត់ជាអតីតារម្មណ៍ ក៏ព្រោះធ្វើបាទកឈានចិត្តនោះឯង ដែលកន្លងទៅហើយ គឺ រលត់ទៅហើយ ឲ្យជាអារម្មណ៍ ។

ជាអនាគតារម្មណ៍សម្រាប់ព្រះយោគីទាំងឡាយអ្នកអធិដ្ឋានឫទ្ធិទុកជាអនាគត ដូចព្រះថេរៈទាំងឡាយ មានព្រះមហាកស្សបត្ថេរជាដើម អធិដ្ឋានទុកក្នុងការបញ្ចុះព្រះមហាធាតុ បានឮថា ព្រះមហាកស្សបត្ថេរកាលបញ្ចុះព្រះមហាធាតុ បានអធិដ្ឋានទុកថា រយៈពេល ២១៨ ឆ្នាំ ក្នុងអនាគត ក្លិនក្រអូបទាំងឡាយនេះកុំអស់ទៅ ផ្កាទាំងនេះកុំក្រៀមស្វិតទៅ ប្រទីបទាំងនេះកុំរលត់ទៅ ដូច្នេះ របស់ទាំងអស់នោះក៏បាន

ប្រាកដតាមដែលបានអធិដ្ឋាននោះឯង ។

ព្រះអស្សគុត្តត្ថេរឃើញពួកភិក្ខុក្នុងវត្តនិយសេនាសនៈឆាន់បាយសៗ គឺបាយទទេ មិនមានសម្លលាយឡើយ ទើបអធិដ្ឋានទុកថា ទឹកក្នុងត្រពាំងចូរជាទឹកដោះខាប់( ខាប់លាយបាយបាន ) ក្នុងពេលបុរេភត្តរាល់ថ្ងៃ ដូច្នេះ ទឹកក្នុងត្រពាំងនោះដែលភិក្ខុដងយកក្នុងបុរេភត្ត ក៏ក្លាយជាទឹកដោះខាប់ទៅ កាលបច្ឆាភត្តវាក៏ក្លាយជាទឹកតាមប្រក្រតីនោះឯង ។

តែជាបច្ចុប្បន្នារម្មណ៍ក្នុងកាលដែលព្រះយោគីធ្វើកាយ ឲ្យអាស្រ័យចិត្តទៅដោយអទិស្សមានកាយ ។

ជាអជ្ឈត្តារម្មណ៍ដោយការធ្វើកាយ និងចិត្តរបស់ខ្លួនឲ្យជាអារម្មណ៍ ក្នុងកាលដែលបង្អោនចិត្តទៅតាមអំណាចកាយ ឬបង្អោនកាយទៅតាមអំណាចចិត្ត និងក្នុងកាលដែលនិម្មិតខ្លួនជាភេទផ្សេងៗ មានភេទកុមារជាដើម តែក្នុងកាលដែលសម្តែងរូបផ្សេងៗ មានដំរីសេះជាដើម ដែលជាវត្ថុខាងក្រៅកាយរបស់ខ្លួន ក៏ជាពហិទ្ធារម្មណ៍ ដូច្នេះ ។

សេចក្តីដែលឥទ្ធិវិធញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍ ៧ បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលមកនេះជាលំដាប់ដំបូង ។

## ទិព្វសោតធាតុញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍៤

ទិព្វសោតធាតុញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍៤ ដោយជាបរិត្តារម្មណ៍ បច្ចុប្បន្នារម្មណ៍ អជ្ឈត្តារម្មណ៍ និងពហិទ្ធារម្មណ៍ សួរថា ប្រព្រឹត្តទៅយ៉ាងដូចម្តេច ? ឆ្លើយថា ក៏ទិព្វសោតធាតុញ្ញាណនោះ ព្រោះហេតុដែលធ្វើសំឡេងឲ្យជាអារម្មណ៍

និងសំឡេងជាបរិត្តធម៌( ជាកាមាវចរ ) ព្រោះហេតុនោះ ទើបជាបរិត្តារម្មណ៍ តែព្រោះធ្វើសំឡេងដែលកំពុងមាន( កំពុងប្រព្រឹត្តទៅ ) នោះឯងឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ ទើបជាបច្ចុប្បន្នារម្មណ៍ ក្នុងកាលដែលបានឮសំឡេងសត្វក្នុងពោះរបស់ខ្លួន ទិព្វសោតធាតុញ្ញាណនោះក៏ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដែលបានឮសំឡេងរបស់អ្នកដទៃ ក៏ជាពហិទ្ធារម្មណ៍ សេចក្ដីដែលទិព្វសោតធាតុញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ បណ្ឌិតគប្បីជ្រាបដោយន័យដូចពោលមកដូច្នេះ ។

## ចេតោបរិយញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍៨

ចេតោបរិយញ្ញាណរមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ ដែលជាបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អប្បមាណារម្មណ៍ មគ្គារម្មណ៍ អតីតារម្មណ៍ អនាគតារម្មណ៍ បច្ចុប្បន្នារម្មណ៍ និងពហិទ្ធារម្មណ៍ បុច្ឆាថា ប្រព្រឹត្តទៅយ៉ាងដូចម្ដេច ? វិសជ្ជនាថា ក៏ចេតោបរិយញ្ញាណនោះ ក្នុងកាលដែលដឹងចិត្តជាកាមាវចរចិត្តរបស់អ្នកដទៃៗ ក៏ជាបរិត្តារម្មណ៍ ក្នុងកាលដែលដឹងចិត្តជារូបាវចរ និងអរូបាវចរ( របស់អ្នកដទៃ ) ក៏ជាមហគ្គតារម្មណ៍ ក្នុងកាលដែលដឹងចិត្តជាមគ្គ និងជាផលរបស់អ្នកដទៃ ក៏ជាអប្បមាណារម្មណ៍ ។

រីឯ ក្នុងអប្បមាណារម្មណ៍នេះ បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នាដូច្នេះ គឺ បុថុជ្ជនរមែងមិនដឹងចិត្តរបស់ព្រះសោតាបន្ន ព្រះសោតាបន្នក៏រមែងមិនដឹងចិត្តព្រះសកទាគាមី... បណ្ឌិតគប្បីនាំពាក្យដូចពោលមកនេះ វៀរទៅរហូតដល់... ព្រះអរហន្តចុះ តែព្រះអរហន្តរមែងដឹងចិត្តរបស់ព្រះអរិយៈទាំងពួង សូម្បីព្រះអរិយៈជាន់ខ្ពស់ដទៃ មានព្រះអនាគាមីជាដើម ក៏រមែងដឹងចិត្តរបស់ព្រះអរិយៈជាន់ទាប

មានព្រះសកទាគាមីជាដើម ។

ចេតោបរិយញ្ញាណនោះ ក្នុងកាលដែលមានមគ្គចិត្តជាអារម្មណ៍ ក៏ជាមគ្គារម្មណ៍ ។

រីឯ កាលណាព្រះយោគីដឹងចិត្តអ្នកដទៃបានក្នុងកាលខាងក្នុង ៧ ថ្ងៃ ដែលកន្លងហើយក្តី ក្នុងកាលខាងក្នុង ៧ ថ្ងៃ ដែលមិនទាន់មកដល់ក្តី កាលនោះ ចេតោបរិយញ្ញាណនោះក៏ជាអតីតារម្មណ៍ និងអនាគតារម្មណ៍ ។

## បច្ចុប្បន្នចិត្ត៣

ចេតោបរិយញ្ញាណជាបច្ចុប្បន្នារម្មណ៍ តើដូចម្តេច ឈ្មោះថា បច្ចុប្បន្នចិត្ត មាន ៣ គឺ**ខណៈបច្ចុប្បន្ន**( ចិត្តជាបច្ចុប្បន្នខណៈ ) ១ , **សន្តតិបច្ចុប្បន្ន** ( ចិត្តជាបច្ចុប្បន្នមួយជួរសន្តតិនៃរូប ) ១ , **អទ្ធាបច្ចុប្បន្ន** ( ចិត្តជាបច្ចុប្បន្នរយៈកាលភពមួយ ) ១ ។

ក្នុងបច្ចុប្បន្នចិត្ត ៣ យ៉ាងនោះ ចិត្តដែលដល់នូវការកើតឡើង តាំងនៅ និងរលត់ទៅ១ខណៈ ឈ្មោះថា **ខណៈបច្ចុប្បន្ន** , ដែលរាប់ទាក់ទងនៅក្នុងរយៈ ១-២ សន្តតិវារៈ ឈ្មោះថា **សន្តតិបច្ចុប្បន្ន** ។

## សន្តតិបច្ចុប្បន្ន

គប្បីជ្រាបអធិប្បាយក្នុងសន្តតិបច្ចុប្បន្ននោះ ដូច្នេះ :

អារម្មណ៍ ( គឺ រូប ) រមែងមិនប្រាកដទាន់ពេលដល់អ្នកអង្គុយនៅក្នុងទីងងឹត ហើយទៅកាន់ទីភ្លឺ រយៈមួយជួរអារម្មណ៍នោះប្រាកដក្នុងរវាងនោះ គប្បីជ្រាបថាជា រយៈ ១-២ សន្តតិវារៈ ។

រូបរមែងមិនប្រាកដដោយរហ័សដល់អ្នកដើរទៅក្នុងទីភ្លឺហើយ ចូលបន្ទប់ក្នុងរយៈមួយជួររូបនោះប្រាកដ ក្នុងរវាងនោះគប្បីជ្រាបថាជា រយៈ ១-២ សន្តតិវារៈ ។

ម្យ៉ាងទៀត ភិក្ខុឈរនៅឆ្ងាយ សូម្បីមើលឃើញកិរិយាកម្រើកដៃ និងកាយវិការ ក្នុងការវាយស្គរជាដើម របស់ពួកអ្នករបាំ ក៏នៅមិនបានឮសំឡេង ទាន់ពេលរយៈមួយជួរបានឮសំឡេងនោះ សូម្បីក្នុងរវាងនោះ ក៏គប្បីជ្រាបថា ជារយៈ ១-២ សន្តតិវារៈ ។

ព្រះមជ្ឈិមភាណកាចារ្យទាំងឡាយពោលទុកយ៉ាងនេះ ចំណែកព្រះសំយុត្តភាណកាចារ្យទាំងឡាយ ពោលសន្តតិ ២ គឺ រូបសន្តតិ អរូបសន្តតិ ហើយពោលអធិប្បាយថា កាលមនុស្សជាន់ចុះទឹកមាត់ច្រាំងទៅ រយៈស្នាមទឹកដែលមនុស្សចុះទៅ មាត់ច្រាំងនៅមិនទាន់ថ្លា នេះឈ្មោះថា រូបសន្តតិ ១ កាលមនុស្សធ្វើដំណើរពីចម្ងាយ រយៈភាពក្តៅក្នុងកាយនៅមិនទាន់រំងាប់ នេះឈ្មោះថា រូបសន្តតិ ១ កាលមនុស្សមកពីក្តៅចូលបន្ទប់ រយៈភាពងឹតនៅមិនទាន់បាត់ នេះឈ្មោះថា រូបសន្តតិ ១ កាលភិក្ខុមនសិការកម្មដ្ឋាននៅខាងក្នុងបន្ទប់ ហើយបើកបង្អួចសម្លឹងចេញទៅ ក្នុងពេលពាក់កណ្តាលថ្ងៃ រយៈភាពស្រវាំងនៃភ្នែកនៅមិនទាន់រំងាប់ នេះឈ្មោះថា រូបសន្តតិ ១ វារៈនៃជវន ២-៣ វារៈ ឈ្មោះថា អរូបសន្តតិ ដូច្នេះហើយទើបពោលសរុបថា សន្តតិទាំងពីរនោះ ឈ្មោះថា **សន្តតិបច្ចុប្បន្ន** ។

## អទ្ធាបច្ចុប្បន្ន

ធម្មជាតិដែលកំណត់ទុករយៈភពមួយ ឈ្មោះថា **អទ្ធាបច្ចុប្បន្ន** ដែលព្រះមហាកច្ចាយត្ថេរសំដៅដល់ពោលទុកក្នុង **ភទ្ទេករត្តសូត្រ** ថា ម្នាលអាវុសោ មនៈ

ឯណាផង ធម៌ទាំងឡាយឯណាផង ធម្មជាតិទាំងពីរនោះឯង ឈ្មោះថា **បច្ចុប្បន្ន** , វិញ្ញាណរមែងជាប់ជំពាក់ដោយអំណាចឆន្ទរាគៈក្នុងបច្ចុប្បន្ននោះ ព្រោះការដែលវិញ្ញាណជាប់ជំពាក់ដោយអំណាចឆន្ទរាគៈ បុគ្គលទើបត្រេកអរខ្លាំងក្នុងបច្ចុប្បន្ននោះ កាលត្រេកអរខ្លាំងក្នុងបច្ចុប្បន្ន ទើបឈ្មោះថា ញាប់ញ័រក្នុងបច្ចុប្បន្នធម៌ទាំងឡាយដូច្នេះ ។

ក៏ក្នុងបច្ចុប្បន្នទាំងពីរនេះ សន្តតិបច្ចុប្បន្នមកក្នុងអដ្ឋកថាទាំងឡាយ អទ្ធា-បច្ចុប្បន្នមកក្នុងព្រះសូត្រ ។

ក្នុងបច្ចុប្បន្នចិត្តទាំង ៣ នោះ អាចារ្យពួកខ្លះពោលថា ខណៈបច្ចុប្បន្នចិត្តជាអារម្មណ៍របស់ចេតោបរិយញ្ញាណបាន មានពាក្យសួរថា ព្រោះហេតុអ្វី ? មានពាក្យឆ្លើយថា ព្រោះចិត្តរបស់អ្នកមានឫទ្ធិ និងរបស់អ្នកដទៃ រមែងកើតឡើងក្នុងខណៈជាមួយគ្នាបាន នេះជាពាក្យឧបមានៃចិត្តទាំងនោះ គឺកាលផ្កាឈើមួយក្ដាប់បុគ្គលបាចទៅក្នុងអាកាសហើយ ផ្កាឈើមួយរមែងដោតទងចូលនឹងជាងរបស់ផ្កាឈើមួយទៀតបានជាប្រាកដ យ៉ាងណា កាលចិត្តរបស់ពួកមនុស្សច្រើន នាំគ្នាគិតជាក្រុមដោយតាំងចិត្តថា យើងនឹងដឹងចិត្តរបស់អ្នកដទៃ ចិត្តរបស់មនុស្សម្នាក់រមែងនឹងផ្គុំចូលគ្នានឹងចិត្តដូងមួយ( របស់អ្នកណា )ក្នុងក្រុមនោះ ក្នុងឧប្បាទក្ខណៈ ឬ ឋិតិខណៈ ឬ ភង្គក្ខណៈក៏បានជាប្រាកដដូច្នេះ ។

តែពាក្យរបស់កេចិអាចារ្យនោះ ត្រូវទំនាស់ក្នុងអដ្ឋកថាទាំងឡាយថា ពាក្យនោះមិនត្រូវ ព្រោះមនុស្សសូម្បីនាំគ្នាគិតដល់ទៅ ១០០ ឆ្នាំ ១.០០០ ឆ្នាំក្ដី ចិត្តដែលជាគ្រឿងនឹកគិត និងចិត្តដែលជាគ្រឿងដឹងទាំងពីរនោះ មិនបានមានខណៈរួមគ្នាឡើយ និងព្រោះទោស គឺ អាវជ្ជនចិត្ត និងជវនចិត្តដល់ភាពមានអារម្មណ៍ផ្សេង

គ្នាក្នុងឋានៈដែលមិនត្រូវការ ដែលជាការប្រាសចាកវិថីនៃមគ្គផល ។

ចំណែកសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ន គប្បីជ្រាបថា ជាអារម្មណ៍នៃចេតោបរិយញ្ញាណបាន ព្រះអដ្ឋកថាចារ្យពោលអធិប្បាយទុកក្នុងអដ្ឋកថាសំយុត្តនិកាយថា ក្នុងបច្ចុប្បន្នពីរយ៉ាងនោះ ចិត្តរបស់អ្នកដទៃក្នុងកាលប្រមាណ ២-៣ ជវនវិថីដែលជាអតីត ឬ អនាគត បន្ទាប់ពីជវនវិថីដែលប្រព្រឹត្តទៅ គឺបច្ចុប្បន្នឯណា ចិត្តរបស់អ្នកដទៃទាំងពួងនោះ ឈ្មោះថា សន្តតិបច្ចុប្បន្ន , ចំណែកអទ្ធាបច្ចុប្បន្នគប្បីចង្អុលបង្ហាញដោយជវនវារៈ ដូច្នេះ , ពាក្យរបស់ព្រះអដ្ឋកថាចារ្យនោះ ពោលល្អហើយ តទៅនេះជាពាក្យចង្អុលបង្ហាញក្នុងអទ្ធាបច្ចុប្បន្ននោះគឺ :

ភិក្ខុអ្នកមានឫទ្ធិប្រាថ្នានឹងដឹងចិត្តរបស់អ្នកដទៃ អាវជ្ជនាការទៅ អាវជ្ជនចិត្តនោះធ្វើខណៈបច្ចុប្បន្នឲ្យជាអារម្មណ៍ហើយ រលត់ទៅព្រមនឹងអារម្មណ៍នោះទុំះឯងបន្ទាប់ពីជវនៈ ៤ ឬ ៥ ខណៈ ប្រព្រឹត្តទៅ ដែលដួងចុងក្រោយ ( ដួងទី ៤ ឬ ទី ៥ ) ជាឥទ្ធិចិត្ត ក្រៅពីនោះជាកាមាវចរចិត្ត ចិត្តដែលរលត់ទៅហើយនោះឯងជាអារម្មណ៍នៃចិត្តទាំងពួងនោះ និងចិត្តទាំងឡាយនោះមិនមានអារម្មណ៍ផ្សេងៗ គ្នាទេ ព្រោះភាពដែលចិត្តទាំងនោះ មានអារម្មណ៍បច្ចុប្បន្ន ដែលកំណត់ទុកដោយអំណាចកាល គឺ ភពជាអារម្មណ៍ , ម្យ៉ាងទៀត ព្រោះក្នុងការមានអារម្មណ៍ដូចគ្នាក៏ឥទ្ធិចិត្តប៉ុណ្ណោះរមែងដឹងចិត្តរបស់អ្នកដទៃបាន ចិត្តក្រៅពីនេះមិនដឹងទេ ប្រៀបដូចចក្ខុវិញ្ញាណក្នុងចក្ខុទ្វារប៉ុណ្ណោះ រមែងឃើញរូបបាន វិញ្ញាណក្រៅពីនេះមិនអាចឃើញទេ ។

ចេតោបរិយញ្ញាណនេះជាបច្ចុប្បន្នារម្មណ៍ ដោយអំណាចនៃសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្នដោយន័យ ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលសន្តតិបច្ចុប្បន្ន ក៏រមែងប្រព្រឹត្តក្នុងអទ្ធាបច្ចុប្បន្នដូចគ្នា ព្រោះហេតុនោះ សន្តតិបច្ចុប្បន្ននោះ ក៏គប្បីជ្រាបថា ជាបច្ចុប្បន្នារម្មណ៍ដោយអំណាចនៃអទ្ធាបច្ចុប្បន្ននោះឯង ។

ឯចេតោបរិយញ្ញាណនោះ ចាត់ជាពហិទ្ធារម្មណ៍ ក៏ព្រោះមានចិត្តរបស់អ្នកដទៃជាអារម្មណ៍ ។

ការប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ នៃចេតោបរិយញ្ញាណ បណ្ឌិតគប្បីជ្រាបដោយប្រការដូចពោលមកនេះ ។

## បុព្វេនិវាសញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍៨

បុព្វេនិវាសញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ ដែលជាបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អប្បមាណារម្មណ៍ មគ្គារម្មណ៍ អតីតារម្មណ៍ អជ្ឈត្តារម្មណ៍ ពហិទ្ធារម្មណ៍ និងនវត្តព្វារម្មណ៍ ( មានរឿងមិនគួរពោលជាអារម្មណ៍ ) ប្រព្រឹត្តទៅយ៉ាងដូចម្តេច ក៏បុព្វេនិវាសញ្ញាណនោះ ក្នុងកាលដែលរឭកដល់ខន្ធដែលជាកាមាវចរ ក៏ជាបរិត្តារម្មណ៍ ក្នុងកាលដែលរឭកដល់ខន្ធដែលជារូបាវចរ និងអរូបាវចរក៏ជាមហគ្គតារម្មណ៍ ក្នុងការដែលរឭកដល់មគ្គដែលខ្លួន ឬអ្នកដទៃចម្រើនហើយ និងដល់ផលដែលខ្លួន និងអ្នកដទៃធ្វើឲ្យជាក់ច្បាស់ហើយ ក្នុងអតីតកាល ក៏ជាអប្បមាណារម្មណ៍ ក្នុងកាលដែលរឭកដល់មគ្គដែលខ្លួន ឬអ្នកដទៃចម្រើនហើយដូចគ្នា ក៏ជាមគ្គារម្មណ៍ ។

ប៉ុន្តែដោយពិត បុព្វេនិវាសញ្ញាណនោះជាអតីតារម្មណ៍ តទៅនេះជានយ័នៃអដ្ឋកថា ក្នុងរឿងអតីតារម្មណញ្ញាណនោះថា បណ្ឌិតគប្បីជ្រាបការផ្សេងគ្នា ដូច្នេះ

គឺ ក្នុងញាណទាំងឡាយនោះ សូម្បីចេតោបរិយញ្ញាណ និងយថាកម្មូបគញ្ញាណ ក៏ជាអតីតារម្មណ៍ ពិតដូច្នេះ តែថា ញាណទាំងពីរនោះ ចេតោបរិយញ្ញាណមានចិត្ត ជាអតីតខាងក្នុងរយៈ ៧ ថ្ងៃប៉ុណ្ណោះជាអារម្មណ៍ ព្រោះចេតោបរិយញ្ញាណនោះមិន ដឹងខន្ធ ឬវត្ថុដែលជាប់ដោយខន្ធដទៃទេ តែលោកពោលថា ជាមគ្គារម្មណ៍ដោយ បរិយាយ ក៏ព្រោះមានចិត្តដែលសម្បយុត្តដោយមគ្គជាអារម្មណ៍ យថាកម្មូបគញ្ញាណ សោត ក៏មានតែចេតនាដែលជាអតីតប៉ុណ្ណោះអារម្មណ៍ តែខន្ធទាំងឡាយ និងវត្ថុ ណាៗ ដែលជាប់ដោយខន្ធដែលជាអតីត និងឈ្មោះថា មិនបានជាអារម្មណ៍នៃ បុព្វេនិវាសញ្ញាណមិនមាន ព្រោះថា បុព្វេនិវាសញ្ញាណនោះ ជាញាណមានគតិស្មើ ដោយសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយ គឺ ខន្ធ និងវត្ថុដែលជាប់ដោយខន្ធ ដែល ជាអតីត ។

ម្យ៉ាងទៀត ព្រោះហេតុដែលក្នុងគម្ពីរបដ្ឋានពោលទុកថា ខន្ធទាំងឡាយដែល ជាកុសល ជាបច្ច័យដោយអារម្មណប្បច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មូបគញ្ញាណ អនាគតំសញ្ញាណ ដូច្នេះ ព្រោះ ហេតុនោះ សូម្បីខន្ធ ៤ ក៏ជាអារម្មណ៍នៃចេតោបរិយញ្ញាណ និងយថាកម្មូបគ្គ-ញ្ញាណបាន ម្យ៉ាងទៀត ក្នុងញាណពីរនោះ ខន្ធទាំងដែលជាកុសល ទាំងដែលជា អកុសលជាអារម្មណ៍នៃយថាកម្មូបគញ្ញាណ ដូច្នោះ ។

ឯបុព្វេនិវាសញ្ញាណនោះ ក្នុងកាលដែលរឭកដល់ខន្ធរបស់ខ្លួន ក៏ជាអជ្ឈត្តា រម្មណ៍ ក្នុងកាលដែលរឭកដល់ខន្ធរបស់អ្នកដទៃ ក៏ជាពហិទ្ធារម្មណ៍ ក្នុងកាលដែល រឭកដល់វត្ថុដែលជាប់ដោយខន្ធ មានឈ្មោះ និងគោត្រជាដើមនោះដោយន័យដូចគ្នា ក្នុងអតីតកាល ព្រះមានព្រះភាគវិបស្សីបានមានហើយ ព្រះមាតារបស់ព្រះអង្គទ្រង់

ព្រះនាមថា **ពន្ធុមតី** ព្រះបិតាទ្រង់ព្រះនាមថា **ពន្ធុមា** ដូច្នេះជានវត្តព្វារម្មណ៍ ។

ក្នុងនវត្តព្វារម្មណ៍នេះ នេះជាការពេញចិត្តរបស់ខ្ញុំ គឺ ពាក្យថា ឈ្មោះ និង គោត្រក្នុងទីនេះ សំដៅដល់វត្ថុដែលជាប់ដោយខន្ធ សម្រេចដោយសម្មតិ គប្បី ឃើញថា ជាការអាស្រ័យព្យញ្ជនៈ មិនមែនព្យញ្ជនៈ ព្រោះព្យញ្ជនៈចាត់ជាបរិត្តធម៌ ព្រោះលោកសង្គ្រោះចូលក្នុងសទ្ទាយតនៈ គឺសំឡេង ដូចបាលីថា **និរុត្តិបដិសម្ភិទា** ជាបរិត្តារម្មណ៍ ។

ការប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ នៃបុព្វេនិវាសញ្ញាណ បណ្ឌិតគប្បីជ្រាប ដោយប្រការដូចពោលមកនេះ ។

## ទិព្វចក្ខុញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍៤

ទិព្វចក្ខុញ្ញាណរមែងប្រព្រឹត្តទៅក្នុងអារម្មណ៍៤ ដែលជាបរិត្តារម្មណ៍ បច្ចុប្បន្នា រម្មណ៍ អជ្ឈត្តារម្មណ៍ និងពហិទ្ធារម្មណ៍ ប្រព្រឹត្តទៅដូចម្តេច ក៏ទិព្វចក្ខុញ្ញាណនោះ ព្រោះហេតុដែលធ្វើរូបឲ្យជាអារម្មណ៍ និងរូបជាបរិត្តធម៌ ព្រោះហេតុនោះ ទើបជា បរិត្តារម្មណ៍ ម្យ៉ាងទៀត ព្រោះប្រព្រឹត្តទៅក្នុងរូបដែលមានប្រាកដចំពោះមុខប៉ុណ្ណោះ ទើបជាបច្ចុប្បន្នារម្មណ៍ ក្នុងកាលដែលឃើញរូបដែលកំបាំង មានរូបដែលនៅក្នុង ពោះរបស់ខ្លួនជាដើម ក៏ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដែលឃើញរូបរបស់អ្នកដទៃ ក៏ជាពហិទ្ធារម្មណ៍ដូច្នេះ ។

ការប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ នៃទិព្វចក្ខុញ្ញាណ បណ្ឌិតគប្បីជ្រាបដោយ ប្រការដូចពោលមកដូច្នេះ ។

## អនាគតំសញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍៨

អនាគតំសញ្ញាណ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ ដែលជាបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អប្បមាណារម្មណ៍ មគ្គារម្មណ៍ អនាគតារម្មណ៍ អជ្ឈត្តារម្មណ៍ ពហិទ្ធារម្មណ៍ និងនវត្តព្វារម្មណ៍ ប្រព្រឹត្តទៅយ៉ាងដូចម្តេច ? ក៏អនាគតំសញ្ញាណនោះ ក្នុងកាលដែលដឹងថា បុគ្គលនេះក្នុងអនាគតនឹងកើតក្នុងកាមាវចរភព ក៏ជាបរិត្តារម្មណ៍ ក្នុងកាលដឹងថា បុគ្គលនេះក្នុងអនាគតនឹងកើតក្នុងរូបាវចរភព ឬអរូបាវចរភព ក៏ជាមហគ្គតារម្មណ៍ ក្នុងកាលដែលដឹងថា បុគ្គលនេះក្នុងអនាគតនឹងធ្វើមគ្គឲ្យមានឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវផល ក៏ជាអប្បមាណារម្មណ៍ ក្នុងកាលដែលដឹងថា បុគ្គលនេះក្នុងអនាគតនឹងធ្វើមគ្គឲ្យកើតឡើងតែប៉ុណ្ណោះក៏ជាមគ្គារម្មណ៍ ។

ប៉ុន្តែដោយពិត អនាគតំសញ្ញាណនេះ ជាអនាគតារម្មណ៍ដែរ ក្នុងអនាគតារម្មណ៍ ញាណទាំងឡាយនោះ សូម្បីចេតោបរិយញ្ញាណក៏ជាអនាគតារម្មណ៍បានដោយពិត តែថា ចេតោបរិយញ្ញាណនោះ មានចិត្តដែលជាអនាគតខាងក្នុងរយៈ ៨ ថ្ងៃប៉ុណ្ណោះជាអារម្មណ៍ ព្រោះចេតោបរិយញ្ញាណនោះ មិនដឹងខន្ធ ឬវត្ថុដែលជាប់ដោយខន្ធដទៃទេ តែវត្ថុណាក្នុងអនាគត ឈ្មោះថា មិនបានជាអារម្មណ៍នៃអនាគតំសញ្ញាណមិនមាន តាមន័យដូចដែលបានពោលមកហើយ ក្នុងបុព្វេនិវាសញ្ញាណ។

ក្នុងកាលដឹងថា យើងក្នុងអនាគតនឹងកើតក្នុងទីនោះ ក៏ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដឹងថា អ្នកនោះក្នុងអនាគតនឹងកើតក្នុងទីនោះ ក៏ជាពហិទ្ធារម្មណ៍ ក្នុងកាលដឹងឈ្មោះ និងគោត្រដោយន័យដូចជាក្នុងអនាគត ព្រះមានព្រះភាគមេត្តេយ្យនឹងកើតឡើង ព្រាហ្មណ៍ឈ្មោះសុព្រហ្មានឹងជាព្រះបិតា ព្រាហ្មណីឈ្មោះព្រហ្មវតី នឹងជាមាតារបស់ព្រះអង្គដូច្នេះ ក៏ជានវត្តព្វារម្មណ៍ ដោយន័យដូចដែលបានពោលក្នុង

បុព្វេនិវាសញ្ញាណនោះឯង ។

ការប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ នៃអនាគតំសញ្ញាណ បណ្ឌិតគប្បីជ្រាបដោយប្រការដូចពោលមកនេះចុះ ។

## យថាកម្មុបគញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍៥

យថាកម្មុបគញ្ញាណ តែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ ដែលជាបរិត្តារម្មណ៍ មហគ្គតារម្មណ៍ អតីតារម្មណ៍ អជ្ឈត្តារម្មណ៍ និងពហិទ្ធារម្មណ៍ ប្រព្រឹត្តទៅយ៉ាងដូចម្តេច ? យថាកម្មុបគញ្ញាណនោះ ក្នុងកាលដឹងកម្មដែលជាកាមាវចរ ក៏ជាបរិត្តារម្មណ៍ ក្នុងកាលដឹងកម្មដែលជារូបាវចរ និងអរូបាវចរក៏ជាមហគ្គតារម្មណ៍ ជាអតីតារម្មណ៍ ព្រោះដឹងតែកម្មដែលជាអតីតប៉ុណ្ណោះ ក្នុងកាលដែលដឹងកម្មរបស់ខ្លួនឯង ជាអជ្ឈត្តារម្មណ៍ ក្នុងកាលដែលដឹងកម្មរបស់អ្នកដទៃ ក៏ជាពហិទ្ធារម្មណ៍ដូច្នេះ ។

ការប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ នៃយថាកម្មុបគញ្ញាណ បណ្ឌិតគប្បីជ្រាបដោយប្រការដូចពោលមកនេះចុះ ។

រីឯ ក្នុងពេលដែលពោលដល់អជ្ឈត្តារម្មណ៍ និងពហិទ្ធារម្មណ៍នេះ ពាក្យណាពោលទុកក្នុងបោរាណអដ្ឋកថាចារ្យ យថាកម្មុបគញ្ញាណប្រាកដទាំងអជ្ឈត្តារម្មណ៍ និងពហិទ្ធារម្មណ៍ ពាក្យនោះលោកពោលអធិប្បាយថា យថាកម្មុបគញ្ញាណ នោះក្នុងពេលដែលដឹងកម្មខាងក្នុង គឺ របស់ខ្លួនតាមកាល , កម្មខាងក្រៅ គឺ របស់អ្នកដទៃតាមកាល សេចក្តីថា គ្រាខ្លះ ដឹងកម្មខាងក្នុង គ្រាខ្លះដឹងកម្មខាងក្រៅ តាមកាលដែលតាំងចិត្តចង់ដឹង និងរាប់ជាអជ្ឈត្តពហិទ្ធារម្មណ៍ខ្លះក៏បានប៉ុណ្ណោះឯង ។

# មហាដីកា
## ពណ៌នាបកិណ្ណកកថា

សព្ទថា **ឥតិ** បានដល់ **ឯវំ** មានសេចក្តីថា តាមប្រការដូចពោលមកហើយ ។ ដោយឥតិ-សព្ទនោះ លោកអាចារ្យដកយក( គោលសេចក្តីអះអាងដល់ ) គតិព្រះបាលី ដែលទ្រង់សម្តែងទុកដោយពាក្យថា **សោ ឯវំ សមាហិតេ ចិត្តេ** ( កិក្ខុកាលចិត្តតាំងមាំដោយប្រពៃយ៉ាងនេះហើយ ) ដូច្នេះជាដើម និងន័យដែលបើកបង្ហាញអត្ថនៃព្រះបាលីនោះ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ឧបាទានក្ខន្ធទាំងឡាយក៏ជាធម៌ដែលប្រជុំចុះក្នុងខន្ធទាំងឡាយ ដូចអរិយសច្ចទាំងឡាយ ជាធម៌ដែលប្រជុំចុះក្នុងសច្ចៈទាំងឡាយដូច្នោះ ។ ក៏ព្រះមានព្រះភាគបានត្រាស់ដឹង គឺទ្រង់ដឹងទូទៅទ្រង់ចាក់ធ្លុះ ឬថា ទ្រង់ប្រកាសខន្ធ និងឧបាទានក្ខន្ធរួមពីរយ៉ាងនោះ ដោយសភាវៈដោយការកើតឡើង ដោយការរលត់ទៅ ដោយគុណ ដោយទោស និងដោយធម៌ដែលជាទីរលាស់ចេញ បានតាមសេចក្តីពិត ដោយព្រះសយម្ភូញាណ ព្រោះហេតុនោះ ព្រះសាស្តាព្រះអង្គនោះ ដែលទ្រង់ជាបុគ្គលដែលអ្នកណាៗ គួរស្ងើចសរសើរព្រោះការដែលទ្រង់ត្រាស់ដឹងខន្ធ ៥ បានដោយប្រពៃ ដូច្នេះហើយ ទើបពោលថា បញ្ចក្ខន្ធវិទូ( អ្នកត្រាស់ដឹងខន្ធ ៥ ) ។ ក្តាប់សេចក្តីថា **ញត្វា វិនេយ្យ** ( បណ្ឌិតដឹងហើយក៏គួរជ្រាប ) បទថា **តាសុ** បានដល់ ក្នុងអភិញ្ញា ៥ ។ លោកអាចារ្យពោលពាក្យថា ៥ ដូច្នេះទុក ព្រោះញាណដែលប្រជុំចុះទាំងឡាយ លោកបានកាន់យកហើយដោយសព្ទថា អភិញ្ញា ៥ នោះ ទុំះឯង ។ ព្រោះហេតុនោះ ទើបលោកពោលថា ក៏ក្នុងអភិញ្ញាទាំងនេះដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បរិកណ្ឌញាណានិ**( ញាណដែលជាបរិកណ្ឌ ) បានដល់ ញាណដែលប្រជុំចុះ ដូចជាស្ថានទីព័ទ្ធជុំវិញភ្នំសិនេរុ ដែលកាលភ្នំសិនេរុនោះ សម្រេច(កើតឡើងហើយ) ទើបសម្រេចបាន ទើបហៅថា ជាស្ថានទីហ៊ុមព័ទ្ធ គឺជាបរិកណ្ឌយ៉ាងណា កាលទិព្វចក្ខុសម្រេចហើយ អនាគតំសញ្ញាណ និងយថា-កម្មូបគញ្ញាណទាំងនេះទើបសម្រេចបាន ទើបពោលថា ជាញាណបរិកណ្ឌនៃទិព្វចក្ខុនោះដូច្នោះ ។ បទថា **ឥធ** ក្នុងបទថា **ឥធាគតានិ**( មកក្នុងទីនេះ ) លោកពោលសំដៅយកបទនៃព្រះសូត្រតាមដែលបានសម្ដែងទុក ។ តែថា ក្នុងព្រះសូត្រដទៃពីព្រះសូត្រនោះ មានសាមញ្ញផលសូត្រជាដើម សូម្បីមនោមយញ្ញាណក៏មកហើយ ដោយភាពជាអភិញ្ញាញាណម្យ៉ាងដោយឡែក ។

សួរថា បទថា **តេសុ** ជាពាក្យដកយកតិកៈទាំងឡាយមក ឬជាពាក្យដកយកអារម្មណ៍ទាំងឡាយមកហ្ន៎ ? ឆ្លើយថា ប្រយោជន៍អ្វីក្នុងរឿងនោះហ្ន៎ បើថាជាពាក្យដកយកតិកៈទាំងឡាយមក ពាក្យនោះក៏មិនត្រឹមត្រូវ , ព្រោះថា អភិញ្ញាញាណទាំងឡាយ មិនបានប្រព្រឹត្តទៅក្នុងតិកៈទាំងឡាយទេ ។ កាលបើដូច្នោះ ក៏ជាពាក្យនិយាយដកយកអារម្មណ៍ទាំងឡាយមក សូម្បីពាក្យនោះក៏មិនត្រឹមត្រូវ , ព្រោះការដែលអាងដល់វត្ថុមួយហើយ ត្រឡប់ទៅដកយកវត្ថុមួយទៀតមក រមែងមិនជារឿងដែលត្រឹមត្រូវ។ សូមឲ្យជាពាក្យពោលដែលយកតិកៈទាំងឡាយមកសិន តាមដែលលោកអាចារ្យត្រូវការចុះ តែខ្ញុំពោលថា ព្រោះថា អភិញ្ញាញាណទាំងឡាយមិនបានប្រព្រឹត្តទៅក្នុងតិកៈទាំងឡាយទេ ដូច្នេះមិនមែនឬ កាលបើដូច្នេះ នឹងថាលោកអាចារ្យត្រូវការឲ្យជាពាក្យដកយកតិកៈទាំងឡាយបានយ៉ាងដូចម្ដេច ? សូមឆ្លើយថា ប្រការដែលលោកអាចារ្យត្រូវការនេះមិនខុសទេ ព្រោះអារម្មណ៍ទាំងឡាយ

នោះឯង លោកក៏កាន់យកបាន ដោយការនិយាយដល់តិកៈ ។ បើថា ជាពាក្យនិយាយ ដកយកអារម្មណ៍ទាំងឡាយមក ខ្ញុំក៏បានពោលហើយថា ព្រោះការដែលអាងដល់វត្ថុមួយ ហើយត្រឡប់ទៅដកយកវត្ថុមួយមក រមែងជារឿងដែលមិនត្រឹមត្រូវ ដូច្នេះមិនមែនឬ សូម្បីខនេះក៏រកទោសមិនបាន ដោយហេតុតាមដែលពោលមកហើយ ដូចគ្នាដូច្នោះឯង ។

សូម្បីមិនមានការផ្សេងគ្នានៃវត្ថុ ឥទ្ធិវិធញ្ញាណរមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៧ ដែលផ្សេងគ្នា ដោយអំណាចការផ្សេងគ្នានៃភូមិ កាល និងសន្តាន ។ ការផ្សេងគ្នានេះក៏ជាការដែលលោកកាន់យកហើយ ដោយអំណាចនៃតិកៈ ។ ព្រោះឥទ្ធិវិធញ្ញាណ មិនមានភាពជាញាណដែលមានមគ្គជាអារម្មណ៍ទេ ទើបក្នុងឥទ្ធិវិធញ្ញាណនេះ មិនបានជាមគ្គារម្មណតិកៈ ។ បទថា **តំ** បានដល់ ឥទ្ធិវិធញ្ញាណ ។ ពាក្យណាក្នុងពាក្យថា ធ្វើកាយឲ្យអាស្រ័យចិត្តជាដើម គួរពោលអធិប្បាយពាក្យនោះ ខ្ញុំបានពោលអធិប្បាយ ក្នុងខាងដើមហើយ ។ ពាក្យថា **ដែលបានឧបយោគ** គឺដែលបានពាក្យនិយាយជាទុតិយាវិភត្តិ ។ លោកពោលទុកដោយទាក់ទងនឹងទុតិយាវិភត្តិថា **កាយំ បរិណា មេតិ** ធ្វើកាយឲ្យបង្អោនទៅដូច្នេះ ។ ព្រោះហេតុនោះ ទើបពោលថា ដោយមានរូបកាយជាអារម្មណ៍ មានសេចក្ដីថា ដោយមានពណ៌របស់រូបកាយជាអារម្មណ៍ ។

ពាក្យថា **ចិត្តនោះនុ៎ះឯង** មានសេចក្ដីថា ឈានចិត្តដែលជាបាទ ដែលបានពោលទុកក្នុងការធ្វើចិត្តឲ្យបង្អោនទៅតាមអំណាចកាយឯណានោះឯង ក៏បានដល់ឈានចិត្តដែលជាបាទនោះនុ៎ះឯង ។ ព្រះមហាកស្សបត្ថេរប្រើឫទ្ធិនាំយកព្រះធាតុក្នុងព្រះចេតិយ ៧ កន្លែងដែលនៅសល់ លើកលែងតែចេតិយនៅរាមគ្រាម ហើយ

សានទីបញ្ចុះព្រះមហាធាតុទុកក្នុងភូមិយរមណ្ឌប ជិតក្រុងរាជគ្រឹះ ។ ដោយពាក្យថា **គ្រឿងក្រអូបទាំងនេះជាដើម** សូម្បីថាលោកកាន់យកវត្ថុទាំងឡាយ មានគ្រឿងក្រអូបទាំងឡាយដែលជាបច្ចុប្បន្ន រូបនៃវត្ថុទាំងនោះ ដែលប្រកបដោយភាពវិសេស មានការមិនរុះរោយអស់កាលទៅជាដើម ចំពោះទីជាអនាគតប៉ុណ្ណោះ រមែងជាអារម្មណ៍នៃអធិដ្ឋានចិត្ត ព្រោះជាការអធិដ្ឋានអារម្មណ៍ដែលជាអនាគត ។ វិហារមួយកន្លែងក្នុងព្រៃវិជ្ឈាដវី ឈ្មោះថា **សេនាសនវត្តនិយ** ។ បទថា **ទធិរសំ** បានដល់ ទឹកដោះជូរ កាលអធិដ្ឋានទឹកដោះជូរនោះ ពណ៌របស់ទឹកដោះជូរដែលជាអនាគតក៏ប្រាកដជាអារម្មណ៍ ។ ឈ្មោះថា រមែងជាញាណដែលមានអារម្មណ៍ជាបច្ចុប្បន្ន ក៏ព្រោះការធ្វើរូបកាយដែលជាបច្ចុប្បន្នឲ្យជាអារម្មណ៍ ។

បទថា **សក្កាយ ចិត្តានំ** បានដល់ កាយ និងចិត្តរបស់ខ្លួន ។

ឈ្មោះថា **និងសំឡេងជាបរិត្តធម៌** ព្រោះភាពដែលរូបទាំងអស់ជាកាមាវចរធម៌ ។ ពាក្យថា **សំឡេងដែលកំពុងមានប្រាកដនោះឯង** គឺដែលកំពុងឲ្យប្រព្រឹត្តទៅនោះឯង ។

ពាក្យថា **ចិត្តរបស់ព្រះសោតាបន្ន** គឺ ចិត្តដែលជាចំណែកចំពោះរបស់ព្រះសោតាបន្ននោះ ។ សូម្បីក្នុងពាក្យថា របស់ព្រះសកទាគាមីជាដើមក៏មានន័យនេះឯង ។ ពាក្យថា **គប្បីនាំន័យទៅរហូតដល់ព្រះអរហន្ត** គឺ គប្បីនាំន័យទៅយ៉ាងនេះថា ព្រះសកទាគាមី រមែងមិនដឹងចិត្តព្រះអនាគាមី ព្រះអនាគាមីរមែងមិនដឹងចិត្តរបស់ព្រះអរហន្តដូច្នេះ ។ ពាក្យថា **របស់បុគ្គលគ្រប់ជំពូក** គឺ ព្រះអរហន្ត រមែងដឹងចិត្តរបស់ព្រះអរិយបុគ្គលទាំងឡាយគ្រប់ជំពូក នឹងពោលថ្វីដល់អ្នកដែលមិនមែនព្រះអរិយបុគ្គលហ្ន៎ ។ ភ្ជាប់សេចក្តីថា បុគ្គលថ្នាក់ខ្ពស់ជាងសូម្បីដទៃៗ ( ក្រៅ

ពីព្រះអរហន្ត ) មានព្រះអនាគាមីជាដើម រមែងដឹងចិត្តរបស់បុគ្គលថ្នាក់ទាបជាង មានព្រះសកទាគាមីជាដើម ។

អាចារ្យខ្លះមានបំណងថា ចេតោបរិយញ្ញាណ មានការដឹងចិត្តរបស់អ្នកដទៃ ដែលជាអតីត និងអនាគតបាន តែថា មិនមានការដឹងចិត្តដែលជាបច្ចុប្បន្ន ទើបសួរថា រមែងជាញាណដែលមានអារម្មណ៍ជាបច្ចុប្បន្នយ៉ាងដូចម្តេច ? ដូច្នេះ លោកអាចារ្យដទៃ ( ព្រះពុទ្ធឃោសាចារ្យ )ប្រាថ្នាសម្តែងអារម្មណ៍ដែលជាបច្ចុប្បន្ន កាលនឹងចែកសម្តែងបច្ចុប្បន្នមុន ទើបពោលថា ឈ្មោះថា បច្ចុប្បន្នមាន ៣ យ៉ាង ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឧប្បាទឋិតិភង្គប្បត្តំ** បានដល់ ធម្មជាតិដែលដល់ឧប្បាទៈ ឋិតិ និងភង្គៈ មានសេចក្តីថា រាប់ទាក់ទងក្នុងខណៈទាំង ៣ ។ ពាក្យថា **ក្នុងរយៈពេលវាងរហូតទាល់តែអារម្មណ៍នោះប្រាកដ** នេះគប្បីជ្រាបថា ១-២ សន្តតិវារៈ មានសេចក្តីថា សន្តតិវារៈនៃរូបដែលប្រព្រឹត្តទៅក្នុងរវាងពេលរហូតទាល់តែអារម្មណ៍នោះនឹងប្រាកដនេះ គប្បីជ្រាបថា ឈ្មោះថា ១-២ សន្តតិវារៈ ។ រយៈពេលដែលរូបត្រូវប្រាកដដល់បុគ្គលអ្នកនៅទីភ្លឺចូលទៅបន្ទប់ ដូចប្រាកដដល់អ្នកដែលអង្គុយនៅក្នុងបន្ទប់នោះមកតាំងអំពីដើមនោះឯង ។ ក្នុងរយៈពេលនោះ កន្លះពេលជាវារៈដែលរូបមិនប្រាកដច្បាស់ កន្លះពេលជារូបដែលប្រាកដច្បាស់ ព្រះមជ្ឈិមភាណកាចារ្យកាន់យកវារៈទាំង ២ នោះ លោកពោលពីរសន្តតិវារៈដូច្នេះ ។ ប្រការដែលពោលនេះនោះ មិនជាសាធារណៈដល់រូបទាំងពួង រូបប្រភេទខ្លះមានការប្រាកដបានយ៉ាងឆាប់រហ័ស ព្រោះហេតុនោះ ទើបធ្វើស័ព្ទថា **ឯក** ( ១ ) ថា **ឯកទ្វេសន្តតិវារា**( ១-២ សន្តតិវារៈ ) , មយ៉ាងទៀត វារៈដែលមានឧតុជាដើម ដែលមានសភាវៈដ៏ល្អិតសុខុមជាសមុដ្ឋាន គប្បីជ្រាបថា ឈ្មោះថា ១-

២ សន្តតិវារៈ ។

ឈ្មោះថា **ចុះទឹកត្រង់មាត់ច្រាំង** បានដល់ ស្នាមញើកនៃទឹកដែលនៅជិតច្រាំង ដែលដល់នូវការល្អក់ខ្វល់ ។ ឈ្មោះថា រយៈពេលដែលនៅមិនទាន់ថ្លា គឺរយៈពេលដែលនៅមិនទាន់ថ្លា ព្រោះប្រាសចាកភាពល្អក់ខ្វល់ ។ ចំណែកអាចារ្យពួកខ្លះពោលអត្ថាធិប្បាយក្នុងពាក្យនេះយ៉ាងនេះថា បានដល់ រយៈពេលដែលស្នាមទឹកក្រោមជើង ដែលប្រើជើងសើមជាន់ចុះលើច្រាំងដែលមិនសើម នៅមិនទាន់ថ្លា គឺ នៅមិនបាត់ស្នាម នៅមិនទាន់អស់ទៅ ដូច្នេះ ។ ក៏អាចារ្យទាំងនោះពោលដល់ការផ្សេងគ្នានៃកាលទុក តាមការផ្សេងគ្នានៃកិរិយាដែលមិនស្មើគ្នានិងគ្នា ។ គប្បីឃើញថា នៅមានចំណែកខ្វះខាតទៅក្រៃលែង ។ អរូបសន្តតិគប្បីជ្រាបថា ឈ្មោះថា ជាជវនវារៈ ២-៣ វារៈ ក៏ដោយទាក់ទងនឹងជវនដែលជាកាមាវចរៈប៉ុណ្ណោះ មិនមែនទាក់ទងនឹងជវនដទៃទេ ព្រោះថា ជវនវារៈក្រៅពីនេះ ទាំងនោះរកប្រមាណកាលមិនបាន ។ គប្បីឃើញថា សូម្បីចិត្តុប្បាទទាំងឡាយ មានកវត្តជាដើម ដែលប្រព្រឹត្តទៅក្នុងលំដាប់ ត្រូវទាក់ទងក្នុងជវនពួកនោះៗ ឯង ។ ពាក្យថា សន្តតិទាំងពីរនោះ គឺ រូបសន្តតិ និងអរូបសន្តតិទាំងពីរ ។

ពាក្យថា **ធម្មជាតិដែលកំណត់ទុកដោយភពមួយ** បានដល់ ធម្មជាតិដែលកំណត់ទុកដោយបដិសន្ធិ និងចុតិ ។ សេចក្ដីថា ធម្មជាតិដែលជាប់ទាក់ទងក្នុងភពមួយ ដែលគួរនឹងពោលថា ក្នុងបច្ចុប្បន្ននេះ ឈ្មោះថា **អទ្ធាបច្ចុប្បន្ន** ។ ពាក្យថា **ចិត្ត** លោកពោលដល់វិញ្ញាណ ព្រមទាំងធម៌ដែលសម្បយុត្ត ។ ពាក្យថា **ធម៌ទាំងឡាយ** បានដល់ ធម៌ដែលជាអារម្មណ៍ទាំងឡាយ ។ ម្យ៉ាងទៀត បទថា **មនោ** ( ចិត្ត ) បានដល់ មនាយតនៈ ។ បទថា **ធម្មា** ( ធម៌ទាំងឡាយ ) បាន

ដល់ នាមក្ខន្ធទាំងឡាយ មានវេទនាជាដើម ។ ពាក្យថា **ធម្មជាតិទាំងពីរនេះជាបច្ចុប្បន្ន** មានសេចក្តីថា ធម្មជាតិទាំងពីរដែលមាននេះជាអទ្ធាបច្ចុប្បន្ន ។ ពាក្យថា **វិញ្ញាណ** បានដល់ និកន្តិវិញ្ញាណ( វិញ្ញាណដែលមានសេចក្តីប្រាថ្នា ) ។ ពិតមែន និកន្តិវិញ្ញាណនោះ រមែងជាធម្មជាតិដែលពាក់ព័ន្ធដោយអំណាចនៃឆន្ទរាគៈក្នុងបច្ចុប្បន្ននោះ ។ ពាក្យថា **ភ្លើតភ្លើនក្រៃលែង** បានដល់ ភ្លើតភ្លើនដោយធម៌ដែលធ្វើឲ្យភ្លើតភ្លើន គឺ តណ្ហា និងទិដ្ឋិ ។ ក៏បុគ្គលយ៉ាងនោះឈ្មោះថា រមែងឃ្លាតទៅ គឺ ត្រូវតណ្ហា និងទិដ្ឋិអូសទាញមកក្នុងបច្ចុប្បន្នធម៌ទាំងឡាយពួកនោះ ព្រោះមិនមានការកំណត់ដឹងវត្ថុ ។ ក៏ក្នុងសេចក្តីនេះ អាយតនៈ ១២ មកហើយថា ជាបច្ចុប្បន្នតែម្យ៉ាង ។ លោកអាចារ្យកាលនឹងសម្តែងថា ឆន្ទរាគៈដែលប្រព្រឹត្តទៅក្នុងអាយតនៈពួកនោះ បណ្ឌិតរមែងដឹងបានថា មានអទ្ធាបច្ចុប្បន្នជាអារម្មណ៍ មិនមែនមានខណៈបច្ចុប្បន្នជាអារម្មណ៍ទេ ដូច្នេះ ទើបពោលថា បានដល់ បច្ចុប្បន្ន ដែលព្រះមហាកច្ចាយនត្ថេរពោលទុកក្នុងភទ្ទេករត្តិសូត្រថា **យោ ចាវុសោ ។ បេ ។ សំហិរតិ** ដូច្នេះ ។ សូម្បីក្នុងពាក្យថា **បច្ចុប្បន្នញ្ច យោ ធម្មំ តត្ថ តត្ថ វិបស្សតិ** ( ប្រែថា **បុគ្គលណា ឃើញនូវធម៌ដែលជាបច្ចុប្បន្នក្នុងអារម្មណ៍នោះ** ) ដូច្នេះនេះ បណ្ឌិតគប្បីកាន់យក គប្បីយល់ថា **វិបស្សនាចិត្តជាខណៈបច្ចុប្បន្ន ធម៌ទាំងឡាយដែលគប្បីឃើញច្បាស់ ជាអទ្ធាបច្ចុប្បន្ន** ។ វិបស្សនានោះមិនអាចកើតបានដោយប្រការដទៃទេ, លោកអាចារ្យមិនពោលថា ខណៈបច្ចុប្បន្នមានក្នុងព្រះបាលី ព្រោះការធ្វើឲ្យជាអារម្មណ៍ ដោយអំណាចនៃខណៈបច្ចុប្បន្ននោះ មិនបានមកក្នុងអដ្ឋកថា។

ពាក្យថា **អាចារ្យពួកខ្លះ** បានដល់ ពួកអាចារ្យនៅក្នុងអភយគិរីវិហារ ។ ពាក្យថា **ចិត្តរមែងកើតឡើងក្នុងខណៈជាមួយគ្នា** ជាពាក្យសម្តែងដ៏ត្រឹមត្រូវថា

ព្រោះសូម្បីចិត្តរបស់បុគ្គលដទៃ ក៏មានការកើតឡើងអស់កាលព្រមគ្នានឹងការកើតឡើងនៃឥទ្ធិចិត្តនោះឯង ។ សេចក្ដីថា **យថា អាកាសេ** ជាដើម ជាឧទាហរណ៍ដល់រឿងដែលប្រៀបប្រដូចគ្នាបាន ។ ពាក្យរបស់អាចារ្យទាំងនោះមិនត្រឹមត្រូវ ។ សួរថា ព្រោះហេតុអ្វី ? ពាក្យឆ្លើយដ៏ត្រឹមត្រូវគឺ ព្រោះទោស ( ប្រការដែលខូច ប្រការដែលមិនត្រឹមត្រូវ ) គឺ ការធ្វើអាវជ្ជនៈ និងជវនៈឲ្យដល់ភាពជាចិត្តដែលមានអារម្មណ៍ផ្សេងគ្នាបាន ក្នុងឋានៈដែលមិនត្រូវការក្នុងវិថីដទៃពីមគ្គ និងផលវិថី ។

លោកអាចារ្យធ្វើទុកក្នុងចិត្តថា ប្រសិនបើថាដូច្នេះ ចេតោបរិយញ្ញាណនឹងជាញាណដែលមានអារម្មណ៍ជាបច្ចុប្បន្នបានយ៉ាងដូចម្ដេច ដូច្នេះហើយ ទើបពោលថា ក៏ចិត្តដែលជាសន្តតិបច្ចុប្បន្នដូច្នេះជាដើម ។ អធិប្បាយថា អទ្ធាបច្ចុប្បន្ន បណ្ឌិតគប្បីសម្ដែងបានដោយជវនវារៈ មិនមែនគប្បីសម្ដែងបានដោយអទ្ធា ( កាលយូរ ) ដែលជាបច្ចុប្បន្នទាំងអស់ទេ ។

ពាក្យថា **តទៅនេះជាពាក្យសម្ដែងក្នុងការដឹងចិត្តដែលជាអទ្ធាបច្ចុប្បន្នជាដើម** គឺជាពាក្យសម្ដែងអាការប្រព្រឹត្តទៅនៃឥទ្ធិចិត្ត ដោយការសម្ដែងភាពជាអទ្ធាបច្ចុប្បន្ន នៃជវនវារៈជាគន្លង ។ ពាក្យថា **ចិត្តដទៃ** បានដល់ អាវជ្ជនចិត្ត និងបរិកម្មចិត្ត ។ ក្នុងសេចក្ដីនេះ ពាក្យថា **អាចារ្យពួកខ្លះ** លោកអាចារ្យបំណងយកពួកអាចារ្យដែលអាស្រ័យនៅក្នុងអភយគិរីវិហារក៏ពិត សូម្បីដូច្នោះ អាចារ្យពួកនោះ ក៏មិនត្រូវការបិតិក្ខណៈនៃចិត្ត ព្រោះហេតុនោះ អាចារ្យពួកនោះ ក៏មិនគួរពោលថា ចាក់ដុះដល់បិតិក្ខណៈ ។ យ៉ាងនោះដូចគ្នា អាចារ្យពួកណាពោលថា ចិត្តរបស់លោកអ្នកមានឫទ្ធិ និងរបស់បុគ្គលដទៃ រមែងកើតឡើងក្នុងខណៈជាមួយគ្នាដូច្នេះ ។ ពាក្យរបស់អាចារ្យទាំងនោះ រមែងមិនសមគួរនឹងពាក្យថា រមែងចាក់ដុះត្រង់បិតិក្ខណៈខ្លះ

កន្តក្ខណៈខ្លះ ព្រោះថា ចិត្តរបស់លោកអ្នកមានឫទ្ធិដែលកំពុងកើតនៅត្រង់ខណៈទាំងពីរនៃចិត្តរបស់អ្នកដទៃនោះ មិនឈ្មោះថា កើតឡើងក្នុងខណៈជាមួយគ្នា ព្រមគ្នានឹងចិត្តរបស់អ្នកដទៃទេ ។ ម្យ៉ាងទៀត ចិត្តរបស់លោកអ្នកមានឫទ្ធិដែលកំពុងកើតត្រង់ឋិតិក្ខណៈ និងភង្គក្ខណៈនៃចិត្តរបស់អ្នកដទៃ រមែងដល់ភាពជាចិត្តដែលមានអារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង មានអារម្មណ៍ជាអតីតតែម្យ៉ាង ។ ចំណែកពាក្យដែលលោកពោលទុកថា កាលភិក្ខុអ្នកមានឫទ្ធិគិតថា យើងនឹងដឹងចិត្តរបស់បុគ្គលដទៃ ( **បរស្សចិត្តំ ជានិស្សាមិ** ) ដូច្នេះ ហើយទឹកដល់ចិត្តរបស់ជនជាច្រើនដោយអំណាចការរួមផ្តុំ ដូច្នេះ យ៉ាងណា ក៏ក្នុងពាក្យនេះ ឈ្មោះថា ជនចំនួនច្រើនដោយសេចក្តី បានដល់ បុគ្គលច្រើននាក់ពួកដទៃ ព្រោះហេតុនោះ ក៏គួរនឹងត្រូវពោលដល់ការប្រព្រឹត្តទៅនៃអាវជ្ជនៈទុកថា យើងនឹងដឹងចិត្តរបស់បុគ្គលទាំងឡាយពួកដទៃ ( **បរេសំ ចិត្តំ ជានិស្សាមិ** ) ដូច្នេះ ។ សូម្បីតាមដូចពោលមកនោះ ពាក្យថា **បរស្ស**( របស់បុគ្គលដទៃ ) គប្បីមានសេចក្តីថា **មហាជនស្ស** ( របស់ជនចំនួនច្រើន ) ម្យ៉ាងទៀត សូម្បីតាមប្រការនោះ ការដែលទឹកដល់ក្រុមចិត្តរបស់បុគ្គលម្នាក់ប៉ុណ្ណោះនោះហើយ ចាក់ដោះចិត្តត្រឹមមួយដួង រមែងជាការមិនត្រឹមត្រូវ , ព្រោះថា ការទឹកដល់ចិត្តជាក្រុម មិនជាការទឹកដល់ចិត្តជាចំណែកមួយទេ ព្រោះដូច្នោះ អាចារ្យពួកនោះក៏មិនគួរពោលថា ការទឹកដល់ចិត្តរបស់បុគ្គលជាច្រើនដូច្នេះឡើយ ។

ចំណែកអាចារ្យទាំងនោះ ពោលពាក្យណាថា ព្រោះហេតុថា ចិត្តរបស់លោកអ្នកមានឫទ្ធិ របស់អ្នកដទៃរមែងកើតឡើងក្នុងខណៈជាមួយគ្នា ។ ពាក្យអធិប្បាយដ៏ត្រឹមត្រូវក្នុងពាក្យនោះ គប្បីមានដូចតទៅនេះ គឺថា ភិក្ខុអ្នកបានចេតោបរិយញ្ញាណ

អ្នកត្រូវការដឹងចិត្តរបស់បុគ្គលដទៃ ចូលឈានដែលជាបាទ ចេញហើយ មិនធ្វើការបែកដោយភាពជាចិត្តអតីតជាដើម ធ្វើបរិកម្មថា យើងនឹងដឹងចិត្តរបស់បុគ្គលនេះ យើងនឹងដឹងចិត្តរបស់បុគ្គលនេះ ដោយភាពជាចិត្តស្មើគ្នា ចូលឈានដែលជាបាទទៀត ចេញហើយក៏នឹកដល់ចិត្ត ដោយភាពជាចិត្តស្មើគ្នានោះឯង ក៏រមែងចាក់ធ្លុះ គឺ តាមដឹងចិត្តរបស់បុគ្គលដទៃបាន ដោយចេតោបរិយញ្ញាណ ក្នុងលំដាប់នៃបរិកម្ម ៣ ឬ ៤ ខណៈ ដូចតាមដឹងរូបដោយទិព្វចក្ខុ ដូច្នោះ ។ ចំណែកតអំពីនោះទៅ ក៏មានការកំណត់ថា ជាចិត្តដែលមានរាគៈជាដើម ដោយកាមាវចរចិត្តដូចទិព្វចក្ខុ មានការកំណត់ថា មានពណ៌ខៀវជាដើមដូច្នោះ ។ ក្នុងបណ្តាចិត្តទាំងនោះអាវជ្ជនៈកាលនឹងនឹកដល់ចិត្តរបស់សត្វដែលមានប្រាកដចំពោះមុខ ដែលមានទិព្វចក្ខុបានឃើញហទយរូបហើយ ដោយភាពជាចិត្តស្មើគ្នា ក៏រមែងនឹកដល់ចិត្តដោយធ្វើចិត្តដែលមានប្រាកដចំពោះមុខ ឲ្យជាអារម្មណ៍ និងបរិកម្មចិត្តទាំងឡាយក៏ធ្វើចិត្តដែលកំពុងមាននោះៗ ឲ្យជាអារម្មណ៍ ដោយភាពជាចិត្តស្មើគ្នានោះឯងប្រព្រឹត្តទៅ ដែលជាបរិកម្មនៃញាណដែលដឹងចិត្ត ។ ចំណែកចេតោបរិយញ្ញាណកាលនឹងចាក់ធ្លុះ កាលនឹងតាមដឹងចិត្តដែលកំពុងប្រាកដ ក៏រមែងកើតឡើងក្នុងខណៈជាមួយគ្នា ព្រមនឹងចិត្តដួងនោះៗឯង ។

ក្នុងបណ្តាចិត្តទាំងនោះ ព្រោះហេតុដែលចិត្តទាំងឡាយ មានអាវជ្ជនៈជាដើមរមែងប្រព្រឹត្តទៅថា ជាចិត្តប៉ុណ្ណោះ ដោយទាក់ទងជាសភាវៈដូចគ្នា ដោយការកាន់យកការជាប់បន្តនៃចិត្តសន្តាន និងចិត្តដែលចេតោបរិយញ្ញាណតាមដឹងនោះឯង ។ ដូច្នោះ អាវជ្ជនៈ និងជវនៈទាំងឡាយ ក៏មិនមានភាពជាចិត្តដែលមានអារម្មណ៍ផ្សេងគ្នាក្នុងឋានៈដទៃពីមគ្គផលវិថី ដែលមិនគួរត្រូវការឡើយ ព្រោះប្រព្រឹត្តទៅដោយ

អាការដែលស្មើគ្នា ។ ម្យ៉ាងទៀត ប្រការថា បរិកម្មដែលមានអារម្មណ៍ជាបច្ចុប្បន្ន រមែង ជាបច្ច័យដោយអាសេវនប្បច្ច័យដល់ចេតោបរិយញ្ញាណដែលមានអារម្មណ៍ជាបច្ចុប្បន្ន ព្រោះហេតុនោះ រមែងជាការសម្រេចបាន ។ និងអតីតត្តិកៈក៏មានការកើត ឡើងបានតាមប្រការដូចពោលនេះ ។ បើនឹងកាន់យកដោយប្រការដទៃ កាលពោលដល់សន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្នក្នុងទីនេះថា ជាបច្ចុប្បន្នចិត្តដែលកន្លងទៅហើយ និងដែលនៅមិនទាន់មកដល់ ក៏នឹងគប្បីដល់ភាពជាបច្ចុប្បន្នផង ។ បើជាយ៉ាងនោះ ក៏គួរនឹងមានពាក្យត្រាស់ទុកថា ធម៌ដែលជាបច្ចុប្បន្នរមែងជាបច្ច័យដោយសមនន្តរប្បច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន តែក៏មិនបានត្រាស់ពាក្យនោះទុក ។ តាមពាក្យតម្រាស់ដែលថា ធម៌ដែលជាអតីតរមែងជាបច្ច័យដោយអនន្តរប្បច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន ខន្ធទាំងឡាយដែលកន្លងទៅហើយ ដែលកើតឡើងមុនៗ រមែងជាបច្ច័យដោយអនន្តរប្បច្ច័យ ដល់ខន្ធទាំងឡាយជាបច្ចុប្បន្នដែលកើតឡើងក្រោយៗ ។ ល ។ អនុលោមជាបច្ច័យដោយអនន្តរប្បច្ច័យដល់គោត្រភូ ដូច្នេះជាដើម បណ្ឌិតរមែងដឹងថា ខន្ធ ៤ ដែលកន្លងទៅហើយក្នុងលំដាប់ ក្នុងបណ្តាខន្ធដែលជាអទ្ធាបច្ចុប្បន្ន និងដែលជាសន្តតិបច្ចុប្បន្ននោះឯង ឈ្មោះថា ជាអតីត ។ ក៏សម្រាប់បទថា បច្ចុប្បន្នដែលមកហើយក្នុងអភិធម្មមាតិកា ក្នុងព្រះបាលីក្នុងទីណាៗ ក៏មិនបានត្រាស់សេចក្តីនៃបទទុកថា ជាអទ្ធាបច្ចុប្បន្ន ឬ សន្តតិបច្ចុប្បន្ន ។ ព្រោះដូច្នោះ អាចារ្យទាំងនោះ ទើបពោលដល់ ភាពជាចេតោបរិយញ្ញាណ មានអារម្មណ៍ជាបច្ចុប្បន្នតាមសេចក្តីដែលចិត្តរបស់លោកអ្នកមានឫទ្ធិរបស់បុគ្គលដទៃប្រព្រឹត្តទៅក្នុងខណៈដូចគ្នា ។ រីឯ ក្នុងពេលណាភិក្ខុអ្នកមានឫទ្ធិធ្វើការត្រិះរិះថា បុគ្គលនេះមានចិត្តដូចណាប្រព្រឹត្តហើយ យើងនឹងដឹងចិត្តដូចនោះដូច្នេះក្តី ថាបុគ្គលនេះនឹងមានចិត្ត

ដូចណា យើងនឹងដឹងចិត្តដូងនោះដូច្នេះក្តី ហើយធ្វើកិច្ចទាំងឡាយ មានការចូលឈានជាបាទជាដើម ក្នុងពេលនោះ អាវជ្ជនបរិកម្ម និងចេតោបរិយញ្ញាណ រមែងមានអារម្មណ៍ជាអតីត ឬ អនាគតនោះឯង ព្រោះបានប្រើអាវជ្ជនៈនោះឯងធ្វើការបែកទុក ។

ចំណែកអាចារ្យពួកណា អាស្រ័យពាក្យនេះថា ភិក្ខុអ្នកមានឫទ្ធិអ្នកត្រូវការនឹងដឹង រមែងនឹកដល់ចិត្តរបស់បុគ្គលដទៃ អាវជ្ជនចិត្តរមែងធ្វើចិត្តដែលជាខណៈបច្ចុប្បន្នឲ្យជាអារម្មណ៍ ហើយក៏រមែងរលត់ទៅព្រមទាំងអារម្មណ៍នោះឯង។ បន្ទាប់ពីនោះ ជវនចិត្ត ៤ ខណៈ ឬ ៥ ខណៈ រមែងស្ទុះទៅដែលជាបណ្តាជវនចិត្តដែលមានខណៈចុងក្រោយជាឥទ្ធិចិត្ត ជវនចិត្តដែលនៅសល់ជាកាមាវចរចិត្ត ចិត្តដែលរលត់ទៅហើយនោះៗឯង ជាអារម្មណ៍នៃជវនចិត្តពួកនោះ សូម្បីគ្រប់ដូង ក៏ជវនចិត្តពួកនោះមិនជាចិត្តដែលមានអារម្មណ៍ផ្សេងគ្នាទេ ព្រោះមានចិត្តដែលជាបច្ចុប្បន្នដោយទាក់ទងនឹងអទ្ធាជាអារម្មណ៍ ដូច្នោះហើយពោលថា កាលនឹកដល់ចិត្តទាំងឡាយដែលជាអនាគត ដែលមានខណៈចិត្ត ១ ឬ ២-៣-៤ ឬ ៥ ខណៈ អាវជ្ជនៈ និងជវនទាំងឡាយ ក៏មិនមានភាពជាចិត្តដែលមានអារម្មណ៍ផ្សេងគ្នាទេ សូម្បីថា មានភាពជាចិត្តដែលមានអារម្មណ៍ជាអនាគត ឬបច្ចុប្បន្ន ឬអតីតបានតាមសមគួរដល់ការកើតបានក៏ដោយ ដូចដែលអាវជ្ជនៈ និងជវនមិនមានភាពជាចិត្តដែលមានអារម្មណ៍ផ្សេងគ្នា សូម្បីថាមានភាពជាចិត្តដែលមានអារម្មណ៍ជាបច្ចុប្បន្ន ឬអតីតបានក៏ដោយ ដូច្នោះ កាលអាវជ្ជនៈនោះនឹកដល់ចិត្តដែលជាអនាគតដែលមានខណៈចិត្ត ៤ ឬ ៥ ខណៈ ក៏នឹងមានការសម្រេចចេតោបរិយញ្ញាណដែលមានអារម្មណ៍ជាខណៈបច្ចុប្បន្ន ក្នុងលំដាប់នៃបរិកម្ម ដែលមានអារម្មណ៍ជាអនាគតបាន

ដូច្នោះ ។ ពាក្យនិយាយរបស់អាចារ្យពួកនោះ រមែងមិនសម្រេច( ប្រើមិនបាន ) ព្រោះព្រះមានព្រះភាគមិនបានលើកបញ្ហាឡើងថា ធម៌ដែលមានអារម្មណ៍ជាអនាគត រមែងជាបច្ច័យដោយអាសេវនប្បច្ច័យដល់ធម៌ដែលមានអារម្មណ៍ជាបច្ចុប្បន្ន ធម៌ដែលមានអារម្មណ៍ជាបច្ចុប្បន្ន រមែងជាបច្ច័យដោយអាសេវនប្បច្ច័យដល់ធម៌ដែលមានអារម្មណ៍ជាអតីត ដូច្នេះ ពួកនេះទុក , និងព្រោះបានត្រាស់ចំនួនរាប់ទុកថា **អាសេវនេ តីណិ** ( ក្នុងអាសេវនប្បច្ច័យមានមូល ៣ ) ។ ពិតមែន មហគ្គតចិត្តដែលជាកុសល និងកិរិយាដែលមិនមានអាសេវនប្បច្ច័យ ( គឺ មិនជាផលនៃអាសេវនប្បច្ច័យ ) មិនមាន ។ ក៏ការៈដែលអាចារ្យទាំងនោះអាស្រ័យវាទៈនេះពោលដល់កាលដែលអាវជ្ជនៈ និងជវនទាំងឡាយ មានចិត្តដែលជាខណៈបច្ចុប្បន្នដែលរលត់ទៅហើយជាអារម្មណ៍ មិនសម្រេចទេ( ប្រើមិនបាន ) ព្រោះវាទៈនោះលោកសំដៅយកការៈដែលអាវជ្ជនៈ មិនមានការកាន់យកចិត្តដែលជាអនាគត ក្នុងពេលកាន់យកចិត្តដោយមិនធ្វើឲ្យប្លែកគ្នាថា ចិត្តដួងណាប្រព្រឹត្តទៅហើយ និងថាចិត្តដួងណានឹងប្រព្រឹត្តទៅដូច្នេះ និងការៈដែលជវនទាំងឡាយ ក៏មិនមានការកាន់យកចិត្តដែលកំពុងប្រព្រឹត្តទៅ ព្រោះមិនមានអាវជ្ជនៈនោះ ។ ពិតមែន ក្នុងពេលនោះ ចិត្តដែលជាអាវជ្ជនៈជាការនឹក រមែងប្រារព្ធយកចិត្តដែលមានប្រាកដចំពោះមុខនោះឯង ប្រព្រឹត្តទៅក្នុងលំដាប់នៃភវង្គដែលញ័រ ព្រោះហេតុនោះ ទើបអាចារ្យបដិសេធថា ពាក្យដែលលោកអាចារ្យទាំងនោះពោលថា ចិត្តដែលជាខណៈបច្ចុប្បន្នរមែងជាអារម្មណ៍របស់ចេតោបរិយញ្ញាណដូច្នេះឯណា ពាក្យនោះ មិនត្រឹមត្រូវ ព្រោះនឹងមានការដល់នូវទោស(ប្រការខ្វះខាត , ប្រការដែលមិនត្រឹមត្រូវ) គឺការដែលអាវជ្ជនចិត្តនិងជា **ននចិត្ត**( អភិញ្ញាចិត្តដែលដឹង ) មានការតាំងចុះ កើតឡើងព្រម

គ្នាបានក្នុងការៈដែលជា **ននចិត្ត** មានចិត្តដែលកំពុងប្រព្រឹត្តទៅជាអារម្មណ៍ និង ព្រោះមានការដែលដល់នូវទោស គឺ ការៈដែលអាវជ្ជនៈ និងជវនទាំងឡាយមាន អារម្មណ៍ផ្សេងគ្នាបាន ក្នុងឋានៈដែលមើលមិនឃើញ( មិនត្រូវការ ) គឺក្នុងការទឹក និងការចាក់ចុះចិត្ត ជាក្រុមនឹងប្រាកដត្រឹមតែចំណែកមួយ និងក្នុងការទឹក ការដឹង ចិត្តដែលប្រសព្វចូលគ្នា និងប្រសព្វចូលគ្នាហើយដូច្នេះ កាលមើលឃើញការ ដល់នូវទោសតាមដែលបានពោលហើយ និងការៈដែលរកភាពជាចិត្តដែលមាន អារម្មណ៍ផ្សេងគ្នាមិនបាន ព្រោះមានចិត្តដែលជាអទ្ធាបច្ចុប្បន្ន ឬ សន្តតិបច្ចុប្បន្ន ដោយអំណាចនៃកាលហើយ ទើបបានពោលដល់ភាពដែលអាវជ្ជនៈ និងជវន ទាំងឡាយដែលកំពុងប្រព្រឹត្តទៅ មានចិត្តដែលរលត់ទៅហើយជាអារម្មណ៍ទុក ។ សូម្បីពាក្យនោះ លោកអាចារ្យដែលមានវាទៈដំបូងទាំងឡាយមិនគួរយល់ព្រម ។ ក៏កាលមានពាក្យនោះ ពេញចិត្តនឹងពោលថា អាវជ្ជនចិត្តដែលមានបច្ចុប្បន្នជា អារម្មណ៍ជាបច្ច័យ ដោយអនន្តរប្បច្ច័យដល់ខន្ធទាំងឡាយ ដែលមានអារម្មណ៍ ជាអតីត ដោយការកាត់បទ ដែលសង្គ្រោះចូលនឹងបទដទៃជាអនន្តរប្បច្ច័យ ដូចក្នុង ព្រះបាលីថា **អវជ្ជនាកុសលានំ** ( អាវជ្ជនចិត្តជាបច្ច័យដល់កុសលធម៌ទាំងឡាយ ) ដូច្នេះជាដើម , តែលោកមិនពោលទុកទេដូច្នេះឯង ។

សួរថា ព្រោះហេតុអ្វី ទើបបានវិចារដល់ភាពដែលចេតោបរិយញ្ញាណមាន អារម្មណ៍ជាបច្ចុប្បន្នទុកយ៉ាងនេះ បណ្ឌិតរមែងដឹងបានថា ចេតោបរិយញ្ញាណរមែង មិនប្រព្រឹត្តទៅក្នុងចិត្តដែលជាបច្ចុប្បន្ន ព្រោះក្នុងការចែកបទទាំងនេះថា **អតីតោ ធម្មោ បច្ចុប្បន្នស្ស ។បេ។ អារម្មណប្បច្ចយេន បច្ចយោ**( ធម៌ដែលជាអតីតរមែង ជាបច្ច័យដោយអនន្តរប្បច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន ធម៌ដែលជាអនាគតរមែង

ជាបច្ច័យដោយអារម្មណប្បច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន ) ដូច្នេះ ទ្រង់ធ្វើការកាន់យកចេតោបរិយញ្ញាណហើយថា **អតីតា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយ-ញ្ញាណស្ស ។ បេ ។ អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ**( ខន្ធដែលជាអតីតរមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់អាវជ្ជនៈរបស់ឥទ្ធិវិធញ្ញាណ នៃចេតោបរិយញ្ញាណ នៃបុព្វេនិវាសានុស្សតិញ្ញាណ នៃយថាកម្មូបគញ្ញាណ ខន្ធដែលជាអនាគត រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់អាវជ្ជនៈនៃឥទ្ធិវិធញ្ញាណ នៃចេតោបរិយញ្ញាណ នៃអនាគតំសញ្ញាណ )ដូច្នេះ និងក្នុងឧប្បន្នតិកៈ ទ្រង់កាន់យកចេតោបរិយញ្ញាណហើយថា **អនុប្បន្នា ខន្ធា ឧបាទិន្នោ ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស ។បេ។ អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ** ( ខន្ធដែលនៅមិនទាន់កើតឡើង ខន្ធដែលមានប្រក្រតីកើតឡើង រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់អាវជ្ជនៈនៃឥទ្ធិវិធញ្ញាណ នៃចេតោបរិយញ្ញាណ នៃអនាគតំសញ្ញាណ )ដូច្នេះ តែក្នុងការចែកបទថា **បច្ចុប្បន្នា ធម្មា បច្ចុប្បន្នស្ស ធម្មស្ស** ( ធម៌ដែលជាបច្ចុប្បន្នជាបច្ច័យដល់ធម៌ដែលជាបច្ចុប្បន្ន ) នេះក៏ត្រឡប់ត្រាស់ទុកត្រឹមនេះថា **បច្ចុប្បន្នា ខន្ធា ឥទ្ធិវិធញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ** ( ខន្ធដែលជាបច្ចុប្បន្នរមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់អាវជ្ជនៈនៃឥទ្ធិវិធញ្ញាណ ) និងក្នុងឧប្បន្នតិកៈ ក៏បានត្រាស់ទុកត្រឹមនេះប៉ុណ្ណោះថា **ឧប្បន្នា ខន្ធា ឥទ្ធិវិធញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ** ( ខន្ធដែលកើតឡើងហើយ រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់អាវជ្ជនៈនៃឥទ្ធិវិធ-ញ្ញាណ ) ដូច្នេះ ។ បើថា ចេតោបរិយញ្ញាណគប្បីប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលជាបច្ចុប្បន្នបានដូច្នោះ ក៏នឹងត្រូវធ្វើការកាន់យកចេតោបរិយញ្ញាណក្នុងបទទាំងឡាយ

ក្រៅពីនេះ ដូចគ្នានឹងបទដំបូងៗទាំងឡាយ មិនមែនឬ ? ឆ្លើយថា ជាការពិត នឹងត្រូវធ្វើការកាន់យកចេតោបរិយញ្ញាណផង តែថា ពាក្យដែលត្រាស់នោះ ជាពាក្យសង្ខេបដោយទាក់ទងជាការសម្តែងដោយន័យ ព្រោះហេតុនោះ បណ្ឌិតរមែងដឹងច្បាស់បានដោយព្រះបាលីកន្លែងដទៃ ។

ពិតមែន ក្នុងពាក្យចែកបទទាំងនេះថា **អតីតារម្មណោ ធម្មោ បច្ចុប្បន្នារម្មណស្ស ។បេ។ បច្ចុប្បន្នារម្មណោ បច្ចុប្បន្នារម្មណស្ស** ( ធម៌ដែលមានអារម្មណ៍ជាអតីត រមែងជាបច្ច័យដោយអារម្មណប្បច្ច័យ ដល់ធម៌ដែលមានអារម្មណ៍ជាបច្ចុប្បន្ន ធម៌ដែលមានអារម្មណ៍ជាអនាគត រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់ធម៌ដែលមានអារម្មណ៍ជាបច្ចុប្បន្ន ធម៌ដែលមានអារម្មណ៍ជាបច្ចុប្បន្ន រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់ធម៌ដែលមានអារម្មណ៍ជាបច្ចុប្បន្ន ) ដូច្នេះ បានត្រាស់ដល់ ការប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលជាបច្ចុប្បន្ននៃចេតោបរិយញ្ញាណទុកថា **ចេតោបរិយញ្ញាណេន អតីតារម្មណបច្ចុប្បន្នចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។បេ។ ចេតោបរិយញ្ញាណស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ** ( ភិក្ខុរមែងដឹងចិត្តរបស់បុគ្គលអ្នកព្រមព្រៀងដោយចិត្តបច្ចុប្បន្ន ដែលមានអារម្មណ៍ជាអតីតដោយចេតោបរិយញ្ញាណ ខន្ធបច្ចុប្បន្នដែលមានអារម្មណ៍ជាអតីត រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់អាវជ្ជនៈនៃចេតោបរិយញ្ញាណ ភិក្ខុរមែងដឹងចិត្តរបស់បុគ្គលអ្នកព្រមព្រៀងដោយចិត្តបច្ចុប្បន្ន ដែលមានអារម្មណ៍ជាអនាគត ដោយចេតោបរិយញ្ញាណ ខន្ធបច្ចុប្បន្នដែលមានអារម្មណ៍ជាបច្ចុប្បន្ន រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់អាវជ្ជនៈនៃចេតោបរិយញ្ញាណ ភិក្ខុរមែងដឹងចិត្តរបស់អ្នកព្រមព្រៀងដោយចិត្តបច្ចុប្បន្ន ដែលមានអារម្មណ៍ជាបច្ចុប្បន្នដោយចេតោបរិយញ្ញាណ ,

ខន្ធបច្ចុប្បន្នដែលមានអារម្មណ៍ជាបច្ចុប្បន្នដល់អាវជ្ជនៈនៃចេតោបរិយញ្ញាណ )ដូច្នេះឯង ។ ទើបគប្បីជ្រាបថា ខ្ញុំបានធ្វើការវិចារប្រការនេះទុក ក៏ព្រោះហេតុនោះឯង ។ បទថា **តេសំ** ជាឆដ្ឋីវិភត្តិ ក្នុងនិទ្ធារណៈ គឺ ក្នុងញាណ ២ នោះ , អធិប្បាយថា ឈ្មោះថា មានចំពោះចិត្តប៉ុណ្ណោះជាអារម្មណ៍ ក៏ព្រោះភាពដែលជាចេតោបរិយញ្ញាណ ។ ព្រោះដូច្នោះ ទើបលោកពោលថា រមែងមិនដឹងខន្ធដទៃ ឬវត្ថុដែលជាប់នឹងខន្ធ ដូច្នេះ ។ ក្នុងពាក្យនោះ ឈ្មោះ និងគោត្រជាដើម ឈ្មោះថា វត្ថុដែលជាប់នឹងខន្ធ ។ លោកអាចារ្យធ្វើពាក្យសួរទុកក្នុងចិត្តថា បើយ៉ាងនេះដូច្នេះ នឹងឈ្មោះថាជាញាណដែលមានអារម្មណ៍ជាមគ្គបានយ៉ាងដូចម្ដេច ? ដូច្នេះហើយ ទើបពោលថា ប៉ុន្តែក៏ពោលបានថា មានអារម្មណ៍ជាមគ្គបានដោយបរិយាយ ព្រោះមានចិត្តដែលសម្បយុត្តនឹងមគ្គជាអារម្មណ៍ ដូច្នោះ ។ ឈ្មោះថា មានត្រឹមចេតនាដែលជាអតីតប៉ុណ្ណោះជាអារម្មណ៍ អធិប្បាយថា សេចក្ដីពិតថា ញាណនោះលោកហៅថា យថាកម្មូបគញ្ញាណ ក៏ដោយប្រការដែលមានត្រឹមចេតនា ជាអារម្មណ៍នោះ ។ ក្នុងបទថា **ខន្ធបដិពទ្ធេសុ** នេះ លោកអាចារ្យទាំងឡាយ ពោលថា សូម្បីព្រះនិព្វានក៏ឈ្មោះថា ជាវត្ថុដែលទាក់ទងនឹងខន្ធដូចគ្នា ព្រោះជាធម៌ដែលព្រះអរិយបុគ្គលធ្វើឲ្យជាអារម្មណ៍បាន ដោយខន្ធទាំងឡាយ ។ ពិតយ៉ាងនោះ លោកពោលទុកក្នុងអដ្ឋសាលិនីថា បុព្វេនិវាសានុស្សតិញ្ញាណ រមែងជាញាណដែលមានអារម្មណ៍ជាអប្បមាណ សូម្បីដោយការពិចារណាមគ្គផល និងព្រះនិព្វានដោយអំណាចនៃការតាមរឭកដល់លោកអ្នកមានដំណើរទៅកាន់ភពខ្ជាក់ចោលហើយថា ព្រះពុទ្ធទាំងឡាយក្នុងអតីត ទ្រង់បានចម្រើនមគ្គហើយ ទ្រង់បានធ្វើផលឲ្យជាក់ច្បាស់ហើយ ទ្រង់បានបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុដូច្នេះ ។ ក្នុងពាក្យនោះ

គប្បីជ្រាបថា ការពិចារណាមគ្គ និងផល រមែងប្រព្រឹត្តទៅបានក្នុងកាលបានដឹងមគ្គ និងផល ដោយបុព្វេនិវាសានុស្សតិញ្ញាណហើយ ។ ការពិចារណាព្រះនិព្វាន រមែងប្រព្រឹត្តទៅបាន ក្នុងកាលបានដឹងអប្បមាណធម៌ទាំងឡាយ ដែលមានព្រះនិព្វានជាអារម្មណ៍ហើយ ព្រោះហេតុនោះ ការពិចារណាមគ្គជាដើម រមែងធ្វើភាពជាញាណដែលមានអារម្មណ៍ជាអប្បមាណឲ្យសម្រេចដល់ បុព្វេនិវាសានុស្សតិ-ញ្ញាណបាន ។

ពិតមែន ទ្រង់ត្រាស់ទុកថា **អប្បមាណា ខន្ធា បុព្វេនិវាសានុស្សតិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ** ( អប្បមាណខន្ធទាំងឡាយ រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់បុព្វេនិវាសានុស្សតិញ្ញាណ ដូច្នេះ , មិនបានត្រាស់ថា **និព្វានំ** ព្រះនិព្វាន រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់បុព្វេនិវាសានុស្សតិញ្ញាណ ) ដូច្នេះទេ ។ ព្រោះដូច្នោះ សូម្បីកាលនឹងពោលដល់កិច្ច គឺការពិចារណាមគ្គ និងផល ដោយបុព្វេនិវាសញ្ញាណនោះឯង ក៏មិនអាចនឹងពោលដល់ការពិចារណា ព្រះនិព្វានបាន ។ ចំណែកក្នុងអដ្ឋកថា លោកបានសម្ដែងដល់ភាពដែលជាញាណដែលមានព្រះនិព្វានជាអារម្មណ៍បាន ។

បើមានពាក្យសួរថា ប្រការថា **កុសលា ខន្ធា** ( ខន្ធដែលជាកុសលទាំងឡាយ ) ជាពាក្យសម្ដែងខៃ ដែលជាពហុវចនៈ ដែលមានការសំដៅដល់ឥទ្ធិវិធញ្ញាណ បុព្វេនិវាសញ្ញាណ និងអនាគតំសញ្ញាណ មិនមានការសំដៅដល់ចេតោបរិយញ្ញាណ និងយថាកម្មូបគញ្ញាណទេ ព្រោះហេតុនោះ ទើបមិនប្រើពាក្យដែលធ្វើឲ្យញាណទាំងនោះ សម្រេចភាពជាញាណដែលមានខន្ធ ៤ ជាអារម្មណ៍ទេ ឬអ្វី ? ឆ្លើយថា មិនបានទេ , ព្រោះសេចក្ដីនេះ ( ដែលថា **កុសលា ខន្ធា** )

សម្រេចហើយថា ជាពាក្យសម្តែងទ្វៃដែលជាពហុវចនៈ ដែលមានការសំដៅដល់ចេតោបរិយញ្ញាណផង ព្រោះត្រាស់ទុកក្នុងទីដទៃថា **អវិតក្កវិចារមត្តា ខន្ធា ច វិចារោ ច ចេតោបរិយញ្ញាណស្ស ។បេ។ អារម្មណប្បច្ចយេន បច្ចយោ** ( ខន្ធទាំងឡាយដែលមិនមានវិតក្កៈ មានត្រឹមតែវិចារៈ និងវិចារៈ រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់ចេតោបរិយញ្ញាណ ដល់បុព្វេនិវាសានុស្សតិញ្ញាណ ដល់អនាគតំសញ្ញាណ ដូច្នេះ និងថា **សវិតក្ក សវិចារោ ខន្ធា ច វិតក្កោ ច ចេតោបរិយញ្ញាណស្ស ។បេ។ អារម្មណប្បច្ចយេន បច្ចយោ** ( ខន្ធទាំងឡាយដែលមានវិតក្កៈ មានវិចារៈផង វិតក្កៈផង រមែងជាបច្ច័យដោយអារម្មណប្បច្ច័យដល់ចេតោបរិយញ្ញាណ ដល់បុព្វេនិវាសានុស្សតិញ្ញាណដល់ អនាគតំសញ្ញាណដូច្នេះ ។ សួរទៀតថា សូម្បីថាបើយ៉ាងនេះ យថាកម្មូបគញ្ញាណ ក៏មិនសម្រេចភាពជាញាណដែលមានខន្ធ ៤ អារម្មណ៍ទេ ព្រោះមិនបានត្រាស់ដល់ ក្នុងពាក្យថា **អវិតក្កវិចារមត្តា ខន្ធា ច វិចារោ ច** ( ខន្ធទាំងឡាយដែលមិនមានវិតក្កៈ មានត្រឹមវិចារៈផង វិចារៈផង )ដូច្នេះជាដើម ឆ្លើយថា មិនមាន ។ ព្រោះមិនបានត្រាស់ទុក ក្នុងទីនេះមានខដទៃជាហេតុ ។ សេចក្តីពិតថា យថាកម្មូបគញ្ញាណរមែងកាន់យកខន្ធ ៤ ដែលលាយឡំនឹងកម្មបាន ដោយមានកម្មជាគន្លង ។ ដូចជាចេតោបរិយញ្ញាណ រមែងតាមដឹងចិត្តដែលមានការបែកដោយជាចិត្ត ដែលមិនមានវិតក្កៈជាដើម និងដែលមានការបែកដោយជាចិត្ត ដែលមានរាគៈជាដើម ដោយអំណាចនៃបរិកម្មដែលកើតមុន យ៉ាងណា យថាកម្មូបគញ្ញាណនោះ រមែងតាមដឹងចិត្តដែលមានការបែកដូច្នោះដូចគ្នាក៏ទេ ។ រមែងតាមដឹងធម៌ដែលរួមគ្នានឹងកម្ម ដែលទាក់ទងនឹងកម្មនោះឯង ។ ព្រោះដូច្នោះ ក្នុងពេលដែលទ្រង់ធ្វើការបែកថា ខន្ធទាំងឡាយ

ដែលមិនមានវិតក្កៈ មានត្រឹមវិចារៈផង វិចារៈផងជាដើម ទើបមិនបានត្រាស់ដល់យថាកម្មូបគញ្ញាណនោះទុក, មិនមែនថា មិនបានត្រាស់ខន្ធ៤ទុក ព្រោះជាអារម្មណ៍ដែលផ្សេងគ្នាទេ ។ ចំណែកអាចារ្យពួកខ្លះពោលថា ប្រការដែលពោលមកនេះមិនមែនជាហេតុនៃសេចក្តីប្រការនេះទេ ។ សូម្បីក្នុងទីនោះ ក៏ត្រាស់ទុកដូចគ្នាថា **បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មូបគញ្ញាណស្ស អនាគតំសញ្ញាណស្ស** ( ដល់បុព្វេនិវាសានុស្សតិញ្ញាណ ដល់យថាកម្មូបគញ្ញាណ ដល់អនាគតំសញ្ញាណ ) ដូច្នេះ ។ ពិតហើយ យថាកម្មូបគញ្ញាណនោះ មិនមែនជាញាណដែលមិនអាចនឹងតាមដឹងកម្មដែលមានការចែក ព្រោះជាកម្មដែលមានវិតក្កៈជាដើម ដូចកម្មដែលមានការចែកជាកុសល និងអកុសលទេ , ព្រោះថា សូម្បីការតាមដឹងដល់ទុច្ចរិតនិងសុចរិត ក៏ចាត់ជាការតាមដឹងដល់កម្ម ដែលមានការចែកពិសេស ដោយប្រការរួមគ្នានឹងលោភៈជាដើម ឬនឹងអលោភៈជាដើម ដូច្នេះ ។

លោកពោលទុកក្នុងអដ្ឋកថាត្រឹមនេះប៉ុណ្ណោះថា បុព្វេនិវាសានុស្សតិញ្ញាណរមែងជាញាណដែលមានអារម្មណ៍ជានវត្តព្វៈ ក្នុងពេលដែលតាមរឭកដល់ឈ្មោះនិងគោត្រដូច្នេះ ។ ក៏ឈ្មោះ និងគោត្រជាសេចក្តីនៃព្យញ្ជនៈដែលជាប់ទាក់ទងនឹងខន្ធសម្រេចដោយសម្មតិ មិនមែនជាព្យញ្ជនៈដូច្នេះ ។ ពាក្យថា **ក្នុងអារម្មណ៍ដែលជានវត្តព្វៈនេះ** ខ្ញុំមានការឃើញសេចក្តីនេះ គឺលោកអាចារ្យមានអត្តនោមតិ គឺការឃើញផ្ទាល់ខ្លួន( ប្រការនេះ )។ ពាក្យដែលលោកអាចារ្យពោលថា មិនមែនជាព្យញ្ជនៈ ដូច្នេះ ពាក្យថា **ព្រោះថា ព្យញ្ជនៈជាដើម** ជាការធ្វើពាក្យដែលពោលទុកនោះឲ្យជាការប្រើបាន ( ឲ្យប្រាកដប្រជា ឲ្យទទួលស្តាប់បាន ) ។

ពាក្យថា **នឹងកើតក្នុងកាមាវចរភូមិ** លោកពោលដល់ការដឹងខន្ធដែលកើត

ឡើង ។

បទថា ឯត្ថ បានដល់ ក្នុងពាក្យវិចារអារម្មណ៍នៃអភិញ្ញាញាណទាំងឡាយ ដោយអំណាចនៃអជ្ឈត្តារម្មណតិកៈនេះ ។ មានពាក្យអធិប្បាយថា ញាណដែលលោកពោលរួមគ្នាក្នុងអដ្ឋកថាបុរាណថា ជាញាណដែលមានអារម្មណ៍ជាខាងក្នុង និងជាញាណដែលមានអារម្មណ៍ជាខាងក្រៅ ដូច្នេះ ញាណនោះ លោកពោលទុកដោយសេចក្ដីថា ប្រាកដទាំងញាណដែលមានអារម្មណ៍ជាខាងក្នុង ។ល។ តាមកាលដ៏គួរនោះឯង ដូច្នេះ ។ ពិតហើយ ធម្មជាតិដែលដាច់ដោយឡែក ឈ្មោះថា ប្រាកដទាំងខាងក្នុង ទាំងខាងក្រៅ មិនមាន ។ ទាំងញាណនឹងធ្វើធម្មជាតិដែលប្រាកដទាំងខាងក្នុង ទាំងខាងក្រៅនោះ ឲ្យជាអារម្មណ៍រួមបាន ក៏ទេដែរ ។ សួរថា បើយ៉ាងនេះ ដូច្នោះ តិកៈនេះឯង រមែងមិនពេញ មិនគ្រប់ចំនួន ព្រោះមិនមានបទទី ៣ ដែលមានសភាវៈដទៃ ដែលសង្គ្រោះដោយបទទាំងពីរខាងដើមមិនបាន ? ឆ្លើយថា មិនបានព្រោះការសម្ដែងតិកៈ មានការបែកទៅដោយប្រការជាវិស័យ ។ ពិតយ៉ាងនោះ ក្នុងអដ្ឋកថា លោកពោលទុកថា រមែងដឹងធម៌ទាំងឡាយដែលមាន ៣ ប្រការពួកនោះៗ ឯង ដូច្នោះទុក ។ សេចក្ដីថា រមែងដឹងធម៌ទាំងឡាយទាំង ៣ យ៉ាង គឺដែលជាខាងក្នុងជាដើមពួកនោះៗ ឯង ។ ក៏ក្នុងទីនេះ ការដែលលោកមិនពោលថា ធម៌ពួកនោះៗ ឯង តែពោលថា ដែលមាន ៣ ប្រការ ក៏ដើម្បីសម្ដែងថា ទេសនាតិកៈ ( ការសម្ដែងធម៌ពួក ៣ ដែលហៅថា អជ្ឈត្តិកៈ )នេះ ឈ្មោះថា មានការពាក់ព័ន្ធនឹងការបែកទៅដោយប្រការទាំងឡាយ ។ ប្រៀបដូចជាទេសនា-តិកៈ និងទុកៈទាំងឡាយ មានកុសលតិកៈជាដើម ជាទេសនាដែលពាក់ព័ន្ធនឹងការបែកទៅនៃធម៌ទាំងឡាយ ដោយជាតិ ការប្រកបរួមគ្នា ការលះសិក្ខា ភូមិ ប្រភេទ

នៃអារម្មណ៍និយម គឺ ការកំណត់កាលជាដើម យ៉ាងណា អជ្ឈត្តត្តិកៈនេះ នឹងជាទេសនាដែលមានការពាក់ព័ន្ធនឹងការបែកទៅដោយជាតិជាដើម ដូច្នេះក៏ទេ , ទាំងជាទេសនាដែលមានការទាក់ទងនឹងការបែកទៅដោយសភាវៈជាដើម ដូចជាសនិទស្សនត្តិកៈ ឬ ហេតុទុកៈជាដើមក៏ទេ ។ បើជាទេសនាដែលមានការពាក់ព័ន្ធនឹងការបែកទៅដោយប្រការទាំងពួងដូច្នេះ ។ ពិតមែន ខន្ធ ៥ នោះឯង អាស្រ័យភាពជារបស់ដែលរាប់ទាក់ទងក្នុងសន្តានរបស់ខ្លួន ក៏ហៅថា **អជ្ឈត្តា**( អាស្រ័យភាពជារបស់ដែលរាប់ទាក់ទងក្នុងសន្តានរបស់អ្នកដទៃ ក៏ហៅថា **ពហិទ្ធា**( ខាងក្រៅ ) អាស្រ័យភាវៈទាំងពីរ ក៏ហៅថា **អជ្ឈត្តពហិទ្ធា** ( ទាំងខាងក្នុង ទាំងខាងក្រៅ ) ដូច្នេះ ។ ព្រោះហេតុនោះ ទើបត្រាស់ទុកថា **អនិន្ទ្រិយពទ្ធរូបញ្ច និព្វានញ្ច ឋបេត្វា សព្វេ ធម្មា សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា**( ធម៌ទាំងឡាយទាំងពួង លើកលែងតែរូបដែលមិនទាក់ទងជាមួយឥន្ទ្រិយ និងព្រះនិព្វានចេញ ដែលជាខាងក្នុងក៏មាន ដែលជាខាងក្រៅក៏មាន ដែលទាំងខាងក្នុងទាំងខាងក្រៅក៏មាន )ដូច្នេះ។ សួរថា ក៏ក្នុងត្តិកៈនេះ កងធម៌ទី ៣ ( ដែលថា ទាំងខាងក្នុងទាំងខាងក្រៅ ) រមែងមិនមាន ព្រោះមិនមានសភាវៈដទៃ និងព្រោះទ្រង់មិនត្រូវការប្រការដទៃ មិនមែនឬ ? ឆ្លើយថា ប្រការនេះមិនដូច្នោះទេ ។ សភាវធម៌ទាំងឡាយទាំងពួង ត្រូវកំណត់កាន់យកបាន ដោយបទទាំងពីរនោះឯង ព្រោះបទទី ២ ប្រព្រឹត្តទៅដោយអំណាចនៃការមិនបានរួមយកសភាវធម៌ ដែលសង្គ្រោះដោយបទទី ១ ទុកក៏ពិត សូម្បីដូច្នោះ ក៏ទ្រង់ត្រាស់ បទទី ៣ ទុកដោយអំណាចនៃការរួមកាន់យកធម៌ទាំងឡាយ ដែលបានកាន់យកមួយកងៗ ដោយពីរបទពួកនោះ ព្រោះហេតុនោះ កងធម៌ទី ៣ ក៏មានដូចគ្នា ។ ពិតមែន របស់រួមមិនឈ្មោះថា ជា

របស់វាត់វាយទេ ។ តែក៏គប្បីឃើញថា ក្នុងធម៌ដែលមានវត្ថុផ្សេងគ្នា មិនស្រប សេចក្ដីគ្នានៃការអធិដ្ឋានហើយ ក៏រមែងមិនកើតការកាន់យករួមគ្នាទៅ ព្រោះហេតុ នោះ ទើបលោកពោលថា ក្នុងពេលដែលដឹងខាងក្នុងតាមកាលដ៏គួរ ក្នុងពេល ដែលដឹងខាងក្រៅតាមកាលគួរដូច្នេះ ។

## បរិច្ឆេទទី ១៣

ឈ្មោះ **អភិញ្ញានិទ្ទេស** ក្នុង

អធិការនៃសមាធិកាថានៃបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ ដែល
ខ្ញុំព្រះករុណាធ្វើដើម្បីជាប្រយោជន៍ដល់សេចក្ដីបាមោជ្ជនៃសាធុជនដូច្នេះឯង ។
( សមាធិនិទ្ទេសមាន ៤ ភាគ ចប់ហើយដោយបរិបូរណ៍ )

អាស្រមព្រះគន្ធកុដិ ថ្ងៃ ៨ កើត ខែពិសាខ ព.ស. ២៥៥៤
ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

# ឈ្មោះសប្បុរសប្រគេនសម្ភារៈ មានត្រំពុងទ័រជាដើម ក្នុងកិច្ចការខាងធម្មទាន

❋ឧបាសិកា ហម យិម

ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ

ឧបាសក បួ ស៊ីផូ ឧបាសិកា ថៃ ស៊ីវន ព្រមទាំងបុត្រ

ឧបាសិកា បួ ចន្ថា និងស្វាមី ព្រមទាំងបុត្រ

កញ្ញា បួ ដាវី កញ្ញា អ៊ឹង មុយហៀក

❋លោកម្ចាស់ សោម ហួន

លោកគ្រូធម្មាចារ្យ អឿ សៅ ( ទក្ខប្បញ្ញោ )

ឧបាសក ប៊ូ ហោនាង ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា

ឧបាសក យ៉ឹម សំណាង ឧបាសិកា យ៉ឹម ច័ន្ទថូ(LAURA) +បុត្រធីតា

ឧបាសិកា លីប៉ុលីន ស៊ីមប៉ូ កូនក្មួយ ប៊ុន ឡុង,សេង ឈិនដានេត

លោកអាចារ្យ ផាត សារឿយ ឧបាសិកា វ៉ាត់ អម +បុត្រធីតា

ឧបាសក សៅ ហ៊ាន ឧបាសិកា មាស មុនីកា +បុត្រធីតា

ឧបាសក សួស ចាន់ធី ឧបាសិកា ឡុង សេង +បុត្រធីតា

ឧបាសក ម៉ៅ វង្ស ឧបាសិកា ធាន់ កាន់ជួន +បុត្រធីតា

ឧបាសក ម៉ៅ ផុន+សាបូរ៉ាក់ សុខ( SABOREAK SOK )

ឧបាសក យក់ ស៊ីម៉ូរ៉ា ឧបាសិកា តាន់ វ៉ាណា

ឧបាសក អ៊ុំង រិទ្ធី ឧបាសិកា ជូធារី

ឧបាសក មាស សារ៉េត

ឧបាសក លឹម ស៊ាង

ឧបាសក ឈុន គឹមអេង

❋ឧបាសក ឈុំ គឹម គឹមហោ ឧបាសិកា គួ ប៊ុនគាង

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ

ឧបាសក សារុន សេងហួរ ឧបាសិកា ឈុំ សុរីណែត

ឧបាសក ឈុំ សុរិណា (ហៅប៊ុន ឃីម) ឧបាសិកា ណៃ គឹមហុង

ឧបាសក ឈុំ សុបូរី ឧបាសិកា កើត កុលាប

❋ឧបាសិកា ច័ន្ទ បុប្ផាណា

ឧបាសក ស្ងួន សុធីរ

ឧបាសិកា ស្ងួន កល្យាណ

ឧបាសិកា ស្ងួន ចរណៃ

ឧបាសិកា ស្ងួន កញ្ញារ័ត្ន

❋ឧបាសិកា ម៉ក់ នាង ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមថៃ និងភរិយា ព្រមទាំងកូនចៅ

ឧបាសក តាំង គឹមលន់ និងភរិយា ព្រមទាំងកូនចៅ

ឧបាសិកា តាំង លាងនិម និងស្វាមី ព្រមទាំងកូនចៅ

❋ពុទ្ធសាសនបណ្ឌិត្យ អ្នកគ្រូ ម៉ម សុខហេង+ពុទ្ធបរិស័ទ+សៀមរាប

ឧបាសក រស់ សុខ ឧបាសិកា សោម ផាន

ឧបាសិកា នួង ឈុំ សោភ័ណ រស្មី

ឧបាសក ជោគ ឌី ឧបាសិកា ដុះ ចំណាន

ឧបាសិកា វិញ ពូន

❋ឧបាសក ឡាំ ធៀន ឧបាសិកា ស៊ីន ចន្ថា

ឧបាសក លឹម សេងយូ ឧបាសិកា ឡាំ ចាន់សុភី

ឧបាសក ឡាំ ចាន់ណា ឧបាសិកា ទុច ចាន់សាក់គ្រីយ៉ា

ឧបាសក ឡាំ ដាវណ្ណ ឧបាសិកា ឡាំ ចាន់វ៉ារី

❋ឧបាសក ជុំ លាង ឧបាសិកា ចៀម អ៊ូន ព្រមទាំងបុត្រ

ញោម ឥម្មន្ទីនិងជូ ញោម ហាន ញោម រ៉ែន ញោម ភ័ណ្ឌ ញោម

សុមនា ញោម ជោត ញោម មាស សុភា ញោម ឡៃ លី កញ្ញា

នា ញោម ធាង ញោម ធីង ឡេង ញោម អៀម ញោម ភួង

ញោម អុំភា ញោម សុភា ញោម វល័ក្ខ ញោម ធាលី លីណា

ញោម ថាក ញោម ផារិន ញោម ឈឿន ញោម ឡាង ញោម

ស៊ុន ញោម ភាព សារឿន ញោម ហ៊ិន ញោម ប៊ូ សៀកលីវ

ញោម យក់ វ៉ាន់ថា ។

❋ឧបាសិកា អ៊ុន ខាត់ណា ឧបាសិកា អ៊ុន ញ៉ាណា ឧបាសក អ៊ុន សេរី

លោក ដែង រស្មី និងអ្នកស្រី ជុង កុយយ៉ា ព្រមទាំងបុត្រ

❋ឧបាសក អ៊ុីង ហេ្គចឡេង ឧបាសិកា តាំង ប៉ោជីង ព្រមទាំងបុត្រ

លោក ឆៃ ហេង អ្នកស្រី អ៊ុីង ស៊ីវគៀង ព្រមទាំងបុត្រ

លោក ភួ ពុយ អ្នកស្រី អ៊ុីង ណាងពិន ព្រមទាំងបុត្រ

លោក អ៊ុីង វណ្ណម៉ៅ អ្នកស្រី ហេង ហ៊ុយទៀង ព្រមទាំងបុត្រ

លោក ប៉ី ទី អ្នកស្រី តាំង ប៉ោគិម ព្រមទាំងបុត្រ

ឧបាសិកា ជា នាង និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា ង៉ែត យូអេង ព្រមទាំងបុត្រ

ឧបាសិកា គង់ ង៉ោ និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ច័ន្ទនី និងស្វាមី ព្រមទាំងបុត្រ

❋ឧបាសិកា សាម៉ុល គឹមធន និងអ្នកម្តាយ

ឧបាសិកា គី វណ្ណហាក់ ព្រមទាំងបុត្រ

លោក សេង យុវនាថ ឧបាសិកា គុជ ឡាំងអេង

ឧបាសិកា ឈន សុភនី ឧបាសក ជីវ និងភរិយា

ឧបាសក សុខ សំ និងភរិយា ព្រមទាំងបុត្រ

ឧបាសក នុត កុសល និងភរិយា ព្រមទាំងបុត្រ

ឧបាសិកា អៀន ភី + អ៊ុំ សុភាព + ឈិត ស្រស់ + សឹម ឡាយ

ញោម ហ៊ុ ជាង + ជាមុយហាង + គុយ លឹម + សេង មុយនី

ញោម ចៅ ជីវ ស៊ុយលៀប+ប៉ែ អេង+គឹម ធី+ខៀវ វ៉ន+ គឹម

ញោម នៀង+យាយ ធឹង+គួង ភាង+សើន គា+សៀង+គឹម អាង

ញោម សេង ចេង+ផាន់ វ៉ាន់+យាយ រុ+ឡាំម៉ាលី+ជាន សុផាត

យាយ ម៉ៅ + ពៅ + ឈួន+ ក. កាវ៉ាឡែន+ ហ៊ុង+ ប៉ែ ង៉ា+ រី វុត្ថ

ញោមអ្នកគ្រូ វ៉ាន់ + យុវសិស្ស អ៊ុំ រតនា + សាមណោរ អ៊ុំ វីរៈ

ញោមប៉ែ ង៉ាថូគោល+អ្នកស្រី លេង យ៉ុង+តី លី+នាង ឈៀត

ញោម ហ៊ឹង+នាង មឿន+អូន ប៉ុច+ ឡាត វ៉ាន់យិន+ ម៉ម សុខហេង

ញោម គឹម ឡេង+ តាំង វេន+ យុន+ យាយ ធុច + យាយ យន
ញោម ហ៊ាន ស៊ឹម ញោម អឿន ភី+វ៉ាន់ ស៊ុនឡាយ+ផល្លី+សវាមី
ញោម ឡុង សាវី+ជា សុខហ៊ាង+គុយ លឹម+សេង ទូច+ស៊ីវ ទី
ញោម ណោ ហ្គេចណៃ+វ៉ាន់ សុផានី+សា វឿន+សំ គី+ចាន់ ណាក់
ញោម ធាក់+យឿត និងស្វាមី+ហួត អេង+អាវ សុវណ្ណី+ណា ស៊ី
ញោម យាយ នៅ+ឈុន គាវ+ យាយ ឌី+ សំ វ៉ាន់នី+ គឹម អ៊ី
ញោម អៀប សាន្ទួន+ យាយ ហឿន+យាយ ឡាំ+កេន សេងមុំ
ស ខាន់ថង+ស៊ី ណាត+យឿន+ចាន់ នី+ផន សារ៉ែន+កោ ហុង ។

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

លោកម្ចាស់ សោម ហួន
លោកគ្រូធម្មបណ្ឌិត ( ទក្ខប្បញ្ញោ ) អឿ សៅ

| | |
|---|---|
| ឧបាសិកា ធឹក ស្រ៊ន | ព្រមទាំងកូនប្រុស អ៊ឹង រិទ្ធី និងភរិយា |
| ឧបាសក ប៊ូហោ នាង | ឧបាសិកា អ៊ឹង រិទ្ធារី ព្រមទាំងបុត្រធីតា |
| ឧបាសក យេម សំណាង | ឧបាសិកា យេម ឡក់ ព្រមទាំងបុត្រ |
| ឧបាសក សៅ ហ៊ាន | ឧបាសិកា មាស ម៉ូនីកា ព្រមទាំងបុត្រ |
| ឧបាសក ឈៀង សាវឿន | ឧបាសិកា ឈុំ ធដា ព្រមទាំងបុត្រធីតា |
| ឧបាសក ម៉ៅ វង្ស | ឧបាសិកា ធាន់ កាន់ជួង ព្រមទាំងបុត្រ |

ឧបាសក និន ហាក់ ឧបាសិកា លុយ ចាន់ថន ព្រមទាំងបុត្រ

ឧបាសិកា មុី ចាន់រ៉ាវី ព្រមទាំងបុត្រធីតា

ឧបាសិកា យ៉ក់ ស៊ីមូរ៉ា ព្រមទាំងបុត្រ

ឧបាសិកា វ៉ាន់ចាន់ ព្រមទាំងបុត្រធីតា

ឧបាសិកា ខៀវ ណាត ព្រមទាំងបុត្រធីតា

## នាមពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិកមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឆាយ អ៊ីវស៊ាង ឧបាសិកា ហុង គីមសែ កូន+ចៅ

ឧបាសិកា យូ ស៊ាងនទ្ធលី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅអូស្ត្រាលីមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ប៊ុន ហេង ឧបាសិកា ជុំ សុខុម

ឧបាសិកា ហេង ស្រីជា ឧបាសិកា ហេង ស្រីចន្ទ

ឧបាសិកា ហេង គន្ធា ឧបាសក ហេង សុកត្រ័

## នាមពុទ្ធបរិស័ទនៅខេត្តបាត់ដំបងមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ឈុំ គីមហោ ឧបាសិកា គួ ប៊ុនគាង ព្រមទាំងកូនចៅ

ឧបាសក សោម សាខន ឧបាសិកា ឈុំ គីមហួយ ព្រមទាំងកូន
ឧបាសក អ៊ឹង ហ៊្គិចឡេង ឧបាសិកា តាំង ប៉េងជីង ព្រមទាំងកូនចៅ
ឧបាសក វៀម ឈើន ឧបាសិកា ប៊ូ ម៉ុន ព្រមទាំងកូនចៅ
ឧបាសក ញ៉ែម មឿន ឧបាសិកា វៀម ថុល ព្រមទាំងកូនចៅ
ឧបាសក អ៊ឹង ប៊ុនហួរ ឧបាសិកា បួ ម៉ាឡា ព្រមទាំងកូនចៅ
ឧបាសក នាង ក៉ា ឧបាសិកា តែម ធារីម ព្រមទាំងកូនចៅ
ឧបាសក សៅ ស៊ុទ្ធា ឧបាសិកា ប៊ុន មុំ ព្រមទាំងកូនចៅ
ឧបាសក ណូ ស្វែង ឧបាសិកា សោម គឹមលួន ព្រមទាំងកូនចៅ
ឧបាសិកា និន យ៉ុន ឧបាសិកា សួស សុខា ព្រមទាំងកូនចៅ
ឧបាសិកា សោម គឹមលឿម និងស្វាមី ព្រមទាំងកូនចៅ
ឧបាសិកា គឹម ធរី និងស្វាមី ព្រមទាំងកូនចៅ
ឧបាសិកា ទាវ គឹមយក់ ឧបាសិកា អ៊ុម គឹមជីវ
ឧបាសិកា គី វណ្ណហាក់ ឧបាសិកា ឡាំ ម៉ាលី
ឧបាសិកា ហួត អេង ឧបាសិកា ឡោ សាយហ៊្គិច
ឧបាសិកា ង៉ែត យូអេង ព្រមទាំងកូនក្មួយ
ឧបាសិកា ហោ កាព ព្រមទាំងកូនក្មួយ
ឧបាសិកា អ៊ុក នៅ ព្រមទាំងបុត្រ
ឧបាសិកា សឿង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទនៅស្ទឹងមានជ័យភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសិកា ឆេង ស៊ីម ព្រមទាំងបុត្រ ធីតា និងចៅ

លោក លី ហុង អ្នកស្រី ជាណារី ព្រមទាំងបុត្រ ធីតា

លោក ផូ ចាន់ថន អ្នកស្រី ជា ណារី ព្រមទាំងបុត្រ ធីតា

លោក លីម ចាន់ឌី អ្នកស្រី ទេព ចិន្តា ព្រមទាំងបុត្រ ធីតា

កញ្ញា ហុង លីដា

លោក ហុង សុវណ្ណតារា អ្នកស្រី លីម ចាន់មុនីរ័ត្ន ព្រមទាំងបុត្រ

ឧបាសក ហុង សុវណ្ណារិទ្ធ

ឧបាសក ហុង សុវណ្ណារ៉េត

លោក ហុង ប៊ុនឡុង

ឧបាសក ហ៊ុន ហេងគង់ ឧបាសិកា ទូច សារុន ព្រមទាំងកូនចៅ

ឧបាសិកា ធុយ ឈីវអួន ព្រមទាំងកូនចៅ

ឧបាសក ប៉ែម យ៉ន ឧបាសិកា យ៉ង់ ទូច ព្រមទាំងកូនចៅ

ឧបាសក មិន ម៉ាង ឧបាសិកា ឈិន គីមហ៊ាន ព្រមទាំងកូនចៅ

ឧបាសិកា ជា សុផល ព្រមទាំងកូនចៅ

ឧបាសិកា មៀច យ៉ន ព្រមទាំងកូនចៅ

ឧបាសិកា មុំ សុន ព្រមទាំងកូនចៅ

លោក លន់ វ៉ាន់ថា អ្នកស្រី មុំ ដាន់ ព្រមទាំងបុត្រ ធីតា

លោក ចាប សោភ័ត អ្នកស្រី មុំ ដា ព្រមទាំងបុត្រ ធីតា

ឧបាសិកា ប៉ោ យេកលៀង ព្រមទាំងបុត្រ ធីតា និងចៅ

លោក រស់ ប៊ុនឡេង អ្នកស្រី ឡេង ស៊ីនី ព្រមទាំងបុត្រ ធីតា

ឧបាសិកា ឈួន សុ ព្រមទាំងកូនចៅ

ឧបាសិកា ថ្វាង តាំងគៀន ព្រមទាំងកូនចៅ

ឧបាសិកា ប៉ែន នាង ព្រមទាំងកូនចៅ

ឧបាសិកា អៀង នឹម និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ដារ៉ុង ព្រមទាំងកូនចៅ

ឧបាសិកា គឹម សេង ព្រមទាំងកូនចៅ

ឧបាសិកា ហួយ ជន ព្រមទាំងកូនចៅ

ឧបាសិកា រ័ត្ន សុផល ព្រមទាំងកូនចៅ

អ្នកស្រី ជុន បូណ៌ិមី និងស្វាមី ព្រមទាំងបុត្រ

ឧបាសិកា ជា ព្រមទាំងកូនចៅ

ឧបាសិកា គឹម អាន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ស៊ីយន ព្រមទាំងកូនចៅ

លោក កេត ចាន់តារា

លោក កេត សំបូរ និងកុមារី សុជាតា

ឧបាសិកា ជា រួចទៀង ព្រមទាំងកូនចៅ

ឧបាសក ជី សុខអៀម ឧបាសិកា តាំង ស៊ូអេង ព្រមទាំងកូនចៅ

ឧបាសិកា តាំង ស៊ូហៀង ព្រមទាំងកូនចៅ

ឧបាសិកា ជី ញ៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ខៀវ សុធី ហៅ អ៊ំម៉ៅ ព្រមទាំងកូនចៅ

ឧបាសិកា ទូច ព្រមទាំងកូនចៅ

ឧបាសក ឡាយ ឧបាសិកា លន់ ព្រមទាំងកូនចៅ

ឧបាសិកា ជាវ ហ៊ិន ព្រមទាំងកូនចៅ

ឧបាសិកា មិល មម ព្រមទាំងកូនចៅ

ឧបាសក រស់ ស្រេង ឧបាសិកា ឡា ហ៊ុយឡេង ព្រមទាំងកូនចៅ

ឧបាសិកា ឡា ស៊ីវឡេង ព្រមទាំងកូនចៅ

ឧបាសិកា គី ប៊ួយ ព្រមទាំងកូនចៅ

លោក យឹម សារ៉ាវិទ្ធ អ្នកស្រី រស់ ចិន្តា ព្រមទាំងបុត្រ

កុមារា យាន ពិសិដ្ឋ

ឧបាសិកា យន សាក ព្រមទាំងកូនចៅ

ឧបាសិកា ហោ យិចឡាំង ព្រមទាំងកូនចៅ

ឧបាសិកា ហ៊ិន ចាន់ថា ព្រមទាំងកូនចៅ

ឧបាសិកា ជី ជុន ព្រមទាំងកូនចៅ

ឧបាសិកា ស៊ិន ឡាច ព្រមទាំងកូនចៅ

ឧបាសក ប៊ុន ប៊ួន ឧបាសិកា យុត សួរ ព្រមទាំងកូនចៅ

លោក ផាន សុបិន អ្នកស្រី សំ សុវណ្ណមល្លិកា ព្រមទាំងបុត្រ

បងស្រី ណៅ សុភី និងប្អូនស្រី ណៅ សុផល

ឧបាសិកា ឈឹន សុន ព្រមទាំងកូនចៅ

លោក ម៉ាន់ រិទ្ធី អ្នកស្រី អួន សារ៉េត ព្រមទាំងបុត្រ

លោក ឱម ឡូត អ្នកស្រី ស៊ុំ ស្រីពៅ ព្រមទាំងបុត្រ

លោក ម៉ាន់ សារឿន អ្នកស្រី ម៉ម សុធា ព្រមទាំងបុត្រ

លោក ស៊ឹម សារ៉ាន់ អ្នកស្រី លី សុខរ៉េត ព្រមទាំងបុត្រ

ឧបាសក ទិត្យ លី ឧបាសិកា ហេងវណ្ណា ព្រមទាំងកូនចៅ

ឧបាសិកា ថោង គឹមលន់ ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូ ប៊ុក ព្រមទាំងកូនចៅ

ឧបាសិកា ប៉េ សារ៉ា ឧបាសក ម៉ើ ធារី

ឧបាសិកា ម៉ៅ ណារី ព្រមទាំងកូនចៅ

ឧបាសក ប៉ៃ ស៊ីថា ឧបាសិកា ង៉ួន សាលីន ព្រមទាំងកូនចៅ

ឧបាសិកា ប៊ូច សាមុត ព្រមទាំងកូនចៅ

ឧបាសក សៅ ម៉េង ឧបាសិកា ថោង វង្ស ព្រមទាំងកូនចៅ

ឧបាសិកា ថោង វ៉េត ព្រមទាំងកូនចៅ

ឧបាសិកា សេក ម៉ាន ព្រមទាំងកូនចៅ

ឧបាសិកា ច័ន្ទ សោភ័ណ្ឌ

ឧបាសក ជូ បូរិន ឧបាសិកា ហែម យ៉ានី ព្រមទាំងកូនចៅ

ឧបាសក ឃ្លោក ម៉ាន ឧបាសិកា ផូ ឡា ព្រមទាំងកូនចៅ

ឧបាសក ហាន គង់ ឧបាសិកា តេង លីគាង ព្រមទាំងកូនចៅ

ឧបាសិកា ឱម សុផាត ព្រមទាំងកូនចៅ

ឧបាសិកា ម៉ៅ សុផានី ព្រមទាំងកូនចៅ

លោក លឹម លី អ្នកស្រី ជាវ ប៊ួយ ព្រមទាំងបុត្រ

ឧបាសិកា សោម សូត្រ ព្រមទាំងកូនចៅ

ឧបាសិកា អ៊ុយ សុខុន និងកូន ឈុន ពុធធារី ព្រមទាំងកូនចៅ

## នាមពុទ្ធបរិស័ទនៅភ្នំពេញមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក ហុក តាំងអ៊ន់ ឧបាសិកា ជួន ស៊ីមយន់ ព្រមទាំងកូនចៅ

ឧបាសិកា យិន មួយឡាង ឧបាសិកា យិន មួយហួ ព្រមទាំងកូនចៅ

ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា ព្រមទាំងកូនចៅ

ឧបាសិកា កាំង ប៉ោទៀង និងស្វាមី ព្រមទាំងកូនចៅ

ឧបាសិកា យ៉ា សុខគីម ព្រមទាំងកូនចៅ

ឧបាសិកា តឹក អេងគី ព្រមទាំងកូនចៅ

ឧបាសិកា ទី សុធី +បុត្រ ហែម តុលា

## នាមពុទ្ធបរិស័ទនៅស្រុកថ្មគោលមានសទ្ធាជ្រះថ្លា ជួយឧបត្ថម្ភប្រាក់ប្រចាំខែ

ឧបាសក តាំង ម៉េង ឧបាសិកា លី ហ៊ុយស៊ីម ព្រមទាំងកូនចៅ

ឧបាសក លី ប៊ុនយូរ ឧបាសិកា យ៉ាន ស៊ី ព្រមទាំងកូនចៅ

លោក លី ប៊ុនហាក់ អ្នកស្រី តាំង ស៊ីវទៀង ព្រមទាំងបុត្រ

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈក្នុងការវេរធម្មទាន

១- ឧបាសក ប៉េង តាំងហៃ ឧបាសិកា ហ៊ួ គីមហៀក

| | |
|---|---|
| ២- ឧបាសក ស្រេង ស្រ៊ាង | ឧបាសិកា គិម ចន្ទា |
| ៣- ឧបាសក ឡាយ សុខុម | ឧបាសិកា គី គឹមហាប់ |
| ៤- ឧបាសិកា បូ ម៉ាឡា | ឧបាសក បញ្ញា |
| ៥- ឧបាសិកា ង៉ែង យូអេង | ឧបាសិកា មាស ម៉ូនីកា |
| ៦- ឧបាសក លឹម ខូង | ឧបាសិកា កែវ អុន |
| ៧- ឧបាសិកា កែវ កល្យាណ | ឧបាសិកា ឡឹក ពេញចិត្ត |
| ៨- ឧបាសិកា ស៊ីន ចន្ទា | លោក ឡាំ ដាវណ្ណ |
| ៩- ឧបាសិកា គួ ប៊ុនគាង | ឧបាសិកា ឈុំ គីមហួយ |
| ១០- ឧបាសិកា នេត្រ នរិន្ទ | ឧបាសិកា តាំង ប៉ោងជីង |
| ១១-ឧបាសិកា ឱម លក្ខណា | ឧបាសិកា ហេង ច័ន្ទបុញ្ញវន្តី |
| ១២-ឧបាសិកា គី យក់បួយ | ឧបាសិកា ឈុន ណាត |
| ១៣-ឧបាសិកា អ៊ុឹង រិទ្ធារី | ឧបាសិកា សៀក ឆាយគីម |
| ១៤-ឧបាសិកា វៀម ថុល | ឧបាសិកា ម៉ៅ នី |
| ១៥-ឧបាសិកា សន ឈៀត | ឧបាសក ឡាន សុខុម |
| ១៦-ឧបាសិកា គី វណ្ណហាក់ | ឧបាសិកា ប៉ាន ណាម |
| ១៧-ឧបាសិកា សួន កល្យាណ | ឧបាសិកា ភួង ភក្តី |
| ១៨-ឧបាសក អ៊ុឹង វ៉ៃយ៉ា | ឧបាសក កុយ សាមន |
| ១៩-ឧបាសក ហុង សុវណ្ណារិទ្ធ | ឧបាសក ហុង សុវណ្ណារ៉េត |

*តម្លៃបោះពុម្ពក្នុង ១ ក្បាល ២$ × ១០០០ ក្បាល = ២០០០ $*

*ខ្ញុំព្រះករុណា អាត្មាភាព មានបំណងនឹងបោះពុម្ពសៀវភៅព្រះធម៌ជាច្រើនមុខ*

ទៀត ដើម្បីចែកជាធម្មទាន បើញាតិញោមពុទ្ធបរិស័ទ មានបំណងចង់ចូលរួមបោះពុម្ព សៀវភៅជាធម្មទាននោះសូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទនេះ ០៧៧ ៦៦ ៦៦ ៣៨, ០៨៨៨ ៧៧ ៩៩ ៦៦, ០១២ ៣០៥ ៧៦៦ ចំពោះសៀវភៅដែលត្រូវបោះពុម្ពនោះ ដូចមានខាងក្រោមនេះ គឺ

-**ជីវប្រវត្តិពុទ្ធឧបាសិកា** មាន ៤ ភាគ ដែលជាភាគបញ្ចប់ ហើយសព្វថ្ងៃនេះ ក៏បានធ្វើចប់រួចអស់ហើយដែរ ទាំង ៤ ភាគ នៅតែមានការបោះពុម្ពជាបន្តបន្ទាប់ ទៀត តែប៉ុណ្ណោះ ។

-**វចនានុក្រមព្រះអភិធម្ម ៧ គម្ពីរ** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរ ហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៨៣៣ ទំព័រ ។

-**គម្ពីរអភិធម្មត្ថសង្គហៈ និង វិភាវិនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរ ហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៦៥០ ទំព័រជាង ។

-**អភិធម្មត្ថសង្គហៈ និង បរមត្ថទីបនីដីកា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរ ហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៩៨៩ ទំព័រជាង ។

-**គម្ពីរអភិធម្មាវតា** សព្វថ្ងៃនេះបានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥៩៧ ទំព័រ ។

-**មិលិន្ទបញ្ហា** សព្វថ្ងៃនេះ បានធ្វើសម្រេចជាស្ថាពរហើយ គឺវាយកុំព្យូទ័ររួចជាស្រេច ដែលមានកម្រាស់រហូតទៅដល់ ៥០០ ទំព័រ ។

-**ខ្ញុំព្រះករុណា អាត្មាភាព** មានបំណងនឹងរាបចំធ្វើ **គម្ពីរព្រះត្រៃបិដក** និង**គម្ពីរព្រះអដ្ឋកថា** បញ្ចូលជាមួយគ្នា ដោយដាក់ព្រះត្រៃបិដកហើយ ដាក់ព្រះអដ្ឋកថាពីខាង

ក្រោមព្រះត្រៃបិដក ក្នុងការបញ្ចូលគម្ពីរព្រះត្រៃបិដក និងគម្ពីរព្រះអដ្ឋកថាជាមួយគ្នានោះព្រះត្រៃបិដកយកតាមបិដកខ្មែរយើង ដែលមាន ១១០ ក្បាល ។

-ព្រះត្រៃបិដកខ្មែរយើងដែលមាន ១១០ ក្បាល បានវាយ កុំព្យូទ័រចប់ហើយ ( ០១.០៥.២០១០, ២៧.០៣.២០១១ ) ។

-ការដាក់ព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ ដែលធ្វើសម្រេចជាស្ថាពរនោះ មានដូចខាងក្រោមនេះ គឺ

-គម្ពីរវិន័យបិដក បានធ្វើរួចជាស្រេចហើយ មានចំនួន ១៤ ភាគ

-គម្ពីរទីឃនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៦ ភាគ

-គម្ពីរមជ្ឈិមនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ៩ ភាគ

-គម្ពីរសំយុត្តនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១១ ភាគ

-គម្ពីរអង្គុត្តរនិកាយ បានធ្វើរួចជាស្រេចហើយ មានចំនួន ១៣ ភាគ

-គម្ពីរខុទ្ទកនិកាយ ប្រែបាន ៣៧ ភាគហើយ

សរុបការប្រែព្រះត្រៃបិដក និងអដ្ឋកថាបញ្ចូលជាមួយគ្នានោះ សព្វថ្ងៃនេះបានចំនួន ៩០ ក្បាលជាងហើយ ។

# សៀវភៅដែលប្រមូលរៀបរៀង និងបោះពុម្ពហើយដោយ
# ខ្ញុំព្រះករុណា អាត្មាភាព
# ✍ យង់ សុផាត ✍

-ជីវប្រវត្តិព្រះអសីតិមហាសាវក មាន ៨ ភាគ ពីភាគ ១ ដល់ភាគ ៨

-ជីវប្រវត្តិព្រះអសីតិមហាសាវក **មាន ៤ ភាគ** ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា មាន ៤ ភាគ ពីភាគ ១ ដល់ភាគ ៤

-ជីវប្រវត្តិព្រះពុទ្ធសាវិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសក មាន ៥ ភាគ ពីភាគ ១ ដល់ភាគ ៥

-ជីវប្រវត្តិព្រះពុទ្ធឧបាសក **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា **មាន ២ ភាគ** ពីភាគ ១ ដល់ភាគ ២

-រឿងរ៉ាវដែលទាក់ទងនឹងពុទ្ធស្ថាន **មាន ៥ ភាគ** ពីភាគ ១ ដល់ភាគ ៥

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សីលនិទ្ទេស មាន ១ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា សមាធិនិទ្ទេស មាន ៤ ភាគ

-វិសុទ្ធិមគ្គ និង បរមត្ថមញ្ជូសាមហាដីកា បញ្ញានិទ្ទេស មាន ៣ ភាគ

-ជីវប្រវត្តិព្រះពុទ្ធឧបាសិកា ភាគ ១-២

-ធម៌សូធ្យនមស្ការបែបសម័យទំនើប

-គម្ពីរសារត្ថសង្គហៈ ភាគ ១

-គម្ពីរមហាសតិប្បដ្ឋានភាវនា

-ពុទ្ធប្បវត្តិ

សូមអនុមោទនាធម្មទាន !!!

សីល សមាធិ បញ្ញា

មហាគមជម្ពូទានអរិយវង្សយស់សុជាត